**ត្រីមាសទី១**

# **កណ្ឌគម្ពីរទំនុកតម្កើង**

The Book of Psalms

មករា កុម្ភៈ មីនា

២០២៤

អមដោយអំណានសម្រាប់លើកប្រាក់តង្វាយ១០ហូត១

និងតង្វាយសទ្ធា

នៅបន្ទាប់ពីមេរៀនទី១៣

សម្រាប់អ្នកអានភាសាអង់គ្លេស សូមចូលមើលគេហទំព័រខាងក្រោមនេះ

https://absg.adventist.org => Easy Reading Edition

# បុព្វកថា

តាងនាមឲ្យនាយកដ្ឋានសប្បាតហ៍ស្គូល នៃបេសកកម្មអាត់វេនទីស្ទកម្ពុជា យើងខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមជំនុំអាត់វេនទីស្ទទាំងអស់ ទាំងក្នុងនិងក្រៅប្រទេស ដែលបានជួយឧបត្ថម្ភគាំទ្រឲ្យមានការបោះពុម្ពសៀវភៅសប្បាតហ៍ស្គូល រៀងរាល់ត្រីមាសកន្លងមកនេះ។ ការគាំទ្រនេះធ្វើឲ្យសៀវភៅសប្បាតហ៍ស្គូល កាន់តែដើរតួយ៉ាងសំខាន់នៅក្នុងការជួយទ្រទ្រង់ជីវិតខាងព្រលឹងវិញ្ញាណជារៀងរាល់ថ្ងៃរបស់អស់លោកអ្នកបងប្អូនរួមជំនឿគ្រប់គ្នា។

នាយកដ្ឋានសប្បាតហ៍ស្គូលក៏សូមថ្លែងអំណរគុណដល់លោកគ្រូគង្វាល អ្នកដាំក្រុមជំនុំ លោកគ្រូ អ្នកគ្រូ គ្រប់រូបដែលបានស្ម័គ្រចិត្ត ដឹកនាំសម្របសម្រួល និងបង្រៀនថ្នាក់សប្បាតហ៍ស្គូលនៅតាមតំបន់នីមួយៗ ទូទាំងប្រទេស។

ជាមួយគ្នានេះ នាយកដ្ឋានសប្បាតហ៍ស្គូលសូមលើកទឹកចិត្តដល់ក្រុមជំនុំអាត់វេនទីស្ទទាំងអស់ឲ្យបន្ថែមការចាប់អារម្មណ៍ និងជួយជ្រោមជ្រែងបងប្អូនរួមជំនឿរបស់យើង ឲ្យកាន់តែភ្ញាក់រឭកឡើង ក្នុងការអធិស្ឋាន និងសិក្សាព្រះបន្ទូលព្រះជាមួយគ្នា។

ប្រសិនបើអស់លោកអ្នក បងប្អូន លោកគ្រូ អ្នកគ្រូ មានមតិយោបល់ ឬសំណួរផ្សេងៗ សូមសរសេរផ្ញើមកកាន់នាយកដ្ឋានសប្បាតហ៍ស្គូល តាមរយៈលោកគ្រូគង្វាល ប្រចាំតំបន់ ឬក៏ផ្ញើមកកាន់អាសយដ្ឋានខាងក្រោមនេះ៖

ប៉ាស្ទ័រហេង្ស សុផល (ប្រធាននាយកដ្ឋានសប្បាតហ៍ស្គូល)
ប្រអប់សំបុត្រលេខ ៤៨៨ ភ្នំពេញ
ឬផ្ញើមកកាន់អាសយដ្ឋានអ៊ីម៉ែល៖ horngsophal@adventist.asia
ឬទូរស័ព្ទទាក់ទងផ្ទាល់ មកកាន់លេខ ០១២ ៣២២ ៤១០ / ០៨១ ៣៣៤ ៤៦៥ នៅរៀងរាល់ម៉ោងធ្វើការ។

ចំពោះបងប្អូនដែលមានបំណងទាញយកសប្បាតហ៍ស្គូលនេះឬឯកសារផ្សេងៗសូមចូលទៅកាន់គេហទំព័រ៖ www.camadventist.org

យើងខ្ញុំសូមអធិស្ឋាន ឲ្យអស់លោកអ្នកបងប្អូនរួមជំនឿទាំងអស់បានប្រុងប្រៀបសព្វគ្រប់នឹងទទួលព្រះបន្ទូល និងសិក្សាពិចារណាខព្រះគម្ពីរជារៀងរាល់ថ្ងៃ ជាពិសេស សូមអនុវត្តគោលការណ៍ ៧៧៧ គឺសូមចូលរួមអធិស្ឋានជាមួយក្រុមជំនុំសេវេនដេយអាត់វេនទីស្ទទូទាំងពិភពលោក ៧ថ្ងៃក្នុងមួយសប្តាហ៍ នៅម៉ោង ៧ព្រឹក ឬ៧ល្ងាច ដើម្បីឲ្យបានចម្រើនលូតលាស់ ក្នុងព្រះគុណនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើងរាល់គ្នា។

សូមព្រះជាម្ចាស់ប្រទានពរតាមរយៈសៀវភៅសប្បាតហ៍ស្គូលនេះ។ អាម៉ែន។

នាយកដ្ឋានសប្បាតហ៍ស្គូល

# មាតិកា


| ចំណងជើងមេរៀន | កាលបរិច្ឆេទ | ទំព័រ |
|---|---|---|
| ១. របៀបអានកណ្ឌគម្ពីរទំនុកតម្កើង | ៣០ ធ្នូ - ៥ មករា | ១ |
| ២. កណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងឱ្យចេះអធិស្ឋាន | ៦ - ១២ មករា | ១៣ |
| ៣. ព្រះអម្ចាស់គឺជាស្ដេច | ១៣ - ១៩ មករា | ១៧ |
| ៤. ព្រះបានសង្គ្រោះយើងចេញពីបញ្ហាទាំងអស់របស់យើង | ២០ - ២៦ មករា | ២៥ |
| ៥. ការច្រៀងចម្រៀងថ្វាយព្រះនៅក្នុងទឹកដីនៃសាសន៍ដទៃ | ២៧ - ២ កុម្ភៈ | ៣៣ |
| ៦. ទូលបង្គំនឹងជួយដល់អ្នកក្រីក្រ | ៣ - ៩ កុម្ភៈ | ៤១ |
| ៧. ព្រះគុណ និងសេចក្ដីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះ | ១០ - ១៦ កុម្ភៈ | ៤៩ |
| ៨. របៀបនៃការទទួលបានសេចក្ដីបរិសុទ្ធ | ១៧ - ២៣ កុម្ភៈ | ៥៧ |
| ៩. អ្នកដែលបានចូលមកតាមព្រះនាមរបស់ព្រះអម្ចាស់ | ២៤ កុម្ភៈ - ១ មីនា | ៦៥ |
| ១០. មេរៀនពីអតីតកាល | ២ - ៨ មីនា | ៧៣ |
| ១១. មានសេចក្ដីរំភើបដោយបាននៅជាប់ជាមួយនឹងព្រះអម្ចាស់ | ៩ - ១៥ មីនា | ៨១ |
| ១២. ទូលបង្គំនឹងច្រៀងថ្វាយព្រះអម្ចាស់ | ១៦ - ២២ មីនា | ៨៩ |
| ១៣. ការរង់ចាំព្រះអម្ចាស់ | ២៣ - ២៩ មីនា | ៩៧ |
| ១៤. អំណានសម្រាប់លើកប្រាក់តង្វាយ | (សប្បាតហ៍ទី១៤-២៦) | ១០៥-១១៧ |


---

**កំណត់ចំណាំ៖**

ខគម្ពីរដែលបានប្រើ៖ ភាគច្រើនបំផុតដកស្រង់ពីព្រះគម្ពីរខ្មែរបរិសុទ្ធ។ កន្លែងណាដែលយើងខ្ញុំដកស្រង់ពីព្រះគម្ពីរខ្មែរបច្ចុប្បន្ន យើងខ្ញុំបានដាក់អក្សរកាត់ថា គខប នៅបន្ទាប់ពីឈ្មោះខគម្ពីរដែលដកស្រង់។ ខគម្ពីរណាដែលយើងខ្ញុំដកស្រង់ពីព្រះគម្ពីរអាល់គីតាប់ យើងខ្ញុំបានដាក់អក្សរកាត់ថា អគត ជាសំគាល់។


បោះពុម្ពផ្សាយជាខេមរភាសាដោយនាយកដ្ឋានសប្បាតហ៍ស្កូលនៃបេសកកម្មអាត់វេនទីស្ទកម្ពុជា ក្រោមការឧបត្ថម្ភពីក្រុមជំនុំនៃសហបេសកកម្មប៉ាស៊ីហ្វិក និងស្ថាប័នអាត់វេនទីស្ទ អាស៊ីប៉ែកអាគ្នេយ៍ ដែលហៅកាត់ថា អេ អេស អេ ភី (ASAP)។ គេហទំព័រ៖ www.khmeradventist.net/voicelove.us


## សមាសភាពអ្នករៀបចំសៀវភៅសប្បាតហ៍ស្កូល


**បកប្រែដោយ៖ ប៉ាស្ទ័រ ញាន ចំរើន**
**កែសម្រួលដោយ៖ ប៉ាស្ទ័រ ហង្ស សុផល**
**ជំនួយការអក្ខរាវិរុទ្ធដោយ៖ អ្នកស្រី ប៉ម ចន្ទី**
**រចនាក្រប និងឡេអៅដោយ៖ លោកសៃ គឹមសេង និង លោកថៃន កែវសាង**

ការិយាល័យពិនិត្យនិងកែសម្រួល៖ 12501 Columbia Pike, Silver Spring, MD 20904
Come Visit us at our Web site: http://www.absg.adventist.org

**Principal Contributor**
Dragonslava Santrac

**Editor**
Soraya Homayouni

**Consulting/Contributing Editors**
Margie English
Esther Doss
William Fagal

**Art Directorand Design**
Lars Justinen

**Publication Manager**
Lea Alexander Greve

**Line Drawings**
Jon Gilbertson

**Pacific Press® Coordinator**
Tricia Wegh

**EGW Estate Consultant**
Dwain Esmond

សៀវភៅមគ្គុទេសក៍សិក្សាព្រះគម្ពីរមេរៀនថ្ងៃបរិសុទ្ធ សម្រាប់មនុស្សចាស់នេះ ត្រូវបានរៀបចំឡើង ដោយការិយាល័យមគ្គុទេសក៍សិក្សាព្រះគម្ពីរ សម្រាប់មនុស្សចាស់របស់ស្ថាប័នព្រះវិហារសេវេនដេយអាត់វេនទីស្ទកំពូល (ពិភពលោក)។ ការរៀបចំសៀវភៅមគ្គុទេសក៍នេះ ស្ថិតនៅក្រោមការដឹកនាំទូទៅរបស់គណៈកម្មាធិការបោះពុម្ពផ្សាយមេរៀនថ្ងៃបរិសុទ្ធ ដែលសមាជិកនៃគណៈកម្មាធិការនេះ បម្រើជាអ្នកប្រឹក្សាយោបល់នៃការពិនិត្យ កែសម្រួល។ សៀវភៅមគ្គុទេសក៍ដែលបានបោះពុម្ពនេះ ឆ្លុះបញ្ចាំងការផ្តល់យោបល់របស់គណៈកម្មាធិការនៃការវាយតម្លៃជាសាកល និងបានឯកភាពពីគណៈកម្មាធិការផ្សព្វផ្សាយ មេរៀនថ្ងៃបរិសុទ្ធ ហេតុដូច្នេះសៀវភៅនេះ មិនឆ្លុះបញ្ចាំងពីគំនិត ឬ ទស្សនៈរបស់អ្នកនិពន្ធតែម្នាក់ឯង (ឬច្រើននាក់) នោះឡើយ។

## កម្មវិធីមេរៀនថ្ងៃបរិសុទ្ធសង្ខេបតាមវិទ្យុសំឡេងមេត្រីភាព

សម្រាប់បងប្អូននៅប្រទេសកម្ពុជា សូមអញ្ជើញស្តាប់កម្មវិធីមេរៀនថ្ងៃបរិសុទ្ធសង្ខេបតាមវិទ្យុសំឡេងមេត្រីភាព រៀងរាល់ថ្ងៃព្រហស្បតិ៍ ១ថ្ងៃពីរលើក ព្រឹកពីម៉ោង ៦៖០០ ដល់ម៉ោង ៦៖៣០នាទី ល្ងាចម៉ោង ៨៖០០ ដល់ម៉ោង ៨៖៣០នាទី តាមរលកធាតុអាកាសខ្លី Short Wave (SW) 15 150 KHZ កម្ពស់១៩ម។ លោកអ្នកក៏អាចស្តាប់កម្មវិធីផ្សេងៗទៀត ជាដំណឹងល្អនៃសេចក្តីសង្គ្រោះ ជារៀងរាល់ថ្ងៃទៀតផង តាមពេលវេលាខាងលើ។

សូមស្តាប់តាមប្រព័ន្ធអ៊ិនធើរណិត នៅលើគេហទំព័រ៖ www.awr.org/program/khmsk សូមចុចលើរូប ឬលើសេចក្តីអញ្ជើញ លោកអ្នកនឹងចូលទៅកាន់កម្មវិធីវិទ្យុសំឡេងមេត្រីភាពនៅ AWR វិទ្យុអាត់វេនទីស្ទពិភពលោកទាំងស្រុង។ សូមព្រះប្រទានពរ!

# កណ្ឌគម្ពីរ ទំនុកតម្កើង គឺជាកន្លែង ដែលព្រះ និងរាស្ត្រ របស់ទ្រង់ជួបជុំគ្នា



កណ្ឌគម្ពីរទំនុកតម្កើងគឺជាសំណុំនៃសេចក្តីអធិស្ឋាន និងបទចម្រៀងថ្វាយព្រះ។ សេចក្តីអធិស្ឋាន និងបទចម្រៀងទាំងនេះក៏ដូចជាកំណាព្យផងដែរ។ សេចក្តីអធិស្ឋាន និងបទចម្រៀងទាំងនេះគឺជាកំណាព្យដ៏ពីរោះជាងគេបំផុត។ កំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានពិពណ៌នាអំពីអារម្មណ៍ និងរឿងផ្សេងៗគ្នារបស់មនុស្សលោកដែលមានដូចជា៖ ការសរសើរតម្កើង អំណរ ភាពសោកសៅ និងការឈឺចាប់ជាដើម។ កំណាព្យ និងចម្រៀងទាំងនេះត្រូវបានអាន និងច្រៀង ទាំងបើកចំហ និងមិនបើកចំហ។ តើអ្នកណាខ្លះដែលបានអាន និងសូត្រកំណាព្យ និងចម្រៀងទាំងនេះនោះ? អ្នកដែលអានកំណាព្យទាំងនេះមានដូចជាស្តេច អ្នកនិពន្ធ និងពួកសង្ឃជាដើម រួមទាំងអ្នកមានបាបដែលបានលន់តួអំពើបាបរបស់ពួកគេ និងបានថ្វាយជីវិតរបស់ពួកគេត្រឡប់ទៅឯព្រះផងដែរ។ ហើយមនុស្សលោកដែលដូចជាលោកអ្នក ហើយនិងខ្ញុំនេះ ក៏បានអាន និងច្រៀងចម្រៀង និងកំណាព្យទាំងនេះផងដែរ។ កណ្ឌគម្ពីរទំនុកតម្កើងគឺជាកណ្ឌគម្ពីរនៃសេចក្តីអធិស្ឋាន និងជាសៀវភៅចម្រៀងសម្រាប់រាស្ត្ររបស់ព្រះទាំងអស់ តាំងតែពីសម័យគម្ពីរសញ្ញាចាស់មកម្ល៉េះ។

កណ្ឌគម្ពីរទំនុកតម្កើងបាននិយាយ**មកកាន់**យើង។ ប៉ុន្តែ លើសពីនេះទៅទៀតនោះ កណ្ឌគម្ពីរទំនុក-ដំកើងក៏បាននិយាយ**ជំនួស**យើង និងបាននិយាយ**ជាមួយនឹង**យើងផងដែរ។ ព្រះបានចាក់បង្ហូរព្រះពរមកលើរាស្ត្ររបស់ទ្រង់តាមរយៈកណ្ឌគម្ពីរទំនុកតម្កើង។ កណ្ឌគម្ពីរទំនុកតម្កើងបានផ្តល់សេចក្តីសង្ឃឹមដល់យើង។ ពីព្រោះកំណាព្យនៃកណ្ឌគម្ពីរនេះបានផ្តល់ជីវិតថ្មីនៅក្នុងព្រះអម្ចាស់។ កណ្ឌគម្ពីរទំនុកតម្កើងក៏ជាមគ្គុទេសក៍ដែលបានបង្រៀនឱ្យយើងយល់អំពីខ្លួនយើង ហើយនិងសិរីល្អរបស់ព្រះផងដែរ។ កណ្ឌគម្ពីរទំនុកតម្កើងបានរំដោះយើងចេញពីភាពសោកសៅ និងការឈឺចុកចាប់។ កណ្ឌគម្ពីរទំនុកតម្កើងក៏បានដឹកនាំយើងទៅរកព្រះ និងបានជំរុញឱ្យយើងចង់ថ្វាយជីវិតទាំងស្រុងរបស់យើងទៅឯទ្រង់ផងដែរ។ យើងមិនគួរភ្ញាក់ផ្អើលដោយបានដឹងថា មនុស្សជាច្រើនបានគិតថា កណ្ឌគម្ពីរទំនុកតម្កើងបានពិពណ៌នាអំពីបទពិសោធន៍ និងអារម្មណ៍ផ្ទាល់ខ្លួនរបស់ពួកគេ។ ហេតុដូច្នេះហើយ បានជាមនុស្សជាច្រើនបានយកកំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងមកធ្វើជាសេចក្តីអធិស្ឋានផ្ទាល់របស់ពួកគេ។

លោកម៉ាទីន លូធើរ (Martin Luther) បាននិយាយអំពីកណ្ឌគម្ពីរទំនុកតម្កើងតាមរយៈពាក្យពេចន៍ទាំងនេះថា៖ «តើយើងអាចរកបានពាក្យដ៏ពីរោះរណ្តំដូចជាកណ្ឌគម្ពីរទំនុកតម្កើងនេះនៅឯណាទៅ? កំណាព្យសរសើរតម្កើង និងសេចក្តីថ្លែងអំណរគុណទាំងនេះបានបង្កើនសេចក្តីអំណរនៅក្នុងចិត្តរបស់យើងជាងកំណាព្យ និងពាក្យណាៗទាំងអស់។ នៅក្នុងកំណាព្យទាំងនេះ លោកអ្នកអាចយល់ពីបំណងចិត្តនៃអ្នកនិពន្ធ ដូចជាលោកអ្នកកំពុងតែមើលសួនច្បាររដ៏ស្រស់ស្អាត ឬកំពុងតែមើលនគរស្ថានសួគ៌យ៉ាងច្បោះដែរ។ . . . តើយើងអាចរកបានពាក្យពេចន៍ឱ្យប្រសើរជាងនេះ ដើម្បីបំបាត់ភាពសោកសៅ និងការ

ឈឺចាប់របស់យើងនៅឯណា? នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង លោកអ្នកបានសម្លឹងឃើញបំណងចិត្តរបស់អ្នកនិពន្ធ ដូចជាលោកអ្នកបានសម្លឹងឃើញសេចក្តីស្លាប់មុខទល់នឹងមុខយ៉ាងដូច្នោះដែរ . . . . ដូច្នេះហើយ ការយល់អំពីមូលហេតុដែលនាំឱ្យកណ្ឌគម្ពីរទំនុកតម្កើងជាកណ្ឌគម្ពីរដែលរាស្ត្ររបស់ព្រះចូលចិត្តជាងគេបំផុតនោះ មិនមែនជារឿងងាយស្រួលនោះឡើយ។ មនុស្សនៅគ្រប់ទីកន្លែងអាចស្វែងរកកំណាព្យ ឬចម្រៀងមួយបទនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងមកបំពេញតម្រូវរបស់ពួកគេ? នៅពេលដែលយើងស្វែងរកកំណាព្យដែលយើងត្រូវការ នោះយើងនឹងមានអារម្មណ៍ថា កំណាព្យនោះត្រូវបានសរសេរសម្រាប់យើងវិញ។ គ្មានសៀវភៅណាដែលអាចប្រៀបផ្ទឹមជាមួយនឹងកណ្ឌគម្ពីរទំនុកតម្កើងនេះបានឡើយ។ ហើយក៏គ្មានសៀវភៅណាដែលមានពាក្យពេចន៍ល្អប្រសើរជាងនេះដែរ»។ ដកស្រង់ពី Martin Luther, Martin Luther: Selections From His Writings, editor, John Dillenberger (New York: Anchor Books, 1962), pages 39, 40, adapted។ តើលោកអ្នកចង់ទទួលបានបទពិសោធន៍នៃការផ្លាស់ប្តូរ នៅពេលដែលលោកអ្នកបានអានអំពីកណ្ឌគម្ពីរទំនុកតម្កើងដែរឬទេ? បើសិនជាមែន នោះលោកអ្នកក៏ត្រូវតែច្រៀង និងអធិស្ឋានជាទំនុកចម្រៀង និងកំណាព្យកាព្យនៅក្នុងសម័យព្រះគម្ពីរផងដែរ។ តាំងពីពេលនោះមក រាស្ត្ររបស់ព្រះបានប្រើកំណាព្យ និងបទចម្រៀងនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង ដើម្បីសរសើរតម្កើងព្រះ អធិស្ឋាន លន់តួអំពើបាបរបស់ពួកគេ ហើយនិងទូលអង្វរដល់ព្រះដ៏មានអំណាចបំផុត។ យើងគួរតែសរសើរទ្រង់ ដោយសារតែទ្រង់យុត្តិធម៌នៅក្នុងកិច្ចការគ្រប់យ៉ាងដែលទ្រង់បានធ្វើ។ យើងក៏គួរតែអរព្រះគុណទ្រង់ចំពោះព្រះគុណ និងសេចក្តីស្រឡាញ់របស់ទ្រង់ផងដែរ។ ដូច្នេះ យើងបានដឹងថា យើងត្រូវតែច្រៀង និងអធិស្ឋានជាបទចម្រៀង និងជាកំណាព្យកាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងវិញ។ ប៉ុន្តែ តើយើងចាំបាច់ត្រូវតែរៀនចម្រៀង និងកំណាព្យទាំងនេះដែរឬទេ? និយាយឱ្យខ្លី គឺយើងត្រូវតែរៀនចម្រៀង និងកំណាព្យទាំងនេះ។ ជាដំបូង យើងត្រូវតែយល់ថា កំណាព្យ និងចម្រៀងនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងត្រូវបានសរសេរនៅក្នុងកាលបរិច្ឆេទ និងទីកន្លែងខុសៗគ្នា។ បន្ទាប់មក កំណាព្យ និងបទចម្រៀងទាំងនេះបានបង្រៀនសារ និងមេរៀនអំពីព្រះខុសៗគ្នា។ នៅពេលដែលយើងសិក្សាកណ្ឌគម្ពីរទំនុកតម្កើង នោះយើងប្រាកដជាចង់ជួយឱ្យអ្នកអានកណ្ឌគម្ពីរនេះបានយល់អំពីចម្រៀង និងកំណាព្យរបស់ពួកគាត់ឱ្យកាន់តែប្រសើរឡើង។ បន្ទាប់មក យើងក៏បានចាប់ផ្តើមយល់អំពីចម្រៀង និងកំណាព្យផងដែរ។ ដូច្នេះ យើងបានដឹងថា កំណាព្យ និងចម្រៀងនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងគឺជាសេចក្តីអធិស្ឋាននៃរាស្ត្ររបស់ព្រះ។ តើលោកអ្នកបានដឹងថា ព្រះយេស៊ូវបានអធិស្ឋានដោយប្រើកំណាព្យ និងចម្រៀងទាំងនេះ នៅពេលដែលទ្រង់មានព្រះជន្មរស់នៅលើផែនដីនេះដែរឬទេ? កំណាព្យ និងចម្រៀងនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងក៏បានចែងអំពីព្រះយេស៊ូវផងដែរ។ នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង ព្រះបានបង្ហាញព្រះយេស៊ូវឱ្យយើងបានឃើញ ហើយព្រះក៏បានប្រាប់យើងអំពីទ្រង់ផងដែរ។ នៅពេលដែលយើងសិក្សាកណ្ឌគម្ពីរទំនុកតម្កើង នោះយើងប្រាកដជាចង់ដឹងអំពីកិច្ចការដែលព្រះយេស៊ូវបានធ្វើ កំពុងតែធ្វើ ហើយនិងត្រូវធ្វើសម្រាប់យើង ដោយសារតែព្រះយេស៊ូវគ្រីស្ទ។

កណ្ឌគម្ពីរទំនុកតម្កើងគឺជាបណ្តុំនៃកំណាព្យចំនួន១៥០។ កំណាព្យទាំងនេះបានជួយឱ្យយើងយល់អំពីដំណើរជីវិតខាងឯវិញ្ញាណរបស់យើង។ ដំណើររបស់យើងបានចាប់ផ្តើមឡើងជាមួយនឹងសេចក្តីជំនឿ។ សេចក្តីជំនឿរបស់យើងនឹងបានលូតលាស់ឡើង នៅពេលដែលយើងយល់ថា ព្រះគឺជាស្តេចរបស់យើង។ ផែនដីទាំងមូល និងអ្វីៗគ្រប់យ៉ាងដែលបានកើតឡើង គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទ្រង់ទាំងស្រុង។ ព្រះដ៏មានគ្រប់ព្រះចេស្តារបស់យើងបានប្រទានរង្វាន់ដល់ឥរិយាបថល្អរបស់យើង ដោយសារតែទ្រង់បានដាក់ទោសអំពើបាបរបស់យើង។ ហើយយើងក៏ត្រូវតែចាំសេចក្តីពិតនៃព្រះគម្ពីរនៅត្រង់នេះដែរ នៅពេលដែលយើងជួបនឹងគ្រាលំបាក ហើយយើងបានឈឺចាប់ដោយសារតែជំនឿរបស់យើងផងដែរ។ ខណៈដែលយើងបន្តការសិក្សារបស់យើងនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងនៅត្រីមាសនេះ យើងនឹងក្រឡេកមើលនូវអ្វីដែលបានកើតឡើង នៅពេលដែលអំពើបាប និងមនុស្សអាក្រក់បានវាយប្រហារសេចក្តីជំនឿនៃរាស្ត្ររបស់ព្រះនោះ។ នៅពេលដែលហេតុការណ៍បានកើតឡើង នោះយើងអាចនឹងសួរទៅទ្រង់ថា ហេតុអ្វីបានជាទ្រង់មិនជួយយើង ដោយប្រើកំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងនេះបាន? តើរាស្ត្ររបស់ព្រះអាចច្រៀងចម្រៀងព្រះនៅក្នុងទឹកដី ដែលមានមនុស្សអាក្រក់កំពុងតែជិះជាន់យើងនោះដោយរបៀបណាដែរ?

សេចក្តីសង្ឃឹម និងការអធិស្ឋានរបស់យើងគឺថា កណ្ឌគម្ពីរទំនុកតម្កើងនឹងជួយឆ្លើយសំណួរពិបាកៗទាំងនេះ។ យើងក៏សង្ឃឹមថា ការសិក្សារបស់យើងនឹងជួយឱ្យយើងបានរឹងមាំឡើង នៅក្នុងអំឡុងនៃដំណើរជីវិតរបស់យើងផងដែរ។ ចូរឱ្យយើងបានណាត់ជួបជាមួយនឹងព្រះជាប្រចាំ ដោយចិត្តទល់នឹងចិត្ត តាមរយៈកណ្ឌគម្ពីរទំនុកតម្កើងនេះ រហូតដល់ថ្ងៃដែលយើងបានជួបជាមួយនឹងព្រះយេស៊ូវមុខទល់មុខចុះ។

## មតិស្លាបនាសម្រាប់ការសិក្សា
## មេរៀនថ្ងៃបរិសុទ្ធ

សៀវភៅមេរៀនថ្ងៃបរិសុទ្ធ គឺជាមគ្គទេសក៍សម្រាប់សិក្សាព្រះគម្ពីរ ទូទាំងសាកលលោក របស់ក្រុមជំនុំសេវេនដេយអាត់វេនទីស្ទ។ សៀវភៅនេះមានការរៀបរៀង និងជ្រើសរើសដោយប្រុងប្រយ័ត្នជាទីបំផុតទៅលើអត្ថន័យ និងខ្លឹមសារដែលទាក់ទងទៅនឹងព្រះគម្ពីរបរិសុទ្ធ។ សៀវភៅតូចនេះអាចជាជំនួយដល់អ្នកអានឲ្យយល់ច្បាស់ពីព្រះគម្ពីរ ហើយទាមទារឲ្យអ្នកអានមើលព្រះគម្ពីរ ដោយហ្មត់ចត់ និងខ្ជាប់ខ្ជួនផង។ មេរៀនថ្ងៃបរិសុទ្ធ ប្រៀបដូចជាអាហារប្រចាំថ្ងៃ សម្រាប់ការចម្រើនលូតលាស់ ខាងព្រលឹងវិញ្ញាណរបស់លោកអ្នក។

**មតិខ្លះៗដើម្បីឲ្យលោកអ្នកទទួលផលជាអតិបរមា ពីសៀវភៅមេរៀនថ្ងៃបរិសុទ្ធនេះ៖**

១- លៃលករកពេលសម្រាប់អានសៀវភៅនេះរៀងរាល់ថ្ងៃកុំបីអាក់ខាន ដូចយើងពិសាបាយមិនដែលខានដូច្នោះដែរ។ សូមអធិស្ឋានរាល់ពេលចាប់ផ្តើម និងពេលបញ្ចប់ការសិក្សា។

២- បើសិនជាអាច នៅរសៀលថ្ងៃបរិសុទ្ធគួរអានមេរៀនពេញមួយសប្តាហ៍តែម្តង រួចសឹមអានតាមថ្ងៃនីមួយៗដោយធ្វើកាលវិភាគផង។

៣- ពេលណាអានសូមនឹកទៅដល់ (១) ចំណងជើងសៀវភៅទាំងមូល (២) ចំណងជើងជំពូក និង (៣) ចំណងជើងប្រចាំថ្ងៃ រួចសូមកត់ត្រាចម្លើយទៅនឹងសំណួរប្រសិនបើមាន។ នៅពេលអានចប់ សូមព្យាយាមឆ្លើយទៅនឹងសំណួរនៅថ្ងៃសុក្រ។

៤- សូមអានខចងចាំនៅមុនពេលសិក្សាមេរៀនជារៀងរាល់ថ្ងៃ។ ធ្វើបែបនេះលោកអ្នកនឹងអាចចាំគម្ពីរមួយខក្នុងមួយសប្តាហ៍។

៥- នៅថ្ងៃបរិសុទ្ធ (ថ្ងៃសៅរ៍) គឺជាពេលដែលយើងពិភាក្សា ចូលរួមចែកចាយពីចំណេះដឹងដែលយើងបានសន្សំប្រាំមួយថ្ងៃមកហើយ។ សូមកត់ចំណាំថានៅថ្ងៃបរិសុទ្ធគឺជាពេលពិភាក្សា (ភាគច្រើនមានរយៈពេល ៤៥-៦០នាទី) ដូច្នេះ ពេលវេលានេះមិនមែនជាពេលដែលអ្នកដឹកនាំថ្នាក់មេរៀនថ្ងៃបរិសុទ្ធបង្រៀនតែឯងឡើយ ហើយពេលនោះក៏មិនមែនជាពេលអធិប្បាយដែរ ផ្ទុយទៅវិញ គឺជាពេលដែលសមាជិកចូលរួមទាំងអស់ អាចបញ្ចេញយោបល់ និងចែកចាយការយល់ដឹងតាមរយៈការសិក្សានៅក្នុងសប្តាហ៍នោះ។ បើធ្វើដូច្នេះនោះយើងនឹងមានអំណរ ព្រមទាំងមានព្រះពរនៃការយល់ដឹងអំពីព្រះបន្ទូលទ្រង់។ នៅពេលដែលពេលវេលាចេះតែកន្លងហួសទៅ លោកអ្នកនឹងបានរៀនព្រះគម្ពីរចប់ទាំងមូលដោយមិនដឹងខ្លួន។

សូមព្រះជាម្ចាស់ប្រទានព្រះពរដ៏បរិបូរដល់បងប្អូនទាំងអស់គ្នា!

**គណៈកម្មការរៀបចំសៀវភៅមេរៀនថ្ងៃបរិសុទ្ធជាភាសាខ្មែរ**

# គ្រីស្ទានកិច្ច និងការបរិច្ចាគទ្រព្យសម្បត្តិថ្វាយព្រះ

*គ្រីស្ទានកិច្ចគឺជារបៀបរស់នៅរបស់មនុស្សដែលទទួលជឿព្រះយេស៊ូវគ្រីស្ទថាជាព្រះអម្ចាស់ សុខចិត្តដើរតាមព្រះអង្គ និងធ្វើជាភ្នាក់ងាររបស់ព្រះអង្គក្នុងការចាត់ចែងកិច្ចការនិងទ្រព្យសម្បត្តិរបស់ព្រះអង្គនៅលើផែនដីនេះ។*

នាងខ្ញុំឈ្មោះសូ ស្រឿន អាយុ៥៥ឆ្នាំ។ នាងខ្ញុំរស់នៅក្នុងភូមិព្រីង ឃុំមោងរាវ ក្រុងសួង ខេត្តត្បូងឃ្មុំ។ នាងខ្ញុំគឺជាក្រុមជំនុំនៃព្រះវិហារសួង។ នាងខ្ញុំដាក់តង្វាយ១០ហូត១ ដោយសារតែនាងខ្ញុំចង់ឱ្យតង្វាយទៅដល់កន្លែងណាសេចក្ដីសុខសាន្តទៅដល់កន្លែងនោះដែរ។





នាងខ្ញុំឈ្មោះខៀវ ផល្លា រស់នៅក្នុងភូមិលិច សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ។ នាងខ្ញុំគឺជាក្រុមជំនុំនៃព្រះវិហារសួង។ នាងខ្ញុំបានដាក់តង្វាយ១០ហូត១ ដោយសារតែនាងខ្ញុំចង់ឱ្យមានមនុស្សជឿព្រះយេស៊ូវបន្ថែមទៀតតាមរយៈតង្វាយ១០ហូត១របស់នាងខ្ញុំនេះ។

នាងខ្ញុំឈ្មោះគង់ ឌីម មានអាយុ៧៥ឆ្នាំ។ នាងខ្ញុំរស់នៅក្នុងភូមិលិច សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ។ នាងខ្ញុំគឺជាក្រុមជំនុំនៃព្រះវិហារសួង។ នាងខ្ញុំបានដាក់តង្វាយ១០ហូត១ ដោយសារតែនាងខ្ញុំចង់ឱ្យក្មេងជំនាន់ក្រោយៗបានជឿព្រះដូចជាកូនចៅរបស់នាងខ្ញុំដែរ។



# របៀបអានកណ្ឌគម្ពីរទំនុកតម្កើង



ល្ងាចថ្ងៃបរិសុទ្ធ - ថ្ងៃសៅរ៍ ទី៣០ ខែធ្នូ ឆ្នាំ២០២៤

**អំណានព្រះគម្ពីរសម្រាប់មេរៀនប្រចាំសប្តាហ៍នេះ៖ នេហេមា ១២:៨; ទំនុកតម្កើង ២៥:១-៥; ទំនុកតម្កើង ៣; សាំយូអែលទី២ ២៣:១, ២; ទំនុកតម្កើង ១៦:៨។**

**ខចងចាំ៖ «ក៏មានព្រះបន្ទូលថា នេះហើយជាសេចក្ដីដែលខ្ញុំបានប្រាប់អ្នករាល់គ្នា កាលនៅជាមួយគ្នានៅឡើយ គឺថា ត្រូវតែសំរេចគ្រប់ទាំងសេចក្ដីដែលបានចែងទុកពីខ្ញុំ ទោះក្នុងក្រឹត្យវិន័យលោកម៉ូសេ ក្នុងទំនាយពួកហោរា ឬក្នុងបទទំនុកតម្កើងផង»** (លូកា ២៤:៤៤)។

កណ្ឌគម្ពីរទំនុកតម្កើងគឺជាសំណុំនៃបទចម្រៀង និងសេចក្ដីអធិស្ឋានសម្រាប់ពួកសាសន៍យូដា និងអ្នកគ្រីស្ទាន។ កវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើង បានសរសេរសេចក្ដីអធិស្ឋាន ហើយនិងបទចម្រៀងរបស់ពួកគេថ្វាយដល់ព្រះ។ កវីទាំងនេះបានសរសេរជាភាសាជាតិរបស់ពួកគេ។ ប៉ុន្តែ ព្រះបានប្រទានគំនិតដល់កវីទាំងនេះវិញ។ ដូច្នេះ កណ្ឌគម្ពីរទំនុកតម្កើងមានប្រភពចេញមកពីព្រះ។ ដ្បិតទ្រង់បានមានបន្ទូលមកកាន់រាស្ត្ររបស់ទ្រង់តាមរយៈកំណាព្យនៅក្នុងកណ្ឌគម្ពីរនេះ ដូចជាទ្រង់បានធ្វើនៅក្នុងកណ្ឌគម្ពីរផ្សេងៗទៀតផងដែរ (ពេត្រុសទី២ ១:២១)។ ព្រះយេស៊ូវ និងអ្នកសរសេរគម្ពីរសញ្ញាថ្មីបានប្រើសម្រង់មតិពីកណ្ឌគម្ពីរទំនុកតម្កើងនៅក្នុងការបង្រៀនរបស់ពួកគេ។ ពួកគេបានបង្រៀនថា កំណាព្យទាំងនេះគឺជាផ្នែកមួយនៃព្រះគម្ពីរ ដែលជាព្រះបន្ទូលរបស់ព្រះ (ម៉ាកុស ១២:១០; យ៉ូហាន ១០:៣៤, ៣៥; យ៉ូហាន ១៣:៨)។ កណ្ឌគម្ពីរទំនុកតម្កើងគឺជាផ្នែកមួយនៃព្រះបន្ទូលរបស់ព្រះ ដូចជាកណ្ឌគម្ពីរដទៃទៀតផងដែរ។

កវីផ្សេងៗគ្នាបានសរសេរកណ្ឌគម្ពីរទំនុកតម្កើង នៅក្នុងអំឡុងនៃសម័យគម្ពីរសញ្ញាចាស់។ កវីបានសរសេរកំណាព្យរបស់ពួកគេជាភាសាហេព្រើរ។ កំណាព្យរបស់ពួកគេបានប្រាប់យើងអំពីសម័យកាលរបស់កវីទាំងនេះ។ កណ្ឌគម្ពីរទំនុកតម្កើងក៏សម្រាប់សម័យកាលយើងដែរ។ នៅពេលដែលយើងទទួលយកកណ្ឌគម្ពីរទំនុកតម្កើងទុកជាព្រះបន្ទូលដែលព្រះបានមានបន្ទូលមកកាន់យើង នោះយើងនឹងអាចយល់អំពីសារនៅក្នុងកណ្ឌគម្ពីរនេះជាមិនខាន។ យើងត្រូវតែយកចិត្តទុកដាក់ចំពោះប្រវត្តិសាស្ត្រ ហើយនិងការបង្រៀននៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង។ យើងក៏ត្រូវតែសិក្សាអំពីរបៀបដែលពួកសាសន៍យូដាបានប្រើចម្រៀង ដើម្បីថ្វាយបង្គំផងដែរ។ នៅពេលនោះ យើងនឹងបានយល់កាន់តែប្រសើរឡើងនូវអ្វីដែលព្រះចង់មានបន្ទូលមកកាន់យើងនៅពេលសព្វថ្ងៃនេះជាមិនខាន។

# ចម្រៀងសម្រាប់ការថ្វាយបង្គំព្រះនៅក្នុងគម្ពីរសញ្ញាចាស់

**តើហេតុអ្វីបានជាកណ្ឌគម្ពីរទំនុកតម្កើងត្រូវបានសរសេរឡើងយ៉ាងដូច្នេះ? តើព្រះបានប្រើកណ្ឌគម្ពីរទំនុកតម្កើងនៅពេលណា? សម្រាប់ចម្លើយ សូមអានខគម្ពីរបាក្សត្រទី១ ១៦:៧; នេហេមា ១២:៨; ទំនុកតម្កើង ១៨:១; ទំនុកតម្កើង ៣០:១; ទំនុកតម្កើង ៩២:១; ទំនុកតម្កើង ៩៥:២; ទំនុកតម្កើង ១០៥:២; កូឡូស ៣:១៦ និងយ៉ាកុប ៥:១៣។**

________________________________________________

________________________________________________

កណ្ឌគម្ពីរទំនុកតម្កើងគឺជាសំណុំនៃកំណាព្យ។ កវីផ្សេងៗគ្នាបានសរសេរកណ្ឌគម្ពីរនេះឡើង។ កំណាព្យរបស់ពួកគេក៏ជាចម្រៀង និងជាសេចក្តីអធិស្ឋានដល់ព្រះផងដែរ។ កវីនៃកណ្ឌគម្ពីរទំនុកតម្កើងបានសរសេរកំណាព្យរបស់ពួកគេសម្រាប់ការថ្វាយបង្គំផ្ទាល់ខ្លួន និងសម្រាប់ការថ្វាយបង្គំជាមួយនឹងអ្នកដទៃទៀត។ ពួកសាសន៍អ៊ីស្រាអែលបានសូត្រកំណាព្យទុកជាបទចម្រៀងថ្វាយព្រះនៅក្នុងព្រះវិហាររបស់ពួកគេ។ កវីជាច្រើននាក់បានបញ្ចូលកំណត់ត្រាខ្លីៗទៅក្នុងកំណាព្យ ឬបទចម្រៀងរបស់ពួកគេនោះ។ កំណត់ត្រាបានប្រាប់អ្នកដឹកនាំភ្លេងពីឧបករណ៍ភ្លេងមួយណាដែលពួកគេត្រូវលេង (ទំនុកតម្កើង ៦១:១) ឬប្រាប់ពីសំឡេងលើកដាក់ ដែលពួកគេគួរតែប្រើ នៅពេលដែលពួកគេច្រៀងចម្រៀង (ទំនុកតម្កើង ៩:១)។

ចំណងជើងនៃកណ្ឌគម្ពីរទំនុកតម្កើងជាភាសាហេព្រើរមានឈ្មោះថា «តេហេលីម (tehelim)»។ «តេហេលីម» មានន័យថា «ការសរសើរតម្កើង»។ «តេហេលីម» បានបង្ហាញយើងនូវហេតុផលដ៏សំខាន់មួយដែលនាំឱ្យកណ្ឌគម្ពីរនេះត្រូវបានសរសេរឡើង ដែលហេតុផលនោះគឺជាការសរសើរតម្កើងព្រះ។ ពាក្យ «ទំនុកតម្កើង» របស់យើងមានប្រភពមកពីគម្ពីរសេបធូជីន (Septuagint)។ គម្ពីរសេបធូជីនគឺជាច្បាប់ចម្លងនៃកណ្ឌគម្ពីរសញ្ញាចាស់ ដែលត្រូវបានសរសេរឡើងជាភាសាក្រេក។

កណ្ឌគម្ពីរទំនុកតម្កើងគឺជាផ្នែកដ៏សំខាន់មួយនៃការថ្វាយបង្គំរបស់សាសន៍អ៊ីស្រាអែល។ រាស្ត្ររបស់ព្រះបានប្រើកណ្ឌគម្ពីរនេះ សម្រាប់ពិធីអបអរសាទរនៅក្នុងព្រះវិហារ ពិធីបុណ្យខាងឯសាសនា ក្បួនដង្ហែ និងនៅពេលដែលហឹបសញ្ញារបស់ព្រះបានមកដល់ទីក្រុងយេរូសាឡិមនោះវិញ។ បទគម្ពីរទំនុកតម្កើងជំពូក១២០-១៣៤ គឺជាបទចម្រៀងសម្រាប់ការចូលទៅព្រះវិហារ។ រាស្ត្ររបស់ព្រះបានច្រៀងចម្រៀងទាំងនេះនៅតាមផ្លូវទៅកាន់ទីក្រុងយេរូសាឡិម ដើម្បីប្រារព្ធពិធីបុណ្យធំៗជារៀងរាល់ឆ្នាំ (និក្ខមនំ ២៣:១៤-១៧)។ ពួកបណ្តាជនបានច្រៀងបទគម្ពីរទំនុកតម្កើង ជំពូក១១៣-១១៨ និងបទទំនុកតម្កើង ជំពូក ១៣៦ នៅក្នុងពិធីបុណ្យទាំង៣នោះ។ ពួកគេបានច្រៀងចម្រៀងទាំងនេះនៅក្នុងពិធីបុណ្យចូលខែ (New Moon Festival) ព្រមទាំងច្រៀងនៅពេលដែលពួកសង្ឃឧទ្ទិសព្រះវិហារថ្វាយដល់ព្រះផងដែរ។ ពួកបណ្តាជនបានច្រៀងបទគម្ពីរទំនុកតម្កើង ជំពូក ១១៣ និងជំពូក១១៤ នៅពេលចាប់ផ្តើមបរិភោគអាហារនៃបុណ្យរំលង ហើយច្រៀងបទគម្ពីរទំនុកតម្កើង ជំពូក១១៥-១១៨ បន្ទាប់ពីពួកគេបរិភោគរួច (ម៉ាថាយ ២៦:៣០)។ បុណ្យរំលងតំណាងឱ្យគ្រាមួយ នៅពេលដែលព្រះបាននាំសាសន៍អ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ។ បទគម្ពីរទំនុកតម្កើង ជំពូក ១៤៥-១៥០ គឺជាផ្នែកមួយនៃសេចក្តីអធិស្ឋាននៅពេលព្រឹក ដែលត្រូវបានប្រើសម្រាប់ការថ្វាយបង្គំព្រះនៅក្នុងព្រះវិហារ។ ព្រះយេស៊ូវបានអធិស្ឋានដោយប្រើពាក្យពេចន៍នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក២២ (ម៉ាថាយ ២៧:៤៦)។ កណ្ឌគម្ពីរទំនុកតម្កើងក៏ជាផ្នែកដ៏សំខាន់មួយនៅក្នុងក្រុមជំនុំសញ្ញាថ្មីផងដែរ (កូឡូស ៣:១៦; អេភេសូរ ៥:១៩)។

**តើសព្វថ្ងៃនេះ យើងអាចប្រើកណ្ឌគម្ពីរទំនុកតម្កើងទាំងនៅក្នុងការថ្វាយបង្គំផ្ទាល់ខ្លួន និងនៅក្នុងការថ្វាយបង្គំជាសាធារណៈនោះដោយរបៀបណា?**

# ជួបជាមួយនឹងកវីនៃកណ្ឌគម្ពីរទំនុកតម្កើង

ស្តេចដាវីឌបានសរសេរកំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងច្រើនជាងគេ។ ស្តេចដាវីឌត្រូវបានគេហៅថា «ជាអ្នកតែងទំនុកយ៉ាងពីរោះ» (សាំយូអែលទី២ ២៣:១)។ ស្តេចដាវីឌបានទទួលផ្នែកដ៏សំខាន់មួយនៅក្នុងការជ្រើសរើសចម្រៀងសម្រាប់ការថ្វាយបង្គំនៅក្នុងព្រះវិហារ។ អ្នកសរសេរគម្ពីរសញ្ញាថ្មីក៏បានមានប្រសាសន៍ថា ស្តេចដាវីឌបានសរសេរកំណាព្យជាច្រើននៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងផងដែរ (ម៉ាថាយ ២២:៤៣-៤៥; កិច្ចការ ២:២៥-២៩, ៣៤, ៣៥; កិច្ចការ ៤:២៥; រ៉ូម ១៤:៦-៨)។ តន្ត្រីករនៅក្នុងព្រះវិហារក៏បានសរសេរកំណាព្យមួយចំនួននៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងផងដែរ។ តន្ត្រីករទាំងនេះក៏ជាពួកលេវីដែរ ពោលគឺៈ លោកអេសាភបានសរសេរបទគម្ពីរទំនុកតម្កើង ជំពូក៥០ និងកណ្ឌគម្ពីរទំនុកតម្កើង ជំពូក៧៨-៨៣។ កូនរបស់លោកកូរេបានសរសេរបទគម្ពីរទំនុកតម្កើង ជំពូក៤២, ទំនុកតម្កើង ជំពូក៤៤-៤៧; ទំនុកតម្កើង ជំពូក៤៩, ទំនុកតម្កើង ជំពូក៨៤; ទំនុកតម្កើង ៨៥ និងទំនុកតម្កើង ជំពូក៨៨។ លោកហីម៉ានដែលជាជនជាតិអេសរ៉ាគីតបានសរសេរបទគម្ពីរទំនុកតម្កើង ជំពូក៨៨។ លោកអ៊ីថានដែលជាជនជាតិអេសរ៉ាគីតបានសរសេរបទគម្ពីរទំនុកតម្កើង ជំពូក៨៩។ បន្ទាប់មក ក៏មានកំណាព្យដែលស្តេចសាឡូម៉ូន និងលោកម៉ូសេបានសរសេរផងដែរ។ ស្តេចសាឡូម៉ូនបានសរសេរបទគម្ពីរទំនុកតម្កើង ជំពូក៧២ និងបទគម្ពីរទំនុកតម្កើង ជំពូក១២៧។ រីឯលោកម៉ូសេវិញ គាត់បានសរសេរបទគម្ពីរទំនុកតម្កើង ជំពូក៩០។

**សូមអានខគម្ពីរទំនុកតម្កើង ២៥:១-៥; ទំនុកតម្កើង ៤២:១; ទំនុកតម្កើង ៧៥:១; ទំនុកតម្កើង ៧៧:១; ទំនុកតម្កើង ៨៤:១, ២; ទំនុកតម្កើង ៨៤:១, ២; ទំនុកតម្កើង ៨៩:១។ តើកំណាព្យទាំងនេះបានប្រាប់យើងអំពីកវី និងបទពិសោធន៍របស់យើងយ៉ាងដូចម្តេចដែរ?**

_______________________________________________

_______________________________________________

ព្រះវិញ្ញាណបរិសុទ្ធបានប្រទានគំនិតដល់កវីទាំងនេះ។ ព្រះបានយកទេពកោសល្យរបស់ពួកគេមកបម្រើទ្រង់ និងបម្រើរាស្ត្ររបស់ទ្រង់។ កវីនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងគឺជាមនុស្សដែលមានជំនឿមុតមាំ និងមានសេចក្តីស្រឡាញ់ចំពោះព្រះយ៉ាងជ្រាលជ្រៅ។ ទន្ទឹមគ្នានេះ កវីតែងតែមានអារម្មណ៍ដូចជាយើងដែរ។ ពួកគេមានអារម្មណ៍អស់សង្ឃឹម។ ពួកគេបានប្រយុទ្ធទាស់នឹងការកុហក និងអន្ទាក់របស់សាតាំង ដូចដែលយើងត្រូវធ្វើដូច្នោះដែរ។ ជាការពិតណាស់ កវីបានសរសេរចម្រៀង និងកំណាព្យរបស់ពួកគេតាំងពីយូរណាស់មកហើយ។ ប៉ុន្តែ ពួកគេបានពិពណ៌នាអំពីបទពិសោធន៍ជាច្រើនដូចជាយើងដែរ ដោយសរសេរថាៈ «សូមឲ្យសេចក្តីអធិស្ឋានរបស់ទូលបង្គំបានចូលមកនៅចំពោះទ្រង់ សូមផ្ទៀងព្រះកាណ៌ស្តាប់ពាក្យទូលបង្គំទូលអង្វរផង ដ្បិតព្រលឹងនៃទូលបង្គំមានពេញដោយសេចក្តីវេទនា ជីវិតនៃទូលបង្គំក៏កាន់តែជិតស្ថានឃុំព្រលឹងមនុស្សស្លាប់» (ទំនុកតម្កើង ៨៨:២, ៣)។ តើអ្នកណាខ្លះដែលមិនមានអារម្មណ៍បែបនេះនោះ? ជាការពិតណាស់ មនុស្សម្នាក់នៅក្នុងសម័យយើង អាចនឹងសរសេរសេចក្តីអំពាវនាវនេះ។

កំណាព្យខ្លះនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានថែងអំពីសេចក្តីអំណរ។ កំណាព្យដទៃទៀតបានថែងអំពីគ្រាលំបាក ដោយកវីទាំងនេះបាននិយាយត្រង់ៗអំពីសេចក្តីវេទនារបស់ពួកគេ។ ពួកគេបានទូលសុំជំនួយពីព្រះ ហើយទ្រង់បានសង្គ្រោះពួកគេ។ កវីបានសរសើរតម្កើងព្រះចំពោះសេចក្តីស្រឡាញ់របស់ទ្រង់។ ពួកគេបានសន្យាថា ពួកគេនឹងបម្រើទ្រង់ជារៀងរហូត។ កណ្ឌគម្ពីរទំនុកតម្កើងគឺជាសារអំពីសេចក្តីស្រឡាញ់ សេចក្តីមេត្តា និងសេចក្តីសង្ឃឹម។ កណ្ឌគម្ពីរទំនុកតម្កើងគឺជាសេចក្តីសន្យារបស់ព្រះ ដែលថា ទ្រង់បានលើកលែងទោសឱ្យយើង ហើយទ្រង់ក៏បានប្រទានជីវិតឱ្យយើងផងដែរ។

**កវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើងបានរងនូវការឈឺចាប់ជាច្រើនដូចជាយើងដែរ។ តើគោលគំនិតនេះបានផ្តល់សេចក្តីសង្ឃឹមអ្វីដល់លោកអ្នក?**

## ចម្រៀងសម្រាប់ផ្នែកទាំងអស់នៃជីវិតរបស់យើង

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក៣; ទំនុកតម្កើង ៣៣:១-៣ និងទំនុកតម្កើង ១០៩:៦-១៥។ តើចម្រៀងទាំងនេះបានរៀបរាប់អំពីបទពិសោធន៍មនុស្សលោកអ្វីខ្លះ?**

________________________________________________________________

________________________________________________________________

កណ្ឌគម្ពីរទំនុកតម្កើងមានពេញទៅដោយចម្រៀងអំពីបទពិសោធន៍មនុស្សលោក។ យើងបានឃើញចម្រៀង៦បែប ដែលមានដូចជា៖ ១. **ចម្រៀងសរសើរតម្កើង** បានបង្ហាញពីសិរីល្អរបស់ព្រះ ដោយសារតែទ្រង់គឺជាស្តេចលើអស់ទាំងស្តេច ហើយទ្រង់ក៏បានរក្សាសេចក្តីសន្យារបស់ទ្រង់ផងដែរ។ ២. **ចម្រៀងអរព្រះគុណ** បានបង្ហាញពីការអរព្រះគុណចំពោះព្រះពរជាច្រើនដែលទ្រង់បានប្រទានឱ្យ។ ៣. **ចម្រៀងទួញសោក** គឺជាចម្រៀងស្តីអំពីការឈឺចាប់ និងភាពសោកសៅ។ **ចម្រៀងទួញសោក** ជាច្រើនបទបានបង្ហាញពីសេចក្តីអំពាវនាវសុំឱ្យព្រះសង្គ្រោះរាស្ត្ររបស់ទ្រង់ចេញពីបញ្ហា។ ៤. **ចម្រៀងប្រៀនប្រដៅ** មានពេញទៅដោយសេចក្តីទូន្មានអំពីរបៀបនៃការរស់នៅក្នុងជីវិតមួយដ៏បរិសុទ្ធ។ ៥. **ចម្រៀងរាជ** បានរៀបរាប់អំពីបុគ្គលម្នាក់ដែលព្រះបានជ្រើសតាំងឱ្យធ្វើជាស្តេចនៃសាសន៍អ៊ីស្រាអែល និងជាព្រះអង្គសង្គ្រោះ។ ៦. **ចម្រៀងប្រវត្តិសាស្ត្រ** បានរៀបរាប់អំពីអតីតកាលរបស់សាសន៍អ៊ីស្រាអែល។ ចម្រៀងទាំងនេះបានបង្ហាញយើងអំពីរបៀបដែលព្រះបានរក្សាសេចក្តីសន្យាដែលទ្រង់បានតាំងឡើងជាមួយនឹងរាស្ត្ររបស់ទ្រង់ នៅពេលដែលពួកគេបានបំពានសេចក្តីសន្យាដែលពួកគេបានស្បថជាមួយនឹងទ្រង់។ ចម្រៀងប្រវត្តិសាស្ត្របានបង្រៀនឱ្យកូនចៅអ៊ីស្រាអែលជំនាន់ក្រោយនឹកចាំអំពីអតីតកាល ដើម្បីកុំឱ្យពួកគេធ្វើខុសតាមដូចជាឪពុករបស់ពួកគេ។

កំណាព្យទាំងនេះបានទាក់ទាញចំណាប់អារម្មណ៍របស់យើង។ តើកវីបានប្រើជំនាញនិពន្ធអ្វីខ្លះដើម្បីឱ្យកំណាព្យរបស់ពួកគេមានពេញទៅដោយឥទ្ធិពលនោះ?

**ការផ្គុំពាក្យ**៖ កវីបានផ្គុំពាក្យដោយប្រើអត្ថន័យដដែល តួយ៉ាង៖ «ឱព្រលឹងអញអើយ ចូរសរសើរដល់ព្រះយេហូវ៉ា ហើយគ្រប់ទាំងអស់ដែលរួមនៅក្នុងខ្លួនអញ ចូរសរសើរដល់ព្រះនាមបរិសុទ្ធនៃទ្រង់ដែរ» (ទំនុកតម្កើង ១០៣:១)។ តើលោកអ្នកបានឃើញអត្ថន័យដូចគ្នារវាងពាក្យថា «ព្រលឹងអញ» និង «គ្រប់ទាំងអស់ដែលរួមនៅក្នុងខ្លួនអញ» ដែរឬទេ? កវីបានផ្គុំពាក្យទាំងនេះនៅក្នុងខតែមួយ ដើម្បីជួយឱ្យយើងយល់គោលគំនិតរបស់គាត់កាន់តែប្រសើរឡើង។ មានពេលខ្លះ កវីក៏បានផ្គុំពាក្យខុសៗគ្នា ទៅលើចំណុចតែមួយ។ «ឱព្រះយេហូវ៉ាជាព្រះដ៏ជួយសង្គ្រោះទូលបង្គំអើយ ទូលបង្គំបានអំពាវនាវនៅចំពោះទ្រង់ ទាំងយប់ទាំងថ្ងៃ» (ទំនុកតម្កើង ៨៨:១)។ ពាក្យថា «ថ្ងៃ» និង «យប់» បានបង្ហាញយើងថា កវីបានស្រែកអំពាវនាវរកព្រះគ្រប់ពេលវេលា។

**រូបស័ព្ទ**៖ រូបស័ព្ទបានជួយឱ្យយើងមើលឃើញ ប៉ះពាល់ ធុំក្លិន ឮ ឬភ្លក្សរសជាតិនៃជីវិត។ រូបស័ព្ទទាំងនេះបានជួយឱ្យយើងយល់សារនៅក្នុងកំណាព្យនេះកាន់តែប្រសើរឡើង។ នៅក្នុងខគម្ពីរទំនុកតម្កើង ១៧:៨ កវីបានប្រៀបធៀបព្រះ ហើយនិងការការពារដែលទ្រង់បានផ្តល់ឱ្យយើងនោះទៅជាមេបក្សីដែលបាន «បាំងទូលបង្គំ នៅក្រោមម្លប់ចំអេងស្លាបរបស់ទ្រង់»។

**អត្ថន័យទ្វេដង**៖ មានពេលខ្លះ កវីបានប្រើពាក្យពេចន៍ដែលមើលទៅស្រដៀងគ្នា ប៉ុន្តែ មានអត្ថន័យខុសគ្នា។ នៅក្នុងខគម្ពីរទំនុកតម្កើង ៩៦:៤, ៥ កវីបានប្រើភាសាហេព្រើរ២ពាក្យ ដែលមើលទៅស្រដៀងគ្នា ដោយចែងថា៖ «អេឡូហ៊ីម (elohim)» ដែលមានន័យថា «ព្រះ» និង «អេលីលីម» ដែលមានន័យថា «ព្រះក្លែងក្លាយ» ឬ «រូបសំណាក់»។ កវីបានប្រើពាក្យទាំងនេះ ដើម្បីជួយឱ្យយើងយល់សាររបស់គាត់ដោយថា៖ ព្រះនៃសាសន៍ដទៃដែលនៅជុំវិញសាសន៍អ៊ីស្រាអែលមើលទៅដូចជា «អេឡូហ៊ីម» ឬអាចហៅបានថា ព្រះ។ ប៉ុន្តែ ព្រះទាំងនេះគ្រាន់តែជា «អេលីលីម» ឬ «រូបសំណាក់» ប៉ុណ្ណោះ។

**សេឡា** (Selah)។ កវីបានប្រើពាក្យ «សេឡា»។ ពាក្យនេះបានប្រាប់ឱ្យអ្នកអានឈប់គិតអំពីសារនៅក្នុងកំណាព្យ។ «សេឡា» ក៏បានដាស់អ្នកភ្លេងឱ្យប្តូរបទចម្រៀងផងដែរ។

# សេចក្តីអធិស្ឋានដែលមកពីព្រះ

**សូមអានខគម្ពីរសាំយូអែលទី២ ២៣:១, ២ និងរ៉ូម ៨:២៦, ២៧។ តើខទាំងនេះបានបង្រៀនយើងអំពីសេចក្តីអធិស្ឋានយ៉ាងដូចម្តេចដែរ?**

________________________________________________________________________

________________________________________________________________________

ព្រះបានចារសេចក្តីអធិស្ឋាន និងការសរសើរតម្កើងនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង។ ទន្ទឹមគ្នានេះ សេចក្តីអធិស្ឋាន និងការសរសើរតម្កើងទាំងនេះមានប្រភពមកពីព្រះ។ ពីព្រោះទ្រង់គឺជាអ្នកប្រទានគំនិតដល់កវីទាំងនេះ។

កវីទាំងនេះបាននិយាយជាមួយនឹងព្រះដោយផ្ទាល់។ នៅក្នុងកំណាព្យរបស់ពួកគេ ព្រះគឺជា «បរមក្សត្រ» (ទំនុកតម្កើង ៥:២) និងជា «ព្រះអម្ចាស់» (ទំនុកតម្កើង ៨៤:៣) របស់ពួកគេ។ ពួកគេតែងតែសុំឱ្យព្រះ «ផ្ទៀងព្រះកាណ៌ស្តាប់ពាក្យ» (ទំនុកតម្កើង ៥:១) «ផ្ទៀងព្រះកាណ៌ស្តាប់សំរែក» (ទំនុកតម្កើង ៣៩:១២) «ពិនិត្យមើលសេចក្តីវេទនា និងសេចក្តីនឿយព្រួយ» (ទំនុកតម្កើង ២៥:១៨) របស់ពួកគេ ហើយសុំឱ្យព្រះ «ឆ្លើយ» (ទំនុកតម្កើង ១០២:២) តបនឹងពួកគេ និង «ជួយសង្គ្រោះ» ពួកគេជានិច្ចផងដែរ។ ពាក្យទាំងនេះបានបង្ហាញយើងអំពីបុគ្គលម្នាក់ដែលកំពុងតែអធិស្ឋានទូលទៅព្រះ។

កណ្ឌគម្ពីរទំនុកតម្កើងគឺជាសេចក្តីអធិស្ឋានដ៏ពីរោះ និងមានអំណាច ដោយសារតែកណ្ឌគម្ពីរនេះក៏ជាព្រះគម្ពីរដែលព្រះបន្ទូលរបស់ព្រះនោះដែរ។ លោកប៉ុលបានប្រាប់យើងដំណើរការនៃសេចក្តីអធិស្ឋានយ៉ាងដូច្នេះថា៖ «ព្រះវិញ្ញាណទ្រង់ក៏ជួយសេចក្តីកម្សោយរបស់យើងបែបដូច្នោះដែរ ដ្បិតយើងមិនដឹងជាគួរអធិស្ឋានសូមអ្វីទេ តែព្រះវិញ្ញាណទ្រង់ជួយអង្វរជំនួសយើង ដោយដំងូរដែលរកថ្លែងពុំបានវិញ ប៉ុន្តែ ព្រះអង្គដែលស្ទង់ចិត្ត ទ្រង់ជ្រាបនូវគំនិតនៃព្រះវិញ្ញាណ ដ្បិតព្រះវិញ្ញាណជួយអង្វរជួសពួកបរិសុទ្ធ ឲ្យត្រូវនឹងព្រះហឫទ័យព្រះ» (រ៉ូម ៨:២៦, ២៧)។ សេចក្តីអធិស្ឋាននៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានជួយឱ្យយើងទទួលបានបទពិសោធន៍បែបនេះជាមួយនឹងព្រះ ដូចដែលលោកប៉ុលបានមានប្រសាសន៍យ៉ាងដូច្នោះដែរ។

ព្រះយេស៊ូវបានប្រើសម្រង់មតិពីកណ្ឌគម្ពីរទំនុកតម្កើង នៅពេលដែលទ្រង់បង្រៀន និងអធិប្បាយ។ នៅក្នុងខគម្ពីរលូកា ២០:៤២, ៤៣ ព្រះយេស៊ូវបានស្រង់សម្រង់មតិនេះពីខគម្ពីរទំនុកតម្កើង ១១០:១ ដែលបានចែងថា៖ «ព្រោះហ្លួងដាវីឌនោះឯង ទ្រង់បានមានព្រះបន្ទូលក្នុងគម្ពីរទំនុកតម្កើងថា 'ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលទៅព្រះអម្ចាស់ខ្ញុំថា ចូរឯងអង្គុយខាងស្តាំអញ ទាល់តែអញដាក់ពួកខ្មាំងសត្រូវឯង ឲ្យធ្វើជាកំណាល់កល់ជើងឯង'»។

យើងបានឃើញរួចមកហើយថា កំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងគឺស្តីអំពីប្រវត្តិសាស្ត្រនៃសាសន៍អ៊ីស្រាអែល។ កវីជាច្រើននាក់បានសរសេរអំពីបទពិសោធន៍នៃជីវិតរបស់ពួកគេ រួមទាំងបទពិសោធន៍នៃជនជាតិយូដាផងដែរ។ នៅពេលដែលលោកអ្នកអានកណ្ឌគម្ពីរទំនុកតម្កើង នោះលោកអ្នកនឹងបានឃើញថា កំណាព្យទាំងនេះបានពិពណ៌នាអំពីសេចក្តីសង្ឃឹម ការសរសើរ សេចក្តីភ័យខ្លាច កំហឹង ហើយនិងទុកសោក។ រឿងទាំងនេះគឺជាអារម្មណ៍ និងជាបទពិសោធន៍ដែលមនុស្សគ្រប់ទីកន្លែង គ្រប់សម័យកាលបានស្គាល់ និងយល់អារម្មណ៍ទាំងនេះ។ កំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងគឺសម្រាប់យើងគ្រប់គ្នា ដោយសារតែកំណាព្យទាំងនេះក៏បានស្តីអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់យើងផងដែរ។

**តើកណ្ឌគម្ពីរទំនុកតម្កើងសំខាន់សម្រាប់បទពិសោធន៍ខាងឯសេចក្តីជំនឿរបស់យើងនោះដោយរបៀបណា? តើការប្រើកណ្ឌគម្ពីរទំនុកតម្កើងរបស់ព្រះយេស៊ូវបានជួយឱ្យយើងឆ្លើយតបទៅនឹងសំណួរនេះដោយរបៀបណា?**

# ព្រះ និងកវីដ៏បរិសុទ្ធរបស់ទ្រង់

**តើព្រះសំខាន់ប៉ុនណាដែរ នៅក្នុងជីវិតនៃកវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើងនោះ? សម្រាប់ចម្លើយ សូមអានខគម្ពីរទំនុកតម្កើង ១៦:៨; ទំនុកតម្កើង ៤៤:៨; ទំនុកតម្កើង ៤៦:១; ទំនុកតម្កើង ៤៧:១, ៧; ទំនុកតម្កើង ៥៧:២; ទំនុកតម្កើង ៦២:៨; ទំនុកតម្កើង ៨២:៨ និងទំនុកតម្កើង ១២១:៧។**

____________________________________________________________________

____________________________________________________________________

ព្រះគឺជាផ្នែកដ៏សំខាន់បំផុតនៅក្នុងជីវិតរបស់កវីនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង។ កវីបានរស់នៅដើម្បីព្រះទាំងស្រុង។ កំណាព្យ ការសរសើរតម្កើង និងបទពិសោធន៍នៃជីវិតគឺស្ដីអំពីការធ្វើនូវអ្វីដែលព្រះចង់បាន។ ព្រះបានបង្កើតអ្វីៗគ្រប់យ៉ាងនៅលើមេឃ និងនៅលើផែនដី។ ព្រះក៏ជាស្ដេច និងជាចៅក្រមនៃពិភពលោកទាំងមូលផងដែរ។ ព្រះបានប្រទានអ្វីៗគ្រប់យើងដល់កូនៗរបស់ទ្រង់ តាមដែលពួកគេត្រូវការ។ ម្ល៉ោះហើយ យើងអាចជឿទុកចិត្តព្រះគ្រប់ពេលវេលា។ នៅពេលដែលរាស្ដ្ររបស់ព្រះរងទុក្ខនោះខ្មាំងសត្រូវរបស់ពួកគេ «សួរជានិច្ចថា 'តើព្រះឯងនៅឯណា'» (ទំនុកតម្កើង ៤២:១០)។ រាស្ដ្ររបស់ព្រះបានដឹងចម្លើយឆ្លើយទៅនឹងសំណួរនេះ។ ពីព្រោះព្រះតែងតែគង់ជាមួយនឹងពួកគេជានិច្ច។ ទ្រង់មិនអាចឱ្យរាស្ដ្ររបស់ទ្រង់បរាជ័យបានឡើយ។ ដូច្នេះហើយ រាស្ដ្ររបស់ព្រះតែងតែអាចជឿទុកចិត្តទៅលើទ្រង់ជានិច្ច។ កណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងថា នៅពេលអនាគត មនុស្សទាំងអស់នឹងថ្វាយបង្គំព្រះជាមិនខាន (ទំនុកតម្កើង ៤៧:១; ទំនុកតម្កើង ៦៤:៩)។

គោលគំនិតដែលថា ព្រះគឺជាផ្នែកដ៏សំខាន់បំផុតនៅក្នុងជីវិតរបស់យើងនេះ ក៏បានធ្វើឱ្យទ្រង់ក្លាយមកជាផ្នែកដ៏សំខាន់បំផុតនៅក្នុងការថ្វាយបង្គំផងដែរ។ ការថ្វាយបង្គំនៅក្នុងសម័យគម្ពីរសញ្ញាចាស់មានលក្ខណៈខុសពីការថ្វាយបង្គំ ដែលមនុស្សជាច្រើន នៅសព្វថ្ងៃនេះបានយល់ឃើញ។ ការថ្វាយបង្គំនៅក្នុងសម័យគម្ពីរសញ្ញាចាស់គឺជាផ្នែកដ៏សំខាន់បំផុតនៅក្នុងជីវិតរបស់មនុស្សលោក។ ដូច្នេះហើយកវីបានសរសេរអំពីអ្វីៗគ្រប់យ៉ាងដែលបានកើតឡើងទាំងល្អទាំងអាក្រក់នៅក្នុងចម្រៀងនៃការថ្វាយបង្គំ និងការសរសើរតម្កើងរបស់ពួកគេ។ ព្រះបានផ្ទៀងព្រះកាណ៌ស្ដាប់កវីទាំងនេះ មិនថាទ្រង់នៅទីណាក៏ដោយ។ ទ្រង់បានឆ្លើយតបនឹងពួកគេនៅក្នុងគ្រាដ៏តតខ្វះរបស់ទ្រង់ (ទំនុកតម្កើង ៣:៤; ទំនុកតម្កើង ១៨:៦; ទំនុកតម្កើង ២០:៦)។

កវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើងបានយល់ឃើញថា ព្រះអាចធ្វើអាចនឹងរឿងដែលមនុស្សលោកមិនអាចធ្វើបាន។ ស្របពេលតែមួយ ព្រះក៏អាចនៅជិតយើង ហើយឆ្ងាយពីយើងផងដែរ។ ព្រះអាចគង់នៅគ្រប់ទីកន្លែង ហើយទន្ទឹមគ្នានេះ ទ្រង់ក៏អាចគង់នៅក្នុងរោងឧបោសថរបស់ទ្រង់ផងដែរ (ទំនុកតម្កើង ១១:៤)។ ព្រះអាចកំបាំងអង្គទ្រង់ពីយើង ប៉ុន្តែ ទន្ទឹមគ្នានេះ ទ្រង់ក៏បានគង់នៅជាមួយនឹងយើងជារៀងរហូតផងដែរ (ទំនុកតម្កើង ៤១:១២)។ រឿងទាំងនេះមនុស្សមិនអាចធ្វើបានឡើយ (ទំនុកតម្កើង ២៤:៧-១០)។ កវីក៏បានយល់ថា ព្រះទ្រង់ល្អ ហើយទ្រង់បានគង់នៅជាមួយនឹងពួកគេនៅក្នុងបទពិសោធន៍ទាំងអស់របស់ពួកគេ។ ចំណេះដឹងនេះបានផ្ដល់សេចក្ដីសង្ឃឹមដល់ពួកគេ ខណៈដែលពួកគេបានរង់ចាំឱ្យព្រះសង្គ្រោះពួកគេនោះ។

**តើយើងអាចកំណត់ព្រះត្រឹមតែជាផ្នែកមួយនៃជីវិតរបស់យើងបានដែរឬទេ? តើកណ្ឌគម្ពីរទំនុកតម្កើងបានជួយឱ្យយើងឆ្លើយសំណួរនេះដោយរបៀបណា? តើលោកអ្នកកំពុងតែព្យាយាមដេញព្រះចេញពីផ្នែកខ្លះនៃជីវិតរបស់លោកអ្នកដែរឬទេ? បើមែន តើផ្នែកទាំងនោះមានអ្វីខ្លះ?**

**ការសិក្សាបន្ថែម៖** សូមអាន Ellen G. White, "The Temple and Its Dedication," pages 35-50, in Prophets and Kings: "The Benefits of Music," pages 291, 292, in *Message to Young People*។

កណ្ឌគម្ពីរទំនុកតម្កើងមានកំណាព្យចំនួន១៥០។ កំណាព្យទាំងនេះរួមចេញជា៥កណ្ឌៈ កណ្ឌទី១ (ទំនុកតម្កើង ជំពូក១-៤១) កណ្ឌទី២ (ទំនុកតម្កើង ជំពូក៤២-៧២) កណ្ឌទី៣ (ទំនុកតម្កើង ៧៣-៨៩) កណ្ឌទី៤ (ទំនុកតម្កើង ៩០-១០៦) និងកណ្ឌទី៥ (ទំនុកតម្កើង ១០៧-១៥០)។

កណ្ឌគម្ពីរទំនុកតម្កើងបានស្រង់សំណុំកំណាព្យ និងចម្រៀងហេព្រើរពីកូនរបស់លោកកូរេ (ទំនុកតម្កើង ជំពូក៤២-៤៩, ទំនុកតម្កើង ជំពូក៨៤, ទំនុកតម្កើង ជំពូក៨៥, ទំនុកតម្កើង ជំពូក៨៧, ទំនុកតម្កើង ជំពូក៨៨) ពីអេសាភ (ទំនុកតម្កើង ជំពូក៧៣-៨៣) ពីចម្រៀងនៃការដើរចូលទៅក្នុងព្រះវិហារ (ទំនុកតម្កើង ១២០-១៣៤) និងពីចម្រៀងសរសើរតម្កើង (ទំនុកតម្កើង ជំពូក១១១-១១៨; ទំនុកតម្កើង ជំពូក១៤៦-១៥០)។ ខគម្ពីរទំនុកតម្កើង ៧២:២០ បានប្រាប់យើងអំពីសំណុំកំណាព្យខ្លីៗ ដែលស្តេចដាវីឌបានសរសេរ។

កំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងភាគច្រើនត្រូវបានសរសេរឡើងនៅក្នុងរជ្ជកាលរបស់ស្តេចដាវីឌ (១០០០ឆ្នាំ មុនគ្រិស្តសករាជ)។ ប៉ុន្តែ សំណុំកំណាព្យ និងបទចម្រៀងទាំងនេះត្រូវបានយកមកប្រើបន្តទៀត បន្ទាប់ពីស្តេចដាវីឌបានសុគតទៅ។ មនុស្សជាច្រើនបានជឿថា លោកអេសរ៉ាបានបង្គាប់ឱ្យអ្នកបម្រើព្រះយកសំណុំចម្រៀង និងកំណាព្យហេព្រើរផ្សេងៗគ្នា មករួមបញ្ចូលគ្នាបង្កើតជាកណ្ឌ១។

ព្រះបានដឹកនាំមនុស្សបរិសុទ្ធទាំងនេះនៅក្នុងកិច្ចការរបស់ពួកគេ។ ព្រះបានបង្ហាញពួកគេថា កំណាព្យណាខ្លះដែលត្រូវយកមកបញ្ចូលនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងនេះ។ យើងអាចមើលឃើញព្រះប្រាជ្ញាញាណរបស់ព្រះ និងជំនាញរបស់មនុស្សលោកនៅក្នុងការបង្កើតកណ្ឌគម្ពីរទំនុកតម្កើងនេះឡើយ។ ការរួមបញ្ចូលគ្នារវាងព្រះ និងមនុស្សលោកបានជួយឱ្យយើងកាន់តែប្រសើរឡើង អំពីរបៀបដែលព្រះយេស៊ូវដែលជាព្រះ បានក្លាយមកជាមនុស្សម្នាក់នៅក្នុងចំណោមពួកយើង។ «សេចក្តីពិតនៃព្រះគម្ពីរមានប្រភពមកពីព្រះ។ មនុស្សលោកបានសរសេរគោលគំនិតរបស់ព្រះជាភាសាមនុស្សលោក។ ដូច្នេះហើយ ព្រះគម្ពីរគឺជាគំរូនៃការរួបរួមរវាងព្រះ និងមនុស្សលោក។ យើងបានឃើញការរួបរួមដដែលនេះនៅក្នុងព្រះយេស៊ូវ។ ពីព្រោះព្រះយេស៊ូវទ្រង់គឺជាព្រះរាជបុត្រារបស់ព្រះ ហើយទ្រង់ក៏ជាកូនមនុស្សផងដែរ។ ព្រះគម្ពីរបានចែងអំពីព្រះយេស៊ូវជាយ៉ាងណា យើងក៏អាចនិយាយតាមព្រះគម្ពីរជាយ៉ាងនោះដែរ។ ដ្បិតព្រះគម្ពីរ និងព្រះយេស៊ូវបាន 'ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា' ដែរ»។ ដកស្រង់ពី Ellen G. White, *The Great Controversy*, page 8, adapted។

## សំណួរពិភាក្សា

**១. ព្រះ និងមនុស្សលោកបានរួមគ្នាចងក្រងកំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង។ តើគោលគំនិតនេះបានជួយឱ្យយើងយល់ថា ព្រះពិតជាចង់នៅជាប់ជាមួយនឹងរាស្ត្ររបស់ទ្រង់នោះដោយរបៀបណាដែរ?**

**២. នៅក្នុងថ្នាក់ សូមពិភាក្សាអំពីគ្រាលំបាកមួយ នៅពេលដែលកណ្ឌគម្ពីរទំនុកតម្កើងបានជួយដល់លោកអ្នក។ តើកណ្ឌគម្ពីរទំនុកតម្កើងបានផ្តល់សេចក្តីសង្ឃឹមអ្វីដែរ ដល់លោកអ្នកនៅក្នុងគ្រាលំបាកនោះ?**

# ការស្វែងរកព្រះយេស៊ូវតាមរយៈគម្ពីរសាសនាដទៃ

លោកប៉ុលបានធ្វើដំណើរពីផ្ទះមួយទៅផ្ទះមួយទៀត ដើម្បីជួបជាមួយនឹងមនុស្សនៅក្នុងទីក្រុងអឺរ៉ុប។ គាត់បានយកព្រះគម្ពីរ និងគម្ពីរសាសនាធំមួយទៀតទៅជាមួយនឹងគាត់។ ថ្ងៃមួយ មានបុរសម្នាក់បានរត់មកបើកទ្វារ។ ដង្ហើមរបស់គាត់ធំក្លិនបារីជោគ។ លោកប៉ុលបាននិយាយថា «ថ្ងៃនេះ ខ្ញុំមានកាដូមួយជូនអ្នក»។ បុរសម្នាក់នោះបានសួរថា «កាដូអី លោកគ្រូ?»។ លោកប៉ុលបាននិយាយថា «កាដូរបស់ខ្ញុំគឺជាព្រះគម្ពីរនេះឯង»។ បុរសម្នាក់នោះបានតបទៅវិញថា «ខ្ញុំមិនចង់បានគម្ពីរហ្នឹងទេ ពីព្រោះខ្ញុំគឺជាអ្នកជឿសាសនាដទៃ លោកគ្រូបានត្រូវការព្រះគម្ពីរហ្នឹង ពីព្រោះលោកគ្រូគឺជាគ្រីស្ទាន»។ លោកប៉ុលបានតបទៅវិញថា «ខ្ញុំក៏មានគម្ពីរសាសនារបស់អ្នកផងដែរ»។ បុរសម្នាក់នោះបានភ្ញាក់ផ្អើលឡើង។ គាត់បានបែរមកចាប់អារម្មណ៍វិញ។ គាត់បាននិយាយថា«បាទ លោកគ្រូ អ៊ីចឹងលោកអាចឱ្យខ្ញុំស្ដាប់មក ប៉ុន្តែ លោកគ្រូអានតែព្រះគម្ពីរខ្ញុំទៅបានហើយ មិនបាច់អានគម្ពីររបស់លោកគ្រូ ក៏បាន»។ លោកប៉ុលបានបើកអានគម្ពីរនោះអំពីព្រះយេស៊ូវ។ បុរសម្នាក់នោះកាន់តែភ្ញាក់ផ្អើលថែមទៀត។ គាត់បានសួរថា «តើបុគ្គលនៅក្នុងគម្ពីរខ្ញុំនេះគឺជាព្រះយេស៊ូវនៅក្នុងគម្ពីររបស់លោកគ្រូមែនទេ?»។

ប៉ុន្មានសប្ដាហ៍ក្រោយមក គាត់បានសិក្សាអំពីព្រះយេស៊ូវពី៤មេរៀននៅក្នុងគម្ពីររបស់គាត់នោះ។ បុរសម្នាក់នោះមិនបានឃើញគម្ពីរសាសនារបស់គាត់ និយាយអំពីការសុគតរបស់ព្រះយេស៊ូវនោះទេ។ គាត់បានឃើញថា គម្ពីរសាសនារបស់គាត់បានទស្សន៍ទាយអំពីព្រះយេស៊ូវដែលត្រូវយាងមកនោះវិញ។ គាត់បានមើលឃើញថា ទាំងអ្នកជឿសាសនាដទៃទាំងអ្នកគ្រីស្ទានសុទ្ធតែបានរង់ចាំព្រះយេស៊ូវយាងត្រឡប់មកវិញដូចគ្នា។ នៅពេលដែលលោកប៉ុលបានអានដល់មេរៀនទី៥ បុរសម្នាក់នោះនៅតែមិនទាន់ទៅទៀត។

១ឆ្នាំក្រោយមក នៅថ្ងៃសប្បាតហ៍មួយ បុរសម្នាក់នោះបានបង្ហាញខ្លួននៅក្នុងព្រះវិហាររបស់លោកប៉ុល។ គាត់បាននិយាយថា «តើខ្ញុំអាចចូលព្រះវិហារនេះបានដែរឬទេ?»។ ម្ដងនេះ លោកប៉ុលគឺជាអ្នកភ្ញាក់ផ្អើលវិញម្ដង ដោយសារតែបុរសម្នាក់នោះបាននិយាយថា «ខ្ញុំចង់ដើរតាមព្រះយេស៊ូវដែរ»។ បន្ទាប់ពីនោះមក បុរសម្នាក់នោះបានមកថ្វាយបង្គំព្រះជារៀងរាល់ថ្ងៃសប្បាតហ៍។ គាត់បាននិយាយថា គម្ពីរសាសនារបស់គាត់បានធ្វើឱ្យគាត់មានអារម្មណ៍ឥតន័យ។ ពីព្រោះ គម្ពីរនោះបកស្រាយអំពីព្រះអង្គសង្គ្រោះដែលត្រូវមកលោះបាបរបស់គាត់នោះឡើយ។ ហេតុដូច្នេះហើយ បានជាគាត់ចង់ទទួលបុណ្យជ្រមុជទឹកវិញ។ លោកប៉ុលបាននិយាយថា «ព្រះយេស៊ូវបាននិយាយថា រូបកាយរបស់យើងគឺជាព្រះវិហាររបស់ព្រះវិញ្ញាណបរិសុទ្ធ តើប្អូនចង់ផ្ដាច់បារីដែរឬទេ? ដ្បិតព្រះយេស៊ូវបានមានបន្ទូលថា 'ដូច្នេះ បើព្រះរាជបុត្រាប្រោសឲ្យអ្នករាល់គ្នាបានរួច នោះនឹងបានរួចជាពិត' (យ៉ូហាន ៨:៣៦) ប្អូនត្រូវតែធ្វើការសម្រេចចិត្តរើសថា រវាងព្រះយេស៊ូវ និងបារី ប្អូនជ្រើសរើសយកមួយណា»។

បុរសម្នាក់នោះបានចាប់ផ្ដើមភ័យខ្លាច។ គាត់បានបន្លឺឡើងថា «ខ្ញុំមិនអាចធ្វើបានទេ លោកគ្រូ»។ ប៉ុន្តែ បន្ទាប់មក គាត់បានលូកដៃចូលបារីនៅក្នុងហោប៉ៅរបស់គាត់ទៅចោលនៅក្នុងធុងសំរាមបាត់ទៅ។ គាត់បានអធិស្ឋានថា «ឱព្រះអម្ចាស់អើយ សូមទ្រង់ជួយឱ្យទូលបង្គំផ្ដាច់បារីនេះផង»។ នៅយប់នោះ គាត់បានទូរស័ព្ទមកកាន់លោកប៉ុល។ គាត់បាននិយាយថា «លោកគ្រូ មិនកើតទេ ខ្ញុំមានអារម្មណ៍មិនស្រួលស្រួលសោះ ខ្ញុំមិនអាចទ្រាំមិនជក់បារីបានឡើយ»។ បុរសទាំង២នេះបានអធិស្ឋានជាមួយគ្នាតាមទូរស័ព្ទ។ ព្រះបានឮសេចក្ដីអធិស្ឋានរបស់ពួកគាត់ ហើយទ្រង់បានជួយឱ្យគាត់ផ្ដាច់បារីបាន។ បើរាប់ពីពេលនោះមក គាត់បានឈប់ជក់បារីជាង៤ឆ្នាំហើយ។ សព្វថ្ងៃនេះ គាត់គឺជាអ្នកដឹកនាំផ្សាយដំណឹងល្អនៅក្នុងព្រះវិហាររបស់គាត់។ លោកប៉ុលបានប្រាប់មិសិនអាត់វេនទីស្ទថា «បុរសម្នាក់នោះបានសេចក្ដីស្រឡាញ់ដល់អ្នកដទៃ ហើយគាត់ក៏មានចិត្តឆេះឆួលនៅក្នុងការរង់ចាំឱ្យព្រះយេស៊ូវយាងត្រឡប់មកវិញដែរ»។

# កណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងឱ្យចេះអធិស្ឋាន



ល្ងាចថ្ងៃបរិសុទ្ធ - ថ្ងៃសៅរ៍ ទី៦ ខែមករា ឆ្នាំ២០២៤

អំណានព្រះគម្ពីរសម្រាប់មេរៀនប្រចាំសប្តាហ៍នេះ៖ ទំនុកតម្កើង ១០៥:៥; កូឡុស ៣:១៦; យ៉ាកុប ៥:១៣; ទំនុកតម្កើង ៤៤; ទំនុកតម្កើង ២២; ទំនុកតម្កើង ១៣; ទំនុកតម្កើង ៦០:១-៥។

ខចងចាំ៖ «ក្រោយមក កាលទ្រង់កំពុងតែអធិស្ឋាននៅកន្លែង១ លុះទ្រង់ឈប់ហើយ នោះសិស្សម្នាក់ទូលថា ព្រះអម្ចាស់អើយ សូមទ្រង់បង្រៀនយើងខ្ញុំ ឲ្យចេះអធិស្ឋានផង ដូចជាលោកយ៉ូហានបានបង្រៀនដល់សិស្សលោកដែរ» (លូកា ១១:១)។

គ្រីស្ទានជាច្រើននាក់បានជឿថា សេចក្តីអធិស្ឋានពិតប្រាកដមិនមែនជាអ្វីដែលលោកអ្នកបានរៀបចំ ឬសរសេរមុនពេលនិយាយនោះឡើយ។ ប៉ុន្តែ សូមចងចាំថា សិស្សរបស់ព្រះយេស៊ូវបានសុំឱ្យទ្រង់បង្រៀនពួកគេឱ្យចេះអធិស្ឋាន។ ការបង្រៀនរបស់ទ្រង់គឺជាព្រះពរសម្រាប់សិស្សរបស់ទ្រង់។ ពីព្រោះព្រះបានដាក់កណ្ឌគម្ពីរទំនុកតម្កើងដែលជាកណ្ឌនៃសេចក្តីអធិស្ឋាននេះនៅចំកណ្តាលព្រះគម្ពីរ ដើម្បីឱ្យរាស្ត្ររបស់ទ្រង់បានអាន។ កណ្ឌគម្ពីរទំនុកតម្កើងបានបង្ហាញយើងពីរបៀបដែលរាស្ត្ររបស់ព្រះបានអធិស្ឋាននៅក្នុងសម័យគម្ពីរសញ្ញាថ្មី។ សព្វថ្ងៃនេះ កណ្ឌគម្ពីរទំនុកតម្កើងក៏អាចបង្រៀនយើងឱ្យចេះអធិស្ឋានផងដែរ។

តាំងតែពីដើមមក កណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនរាស្ត្ររបស់ព្រះអំពីរបៀបអធិស្ឋាន (ពង្សាវតារក្សត្រទី១ ១៦:៧, ៩; នេហេមា ១២:៨)។ នៅពេលដែលព្រះយេស៊ូវអធិស្ឋាន នោះទ្រង់ក៏បានប្រើខទាំងនេះពីកណ្ឌគម្ពីរទំនុកតម្កើងផងដែរ (ម៉ាថាយ ២៧:៤៦)។ ព្រះគម្ពីរបានបង្រៀនយើងឱ្យធ្វើរឿងដូចគ្នានេះនៅក្នុងការថ្វាយបង្គំរបស់យើង (អេភេសូរ ៥:១៩)។ សប្តាហ៍នេះ យើងនឹងក្រឡេកមើលអំពីរបៀបដែលកណ្ឌគម្ពីរទំនុកតម្កើងបានជួយឱ្យរាស្ត្ររបស់ទ្រង់បានរីកចម្រើននៅក្នុងសេចក្តីស្រឡាញ់ដែលពួកគេមានសម្រាប់ព្រះ និងសម្រាប់សេចក្តីជំនឿរបស់ពួកគេនោះ។ សូមចងចាំថា កណ្ឌគម្ពីរទំនុកតម្កើងគឺជាសេចក្តីអធិស្ឋាន។ ពីព្រោះកណ្ឌគម្ពីរនេះបានបង្រៀនយើងអំពីព្រះ។ ហើយការបង្រៀនទាំងនេះក៏អាចផ្លាស់ប្តូររបៀបនៃការអធិស្ឋានរបស់យើងផងដែរ។

សូមឱ្យលោកអ្នកបានយកកណ្ឌគម្ពីរទំនុកតម្កើងមកធ្វើជាសេចក្តីអធិស្ឋានរបស់លោកអ្នកផ្ទាល់។ នៅពេលដែលយើងអធិស្ឋានទៅតាមកណ្ឌគម្ពីរទំនុកតម្កើង នោះសេចក្តីអធិស្ឋានរបស់យើងនឹងបានរឹងមាំឡើង។ ប៉ុន្តែ យើងក៏ត្រូវតែអធិស្ឋានឱ្យបានញឹកញាប់ផងដែរ។

# របៀបប្រើកណ្ឌគម្ពីរទំនុកតម្កើងនៅក្នុងការអធិស្ឋាន

**តើកណ្ឌគម្ពីរទំនុកតម្កើងមានផ្នែកសំខាន់អ្វីដែរ នៅក្នុងបទពិសោធន៍ថ្វាយបង្គំរបស់អ្នកគ្រីស្ទាន នោះ? សូមអានខគម្ពីរទំនុកតម្កើង ១០៥:៥; កូឡូស ៣:១៦ និងយ៉ាកុប ៥:១៣ សម្រាប់ចម្លើយ។**

---

---

តើយើងអាចប្រើកណ្ឌគម្ពីរទំនុកតម្កើងនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើងដោយរបៀបណា? គឺដោយការអានកំណាព្យពីកណ្ឌគម្ពីរទំនុកតម្កើងជារៀងរាល់ថ្ងៃ។ សូមចាប់ផ្តើមជាមួយនឹងបទគម្ពីរទំនុកតម្កើងជំពូក១ បន្ទាប់មក សូមអានកំណាព្យថ្មីមួយជារៀងរាល់ថ្ងៃ រហូតដល់លោកអ្នកអានចប់កណ្ឌគម្ពីរនេះ។ របៀបអានកណ្ឌគម្ពីរទំនុកតម្កើងមួយបែបទៀតនោះគឺជាការរើសយកប្រធានបទមួយ ដែលនិយាយអំពីបទពិសោធន៍ដដែលដែលលោកអ្នកកំពុងទទួលនោះ។ លោកអ្នកអាចរើសយកប្រធានបទជាច្រើន។ តួយ៉ាង ការទួញសោកគឺជាប្រធានបទមួយ ដែលយើងបានឃើញកាលពីសប្តាហ៍មុនរួចមកហើយ។ ការទួញសោកគឺជាកំណាព្យប្រាប់អំពីអារម្មណ៍សោកសៅ។ ការទួញសោកក៏ជាសេចក្តីអង្វរសុំឱ្យព្រះជួយផងដែរ។ ក៏មានកំណាព្យអរព្រះគុណ ចម្រៀងសរសើរតម្កើង ចម្រៀងលន់តួបាប និងកំណាព្យទូន្មានផងដែរ។ នៅក្នុងកំណាព្យទូន្មាន កវីបានសុំដំបូន្មានពីព្រះ។ យើងបានឃើញហើយថា កំណាព្យប្រវត្តិសាស្ត្របានរៀបរាប់អំពីអតីតកាលនៃសាសន៍អ៊ីស្រាអែល។ ក៏មានកំណាព្យអំពីកំហឹងផងដែរ។ កំណាព្យមួយចំនួនទៀតគឺជាចម្រៀងព្យុហយាត្រា។ ពួកបណ្តាជនបានច្រៀងចម្រៀងព្យុហយាត្រា នៅពេលដែលពួកគេធ្វើដំណើរទៅថ្វាយបង្គំព្រះនៅឯទីក្រុងយេរូសាឡិមនោះ។

ដូច្នេះហើយ តើយើងគួរតែយល់កំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងនេះដោយរបៀបណា? ជាដំបូង សូមអានកំណាព្យជាមុនសិន។ បន្ទាប់មក សូមគិតអំពីកំណាព្យនោះទាំងយកចិត្តទុកដាក់ ហើយអធិស្ឋានផង។ សូមកត់ចំណាំអំពីរបៀបដែលកវីបានទូលទៅកាន់ព្រះ។ តើសេចក្តីអធិស្ឋានរបស់គាត់មានហេតុផលអ្វីខ្លះ? តើបទពិសោធន៍របស់លោកអ្នកស្របគ្នាទៅនឹងបទពិសោធន៍នៅក្នុងកំណាព្យនៃកណ្ឌគម្ពីរទំនុកតម្កើងនេះដោយរបៀបណា? តើកវីនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងអាចជួយឱ្យលោកអ្នករៀបរាប់អំពីបទពិសោធន៍របស់លោកអ្នកដោយរបៀបណា? លោកអ្នកនឹងភ្ញាក់ផ្អើលពីរបៀបដែលកវីបានយល់នូវអ្វីដែលកំពុងតែកើតឡើងនៅក្នុងជីវិតរបស់លោកអ្នក។

តើយ៉ាងណាទៅវិញ បើសិនជាលោកអ្នកបានអានអ្វីមួយដែលលោកអ្នកមានអារម្មណ៍ថា លោកអ្នកចាំបាច់ត្រូវតែផ្លាស់ប្តូរឥរិយាបថ ឬគោលគំនិតរបស់លោកអ្នកវិញនោះ? សូមឱ្យលោកអ្នកបាននៅស្ងៀមសិន រួចសួរខ្លួនឯងថា តើកំណាព្យដែលលោកអ្នកបានអាននោះកំពុងតែកែតម្រង់សេចក្តីសង្ឃឹមខុសឆ្គងរបស់លោកអ្នកដែរឬទេ ឬមួយ ក៏កំណាព្យនោះកំពុងតែសុំឱ្យលោកអ្នកផ្លាស់ប្តូរអ្វីមួយផ្សេងទៀតនៅក្នុងជីវិតរបស់លោកអ្នកនោះ? សូមគិតអំពីអត្ថន័យដែលសារនៅក្នុងកំណាព្យនោះបានបង្រៀនលោកអ្នកអំពីព្រះយេស៊ូវ និងកិច្ចការដែលទ្រង់បានធ្វើ ដើម្បីសង្គ្រោះលោកអ្នកនោះ។ យើងបានយល់អំពីគោលគំនិតនេះកាន់តែប្រសើរឡើង នៅពេលដែលយើងក្រឡេកមើលអំពីរបៀបដែលកំណាព្យនោះបានភ្ជាប់ជាមួយនឹងឈើឆ្កាង ហើយនិងការលើកលែងទោសដែលព្រះបានប្រទានឱ្យយើងនោះ។

នៅពេលដែលលោកអ្នកអានកំណាព្យ សូមឱ្យលោកអ្នកបានទូលសុំឱ្យព្រះចារសេចក្តីពិតនៃព្រះគម្ពីរនៅក្នុងចិត្ត និងគោលគំនិតរបស់លោកអ្នក។ ប្រសិនបើកំណាព្យបានធ្វើឱ្យលោកអ្នកគិតអំពីអ្នកណាម្នាក់ដែលលោកអ្នកបានស្គាល់ នោះសូមឱ្យលោកអ្នកបានអធិស្ឋានឱ្យបុគ្គលម្នាក់នោះផងចុះ។ នៅពេលដែលយើងធ្វើកិច្ចការទាំងនេះ សារពីកណ្ឌគម្ពីរទំនុកតម្កើងនឹងប្រទានពរដល់ជីវិតរបស់យើងជាមិនខាន។

**«ចូរឲ្យព្រះបន្ទូលនៃព្រះគ្រីស្ទ បានសណ្ឋិតនៅក្នុងអ្នករាល់គ្នាជាបរិបូរ» (កូឡូស ៣:១៦)។ តើនៅក្នុងខនេះ លោកអ្នកបានឃើញរូបស័ព្ទអ្វីដែរ? តើខនេះមានន័យយ៉ាងណាដែរ? តើការបង្រៀនរបស់ព្រះបានសណ្ឋិតនៅក្នុងយើងដោយរបៀបណា? តើការអានព្រះគម្ពីរបានជួយឱ្យយើងមានបទពិសោធន៍នេះដោយរបៀបណា?**

# ការជឿទុកចិត្តនៅក្នុងគ្រាលំបាក

**តើលោកអ្នកមានអារម្មណ៍ថា ព្រះនៅឆ្ងាយពីលោកអ្នកដែរឬទេ? តើលោកអ្នកមានចម្ងល់ថា ហេតុអ្វីបានជាព្រះបណ្ដោយឱ្យលោកអ្នករងទុក្ខ និងអនុញ្ញាតឱ្យរឿងអាក្រក់ៗបានកើតឡើងនោះដែរឬទេ? ជាការពិតណាស់ យើងទាំងអស់គ្នាសុទ្ធតែមានអារម្មណ៍បែបនេះ។ កវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើងក៏មានអារម្មណ៍បែបនេះនៅពេលនោះដែរ។**

________________________________________________________________________

________________________________________________________________________

តើបទគម្ពីរទំនុកតម្កើង ជំពូក៤៤ បានប្រាប់យើងយ៉ាងដូចម្ដេចដែរ? តើហេតុអ្វីបានជាលោកអ្នកគិតដូច្នេះ? លោកអ្នកអាចនឹងគិតថា មានពាក្យពេចន៍ខ្លះនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង ដែលយើងមិនគួរនិយាយ នៅក្នុងអំឡុងពេលថ្វាយបង្គំនៅក្នុងព្រះវិហារ។ យើងក៏អាចនឹងគិតថា បទពិសោធន៍ខ្លះនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងគឺជាបទពិសោធន៍មិនល្អ ដែលត្រូវយកមកនិយាយនៅក្នុងអំឡុងពេលអធិស្ឋានជាសាធារណៈ ឬអាចនៅក្នុងការថ្វាយបង្គំរបស់យើងក៏បាន។

មែនហើយ យើងត្រូវតែជ្រើសរើសពាក្យពេចន៍ដែលត្រូវអធិស្ឋាននោះឱ្យបានត្រឹមត្រូវ។ ទន្ទឹមគ្នានេះ យើងមិនត្រូវលាក់ទុកអារម្មណ៍ភ័យខ្លាច និងអារម្មណ៍អវិជ្ជមានផ្សេងៗទៀតនៅក្នុងចិត្តរបស់យើងនោះទេ។ បើសិនជាយើងមិនបានទូលទៅព្រះនូវអ្វីអារម្មណ៍របស់យើងទេ នោះយើងនឹងរងនូវការឈឺចាប់ជាមិនខាន។ លើសពីនេះទៅទៀតនោះ យើងក៏មិនបានរៀនជឿទុកចិត្តទៅលើព្រះនោះដែរ។ នៅពេលដែលយើងយកកំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងមកធ្វើជាសេចក្ដីអធិស្ឋានរបស់យើង នោះយើងនឹងចេះអធិស្ឋាន ដោយគ្មានសេចក្ដីភ័យខ្លាចនៅក្នុងចិត្តរបស់យើងឡើយ។ កំណាព្យទាំងនេះបានលើកទឹកចិត្តឱ្យយើងហ៊ានទូលសុំនូវអ្វីដែលយើងមិនហ៊ានទូលសុំ។ យើងក៏បានដឹងថា ព្រះក៏មិនបានសុំឱ្យយើងធ្វើពើដូចជាយើងមិនមានការរងទុក្ខ និងការឈឺចាប់នោះដែរ។

បទគម្ពីរទំនុកតម្កើង ជំពូក៤៤ បានជួយដល់អ្នកគ្រីស្ទានស្លូតស្រង់ ដែលកំពុងតែរងទុក្ខ។ កវីនៅក្នុងជំពូកនេះបានមានប្រសាសន៍៖ «ចិត្តយើងខ្ញុំមិនបានថយត្រឡប់ទេ ជំហាននៃយើងខ្ញុំក៏មិនបានទាស់ចេញពីផ្លូវទ្រង់ដែរ ទោះបើទ្រង់បានបំបាក់បំបែកយើងខ្ញុំនៅទីរបស់ឆ្កែព្រៃ ហើយគ្របយើងខ្ញុំ ដោយម្លប់នៃសេចក្ដីស្លាប់ក៏ដោយ» (ទំនុកតម្កើង ៤៤:១៨, ១៩)។ ប៉ុន្តែ សូមឱ្យលោកអ្នកបានក្រឡេកមើលពីរបៀបចាប់ផ្ដើមនៅក្នុងកំណាព្យនេះវិញ។ កវីនៅក្នុងកំណាព្យនេះបានរៀបរាប់អំពីរបៀបដែលព្រះបានធ្វើនូវរឿងអស្ចារ្យជាច្រើនសម្រាប់រាស្ត្ររបស់ទ្រង់កាលពីអតីតកាល។ ដូច្នេះហើយ កវីបានជឿទុកចិត្តទៅលើព្រះ ដោយមិនបាន «មិនពឹងធ្នូរបស់» (ទំនុកតម្កើង ៤៤:៦) គាត់នោះឡើយ។

ទោះជាយ៉ាងនេះក្ដី រាស្ត្ររបស់ព្រះនៅតែជួបនឹងបញ្ហាដដែល។ ពីព្រោះកវីនៅក្នុងជំពូកនេះបានសរសេរបញ្ជីរៀបរាប់ពីបញ្ហាទាំងអស់របស់គាត់។ ចម្រៀងដ៏កំសត់របស់គាត់គឺជាចម្រៀងដ៏វែង និងមានពេញទៅដោយសេចក្ដីឈឺចាប់។ តើកវីនៅក្នុងជំពូកនេះបានផ្ដល់សេចក្ដីសង្ឃឹមដែលថា ព្រះនឹងសង្គ្រោះរាស្ត្ររបស់ទ្រង់នោះដែរឬទេ? ទេ មិនមែនដូច្នោះទេ។ ផ្ទុយទៅវិញ កវីបានទូលទៅព្រះថា «សូមទ្រង់តើនឡើងជួយយើងខ្ញុំ ហើយលោះយើងខ្ញុំ ដោយយល់ដល់សេចក្ដីសប្បុរសរបស់ទ្រង់ផង» (ទំនុកតម្កើង ៤៤:២៦)។ កវីបានដឹងថា ព្រះបានផ្ទៀងស្ដាប់បញ្ហានៃរាស្ត្ររបស់ទ្រង់ និងបានស្រឡាញ់ពួកគេ ដូចដែលទ្រង់បានផ្ទៀងស្ដាប់បញ្ហានៃសាសន៍អ៊ីស្រាអែលដូច្នោះដែរ។

**សូមឱ្យលោកអ្នកបាននឹកចាំពីគ្រាមួយ នៅពេលដែលព្រះបានសង្គ្រោះលោកអ្នកកាលពីអតីតកាលនោះ។ តើលោកអ្នកគិតថា នៅក្នុងចិត្តរបស់លោកអ្នក លោកអ្នកនៅជិតនឹងព្រះប៉ុនណាដែរ? តើការនឹកចាំពីគ្រាមួយនោះបានជួយឱ្យលោកអ្នកដោយរបៀបណា នៅពេលដែលបញ្ហារបស់លោកអ្នកបានធ្វើឱ្យលោកអ្នកគិតថា ព្រះបានគង់នៅឆ្ងាយពីលោកអ្នកនោះ?**

# ចម្រៀងដ៏កម្សត់

កាលពីម្សិលមិញ យើងបានរៀនពីរបៀបស្ថាបនាជីវិតរបស់យើងខាងឯសេចក្តីអធិស្ឋាន នៅពេលដែលយើងយកកំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងមកធ្វើជាសេចក្តីអធិស្ឋានរបស់យើងនោះ។ កំណាព្យទាំងនេះក៏បានផ្តល់សេចក្តីសង្ឃឹមដល់យើងផងដែរ។ ដ្បិតកំណាព្យទាំងនេះបានជួយឱ្យយើងដឹងថា ព្រះបានគង់នៅកៀកនឹងចិត្តរបស់យើងជាទីបំផុត។

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក២២។ តើយើងអាចរៀនអ្វីខ្លះ ចេញពីកំណាព្យនេះទាក់ទងទៅនឹងការជឿទុកចិត្តទៅលើព្រះ នៅពេលដែលយើងឈឺចាប់នោះ?**

____________________________________________________________

ពាក្យសោកសៅនៅក្នុងខគម្ពីរទំនុកតម្កើង ២២:១ អាចនឹងបង្ហាញនូវពាក្យពេចន៍នៃអារម្មណ៍សោកសៅ និងអារម្មណ៍ឯកោរបស់ពួកគេ។ កវីនៅក្នុងជំពូកនេះបានអង្វរទៅ ព្រះថា «ឱព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់លះចោលទូលបង្គំ ហើយគង់ឆ្ងាយតតជួយទូលបង្គំ ឬស្តាប់សេចក្តីដំងូររបស់ទូលបង្គំដូច្នេះ» (ទំនុកតម្កើង ២២:១)។

ពាក្យទាំងនេះគឺជាពាក្យពេចន៍ដែលគ្រីស្ទានបានស្គាល់យ៉ាងច្បាស់។ ព្រះយេស៊ូវបានមានបន្ទូលនូវពាក្យពេចន៍ទាំងនេះ នៅពេលដែលទ្រង់ជាប់នៅលើឈើឆ្កាង។ នៅពេលដែលទ្រង់បានមានបន្ទូលជាពាក្យពេចន៍ទាំងនេះ ទ្រង់បានបង្ហាញយើងពីសារៈសំខាន់នៃកណ្ឌគម្ពីរទំនុកតម្កើង ដែលជាបទពិសោធន៍របស់ទ្រង់នៅក្នុងនាមជាព្រះអង្គសង្គ្រោះនោះ (សូមអានខគម្ពីរម៉ាថាយ ២៧:៤៦)។

កវីនៅក្នុងជំពូកនេះក៏បានរៀបរាប់អំពីសេចក្តីសង្ឃឹមនៅក្នុងកំណាព្យដដែលនេះផងដែរ ដោយថា៖ «ទូលបង្គំនឹងប្រកាសប្រាប់ពីព្រះនាមទ្រង់ដល់ពួកបងប្អូន ទូលបង្គំនឹងសរសើរដំកើងទ្រង់ នៅកណ្តាលពួកជំនុំ» (ទំនុកតម្កើង ២២:២២)។ សូមប្រៀបធៀបខ២២ជាមួយនឹងខ១។ ខ១មានពេញទៅដោយការរងទុក្ខ និងការឈឺចាប់។ ប៉ុន្តែ ខ២២មានពេញទៅដោយសេចក្តីជំនឿ និងការសរសើរតម្កើងវិញ។ ពាក្យសម្តី និងអារម្មណ៍នៃសេចក្តីសង្ឃឹមនៅក្នុងខ២២មិនស្របជាមួយនឹងអារម្មណ៍សោកសៅ ហើយនិងបទពិសោធន៍ឈឺចាប់នៅក្នុងខ១នោះឡើយ។ ដូច្នេះហើយ តើកវីអាចសរសើរព្រះដោយរបៀបណា ខណៈពេលដែលគាត់បានឈឺចាប់ជាច្រើននោះ? នោះគឺដោយសារតែកវីម្នាក់នេះបានជឿទុកចិត្តទៅលើព្រះ។

យើងក៏អាចទទួលបានបទពិសោធន៍បែបនេះផងដែរ។ នៅពេលដែលយើងអធិស្ឋានដោយប្រើពាក្យពេចន៍នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក២២ យើងនឹងរៀនសម្លឹងមើលឱ្យហួសពីការឈឺចាប់របស់យើង។ យើងនឹងក្រឡេកមើលគ្រាមួយ នៅពេលដែលព្រះបានព្យាបាលយើងតាមរយៈព្រះគុណរបស់ទ្រង់ ហើយទ្រង់ក៏បានប្រទានជីវិតថ្មីដល់យើងផងដែរ ដោយប្រើចក្ខុវិស័យនៃសេចក្តីជំនឿរបស់យើង។

នៅពេលដែលយើងយកកំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងមកធ្វើជាសេចក្តីអធិស្ឋានរបស់យើង នោះយើងនឹងបានលូតលាស់ឡើងនៅក្នុងអំណាច និងការយល់ដឹងខាងឯវិញ្ញាណ។ កណ្ឌគម្ពីរទំនុកតម្កើងបានបង្ហាញយើងនូវពាក្យពេចន៍សម្រាប់បទពិសោធន៍ និងអារម្មណ៍ឈឺចាប់បំផុតរបស់យើង។ អ្វីដែលល្អបំផុតនោះគឺថា កណ្ឌគម្ពីរទំនុកតម្កើងមិនបានទុកយើងចោលឱ្យនៅឈឺចាប់នោះឡើយ។ កំណាព្យនៅក្នុងជំពូកនេះបានជួយរំដោះយើងចេញពីការរងទុក្ខ ការឈឺចាប់ ការខកចិត្ត កំហឹង និងទុក្ខព្រួយជាដើម។ ទោះជាយ៉ាងនេះក្តី ក៏កវីនៅក្នុងជំពូកនេះបានបង្រៀនយើងឱ្យជឿទុកចិត្តទៅលើព្រះដែរ។

យើងបានឃើញពីរបៀបដែលបទគម្ពីរទំនុកតម្កើង ជំពូក២២ បានចាប់ផ្តើមឡើងដោយទុក្ខព្រួយ ហើយក៏បានបញ្ចប់ដោយការសរសើរផងដែរ។ កំណាព្យជាច្រើននៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងក៏បានចាប់ផ្តើម និងបញ្ចប់ដោយការសរសើរផងដែរ។ បទពិសោធន៍ដែលបែរចេញពីការឈឺចាប់មកការសរសើរតម្កើងនេះ បានបង្ហាញយើងអំពីការផ្លាស់ប្តូរ ដែលបានកើតឡើងនៅក្នុងជីវិតរបស់យើង នៅពេលដែលយើងបានទទួលយកព្រះគុណរបស់ព្រះនោះ។

**តើយើងអាចសម្លឹងមើលឱ្យហួសពីបញ្ហារបស់យើង ដោយជឿទុកចិត្តទៅលើព្រះនោះដោយរបៀបណា?**

## ពីអារម្មណ៍អស់សង្ឃឹមទៅជាមានសង្ឃឹម

យើងបានឃើញរួចមកហើយថា មានពេលខ្លះ យើងទាំងអស់គ្នាសុទ្ធតែមានអារម្មណ៍ថា ព្រះនៅឆ្ងាយពីយើងជាទីបំផុត។ នៅក្នុងអំឡុងនៃគ្រាលំបាក យើងអាចនឹងគិតថា ហេតុអ្វីបានជាព្រះបណ្តោយឱ្យយើងរងទុក្ខយ៉ាងដូច្នេះ? ជាញឹកញាប់ កវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើងក៏បានគិតពីរឿងនេះផងដែរ។ មែនហើយ អំពើបាបរបស់យើងបានធ្វើឱ្យយើងរងទុក្ខមែនពិត ប៉ុន្តែ មានពេលខ្លះ ការរងទុក្ខរបស់យើងមិនមែនកំហុសរបស់យើង ហើយក៏មិនមែនជាភាពអយុត្តិធម៌នោះដែរ។ យើងទាំងអស់គ្នាសុទ្ធតែមានអារម្មណ៍បែបនេះ មែនទេ?

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក១៣។ តើនៅក្នុងកំណាព្យនេះ កវីបង្ហាញពីអារម្មណ៍២យ៉ាងអ្វីខ្លះ? តើលោកអ្នកគិតថា កវីបានធ្វើការសម្រេចចិត្តយ៉ាងដូចម្តេចដែរ ទើបបណ្តាលឱ្យគាត់ផ្លាស់ប្តូរទស្សនរបស់គាត់អំពីអ្វីៗគ្រប់យ៉ាងនោះ?**

________________________________________

________________________________________

«ឱព្រះយេហូវ៉ាអើយ តើទ្រង់នឹងភ្លេចទូលបង្គំដល់កាលណាទៀត តើដល់អស់កល្បឬអី តើនឹងលាក់ព្រះភក្ត្រទ្រង់ចំពោះទូលបង្គំដល់កាលណា» (ទំនុកតម្កើង ១៣:១)។ ជាថ្មីម្តងទៀត តើអ្នកណាខ្លះដែលមិនដែលមានអារម្មណ៍បែបនេះនោះ? (តើព្រះពិតជាបានភ្លេចយើងដែរឬទេ?)។ មានពេលខ្លះ នៅពេលដែលយើងអធិស្ឋាន យើងត្រឹមតែបានគិតអំពីខ្លួនយើង និងបញ្ហារបស់យើងប៉ុណ្ណោះ។ ការអធិស្ឋានដែលលើកបញ្ហារបស់យើងមិនមែនជាការអធិស្ឋានត្រឹមត្រូវនោះឡើយ។ បទគម្ពីរទំនុកតម្កើង ជំពូក១៣ បានបង្ហាញយើងថា យើងគួរតែនឹកចាំអំពីព្រះ និងព្រះគុណដែលទ្រង់បានផ្តល់ឱ្យយើង នៅពេលដែលយើងអធិស្ឋាន។ យើងគួរតែទូលទៅព្រះថា យើងបានជឿថា ទ្រង់តែងតែរក្សាសេចក្តីសន្យារបស់ទ្រង់ជានិច្ច។ ហើយទ្រង់ក៏មិនដែលផ្លាស់ប្តូរម្តងណាដែរ។

ជាការពិតណាស់ បទគម្ពីរទំនុកតម្កើង ជំពូក១៣ បានចាប់ផ្តើមឡើងជាមួយនឹងពាក្យទូលអង្វរ ហើយនិងពាក្យរអ៊ូរទាំ។ ប៉ុន្តែ កវីនៅក្នុងជំពូកនេះមិនបានបញ្ចប់កំណាព្យរបស់គាត់ជាមួយនឹងភាពរអ៊ូរទាំ និងភាពសោកសង្រេងនោះឡើយ។ យើងត្រូវតែនឹកចាំអំពីសេចក្តីពិតនៃព្រះគម្ពីរដ៏សំខាន់នៅត្រង់នេះ។

បទគម្ពីរទំនុកតម្កើង ជំពូក១៣ បានបង្រៀនយើងឱ្យជឿទុកចិត្តទៅលើព្រះគុណ និងសេចក្តីស្រឡាញ់របស់ព្រះ (ទំនុកតម្កើង ១៣:៥)។ នៅពេលដែលយើងជឿទុកចិត្តថា ព្រះនឹងសង្គ្រោះយើង នោះសេចក្តីភ័យខ្លាច និងសេចក្តីព្រួយបារម្ភរបស់យើង (ទំនុកតម្កើង ១៣:១-៤) នឹងរលាយបាត់អស់ជាមិនខាន។ បន្ទាប់មក ចិត្តរបស់យើងនឹងបានផ្លាស់ប្តូរ។ ហើយការទូលអង្វររបស់យើងក៏នឹងក្លាយមកជាចម្រៀងនៃសេចក្តីអំណរ និងសេចក្តីសរសើរតម្កើងផងដែរ។ ដ្បិតយើងនឹងលែងមានអារម្មណ៍អស់សង្ឃឹមតទៅហើយ។

ប្រសិនបើយើងចង់ឱ្យការផ្លាស់ប្តូរនេះបានកើតឡើង នោះយើងត្រូវតែធ្វើឱ្យលើសពីការអានពាក្យពេចន៍នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក១៣នេះ។ យើងត្រូវតែជឿពួកគេទៅលើពាក្យពេចន៍ទាំងនេះ។ ហើយនៅពេលដែលយើងអធិស្ឋាន យើងក៏ត្រូវតែសុំឱ្យព្រះវិញ្ញាណបរិសុទ្ធជួយឱ្យយើងរស់នៅតាមរបៀបដែលកំណាព្យនេះបានសំណូមពរ។ កំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងគឺជាព្រះគម្ពីរដែលជាព្រះបន្ទូលដ៏រស់របស់ព្រះនោះឯង។ ព្រះបន្ទូលរបស់ព្រះបានផ្លាស់ប្តូរជីវិត ចិត្ត ហើយនិងទង្វើរបស់យើង។ នៅពេលដែលយើងអនុញ្ញាតព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះផ្លាស់ប្តូរយើង នោះយើងនឹងបានរួបរួមជាមួយនឹងព្រះយេស៊ូវជាមិនខាន។ នៅក្នុងនាមជាព្រះរាជបុត្រារបស់ព្រះ ព្រះយេស៊ូវបានបង្ហាញពីផែនការដ៏ល្អឥតខ្ចោះតាមរយៈផ្នែកទាំងអស់នៃជីវិតរបស់ទ្រង់។ ព្រះយេស៊ូវបានយកកំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងមកធ្វើជាសេចក្តីអធិស្ឋានរបស់ទ្រង់។ ហើយយើងក៏គួរតែធ្វើដូច្នោះដែរ។

**តើបញ្ហារបស់លោកអ្នកបាននាំឱ្យចិត្តរបស់លោកអ្នកបានកៀកនឹងព្រះដោយរបៀបណា? តើហេតុអ្វីបានជាបញ្ហារបស់លោកអ្នកអាចនាំលោកអ្នកឱ្យចេញពីព្រះយ៉ាងដូច្នេះ បើសិនជាលោកអ្នកមិនបានប្រុងប្រយ័ត្ននោះ?**

# សូមឱ្យទ្រង់ត្រឡប់មកឯពួកយើងវិញ

សូមអានខគម្ពីរទំនុកតម្កើង ៦០:១-៥។ បទគម្ពីរទំនុកតម្កើង ជំពូក៦០ គឺជាកំណាព្យទួញសោក។ យើងបានដឹងថា កំណាព្យទួញសោកគឺជាកំណាព្យកំសត់។ កំណាព្យទួញសោកនេះក៏ជាសេចក្តីអធិស្ឋានផងដែរ។ តើលោកអ្នកបានគិតថា ពេលណាជាពេលវេលាដែលត្រូវទូលប្រាប់នូវសេចក្តីអធិស្ឋានបែបនេះនោះ? តើយើងអាចទទួលបានព្រះពរពីការអានកំណាព្យកំសត់នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង នៅពេលដែលជីវិតរបស់លោកអ្នកមានពេញដោយសេចក្តីអំណរ និងអារម្មណ៍រីករាយនោះដោយរបៀបណា?

____________________________________________________________

____________________________________________________________

កំណាព្យទួញសោកគឺជាកំណាព្យដ៏ពិសេសមួយបែបនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង។ យើងបានឃើញរួចមកហើយថា កំណាព្យកំសត់ទាំងនេះក៏ជាសេចក្តីអធិស្ឋានផងដែរ។ កំណាព្យកំសត់បានពិពណ៌នាអំពីបទពិសោធន៍របស់មនុស្សលោក នៅក្នុងអំឡុងនៃគ្រាលំបាក។ បទពិសោធន៍ទាំងនេះអាចមានដូចជាជំងឺតម្កាត់ ទុក្ខព្រួយ និងការរងទុក្ខខាងឯវិញ្ញាណ។ មានពេលខ្លះ កំណាព្យទួញសោកក៏អាចមានបទពិសោធន៍ទាំង៣នេះរួមគ្នាផងដែរ។

តើយើងគួរតែអានកំណាព្យទួញសោកនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង តែនៅពេលដែលយើងមានទុក្ខដែរឬទេ? ទេ មិនមែនដូច្នោះឡើយ។ កំណាព្យទួញសោកអាចផ្តល់ពរឱ្យយើងទៅតាមរបៀបជាច្រើន ទាំងនៅក្នុងអំឡុងពេលរីករាយ និងនៅក្នុងអំឡុងពេលសោកសៅនៅក្នុងជីវិតរបស់យើងនេះ។

កំណាព្យទួញសោកនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងឱ្យស្រឡាញ់ដល់អ្នករងទុក្ខ។ នៅពេលដែលយើងអធិស្ឋានជាសាធារណៈ ហើយអរព្រះគុណព្រះសម្រាប់ព្រះពររបស់ទ្រង់ នោះយើងត្រូវតែគិតដល់អ្នករងទុក្ខ។ ជាការពិតណាស់ នៅឥឡូវនេះ អ្វីៗអាចនឹងរលូនសម្រាប់យើងមែនពិត។ ប៉ុន្តែចុះចំណែកឯមនុស្សនៅជុំវិញយើង ដែលបានរងទុក្ខយ៉ាងវេទនានោះ តើយើងបានគិតពីពួកគេដែរឬទេ? នៅពេលដែលយើងយកកំណាព្យទួញសោកមកធ្វើជាសេចក្តីអធិស្ឋានរបស់យើង នោះយើងក៏ត្រូវតែនឹកដល់អ្នកដែលស្ថិតនៅក្នុងគ្រាលំបាកផងដែរ។ កណ្ឌគម្ពីរទំនុកតម្កើងគួរតែបានបំពេញយើងនូវសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ ហើយកណ្ឌគម្ពីរនេះក៏គួរតែជំរុញឱ្យយើងចង់ជួយពួកគេ ដូចដែលព្រះយេស៊ូវបានធ្វើដូច្នោះដែរ។

«ដ្បិតផែនដីក៏ប្រៀបដូចជាមន្ទីរពេទ្យផ្ទុកអ្នកជំងឺឈឺធ្ងន់យ៉ាងដូច្នោះដែរ។ ព្រះយេស៊ូវបានយាងមកប្រោសអ្នកឈឺ។ ហើយទ្រង់ក៏បានយាងមកប្រកាសថា ទ្រង់នឹងរំដោះមនុស្សលោកចេញពីសាតាំងផងដែរ។ ព្រះយេស៊ូវទ្រង់មានទាំងសុខភាព និងមានទាំងកម្លាំង។ ព្រះយេស៊ូវបានប្រទានជីវិតរបស់ទ្រង់ដើម្បីសង្គ្រោះអ្នកឈឺ អ្នករងទុក្ខ និងមនុស្សដែលមានអារក្សចូល។ ព្រះយេស៊ូវបានទទួលយកមនុស្សគ្រប់គ្នា ដែលបានចូលមកសុំឱ្យទ្រង់ប្រោសពួកគេ។ ព្រះយេស៊ូវបានដឹងថា មនុស្សដែលចូលមកសុំជំនួយពីទ្រង់បាននាំយកជំងឺរបស់ពួកគេមកជាមួយដែរ។ ព្រះយេស៊ូវក៏មិនបានបដិសេធថា ទ្រង់នឹងមិនប្រោសពួកគេនោះដែរ។ ដ្បិតសេចក្តីស្រឡាញ់ដែលចេញមកពីព្រះយេស៊ូវបានជ្រាបចូលទៅក្នុងចិត្តនៃអ្នកជំងឺទាំងនេះ។ ហើយពួកគេក៏បានដឹងច្បាស់ថា ពួកគេបានប្រព្រឹត្តអំពើបាបផងដែរ។ ព្រះយេស៊ូវបានប្រោសវិញ្ញាណ និងរូបកាយនៃមនុស្សឈឺទាំងនេះជាច្រើននាក់។ ដំណឹងល្អអំពីព្រះយេស៊ូវនៅសព្វថ្ងៃនេះក៏ដូចជាដំណឹងល្អនៅក្នុងសម័យទ្រង់ផងដែរ។ ដូច្នេះហើយ សព្វថ្ងៃនេះ យើងក៏គួរតែរំពឹងចង់ឃើញការអស្ចារ្យបែបនេះកើតឡើងម្តងទៀតផងដែរ»។ ដកស្រង់ពី Ellen G. White, *Welfare Ministry*, pages 24, 25, adapted។

តើនៅពេលនេះ លោកអ្នកបានស្គាល់អ្នកណាម្នាក់ដែលត្រូវការសេចក្តីអធិស្ឋានរបស់លោកអ្នក និងត្រូវការព្រះហស្តព្យាបាលរបស់ទ្រង់ដែរឬទេ? សូមអធិស្ឋានឱ្យបុគ្គលម្នាក់នេះនៅពេលឥឡូវនេះ ដោយទូលសុំឱ្យព្រះយេស៊ូវជួយឱ្យលោកអ្នកក្លាយមកជាព្រះពរនៅក្នុងជីវិតនៃបុគ្គលម្នាក់នេះ។

ការសិក្សាបន្ថែម៖ សូមអាន Psalm 42:8, and Ellen G. White, "Poetry and Song," Pages 159-168, in Education។ បើយោងទៅតាមបទគម្ពីរទំនុកតម្កើង ជំពូក៤២ ហើយនិងសៀវភៅអប់រំ ដែលបានបង្ហាញយើងនេះ តើសេចក្តីអធិស្ឋាន ហើយនិងចម្រៀងមានទំនាក់ទំនងអ្វីនឹងគ្នាដែរ?

នៅក្នុងកំណាព្យជាច្រើន ស្តេចដាវីឌបានសរសេរអំពីរបៀបលន់តួអំពើបាបរបស់ទ្រង់។ (គំរូដែលគេស្គាល់ជាងគេបំផុតនោះគឺបទគម្ពីរទំនុកតម្កើង ជំពូក៥១)។ អ្នកស្រីអេឡែន ជីវ៉ៃត៍បានមានប្រសាសន៍ថា កំណាព្យទាំងនេះគឺជាសេចក្តីអធិស្ឋាន ដែលបានបង្ហាញនូវភាពសោកសៅចំពោះអំពើបាបយ៉ាងអស់ពីចិត្ត (សូមអាន Steps to Christ, pages 24, 25)។ អ្នកស្រីអេឡែន ជីវ៉ៃត៍បានលើកទឹកចិត្តអ្នកគ្រីស្ទានឱ្យរៀនសូត្រខទាំងឡាយពីកណ្ឌគម្ពីរទំនុកតម្កើង ដើម្បីជួយឱ្យពួកគេមានអារម្មណ៍ថា ព្រះបានគង់នៅក្បែរពួកគេ គឺនៅក្នុងចិត្ត និងនៅក្នុងជីវិតរបស់ពួកគេ។ អ្នកស្រីអេឡែន ជីវ៉ៃត៍ក៏បានមានប្រសាសន៍អំពីរបៀបដែលព្រះយេស៊ូវបានសូត្រខពីកណ្ឌគម្ពីរទំនុកតម្កើង នៅពេលដែលសាតាំងបានព្យាយាមល្បួងឱ្យទ្រង់ប្រព្រឹត្តអំពើបាប ឬធ្វើឱ្យទ្រង់មានអារម្មណ៍ភ័យខ្លាច។ អ្នកស្រីអេឡែន ជីវ៉ៃត៍បានមានប្រសាសន៍ថា៖ «ពាក្យពេចន៍នៃចម្រៀងបរិសុទ្ធបានបំពេញសេចក្តីជំនឿនៅក្នុងចិត្តរបស់យើងជាច្រើនលើកច្រើនសា។ ចម្រៀងទាំងនេះបានធ្វើឱ្យយើងមានអារម្មណ៍សោកស្តាយចំពោះអំពើបាបរបស់យើង។ ចម្រៀងទាំងនេះក៏បានផ្តល់សេចក្តីសង្ឃឹម សេចក្តីស្រឡាញ់ និងសេចក្តីអំណរផងដែរ . . . . ជាការពិតណាស់ ចម្រៀងទាំងនេះភាគច្រើនគឺជាសេចក្តីអធិស្ឋាន»។ ដកស្រង់ពី *Education*, pages 162-168, adapted។

នៅពេលដែលយើងអធិស្ឋាន និងច្រៀងកំណាព្យ និងចម្រៀងនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង នោះសេចក្តីជំនឿ សេចក្តីកម្សាន្តចិត្ត និងសេចក្តីសង្ឃឹមរបស់កវីនៅក្នុងកណ្ឌគម្ពីរនេះ នឹងបានក្លាយមកជាសេចក្តីជំនឿ សេចក្តីកម្សាន្តចិត្ត និងសេចក្តីសង្ឃឹមរបស់យើងវិញ។ កវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើងបានជួយកម្សាន្តចិត្តយើងឱ្យបន្តដំណើរជីវិតខាងឯវិញ្ញាណរបស់យើងតទៅទៀត ព្រមទាំងបានជួយលើកទឹកចិត្តយើងកុំឱ្យបោះបង់សេចក្តីជំនឿ និងសេចក្តីសង្ឃឹមនោះដែរ។ កវីនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានកម្សាន្តចិត្តយើង។ ពួកគេបានជួយឱ្យយើងដឹងថា យើងមិនមែននៅតែម្នាក់ឯងនោះទេ។ អ្នកខ្លះទៀតដែលមានបញ្ហាដូចជាយើង បានរងទុក្ខនៅក្នុងគ្រាដ៏អួរអាប់។ ដោយមានព្រះគុណរបស់ព្រះ ពួកគេបានឈ្នះសង្គ្រាមទាស់នឹងអំពើបាបជាមិនខាន។ កណ្ឌគម្ពីរទំនុកតម្កើងក៏បានបង្ហាញយើងពីរបៀបដែលព្រះយេស៊ូវបានធ្វើកិច្ចការ ដើម្បីសង្គ្រោះយើងនោះដែរ។ ដ្បិតទ្រង់បានមានព្រះជន្មរស់ជានិច្ច ដើម្បីអធិស្ឋានឱ្យយើង (ហេព្រើរ ៧:២៥)។

កំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងគឺជាសេចក្តីអធិស្ឋាន និងជាបទចម្រៀង។ មនុស្សលោកជាអ្នកសរសេរកំណាព្យទាំងនេះ។ ប៉ុន្តែ កំណាព្យទាំងនេះមានប្រភពមកពីព្រះវិញ។ ដូច្នេះហើយ នៅពេលដែលយើងបញ្ចូលកណ្ឌគម្ពីរទំនុកតម្កើងនៅក្នុងការថ្វាយបង្គំរបស់យើង នោះយើងនឹងរៀនពីផែនការដែលព្រះបានរៀបចំសម្រាប់យើង។ សេចក្តីមេត្តាដ៏ធំបំផុតរបស់ទ្រង់ក៏នឹងព្យាបាលយើងផងដែរ។

## សំណួរពិភាក្សា

១. មនុស្សជាច្រើនបានគិតថា នៅពេលដែលលោកអ្នកអធិស្ឋាន លោកអ្នកគួរតែនិយាយនូវអ្វីដែលចូលមកក្នុងគំនិតរបស់លោកអ្នក ដោយមិនចាំបាច់គិតច្រើនអំពីអ្វីដែលលោកអ្នកត្រូវព្រាងទុក។ តើហេតុអ្វីបានជាវិធីសាស្ត្រនៃការអធិស្ឋានបែបនេះមិនត្រឹមតែជាវិធីតែមួយគត់យ៉ាងដូច្នេះ?

២. តើកណ្ឌគម្ពីរទំនុកតម្កើងអាចស្តាបនាបទពិសោធន៍នៃការអធិស្ឋានជាក្រុមរបស់យើងនោះដោយរបៀបណា? តើមានវិធីណាខ្លះ ដែលក្រុមជំនុំរបស់លោកអ្នកអាចប្រើកណ្ឌគម្ពីរទំនុកតម្កើងនៅក្នុងការថ្វាយបង្គំព្រះរបស់ពួកគេនោះ?

៣. តើកណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងអំពីសេចក្តីជំនឿ ហើយនិងព្រះគុណប្រោសលោះរបស់ទ្រង់នោះដោយរបៀបណា?

# សេចក្តីទូលអង្វរដែលចេញពីចិត្តរបស់លោករ៉ាដូស្ទីន

លោករ៉ាដូស្ទីន (Radostin) មិនពេញចិត្តនឹងជីវិតរបស់គាត់ទាល់តែសោះ។ មិត្តភក្តិរបស់គាត់មិនបានផ្តល់ឥទ្ធិពលល្អមកលើគាត់នោះឡើយ។ គាត់បានជាប់ពាក់ព័ន្ធនឹងគ្រឿងញៀនខុសច្បាប់ ហើយគាត់ក៏បានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មមួយចំនួនផងដែរ។ ការទទួចឥតឈប់ឈរនៅក្នុងចិត្តរបស់គាត់នោះគឺថា «ខ្ញុំចង់ផ្លាស់ប្តូរជីវិតរបស់ខ្ញុំណាស់»។ លុះដល់ធំឡើង លោករ៉ាដូស្ទីនបានរៀបអាពាហ៍ពិពាហ៍ បន្ទាប់មកគាត់មានកូនប្រុស២នាក់។ ពេលវេលាដូចជាមិនអំណោយផលដល់គាត់ទាល់តែសោះ ម្ល៉ោះហើយ គាត់បានចាកចេញពីប្រទេសប៊ុលហ្គារីរបស់គាត់ទៅស្វែងរកការងារធ្វើ។ ខណៈដែលគាត់បានធ្វើការនៅក្នុងបែកអឺរ៉ុបខាងលិច គាត់បានរាប់អានមិត្តភក្តិថ្មីៗជាច្រើន។ គាត់ចង់ដឹងសេចក្តីពិតណាស់។ គាត់បានប្រាថ្នាថា មិត្តភក្តិថ្មីរបស់គាត់នឹងបើកបង្ហាញឱ្យគាត់បានឃើញសេចក្តីពិត។ ឥឡូវនេះ សំណួរទទូចឥតឈប់ឈរដែលបានដក់នៅក្នុងចិត្តរបស់គាត់នោះគឺថា «តើអ្នកដែលដឹងសេចក្តីពិតពិតប្រាកដនោះអាចមករកខ្ញុំឃើញដោយរបៀបណា?»។ មួយស្របក់ក្រោយមក គាត់បានដឹងថា ខ្លួនគាត់កំពុងតែស្នាក់នៅក្នុងផ្ទះជួលដ៏តូចមួយទាំងគ្មានប្រាក់គ្មានអាហារបរិភោគ។ គាត់ពិតជាឃ្លានណាស់។ យប់មួយ ដោយអស់សង្ឃឹមពេកចិត្តរបស់គាត់បានស្រែកដង្ហោយរកព្រះ។ គាត់បានអធិស្ឋានជាលើកដំបូងនៅក្នុងជីវិតរបស់គាត់យ៉ាងដូច្នេះថា «ឱព្រះអម្ចាស់អើយ សូមព្រះអង្គចាត់អ្នកណាម្នាក់ឱ្យមករកទូលបង្គំផង»។ លុះដល់ព្រឹកឡើង មានមនុស្សម្នាក់បានគោះទ្វាររបស់គាត់។ បុរសម្នាក់នោះបានស្លៀកពាក់យ៉ាងសមរម្យ។ គាត់បានកាន់ព្រះគម្ពីរនៅជាប់នឹងដៃ។ លោករ៉ាដូស្ទីនបានយល់ថា ព្រះបានឆ្លើយតបនឹងការអធិស្ឋានរបស់គាត់ ដោយចាត់ឱ្យបុរសម្នាក់នេះមកជួបជាមួយនឹងគាត់។ លោកប៉ុលដែលជាបុរសម្នាក់នោះបានយកអាហារមកឱ្យលោករ៉ាដូស្ទីនបរិភោគ។ លោកប៉ុលបានបបួលលោករ៉ាដូស្ទីនទៅលេងព្រះវិហារ។ លោករ៉ាដូស្ទីនបានទៅជាមួយនឹងលោកប៉ុល ហើយគាត់បានភ្ញាក់ផ្អើលជាខ្លាំង។ ដ្បិតគាត់មិនដែលបានចូលព្រះវិហារ ដែលជាកន្លែងដែលគាត់ចង់ទទួលបានអារម្មណ៍កក់ក្តៅនោះឡើយ។ ព្រះបានប៉ះពាល់ចិត្តរបស់គាត់ធ្វើឱ្យគាត់ទ្រហោយំឡើង។

នៅពេលដែលគាត់ត្រឡប់មកកាន់ប្រទេសប៊ុលហ្គារីវិញ គាត់បានប្រាប់គ្រួសាររបស់គាត់ជាច្រើនលើកច្រើនសា អំពីការជួបជាមួយនឹងព្រះ ហើយនិងបទពិសោធន៍នៃសេចក្តីស្រឡាញ់របស់ព្រះនៅឯព្រះវិហាររបស់លោកប៉ុលនោះ។ គាត់ពិតជាចង់ទៅព្រះវិហារនោះម្តងទៀតណាស់ ប៉ុន្តែ គាត់មិនច្បាស់ថា ភរិយារបស់គាត់នឹងយល់ព្រមផ្លាស់ប្តូរទៅទីនោះនោះឡើយ។ ពីព្រោះនាងក៏បានធំធាត់ឡើងនៅក្នុងសាសនាធំមួយទៀត ដូចជាគាត់ដែរ។ គាត់បានអធិស្ឋានថា «ឱព្រះអម្ចាស់អើយ បើសិនជាទ្រង់ជាព្រះមែនពិត ហើយការនេះពិតជាបំណងព្រះហឫទ័យរបស់ទ្រង់មែន នោះសូមទ្រង់ជួយដល់ទូលបង្គំផង ម្យ៉ាងទៀត បើសិនជាព្រះវិហាររបស់លោកប៉ុលគឺជាព្រះវិហារពិតប្រាកដរបស់ទ្រង់មែន នោះសូមឱ្យទ្រង់បានបញ្ជូនទូលបង្គំ និងក្រុមគ្រួសាររបស់ទូលបង្គំទៅទីនោះចុះ ពីព្រោះទូលបង្គំចង់ឱ្យជីវិតរបស់ទូលបង្គំនេះបានផ្លាស់ប្តូរទាំងស្រុង»។ ថ្ងៃមួយ ភរិយារបស់លោករ៉ាដូស្ទីនបានប្រកាសភ្លាមៗថា «បង ខ្ញុំមិនចង់រស់នៅក្នុងប្រទេសប៊ុលហ្គារីនេះទេ ប៉ុន្តែ ខ្ញុំចង់ទៅរស់នៅក្នុងទីក្រុងនៃព្រះវិហាររបស់លោកប៉ុលវិញ»។ ដោយពុបែបនេះ លោករ៉ាដូស្ទីនបានដឹងភ្លាមៗថា នេះគឺជាបំណងព្រះហឫទ័យព្រះ ដែលទ្រង់ចង់ឱ្យគ្រួសាររបស់គាត់ផ្លាស់ទៅរស់នៅក្បែរព្រះវិហារទ្រង់វិញ។ ក្រុមគ្រួសាររបស់គាត់ក៏បានផ្លាស់ទៅរស់នៅទីនោះមែន។ សព្វថ្ងៃនេះ លោករ៉ាដូស្ទីនគឺជាសមាជិកសកម្មនៅក្នុងព្រះវិហារសេវេនដេយអាត់វេនទីស្ទ ហើយគាត់ក៏បានទៅថ្វាយបង្គំនៅឯព្រះវិហាររបស់លោកប៉ុលរាល់ថ្ងៃសប្បាតហ៍ផងដែរ។

លោករ៉ាដូស្ទីននៅតែជួបនឹងការលំបាក ប៉ុន្តែ គាត់លែងព្រួយបារម្ភដូចពីមុនហើយ ដោយគាត់បានប្រាប់មិសិនអាត់វេនទីស្ទថា «យើងមិនគួរទូលសូមឱ្យព្រះប្រទានអ្វីៗគ្រប់យ៉ាងដល់យើងនោះឡើយ ប៉ុន្តែ យើងគួរតែអធិស្ឋានសូមឱ្យទ្រង់ការពារយើងចេញពីសេចក្តីអាក្រក់វិញ ដោយការទូលសូមឱ្យទ្រង់ជួយឱ្យយើងរស់នៅក្នុងការសាកល្បងវិញ»។

សេចក្តីអធិស្ឋានរបស់គាត់គ្មានមន្ទិលសង្ស័យ ដោយគាត់បាននិយាយថា «ខ្ញុំមិនមែនជាមនុស្សល្អដូចជាបុរសម្នាក់នេះទេ ប៉ុន្តែ ខ្ញុំសូមអរគុណព្រះ ដែលបានផ្លាស់ប្តូរជីវិតរបស់ខ្ញុំយ៉ាងពិតប្រាកដមែន»។

# ព្រះអម្ចាស់គឺជាស្តេច



**ល្ងាចថ្ងៃបរិសុទ្ធ - ថ្ងៃសៅរ៍ ទី១៣ ខែមករា ឆ្នាំ២០២៤**

**អំណានព្រះគម្ពីរសម្រាប់មេរៀនប្រចាំសប្តាហ៍នេះ៖ ទំនុកតម្កើង ៨; ទំនុកតម្កើង ១០០; ទំនុកតម្កើង ៩៧; ទំនុកតម្កើង ៧៥; ទំនុកតម្កើង ៩៤:១៤; កាឡាទី ៣:២៦-២៩; ទំនុកតម្កើង ១៩:៧។**

**ខចងចាំ៖ «ព្រះយេហូវ៉ាទ្រង់ជាអ្នកគ្រប់គ្រង ទ្រង់ប្រដាប់អង្គដោយភាពដ៏រុងរឿងឧត្តម ព្រះយេហូវ៉ាទ្រង់ប្រដាប់អង្គ ដោយតេជានុភាព ព្រមទាំងក្រវាត់អង្គ ដោយសេចក្តីនោះដែរ ឯលោកីយ៍នោះបានតាំងមាំមួន និងរង្គើមិនបានឡើយ»** (ទំនុកតម្កើង ៩៣:១)។

កណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងថា ព្រះអម្ចាស់គឺជាស្តេចនៃផែនដីទាំងមូល។ ពីព្រោះទ្រង់បានបង្កើតអ្វីៗគ្រប់យ៉ាង។ ហើយទ្រង់ក៏បានទ្រទ្រង់របស់ទាំងនោះផងដែរ។ នៅក្នុងនាមជាស្តេចរបស់យើង ព្រះអម្ចាស់ទ្រង់បរិសុទ្ធ និងយុត្តិធម៌។ បញ្ញត្តរបស់ទ្រង់គឺជាបញ្ញត្តល្អប្រពៃ ពីព្រោះបញ្ញត្តរបស់ទ្រង់បានផ្តល់ជីវិតដល់មនុស្សគ្រប់គ្នា ដែលបានគោរពពួកគេ។ ព្រះអម្ចាស់ក៏ជាចៅក្រមដ៏យុត្តិធម៌មួយអង្គផងដែរ ពីព្រោះទ្រង់បានការពារជីវិតនៅលើផែនដីនេះ។ ទ្រង់បានផ្តល់រង្វាន់ដល់អស់អ្នកណាដែលគោរពតាមបញ្ញត្តិរបស់ទ្រង់ តែដាក់ទោសដល់អស់អ្នកណាដែលមិនបានគោរពតាមទ្រង់វិញ។ ព្រះអម្ចាស់នឹងកំណត់ថា ពេលណាដែលទ្រង់ត្រូវដាក់ទោសពួកគេ នៅពេលដែលទ្រង់បញ្ចប់កិច្ចការរបស់ទ្រង់ ដែលស្ថិតនៅក្រោមពេលវេលារបស់ទ្រង់ មិនមែននៅក្រោមពេលវេលារបស់យើងឡើយ។

សេចក្តីសន្យាដែលព្រះបានតាំងឡើងជាមួយនឹងសាសន៍អ៊ីស្រាអែលគឺជាហេតុផលដែលនាំឱ្យទ្រង់ការពារផែនដីនេះ។ សេចក្តីសន្យារបស់ទ្រង់បានបង្ហាញយើងអំពីផែនការសង្គ្រោះរបស់ទ្រង់។ នៅក្នុងផ្នែកនៃសេចក្តីសន្យារបស់ទ្រង់នេះ ព្រះបានយកសាសន៍អ៊ីស្រាអែលមកធ្វើជារាស្ត្ររបស់ទ្រង់ ដែលមានតម្លៃលើសពីជាតិសាសន៍ទាំងអស់នៅលើផែនដីនេះ។ ព្រះអម្ចាស់បានរក្សាសេចក្តីសន្យាដែលទ្រង់បានតាំងឡើងជាមួយនឹងរាស្ត្ររបស់ទ្រង់។ ហើយទ្រង់ក៏នឹងនៅតែបន្តថែរក្សាយើងផងដែរ ទោះបីជាមានពេលខ្លះ យើងបានធ្វើបាបទាស់នឹងទ្រង់ក៏ដោយ។

យើងអាចជឿទុកចិត្តបានថា ទ្រង់នឹងការពារយើងនៅលើផែនដីនេះ ដោយសារតែព្រះអម្ចាស់គឺជាស្តេច។ ដូច្នេះហើយ កវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើងក៏ចង់ឱ្យយើងយល់សេចក្តីពិតនេះដែរ។ នៅពេលដែលយើងយល់សេចក្តីពិតនេះ យើងនឹងអាចបម្រើទ្រង់ដោយអស់ពីចិត្តរបស់យើង ដូចជាកវីទាំងនេះបានធ្វើយ៉ាងដូច្នោះដែរ។

# ព្រះអម្ចាស់គឺជាព្រះអាទិកររបស់យើង

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក៨ និងទំនុកតម្កើង ១០០។ តើបទគម្ពីរទំនុកតម្កើង ឬកំណាព្យទាំង២នេះ បានបង្រៀនយើងអំពីព្រះ ហើយនិងរាស្ត្ររបស់ទ្រង់យ៉ាងដូចម្តេចដែរ?**

________________________________________________________________

________________________________________________________________

ព្រះគម្ពីរបានបង្រៀនយើងថា ព្រះបានបង្កើតរបស់គ្រប់យ៉ាង។ ភាពស្រស់ស្អាតនៃផ្ទៃមេឃ បានបង្ហាញយើងថា ព្រះរបស់យើងទ្រង់មានអំណាចអស្ចារ្យណាស់ (ទំនុកតម្កើង ១៩:១-៤; ទំនុកតម្កើង ៩៧:៦)។ ព្រះនាមរបស់ទ្រង់ខ្ពស់លើអស់នាមនៅលើផែនដីនេះ (ទំនុកតម្កើង ៨:១, ៩)។ ព្រះអម្ចាស់ទ្រង់គ្មានដើមកំណើត (ទំនុកតម្កើង ៩៣:២) និងគ្មានទីបញ្ចប់នោះឡើយ (ទំនុកតម្កើង ១០២:២៥-២៧)។ ព្រះទ្រង់មានព្រះជន្មរស់នៅជារៀងរហូត។ ហើយទ្រង់ក៏មានអំណាចលើអស់ទាំង«ព្រះក្លែងក្លាយ» របស់ជាតិសាសន៍ដទៃផងដែរ។ ដ្បិត «ព្រះរបស់គេ នោះសុទ្ធតែជារូប ធ្វើពីប្រាក់ និងមាសជាស្នាដៃដែលមនុស្សធ្វើ» (ទំនុកតម្កើង ១១៥:៤) ប៉ុណ្ណោះ មិនអាចធ្វើអ្វីបានឡើយ។ រូបសំណាកទាំងនេះ «មានដៃ តែចាប់កាន់មិនបាន មានជើង តែមិនចេះដើរឡើយ» (ទំនុកតម្កើង ១១៥:៧)។ ប៉ុន្តែ «អស់ទាំងទីជម្រៅនៃផែនដីនៅក្នុងព្រះហស្តទ្រង់ ហើយកំពូលភ្នំទាំងប៉ុន្មាន សុទ្ធតែជារបស់ផងទ្រង់ដែរ សមុទ្រជារបស់ផងទ្រង់ គឺទ្រង់ដែលបានបង្កើតមក ហើយគឺព្រះហស្តទ្រង់ដែលបានសូនធ្វើដីគោក» (ទំនុកតម្កើង ៩៥:៤, ៥)។

បទគម្ពីរទំនុកតម្កើង ឬកំណាព្យមួយចំនួនបានបង្រៀនសាសន៍អ៊ីស្រាអែលថា ព្រះគឺជាម្ចាស់នៃធម្មជាតិ។ រីឯសាសន៍ដទៃទៀត បានថ្វាយបង្គំធម្មជាតិទុកជាព្រះរបស់ពួកគេវិញ។ បទគម្ពីរទំនុកតម្កើង ជំពូក២៩, ទំនុកតម្កើង ជំពូក៩៣, ទំនុកតម្កើង ជំពូក១០៤ បានប្រាប់យើងថា ព្រះអម្ចាស់គឺជាស្តេចគ្រប់គ្រងផែនដីទាំងមូល។ ព្រះអម្ចាស់ទ្រង់មានអំណាចលើសបុគ្គលណា ឬព្រះណាទាំងអស់។ មិនមែនរូបសំណាកទាំងអស់សុទ្ធតែបានធ្វើឡើងពីថ្ម ឈើ ឬមាសនោះឡើយ។ ពីព្រោះអ្នកខ្លះបានថ្វាយបង្គំគោលគំនិតខុសឆ្គងទុកជាព្រះក្លែងក្លាយរបស់ពួកគេ។ មនុស្សទាំងនេះបានជឿទុកចិត្តទៅលើខ្លួនឯង ជាជាងជឿទុកចិត្តទៅលើព្រះ។ គោលគំនិតខុសឆ្គងនេះក៏ប្រៀបដូចជាការលុតជង្គង់ថ្វាយបង្គំរូបសំណាកយ៉ាងដូច្នោះដែរ។ បទគម្ពីរទំនុកតម្កើង ជំពូក១០០:៣ បានប្រាប់យើងថា ព្រះគឺជាបុគ្គលតែម្នាក់គត់ ដែលយើងគួរតែថ្វាយបង្គំ ពីព្រោះទ្រង់គឺជាព្រះអាទិកររបស់យើង។

អ្វីៗគ្រប់យ៉ាងដែលព្រះបានបង្កើតមក បានបង្ហាញយើងពីសេចក្តីស្រឡាញ់របស់ទ្រង់។ របស់គ្រប់យ៉ាងដែលមាននៅលើផ្ទៃមេឃ និងនៅលើផែនដីនេះបានជំពាក់ព្រះនូវជីវិតដែលទ្រង់បានប្រទានឱ្យ។ ព្រះបានទ្រទ្រង់អ្វីៗគ្រប់យ៉ាងឱ្យមានជីវិតរស់ ហើយទ្រង់ក៏នៅតែបន្តផ្គត់ផ្គង់របស់ទាំងនោះផងដែរ (ទំនុកតម្កើង ៩៥:៧; ទំនុកតម្កើង ១៤៧:៤-៩)។ ព្រះក៏បានជ្រើសរើសសាសន៍អ៊ីស្រាអែលឱ្យធ្វើជារាស្ត្រ និងធ្វើជាចៀមរបស់ទ្រង់ផងដែរ (ទំនុកតម្កើង ១០០:៣)។ គោលគំនិតទាំង២នេះបានបង្ហាញយើងថា ព្រះមានព្រះហឫទ័យចង់នៅជាប់ជាមួយនឹងយើងណាស់។ ម្ល៉ោះហើយ ទ្រង់គឺជាអ្នកដែលស័ក្តិសមនឹងទទួលបាននូវការថ្វាយបង្គំ និងការជឿទុកចិត្តពីយើងណាស់។ នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង កវីបានប្រាប់ឱ្យភាវៈរស់នៅលើផែនដីនេះទាំងអស់បានសរសើរតម្កើងព្រះ និងមានពេញទៅដោយសេចក្តីអំណរ។ មែនហើយ ផែនដីនេះមិនមែនជាផែនដីល្អឥតខ្ចោះនោះទេ។ ប៉ុន្តែ យើងបានឃើញសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះតាមរយៈអ្វីៗគ្រប់យ៉ាងដែលទ្រង់បានបង្កើតមក។ នេះហើយគឺជាមូលហេតុដែលកណ្ឌគម្ពីរទំនុកតម្កើងបានប្រាប់យើងថា យើងគួរតែថ្វាយបង្គំព្រះនោះ។

**«នោះតើមនុស្សជាអ្វី ដែលទ្រង់នឹករឭកដល់គេ ហើយកូនមនុស្សផង ដែលទ្រង់ប្រោសដូច្នេះ» (ទំនុកតម្កើង ៨:៤)។ តើខនេះបានបង្រៀនលោកអ្នកអំពីសេចក្តីស្រឡាញ់របស់ព្រះយ៉ាងដូចម្តេចដែរ? ព្រះគម្ពីរបានចែងថា ព្រះ «ទ្រង់រាប់ចំនួននៃអស់ទាំងផ្កាយក៏ហៅបានតាមឈ្មោះទាំងអស់» (ទំនុកតម្កើង ១៤៧:៤)។ តើលោកអ្នកគិតថា ព្រះបានយកព្រះទ័យទុកដាក់ចំពោះលោកអ្នកលើសអស់ទាំងផ្កាយនោះច្រើនប៉ុនណាដែរ?**

# ព្រះអម្ចាស់គឺជាស្ដេច

គោលគំនិតដែលថា ព្រះបានបង្កើតអ្វីៗគ្រប់យ៉ាង មានទំនាក់ទំនងជិតស្និទ្ធជាមួយការបង្រៀនដែលថា ព្រះទ្រង់គឺជាស្ដេច។ ខគម្ពីរទំនុកតម្កើង ៩៣:១, ទំនុកតម្កើង ៩៦:១០, ទំនុកតម្កើង ៩៧:១ និងទំនុកតម្កើង ៩៩:១ បានប្រកាសថា៖ «ព្រះអម្ចាស់គឺជាស្ដេច»។ យើងបានឃើញគោលគំនិតនេះនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងទាំងមូល។

ព្រះអម្ចាស់ទ្រង់មានកិត្តិនាម មានសិរីលម្អ និងមានអំណាចជាស្ដេច (ទំនុកតម្កើង ៩៣:១; ទំនុកតម្កើង ១០៤:១)។ «មានពពក និងសេចក្ដីងងឹតបាំងជុំវិញទ្រង់» (ទំនុកតម្កើង ៩៧:២)។ ព្រះអម្ចាស់ក៏បានហ៊ុមព្រះអង្គទ្រង់ «ដោយពន្លឺ ដូចជាទ្រង់ព្រះភូសា» (ទំនុកតម្កើង ១០៤:២) ដូច្នោះដែរ។ រូបស័ព្ទទាំងនេះបានបង្រៀនយើងថា ព្រះអម្ចាស់ទ្រង់មានអំណាចខ្លាំងពូកែជាទីបំផុត។ រូបស័ព្ទទាំងនេះក៏បានបង្ហាញយើងថា អំណាច និងសិរីលម្អនៃភាពជាស្ដេចរបស់ទ្រង់គឺលើសពីអ្វីៗទាំងអស់ដែលគំនិតយើងអាចគិតឃើញបាន។

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក៩៧។ តើខគម្ពីរទំនុកតម្កើង ៩៧:២, ១០ បានប្រាប់យើងអំពីព្រះជាស្ដេចនោះយ៉ាងដូចម្ដេចដែរ? តើនគររបស់ព្រះអម្ចាស់មានទំហំប៉ុនណាដែរ? (សូមអានខគម្ពីរទំនុកតម្កើង ៩៧:១, ៥, ៩ សម្រាប់ចម្លើយ)។**

______________________________________________________________

______________________________________________________________

ព្រះអម្ចាស់គឺជាស្ដេចគ្រប់គ្រងផែនដីទាំងមូល (ទំនុកតម្កើង ៤៧:៦-៩)។ នៅក្នុងនាមជាស្ដេចព្រះយេស៊ូវបានបង្ហាញព្រះគុណរបស់ទ្រង់ដល់យើង។ ទ្រង់យុត្តិធម៌ និងបរិសុទ្ធ។ ទ្រង់បានការពារផែនដីនេះ។ ទ្រង់បានធ្វើនូវអ្វីដែលត្រឹមត្រូវសម្រាប់រាស្ត្ររបស់ទ្រង់ (ទំនុកតម្កើង ៩៨:៣; ទំនុកតម្កើង ៩៩:៤)។ ទ្រង់គឺជាព្រះអង្គសង្គ្រោះរបស់យើង (ទំនុកតម្កើង ៩៨:២) និងជាចៅក្រមរបស់យើង (ទំនុកតម្កើង ៩៦:១០)។ អ្វីៗដែលព្រះបានបង្កើត បានបង្ហាញយើងពីនគររបស់ទ្រង់ (ទំនុកតម្កើង ៩៦:៥)។ នគររបស់ព្រះគឺជានគរដ៏នៅអស់កល្បជានិច្ច។ គ្មាននគរណាមានអំណាចដូចជានគររបស់ទ្រង់នោះឡើយ (ទំនុកតម្កើង ៤៥:៦; ទំនុកតម្កើង ៩៣:១; ទំនុកតម្កើង ១០៣:១៩)។ នគររបស់ព្រះបានបង្រួបបង្រួមភាវៈទាំងអស់ឱ្យសរសើរតម្កើងដល់ព្រះ (ទំនុកតម្កើង ៩៦:១០; ទំនុកតម្កើង ៩៧:១; ទំនុកតម្កើង ៩៩:១; ទំនុកតម្កើង ១៤៥:១១-១៣)។

ប៉ុន្តែ មិនមែនមនុស្សទាំងអស់សុទ្ធតែនិយាយថា ឥឡូវនេះ ព្រះអម្ចាស់គឺជាស្ដេចនោះឡើយ។ មនុស្សអាក្រក់បានបដិសេធមិនព្រមលើកតម្កើងព្រះជាស្ដេច (ទំនុកតម្កើង ១៤:១; ទំនុកតម្កើង ៧៤:៣-២២)។ លើសពីនេះទៅទៀតនោះ មនុស្សអាក្រក់ជាច្រើននាក់បានរីករាយជាមួយនឹងភាពជោគជ័យទាំងឡាយរបស់ពួកគេ។ ប៉ុន្តែ ព្រះបានអត់ធ្មត់ជាមួយនឹងពួកគេ។ កវីដែលបានសរសេរកណ្ឌគម្ពីរទំនុក-ដំកើងកំពុងតែនៅមិនស្ងៀម នៅពេលដែលពួកគេបានឃើញថា ព្រះកំពុងអត់ធ្មត់ជាមួយនឹងរាស្ត្ររបស់ទ្រង់នោះ។ ប៉ុន្តែ កវីនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានជឿទុកចិត្តទៅលើអំណាចរបស់ព្រះ ព្រមទាំងជឿជាក់ទៅលើកិច្ចការជាចៅក្រមដ៏បរិសុទ្ធរបស់ទ្រង់នោះដែរ (ទំនុកតម្កើង ៦៨:២១; ទំនុកតម្កើង ៧៣:១៧-២០)។ សព្វថ្ងៃនេះដែររាស្ត្ររបស់ព្រះបានជឿទុកចិត្តទៅលើកិច្ចការសង្គ្រោះដែលព្រះមានសម្រាប់ពួកគេនោះដែរ (ម៉ាថាយ ១២:២៦-២៨)។ ពួកគេបានរង់ចាំឱ្យទ្រង់យាងមកវិញជាលើកទី២នៅក្នុងនាមជាស្ដេចផងដែរ (កូរិនថូសទី១ ១៥:២០-២៨)។

«ឱពួកអ្នកដែលស្រឡាញ់ព្រះយេហូវ៉ាអើយ ចូរស្អប់ការអាក្រក់ចុះ» (ទំនុកតម្កើង ៩៧:១០)។ **តើហេតុអ្វីបានជាសេចក្ដីស្រឡាញ់ដែលយើងមានចំពោះព្រះបានធ្វើឱ្យយើងស្អប់សេចក្ដីអាក្រក់យ៉ាងដូច្នេះ? តើសេចក្ដីស្រឡាញ់ដែលយើងមានចំពោះព្រះមានទំនាក់ទំនងអ្វីដែរ ជាមួយនឹងការស្អប់សេចក្ដីអាក្រក់របស់យើងនោះ?**

# ព្រះគឺជាចៅក្រម

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក៧៥។ បទគម្ពីរទំនុកតម្កើងនេះបានបង្ហាញយើងថា មនុស្សអាក្រក់ចូលចិត្តអួតជាទីបំផុត។ តើហេតុអ្វីបានជាព្រះព្រមានមិនឱ្យពួកគេមានអំនួតយ៉ាងដូច្នេះ?**

---

---

ព្រះអម្ចាស់គឺជាស្តេចដ៏មានអំណាចបំផុត។ ទ្រង់ក៏ជាអ្នកបង្កើតច្បាប់ (ទំនុកតម្កើង ៩៩:៧) និងជាចៅក្រមផងដែរ (ទំនុកតម្កើង ៩៨:៩; ទំនុកតម្កើង ៩៧:២)។ ព្រះអម្ចាស់នឹងជំនុំជម្រះមនុស្សអាក្រក់ដែលបានវាយប្រហារនគររបស់ទ្រង់ (ទំនុកតម្កើង ៧៥:៨-១០; ទំនុកតម្កើង ៩៦:១៣)។

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៧៥ រូបស័ព្ទជាច្រើនបានបង្ហាញយើងថា ព្រះនឹងបំផ្លាញមនុស្សអាក្រក់។ នៅក្នុងខគម្ពីរទំនុកតម្កើង ៧៥:៨ យើងបានឃើញពែងមួយដែលមានទឹកទំពាំងបាយជូរក្រហមនៅក្នុងនោះ។ ពែងនេះបានបង្ហាញយើងថា ព្រះបានក្រោធជាខ្លាំង ដោយព្រោះអំពើបាប ហើយនិងការឈឺចាប់ (យេរេមា ២៥:១៥; វិវរណៈ ១៤:១០)។ យោងទៅតាមខគម្ពីរទំនុកតម្កើង ៧៥:១០ ព្រះនឹងបំផ្លាញមនុស្សអាក្រក់ ប៉ុន្តែ ទ្រង់នឹងលើកតម្កើងរាស្ត្ររបស់ទ្រង់ដែលបានស្រឡាញ់ និងគោរពដល់ទ្រង់វិញ។ ដ្បិតទ្រង់នឹងជ្រើសរើសពេលវេលាស័ក្តិសមមួយ (ទំនុកតម្កើង ៧៥:២) ដែលទ្រង់ត្រូវជំនុំជម្រះមនុស្សគ្រប់គ្នា។ ព្រះគម្ពីរបានបង្រៀនយើងថា កិច្ចការរបស់ព្រះជាចៅក្រមនឹងបានកើតឡើងនៅចុងបញ្ចប់នៃពេលវេលា (ទំនុកតម្កើង ៩៦:១៣; កូរិនថូសទី១ ១៥:២៣-២៦)។

ផ្នែកនៅក្នុងកិច្ចការរបស់ព្រះជាចៅក្រមរួមបញ្ចូលទាំងការទតមើលនៅក្នុងចិត្តរបស់មនុស្សលោកផងដែរ។ សូមអានខគម្ពីរទំនុកតម្កើង ១៤:២។ ខនេះបានជួយឱ្យយើងនឹកចាំពីខគម្ពីរលោកុប្បត្តិ ៦:៥, ៨។ ខទាំង២នេះបានបង្ហាញយើងថា ព្រះនឹងសាកល្បងជីវិតរបស់មនុស្សលោក ដើម្បីសង្គ្រោះពួកគេឱ្យបានកាន់តែច្រើនតាមដែលទ្រង់អាចធ្វើទៅបាន។ ទ្រង់នឹងធ្វើកិច្ចការនេះ មុនពេលដែលទ្រង់យាងមកម្តងទៀត ដើម្បីប្រទានរង្វាន់ដល់រាស្ត្ររបស់ទ្រង់ និងដាក់ទោសមនុស្សអាក្រក់។

តើព្រះនឹងធ្វើកិច្ចការពិសេសជាចៅក្រមនេះដោយរបៀបណា?

ជាដំបូង ព្រះបានសង្គ្រោះរាស្ត្ររបស់ទ្រង់ចេញពីសេចក្តីអាក្រក់ ដែលកំពុងតែធ្វើបាបពួកគេ (ទំនុកតម្កើង ៩៧:១០; ទំនុកតម្កើង ១៤៦:៩)។ ព្រះបានប្រទានជីវិតអស់កល្បដល់សិស្សរបស់ទ្រង់ណាដែលគ្មានអំនួតនៅក្នុងចិត្តរបស់ពួកគេ (ទំនុកតម្កើង ១៤៩:៤)។ បន្ទាប់មក មនុស្សអាក្រក់នឹងត្រូវវិនាសជារៀងរហូតតទៅ (ទំនុកតម្កើង ៩៧:៣)។ ព្រះអម្ចាស់គឺជាព្រះនៃសេចក្តីលើកលែងទោស។ ទន្ទឹមគ្នានេះ ទ្រង់ក៏បានដាក់ទោសអំពើបាបនៃមនុស្សគ្រប់គ្នាផងដែរ។ កវីខ្លះនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានពិពណ៌នាថា អាវុធរបស់មនុស្សលោកមិនអាចទាស់នឹងចៅក្រមពីនគរស្ថានសួគ៌បានឡើយ (ទំនុកតម្កើង ៩៩:៨)។ ទាំងមនុស្សអាក្រក់ទាំងមនុស្សបរិសុទ្ធត្រូវតែពន្យល់ព្រះនូវហេតុផលនៃទង្វើដែលពួកគេបានធ្វើនៅក្នុងជីវិតនេះ។

កិច្ចការរបស់ព្រះជាចៅក្រមបានចាប់ផ្តើមឡើងជាមួយនឹងរាស្ត្ររបស់ទ្រង់ជាមុនសិន។ បន្ទាប់មក ព្រះបានជំនុំជម្រះមនុស្សដទៃទៀតនៅលើផែនដីនេះ (ចោទិយកថា ៣២:៣៦; ពេត្រុសទី១ ៤:១៧)។ កវីម្នាក់នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានសូមឱ្យព្រះជំនុំជម្រះគាត់។ ទន្ទឹមគ្នានេះ កវីម្នាក់នេះក៏បានពឹងផ្អែកទៅលើជីវិតដ៏បរិសុទ្ធរបស់ព្រះ និងព្រះគុណរបស់ទ្រង់ ដើម្បីការពារគាត់ផងដែរ (ទំនុកតម្កើង ៧:៨-១១; ទំនុកតម្កើង១៣៩:២៣, ២៤)។

**កណ្ឌគម្ពីរទំនុកតម្កើងបានអញ្ជើញយើងឱ្យទទួលយកអារម្មណ៍ត្រេកអរដែលព្រះគឺជាចៅក្រមរបស់យើង (ទំនុកតម្កើង៦៧:៤; ទំនុកតម្កើង៩៦:១០-១៣; ទំនុកតម្កើង ៩៨:៤-៩)។ តើហេតុអ្វីបានជាកិច្ចការចៅក្រមរបស់ព្រះគឺជាដំណឹងល្អសម្រាប់មនុស្សគ្រប់គ្នាយ៉ាងដូច្នេះ?**

## ការនឹកចាំអំពីសេចក្ដីសន្យារបស់ព្រះ

**នៅក្នុងខគម្ពីរដានីយ៉ែល ៧:៩, ១០ យើងបានអានអំពីគ្រាមួយ នៅពេលដែលព្រះត្រូវជំនុំជម្រះមនុស្សលោកទាំងអស់ ទាំងមនុស្សស្លាប់ទាំងមនុស្សរស់។ តើហេតុអ្វីបានជារាស្ត្ររបស់ព្រះបានទទួលសេចក្ដីសុខសាន្តជាមួយនឹងព្រះ នៅក្នុងអំឡុងពេលនេះយ៉ាងដូច្នេះ? សូមអានខគម្ពីរទំនុកតម្កើង ៩៤:១៤ និងទំនុកតម្កើង ១០៥:៧-១០ សម្រាប់ចម្លើយ។**

---

---

រាស្ត្ររបស់ព្រះអាចជឿទុកចិត្តបានថា ព្រះនឹងសង្គ្រោះពួកគេ ដោយសារតែទ្រង់បានគង់នៅក្នុង «រោងឧបោសថរបស់ទ្រង់នៅក្រុងសាឡិម ហើយទីលំនៅទ្រង់នៅភ្នំស៊ីយ៉ូន» (ទំនុកតម្កើង ៩៤:១៤; ទំនុកតម្កើង ១០៥:៨-១០)។ រាស្ត្ររបស់ព្រះមានតម្លៃចំពោះទ្រង់ជាទីបំផុត។ ព្រះបានបំពេញកិច្ចការដើម្បីការពាររាស្ត្ររបស់ទ្រង់ឱ្យមានសុវត្ថិភាពនៅក្នុងទ្រង់ (ទំនុកតម្កើង ១០៣:៣)។ ព្រះបានបង្រៀន និងប្រទានពរដល់រាស្ត្ររបស់ទ្រង់។ ទ្រង់បានធ្វើឱ្យពួកគេរឹងមាំ (ទំនុកតម្កើង ២៥:៨-១១; ទំនុកតម្កើង ២៩:១១; ទំនុកតម្កើង ១០៥:២៤)។ ព្រះបានជំនុំជម្រះជំនួសឱ្យរាស្ត្ររបស់ទ្រង់។ ព្រះបានជួយឱ្យពួកគេក្លាយមកជាមនុស្សបរិសុទ្ធ។ ទ្រង់បានបង្ហាញរាស្ត្ររបស់ទ្រង់ថា ទ្រង់បានយកព្រះទ័យទុកដាក់ចំពោះពួកគេ (ទំនុកតម្កើង ៩៤:៨-១៥)។

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក១៥ យើងបានអានអំពីប្រវត្តិសាសន៍នៃសាសន៍ដទៃ។ ព្រះបានគង់នៅក្នុងហេតុការណ៍ទាំងអស់ដែលបានកើតឡើង មិនថា ជាហេតុការណ៍អាក្រក់ ឬជាហេតុការណ៍ល្អនោះទេ។ ព្រះបានដឹកនាំលោកយ៉ូសែបទៅកាន់ស្រុកអេស៊ីព្ទ។ ហើយទ្រង់ក៏បានប្រើឱ្យលោកយ៉ូសែបទៅសង្គ្រោះក្រុមគ្រួសាររបស់គាត់ ហើយនិងសាសន៍ដទៃឱ្យរួចផុតពីគ្រោះទុរភិក្ខ (ទំនុកតម្កើង ១០៥:១៦-២៤)។ ព្រះអម្ចាស់បានជ្រើសរើសលោកម៉ូសេឱ្យដឹកនាំរាស្ត្ររបស់ទ្រង់ចេញពីស្រុកអេស៊ីព្ទ។ នៅពេលនោះ ព្រះបានធ្វើការអស្ចារ្យជាច្រើន ដើម្បីសង្គ្រោះរាស្ត្ររបស់ទ្រង់ (ទំនុកតម្កើង ១០៥:២៥-៣៨)។

ព្រះអម្ចាស់បានប្រទានទឹកដីសន្យាដល់រាស្ត្ររបស់ទ្រង់ (ទំនុកតម្កើង ១០៥:១១, ៤៤)។ ព្រះបានការពាររាស្ត្ររបស់ទ្រង់ (ទំនុកតម្កើង ១០៥:១២-១៥)។ ព្រះបានធ្វើឱ្យរាស្ត្ររបស់ទ្រង់មានចំនួនច្រើនឡើង (ទំនុកតម្កើង ១០៥:៣៧, ៣៨)។ ព្រះបានប្រទានឱ្យរាស្ត្ររបស់ទ្រង់នូវអ្វីដែលពួកគេត្រូវការជារៀងរាល់ថ្ងៃនៅក្នុងការរស់នៅរបស់ពួកគេ (ទំនុកតម្កើង ១០៥:៣៩-៤១)។ ព្រះអម្ចាស់បានគ្រប់គ្រងអ្វីៗគ្រប់យ៉ាងដែលបានកើតឡើងដល់រាស្ត្ររបស់ទ្រង់។ ដូច្នេះហើយ កវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើងតែងតែមានបំណងចង់ឱ្យរាស្ត្ររបស់ទ្រង់នឹកចាំអំពីសេចក្ដីពិតរបស់ពួកគេជានិច្ច។

នៅពេលដែលព្រះនឹកចាំពីសេចក្ដីសន្យារបស់ទ្រង់ មានន័យថា ទ្រង់បានធ្វើលើសពីការគិតអំពីសេចក្ដីសន្យានោះទៅទៀត។ ពោលគឺទ្រង់បានបញ្ចេញជាសកម្មភាព តាមរយៈការជួយដល់រាស្ត្ររបស់ទ្រង់វិញ (លោកុប្បត្តិ ៨:១; ទំនុកតម្កើង ៩៨:៣; ទំនុកតម្កើង ១០៥:៤២-៤៤)។ តើរាស្ត្ររបស់ព្រះបាននឹកចាំពីទ្រង់ដោយរបៀបណា? គឺដោយការលើកតម្កើងទ្រង់នេះឯង។

ព្រះបានបង្គាប់ឱ្យរាស្ត្ររបស់ទ្រង់គោរពបញ្ញត្តរបស់ទ្រង់ (ទំនុកតម្កើង ៧៨:៥-៧; ទំនុកតម្កើង ១០៥:៤៥)។ ព្រះក៏ចង់ឱ្យសាសន៍អ៊ីស្រាអែលប្រាប់អ្នកដទៃអំពីទ្រង់ផងដែរ។ ព្រះអម្ចាស់ចង់ឱ្យមនុស្សគ្រប់គ្នាចូលរួមត្រេកអរព្រះពរនៃសេចក្ដីសន្យារបស់ទ្រង់ជាមួយនឹងសាសន៍អ៊ីស្រាអែល (ទំនុកតម្កើង ១០៥:១, ២)។ បន្ទាប់មក ព្រះក៏អាចការពារពួកគេផងដែរ (ទំនុកតម្កើង ៨៩:២៨-៣៤)។

**តើហេតុអ្វីបានជាសេចក្ដីសន្យាដែលព្រះបានតាំងឡើងជាមួយនឹងសាសន៍អ៊ីស្រាអែលក៏ជាសេចក្ដីសន្យាសម្រាប់យើងដែរយ៉ាងដូច្នេះ? តើព្រះយេស៊ូវបានប្រទានអ្វីខ្លះដល់យើង ដើម្បីជួយឱ្យយើងឆ្លើយសំណួរនេះបាននោះ? គន្លឹះ៖ សូមអានខគម្ពីរកាឡាទី ៣:២៦-២៩។**

# ការបង្រៀនរបស់ព្រះអម្ចាស់គឺការបង្រៀនដ៏ល្អឥតខ្ចោះ

**សូមអានខគម្ពីរទំនុកតម្កើង ១៩:៧; ទំនុកតម្កើង ៩៣:៥; ទំនុកតម្កើង ១១៩:១៦៥; ទំនុកតម្កើង ១:២, ៦; ទំនុកតម្កើង ១៨:៣០ និងទំនុកតម្កើង ២៥:១០។ តើនៅក្នុងខទាំងនេះ យើងបានឃើញសារដូចគ្នានោះអ្វីដែរ?**

________________________________________________________________________

________________________________________________________________________

ព្រះអម្ចាស់គឺជាអ្នកបង្កើតយើងមក។ ទ្រង់គឺជាស្តេច និងជាចៅក្រមរបស់យើង។ ទ្រង់បានគ្រប់គ្រងផែនដីនេះ។ សេចក្តីពិតនៃព្រះគម្ពីរទាំងនេះបានជួយឱ្យយើងជឿទុកចិត្តទៅលើបញ្ញត្ត និងការបង្រៀនរបស់ទ្រង់។ បញ្ញត្តរបស់ព្រះបានបង្រៀនរាស្ត្ររបស់ទ្រង់អំពីរបៀបថ្វាយបង្គំទ្រង់ និងអំពីរបៀបរស់នៅដើម្បីទ្រង់ (និក្ខមនំ ៣២:១៥)។ បញ្ញត្ត និងការបង្រៀនរបស់ទ្រង់ «នៅអស់កល្បតទៅផង» (ទំនុកតម្កើង ៩៣:៥)។ នគររបស់ព្រះនឹងនៅអស់កល្បជារៀងរហូត។ ទ្រង់បានបង្កើតផែនដីនេះ ហើយទ្រង់ក៏នៅតែបន្តទ្រទ្រង់ផែនដីនេះផងដែរ (ទំនុកតម្កើង ៩៣:១, ២)។ ដូច្នេះហើយ យើងតែងតែអាចពឹងផ្អែកទៅលើព្រះ និងព្រះគុណរបស់ទ្រង់ជានិច្ច។

ដ្បិតព្រះបានមានបន្ទូលថា យើងអាចជឿទុកចិត្តទៅលើសេចក្តីសន្យា និងសេចក្តីបង្គាប់របស់ទ្រង់បាន។ ព្រះក៏បានបង្គាប់ឱ្យរាស្ត្ររបស់ទ្រង់ជឿទុកចិត្តទៅលើទ្រង់ ហើយគោរពតាមបញ្ញត្តរបស់ទ្រង់ផងដែរ។

ទន្ទឹមគ្នានេះ យើងក៏រស់នៅលើផែនដីនេះដែលពេញទៅដោយអំពើបាបផងដែរ។ មានពេលខ្លះច្បាប់របស់មនុស្សលោក ហើយនិងការកាត់ទោសរបស់មនុស្សលោកមិនយុត្តិធម៌នោះទេ។ កវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើងបានប្រើរូបស័ព្ទដ៏ពិសេសមួយ ដើម្បីបង្ហាញថា ច្បាប់របស់មនុស្សលោកជានិច្ចជាកាលមិនយុត្តិធម៌នោះឡើយ។ រង្គើគឺជារូបស័ព្ទមួយដែលពួកគេបានយកមកប្រើ (ទំនុកតម្កើង ១៨:៧; អេសាយ ២៤:១៨-២១)។ បញ្ញត្តរបស់ព្រះបានបង្រៀនរាស្ត្ររបស់ទ្រង់អំពីរបៀបរស់នៅ ដើម្បីកុំឱ្យពួកគេភ័យខ្លាច ឬបាត់បង់ នៅពេលដែលទ្រង់ជំនុំជម្រះពួកគេឡើយ។ រាស្ត្ររបស់ព្រះបានគោរពតាមបញ្ញត្តរបស់ទ្រង់។ ដូច្នេះហើយ គ្មានអ្វីដែលអាច «រង្គើ» ឬបំផ្លាញសេចក្តីជំនឿដែលពួកគេមានចំពោះព្រះ នៅក្នុងអំឡុងពេលនោះបានឡើយ (ទំនុកតម្កើង ១១២:១, ៦, ៧)។ បទគម្ពីរទំនុកតម្កើង ជំពូក ១១៩ បានចែងថា «ពួកអ្នកដែលស្រឡាញ់ក្រឹត្យវិន័យទ្រង់ នោះមានសេចក្តីសុខដ៏លើសលុប ហើយគ្មានហេតុនឹងចំពប់ដួលឡើយ» ទៅក្នុងអំពើបាប (ទំនុកតម្កើង ១១៩:១៦៥)។ ព្រះបានការពាររាស្ត្ររបស់ទ្រង់ ព្រមទាំងដឹកនាំពួកគេនៅក្នុងផ្នែកទាំងអស់នៃជីវិតរបស់ពួកគេផងដែរ (ទំនុកតម្កើង ១:២, ៣, ៦)។

ព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះក៏ប្រៀបដូចជាចង្កៀងមួយយ៉ាងដូច្នោះដែរ។ ពីព្រោះព្រះគម្ពីរបានបង្ហាញរាស្ត្ររបស់ទ្រង់អំពីផ្លូវទៅឯទ្រង់ផងដែរ។ ព្រះគម្ពីរក៏បានការពាររាស្ត្ររបស់ទ្រង់ចេញពីអន្ទាក់នៃខ្មាំងសត្រូវរបស់ពួកគេផងដែរ (ទំនុកតម្កើង ១១៩:១០៥, ១១០)។ តើសេចក្តីសុខសាន្តដែលយើងបានទទួលមកពីការស្រឡាញ់បញ្ញត្តរបស់ព្រះនេះ (ទំនុកតម្កើង ១១៩:១៦៥ មានន័យថា យើងនឹងជួបបញ្ហាដែរឬទេ? ទេ មិនមែនដូច្នោះឡើយ។ អ្វីដែលកណ្ឌគម្ពីរទំនុកតម្កើង ជំពូក១១៩ ចង់បង្ហាញនោះគឺថា យើងនឹងទទួលបានសេចក្តីសុខសាន្តចេញពីការអនុញ្ញាតឱ្យព្រះ និងសេចក្តីស្រឡាញ់របស់ទ្រង់សណ្ឋិតនៅក្នុងចិត្តរបស់យើង។

**តើការរក្សាបញ្ញត្ត និងការធ្វើតាមការបង្រៀនរបស់ទ្រង់បានជួយដល់លោកអ្នកនៅក្នុងជីវិតនេះដោយរបៀបណា? តើលោកអ្នកបានរងទុក្ខដោយការបំពានបញ្ញត្តរបស់ព្រះ និងមិនធ្វើតាមការបង្រៀនរបស់ទ្រង់នោះដោយរបៀបណា?**

**ការសិក្សាបន្ថែម៖** សូមអាន Psalm 86:5 15; Ellen G. White, "God's Love for Man," pages 9-15, in *Steps to Christ*។ យើងបានដឹងថា ព្រះគឺជាសេចក្តីស្រឡាញ់។ តើសេចក្តីពិតនៃព្រះគម្ពីរនៅត្រង់នេះ បានជួយឱ្យយើងកាន់តែប្រសើរឡើង អំពីអត្តសញ្ញាណរបស់ព្រះ និងរបៀបដែលទ្រង់បានជួយដល់រាស្ត្ររបស់ទ្រង់នោះដោយរបៀបណា? តើកណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងយ៉ាងដូចម្តេចដែរ?

នៅពេលដែលយើងបន្តសិក្សាកណ្ឌគម្ពីរទំនុកតម្កើង នោះយើងត្រូវតែគិតអំពីអ្វីដែលកណ្ឌគម្ពីរនេះបានបង្រៀនអំពីសេចក្តីស្រឡាញ់របស់ព្រះ ព្រះគុណ និងផែនការរបស់ទ្រង់ ដើម្បីសង្គ្រោះយើង ហើយនិងបង្កើតផែនដីថ្មី។ «ឈើឆ្កាងបានបង្រៀនយើងអំពីព្រះ និងសេចក្តីស្រឡាញ់របស់ទ្រង់។ កាលណាដែលយើងកាន់តែសិក្សាប្រធានបទនេះ នោះយើងនឹងកាន់តែយល់អំពីសេចក្តីមេត្តា សេចក្តីខ្វល់ខ្វាយ និងសេចក្តីលើកលែងទោសរបស់ព្រះ។ យើងនឹងបានភាពយុត្តិធម៌នៅក្នុងព្រះ និងបញ្ញត្តរបស់ទ្រង់។ យើងក៏នឹងបានឃើញភស្តុតាងនៃសេចក្តីស្រឡាញ់ដ៏គ្មានដែនកំណត់របស់ទ្រង់។ សេចក្តីស្រឡាញ់ដែលទ្រង់មានចំពោះយើងនេះគឺមានទំហំធំជាងសេចក្តីស្រឡាញ់ដែលម្តាយមានចំពោះកូនមិនស្តាប់បង្គាប់របស់គាត់ទៅទៀត»។ ដកស្រង់ពី Ellen G. White, *Steps to Christ*, page 15, adapted។ យោងទៅតាមកណ្ឌគម្ពីរទំនុកតម្កើង តើមនុស្សទាំងនេះបានធ្វើអ្វីខ្លះ នៅពេលដែលព្រះជំនុំជម្រះមនុស្សដែលបានគោរពតាមទ្រង់នោះ? ពួកគេបានចូលមករកព្រះអម្ចាស់ ព្រមទាំងបានបន្តអធិស្ឋានទៅឯទ្រង់ ដើម្បីសុំជំនួយសង្គ្រោះពួកគេផងដែរ។ តើហេតុអ្វី? នោះគឺដោយសារតែពួកគេបានដឹងថា សេចក្តីក្រោធរបស់ព្រះមិនមែនជាសេចក្តីក្រោធតែមួយស្របក់នោះឡើយ។ ប៉ុន្តែ សេចក្តីមេត្តារបស់ទ្រង់គឺនៅអស់កល្បជានិច្ចវិញ (ទំនុកតម្កើង ១០៣:៨)។

សំណួរពិភាក្សា

១. កណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងថា ព្រះគឺជាស្តេច។ ដ្បិតទ្រង់គឺជាអ្នកគ្រប់គ្រងរបស់ទាំងអស់ដែលបានកើតមាននៅលើផែនដីនេះ។ ទន្ទឹមគ្នានេះ តើហេតុអ្វីបានជាយើងត្រូវតែយល់ថា សង្គ្រាមរវាងព្រះនិងសាតាំងកំពុងតែកើតឡើងនៅជុំវិញយើងដូច្នេះ? តើសេចក្តីពិតនៃព្រះគម្ពីរនៅត្រង់នេះបានជួយឱ្យយើងកាន់តែប្រសើរឡើង អំពីមូលហេតុដែលនាំឱ្យមានអំពើបាប និងសេចក្តីរងទុក្ខនៅលើផែនដីនេះដោយរបៀបណា?

២. ព្រះគម្ពីរក៏បានបង្រៀនយើងថា ព្រះបានបង្កើតយើងផងដែរ។ តើការបង្រៀននេះបានជួយឱ្យយើងយល់អំពីអត្តសញ្ញាណរបស់យើង ហើយនិងយល់អំពីរបៀបដែលយើងត្រូវតែថែរក្សារបស់គ្រប់យ៉ាងដែលព្រះបានបង្កើតនៅលើផែនដីនេះដោយរបៀបណា? តើនឹងមានអ្វីកើតឡើង នៅពេលដែលមនុស្សមិនបានធ្វើតាមសេចក្តីបង្រៀនទាំងនេះនោះ? សូមអានខគម្ពីរទំនុកតម្កើង ១០៦:៣៥-៤២ សម្រាប់ចម្លើយ។

៣. តើព្រះក្លែងក្លាយដែលមនុស្សនៅក្នុងសម័យព្រះគម្ពីរបានថ្វាយបង្គំនោះមានបញ្ហាអ្វីដែរ (ទំនុកតម្កើង ១១៥:៤-៨)? ចុះចំណែកព្រះក្លែងក្លាយនៅសម័យនេះ តើលោកអ្នកយល់យ៉ាងណាដែរ? ម្យ៉ាងទៀត តើហេតុអ្វីបានជាព្រះទាំងនេះបង្កគ្រោះថ្នាក់ដល់ទំនាក់ទំនងរវាងយើងជាមួយនឹងព្រះអម្ចាស់យ៉ាងដូច្នេះ?

៤. ព្រះគម្ពីរបានប្រាប់យើងថា កិច្ចការរបស់ព្រះជាចៅក្រមនឹងត្រូវចាប់ផ្តើមជាមួយនឹងរាស្ត្ររបស់ទ្រង់ជាមុនសិន។ ដូច្នេះ តើរាស្ត្ររបស់ព្រះគួរតែរស់នៅបែបយ៉ាងណាដែរ? តើព្រះបានជំនុំជម្រះរាស្ត្ររបស់ទ្រង់ដោយរបៀបណា?

## «ខ្ញុំបានប្រយុទ្ធទាល់តែខ្ញុំបានទទួលជោគជ័យ»

លោកពេត្រ (Pedro) បានភ្ញាក់ផ្អើលជាខ្លាំង ចំពោះការស្វាគមន៍ដែលគាត់បានទទួល នៅពេលដែលគាត់ត្រឡប់មកពីកម្មវិធីថ្វាយបង្គំព្រះនៅក្នុងប្រទេសម៉ូហ្សាំប៊ិក (Mozambigque)។ បងស្រីរបស់គាត់បាននិយាយប្រាប់គាត់ថា «ឯងឈប់ទៅព្រះវិហារសេវេនដេយអាត់វេនទីស្ទទៀតទៅ ពីព្រោះព្រះវិហារហ្នឹងមិនមែនជាព្រះវិហារល្អនោះទេ ដោយសារតែនៅក្នុងព្រះវិហារហ្នឹង មានហោរាក្លែងក្លាយជាច្រើននាក់ បើសិនជាឯងនៅតែមានៈទៅទីហ្នឹងទៀត ឯងមិនអាចរស់នៅទីនេះតទៅទៀតបានឡើយ»។

គំនិតរបស់នាងវ៉រីរីសាំ (Worrisome) មិនអាចបន្ទច់ចិត្តរបស់លោកពេត្របានឡើយ។ បញ្ហាគ្រួសារនៅក្នុងទីក្រុងបេរ៉ាដែលជាស្រុកកំណើតរបស់គាត់ បានបង្ខំឱ្យគាត់ផ្លាស់ទីចម្ងាយ១១៤០គីឡូម៉ែតមកកាន់ផ្ទះបងស្រីរបស់គាត់នៅក្នុងទីក្រុងម៉ាភូតូនៃប្រទេសម៉ូសហ្សាំប៊ិកចម្ងាយ១១៤០គីឡូម៉ែតឯណោះវិញ។ គាត់បានអាក់ខានមិនបានចូលរួមថ្វាយបង្គំព្រះអស់រយៈ២ទៅ៣សប្តាហ៍ ដោយសារតែគាត់ជាអ្នកចំណូលថ្មី ហើយត្រូវស្វែងរកព្រះវិហារអាត់វេនទីស្ទនៅទីនោះ។ ឥឡូវនេះ គាត់បានរកឃើញព្រះវិហារអាត់វេនទីស្ទមួយកន្លែង ដែលគាត់បានថ្វាយបង្គំបានតែម្តងគត់ លុះ នៅពេលដែលគាត់ត្រឡប់មកផ្ទះវិញ បងស្រីរបស់គាត់បានហាមគាត់មិនឱ្យទៅទីនោះម្តងទៀតឡើយ។ ប៉ុន្តែ គាត់បានអធិស្ឋាន ហើយបន្តទៅព្រះវិហារតទៅទៀត។ បងស្រីរបស់គាត់បានផ្តាច់របបអាហាររបស់លោកពេត្រ។ គាត់បានសង្ឃឹមថាការស្រេកឃ្លាននឹងធ្វើឱ្យលោកពេត្រផ្លាស់ប្តូរគំនិតរបស់គាត់។ ប៉ុន្តែ ក្រុមជំនុំបានផ្តល់ស្បៀងអាហារឱ្យគាត់បរិភោគជំនួសវិញ។ នៅពេលព្រឹកថ្ងៃសប្បាតហ៍មួយ ខណៈដែលគាត់កំពុងតែរៀបចំចេញទៅឯព្រះវិហារ នោះបងស្រីគាត់បានប្រាប់គាត់ថា កុំឱ្យត្រឡប់មកផ្ទះវិញទៀត។ នាងបានសួរគាត់ថា «តើឯងនៅតែបដិសេធមិនព្រមស្តាប់ ហើយទទូចចង់ទៅព្រះវិហាររបស់ឯងតទៅទៀតដែរឬទេ? មើលទៅឯង មិនចង់រស់នៅក្នុងផ្ទះនេះតទៅទៀតឡើយ ពីព្រោះឯងមិនចង់ធ្វើតាមច្បាប់នៅក្នុងផ្ទះនេះ»។

លោកពេត្របានអន់ចិត្ត ប៉ុន្តែ គាត់មិនបានបាក់ទឹកចិត្តនោះទេ ដោយគាត់បានដឹងថា «គាត់មិនបានជាប់ពាក់ព័ន្ធនឹងច្បាប់នៅក្នុងផ្ទះរបស់បងស្រីគាត់នោះទេ ប៉ុន្តែ គាត់បានជាប់ពាក់ព័ន្ធនៅក្នុងការប្រយុទ្ធរវាងព្រះយេស៊ូវ ហើយនិងសាតាំងនោះវិញ។ គាត់បាននឹកចាំពីពាក្យពេចន៍ដែលព្រះបានមានបន្ទូលតាមរយៈលោកប៉ុលនៅក្នុងខគម្ពីរអេភេសូរ ៦:១២ យ៉ាងដូច្នេះថា «ដ្បិតយើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ គឺ និងពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្តីងងឹតនៅលោកីយ៍នេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ដែរ»។ គាត់បានទៅព្រះវិហារ ដើម្បីសុំឱ្យប៉ាស្ទ័រ និងក្រុមជំនុំអធិស្ឋានឱ្យគាត់។ នៅក្នុងថ្ងៃដដែល នៅពេលដែលគាត់ត្រឡប់មកផ្ទះវិញ បងស្រីរបស់គាត់បានបណ្តេញគាត់ចេញពីផ្ទះ។ មិត្តភក្តិម្នាក់បានអនុញ្ញាតឱ្យលោកពេត្រស្នាក់២យប់ជាមួយនឹងគាត់។ បន្ទាប់មក ក្រុមជំនុំបានផ្តល់ការងារឱ្យលោកពេត្រធ្វើជាអ្នកមើលថែផ្ទះរបស់គាត់វិញ ដើម្បីដោះដូរជាមួយនឹងថ្លៃស្នាក់នៅ ហើយនិងថ្លៃសិក្សា។

សព្វថ្ងៃនេះ លោកពេត្រនៅតែធ្វើការជាអ្នកមើលថែផ្ទះដដែល ប៉ុន្តែ គាត់មានសេរីភាពនៅក្នុងការថ្វាយបង្គំព្រះជារៀងរាល់ថ្ងៃសប្បាតហ៍ ហើយគាត់ក៏ជឿថា ព្រះកំពុងតែធ្វើការនៅក្នុងចិត្តរបស់បងស្រីដែរ។ មិត្តភាពរបស់ពួកគេបានស្តារឡើងវិញ ហើយបងស្រីរបស់គាត់ក៏លែងហាមគាត់មិនឱ្យទៅព្រះវិហារនៅថ្ងៃសប្បាតហ៍តទៅទៀតដែរ។ លោកពេត្រសង្ឃឹមថា នាងនឹងទទួលយកសេចក្តីពិតនៅក្នុងព្រះគម្ពីរទាំងមូល ហើយនាងក៏នឹងរៀនសរសើរសំណេរបំផុសបំផុលចិត្តរបស់អ្នកស្រីអេឡែន ជីវ៉ៃត៍ផងដែរ។

ខគម្ពីរភីលីព ៤:១៣ បានចែងថា «ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចម្រើនកំឡាំងដល់ខ្ញុំ»។

# ព្រះបានសង្គ្រោះយើងចេញពីបញ្ហាទាំងអស់របស់យើង



ល្ងាចថ្ងៃបរិសុទ្ធ - ថ្ងៃសៅរ៍ ទី២០ ខែមករា ឆ្នាំ២០២៤

**អំណានព្រះគម្ពីរសម្រាប់មេរៀនប្រចាំសប្តាហ៍នេះ៖ ទំនុកតម្កើង ១៣៩:១-១៨; ទំនុកតម្កើង ៤០:១-៣; ទំនុកតម្កើង ១៧:៧-៩; កូរិនថូសទី១ ១០:១-៤; ទំនុកតម្កើង ១១៤; ទំនុកតម្កើង ៣:៤។**

**ខចងចាំ៖ «ឯមនុស្សសុចរិត គេអំពាវនាវ ហើយព្រះយេហូវ៉ាទ្រង់ទទួលស្តាប់ ទ្រង់ក៏ប្រោសគេឲ្យរួចពីគ្រប់សេចក្តីលំបាករបស់គេ»** (ទំនុកតម្កើង ៣៤:១៧)។

កណ្ឌគម្ពីរទំនុកតម្កើងបានប្រាប់យើងជាច្រើនដងថា ព្រះអម្ចាស់គឺជាស្តេច។ ដោយសារតែទ្រង់បានបង្កើតផ្ទៃមេឃ និងផែនដីនេះ។ ហើយទ្រង់ក៏បានទ្រទ្រង់របស់ទាំងអស់ផងដែរ។ ព្រះដ៏មានអំណាចដដែលនេះក៏ជាព្រះអង្គសង្គ្រោះរបស់យើងផងដែរ។

ព្រះអម្ចាស់តែងតែគង់ជាមួយនឹងរាស្ត្ររបស់ទ្រង់ ហើយនិងគង់ជាមួយនឹងរបស់ដែលទ្រង់បានបង្កើតនៅឯស្ថានសួគ៌ និងនៅលើផែនដីនេះ (ទំនុកតម្កើង ៧៣:២៣, ២៥) ពីព្រោះ «ព្រះយេហូវ៉ាទ្រង់បានតាំងបល្ល័ង្កទ្រង់នៅលើស្ថានសួគ៌ ហើយរាជ្យទ្រង់ក៏គ្រប់គ្រងលើទាំងអស់»(ទំនុកតម្កើង ១០៣:១៩)។ ទ្រង់បាន «ជិះនៅលើពពក» (ទំនុកតម្កើង ៦៨:៤, បកប្រែថ្មីពី ERV) ដូចជាជិះសេះយ៉ាងដូច្នោះដែរ។ «ព្រះយេហូវ៉ាទ្រង់គង់នៅជិតនឹងអស់អ្នកដែលអំពាវនាវដល់ទ្រង់ គឺអស់អ្នកដែលអំពាវនាវដល់ទ្រង់ដោយពិតត្រង់» (ទំនុកតម្កើង ១៤៥:៨)។ កណ្ឌគម្ពីរទំនុកតម្កើងបានប្រាប់យើងថា ព្រះអម្ចាស់គឺជាព្រះដ៏មានព្រះជន្មរស់។ ទ្រង់បានសង្គ្រោះមនុស្សដែលបានសុំជំនួយពីទ្រង់ (ទំនុកតម្កើង ៥៥:១៦-២២)។ កណ្ឌគម្ពីរទំនុកតម្កើងត្រូវបានសរសេរថ្វាយព្រះដ៏មានព្រះជន្មរស់ ដែលបានផ្ទៀងស្តាប់ និងឆ្លើយតបទៅនឹងសេចក្តីអធិស្ឋាន។ ហេតុដូច្នេះហើយ បានជាកណ្ឌគម្ពីរទំនុកតម្កើងមានន័យណាស់ចំពោះអ្នកអានកណ្ឌគម្ពីរនេះ។

ព្រះបានត្រាស់ហៅយើងឱ្យមានទំនាក់ទំនងជាមួយនឹងទ្រង់។ តើយើងត្រូវឆ្លើយបែបណាដើម្បីឆ្លើយទៅនឹងការត្រាស់ហៅរបស់ព្រះនេះ? ចម្លើយដែលយើងត្រូវឆ្លើយនោះគឺថា យើងត្រូវតែប្រាថ្នាចង់បានជីវិតនៃសេចក្តីជំនឿទៅលើព្រះឱ្យអស់ពីចិត្តរបស់យើង។ យើងត្រូវគោរពតាមបញ្ញត្តរបស់ទ្រង់ ពីព្រោះទ្រង់នឹងទទួលយកអ្វីផ្សេងក្រៅពីសេចក្តីជំនឿ និងការស្តាប់បង្គាប់របស់យើងនោះឡើយ។ ដ្បិតប្រវត្តិសាស្ត្រនៃសាសន៍អ៊ីស្រាអែលបានបង្ហាញសេចក្តីពិតនៃព្រះគម្ពីរនេះដល់យើង។

# ទ្រង់បានផ្សំគ្រឿងនៃទូលបង្គំនៅក្នុងផ្ទៃម្តាយរបស់ទូលបង្គំ

សូមអានខគម្ពីរទំនុកតម្កើង ១៣៩:១-១៨។ តើកំណាព្យនេះបានបង្ហាញយើងថា ព្រះទ្រង់មានអំណាចខ្លាំងពូកែដោយរបៀបណា (ខ១-៦)? តើកំណាព្យនេះក៏បានបង្ហាញយើងថា ព្រះវិញ្ញាណរបស់ព្រះបានគង់ជាមួយនឹងយើងនៅគ្រប់កន្លែងដែលយើងទៅនោះដោយរបៀបណា (ខ៧-១២)? តើកំណាព្យនេះបានប្រើរូបស័ព្ទអ្វី ដើម្បីបង្ហាញយើងថា ព្រះទ្រង់ល្អនោះ (ខ១៣-១៨)? ជាការពិតណាស់ បទគម្ពីរទំនុកតម្កើង ជំពូក១៣៩ បានបង្ហាញយើងថា ព្រះទ្រង់មានឫទ្ធានុភាព និងមានអំណាចនៅក្នុងការសង្គ្រោះ។ តើសេចក្តីពិតនៃព្រះគម្ពីរនៅត្រង់នេះបានបង្រៀនយើងអំពីព្រះ ហើយនិងសេចក្តីសន្យារបស់ទ្រង់នោះយ៉ាងដូចម្តេចដែរ?

---

តើលោកអ្នកធ្លាប់មានបំណងចង់ជួយអ្នកណាម្នាក់ តែមិនដឹងធ្វើយ៉ាងណាដែរឬទេ? ឬមានអ្នកណាម្នាក់មានបំណងចង់ជួយលោកអ្នក ប៉ុន្តែ បុគ្គលម្នាក់នោះមិនបានយល់នូវអ្វីដែលជាសេចក្តីត្រូវការពិតប្រាកដរបស់លោកអ្នកនោះទេ។ ព្រះបានជ្រាបអំពីអ្វីៗគ្រប់យ៉ាងដែលយើងត្រូវការ។ ទ្រង់បានជ្រាបនូវអ្វីគ្រប់យ៉ាងដែលកំពុងតែកើតឡើងនៅក្នុងជីវិតរបស់យើងនៅពេលតឡូវនេះ។ ដូច្នេះហើយ ទ្រង់ក៏តែងតែជ្រាបអំពីវិធីល្អបំផុត ដើម្បីជួយដល់យើងផងដែរ។ នេះហើយគឺជាមូលហេតុដែលយើងអាចជឿទុកចិត្តទៅលើសេចក្តីសន្យារបស់ព្រះដែលថា ទ្រង់នឹងជួយដល់យើង ព្រមទាំងសង្គ្រោះយើងផងដែរ។

ព្រះបានជ្រាបពីរឿងគ្រប់យ៉ាងអំពីកវីដែលបានសរសេរបទគម្ពីរទំនុកតម្កើង ជំពូក១៣៩។ ព្រះបានទតឃើញកវីម្នាក់នេះ មុនពេលដែលគាត់បានចាប់កំណើតនៅក្នុងផ្ទៃម្តាយរបស់គាត់មកម្ល៉េះ។ ពីព្រោះផ្ទៃម្តាយរបស់គាត់មិនអាចបាំងគាត់ពីព្រះបានឡើយ ទំនុកតម្កើង ១៣៩:១៣, ១៥)។ ព្រះទ្រង់ជ្រាបពីពេលវេលាដែលយើងបានធ្វើរឿងគ្រប់យ៉ាង (ទំនុកតម្កើង១៣៩:២)។ ទ្រង់បានជ្រាបពីការទាំងអស់ដែលយើងបានគិត និងមានអារម្មណ៍ (ទំនុកតម្កើង ១៣៩:២, ៤)។ ហើយព្រះក៏បានជ្រាបពីទីកន្លែងដែលយើងស្នាក់នៅ ហើយទ្រង់ក៏ជ្រាបពីអ្វីដែលយើងបានធ្វើគ្រប់យ៉ាងផងដែរ (ទំនុកតម្កើង ១៣៩:៣)។ ចំណេះដឹងដ៏អស្ចារ្យដែលព្រះបានជ្រាបពីយើងនេះគឺជាផ្នែកនៃទំនាក់ទំនងជិតស្និទ្ធដែលទ្រង់មានជាមួយនឹងរាស្ត្ររបស់ទ្រង់។ ទ្រង់បានជ្រាបអំពីរឿងគ្រប់យ៉ាងអំពីយើង ដោយសារតែទ្រង់បានបង្កើតយើងមក។ ព្រះបានយកព្រះទ័យទុកដាក់ចំពោះយើង។ ហើយការដែលទ្រង់បានយកព្រះទ័យទុកដាក់ចំពោះយើងនេះ ក៏បានបង្ហាញយើងនូវទំហំដែលទ្រង់បានជ្រាបអំពីយើងផងដែរ។

សូមកុំឱ្យលោកអ្នកខ្លាចព្រះ ដោយសារតែទ្រង់បានជ្រាបពីរឿងគ្រប់យ៉ាងអំពីលោកអ្នកនោះទេ តែសូមឱ្យលោកអ្នកបានរីករាយឡើង ដោយសារតែទ្រង់បានជ្រាបពីរឿងគ្រប់យ៉ាងអំពីលោកអ្នក តែទ្រង់នៅតែបន្តស្រឡាញ់លោកអ្នកតទៅមុខទៀត។ សូមឱ្យលោកអ្នកបានរត់ចូលមកក្នុងព្រះហស្តរបស់ព្រះយេស៊ូវ ដោយទទួលយកនូវអ្វីដែលទ្រង់បានធ្វើសម្រាប់យើងនៅត្រង់ឈើឆ្កាង។ នៅពេលដែលយើងមានសេចក្តីជំនឿទៅលើព្រះយេស៊ូវ នោះព្រះនឹងសង្គ្រោះយើង ហើយទទួលយកយើង ដោយព្រះគុណរបស់ទ្រង់ (រ៉ូម ៣:៥, ២១)។

តើមានអ្វីដែលអាចញែកយើងចេញពីព្រះបានដែរឬទេ? តើផ្នូរអាចញែកយើងចេញពីព្រះបានដែរឬទេ? តើយប់អាធ្រាត្រអាចកំបាំងយើងពីទ្រង់បានដែរឬទេ (ទំនុកតម្កើង ១៣៩:៨, ១១, ១២)? ផ្នូរហើយនិងសេចក្តីងងឹតមិនមែនជាកន្លែងដែលព្រះអម្ចាស់បានគង់នៅនោះឡើយ (ទំនុកតម្កើង ៥៦:១៣)។ រូបស័ព្ទទាំងនេះបានបង្ហាញយើងអំពីសេចក្តីពិតនៃព្រះគម្ពីរដ៏សំខាន់មួយ គឺថា ព្រះអាចយាងទៅគ្រប់ទីកន្លែងនៅលើស្ថានសួគ៌ និងនៅលើផែនដីនេះទៅតាមព្រះហឫទ័យទ្រង់។ ព្រះមិនមែនជាផ្នែកមួយនៃផ្កាយ និងផ្ទៃមេឃ ដូចជាមនុស្សមួយចំនួនបានយល់ឃើញនោះឡើយ។ ដ្បិតទ្រង់បានបង្កើតរបស់ទាំងនេះនៅក្នុងនាមជាព្រះអាទិករ និងនៅក្នុងនាមជាអ្នកទ្រទ្រង់ (ហេព្រើរ ១:៣) ព្រះអាចយាងទៅគ្រប់ទីកន្លែងដែលទ្រង់ចង់ទៅ។

ព្រះបានជ្រាបរឿងគ្រប់យ៉ាងអំពីយើង។ ដូច្នេះហើយ ទ្រង់អាចជួយដល់យើង ដោយធ្វើឱ្យយើងក្លាយមកជាមនុស្សថ្មីបាន។ សេចក្តីពិតនៃព្រះគម្ពីរនៅត្រង់នេះបានបំពេញចិត្តរបស់កវីនៅក្នុងជំពូកនេះដោយការជឿទុកចិត្ត និងការសរសើរតម្កើង។ ដ្បិតកវីនៅក្នុងជំពូកនេះក៏មានបំណងចង់ឱ្យព្រះទតមើលនៅក្នុងចិត្តរបស់គាត់ ដោយបង្ហាញឱ្យគាត់បានឃើញអំពើបាបរបស់គាត់ផងដែរ។

# ការជឿទុកចិត្តទៅលើការថែទាំរបស់ព្រះ

**សូមអានខគម្ពីរទំនុកតម្កើង ៤០:១-៣; ទំនុកតម្កើង ៥០:១៥; ទំនុកតម្កើង ៥៥:២២ និង ទំនុកតម្កើង ១២១។ តើព្រះបានបង្ហាញយើងជារៀងរាល់ថ្ងៃថា ទ្រង់បានយកព្រះទ័យទុកដាក់ចំពោះយើងដោយរបៀបណា?**

---

---

ព្រះគម្ពីរបានបង្ហាញយើងថា ព្រះអម្ចាស់គឺជាព្រះដ៏មានព្រះជន្មរស់ ដែលបានសង្គ្រោះដល់អ្នកដែលបានអធិស្ឋានសុំជំនួយពីទ្រង់។ នៅក្នុងខគម្ពីរទំនុកតម្កើង ជំពូក១៦ កវីបានមានប្រសាសន៍ថា «ទូលបង្គំបានតាំងព្រះយេហូវ៉ា នៅមុខទូលបង្គំជាដរាប ហើយដោយព្រោះទ្រង់គង់នៅខាងស្តាំទូលបង្គំ» (ទំនុកតម្កើង ១៦:៨)។ ដូច្នេះហើយ កវីនៅក្នុងជំពូកនេះបានជឿទុកចិត្តទៅលើព្រះ ហើយនិងសុំជំនួយពីទ្រង់ (ទំនុក-តម្កើង ៧:១; ទំនុកតម្កើង ៩:១០)។ ព្រះអម្ចាស់នឹងផ្ទៀងព្រះកាណ៌ស្តាប់កវីម្នាក់នេះ នៅពេលគាត់ជួបនឹង «បញ្ហាធ្ងន់ធ្ងរ» ហើយស្រែកអំពាវនាវសុំជំនួយពីទ្រង់នោះ (ទំនុកតម្កើង ១៣០:១, ២)។ ព្រះទ្រង់មានអំណាចអាចផ្លាស់ប្តូរអ្វីៗគ្រប់យ៉ាងនៅក្នុងជីវិតរបស់យើងបាន។ ទ្រង់អាចដោះស្រាយបញ្ហាទាំងអស់ដែលយើងមាន។ ហេតុដូច្នេះហើយ បានជាកវីនៅក្នុងជំពូកនេះតែងតែមានសង្ឃឹមថា ព្រះនឹងសង្គ្រោះគាត់ជានិច្ច។

បទគម្ពីរទំនុកតម្កើង ជំពូក១២១ បានអបអរចំពោះអំណាចរបស់ព្រះ នៅក្នុងការសង្គ្រោះយើង។ កំណាព្យនេះក៏បានរួមបញ្ចូលសេចក្តីសន្យាដូចខាងក្រោមផងដែរ គឺថា៖ «ទ្រង់នឹងមិនឲ្យជើងអ្នករអិលភ្លាត់ឡើយ ព្រះអង្គដែលរក្សាអ្នក ទ្រង់នឹងមិនផ្ទំរលីវឡើយ» (ទំនុកតម្កើង ១២១:៣)។ ដោយសារតែទ្រង់ជាអ្នករក្សាសាសន៍អ៊ីស្រាអែលនេះហើយ បានជាទ្រង់តែងតែត្រៀមសង្គ្រោះរាស្ត្ររបស់ទ្រង់ជានិច្ច (ទំនុកតម្កើង ១២១:៣, ៤)។

«ព្រះយេហូវ៉ាទ្រង់ជាព្រះដែលថែរក្សាអ្នក ព្រះយេហូវ៉ាទ្រង់ជាម្លប់នៅខាងស្តាំអ្នក នៅពេលថ្ងៃអ្នកនឹងមិនត្រូវព្រះអាទិត្យធ្វើទុក្ខឡើយ ហើយនៅពេលយប់ក៏មិនត្រូវព្រះចន្ទធ្វើទុក្ខដែរ» (ទំនុកតម្កើង ១២១:៥, ៦)។ រូបសព្ទនេះបានជួយឱ្យយើងនឹកចាំអំពី «បង្គោលពពក» នៅក្នុងកណ្ឌគម្ពីរនិក្ខមនំ ១៣:២១, ២២)។ ព្រះអម្ចាស់បានប្រើបង្គោលពពក ដើម្បីដឹកនាំរាស្ត្ររបស់ទ្រង់នៅក្នុងទីរហោស្ថានទៅកាន់ទឹកដីសន្យា។ ទន្ទឹមគ្នានេះ ព្រះអម្ចាស់បានបន្តដឹកនាំរាស្ត្ររបស់ទ្រង់ឱ្យមានសុវត្ថិភាព។

យើងបានឃើញនៅក្នុងខជួចមកហើយថា ព្រះអម្ចាស់បានការពារ និងបាន «ថែរក្សាអ្នក» (ទំនុកតម្កើង ១២១:៥)។ ពីព្រោះព្រះអម្ចាស់ទ្រង់មានអំណាចខ្លាំងពូកែ។ ទ្រង់បានត្រៀមបញ្ចេញសកម្មភាពជាស្រេច ដើម្បីជួយដល់រាស្ត្ររបស់ទ្រង់ (ទំនុកតម្កើង ៧៤:១១; ទំនុកតម្កើង ៨៩:១៣)។ ព្រះអម្ចាស់បានគង់នៅជាប់នឹងរាស្ត្ររបស់ទ្រង់ ព្រមទាំងប្រទានព្រះពរដល់ពួកគេជាមួយនឹងព្រះគុណរបស់ទ្រង់ផងដែរ (ទំនុកតម្កើង ១៦:៨; ទំនុកតម្កើង ១០៩:៣១; ទំនុកតម្កើង ១១០:៥)។

នៅក្នុងខគម្ពីរទំនុកតម្កើង ១២១:៦-៨ យើងបានដឹងថា ព្រះនឹងការពាររាស្ត្ររបស់ទ្រង់ឱ្យផុតពីគ្រោះថ្នាក់ទាំងអស់។ ហើយព្រះក៏នឹងថែរក្សារាស្ត្ររបស់ទ្រង់ឱ្យរួចផុតពីអំពើបាបទាំងអស់ផងដែរ។ «ព្រះអាទិត្យ» និង «ព្រះចន្ទ» មិនអាចធ្វើទុក្ខពួកគេបានឡើយ (ខ៦)។ ពីព្រោះព្រះនឹងថែរក្សាកូនៗរបស់ទ្រង់ នៅពេលដែលពួកគេធ្វើដំណើរចេញពីស្រុកកំណើតរបស់ពួកគេ ហើយទ្រង់ក៏នឹងថែរក្សាពួកគេ នៅពេលដែលពួកគេធ្វើដំណើរត្រឡប់មកវិញផងដែរ។ រូបសព្ទទាំងនេះបានជួយឱ្យយើងយល់ថា ព្រះបានយកព្រះទ័យទុកដាក់ចំពោះយើងជាខ្លាំង។ ទ្រង់តែងតែខិតខំធ្វើការ ដើម្បីថែរក្សាយើងទាំងអស់គ្នា។

តើសេចក្តីសន្យាពីកណ្ឌគម្ពីរទំនុកតម្កើង ជំពូក១២១ នេះ បានបង្រៀនយើងអំពីសេចក្តីជំនឿរបស់កវីដែលបានសរសេរជំពូកនេះយ៉ាងដូចម្តេចដែរ? កវីនៅក្នុងជំពូកនេះបានជឿទុកចិត្តទៅលើការថែរក្សារបស់ព្រះដែលប្រកបទៅដោយសេចក្តីស្រឡាញ់។ ដូច្នេះហើយ យើងក៏គួរតែជឿទុកចិត្តទៅលើព្រះផងដែរ។

**តើមានវិធីណាខ្លះ ដែលលោកអ្នកអាចរៀនបន្ថែមទៀត អំពីព្រះទ័យទុកដាក់ដែលព្រះមានចំពោះលោកអ្នកនោះ? ម៉្យាងទៀត តើលោកអ្នកអាចធ្វើអ្វីខ្លះ ដើម្បីអនុញ្ញាតឱ្យព្រះធ្វើកិច្ចការនៅក្នុងចិត្តរបស់លោកអ្នក និងធ្វើកិច្ចការសម្រាប់លោកអ្នកនោះ?**

# ព្រះគឺជាខែលនៅក្នុងគ្រាអាសន្ន

**តើកវីនៅក្នុងជំពូកនេះបានធ្វើអ្វីខ្លះ នៅពេលដែលគាត់ស្ថិតនៅក្នុងគ្រាអាសន្ននោះ? សូមអានខគម្ពីរទំនុកតម្កើង ១៧:៧-៩; ទំនុកតម្កើង ៣១:១-៣ និងទំនុកតម្កើង ៩១:២-៧ សម្រាប់ចម្លើយ។**

_______________________________________________

កវីនៅក្នុងជំពូកនេះបានរងទុក្ខនូវបញ្ហាជាច្រើន។ នៅក្នុងអំឡុងនៃបទពិសោធន៍របស់គាត់នេះ គាត់បានចូលទៅឯព្រះ ដើម្បីសុំជំនួយ។ ព្រះអម្ចាស់ក៏ប្រៀបដូចជាខែលដូច្នោះដែរ។ ព្រះអម្ចាស់នឹងជួយដល់យើងនៅក្នុងអំឡុងនៃគ្រាទាំងអម្បាលម៉ាន។ នៅក្នុងនេះ ការជឿទុកចិត្តគឺជាជម្រើសមួយ។ នៅពេលណាដែលយើងជឿទុកចិត្តទៅលើព្រះ នោះយើងនឹងទទួលយកទ្រង់ទុកជាព្រះអម្ចាស់គ្រប់គ្រងជីវិតរបស់យើងនៅក្នុងបទពិសោធន៍ទាំងអស់ដែលយើងមាន។ បើសិនជាយើងអាចជឿទុកចិត្តទៅលើព្រះនៅក្នុងអំឡុងនៃគ្រាលំបាក នោះយើងក៏អាចជឿទុកចិត្តទៅលើទ្រង់គ្រប់ពេលវេលាផងដែរ។

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៩១ កវីបានប្រាប់យើងថា៖ «ឯទូលបង្គំ នឹងពោលពីព្រះយេហូវ៉ាថា 'ទ្រង់ជាទីពឹងពំនាក់ ជាបន្ទាយនៃទូលបង្គំ គឺជាព្រះនៃទូលបង្គំហើយ ទូលបង្គំទុកចិត្តនឹងទ្រង់'» (ទំនុក-ដំកើង ៩១:២)។ បទពិសោធន៍ដែលកវីមានជាមួយនឹងព្រះនោះ បានធ្វើឱ្យសេចក្ដីជំនឿរបស់គាត់បានរឹងមាំឡើងនៅពេលឥឡូវនេះ និងនៅពេលអនាគត។ កវីនៅក្នុងជំពូកនេះបានឧទ្ទិសនាមព្រះថាជា «ព្រះដ៏ខ្ពស់បំផុត» និងជា «ព្រះដ៏មានគ្រប់ព្រះចេស្ដា» (ទំនុកតម្កើង ៩១:១)។ កវីនៅក្នុងជំពូកនេះបានដឹងថានៅលើលោកនេះ គ្មានអ្នកណាមានអំណាចខ្លាំងពូកែដូចជាព្រះរបស់គាត់នោះឡើយ។

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៩១ កវីក៏បានប្រាប់យើងអំពីសេចក្ដីសុខសាន្ត និងសុវត្ថិភាពដែលព្រះបានប្រទានដល់យើងផងដែរ។ យើងអាចចូលទៅឯព្រះ ដើម្បីឱ្យបានសម្រាក និងបាន «ជ្រក» (ទំនុកតម្កើង ៩១:១) ដោយមានទ្រង់ជាអ្នកការពារយើង។ ព្រះអម្ចាស់ក៏ប្រៀបដូចជា «បន្ទាយ» (ទំនុកតម្កើង ៩១:២) ផងដែរ។ ទ្រង់ក៏ប្រៀបដូចជា «ជាទីពឹងពំនាក់» (ទំនុកតម្កើង ៩១:២) ដើម្បីជ្រកកោនផងដែរ។ យើងអាចចូលទៅឯទ្រង់បាន នៅពេលដែលយើងជួបនឹងបញ្ហា។ ដ្បិតព្រះអម្ចាស់នឹង «នឹងគ្រងឯងដោយស្លាបទ្រង់» (ទំនុកតម្កើង ៩១:៤)។ ហើយ «ឯងនឹងជ្រកនៅក្រោមចំអេងស្លាបរបស់ទ្រង់» (ទំនុកតម្កើង ៩១:៤)។ ព្រះអម្ចាស់ក៏ប្រៀបដូចជា «ខែល» យ៉ាងដូច្នោះដែរ (ទំនុកតម្កើង៩១:៤)។ នៅក្នុងសម័យព្រះគម្ពីរ បន្ទាយ ចំអេងស្លាប និងខែលគឺជារូបស័ព្ទតំណាងឱ្យសុវត្ថិភាព ឬកន្លែងដែលមានសុវត្ថិភាព។

**សូមអានខគម្ពីរទំនុកតម្កើង ១៧:៨ និងម៉ាថាយ ២៣:៣៧។ តើនៅក្នុងខនេះបានប្រើរូបស័ព្ទអ្វីដែរ? តើរូបស័ព្ទនេះបានបង្រៀនយើងយ៉ាងដូចម្ដេចដែរ?**

_______________________________________________

_______________________________________________

កវីនៅក្នុងជំពូកនេះបានសូមឱ្យព្រះបាំងគាត់ «នៅក្រោមម្លប់ចំអេងស្លាបរបស់ទ្រង់» (ទំនុកតម្កើង ១៧:៨; ទំនុកតម្កើង ៥៧:១; ទំនុកតម្កើង ៦៣:៧)។ រូបស័ព្ទនេះបានបង្ហាញយើងអំពីបក្សីដែលបានការពារកូនៗរបស់វា។ រូបស័ព្ទនេះបានជួយឱ្យយើងមានអារម្មណ៍ថា ខ្លួនមានសុវត្ថិភាព។ ព្រះគម្ពីរក៏បានប្រៀបធៀបព្រះទៅនឹងសត្វឥន្ទ្រីដែលបានការពារកូនៗរបស់វាផងដែរ (និក្ខមនំ ១៩:៤) ព្រមទាំងបានប្រៀបធៀបទ្រង់ទៅនឹងសត្វមាន់ដែលបានការពារកូនរបស់នាង ដោយចំអេងស្លាបរបស់វាផងដែរ (ម៉ាថាយ ២៣:៣៧)។

**នៅពេលដែលរឿងអាក្រក់កើតឡើង នោះយើងនឹងពិបាកជឿថា ព្រះបានគង់នៅជាមួយនឹងយើងណាស់។ ប៉ុន្តែ តើយើងបានដឹងថា ទ្រង់បានគង់នៅជាមួយនឹងយើងនោះដោយរបៀបណាដែរ?**

## ព្រះគឺជាអ្នកការពារ និងជាអ្នកសង្គ្រោះយើង

**សូមអានខគម្ពីរកូរិនថូសទី១ ១០:១-៤។ តើនៅក្នុងខទាំងនេះ លោកប៉ុលបានមានប្រសាសន៍អំពីរឿងនៅក្នុងកណ្ឌគម្ពីរនិក្ខមនំនោះយ៉ាងដូចម្ដេចដែរ? គឺថា លោកប៉ុលបានប្រើរឿងនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង ដើម្បីបង្រៀនយើងអំពីមេរៀនមួយខាងឯវិញ្ញាណ។ តើមេរៀននោះគឺជាមេរៀនអ្វីដែរ?**

---

---

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក១១៤។ តើកំណាព្យនេះបានប្រាប់យើងអំពីគ្រាដែលព្រះបានរំដោះរាស្ត្ររបស់ទ្រង់ចេញពីស្រុកអេស៊ីព្ទនោះយ៉ាងដូចម្ដេចដែរ?**

---

បទគម្ពីរទំនុកតម្កើង ជំពូក១១៤ គឺជាកំណាព្យដ៏ពីរោះមួយ ដែលស្ដីអំពីរបៀបដែលព្រះបានជួយឱ្យរាស្ត្ររបស់ទ្រង់គេចចេញពីស្រុកអេស៊ីព្ទ។ នៅក្នុងគម្ពីរសញ្ញាថ្មី និងគម្ពីរសញ្ញាចាស់ អ្នកសរសេរព្រះគម្ពីរបានយកបទពិសោធន៍ដដែលនេះមកធ្វើជារូបស័ព្ទមួយ ដើម្បីបង្ហាញយើងពីរបៀបដែលព្រះបានសង្គ្រោះរាស្ត្ររបស់ទ្រង់។ នៅក្នុងខគម្ពីរកូរិនថូសទី១ ១០:១-៤ លោកប៉ុលបានចាត់ទុករឿងនៅក្នុងកណ្ឌគម្ពីរនិក្ខមនំទាំងមូលថា ជារូបស័ព្ទមួយតំណាងឱ្យរបៀបដែលព្រះគ្រីស្ទយេស៊ូវបានសង្គ្រោះយើងចេញពីអំពើបាប។

បទគម្ពីរទំនុកតម្កើង ជំពូក១១៤ ក៏បានបង្ហាញយើងថា ទ្រង់បានគ្រប់គ្រងធម្មជាតិ ដោយសារតែទ្រង់បានបង្កើតរបស់ទាំងនោះ។ ការគ្រប់គ្រងរបស់ព្រះនៅលើធម្មជាតិនេះ គឺជារបៀបដែលទ្រង់បានសង្គ្រោះរាស្ត្ររបស់ទ្រង់ចេញពីស្រុកអេស៊ីព្ទ។ សមុទ្រ ទន្លេយ័រដាន់ ភ្នំ និងជ្រលងភ្នំគឺជារូបស័ព្ទតំណាងឱ្យអំណាចនៃធម្មជាតិ និងអំណាចរបស់មនុស្ស។ អំណាចទាំងនេះបានព្យាយាមរាំងផ្លូវមិនឱ្យសាសន៍អ៊ីស្រាអែលចូលទៅក្នុងទឹកដីសន្យាបានឡើយ (ចោទិយកថា ១:៤៤; យ៉ូស្វេ ៣:១៤-១៧)។ ប៉ុន្តែ ព្រះគឺជាអ្នកគ្រប់គ្រងអំណាចនៃធម្មជាតិ និងអំណាចរបស់មនុស្សលោកទាំងអស់។

សព្វថ្ងៃនេះក៏ដូច្នោះដែរ។ ដ្បិតរាស្ត្ររបស់ព្រះនៅគ្រប់សម័យកាលទាំងអស់ និងនៅគ្រប់ទីកន្លែងទាំងអស់កំពុងតែធ្វើដំណើរទៅកាន់ទឹកដីសន្យានៅក្នុងនគរស្ថានសួគ៌។ ផ្លូវទៅទីនោះមានពេញទៅដោយគ្រោះថ្នាក់។ ដូច្នេះហើយ កណ្ឌគម្ពីរទំនុកតម្កើងបានលើកទឹកចិត្តយើងឱ្យងាកចេញពីគ្រោះថ្នាក់នៅតាមជ្រលងភ្នំឆ្ពោះទៅរកអ្នកដែលបានបង្កើតផែនដីនេះវិញ (ទំនុកតម្កើង ១២១:១)។

តើយើងបានឃើញសារនៃបទគម្ពីរទំនុកតម្កើង ជំពូក១១៤ នេះនៅកណ្ឌគម្ពីរណាទៀត? ពោលគឺថា យើងបានឃើញកណ្ឌគម្ពីរនេះនៅក្នុងរឿងរបស់ព្រះយេស៊ូវនៅឯសមុទ្រ នៅពេលដែលទ្រង់បានបង្គាប់ឱ្យខ្យល់ព្យុះស្ងប់ទៅនោះ (ម៉ាថាយ ៨:២៣-២៧)។ ក្រោយមក ព្រះយេស៊ូវបានបង្គាប់ឱ្យក្រុមជំនុំមានចិត្តក្លាហានឡើង ពីព្រោះទ្រង់បានឈ្នះសង្គ្រាមទាស់នឹងអំពើបាបហើយ។ ហើយព្រះយេស៊ូវក៏បានគ្រប់គ្រងផែនដីនេះ ដោយសារតែជ័យជម្នះរបស់ទ្រង់នេះផងដែរ (យ៉ូហាន ១៦:៣៣)។

ព្រះអម្ចាស់ទ្រង់មានអំណាចខ្លាំងពូកែណាស់។ សេចក្ដីពិតនៃព្រះគម្ពីរនេះគួរតែជំរុញឱ្យផែនដីទាំងមូល «ញ័ររន្ធត់» នៅមុខព្រះអម្ចាស់ (ទំនុកតម្កើង ១១៤:៧)។ ពាក្យថា «ញ័ររន្ធត់» គឺជារូបស័ព្ទមួយ។ តើយើងគួរតែយល់ពាក្យនេះដោយរបៀបណា? តើការ «ញ័ររន្ធត់» មានន័យថា យើងគួរតែខ្លាចព្រះដែរឬទេ? ទេ មិនមែនដូច្នោះឡើយ។ ផ្ទុយទៅវិញ ពាក្យថា «ញ័ររន្ធត់» បានបង្ហាញយើងថា យើងគួរតែថ្វាយបង្គំព្រះអម្ចាស់វិញ។ (សូមអានខគម្ពីរទំនុកតម្កើង ៩៦:៩ និងទំនុកតម្កើង ៩៩:១ សម្រាប់គំរូមួយចំនួនបន្ថែមទៀត ដែលបានជួយបកស្រាយគោលគំនិតនេះ)។ ដោយមានព្រះនៅគង់ខាងយើង នោះយើងមិនត្រូវខ្លាចអ្វីទាំងអស់។

**តើនៅក្នុងនាមជាគ្រីស្ទាន យើងអាចនឹងជួបនឹងគ្រោះថ្នាក់អ្វីខ្លះ? តើយើងអាចជឿទុកចិត្តទៅលើព្រះអម្ចាស់ថា ទ្រង់នឹងសង្គ្រោះយើងនោះដោយរបៀបណា?**

# ជំនួយពីរោងឧបោសថរបស់ព្រះនៅឯស្ថានសួគ៌

**តើជំនួយរបស់យើងមានប្រភពមកពីណា? សូមអានខគម្ពីរទំនុកដំកើង ៣:៤; ទំនុកតម្កើង ១៤:៧; ទំនុកតម្កើង ២០:១-៣; ទំនុកតម្កើង ២៧:៥; ទំនុកតម្កើង ៣៦:៨; ទំនុកតម្កើង ៣៦:៨; ទំនុកដំកើង ៦១:៤ និងទំនុកតម្កើង ៦៨:៥, ៣៥ សម្រាប់ចម្លើយ។**

____________________________________________________________

____________________________________________________________

រោងឧបោសថគឺជាកន្លែងជ្រកកោន និងជាកន្លែងផ្តល់ជំនួយ។ រោងឧបោសថរបស់ព្រះបានផ្តល់ជម្រកដល់អ្នកដែលមានបញ្ហា។ ព្រះបានជួយដល់ស្ត្រីមេម៉ាយ និងក្មេងកំព្រាមកពីរោងឧបោសថរបស់ទ្រង់។ ទ្រង់ក៏បានប្រទានអំណាចដល់រាស្ត្ររបស់ទ្រង់ផងដែរ។ យើងបានអានថា «ព្រះទ្រង់បានបំភ្លឺមកពីក្រុងស៊ីយ៉ូន ដែលជាទីក្រុងមានលំអដ៏គ្រប់លក្ខណ៍» (ទំនុកតម្កើង ៥០:២)។ ទីក្រុងស៊ីយ៉ូនគឺជារូបស័ព្ទមួយតំណាងឱ្យរោងឧបោសថរបស់ព្រះ។ ដ្បិតទ្រង់បានប្រទានព្រះពរដល់រាស្ត្ររបស់ទ្រង់ពីទីក្រុងស៊ីយ៉ូននេះឯង (ទំនុកតម្កើង ៨៤:៤; ទំនុកតម្កើង ១២៨:៥; ទំនុកតម្កើង ១៣៤:៣)។

តើនៅលើផែនដីនេះមានកន្លែងណាដែលមានសុវត្ថិភាពដូចជារោងឧបោសថរបស់ព្រះដែរឬទេ? ទេ នៅលើផែនដីនេះគ្មានកន្លែងបែបនេះឡើយ។ តើហេតុអ្វីបានជារោងឧបោសថរបស់ព្រះគឺជាកន្លែងមានសុវត្ថិភាពបំផុតយ៉ាងដូច្នេះ? នោះគឺដោយសារតែព្រះទ្រង់គង់នៅក្នុងរោងឧបោសថនេះដោយផ្ទាល់។ ទន្ទឹមគ្នានេះ ភ្នំដ៏ខ្ពស់ដែលមានឈ្មោះថា ស៊ីយ៉ូននេះ គឺខ្ពស់ជាងភ្នំដទៃទៀត ដោយសារតែព្រះទ្រង់គង់នៅទីនោះផ្ទាល់ (ទំនុកតម្កើង ៦៨:១៥, ១៦; អេសាយ ២:២)។

**«ដ្បិតសំដេចសង្ឃនៃយើង ទ្រង់មិនមែនមិនអាចនឹងអាណិតអាសូរ ដល់សេចក្តីកម្សោយរបស់យើងរាល់គ្នានោះទេ ព្រោះទ្រង់បានត្រូវសេចក្តីល្បួងគ្រប់យ៉ាង ដូចជាយើងរាល់គ្នាដែរ តែឥតធ្វើបាបឡើយ ដូច្នេះ ត្រូវឲ្យយើងរាល់គ្នា មកដល់បល្ល័ង្កនៃព្រះគុណ ដោយក្លាហាន ដើម្បីនឹងទទួលសេចក្តីមេត្តា ហើយរកបានព្រះគុណសម្រាប់នឹងជួយដល់ពេលត្រូវការចុះ» (ហេព្រើរ ៤:១៥, ១៦)។ តើខទាំងនេះបានប្រាប់អំពីរោងឧបោសថរបស់ព្រះដូចនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងនេះដោយរបៀបណា?**

____________________________________________________________

____________________________________________________________

រោងឧបោសថរបស់ព្រះគឺបរិសុទ្ធ។ ហើយកណ្ឌគម្ពីរទំនុកតម្កើងក៏បានបង្រៀនយើងថា មនុស្សទាំងអស់គឺជាបាបជនផងដែរ។ យើងមិនស័ក្តិសមនឹងទទួលបានព្រះពររបស់ទ្រង់នោះឡើយ។ ប៉ុន្តែ ព្រះបានសង្គ្រោះយើងចេញពីអំពើបាប ដោយសារព្រះគុណរបស់ទ្រង់វិញ (ទំនុកតម្កើង ១៤៣:២, ៩-១២)។ យើងមិនអាចទិញសេចក្តីលើកលែងទោស ឬព្រះគុណរបស់ព្រះ ដោយទង្វើល្អរបស់យើងនោះឡើយ។ យើង ត្រូវតែលន់តួអំពើបាបរបស់យើង ដោយទទួលយកព្រះគុណរបស់ទ្រង់ជាមុនសិន។ បន្ទាប់មក យើងនឹងអាចសូមឱ្យព្រះសង្គ្រោះយើងបាន ពីព្រោះរោងឧបោសថរបស់ទ្រង់បានបង្ហាញយើងថា មានតែព្រះយេស៊ូវមួយគត់ដែលអាចសង្គ្រោះយើងបាន។

ការសិក្សាបន្ថែម៖ សូមអាន Ellen G. White, "The Night of Wrestling," pages 195-203, in *Patriarchs and Prophets*។ តើយើងអាចរៀនចេញពីបទពិសោធន៍នៃការថ្វាយបង្គំ និងការជឿទុកចិត្តទៅលើព្រះ ដែលលោកយ៉ាកុបបានជឿទុកចិត្តទៅលើព្រះនោះយ៉ាងដូចម្ដេចដែរ?

កណ្ឌគម្ពីរទំនុកតម្កើងបានធ្វើឱ្យសេចក្ដីជំនឿដែលយើងមានចំពោះព្រះបានរឹងមាំឡើង។ ព្រះនឹងមិនធ្វើឱ្យរាស្ត្ររបស់ទ្រង់ដែលបានជឿទុកចិត្តទៅលើទ្រង់ពេញមួយជីវិតរបស់ពួកគេនោះខកចិត្តនោះទេ។ ពីព្រោះទ្រង់គឺជា «ជម្រក» ដ៏មានសុវត្ថិភាពរបស់ពួកគេ។ «ព្រះនឹងធ្វើរឿងអស្ចារ្យជាច្រើនសម្រាប់អស់អ្នកណាដែលជឿទុកចិត្តទៅលើទ្រង់។ ហេតុផលមួយចំនួនដែលធ្វើឱ្យរាស្ត្ររបស់ទ្រង់ចុះខ្សោយនោះគឺដោយសារតែពួកគេបានជឿទុកចិត្តទៅលើប្រាជ្ញារបស់ពួកគេផ្ទាល់។ ពួកគេមិនបានបើកឱកាសឱ្យព្រះអម្ចាស់ជួយពួកគេនោះឡើយ។ ព្រះនឹងជួយដល់កុមារដែលមានជំនឿទៅលើទ្រង់នៅពេលដែលពួកគេត្រូវការទ្រង់បន្ទាន់បំផុត បើសិនជាពួកគេបានជឿទុកចិត្តទៅលើព្រះទាំងស្រុង ហើយនិងធ្វើតាមទ្រង់ ដោយសេចក្ដីជំនឿនោះ»។ ដកស្រង់ Ellen G. White, *Patriarchs and Prophets*, page 493, adapted។

មានពេលខ្លះ យើងពិបាកនឹងជឿទៅលើសេចក្ដីសន្យាដ៏អស្ចារ្យដែលមានចែងនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងនេះណាស់។ បញ្ហា និងទុក្ខលំបាករបស់យើងមានមន្ទិលសង្ស័យចំពោះជំនួយដែលព្រះបានប្រទានឱ្យយើង។ នៅពេលដែលជួបនឹងគ្រាលំបាក នោះយើងត្រូវតែជឿទុកចិត្តទៅលើសេចក្ដីមេត្តារបស់ព្រះ។

ម៉្យាងទៀត មានពេលខ្លះ មនុស្សខ្លះមិនបានយល់អំពីអត្ថន័យពិតប្រាកដនៃសេចក្ដីសន្យារបស់ព្រះនោះទេ។ ហើយយើងក៏មិនត្រូវល្បងលព្រះ ដូចជាសាតាំងបានធ្វើនោះដែរ។ ដ្បិតសាតាំងបានព្យាយាមធ្វើឱ្យព្រះយេស៊ូវជឿថា ខគម្ពីរទំនុកតម្កើង ៩១:១១, ១២ បានសន្យានូវអ្វីដែលព្រះមិនបានសន្យាទាល់តែសោះ។ ចម្លើយដែលព្រះយេស៊ូវបានឆ្លើយទៅកាន់សាតាំងបានបង្ហាញយើងថា ការជឿទុកចិត្តទៅលើព្រះមិនមែនជារឿងដដែល ដូចជាការល្បងលព្រះនោះឡើយ។ ការល្បងលព្រះគឺជាអំពើបាបមួយ។ ដូច្នេះហើយ យើងមិនត្រូវសូមឱ្យព្រះធ្វើអ្វីមួយ ដែលទាស់នឹងផែនការរបស់ទ្រង់ ឬទាស់នឹងព្រះបន្ទូលរបស់ទ្រង់នោះឡើយ។

«តើយើងបានទទួលជោគជ័យនៅក្នុងនាមជាគ្រីស្ទានដោយរបៀបណា? តើជំនាញ ឬការអប់រំរបស់យើងបានធ្វើឱ្យយើងជោគជ័យដែរឬទេ? តើយើងអាចយកបានភាពជោគជ័យ ដោយសារតែទ្រព្យសម្បត្តិរបស់យើង ឬដោយសារតែប្រជាប្រិយរបស់យើងនោះដែរឬទេ? របៀបដែលយើងត្រូវទទួលបាននូវភាពជោគជ័យ នោះគឺជាការចូលទៅឯព្រះ ដោយសេចក្ដីជំនឿ។ យើងត្រូវតែជឿទុកចិត្តទៅលើអំណាចរបស់ព្រះ ដើម្បីសង្គ្រោះយើង។ បន្ទាប់មកយើងនឹងទទួលបានជោគជ័យជាមិនខាន»។ ដកស្រង់ពី Ellen G. White, *Patriarchs and Prophets*, page 203, adapted។

## សំណួរពិភាក្សា

១. តើយើងបានជឿទុកចិត្តទៅលើព្រះដោយរបៀបណា នៅពេលដែលអ្វីៗគ្រប់យ៉ាងបានដំណើរការខុសប្រក្រតីនោះ? តើហេតុអ្វីបានជារឿងអាក្រក់បានកើតឡើងដល់រាស្ត្ររបស់ព្រះយ៉ាងដូច្នេះ បើទោះបីជាយើងបានទទួលសេចក្ដីសន្យាជាច្រើនអំពីការការពាររបស់ព្រះក៏ដោយនោះ?

២. តើយើងអាចជឿទុកចិត្តទៅលើព្រះឱ្យអស់ពីចិត្តរបស់យើងគ្រប់ពេលវេលានោះដោយរបៀបណា? (សូមអានខគម្ពីរទំនុកតម្កើង ៩១:១៤; ទំនុកតម្កើង ១៤៣:៨, ១០ និងទំនុកតម្កើង ១៤៥:១៨-២០)។ តើអ្វីខ្លះដែលអាចឱ្យយើងបាត់បង់សេចក្ដីជំនឿនោះ? តើហេតុអ្វីបានជាការជឿទុកចិត្តទៅលើព្រះនៅក្នុងគ្រាសប្បាយនេះ ក៏ជារឿងសំខាន់ណាស់ដែរ សម្រាប់ការរៀនជឿទុកចិត្តទៅលើទ្រង់នៅក្នុងគ្រាលំបាកនោះ?

## ព្រះបានឆ្លើយតបទៅនឹងសេចក្តីអធិស្ឋាននៅក្នុងប្រទេសភីត

ថ្ងៃមួយ នាងម៉ាហ្គារេត (Margaret) និងលោកលេវាន់ណា (Levana) ដែលជាស្វាមីរបស់នាងកំពុងតែអង្គុយនៅក្នុងបន្ទប់ទទួលភ្ញៀវនៅក្នុងទីក្រុងភីត (Perth) នៃប្រទេសអូស្ត្រាលី បន្ទាប់ពីបានត្រឡប់មកពីប្រទេសប៉ាពូញូហ្គីនីកាលយប់ម្សិលមិញ ដែលត្រូវធ្វើដំណើររយៈចម្ងាយ៩៥០០គីឡូម៉ែត។

នាងម៉ាហ្គារេតកំពុងតែសញ្ជឹងគិតយ៉ាងស្ងាត់ស្ងៀម អំពីពាក្យលាគ្នារបស់ឪពុកនាង។ បន្ទាប់ពីបានអធិស្ឋានជាមួយនឹងកូនស្រីរួច គាត់បាននិយាយប្រាប់នាងថា «ម៉ាហ្គារេតកូនស្រីអើយ នៅពេលដែលកូនទៅដល់ផ្ទះកូនស្រីនៅឯទីក្រុងភីតនោះវិញ ស្អែកឡើង ព្រះនឹងទៅដល់មាត់ទ្វារផ្ទះកូនស្រីជាមិនខាន»។

នាងចូ លៀង (Jo Laing) ដែលជាអ្នកផ្សាយដំណឹងល្អតាមសៀវភៅ និងមិត្តភក្តិមួយចំនួនរបស់គាត់កំពុងតែអធិស្ឋាននៅក្នុងព្រះវិហារសេវេនដេយអាត់វេនទីស្ទ ដែលស្ថិតនៅជិតផ្ទះរបស់នាងម៉ាហ្គារេត និងលោកលេវាន់ណា។ នាងចូ លៀង និងក្រុមការងាររបស់នាងកំពុងតែអធិស្ឋានទូលសូមទៅព្រះ ខណៈពេលដែលពួកគេបានរៀបចំចេញទៅលក់សៀវភៅនៅថ្ងៃនោះ។

២ម៉ោងក្រោយមក នាងចូបានចូលមកគោះទ្វារផ្ទះនាងម៉ាហ្គារេត និងលោកលេវាន់ណា។ ផ្ទះរបស់ពួកគេមានសណ្ឋានមិនខុសគ្នាពីផ្ទះដទៃនៅតាមដងផ្លូវនោះឡើយ។ លោកលេវាន់ណាបានបើទ្វារ រួចនិយាយយ៉ាងទន់ភ្លន់ទៅតាមសៀវភៅចំអិនអាហារដែលនាងចូបានបង្ហាញគាត់នោះ។ ប៉ុន្តែ លោកលេវាន់ណាមិនបានបង្ហាញថា គាត់បានចាប់អារម្មណ៍ទៅលើសៀវភៅនោះទេ។ បន្ទាប់មក នាងចូបានជូនសៀវភៅ*មហាវិវាទ*របស់អ្នកស្រីអេឡែន ជីវ៉ៃត៍ដល់នាង រួចបានចាប់ផ្តើមប្រាប់គាត់អំពីសៀវភៅនោះ។ លោកលេវាន់ណាបានចាប់ផ្តើមបើកមើល២ទៅ៣ទំព័រ បន្ទាប់មក គាត់បានហៅភរិយារបស់គាត់មកមើលសៀវភៅនោះ។ នាងបានសួរនាងម៉ាហ្គារេតថា «តើយើងមានសៀវភៅហើយឬនៅ?»។ នាងម៉ាហ្គារេតបានដើរមកកាន់ទ្វារផ្ទះរួចបញ្ជាក់ប្រាប់ក្រុមរបស់នាងចូ លៀងថា ពួកគេមានសៀវភៅនោះរួចទៅហើយ។ នាងបានក្រឡេកមើលនាងចូ រួចពន្យល់ថា នាងគឺជាអតីតសេវេនដេយអាត់វេនទីស្ទ។ នាង បាននិយាយពាក្យទាំងនេះដោយមិនបានតាំងចិត្ត។ នាងបាននិយាយទៀតថា «ពួកយើងទើបតែត្រឡប់ ពីប្រទេសប៉ាពូញូហ្គីណេកាលពីម្សិលមិញ ហើយពាក្យចុងក្រោយដែលឪពុករបស់ខ្ញុំបានផ្តាំផ្ញើខ្ញុំនោះគឺថា គាត់នឹងមិនអធិស្ឋានសូមឱ្យព្រះបានបង្ហាញព្រះអង្គទ្រង់នៅក្នុងផ្ទះរបស់ខ្ញុំនេះនោះទេ»។

ថ្ងៃនោះគឺជាថ្ងៃដ៏សែនក្តៅ ដែលមានសីតុណ្ហភាព៤៣អង្សាសេ។ ប៉ុន្តែ នាងចូមានអារម្មណ៍ថា ដៃរបស់នាងបានព្រឺរសម្បុរជាខ្លាំង។ នាង និងនាងម៉ាហ្គារេតបានក្រឡេកមើលគ្នាទៅវិញទៅមក ដោយស្នាមញញឹម និងសេចក្តីអស្ចារ្យនៅក្នុងចិត្ត អំពីរបៀបដែលព្រះបានឆ្លើយតបទៅនឹងសេចក្តីអធិស្ឋានរបស់ឪពុកនាងម៉ាហ្គារេត។ នាងម៉ាហ្គារេតបាននិយាយថា «តើអ្នកយល់យ៉ាងណាដែរ បើសិនជាខ្ញុំអាចចូលទៅចែកចាយទីបន្ទាល់នេះនៅក្នុងព្រះវិហាររបស់អ្នកបាននោះ?»។ នាងចូបាននិយាយថា «ចាស ប្អូនអាចចែកចាយទីបន្ទាល់នៅក្នុងព្រះវិហាររបស់បងបាន»។ បន្ទាប់មក ពួកគេទាំង២នាក់បានឱ្យលេខទូរស័ព្ទគ្នាទៅវិញទៅមក។

ប៉ុន្មានអាទិត្យក្រោយមក នាងម៉ាហ្គារេតបានឈររៀបរាប់ពីទីបន្ទាល់របស់នាងអំពីរបៀបដែលព្រះបានរកឃើញចៀមបាត់បង់របស់ទ្រង់ នៅក្នុងព្រះវិហារសេវេនដេយអាត់វេនទីស្ទប៊ីកលី។

ព្រះបានប្រើស្ត្រីម្នាក់ជាមួយនឹងសៀវភៅ*មហាវិវាទ*នៅក្នុងប្រទេសអូស្ត្រាលី ដើម្បីឆ្លើយតបទៅនឹងការអធិស្ឋានរបស់ឪពុកនាង ដែលគាត់បានទូលសូមដល់ព្រះចេញពីប្រទេសប៉ាពូញូហ្គីនីនោះមក។

# ការច្រៀងចម្រៀងថ្វាយព្រះនៅក្នុងទឹកដីសន្យានៃសាសនដទៃ



ល្ងាចថ្ងៃបរិសុទ្ធ - ថ្ងៃសៅរ៍ ទី២៧ ខែមករា ឆ្នាំ២០២៤

**អំណានព្រះគម្ពីរសម្រាប់មេរៀនប្រចាំសប្តាហ៍នេះ៖ ទំនុកតម្កើង ៧៤:១៨-២២; ទំនុកតម្កើង ៨៨:៣-១២; ទំនុកតម្កើង ៤២:១-៣; ទំនុកតម្កើង ៧៧; ទំនុកតម្កើង ៣៧:១, ៨; ទំនុកតម្កើង ១២៥:៣។**

**ខចងចាំ៖ «តែយើងនឹងច្រៀងបទនៃព្រះយេហូវ៉ា នៅក្នុងប្រទេសដទៃដូចម្តេចបាន» (ទំនុកតម្កើង ១៣៧:៤)។**

នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង កវីបានយល់ឃើញថា ជីវិតនៅលើផែនដីនេះមានទៅដោយអំពើបាប សេចក្តីអាក្រក់ សេចក្តីរងទុក្ខ និងសេចក្តីស្លាប់។ សាតាំង និងអ្នកដែលបានធ្វើតាមវាតែងតែធ្វើការ ដើម្បីបំផ្លាញផែនដីនេះ និងបានបៀតបៀនដល់បញ្ញត្តដ៏បរិសុទ្ធរបស់ព្រះ។ មានពេលខ្លះ នៅពេលដែលអំពើបាប និងសេចក្តីអាក្រក់បានធ្វើឱ្យជីវិតនៅលើផែនដីនេះកាន់តែអាក្រក់ទៅៗ នោះរាស្ត្ររបស់ព្រះតែងតែគិតជានិច្ចថា ការរស់នៅលើផែនដីនេះគឺដូចគ្នាទៅនឹងការរស់នៅក្នុង «ទឹកដីនៃសាសន៍ដទៃ» យ៉ាងដូច្នោះដែរ។ កវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើងតែងតែមានអារម្មណ៍បែបនេះជានិច្ច។ ពួកគេបានឆ្ងល់ថា តើពួកយើងបានរស់នៅក្នុងជីវិតនៃសេចក្តីជំនឿនៅក្នុងទឹកដីនៃសាសន៍ដទៃនេះដោយរបៀបណា?

យើងបានឃើញរួចមកហើយថា កវីនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានដឹងថា ព្រះគឺជាអ្នកគ្រប់គ្រង។ ពួកគេក៏បានជឿថា ព្រះក៏ប្រៀបដូចជាខែលការពាររាស្ត្ររបស់ទ្រង់នៅក្នុងគ្រាលំបាកយ៉ាងដូច្នោះដែរ។ ដូច្នេះហើយ មានពេលខ្លះ កវីបានស្រឡាំងកាំង នៅពេលដែលសេចក្តីអាក្រក់បានឈ្នះសេចក្តីល្អនោះ។ កវីបានឆ្ងល់ថា តើព្រះគឺជាអ្នកណា? មានពេលខ្លះ យើងក៏បានដឹងរឿងទាំងនេះផងដែរ។ ប៉ុន្តែ យើងត្រូវតែចាំថា កំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងក៏ជាសេចក្តីអធិស្ឋានផងដែរ។ នៅក្នុងសេចក្តីអធិស្ឋានទាំងនេះ កវីបានរៀបរាប់អំពីអារម្មណ៍របស់ពួកគេ នៅពេលដែលព្រះទ្រង់នៅស្ងៀមដោយមិនបានឆ្លើយតបទៅនឹងសេចក្តីអធិស្ឋានសូមជំនួយរបស់ពួកគេភ្លាមៗនោះ។ លោកអ្នកក៏អាចនឹងមានអារម្មណ៍បែបនេះផងដែរ នៅពេលដែលលោកអ្នកបានអធិស្ឋាន។ លោកអ្នកអាចនឹងឆ្ងល់ពីមូលហេតុដែលជំរុញឱ្យព្រះឆ្លើយតបទៅនឹងសេចក្តីអធិស្ឋានរបស់លោកអ្នកភ្លាមៗនោះ។ លោកអ្នកក៏អាចនឹងមានអារម្មណ៍ថា ព្រះបានគង់នៅឆ្ងាយពីលោកអ្នកផងដែរ។ ដូច្នេះហើយ សប្តាហ៍នេះ យើងនឹងក្រឡេកមើលកវីនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងដែលបានចែងអំពីកិច្ចការដែលយើងគួរធ្វើ នៅក្នុងអំឡុងពេលដែលព្រះបាននៅស្ងៀមនោះ។

# សម័យកាលនៃសេចក្តីអាក្រក់

**សូមអានខគម្ពីរទំនុកតម្កើង ៧៤:១៨-២២ និងទំនុកតម្កើង ៧៩:៥-១៣។ កំណាព្យទាំង២ នេះក៏ជាសេចក្តីអធិស្ឋានផងដែរ។ តើសេចក្តីអធិស្ឋានទាំងនេះបានរៀបរាប់អំពីអ្វីខ្លះ? តើកវីដែលកំពុងតែទូលសូមទៅឯព្រះអម្ចាស់នោះបានធ្វើអ្វីខ្លះ?**

---

---

កវីនៅក្នុងជំពូកទាំងនេះមានបំណងចង់យល់អំពីសង្គ្រាមរវាងសេចក្តីល្អ និងសេចក្តីអាក្រក់។ កវីនៅក្នុងជំពូកទាំងនេះបានមានប្រសាសន៍ថា ព្រះទ្រង់មានព្រះទ័យអត់ធ្មត់ មានប្រាជ្ញាញាណ និងអំណាចខ្លាំងក្លានៅក្នុងសង្គ្រាមនេះ។

នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង នៅពេលណាដែលកវីបានរៀបរាប់អំពីសេចក្តីអាក្រក់ នោះពួកគេក៏បានរៀបរាប់អំពីរបៀបដែលព្រះត្រូវដោះស្រាយបញ្ហានេះដែរ។ ការដែលខ្មាំងសត្រូវរបស់ព្រះបានបំផ្លាញទីក្រុងយេរូសាឡិម និងបានបំផ្លាញព្រះវិហារ បានធ្វើឱ្យកវីនៅក្នុងជំពូកនេះអន់ចិត្តជាខ្លាំង។ ពួកគេបានព្រួយបារម្ភខ្លាចសាសន៍ដទៃនឹងគិតថា ព្រះទ្រង់ខ្សោយ បន្ទាប់មក ពួកគេនឹងចំអកឱ្យទ្រង់។ ពួកសាសន៍អ៊ីស្រាអែលគឺជាទ្រព្យសម្បត្តិរបស់ព្រះ ដោយសារតែព្រះបានតាំងសេចក្តីសន្យារបស់ទ្រង់ជាមួយនឹងពួកគេ (ចោទិយកថា ៤:២-៣៨; ចោទិយកថា ៣២:៨, ៩)។ សាសន៍អ៊ីស្រាអែលគឺជា «ទីបន្ទាល់រស់» ដែលព្រះត្រូវរក្សាសេចក្តីសន្យារបស់ទ្រង់។ សេចក្តីសន្យាដែលព្រះបានតាំងឡើងជាមួយនឹងសាសន៍អ៊ីស្រាអែលនៅក្នុងអំឡុងពេលនៃគ្រាលំបាកនេះ ក៏ជាសេចក្តីសន្យាចុងក្រោយសម្រាប់យើងផងដែរ។ ម្យ៉ាងទៀតយើងក៏ជាសម្បត្តិទ្រព្យដ៏ពិសេសរបស់ព្រះផងដែរ។ នៅពេលអនាគត មនុស្សគ្រប់គ្នានឹងក្រាបថ្វាយបង្គំព្រះ។ មនុស្សពីគ្រប់សម័យកាលទាំងអស់នឹងចូលមកបម្រើទ្រង់។ សេចក្តីសន្យាទាំងនេះមានតម្លៃចំពោះកវីទាំងនេះណាស់។ ហេតុដូច្នេះហើយ បានជាពួកគេអន់ចិត្ត នៅពេលដែលខ្មាំងសត្រូវនៃសាសន៍ដទៃបានវាយចូលមកក្នុងប្រទេសអ៊ីស្រាអែលនោះ។ ខ្មាំងសត្រូវទាំងនេះគឺជាឧបសគ្គដល់សន្យាគ្រប់យ៉ាងដែលព្រះបានតាំងឡើងជាមួយនឹងរាស្ត្ររបស់ទ្រង់នោះ។

កវីនៅក្នុងជំពូកនេះបានដឹងថា អំពើបាបនៃសាសន៍អ៊ីស្រាអែលបានធ្វើបាបទំនាក់ទំនងរបស់យើងជាមួយនឹងព្រះ។ អំពើបាបឪពុករបស់ពួកគេបាននាំបណ្តាសាមកលើទឹកដី និងកូនចៅរបស់ពួកគេ (ទំនុកតម្កើង ៧៩:៨, ៩)។ ឥឡូវនេះ មានតែព្រះមួយគត់ដែលអាចសង្គ្រោះរាស្ត្ររបស់ទ្រង់បាន។ កវីបានសរសេរថា ព្រះអម្ចាស់គឺជា «ព្រះដ៏ជួយសង្គ្រោះ» (ទំនុកតម្កើង ៧៩:៩)។ នាមទាំងនេះរបស់ព្រះអម្ចាស់បានបង្ហាញយើងថា ទ្រង់នឹងរក្សាសេចក្តីសន្យារបស់ទ្រង់ (ទំនុកតម្កើង ៧៩:៩)។

តើមានអ្វីដែលសំខាន់ចំពោះកវីនៅក្នុងជំពូកនេះជាងព្រះពរដែលព្រះបានប្រទានដល់សាសន៍អ៊ីស្រាអែលនោះដែរឬទេ? ទេ មិនមានអ្វីសំខាន់ជាងនេះឡើយ។ នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៧៩ កវីមានបំណងចង់ឱ្យមនុស្សទាំងអស់បានលើកតម្កើង និងបានសរសើរតម្កើងព្រះ (ទំនុកតម្កើង ៧៩:៩)។ កវីចង់ឱ្យព្រះដាក់ទោសដល់សាសន៍ណាដែលបានធ្វើបាបសាសន៍អ៊ីស្រាអែល។ បើសិនជាព្រះបានដាក់ទោសមនុស្សទាំងនេះ នោះពួកគេនឹងបានដឹងថា ព្រះទ្រង់មានអំណាចជាទីបំផុត (ទំនុកតម្កើង ៧៤:១៨-២៣); ទំនុកតម្កើង ៨៣:១៦-១៨; ទំនុកតម្កើង ១០៦:៤៧)។ នៅពេលដែលព្រះសង្គ្រោះរាស្ត្ររបស់ទ្រង់ ព្រះនាមរបស់ទ្រង់ក៏ត្រូវបានសរសើរតម្កើង និងលើកតម្កើងផងដែរ។

សព្វថ្ងៃនេះ អំពើបាបរបស់យើងក៏បានធ្វើបាបយើង ធ្វើបាបព្រះ និងធ្វើឱ្យអ្នកដទៃមើលងាយទ្រង់ផងដែរ។ តើមនុស្សជាច្រើននាក់បានបដិសេធព្រះ ដោយសារទង្វើអាក្រក់របស់អ្នកគ្រីស្ទាននោះដោយរបៀបណា?

**«ការលើកតម្កើងព្រះ និងការលើកតម្កើងព្រះយេស៊ូវនឹងបានឃើញនៅក្នុងជីវិតដ៏បរិសុទ្ធនៃរាស្ត្ររបស់គាត់»។ ដកស្រង់ពី Ellen G. White, *The Desire of Ages*, page 671, adapted។ តើសេចក្តីពិតនៃព្រះគម្ពីរខាងឯវិញ្ញាណដ៏សំខាន់នេះមានន័យយ៉ាងណាដែរសម្រាប់លោកអ្នក? តើសេចក្តីពិតនេះបានផ្លាស់ប្តូររបៀបរស់នៅរបស់យើងដោយរបៀបណា?**

# ទូលបង្គំបានត្រៀមលក្ខណៈជាស្រេច ដើម្បីនឹងលះបង់ជីវិតរបស់ទូលបង្គំ

**សូមអានខគម្ពីរទំនុកតម្កើង ៤១:១-៤; ទំនុកតម្កើង ៨៨:៣-១២ និងទំនុកតម្កើង ១០២:៣-៥, ១១, ២៣, ២៤។ តើកំណាព្យទាំងនេះបានរៀបរាប់អំពីបទពិសោធន៍អ្វីខ្លះ? តើលោកអ្នកបានគិតបែបនេះដែរឬទេ?**

---

---

បទគម្ពីរទំនុកតម្កើង ជំពូក៤១ និងបទគម្ពីរទំនុកតម្កើង ជំពូក១០២ គឺជាសេចក្តីអធិស្ឋាន។ កំណាព្យបានសូមឱ្យព្រះសង្គ្រោះពួកគេចេញពីរោគា និងសេចក្តីស្លាប់។ កវីបានជួយឱ្យយើងនឹកចាំជានិច្ចថា រាស្ត្ររបស់ព្រះតែងតែទទួលបានបទពិសោធន៍ខុសៗគ្នានៅក្នុងជីវិតនេះ។ រាស្ត្ររបស់ព្រះអាចនឹងរងទុក្ខ ហើយធ្លាក់ខ្លួនឈឺ។ ពីព្រោះកវីនៅក្នុងជំពូកទាំងនេះបានរៀបរាប់អំពីសេចក្តីរងទុក្ខ និងការឈឺចាប់របស់ពួកគេ។ ដ្បិតពួកគេគ្មានអំណាចអ្វីឡើយ។ ហើយពួកគេក៏ត្រូវបញ្ចប់ជីវិតទៅ ដូចជាស្មៅដូច្នោះដែរ។ ពួកគេបានមានអារម្មណ៍ហាក់ដូចជាពួកគេហៀបនឹងស្លាប់ ហើយដេកនៅលើគ្រែស្នែងអ៊ីចឹង។ មិត្តភក្តិរបស់ពួកគេបានឃ្លាតចេញពីពួកគេ។ កវីម្នាក់បានមានប្រសាសន៍ថា «អស់ទាំងឆ្អឹងរបស់ទូលបង្គំជាប់ជិតនឹងសាច់ ដោយព្រោះដំងូរដែលទូលបង្គំថ្ងូរជានិច្ច» (ទំនុកតម្កើង ១០២:៥)។

កវីជាច្រើននាក់នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានយល់ឃើញថា សាសន៍អ៊ីស្រាអែលបានរងទុក្ខ ដោយសារតែពួកគេបានបដិសេធមិនព្រមគោរពតាមព្រះ។ កវីទាំងនេះបានយល់ឃើញថា អំពើបាបធ្វើឱ្យមនុស្សឈឺបាន។ ដូច្នេះហើយ ពួកគេបានរៀបរាប់អំពីតម្រូវការនៃការសូមសេចក្តីលើកលែងទោសពីព្រះ ដើម្បីឱ្យព្រះបានព្យាបាលពួកគេ (ទំនុកតម្កើង ៤១:៣, ៤)។ មានពេលខ្លះ ការឈឺចាប់របស់យើងបានកើតឡើងទាំងដែលយើងមិនបានធ្វើអ្វីទាល់តែសោះ។ កណ្ឌគម្ពីរទំនុកតម្កើង ជំពូក៨៨ និងកណ្ឌគម្ពីរទំនុកតម្កើង ជំពូក១០២ ក៏បានថែងអំពីការឈឺចាប់នៃរាស្ត្ររបស់ព្រះផងដែរ ដោយសាតែយើងបានរស់នៅលើផែនដីដែលពេញទៅដោយអំពើបាប។ ដូច្នេះហើយ ការរងទុក្ខគឺជាផ្នែកមួយនៃជីវិតរបស់យើង។ ប៉ុន្តែ គោលគំនិតនេះពិបាកនឹងឱ្យមនុស្សគ្រប់គ្នាទទួលយក និងយល់ស្របតាមណាស់។

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៨៨ កវីបានអធិស្ឋានថា ព្រះគឺជាមូលហេតុនៃការឈឺចាប់របស់គាត់ (ទំនុកតម្កើង ៨៨:៦-៨)។ តើលោកអ្នកបានឃើញការអធិស្ឋានរបស់កវីបង្កប់ទៅដោយសេចក្តីជំនឿដែរឬទេ? ប្រសិនបើព្រះអម្ចាស់បានបណ្តោយឱ្យកវីនៅក្នុងជំពូកនេះឱ្យរងទុក្ខ នោះទ្រង់ក៏អាចសង្គ្រោះកូនរបស់ទ្រង់ចេញពីការរងទុក្ខនោះបានដែរ។ ជាការពិតណាស់ កវីបានយល់ឃើញថា ព្រះបានដាក់ទោសគាត់។ ទន្ទឹមគ្នានេះ កវីក៏បានតោងព្រះយ៉ាងជាប់ផងដែរ។ ដ្បិតកវីបានដឹងថា ព្រះបានស្រឡាញ់គាត់ ហើយមានតែទ្រង់មួយគត់ដែលអាចសង្គ្រោះគាត់បាន។ កវីនៅក្នុងជំពូកនេះបានដឹងអំពីការរងទុក្ខ ប៉ុន្តែគាត់ក៏បានដឹងអំពីសេចក្តីមេត្តារបស់ព្រះផងដែរ។

កណ្ឌគម្ពីរទំនុកតម្កើង ជំពូក៨៨ បានបង្ហាញយើងថា ព្រះគឺជាអ្នកគ្រប់គ្រងហេតុការណ៍ទាំងអស់ដែលបានកើតឡើងនៅក្នុងជីវិតនេះ។ ជួនកាល ព្រះអាចនឹងបណ្តោយឱ្យមានការរងទុក្ខកើតឡើង។ ប៉ុន្តែទ្រង់ក៏អាចសង្គ្រោះរាស្ត្ររបស់ទ្រង់ចេញពីការរងទុក្ខនោះបានដែរ។ ដូច្នេះហើយ ការគ្រប់គ្រងរបស់ទ្រង់ទៅលើអ្វីដែលបានកើតឡើងចំពោះយើងនេះគួរតែផ្តល់សេចក្តីសង្ឃឹមដល់ចិត្តរបស់យើង។

**សូមគិតអំពីព្រះយេស៊ូវដែលជាប់នៅលើឈើឆ្កាង ព្រមទាំងគិតអំពីការរងទុក្ខរបស់ទ្រង់ ដោយសារតែអំពើបាបនោះដែរ នោះលោកអ្នកបានឃើញថា ព្រះដ៏ជាព្រះវរបិតាក៏បានរងទុក្ខជាមួយនឹងព្រះយេស៊ូវនៅក្នុងតួអង្គព្រះយេស៊ូវផងដែរ។ ព្រះវរបិតា និងព្រះយេស៊ូវបានរងទុក្ខលើសពីការរងទុក្ខរបស់យើងទៅទៀត។ តើគោលគំនិតនេះបានជួយឱ្យយើងរក្សាសេចក្តីជំនឿនៅក្នុងគ្រានៃការរងទុក្ខនោះដោយរបៀបណា?**

## តើព្រះនៅទីណា?

**សូមអានខគម្ពីរទំនុកតម្កើង ៤២:១-៣; ទំនុកតម្កើង ៦៣:១; ទំនុកតម្កើង ៦៩:១-៣; ទំនុកតម្កើង ១០២:១-៧។ តើអ្វីដែលបានធ្វើឱ្យកវីឈឺចាប់យ៉ាងខ្លាំងនោះ?**

______________________________________________________________

______________________________________________________________

កវីនៅក្នុងជំពូកទាំងនេះបានរងទុក្ខ ដោយសារតែបញ្ហាផ្ទាល់ខ្លួន។ លើសពីនេះទៅទៀតនោះ គាត់បានភិតភ័យខ្លាចព្រះមិនបានគង់នៅជាមួយនឹងគាត់។ ការភ័យខ្លាចនេះបានធ្វើឱ្យកវីនៅក្នុងជំពូកទាំងនេះអាក់អន់ចិត្តលើសពីការឈឺចាប់ផ្ទាល់ខ្លួនរបស់គាត់ទៅទៀត។ កវីបានប្រើរូបស័ព្ទជាច្រើន ដើម្បីបកស្រាយអំពីអារម្មណ៍របស់គាត់។ គាត់បានប្រៀបធៀបសេចក្តីព្រួយបារម្ភរបស់គាត់ទៅនឹងការស្រេកទឹកនៅក្នុងកន្លែងរាំងស្ងួតដូច្នោះដែរ (ទំនុកតម្កើង ៤២:១-៣; ទំនុកតម្កើង ៦៣:១)។ ការដែលកវីបានព្រួយបារម្ភអំពីព្រះបានធ្វើឱ្យគាត់ធ្លាក់ខ្លួនឈឺរហូតដល់ជិតស្លាប់ (ទំនុកតម្កើង ១០២:២-៤)។ កវីបានប្រៀបធៀបខ្លួនគាត់ទៅនឹងបក្សីដែលសាត់ព្រាត់ ដោយគាត់បានរៀបរាប់យ៉ាងដូច្នេះថា៖

«ទូលបង្គំប្រៀបដូចជាសត្វទុងនៅទីរហោស្ថាន ក៏បានត្រឡប់ដូចជាមៀមនៅទីសូន្យស្ងាត់ ទូលបង្គំចាំយាម ក៏ដូចជាចាបឥតគូ នៅលើដំបូលផ្ទះ» (ទំនុកតម្កើង ១០២:៦, ៧)។

«វាលរហោស្ថាន» គឺជារូបស័ព្ទមួយដែលបានជួយឱ្យយើងមើលឃើញថា កវីនៅក្នុងជំពូកនេះមានអារម្មណ៍តែលតោល និងមានអារម្មណ៍ឃ្លាតចេញពីព្រះ។ «ចាបឥតគូ នៅលើដំបូលផ្ទះ» មិនមែននៅក្នុងសំបុករបស់វា ដែលវាអាចសម្រាកបាននោះឡើយ។ ម្ល៉ោះហើយ កវីនៅក្នុងជំពូកនេះបានគិតថា គាត់កំពុងតែលិចចូលទៅក្នុងជីភក់ដ៏ជ្រៅមួយ (ទំនុកតម្កើង ៦៩:១-៣; ទំនុកតម្កើង ១៣០:១)។ រូបស័ព្ទទាំងអស់នេះបានបង្ហាញយើងថា កវីបានគិតថា គាត់មិនអាចគេចចេញពីការរងទុក្ខរបស់គាត់ ដោយគ្មានជំនួយពីព្រះបានឡើយ។

សូមអានខគម្ពីរទំនុកតម្កើង ១០:១២; ទំនុកតម្កើង ២២:១; ទំនុកតម្កើង ២៧:៩ និងទំនុកតម្កើង ៣៩:១២។ នៅក្នុងកំណាព្យទាំងនេះ កវីបានព្រួយចិត្តខ្លាចព្រះមិនបានគង់នៅជាមួយនឹងគាត់។ តើគោលគំនិតនេះបានធ្វើឱ្យកវីមានអារម្មណ៍យ៉ាងដូចម្តេចដែរ?

កវីបានបដិសេធមិនព្រមនៅស្ងៀមឡើយ នៅពេលដែលព្រះមិនបានឆ្លើយតបទៅនឹងសេចក្តីអធិស្ឋានរបស់គាត់នោះ។ សេចក្តីជំនឿដែលកវីបានមានជឿទៅលើសេចក្តីអធិស្ឋាននោះគឺជាសេចក្តីជំនឿដ៏មុតមាំ ដោយគាត់បានជឿថា ព្រះទ្រង់មានព្រះជន្មរស់ ហើយទ្រង់ក៏សព្វព្រះទ័យនឹងបង្ហាញសេចក្តីមេត្តារបស់ទ្រង់ដល់កូនៗរបស់ទ្រង់ផងដែរ។ ដ្បិតព្រះដែលបាននៅស្ងៀមនៅសព្វថ្ងៃនេះក៏ជាព្រះដែលបានឆ្លើយតបទៅនឹងសេចក្តីអធិស្ឋានរបស់កវីនៅក្នុងជំពូកនេះកាលពីសម័យមុនផងដែរ។ ដូច្នេះហើយ កវីក៏បានជឿថា នៅពេលនោះ ព្រះក៏បានផ្ទៀងស្តាប់សេចក្តីអធិស្ឋានរបស់គាត់ផងដែរ។

នោះកវីបានក្រឡេកមើលចិត្តរបស់គាត់ និងជីវិតរបស់គាត់ម្តង នៅពេលដែលព្រះមិនបានឆ្លើយតបទៅនឹងសេចក្តីអធិស្ឋានរបស់កវីភ្លាមៗនោះ។ គាត់បានលន់តួអំពើបាបរបស់គាត់។ គាត់បានបន្តអធិស្ឋានអំពាវនាវទៅព្រះអំពីតម្រូវការរបស់គាត់តទៅទៀត ដោយគាត់បានដឹងថា ព្រះនឹងមិននៅស្ងៀមជារៀងរហូតនោះឡើយ។

**តើយើងអាចរៀនអ្វីខ្លះ ចេញពីមេរៀននៃសេចក្តីអធិស្ឋានដែលកវីបានទូលទៅព្រះនៅក្នុងគ្រាដែលព្រះមិនបានឆ្លើយតបទៅនឹងគាត់ភ្លាមៗនោះ? តើលោកអ្នកបានធ្វើអ្វីខ្លះ នៅពេលដែលព្រះទ្រង់នៅស្ងៀមនោះ? តើអ្វីដែលបានរក្សាសេចក្តីជំនឿរបស់លោកអ្នកឱ្យបានរឹងមាំនោះ?**

## តើសេចក្តីសន្យារបស់ព្រះមិនត្រូវបានបំពេញដែរឬទេ?

### តើកវីនៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៧៧ កំពុងតែជួបនឹងបទពិសោធន៍អ្វីដែរ?

______________________________________________________________________

______________________________________________________________________

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៧៧ កវីបានចាប់ផ្តើមជាមួយនឹងសេចក្តីអធិស្ឋានសូមជំនួយ។ អតីតកាលរបស់កវីនៅក្នុងជំពូកនេះមានពេញទៅដោយការឈឺចាប់ (ទំនុកតម្កើង ៧៧:១-៦)។ កវីបានបដិសេធសេចក្តីសង្ឃឹមដទៃទៀត ដែលមិនមានប្រភពមកពីព្រះ។

អតីតកាលរបស់កវីបានធ្វើឱ្យគាត់មានអារម្មណ៍អាក់អន់ចិត្ត។ ហើយគាត់ក៏មានអារម្មណ៍អន់ចិត្តលើសពីការចងចាំអតីតកាលរបស់គាត់ទៅទៀត។ «ខ្ញុំនឹកពីព្រះ នោះខ្ញុំមានចិត្តទុរន់ទុរា ខ្ញុំនឹកសញ្ជឹង នោះវិញ្ញាណខ្ញុំក៏ល្វើយទៅ» (ទំនុកតម្កើង ៧៧:៣)។ ពាក្យថា «ដំងូរ» ប្រែមកពីពាក្យថា «ហាម៉ា (hamah)» ជាភាសាហេព្រើរ។ កវីនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានយកពាក្យ «ហាម៉ា» មកប្រើ ដើម្បីពិពណ៌នាអំពីរបៀបដែល «ទឹកសមុទ្របញ្ចេញសូរគឹកកង ហើយរំជួលឡើង ឬភ្នំទាំងឡាយត្រូវកក្រើកញ័រ ដោយរលកលោតចុះឡើងក្តី» (ទំនុកតម្កើង ៤៦:៣)។ នៅកណ្ឌគម្ពីរទំនុកតម្កើង ជំពូក៧៧ កវីបានគិតថា គាត់មានសេចក្តីសុខសាន្តនៅក្នុងចិត្តនោះឡើយ។

តើការចងចាំរបស់កវីអំពីព្រះនេះអាចធ្វើឱ្យគាត់មានអារម្មណ៍មិនសប្បាយចិត្តដោយរបៀបណាទៅ? នៅពេលដែលយើងក្រឡេកមើលសំណួរដែលកវីបានសួរ នោះនឹងបានដឹងហេតុផលដែលនាំឱ្យគាត់អាក់អន់ចិត្តនោះ (ទំនុកតម្កើង ៧៧:៧-៩)។ កវីបានងឿងឆ្ងល់ថា តើព្រះបានផ្លាស់ប្តូរព្រះទ័យរបស់ទ្រង់ដែរឬទេ? តើទ្រង់នឹងបំពេញសេចក្តីសន្យារបស់ទ្រង់ដែរឬទេ? តើទ្រង់បានបាត់បង់ព្រះចេស្តារបស់ទ្រង់ដែរឬទេ? តើទ្រង់លែងមានអំណាចខ្លាំងពូកែដូចមុនដែរឬទេ?

ព្រះបានសង្គ្រោះកវីនៅក្នុងជំពូកនេះម្តងរួចទៅហើយ។ ប៉ុន្តែ ឥឡូវនេះ ព្រះមិនបានឆ្លើយតបទៅនឹងសេចក្តីអធិស្ឋានរបស់គាត់នោះឡើយ។ ដូច្នេះហើយ កវីបានគិតថា គាត់នៅតែម្នាក់ឯង។ បើសិនជាព្រះពិតបានផ្លាស់ប្តូរមែន នោះកវីនៅក្នុងជំពូកនេះនឹងគ្មានសង្ឃឹមអ្វីទៀតឡើយ។ ប៉ុន្តែ ផ្ទុយទៅវិញ កវីបានបដិសេធមិនជឿគោលគំនិតខុសឆ្គងនេះឡើយ។

មួយស្របក់ក្រោយមក កវីមិនអាចគេងលក់បានឡើយ ពីព្រោះព្រះអម្ចាស់បានធ្វើឱ្យគាត់ភ្ញាក់ឡើង (ទំនុកតម្កើង ៧៧:៤)។ បញ្ហានៃការគេងមិនលក់របស់កវីនេះបានជួយឱ្យយើងនឹកចាំពីរឿងដទៃទៀត អំពីតួអង្គដទៃទៀត ដែលមានបញ្ហាគេងមិនលក់នេះដែរ។ ដ្បិតព្រះបានធ្វើឱ្យពួកគេគេងមិនលក់ដើម្បីយកផែនការសង្គ្រោះរបស់ទ្រង់មកអនុវត្ត (លោកុប្បត្តិ ៤១:១-៨; នាងអេសធើរ ៦:១; ដានីយ៉ែល ២:១-៣)។ នៅពេលដែលកវីបានភ្ញាក់ពេញមួយយប់ នោះគាត់បាននឹកចាំអំពីរបៀបដែលព្រះបានសង្គ្រោះរាស្ត្ររបស់ទ្រង់កាលពីអតីតកាល។ នៅពេលដែលកវីបាននឹកចាំពីរឿងនេះ នោះគាត់កាន់តែចង់បម្រើព្រះខ្លាំងជាងមុនទៀត (ទំនុកតម្កើង ៧៧:៥, ១០)។

នៅទីបំផុត ព្រះបានឆ្លើយតបទៅនឹងសេចក្តីអធិស្ឋានរបស់កវីនៅក្នុងជំពូកនេះ។ ចម្លើយដែលព្រះបានឆ្លើយនោះមិនមានការបកស្រាយអំពីមូលហេតុនៃការរងទុក្ខរបស់កវីនៅពេលនោះនោះឡើយ។ ព្រះបានប្រទានហេតុផលជាច្រើន ដើម្បីឱ្យកវីបានបន្តជឿទុកចិត្តទៅលើទ្រង់។ ឥឡូវនេះ កវីមានកម្លាំងចិត្តនៅក្នុងការរង់ចាំព្រះអម្ចាស់ ដោយសេចក្តីជំនឿ។ កវីបានដឹងថា ព្រះអម្ចាស់គឺជាព្រះដែលបានធ្វើការអស្ចារ្យជាច្រើននៅក្នុងអតីតកាលនៃសាសន៍អ៊ីស្រាអែល (ទំនុកតម្កើង ៧៧:១១-១៨)។ កវីបានដឹងថា រាស្ត្ររបស់ព្រះតែងតែមើលឃើញកិច្ចការដែលទ្រង់បានធ្វើសម្រាប់ពួកគេជានិច្ច ដោយគាត់បានសរសេរថា៖ «ផ្លូវដែលទ្រង់យាង នោះនៅក្នុងសមុទ្រ ហើយផ្លូវច្រករបស់ទ្រង់ ក៏នៅទីមានទឹកច្រើន ឥតមានអ្នកណា ឃើញដានព្រះបាទទ្រង់ឡើយ» (ទំនុកតម្កើង ៧៧:១៩)។

**សូមគិតអំពីពេលវេលាកាលពីមុន នៅពេលដែលព្រះអម្ចាស់បានធ្វើការនៅក្នុងជីវិតរបស់លោកអ្នក។ តើបទពិសោធន៍ទាំងនោះបានជួយដល់លោកអ្នកនៅក្នុងគ្រាលំបាក ដែលលោកអ្នកអាចនឹងជួបនៅពេលឥឡូវនេះដោយរបៀបណាដែរ?**

# មនុស្សអាក្រក់មិនអាចគ្រប់គ្រងទឹកដីជារៀងរហូតបានឡើយ

**សូមអានខគម្ពីរទំនុកតម្កើង ៣៧:១, ៨; ទំនុកតម្កើង ៤៩:៥-៧; ទំនុកតម្កើង ៩៤:៣-៧ និង ទំនុកតម្កើង ១២៥:៣។ តើកំណាព្យទាំងនេះកំពុងតែរៀបរាប់អំពីបញ្ហាអ្វីដែរ?**

__________________________________________________________________

__________________________________________________________________

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៣៧; ទំនុកតម្កើង ជំពូក៤៩; ទំនុកតម្កើង ជំពូក៩៤ និង ទំនុកតម្កើង ជំពូក១២៥ កវីបានរៀបរាប់អំពីមនុស្សអាក្រក់។ គាត់ពិបាកនឹងយល់អំពីភាពជោគជ័យរបស់ពួកគេណាស់។ ហើយពួកគេក៏មិនបានលាក់សម្ងប់របស់ពួកគេចេញពីព្រះនោះដែរ។ ពួកគេបានធ្វើបាបអ្នកដទៃ ដោយមិនមានសេចក្តីខ្មាសអៀន។ ជំពូកទាំងនេះបានប្រាប់យើងថា មនុស្សអាក្រក់មិនអាចគ្រប់គ្រងទឹកដីជារៀងរហូតបានឡើយ (ទំនុកតម្កើង ១២៥:៣)។ ជំពូកទាំងនេះបានប្រាប់យើងថា នគររបស់ព្រះនឹងបន្តជារៀងរហូតតទៅ (ទំនុកតម្កើង ៤៥:៦)។ ប៉ុន្តែ មានពេលខ្លះ យើងអាចនឹងយល់ឃើញថា មនុស្សអាក្រក់កំពុងតែឈ្នះ ហើយពួកគេក៏កំពុងតែសប្បាយជាមួយនឹងជីវិតរបស់ពួកគេផងដែរ។ ដូច្នេះហើយ យើងក៏ប្រហែលជាចង់លះបង់សេចក្តីជំនឿរបស់យើងទៅចូលរួមធ្វើអាក្រក់នៅក្នុងជីវិតនេះជាមួយនឹងមនុស្សអាក្រក់ទាំងនោះ។

**តើអ្វីដែលបានជួយដល់កវី នៅក្នុងគ្រាលំបាកនោះ? សូមអានខគម្ពីរទំនុកតម្កើង ៧៣:១-២០; ២៧ សម្រាប់ចម្លើយ។ តើនឹងមានអ្វីកើតឡើងដល់មនុស្សដែលមិនបានជឿព្រះនោះ? (សូមអានខគម្ពីរពេត្រុសទី១ ១:១៧)។**

__________________________________________________________________

__________________________________________________________________

នៅពេលដែលកវីបានក្រឡេកមើលរឿងអាក្រក់នៅជុំវិញគាត់ នោះគាត់បានចាប់ផ្តើមសង្ស័យព្រះ។ កវីបានយល់ឃើញថា មនុស្សអាក្រក់បានរីករាយជាមួយនឹងភាពជោគជ័យជាច្រើន។ ការជោគជ័យរបស់ពួកគេបានធ្វើឱ្យកវីសង្ស័យចំពោះផែនការរបស់ព្រះ។ កវីបានសង្ស័យថា «តើការដែលមានសេចក្តីជំនឿនោះគឺជារឿងឥតប្រយោជន៍ដែរឬទេ?»។

បន្ទាប់មក កវីបានគិតអំពីរោងឧបោសថរបស់ព្រះ នៅពេលដែលព្រះជំនុំជម្រះមនុស្សទាំងអស់។ ដូច្នេះហើយ សេចក្តីពិតនៅត្រង់នេះបានជួយឱ្យកវីយល់ថា ព្រះគឺជាអ្នកគ្រប់គ្រងអ្វីៗទាំងអស់។ មនុស្សអាក្រក់អាចនឹងគិតថា ពួកគេអាចធ្វើអ្វីតាមដែលពួកគេចង់បាននៅក្នុងជីវិតនេះ។ ប៉ុន្តែ នៅពេលអនាគត ពួកគេនឹងឆ្លើយប្រាប់ព្រះនូវរឿងទាំងអស់ដែលពួកគេបានធ្វើ។ នៅពេលដែលកវីបានយល់សេចក្តីពិតនេះ នោះគាត់បានដឹងថា គាត់បានធ្វើខុស ដោយបានសង្ស័យព្រះ។ គាត់បានលន់តួអំពើបាបរបស់គាត់ ពីព្រោះមានតែព្រះមួយគត់ដែលអាចជួយឱ្យយើងយល់អំពីអ្វីដែលសំខាន់នៅក្នុងជីវិតនេះ ពោលគឺ៖ យើងត្រូវតែរស់នៅដើម្បីទ្រង់ ទោះបីជាមនុស្សនៅជុំវិញយើងភាគច្រើនកំពុងតែរស់នៅដើម្បីខ្លួនឯង និងអំពើបាបក៏ដោយ។

**ព្រះនឹងជំនុំជម្រះមនុស្សគ្រប់គ្នាដែលបានរស់នៅលើផែនដីនេះ។ ព្រះនឹងជំនុំជម្រះសេចក្តីអាក្រក់ទាំងអស់ដែលមនុស្សលោកបានធ្វើ។ តើសេចក្តីសន្យានេះបានផ្តល់ក្តីសង្ឃឹមដល់យើង នៅពេលដែលមនុស្សជាច្រើននាក់បានធ្វើការអាក្រកក់ តែមិនទាន់បានជំនុំជម្រះនៅពេលឥឡូវនេះនោះដោយរបៀបណា?**

**ការសិក្សាបន្ថែម៖** សូមអាន Psalm 56: Ellen G. White, "Rejoicing in the Lord," pages 115-126, *in Steps to Christ*។

«នៅពេលដែលលោកអ្នកជួបនឹងបញ្ហា សូមកុំឱ្យលោកអ្នកឱនចុះក្រោមឡើយ តែសូមឱ្យលោកអ្នកបានសម្លឹងទៅឯព្រះនៅខាងលើវិញ។ សូមកុំឱ្យលោកអ្នកក្រឡេកមើលពីផលលំបាកនៃបញ្ហារបស់លោកអ្នកនោះឡើយ។ ប៉ុន្តែ នៅពេលដែលលោកអ្នកក្រឡេកទៅឯព្រះ នោះលោកអ្នកនឹងទទួលបានការកម្សាន្តចិត្តជានិច្ច។ មិនយូរប៉ុន្មាន លោកអ្នកនឹងបានឃើញព្រះហស្តរបស់ព្រះយេស៊ូវហុចទៅជួយលោកអ្នកជាមិនខាន។ អ្វីដែលលោកអ្នកត្រូវធ្វើនោះគឺថ្វាយដៃទាំងគូរបស់លោកអ្នកទៅឱ្យទ្រង់ដោយក្តីជំនឿវិញ។ ចូរឱ្យទ្រង់បានដឹកនាំលោកអ្នក។ នៅពេលដែលលោកអ្នកបានរៀនជឿទុកចិត្តទៅលើទ្រង់នោះលោកអ្នកនឹងមានពេញទៅដោយសេចក្តីសង្ឃឹមជាមិនខាន»។ ដកស្រង់ពី Ellen G. White, *Testimonies for the Church*, volume 5, pages 578, 579, adapted។

តើលោកអ្នកធ្លាប់បានគិតថា លោកអ្នកកំពុងតែតែលតោលម្នាក់ឯងដែរឬទេ? តើលោកអ្នកធ្លាប់បានគិតថា ព្រះបានបែរព្រះភ័ក្ត្ររបស់ទ្រង់ចេញពីលោកអ្នកដែរឬទេ? សូមឱ្យលោកអ្នកបានបន្តអធិស្ឋានតទៅទៀត។ នៅក្នុងសម័យយុគងងឹត កវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើងបានគិតថាព្រះបានគង់នៅឆ្ងាយពីពួកគេ។ តើកវីទាំងនេះបានធ្វើអ្វីខ្លះ? កវីទាំងនេះបានបន្តអធិស្ឋានតទៅមុខទៀត។ ពួកគេក៏បានក្រឡេកមើលទៅក្នុងចិត្តរបស់ពួកគេផងដែរ។ ពួកគេបាននឹកចាំពីសកម្មភាពសង្គ្រោះរបស់ព្រះកាលពីមុនមក។ ដូច្នេះហើយ ពួកគេបានលន់តួទៅព្រះនូវអំពើបាបរបស់ពួកគេ។ ហើយពួកគេក៏នៅតែបន្តសូមជំនួយពីទ្រង់ផងដែរ (ទំនុកតម្កើង ៧៧:១០-១២; ទំនុកតម្កើង ៨៩:៤៦-៥២)។

«សេចក្តីជំនឿរបស់យើងនឹងបានរឹងមាំឡើង នៅពេលដែលយើងបានជួបនឹងបញ្ហា និងមន្ទិលសង្ស័យតែយើងបានប្រយុទ្ធទាស់នឹងសេចក្តីទាំងនេះ។ នៅពេលដែលយើងប្រយុទ្ធទាស់នឹងបញ្ហា និងមន្ទិលសង្ស័យនេះ នោះយើងនឹងបានរៀនមេរៀនអំពីជីវិតដ៏សំខាន់មួយ ដែលមានតម្លៃវិសេសវិសាលជាងគ្រឿងអលង្ការទៅទៀត»។ ដកស្រង់ពី Ellen G. White, *Testimonies for the Church*, volume 3, page 555, adapted។

## សំណួរពិភាក្សា

១. តើកវីបានប្រយុទ្ធទាស់នឹងសេចក្តីភ័យខ្លាច ហើយនិងសេចក្តីមន្ទិលសង្ស័យអ្វីខ្លះ? តើលោកអ្នកបានជួបនឹងបទពិសោធន៍របស់លោកអ្នក ដោយសេចក្តីសង្ស័យ ហើយនិងសេចក្តីភ័យខ្លាចនេះយ៉ាងដូចម្តេចដែរ? តើលោកអ្នកបានរក្សាសេចក្តីជំនឿរបស់លោកអ្នកឱ្យបានរឹងមាំនៅក្នុងសេចក្តីជំនឿ នៅក្នុងអំឡុងនៃគ្រាលំបាកទាំងនេះដោយរបៀបណា?

២. តើយើងគួរតែស្វែងរកចម្លើយនៅទីណា នៅពេលដែលសេចក្តីជំនឿដែលយើងមានចំពោះព្រះត្រូវបានដាក់ទៅក្នុងការសាកល្បងនោះ? តើលោកអ្នកអាចផ្តល់សេចក្តីសង្ឃឹមអ្វី ដល់អ្នកដែលការឈឺចាប់បានធ្វើឱ្យពួកគេមានចម្ងល់ទៅលើសេចក្តីស្រឡាញ់របស់ព្រះនោះ?

៣. តើចម្លើយដែលលោកអ្នកបានឆ្លើយទាក់ទងទៅនឹងមូលហេតុដែលជំរុញឱ្យព្រះនៃសេចក្តីស្រឡាញ់ដែលមានអំណាចបំផុត បានបណ្តោយឱ្យរឿងអាក្រក់កើតឡើងនៅលើផែនដីនេះដោយរបៀបណា? តើសង្គ្រាមពិភពលោករវាងសេចក្តីល្អ និងសេចក្តីអាក្រក់ (មហាវិវាទ បានជួយឆ្លើយតបទៅនឹងសំណួរនេះយ៉ាងដូចម្តេចដែរ?

# ការដើរចេញពីព្រះ

កុមារសេគូលដែលមានអាយុ៥ឆ្នាំបានភិតភ័យជាខ្លាំង នៅពេលដែលលោកយាយរបស់គាត់បានព្រមានគាត់អំពីឋាននរកនោះ។ លោកយាយរបស់គាត់បាននិយាយថា «ឯងត្រូវតែធ្វើជាក្មេងល្អ បើមិនដូច្នោះទេ ឯងនឹងត្រូវធ្លាក់ទៅក្នុងឋាននរកជាមិនខាន។ ក្មេងប្រុសម្នាក់នេះបានសួរទៅវិញថា «តើ 'ធ្លាក់ទៅក្នុងឋាននរក' ហ្នឹង លោកយាយមានន័យយ៉ាងម៉េចដែរ?»។ គាត់បានឆ្លើយថា «ឯងនឹងត្រូវធ្លាក់ទៅក្នុងបឹងភ្លើង បើសិនជាឯងលួច ឬប្លន់របស់គេនោះ ដ្បិតឯងនឹងត្រូវឆេះអស់កល្បជានិច្ច»។

ពាក្យសម្តីរបស់លោកយាយបានធ្វើឱ្យដក់ជាប់អារម្មណ៍ភ័យខ្លាចនៅក្នុងចិត្តក្មេងប្រុសម្នាក់នេះ។ គាត់មិនដឹងថា គាត់ត្រូវយ៉ាងណាទេ ដោយសារតែដំបូង លោកយាយបាននិយាយថា ព្រះគឺជាសេចក្តីស្រឡាញ់ ប៉ុន្តែ ក្រោយមក លោកយាយបាននិយាយថា បើសិនជាសេគូលនិយាយកុហកវិញ នោះគាត់នឹងត្រូវធ្លាក់ទៅក្នុងឋាននរកជាមិនខាន។ កុមារសេគូលបានភិតភ័យ ដោយសារតែមានពេលខ្លះគាត់មិនដឹងថា គាត់គិតអ្វីមិនចេញ ក្រៅពីកុហកនោះឡើយ។ ក្មេងប្រុសម្នាក់នេះមិនដឹងថា គាត់ត្រូវធ្វើយ៉ាងណានោះឡើយ។ ដ្បិតគាត់មិនអាចវិលត្រឡប់ទៅរកឪពុកម្តាយរបស់គាត់វិញបានឡើយ ពីព្រោះពួកគេគឺជាអ្នកមិនជឿព្រះនៅក្នុងប្រទេសម៉ុងតេណេហ្គ្រោដែលជាប្រទេសកុម្មុយនីស្ត។ ហើយលោកយាយក៏ជាគ្រីស្ទានតែម្នាក់គត់ដែលកុមារសេគូលបានស្គាល់នៅក្នុងភូមិរបស់គាត់ផងដែរ។

ថ្ងៃមួយ នៅពេលដែលគាត់មិនឃើញមានអ្នកណានៅជុំវិញគាត់ នោះសេគូលបានចូលទៅពួននៅក្នុងគុម្ពព្រៃ ដើម្បីស្តីបន្ទោសព្រះ។ គាត់បាននិយាយថា «ឱព្រះអម្ចាស់អើយ ទូលបង្គំពិតជាមិនយល់ថា ហេតុអ្វីបានជាមនុស្សគ្រប់គ្នាហៅទ្រង់ថា ជាព្រះនៃសេចក្តីស្រឡាញ់យ៉ាងណានោះទេ ដ្បិតទូលបង្គំបានសម្លឹងឃើញថា ទ្រង់គឺជាអារក្ស មិនមែនជាព្រះនៃសេចក្តីស្រឡាញ់នោះឡើយ តើហេតុអ្វីបានជាទ្រង់បង្កើតទូលបង្គំមក ដើម្បីឱ្យធ្លាក់ទៅក្នុងបឹងភ្លើងយ៉ាងដូច្នេះ? តើទូលបង្គំត្រូវតែស្មោះត្រង់ដោយមិនអាចកុហក និងមិនអាចធ្វើរឿងអាក្រក់យ៉ាងដូចម្តេចទៅបាន? ទូលបង្គំមិនអាចជឿទ្រង់បានឡើយ ហើយក៏គ្មានថ្ងៃជឿទ្រង់ដែរ ពីព្រោះទ្រង់គឺជាអារក្ស»។

កុមារសេគូលបានសម្រេចចិត្តដើរចេញពីព្រះ។ គាត់បានដកចំណាប់អារម្មណ៍ចេញពីព្រះទាំងដែលគាត់មានអាយុត្រឹមតែ៥ឆ្នាំប៉ុណ្ណោះ។ ៩ឆ្នាំក្រោយមក នៅពេលដែលគាត់អាយុបាន១៤ឆ្នាំ លោកយាយបានឱ្យសេគូលទៅរៀននៅឯវិទ្យាល័យនៅក្នុងទីក្រុងសារ៉ាយេវ៉ូ (Sarajevo) ដែលជារាជធានីនៃប្រទេសបូស្នៀ និងហេហ្សេហ្គូវីណា (Bosnia and Herzegovina)។ នៅក្នុងចំណោមក្មេងប្រុស៧០០នាក់នៅឯសាលារៀន គាត់គឺជាមនុស្សតែម្នាក់គត់ដែលមកពីទីក្រុងម៉ុងតេណេហ្គ្រោ។ ដោយមានអារម្មណ៍ថា គាត់បានប្រឈមនឹងការតស៊ូដ៏ធំមួយនៅក្នុងនាមជាអ្នកក្រៅ ម្ល៉ោះហើយ គាត់បានប្រយុទ្ធ ដើម្បីឱ្យមិត្តរួមថ្នាក់បានទទួលយកគាត់។ គាត់បានព្យាយាមសឹងតែរាល់ថ្ងៃ។ សេគូលបានតបតទៅវិញយ៉ាងសាហាវ បើសិនជាមានអ្នកណាម្នាក់យកដៃមកប៉ះត្រចៀករបស់គាត់ទាំងខ្ទាន់ខ្ទាញ់ ដោយសារតែត្រចៀករបស់គាត់មានទ្រង់ទ្រាយដូចជាដៃពែង។ មានម្តងនោះ គាត់បានស្នាមដៃ ដោយសារតែមុតកាំបិត។ សេគូលក៏ជាអ្នកធ្វើបាបគេឯងផងដែរ។ នៅពេលដែលក្មេងៗតូចបានយកប្រអប់បាយពីផ្ទះមក នោះសេគូលនឹងទៅក្រឞួចអាវសិស្សពីក្រៅបង្អួតនៃបន្ទប់ស្នាក់របស់ពួកគេ ដើម្បីឱ្យពួកគេប្រគល់ប្រអប់បាយឱ្យគាត់។

បន្ទាប់ពីបានប្រយុទ្ធអស់រយៈពេល៣ឆ្នាំរួចមក ចំណង់នៃការចង់ដឹងសេចក្តីពិតបានជ្រាបចូលទៅក្នុងចិត្តរបស់សេគូល ធ្វើឱ្យគាត់ងឿងឆ្ងល់ថា លោកយាយរបស់គាត់ពិតជាបានប្រាប់គាត់នូវសេចក្តីអំពីព្រះដែរឬទេ។ ប៉ុន្តែ តើអ្វីទៅជាសេចក្តីពិតនោះ? វិទ្យាល័យសារ៉ាយេវ៉ូបានបើកបង្រៀនសាសនាធំៗជាច្រើន ដែលមានដូចជាសាសនាអ៊ីស្លាម សាសនាព្រះពុទ្ធ សាសនាកាតូលិក ហើយនិងសាសនាយូដា។ ប៉ុន្តែ សេគូលបានឆ្ងល់ថា ព្រះមានតែមួយអង្គគត់ ចុះហេតុអ្វីបានជាមានសាសនាច្រើនម្ល៉េះ? ដូច្នេះហើយ គាត់បានសម្រេចចិត្តរៀនអំពីសាសនាទាំងអស់ ដើម្បីស្វែងរកសេចក្តីពិត។

# ទូលបង្គំនឹងជួយដល់អ្នកក្រីក្រ



**ល្ងាចថ្ងៃបរិសុទ្ធ - ថ្ងៃសៅរ៍ ទី៣ ខែកុម្ភៈ ឆ្នាំ២០២៤**

**អំណានព្រះគម្ពីរសម្រាប់មេរៀនប្រចាំសប្តាហ៍នេះ៖ ទំនុកតម្កើង ១៨:៣-១៨; ទំនុកតម្កើង ៩:១៨; ទំនុកតម្កើង ៨២; ទំនុកតម្កើង ៩៦:៦-១០; ទំនុកតម្កើង ៩៩:១-៤។**

**ខចងចាំ៖ «ដូច្នេះ ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា អញនឹងក្រោកឡើងឥឡូវ ដោយព្រោះមានការសង្កត់សង្កិនដល់មនុស្សក្រលំបាក ហើយដោយព្រោះដំងូររបស់មនុស្សកម្សត់ទុគ៌ត អញនឹងដាក់គេឲ្យនៅទីសាន្តត្រាណ ដែលគេដង្ហក់រកនោះ» (ទំនុកតម្កើង ១២:៥)។**

យើងមិនមែនជាមនុស្សតែម្នាក់គត់ ដែលបានរស់នៅក្នុងសម័យអាក្រក់នោះឡើយ។ ដ្បិតកវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើងក៏បានរស់នៅក្នុងសម័យមួយដ៏អាក្រក់ផងដែរ។ កណ្ឌគម្ពីរទំនុកតម្កើងបានប្រាប់យើង អំពីសេចក្តីក្រោធរបស់ព្រះទាស់នឹងអំពើបាប និងការរងទុក្ខទាំងអស់ដែលបានកើតឡើងនៅលើផែនដីនេះ។

ជាការពិតណាស់ ព្រះអម្ចាស់ទ្រង់មានព្រះទ័យអត់ធ្មត់ ដោយទ្រង់បានទប់សេចក្តីក្រោធរបស់ទ្រង់ ដោយសារតែទ្រង់មិនចង់ឱ្យអ្នកណាម្នាក់បាត់បង់ជីវិតនោះឡើយ។ ព្រះអម្ចាស់ចង់ឱ្យមនុស្សគ្រប់គ្នាលន់តួអំពើបាបរបស់ពួកគេ ដោយផ្លាស់ប្តូររបៀបរស់នៅមិនល្អរបស់ពួកគេ (ពេត្រុសទី២ ៣:៩-១៥)។ ព្រះមិនដែលធ្វើកិច្ចការទៅតាមអ្វីដែលយើងបានរំពឹងទុកពីទ្រង់ ឬទៅតាមអ្វីដែលយើងចង់ឱ្យទ្រង់ធ្វើនោះឡើយ។ ប៉ុន្តែ យើងបានដឹងថា ពេលវេលាដែលទ្រង់ត្រូវបញ្ចប់កិច្ចការរបស់ទ្រង់ជាចៅក្រមនោះជិតមកដល់ហើយ (ទំនុកតម្កើង ៩៦:១៣; ទំនុកតម្កើង ៩៨:៩)។ ទ្រង់ក៏ជាព្រះអាទិកររបស់យើងផងដែរ។ ដូច្នេះហើយ ព្រះគឺជាបុគ្គលតែម្នាក់គត់ដែលអាចបង្កើតជីវិតជាថ្មី ឬអាចជំនុំជម្រះយើងបាន។ កិច្ចការរបស់ព្រះជាចៅក្រមនេះត្រូវបានចែកចេញជា២ផ្នែក៖ (១) ព្រះនឹងសង្គ្រោះកូនៗរបស់ទ្រង់ និង (២) ទ្រង់នឹងបំផ្លាញមនុស្សអាក្រក់ ដោយសារតែពួកគេបានបដិសេធមិនទទួលយកព្រះគុណរបស់ទ្រង់។

ព្រះបានសន្យាថា ទ្រង់នឹងធ្វើរឿងទាំង២យ៉ាងនេះសម្រាប់រាស្ត្ររបស់ទ្រង់។ យើងអាចជឿទុកចិត្តទៅលើព្រះបានថា ទ្រង់នឹងរក្សាសេចក្តីសន្យារបស់ទ្រង់។ ប៉ុន្តែ កណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងថា ព្រះនឹងធ្វើកិច្ចការរបស់ទ្រង់នៅក្នុងពេលវេលារបស់ទ្រង់ មិនមែននៅក្នុងពេលវេលារបស់យើងនោះឡើយ។

# ព្រះអម្ចាស់គឺជាអ្នកចម្បាំងដ៏ខ្លាំងពូកែ

**សូមអានខគម្ពីរទំនុកតម្កើង ១៨:៣-១៨; ទំនុកតម្កើង ៧៦:៣-៩, ១២; ទំនុកតម្កើង ១៤៤: ៥-៧។ តើខទាំងនេះបានបង្រៀនរូបស័ព្ទអ្វីខ្លះ? តើរូបស័ព្ទទាំងនេះបានបង្ហាញយើងថា ព្រះបានត្រៀមព្រះអង្គជាស្រេច ដើម្បីសង្គ្រោះរាស្ត្ររបស់ទ្រង់នោះដោយរបៀបណា?**

---

---

បទគម្ពីរទំនុកតម្កើង ជំពូក១៨; ទំនុកតម្កើង ជំពូក៧៦ និងទំនុកតម្កើង ជំពូក១១៤ គឺជាបទចម្រៀង។ បទចម្រៀងទាំងនេះបានសរសើរតម្កើងព្រះ ដោយបានសង្គ្រោះរាស្ត្ររបស់ទ្រង់ចេញពីខ្មាំងសត្រូវរបស់ពួកគេ។ បទចម្រៀងទាំងនេះបានបង្ហាញយើងថា ព្រះគឺជាចៅក្រម និងជាអ្នកចម្បាំងដ៏ខ្លាំងពូកែមួយអង្គ។ កណ្ឌគម្ពីរទំនុកតម្កើងតែងតែបង្ហាញយើងជានិច្ចថា ព្រះគឺជាអ្នកចម្បាំងដ៏ខ្លាំងពូកែម្នាក់។ កវីនៅក្នុងជំពូកទាំងនេះបានប្រើរូបស័ព្ទនេះ ដើម្បីបង្ហាញយើងថា ព្រះបានប្រយុទ្ធជំនួសមនុស្សរងទុក្ខរបស់ទ្រង់ ដែលបានអំពាវនាវសុំជំនួយពីទ្រង់នោះយ៉ាងដូច្នេះថា៖ «ព្រះយេហូវ៉ាទ្រង់បញ្ចេញជាផ្គរនៅលើមេឃ ព្រះដ៏ខ្ពស់បំផុត ទ្រង់បញ្ចេញព្រះសូរសៀង ព្រមទាំងព្រិល និងរងើកភ្លើងផង ក៏បាញ់ព្រួញនៃទ្រង់ទៅកំចាត់កំចាយគេនឹងរន្ទះជាច្រើន ទៅបំបាក់ពួកគេ នោះបាតផ្លូវទឹកក៏លេចឡើង ហើយឫសលោកីយ៍បានបើកឲ្យឃើញ ដោយទ្រង់បន្ទោស ឱព្រះយេហូវ៉ាអើយ គឺដោយព្យុះសូរខ្យល់គំហុក ចេញពីព្រះនាសាទ្រង់» (ទំនុកតម្កើង ១៨:១៣-១៥)។

បទគម្ពីរទំនុកតម្កើង ជំពូក១៨ បានជួយឱ្យយើងយល់ថា យើងមិនគួរសង្ស័យចំពោះការយកព្រះទ័យទុកដាក់ចំពោះយើងនោះទេ។ ទ្រង់មានព្រះចេស្តាល្មមនឹងច្បាំងទាស់នឹងខ្មាំងសត្រូវរបស់យើង ដោយយើងគ្រាន់តែត្រូវការរង់ចាំឱ្យទ្រង់ជួយដល់យើង នៅក្នុងពេលវេលារបស់ទ្រង់ប៉ុណ្ណោះ។

នៅពេលដែលរាស្ត្ររបស់ព្រះត្រូវការការសង្គ្រោះ នោះពួកគេបានដឹងថា ជំនួយរបស់មនុស្សលោកគឺជាជំនួយគ្មានប្រយោជន៍។ ស្តេចដាវីឌបានដឹងសេចក្តីពិតនេះយ៉ាងច្បាស់។ ទ្រង់បានសរសើរតម្កើងព្រះទុកជាបុគ្គលម្នាក់ដែលបានជួយឱ្យគាត់ឈ្នះសង្គ្រាមដែលគាត់បានច្បាំងនោះ។ ស្តេចដាវីឌបានសរសើរតម្កើងនូវភាពជោគជ័យទាំងអស់ដែលព្រះប្រទានឱ្យគាត់។

មែនហើយ ស្តេចដាវីឌបានមានបន្ទូលថា ព្រះអម្ចាស់បានបង្ហាត់ដៃរបស់គាត់ឱ្យចេះច្បាំង (ទំនុក-តម្កើង ១៨:៣៤)។ ប៉ុន្តែ ស្តេចបានសរសើរជំនាញដែលទ្រង់ចេះនៅក្នុងសង្គ្រាមនោះទេ។ ផ្ទុយទៅវិញ ស្តេចដាវីឌតែងតែជឿទុកចិត្តជានិច្ចថា ព្រះនឹងច្បាំងជំនួសគាត់ ហើយទ្រង់ក៏នឹងសង្គ្រោះគាត់ផងដែរ (ទំនុកតម្កើង ១៨:៤៧, ៤៨)។

នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង ស្តេចដាវីឌបានសរសើរតម្កើងព្រះអម្ចាស់ទុកជាព្រះអង្គសង្គ្រោះនៃរាស្ត្ររបស់ទ្រង់ (ទំនុកតម្កើង ១៤៤:១០-១៥)។ ការសរសើរតម្កើង ហើយនិងការអធិស្ឋានទៅកាន់ព្រះអម្ចាស់គឺជាអាថ៌កំបាំងនៃភាពជោគជ័យ និងជាកម្លាំងចិត្តរបស់ស្តេចដាវីឌ។ ដូច្នេះហើយ ចម្រៀងសរសើរតម្កើងព្រះ និងសេចក្តីអធិស្ឋានមានអំណាចខ្លាំងជាងអាវុធដទៃទៀត។ ពោលគឺយើងគ្រាន់តែជឿទុកចិត្តទៅលើព្រះប៉ុណ្ណោះ។ ទ្រង់ក៏ជាបុគ្គលម្នាក់ដែលស័ក្តិសមឱ្យយើងថ្វាយបង្គំទ្រង់។

**តើអ្នកប្រទានជំនាញ និងភាពជោគជ័យនៅក្នុងជីវិតរបស់លោកអ្នកនោះគឺជាអ្នកណា? តើហេតុអ្វីបានជាលោកអ្នកត្រូវតែចាំជានិច្ចថា លោកអ្នកបានជំពាក់របស់គ្រប់យ៉ាងនឹងទ្រង់យ៉ាងដូច្នេះ?**

# ការជួយដល់អ្នកក្រីក្រ និងអ្នកកម្សត់

**សូមអានខគម្ពីរទំនុកតម្កើង ៩:១៨; ទំនុកតម្កើង ១២:៥; ទំនុកតម្កើង ៤០:១៧; ទំនុកតម្កើង ១១៣:៧; ទំនុកតម្កើង ១៤៦:៦-១០ និងទំនុកតម្កើង ៤១:១-៣។ តើនៅក្នុងកំណាព្យនេះ យើងបានទទួលសារអ្វីដែរ?**

ព្រះគម្ពីរបានបង្រៀនយើងថា ព្រះបានយកព្រះទ័យទុកដាក់ចំពោះអ្នកណាដែលជាមនុស្សក្រីក្រ មនុស្សខ្វះខាត ស្ត្រីមេម៉ាយ ក្មេងកំព្រា និងសាសន៍ដទៃ (និក្ខមនំ ២២:២១-២៧; អេសាយ ៣:១៣-១៥)។ កណ្ឌគម្ពីរទំនុកតម្កើងក៏បានបង្ហាញឱ្យយើងឃើញនូវសារដដែលនេះផងដែរ។

កំណាព្យជាច្រើននៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានប្រើពាក្យថា «ពួកក្រីក្រ និងពួកកំសត់» ដើម្បីរៀបរាប់អំពីមនុស្សដែលត្រូវជំនួយពិសេសមកពីព្រះ។ កវីនៅក្នុងជំពូកទាំងនេះបានធ្វើកិច្ចការនេះ ដើម្បីបង្ហាញថា ព្រះមិនត្រឹមតែចង់ជួយរាស្ត្រដែលទ្រង់បានជ្រើសតាំងប៉ុណ្ណោះទេ តែទ្រង់ក៏ចង់ជួយមនុស្សទាំងអស់នៅគ្រប់ទីកន្លែងផងដែរ។

ពាក្យថា «ពួកក្រីក្រ និងពួកកំសត់» មានអត្ថន័យលើសពីមនុស្សដែលគ្មានប្រាក់ ឬសម្ភារៈប្រើប្រាស់ទៅទៀត។ «ពួកក្រីក្រ និងពួកកំសត់» ក៏បានបង្ហាញយើងអំពីមនុស្សដែលគ្មានសង្ឃឹម និងមនុស្សដែលងាយនឹងរងគ្រោះផងដែរ។ ដ្បិតព្រះបានស្រឡាញ់អ្នកក្រីក្រ និងអ្នកកម្សត់កំពុងតែរងទុក្ខតែម្នាក់ឯង។ ព្រះគឺជាបុគ្គលតែម្នាក់គត់ ដែលអាចជួយដល់មនុស្សបែបនេះបាន។ «ពួកក្រីក្រ និងពួកកម្សត់» ក៏មានបង្កប់អត្ថន័យខាងឯវិញ្ញាណផងដែរ។ ពេលគឺកវីបានប្រើអត្ថន័យនេះ ដើម្បីសំដៅទៅលើមនុស្សដែលបានស្រឡាញ់ព្រះ និងស្រឡាញ់សេចក្តីពិតនៅក្នុងព្រះគម្ពីររបស់ទ្រង់ផងដែរ។ បុគ្គលបែបនេះមិនបានពឹងផ្អែកទៅលើខ្លួនគាត់ឡើយ តែគាត់បានពឹងផ្អែកទៅលើព្រះទាំងស្រុងវិញ។

នៅពេលដែលយើងយកចិត្តទុកដាក់ចំពោះអ្នកក្រីក្រ និងអ្នកកម្សត់ (ទំនុកតម្កើង ៤១:១-៣) នោះយើងបានបង្ហាញសេចក្តីជំនឿរបស់យើងចំពោះព្រះជាមិនខាន។ នៅក្នុងសម័យព្រះគម្ពីរ មនុស្សដែលធ្វើបាបអ្នកក្រីក្រ និងអ្នកក្រីក្រត្រូវបានគេចាត់ទុកថា អំពើឧក្រិដ្ឋកម្មដ៏សាហាវមួយ (ចោទិយកថា ១៥:៧-១១)។ កណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងឱ្យធ្វើរឿងគ្រប់យ៉ាង ដែលយើងអាចធ្វើទៅបាន ដើម្បីជួយដល់អ្នកក្រីក្រ និងអ្នកកម្សត់។ ទន្ទឹមគ្នានេះ យើងក៏ត្រូវប្រកាន់ជំហរទាស់នឹងអ្នកដែលបានធ្វើបាបអ្នកក្រីក្រផងដែរ។

កណ្ឌគម្ពីរទំនុកតម្កើងបានបង្ហាញថា យើងអាចជឿទុកចិត្តទៅលើព្រះតែមួយគត់ ដើម្បីឱ្យបានប្រាជ្ញា និងបានជម្រកជ្រកកោណ។ រាស្ត្ររបស់ព្រះមិនត្រឹមតែដាក់សេចក្តីជំនឿទាំងអស់របស់ពួកគេទៅលើមនុស្សលោកដទៃទៀត ដើម្បីឱ្យពួកគេបានសង្គ្រោះ ដើម្បីសង្គ្រោះពួកគេ និងដោះស្រាយបញ្ហារបស់ពួកគេនោះឡើយ។ ដ្បិតមនុស្សទាំងនេះជាច្រើននាក់មិនបានគោរពតាមព្រះ ឬគោរពតាមបែបបទរបស់ទ្រង់នោះឡើយ។

ព្រះអម្ចាស់យេស៊ូវបានយាងមករស់នៅលើផែនដីនេះនៅក្នុងសណ្ឋានជាអ្នកក្រីក្រម្នាក់។ ទ្រង់បានបង្ហាញតាមរយៈជីវិតរបស់ទ្រង់ថា ទ្រង់បានយកព្រះទ័យទុកដាក់ចំពោះអ្នកក្រីក្រ ហើយនិងអ្នកកម្សត់។ ព្រះយេស៊ូវបានក្លាយជាអ្នកក្រ ដើម្បីឱ្យយើងបានក្លាយជាអ្នកមានវិញ (កូរិនថូសទី២ ៨:៩)។ ដ្បិតទ្រព្យសម្បត្តិរបស់ទ្រង់ក៏បានរួមបញ្ចូលទាំងការសង្គ្រោះយើងចេញពីអំពើបាប ហើយនិងការសង្គ្រោះយើងចេញពីការរងទុក្ខផងដែរ។ ព្រះយេស៊ូវបានសន្យានឹងយើងថា ទ្រង់នឹងប្រទានជីវិតអស់កល្បឱ្យនៅក្នុងនគររបស់ព្រះ (វិវរណៈ ២១:៤)។ ព្រះយេស៊ូវគឺជាចៅក្រមរបស់យើង ដែលទ្រង់នឹងដាក់ទោសមនុស្សទាំងឡាយណាដែលបានធ្វើបាបអ្នកក្រីក្រ ឬអ្នកកម្សត់ ហើយទ្រង់ក៏នឹងដាក់ទោសដល់អ្នកដែលបដិសេធមិនព្រមជួយពួកគេផងដែរ (ម៉ាថាយ ២៥:៣១-៤៦)។

**តើលោកអ្នកបានគិតអំពី «ពួកក្រីក្រ និងពួកកម្សត់» ដែលនៅជុំវិញយើងនេះច្រើនប៉ុនណាដែរ? តើយើងបានជួយពួកគេច្រើនប៉ុនណាដែរ?**

# មេដឹកនាំអាក្រក់

ព្រះអម្ចាស់បានប្រទានប្រាជ្ញាដល់ស្តេចនៃសាសន៍អ៊ីស្រាអែល ដើម្បីឱ្យស្តេចធ្វើការសម្រេចចិត្តឱ្យបានយុត្តិធម៌ (ទំនុកតម្កើង ៧២:១-៧, ១២-១៤)។ ស្តេចនៃសាសន៍អ៊ីស្រាអែលក៏បានបម្រើការជាចៅក្រមផងដែរ។ ព្រះបានបង្គាប់ឱ្យមេដឹកនាំទាំងនេះរក្សាសេចក្តីសុខសាន្តនៅក្នុងសាសន៍អ៊ីស្រាអែល ហើយក៏ឱ្យពួកគេយកចិត្តទុកដាក់ចំពោះអ្នកក្រីក្រ និងអ្នកកម្សត់ផងដែរ។ នៅពេលដែលមេដឹកនាំបានគោរពតាមព្រះ នោះទ្រង់នឹងសន្យាថា ទ្រង់នឹងប្រទានព្រះពរដល់ពួកបណ្តាជន ហើយនិងទឹកដីរបស់ពួកគេ។ អំណាចរបស់ស្តេចនៅក្នុងអ្នកដឹកនាំមានប្រភពមកពីការគោរពតាមព្រះ មិនមែនមកពីអំណាច ឬប្រាជ្ញារបស់មនុស្សនោះឡើយ។

**តើមានអ្វីកើតឡើង នៅពេលដែលមេដឹកនាំមិនមានភាពយុត្តិធម៌ ហើយធ្វើបាបមនុស្សដែលពួកគេគួរតែការពារវិញនោះ? សូមអានបទគម្ពីរទំនុកតម្កើង ជំពូក៨២ សម្រាប់ចម្លើយ។**

________________________________________________________________________

________________________________________________________________________

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៨២ ព្រះបានប្រកាសអំពីការដាក់ទោសរបស់ទ្រង់ទាស់នឹងការជំនុំជម្រះដ៏អាក្រក់របស់សាសន៍អ៊ីស្រាអែល។ នៅក្នុងខគម្ពីរទំនុកតម្កើង ៨២:១, ៦, «ព្រះ [ក្លែងក្លាយ]» មិនមានជារូបសំណាក ឬទេវតានោះឡើយ។ ដ្បិតទេវតា និងរូបសំណាកមិនអាចសង្គ្រោះរាស្ត្ររបស់ព្រះបានឡើយ។ ហេតុដូច្នេះហើយ ព្រះក្លែងក្លាយទាំងនេះមិនត្រូវបានព្រះជំនុំជម្រះនៅក្នុងបទនៃការមិនសង្គ្រោះសាសន៍អ៊ីស្រាអែលនោះឡើយ។ ហើយយើងក៏បានដឹងថា ព្រះក្លែងក្លាយទាំងនេះគឺជាមេដឹកនាំនៃសាសន៍អ៊ីស្រាអែលផងដែរ។ តើយើងបានដឹងដោយរបៀបណា? ពោលគឺដោយសារតែអំពើឧក្រិដ្ឋកម្មរបស់មេដឹកនាំត្រូវបានកត់ទុកនៅក្នុងខគម្ពីរទំនុកតម្កើង ៨២:២-៤។ អំពើឧក្រិដ្ឋកម្មទាំងនេះបានជួយឱ្យយើងនឹកចាំអំពីបញ្ញត្ត ដែលព្រះបានប្រទានដល់លោកម៉ូសេនៅក្នុងខគម្ពីរចោទិយកថា ១:១៦-១៨ និងចោទិកយកថា ១៦:១៨-២០។ (សូមអានខគម្ពីរយ៉ូហាន ១០:៣៣-៣៥)។ ព្រះបានសួរមេដឹកនាំថា ពួកគេបានកាត់ក្តីដោយយុត្តិធម៌ដែរឬទេ។ ព្រះបានសួរសំណួរបែបនេះ ដោយសារតែទ្រង់បានជ្រាបថា ពួកគេមិនបានកាត់ក្តីដោយយុត្តិធម៌នោះទេ។ ដូច្នេះហើយ ព្រះបានប្រកាសអំពីការដាក់ទោសរបស់ពួកគេ។ ហើយមេដឹកនាំទាំងនេះក៏មិនយល់អ្វីដែរ (ទំនុកតម្កើង ៨២:៥) ពីព្រោះពួកគេបានបដិសេធមិនគោរពតាមបញ្ញត្តរបស់ព្រះ (ទំនុកតម្កើង ១១៩:១០៥)។

ព្រះគម្ពីរបានប្រាប់យើងម្តងហើយម្តងទៀតថា ព្រះអម្ចាស់គឺជាព្រះតែមួយគត់។ ហើយទ្រង់ក៏បានចែករំលែកការគ្រប់គ្រងរបស់ទ្រង់នៅលើផែនដីនេះជាមួយនឹងមេដឹកនាំដែលទ្រង់បានជ្រើសតាំងផងដែរ (រ៉ូម ១៣:១)។ ប៉ុន្តែ មេដឹកនាំទាំងនេះភាគច្រើនមិនបានស្មោះត្រង់ចំពោះព្រះនោះទេ។

បទគម្ពីរទំនុកតម្កើង ជំពូក៨២ បានបង្ហាញសេចក្តីអាក្រក់នៅក្នុងចិត្តនៃមេដឹកនាំមួយចំនួន។ ហើយមេដឹកនាំទាំងនេះបានតាំងខ្លួន ដូចជាពួកគេជា «ព្រះ [ក្លែងក្លាយ]» ដែលខ្ពស់ជាងអ្នកដទៃអ៊ីចឹង។ ដ្បិតព្រះបានប្រទានប្រាជ្ញា និងអំណាចដល់មេដឹកនាំនៃសាសន៍អ៊ីស្រាអែល។ ប៉ុន្តែ ព្រះក៏បានបដិសេធមេដឹកនាំផងដែរ ដោយសារតែទ្រង់ចង់ឱ្យពួកគេចាំថា ពួកគេមិនអាចរស់នៅលើផែនដីនេះជារៀងរហូតបានឡើយ។ ដូច្នេះហើយ ពួកគេត្រូវតែគោរពតាមបញ្ញត្ត ដែលមេដឹកនាំដទៃទៀតបានគោរពនោះដែរ។ ដ្បិតបញ្ញត្តទាំងនេះគឺជាបញ្ញត្តរបស់ព្រះ ដែលមនុស្សគ្រប់គ្នាត្រូវកាន់តាមបញ្ញត្តដ៏បរិសុទ្ធរបស់ព្រះ (ទំនុកតម្កើង ៨២:៦-៨)។

ព្រះនឹងជំនុំជម្រះមនុស្សស្លាប់ និងមនុស្សរស់។ ដូច្នេះហើយ រាស្ត្ររបស់ព្រះក៏ត្រូវតែឈរនៅមុខព្រះ ដើម្បីបកស្រាយអំពីទង្វើ និងឥរិយាបថដែលពួកគេបានធ្វើចំពោះព្រះនោះដែរ។ ដូច្នេះហើយ ទាំងមេដឹកនាំទាំងពួកបណ្តាជនត្រូវតែរស់នៅតាមរបៀបដែលព្រះយេស៊ូវ ដែលជាចៅក្រមរបស់ពួកគេបានរស់នៅ ខណៈដែលទ្រង់នៅមានព្រះជន្មរស់នៅលើផែនដីនេះនៅឡើយ។ មានតែព្រះយេស៊ូវមួយគត់ដែលអាចសង្គ្រោះពួកគេបាន។

**តើលោកអ្នកគឺជាមេដឹកនាំ ឬជាចៅហ្វាយរបស់អ្នកណាម្នាក់ដែរឬទេ? តើលោកអ្នកយុត្តិធម៌ចំពោះកូនចៅរបស់លោកអ្នកច្រើនប៉ុនណាដែរ?**

## ឱព្រះអម្ចាស់អើយ សូមទម្លាក់សេចក្ដីក្រោធរបស់ទ្រង់មកលើទូលបង្គំចុះ

**សូមខគម្ពីរទំនុកតម្កើង ៨៨:៦-៨; ទំនុកតម្កើង ៦៩:២២-២៨; ទំនុកតម្កើង ៨៣:៩-១៧; ទំនុកតម្កើង ៩៤:១, ២ និងទំនុកតម្កើង ១៣៧:៧-៩ បន្ទាប់មក សូមឆ្លើយសំណួរទាំងនេះ។ តើកវីបានអាក់អន់ចិត្តអំពីអ្វីដែរ? តើក្នុងកំណាព្យទាំងនេះ អ្នកយុត្តិធម៌ដែលដាក់ទោសសេចក្ដីអាក្រក់នោះគឺជាអ្នកណា?**

______________________________________________________________

______________________________________________________________

កវីខ្លះនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានសូមឱ្យព្រះដាក់ទោសមនុស្ស និងនគរដែលបានមានបំណងចង់ធ្វើបាបសាសន៍អ៊ីស្រាអែល ឬបានធ្វើបាបពួកគេកាលពីមុនមក។ យើងអាចនឹងពិបាកយល់អំពីមូលហេតុដែលនាំឱ្យកវីទាំងនេះខឹងសម្បារ និងអាក់អន់ចិត្តនៅក្នុងកំណាព្យរបស់ពួកគេ។ ព្រះបានបង្រៀនយើងថា យើងគួរតែស្រឡាញ់ខ្មាំងសត្រូវរបស់យើង។ ដូច្នេះហើយ យើងអាចស្រមៃឃើញអំពីភាសានៃកំហឹង ដែលកវីនៅក្នុងជំពូកទាំងនេះបានយកមកប្រើ ដើម្បីទាស់នឹងបញ្ញត្តនៃព្រះគម្ពីរដែលថា យើងត្រូវតែស្រឡាញ់ខ្មាំងសត្រូវរបស់យើង (ម៉ាថាយ ៥:៤៤)។

ប៉ុន្តែ កំហឹងដែលកវីបានយកប្រើ ដើម្បីទាស់នឹងសេចក្ដីអាក្រក់ បានបង្ហាញយើងនូវអ្វីដែលមាននៅក្នុងចិត្តរបស់គាត់។ កំហឹងរបស់កវីបានបង្ហាញយើងថា គាត់បានយកចិត្តទុកដាក់ចំពោះអ្វីដែលបានកើតឡើងដល់អ្នកដទៃ។ កវីក៏បានយកចិត្តទុកដាក់ចំពោះបញ្ញត្តដ៏បរិសុទ្ធ និងសេចក្ដីសម្អប់ដែលព្រះមានចំពោះអំពើបាបដែលបានរំលងបញ្ញត្តនេះផងដែរ។

កវីមិនបានព្យាយាមសងសឹកខ្មាំងសត្រូវរបស់គាត់ ឬដាក់ទោសពួកគេនោះទេ។ ប៉ុន្តែ គាត់បានជឿថា មានតែព្រះមួយគត់គឺជាអ្នករកយុត្តិធម៌ឱ្យរាស្ត្ររបស់ទ្រង់។ កវីបានសូមឱ្យព្រះនឹកចាំអំពីសេចក្ដីសន្យារបស់ទ្រង់ដែលថា ទ្រង់នឹងដាក់ទោសមនុស្សអាក្រក់ជាមួយនឹងបណ្ដាសា (ចោទិយកថា ២៧:៩-១៦)។ ដូច្នេះហើយ កវីក៏បានសូមឱ្យព្រះបំពេញសេចក្ដីសន្យា និងសកម្មភាពរបស់គាត់នៅពេលឥឡូវនេះផងដែរ។

យើងត្រូវតែនឹកចាំថា កវីនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងគឺជាអ្នកអធិស្ឋាន។ ទន្ទឹមគ្នានេះ ពួកគេក៏ជាអ្នកប្រកាសអំពីកិច្ចការរបស់ព្រះជាចៅក្រមនៅពេលអនាគតផងដែរ។ បទគម្ពីរទំនុកតម្កើង ជំពូក ១៣៧ បានព្រមានយើងថា ព្រះនឹងជំនុំជម្រះទីក្រុងបាប៊ីឡូន។ ដ្បិតទីក្រុងនេះបានវាយប្រហារមនុស្ស និងនគរជាច្រើន ហើយក៏បានបង្កការឈឺចាប់ជាច្រើនយ៉ាងផងដែរ។ ព្រះនឹងធ្វើឱ្យអ្នកក្រុងបាប៊ីឡូនរងនូវការឈឺចាប់ ដែលពួកគេបានបង្កដល់សាសន៍ដទៃ។ កំណាព្យនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងមានពេញទៅដោយការព្រមានជាច្រើនយ៉ាង ដែលព្រះបានបង្ហាញដល់មនុស្សអាក្រក់។ ព្រះមិនដែលអនុញ្ញាតឱ្យមនុស្សអាក្រក់ធ្វើនូវអ្វីដែលពួកគេចង់ធ្វើនោះឡើយ តែទ្រង់នឹងដាក់ទោសពួកគេវិញ។

នៅពេលដែលព្រះជំនុំជម្រះមនុស្សលោក ទ្រង់តែងតែយុត្តិធម៌ជានិច្ច ដោយទ្រង់បានបង្ហាញសេចក្ដីមេត្តាដល់ពួកគេ។ ទន្ទឹមគ្នានេះ ព្រះក៏សូមឱ្យកូនៗរបស់ទ្រង់អធិស្ឋានឱ្យអ្នកដែលបានធ្វើដល់ពួកគេផងដែរ។ ដូច្នេះហើយ យើងក៏ត្រូវតែអធិស្ឋានឱ្យព្រះផ្លាស់ប្ដូរព្រះទ័យ ដើម្បីឱ្យទ្រង់សណ្ដិតនៅក្នុងមនុស្សដែលបានធ្វើបាបយើងវិញ ដើម្បីឱ្យពួកគេបានបម្រើព្រះផងដែរ (ទំនុកតម្កើង ៨៣:១៨; យេរេមា ២៩:៧)។

ព្រះបានជ្រាបពីរឿងទាំងអស់ដែលរាស្ត្ររបស់ទ្រង់បានរងទុក្ខ។ ដ្បិត «ការស្លាប់របស់ពួកអ្នកបរិសុទ្ធនៃព្រះយេហូវ៉ា ជាការវិសេសដល់ព្រះនេត្រទ្រង់» (ទំនុកតម្កើង ១១៦:១៥)។ ដោយសារតែព្រះត្រូវជំនុំជម្រះមនុស្សអាក្រក់នេះហើយ បានជាយើងត្រូវតែព្រមានមនុស្សគ្រប់គ្នាឱ្យទាស់នឹងអំពើបាប និងសេចក្ដីអាក្រក់វិញ។ កវីនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានអនុញ្ញាតឱ្យអ្នករងទុក្ខមើលឃើញថា ព្រះបានទតមើលការឈឺចាប់ទាំងអស់របស់ពួកគេ។ ដ្បិតព្រះនឹងធ្វើជាអ្នករកយុត្តិធម៌ឱ្យពួកគេ ដោយទ្រង់បានសន្យាថា ទ្រង់នឹងដាក់ទោសមនុស្សអាក្រក់ដែលបានធ្វើបាបកូនៗរបស់ទ្រង់។

## ចៅក្រមរបស់យើង និងរោងឧបោសថរបស់ទ្រង់

**តើកិច្ចការរបស់ព្រះជាចៅក្រមបានកើតឡើងនៅកន្លែងណា? តើចម្លើយនេះមានយ៉ាងណាដែរសម្រាប់យើង? តើរោងឧបោសថរបស់ព្រះនៅឯស្ថានសួគ៌បានជួយឱ្យយើងយល់អំពីរបៀបដែលព្រះត្រូវដោះស្រាយបញ្ហានៃអំពើបាប និងបញ្ហានៃសេចក្តីអាក្រក់នោះដោយរបៀបណា? សូមអានខគម្ពីរទំនុកតម្កើង ៩៦:៦-១០; ទំនុកតម្កើង ៩៩:១-៤ និងទំនុកតម្កើង ១៣២:៧-៩, ១៣-១៨ សម្រាប់ចម្លើយ។**

___

___

កិច្ចការរបស់ព្រះជាចៅក្រមត្រូវបានផ្សាភ្ជាប់ជាមួយនឹងរោងឧបោសថនៅឯស្ថានសួគ៌។ ដូច្នេះហើយ សេចក្តីពិតនៃព្រះគម្ពីរដែលស្តីអំពីរោងឧបោសថនេះ បានជួយឱ្យកវីនៅក្នុងបទគម្ពីរទំនុកតម្កើងជំពូក៧៣ បានយល់អំពីរបៀបដែលព្រះត្រូវជំនុំជម្រះបញ្ហានៃអំពើបាប ហើយនិងបញ្ហានៃសេចក្តីអាក្រក់ (ទំនុកតម្កើង ៧៣:១៧-២០)។ សម្លៀកបំពាក់របស់សម្តេចសង្ឃនៃសាសន៍អ៊ីស្រាអែលបានបង្ហាញថា រោងឧបោសថរបស់ព្រះគឺជាកន្លែងដែលព្រះត្រូវធ្វើកិច្ចការរបស់ទ្រង់ជាចៅក្រម ហើយក៏ជាកន្លែងដែលទ្រង់ត្រូវដោះស្រាយបញ្ហាអំពើបាបផងដែរ (លេវីវិន័យ ២៧:២១; និក្ខមនំ ២៨:១៥, ២៨-៣០)។ កវីនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងជាច្រើននាក់បានបង្ហាញថា ព្រះទ្រង់គង់នៅលើបល្ល័ង្ករបស់ទ្រង់នៅក្នុងរោងឧបោសថនៅឯស្ថានសួគ៌។ នៅទីនោះ ព្រះបានត្រៀមខ្លួនជាស្រេច ដើម្បីដាក់ទោសមនុស្សស្លាប់ និងមនុស្សរស់នូវរឿងគ្រប់យ៉ាងដែលពួកគេបានធ្វើនៅក្នុងជីវិតនេះ។

រោងឧបោសថរបស់ព្រះបានជួយឱ្យយល់ពីផែនការរបស់ព្រះនៅក្នុងការសង្គ្រោះយើងចេញពីអំពើបាបរបស់យើង។ នៅក្នុងសម័យព្រះគម្ពីរ មនុស្សដែលបានថ្វាយបង្គំព្រះក្លែងក្លាយបានជឿថា អំពើបាបគឺជារបស់ម៉្យាងដែលត្រូវតែដកចេញ ដោយប្រើវេទមន្ត។ ព្រះគម្ពីរបានប្រាប់យើងថា អំពើបាបគឺជាការរំលងបញ្ញត្តរបស់ព្រះ។ ដ្បិតព្រះជន្មដ៏បរិសុទ្ធរបស់ព្រះមានន័យថា គាត់បានស្រឡាញ់អ្វីៗគ្រប់យ៉ាងដែលស្អាតស្អំ នឹងយុត្តិធម៌។ ដូច្នេះហើយ រាស្ត្ររបស់ព្រះគួរតែបរិសុទ្ធ និងយុត្តិធម៌នៅក្នុងរឿងគ្រប់យ៉ាងដែលពួកគេបានធ្វើ។ ដើម្បីឱ្យបានសេចក្តីបរិសុទ្ធ រាស្ត្ររបស់ព្រះត្រូវតែរក្សាបញ្ញត្តរបស់ទ្រង់ ពីព្រោះបញ្ញត្តរបស់ទ្រង់បានបង្ហាញយើងអំពីជីវិត និងព្រះទ័យដ៏បរិសុទ្ធរបស់ទ្រង់។

រោងឧបោសថនៅឯស្ថានសួគ៌គឺជាកន្លែងដែលព្រះលើកលែងទោសអំពើបាប។ ទ្រង់ក៏បានធ្វើឱ្យយើងក្លាយមកជាមនុស្សថ្មី និងបរិសុទ្ធមកពីរោងឧបោសថរបស់ទ្រង់ផងដែរ។ ទន្ទឹមគ្នានេះ ព្រះដែលលើកលែងទោសក៏ជាអ្នករកយុត្តិធម៌ឱ្យរាស្ត្ររបស់ទ្រង់ផងដែរ។ ដ្បិតទ្រង់នឹងដាក់ទោសដល់មនុស្សអាក្រក់ដែលមិនបានលន់តួអំពើបាបរបស់ពួកគេ ហើយពួកគេក៏មិនបានឈប់ធ្វើរឿងទាំងនោះដែរ (ទំនុកតម្កើង ៩៩:៨)។

កិច្ចការរបស់ព្រះអម្ចាស់ជាចៅក្រមបានកើតឡើងនៅលើភ្នំស៊ីយ៉ូន។ ភ្នំស៊ីយ៉ូនគឺជាឈ្មោះតំណាងឱ្យរោងឧបោសថដ៏បរិសុទ្ធរបស់ព្រះ។ នៅក្នុងកិច្ចការរបស់ទ្រង់ជាចៅក្រមព្រះនឹងសង្គ្រោះកូនៗរបស់ទ្រង់ ហើយដាក់ទោសដល់មនុស្សអាក្រក់វិញ (ទំនុកតម្កើង ១៣២:១៣-១៨)។ រោងឧបោសថរបស់ព្រះបានផ្តល់សេចក្តីសង្ឃឹមដល់យើង ដោយបង្រៀនយើងឱ្យរំពឹងទុកថា ព្រះបានធ្វើកិច្ចការរបស់ទ្រង់ជាចៅក្រម។ កណ្ឌគម្ពីរទំនុកតម្កើងបានប្រទានសេចក្តីជំនឿ និងសេចក្តីសង្ឃឹមដល់យើងនៅក្នុងកិច្ចការរបស់ទ្រង់ជាចៅក្រម (ទំនុកតម្កើង ៩៦:១៣; ទំនុកតម្កើង ៩៨:៩)។ ព្រះយេស៊ូវគ្រីស្ទគឺជាចៅក្រមរបស់យើងដែលបានធ្វើកិច្ចការជាច្រើននៅក្នុងរោងឧបោសថនៅឯស្ថានសួគ៌ ដើម្បីសង្គ្រោះយើង (វិវរណៈ ១១:១៥-១៩)។

**សូមអានខគម្ពីររ៉ូម ៨:៣៤។ តើខនេះបានបង្ហាញយើងថា កិច្ចការដែលព្រះយេស៊ូវបានធ្វើសម្រាប់យើងនៅក្នុងរោងឧបោសថនៅឯស្ថានសួគ៌គឺជាដំណឹងល្អសម្រាប់រាស្ត្ររបស់ទ្រង់នោះដោយរបៀបណា?**

**ការសិក្សាបន្ថែម៖** សូមអាន Ellen G. White, "The Beatitudes," pages 6-13, 29-35, in *Thoughts From the Mount of Blessing*។

«ព្រះយេស៊ូវបានមានបន្ទូលថា ' អ្នករាល់គ្នាមានពរ ក្នុងកាលដែលគេជេរ បៀតបៀន ហើយនិយាយបង្ខូសគ្រប់ទាំងសេចក្តីអាក្រក់ ពីអ្នករាល់គ្នា ដោយព្រោះខ្ញុំ' (ម៉ាថាយ ៥:១១)។ ព្រះយេស៊ូវក៏បានប្រាប់ឱ្យសិស្សរបស់ទ្រង់នឹកចាំពីពាក្យពេចន៍នៃពួកហោរារបស់ព្រះនៅក្នុងគម្ពីរសញ្ញាចាស់ផងដែរ។ ហោរាទាំងនេះគឺជាអ្នកនាំសារពិសេសមកពីព្រះ។ ពួកគេបានចែកចាយនូវព្រះបន្ទូលដែលព្រះអម្ចាស់បានបង្គាប់ឱ្យពួកគេនិយាយ។ ហោរាពិសេសទាំងនេះគឺជារូបស័ព្ទតំណាងឱ្យសិស្សរបស់ព្រះយេស៊ូវ។ ដ្បិតព្រះគម្ពីរបានចែងថា 'មានពរហើយ អស់អ្នកដែលត្រូវគេបៀតបៀន ដោយព្រោះសេចក្តីសុចរិត ដ្បិតនគរស្ថានសួគ៌ជារបស់ផងអ្នកទាំងនោះ' (ម៉ាថាយ ៥:១០)។ លោកអេបិល (Abel) គឺជាអ្នកគ្រីស្ទានដំបូងគេបង្អស់នៅក្នុងចំណោមកូនទាំងអស់របស់លោកអ័ដាម។ ពីព្រោះគាត់ត្រូវបានគេសម្លាប់ ដោយសារតែសេចក្តីជំនឿដែលគាត់មានចំពោះព្រះ។ លោកហេណុកបានរស់នៅក្នុងជីវិតនៃការស្តាប់បង្គាប់។ ដ្បិតមនុស្សនៅសម័យគាត់មិនបានយល់អំពីលោកហេណុក ដោយសារតែគាត់បានដើរជាមួយនឹងព្រះ។ នៅក្នុងសម័យលោកណូអេ ពួកបណ្ឌិតជនបានសើចចំអកឱ្យគាត់ ដោយសារតែសេចក្តីជំនឿ និងគោលជំនឿរបស់គាត់។ អ្នក 'ខ្លះទៀតត្រូវសេចក្តីល្បួង ដោយមានគេចំអកឲ្យ ទាំងវាយនឹងរំពាត់ ក៏ទ្រាំទាំងជាប់ចំណង និងជាប់គុកផង' (ហេព្រើរ ១១:៣៦)។ 'ពួកស្រីៗ បានទទួលមនុស្សស្លាប់របស់ខ្លួនមក ដោយរស់ពីស្លាប់ឡើងវិញ ខ្លះត្រូវគេធ្វើទុក្ខវេទនា ឥតទទួលការប្រោសលោះឲ្យរួចឡើយ គឺដើម្បីឲ្យបានរស់ឡើងវិញបែបប្រសើរជាង' (ហេព្រើរ ១១:៣៥)»។ ដកស្រង់ពី Ellen G. White, *Thoughts From the Mount of Blessing*, page 33, adapted។

### សំណួរពិភាក្សា

១. នៅពេលដែលយើងបានឃើញសេចក្តីអាក្រក់បានកើតឡើងនៅជុំវិញយើង នោះយើងប្រហែលជាឆ្ងល់ថា «តើព្រះអម្ចាស់ពិតជាអ្នកគ្រប់គ្រងអ្វីៗគ្រប់យ៉ាងដែរឬទេ?»។ តើយើងអាចប្រកាន់ជំហរនៅក្នុងព្រះអម្ចាស់ នៅក្នុងអំឡុងពេលនេះដោយរបៀបណា នៅពេលដែលសេចក្តីជំនឿរបស់យើងត្រូវដាក់ទៅក្នុងការសាកល្បងនោះ? តើយើងត្រូវតែធ្វើដូចម្តេច ដើម្បីរក្សាសេចក្តីជំនឿរបស់យើងឱ្យបានរឹងមាំនៅក្នុងសេចក្តីស្រឡាញ់ និងនៅក្នុងអំណាចរបស់ព្រះដោយរបៀបណា? តើឈើឆ្កាងបានបង្រៀនយើងអំពីសេចក្តីស្រឡាញ់ និងអំណាចរបស់ព្រះយ៉ាងដូចម្តេចដែរ?

២. តើហេតុអ្វីបានវាសំខាន់ម្ល៉េះ នៅក្នុងការមិនពឹងផ្អែកទៅលើមេដឹកនាំ រាជរដ្ឋាភិបាល ឬក្រុមពិសេសណាមួយ ដែលយើងបានឃើញនៅជុំវិញយើង តែងតែទទួលបាននូវការកាត់ក្តីយ៉ាងយុត្តិធម៌យ៉ាងដូច្នេះ? តើហេតុអ្វីបានជាយើងត្រូវតែជឿទៅលើព្រះគម្ពីរ ដែលជាព្រះបន្ទូលរបស់ព្រះ ហើយក៏ត្រូវតែជឿទៅលើកិច្ចការដែលទ្រង់បានធ្វើសម្រាប់យើងនៅក្នុងនាមជាចៅក្រមនោះយ៉ាងដូច្នេះ?

# ការអញ្ជើញឱ្យចូលថ្វាយបង្គំនៅក្នុងព្រះវិហារ

លោកសេគូល (Sekule) ដែលជាសិស្សវិទ្យាល័យនៅក្នុងទីក្រុងសារ៉ាយេវ៉ូ ដែលជាទីក្រុងនៃប្រទេសប៊ូស្នៀ និងហេហ្សេហ្គូវីណា អាយុ១៧ឆ្នាំ មានបំណងចង់ដឹងសេចក្តីពិត ដូច្នេះហើយ គាត់បានចាប់ផ្តើមចូលថ្វាយបង្គំនៅក្នុងព្រះវិហារនៅតាមផ្ទះជាច្រើនកន្លែង។ ប៉ុន្តែ គាត់មិនបានស្កប់ចិត្តនឹងចម្លើយឆ្លើយតបទៅនឹងសំណួររបស់គាត់ទាល់តែសោះ ដែលសំណួរបានថា ហេតុអ្វីបានជាព្រះនៃសេចក្តីស្រឡាញ់ដុតមនុស្សនៅក្នុងឋាននរករអស់កល្បជានិច្ចយ៉ាងដូច្នេះ។ ម្ល៉ោះហើយ លោកសេគូលបានសម្រេចចិត្តស្វែងរកសេចក្តីពិតដោយខ្លួនគាត់ តាមរយៈការអានគម្ពីរសញ្ញាថ្មី។

លុះដល់គាត់ត្រឡប់មកកាន់ភូមិរបស់គាត់នៅក្នុងទីក្រុងម៉ុងតេណេហ្គ្រោនៅក្នុងរដូវក្តៅ នោះគាត់បានអានព្រះគម្ពីរមួយថ្ងៃមួយកណ្ឌ។ នៅថ្ងៃដំបូង គាត់បានអានបទគម្ពីរម៉ាថាយ ជំពូក២៨។ នៅថ្ងៃបន្ទាប់ គាត់បានអានកណ្ឌគម្ពីរម៉ាកុស។ បន្ទាប់មក គាត់បានអានកណ្ឌគម្ពីរលូកា យ៉ូហាន កិច្ចការ និងកណ្ឌគម្ពីររ៉ូម។ គាត់បានអានមួយកណ្ឌនៅក្នុងរយៈពេលត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ទោះបីជាគាត់បានអានមកដល់សំបុត្រតូចៗ ដូចជាកណ្ឌគម្ពីរទីតុស និងកណ្ឌគម្ពីរភីលីម៉ូនក៏ដោយ។

ចម្លើយមួយចំនួនដែលបានឆ្លើយតបទៅនឹងសំណួរដែលគាត់បានចោទសួរអំពីព្រះនេះ បានផុសឡើង នៅពេលដែលគាត់បានអានគម្ពីរសញ្ញាថ្មី។ ប៉ុន្តែ គាត់នៅតែប្រាថ្នាចង់បានព័ត៌មានបន្ថែមទៀត។ គាត់បានបន្តទៅថ្វាយបង្គំនៅឯព្រះវិហារនៅតាមផ្ទះជាច្រើនកន្លែងទៀត។ ប៉ុន្តែ គាត់មិនបានទៅថ្វាយបង្គំនៅក្នុងព្រះវិហារសេវេនដេយអាត់វេនទីស្ទនោះឡើយ។ ពីព្រោះគាត់ធ្លាប់ឮគេថា អ្នកអាត់វេនទីស្ទបានប្រារព្ធ «ថ្ងៃសប្បាតហ៍ដ៏រីករាយ» ជារៀងរាល់សប្តាហ៍ ដែលថ្ងៃនោះគឺជាពេលដែលសមាជិកប្រុសស្រីបានចូលមក ដើម្បីញៀញង់គ្នា។ លោកសេគូលបានគិតថា *អ្នកអាត់វេនទីស្ទគឺជាក្រុមវ៉ល់ ដូច្នេះហើយ ក្រុមនេះគ្មានសេចក្តីពិតអ្វីឡើយ*។

ដោយការអាក់ខានមិនមានចម្លើយនៅក្នុងព្រះវិហារនៅតាមផ្ទះដែលគាត់បានសួរសុខទុក្ខ នោះគាត់បានសន្មតថា នៅលើលោកនេះ គ្មានព្រះនោះទេ។ គាត់បានឈប់អានព្រះគម្ពីរ។ បន្ទាប់មក គ្រូវិទ្យាល័យរបស់គាត់ម្នាក់បានឃើញព្រះគម្ពីររបស់លោកសេគូល។ នាងគឺជាអ្នកអាត់វេនទីស្ទ ហើយនាងបានឃើញព្រះគម្ពីររបស់គាត់ ខណៈពេលដែលគ្រូដទៃទៀតបានរៀបចំឆែកគ្រឿងញៀន និងស្រាដែលសិស្សលាក់នៅក្នុងបន្ទប់ស្នាក់នៅ។ នាងបាននិយាយថា «សេគូល តើនេះជាព្រះគម្ពីររបស់កូនឬ?»។ លោកសេគូលបានតបទៅវិញថា «បាទ អ្នកគ្រូ»។ អ្នកគ្រូសួរទៀតថា «តើកូនបានរៀនមេរៀនអ្វីខ្លះ?»។ គាត់បានតបទៅវិញថា «ខ្ញុំបានរៀនមេរៀនជាច្រើន»។

អ្នកគ្រូបានសួរសំណួរលោកសេគូលអំពីលោកដានីយ៉ែល ប៉ុន្តែ លោកសេគូលដែលមានការចងចាំល្អបានឆ្លើយចម្លើយយ៉ាងច្បាស់លាស់វិញ។ នាងបានលាន់មាត់ថា «កូនពិតជាយល់ច្រើនមែន ពីព្រោះកូនគឺជាអ្នកយល់ច្រើនជាងសិស្សដទៃទៀតទាំងអស់ ដែលអ្នកគ្រូបានជួប ដូច្នេះហើយ កូនត្រូវតែទៅថ្វាយបង្គំនៅឯព្រះវិហារសេវេនដេយអាត់វេនទីស្ទ»។ លោកសេគូលមិនហ៊ានបដិសេធនឹងសំណើនេះឡើយ ដោយសារតែគាត់គឺជាអ្នកគ្រូរបស់សេគូល។ គាត់ខ្លាចអ្នកគ្រូដកពិន្ទុគាត់ បើសិនមិនបានទៅព្រះវិហារអាត់វេនទីស្ទនោះ។ ដូច្នេះហើយ គាត់បាននិយាយថា «បាទ អ្នកគ្រូ ខ្ញុំនឹងទៅ»។ ប៉ុន្តែ គាត់គ្រាន់តែនិយាយកុហកអ្នកគ្រូប៉ុណ្ណោះ។ ដ្បិតគ្មានគម្រោងទៅថ្វាយបង្គំនៅក្នុងព្រះវិហារអាត់វេនទីស្ទនោះឡើយ។

# ព្រះគុណ និងសេចក្ដីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះ



**ល្ងាចថ្ងៃបរិសុទ្ធ - ថ្ងៃសៅរ៍ ទី១០ ខែកុម្ភៈ ឆ្នាំ២០២៤**

**អំណានព្រះគម្ពីរសម្រាប់មេរៀនប្រចាំសប្ដាហ៍នេះ៖ ទំនុកតម្កើង ១៣៦; ទំនុកតម្កើង ៥១; ទំនុកតម្កើង ១៣០; ទំនុកតម្កើង ១១៣; ទំនុកតម្កើង ១២៣; ទំនុកតម្កើង ១០៣។**

**ខចងចាំ៖ «ឱព្រះអម្ចាស់អើយ ទូលបង្គំនឹងប្រទូលដែដល់ទ្រង់នៅកណ្ដាលពួកជន ទូលបង្គំនឹងច្រៀងសរសើរទ្រង់ នៅកណ្ដាលពួកសាសន៍ដទៃ ដ្បិតសេចក្ដីសប្បុរសនៃទ្រង់ខ្ពស់ដល់ស្ថានសួគ៌ ហើយសេចក្ដីពិតរបស់ទ្រង់ក៏ខ្ពស់ដល់ផ្ទៃមេឃ»** (ទំនុកតម្កើង ៥៧:៩, ១០)។

កវីដែលបានសរសេរកណ្ឌគម្ពីរទំនុកតម្កើងបានយល់ឃើញថា ពួកគេគឺជាមនុស្សក្រីក្រ និងជាមនុស្សខ្វះខាត។ ដូច្នេះហើយ ពួកគេត្រូវការព្រះគុណរបស់ព្រះ ដើម្បីសង្គ្រោះពួកគេ។ ពួកគេក៏បានដឹងថា ពួកគេមិនអាចយកទង្វើល្អរបស់ពួកគេទៅដោះដូរយកព្រះគុណរបស់ព្រះបានទេ។ ដូច្នេះហើយ ពួកគេគ្មានអ្វីល្អនឹងថ្វាយទៅព្រះនោះឡើយ។

កណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងថា មនុស្សលោកត្រូវតែពឹងផ្អែកទាំងទៅលើព្រះគុណរបស់ព្រះទាំងស្រុង។ យើងអាចអរព្រះគុណដល់ព្រះ ដែលព្រះគុណរបស់ទ្រង់នោះគឺនៅអស់កល្បជានិច្ច។ ប្រវត្តិសាស្ត្រនៃរាស្ត្ររបស់ព្រះបានបង្ហាញសេចក្ដីពិតនេះដល់យើង រួមទាំងរបស់គ្រប់យ៉ាងដែលព្រះបានបង្កើតផងដែរ (ទំនុកតម្កើង ១៣៦)។ ដ្បិតព្រះទ្រង់មានព្រះជន្មរស់អស់កល្បជានិច្ច ប៉ុន្តែ ជីវិតមនុស្សលោកគឺដូចជាស្មៅវិញ។ យើងរស់នៅលើផែនដីនេះតាមត្រឹមតែមួយរយៈពេលខ្លីប៉ុណ្ណោះ បន្ទាប់មកយើងនឹងត្រូវស្លាប់ទៅ។ ប៉ុន្តែ ព្រះទ្រង់មានព្រះទ័យអាណិតអាសូរដល់យើងដែលជាមនុស្សលោក ដោយបានធ្វើឱ្យយើងមានកម្លាំងចិត្តជាថ្មីវិញ (ទំនុកតម្កើង ១០៣:៣, ៥, ១៥)។ ព្រះបានប្រទានសេចក្ដីសន្យានៃជីវិតអស់កល្បដល់យើង។

រាស្ត្ររបស់ព្រះបានដឹងថា ពួកគេបានអធិស្ឋានទៅកាន់ព្រះវរបិតានៅឯស្ថានសួគ៌ដែលបានស្រឡាញ់ពួកគេ (ទំនុកតម្កើង ១០៣:១៣; ទំនុកតម្កើង ៦៨:៥; ទំនុកតម្កើង ៨៩:២៦)។ ពួកគេបានទទួលបទពិសោធន៍ថ្មីៗដែលបានបង្រៀនពួកគេអំពីសេចក្ដីមេត្តា និងសេចក្ដីស្រឡាញ់របស់ព្រះនេះជារៀងរាល់ថ្ងៃ។ បទពិសោធន៍ទាំងនេះបានជួយឱ្យពួកគេបានថ្វាយបង្គំព្រះ និងបម្រើទ្រង់បន្ថែមទៀត។ ដោយសារតែព្រះទ្រង់អស្ចារ្យនេះឯង បានជារាស្ត្ររបស់ទ្រង់មានបំណងចង់ថ្វាយបង្គំទ្រង់ និងចង់បម្រើទ្រង់តែម្នាក់គត់ប៉ុណ្ណោះ។

# ព្រះគុណរបស់ព្រះនឹងបន្តជារៀងរហូតតទៅ

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក១៣៦។ តើសេចក្តីពិតនៃព្រះគម្ពីរដ៏សំខាន់បំផុតនៅក្នុងកំណាព្យនេះគឺជាអ្វី? តើកវីបានស្វែងរកភស្តុតាងគាំទ្រគោលគំនិតនេះនៅកន្លែងណា?**

___

___

បទគម្ពីរទំនុកតម្កើង ជំពូក១៣៦ បានសូមឱ្យរាស្ត្ររបស់ព្រះសរសើរតម្កើងព្រះអម្ចាស់ចំពោះព្រះគុណរបស់ទ្រង់។ សាសន៍អ៊ីស្រាអែលដែលជារាស្ត្ររបស់ព្រះអាចមើលឃើញព្រះគុណរបស់ទ្រង់តាមរយៈរបស់គ្រប់យ៉ាងដែលទ្រង់បានបង្កើតមក ហើយនិងតាមរយៈប្រវត្តិសាស្ត្ររបស់ពួកគេ (ទំនុកតម្កើង ១៣៦:១០-២២)។ ពាក្យថា «ព្រះគុណ» ប្រែមកពីពាក្យថា «ឃេសេដ (Khesed)» ជាភាសាហេព្រើរ ដែលមានន័យថា សេចក្តីស្រឡាញ់របស់ព្រះមិនដែលផ្លាស់ប្តូរឡើយ។

ព្រះអម្ចាស់គឺជា «ព្រះដ៏ធំលើអស់ទាំងព្រះ» និងជា «ព្រះអម្ចាស់ដ៏ធំលើអស់ទាំងព្រះអម្ចាស់» (ទំនុកតម្កើង ១៣៦:២, ៣)។ ព្រះនាមដ៏ពិសេសទាំងនេះមិនមានន័យថា មានថា នៅលើសកលលោកនេះមានព្រះដទៃទៀតនោះឡើយ។ ដ្បិត «ព្រះដ៏ធំលើអស់ទាំងព្រះ» និងជា «ព្រះអម្ចាស់ដ៏ធំលើអស់ទាំងព្រះអម្ចាស់» បានបង្ហាញយើងថា ទ្រង់គឺជាព្រះតែមួយគត់។

គ្មានអ្នកណាម្នាក់អាចធ្វើបាដិហារ្យដ៏អស្ចារ្យដែលព្រះបានធ្វើនោះឡើយ (ទំនុកតម្កើង ១៣៦:៤)។ ដ្បិតទ្រង់បានបង្កើតផ្ទៃមេឃ ផែនដី ផ្កាយ និងភពទាំងអស់នៅលើសកលលោកនេះ។ មនុស្សជាច្រើននាក់នៅក្នុងសម័យព្រះគម្ពីរបានជឿថា ផ្កាយ និងភពដទៃទៀតគឺជាព្រះ ដូច្នេះហើយ ពួកគេបានថ្វាយបង្គំផ្កាយ និងភពទាំងនោះ (ចោទិយកថា ៤:១៩)។ កណ្ឌគម្ពីរទំនុកតម្កើងបានបង្ហាញយើងថា «ព្រះ[ក្លែងក្លាយ]» ទាំងនេះគឺជារបស់ដែលព្រះបានបង្កើត។ ដូច្នេះហើយ «ព្រះ» ទាំងនេះមិនអាចគ្រប់គ្រងអ្វីបានឡើយ។

នៅក្នុងខគម្ពីរទំនុកតម្កើង ១៣៦:១២ កវីបានយកព្រះហស្តរបស់ព្រះមកធ្វើជារូបស័ព្ទ ដើម្បីបង្ហាញយើងថា ព្រះទ្រង់មានអំណាចខ្លាំងពូកែជាទីបំផុត។ ព្រះហស្តរបស់ព្រះបានជួយឱ្យយើងយល់ថា ព្រះគុណរបស់ព្រះអាចទៅប៉ះពាល់ចិត្តមនុស្សគ្រប់គ្នានៅគ្រប់ទីកន្លែង។

ព្រះគុណរបស់ព្រះគួរតែធ្វើឱ្យរាស្ត្ររបស់ទ្រង់ជឿទុកចិត្តទៅលើទ្រង់ ដោយរក្សាភាពស្មោះត្រង់ចំពោះទ្រង់ និងចំពោះសេចក្តីសន្យារបស់ទ្រង់ផងដែរ។ នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក១៣៦ កវីបានប្រកាស២៦ដងថា សេចក្តីមេត្តារបស់ព្រះបានបន្តជារៀងរហូត។ ការប្រកាសនេះបានផ្តល់សេចក្តីសង្ឃឹមដល់យើងថា ព្រះអម្ចាស់មិនបានផ្លាស់ប្តូរព្រះទ័យរបស់ទ្រង់ឡើយ។ តែទ្រង់នឹងបង្ហាញព្រះគុណដល់រាស្ត្ររបស់ទ្រង់ ដោយបន្តប្រទានព្រះពរដល់កូនចៅរបស់ពួកគេតទៅទៀត។ ព្រះបាននឹកចាំអំពីរាស្ត្ររបស់ទ្រង់ (ទំនុកតម្កើង ១៣៦:២៣)។ ហើយទ្រង់ក៏បានរក្សាសេចក្តីសន្យារបស់ទ្រង់ផងដែរ។ ពីព្រោះព្រះគុណគឺជាគ្រឹះនៃសេចក្តីសន្យារបស់ព្រះ។ នៅពេលដែលយើងជឿទៅលើព្រះគុណរបស់ព្រះ នោះយើងនឹងបានពេញទៅដោយសេចក្តីអំណរនៅក្នុងការថ្វាយបង្គំទ្រង់ជាមិនខាន។

ខគម្ពីរទំនុកតម្កើង ១៣៦:២៣-២៥ បានបញ្ចប់ជាមួយនឹងពិពណ៌នាប្រាប់យើង អំពីរបៀបដែលព្រះបានយកព្រះទ័យទុកដាក់ចំពោះមនុស្សគ្រប់គ្នា ព្រមទាំងយកព្រះទ័យទុកដាក់ចំពោះរបស់គ្រប់យ៉ាងនៅលើផែនដីនេះផងដែរ។ ដ្បិតទ្រង់បានប្រទានព្រះគុណរបស់ទ្រង់ដល់រាស្ត្ររបស់ទ្រង់ និងដល់អ្វីៗគ្រប់យ៉ាងដែលទ្រង់បានបង្កើតនោះដែរ។ កណ្ឌគម្ពីរទំនុកតម្កើងបានប្រាប់យើងថា ព្រះគុណរបស់ព្រះគឺសម្រាប់មនុស្សគ្រប់គ្នា។ ដូច្នេះហើយ កវីបានអញ្ជើញឱ្យអ្នកអានកណ្ឌគម្ពីរនេះបានចូលរួមជាមួយនឹងសាសន៍យូដា នៅពេលដែលពួកគេសរសើរតម្កើងព្រះអម្ចាស់ (សូមអានខគម្ពីរលូកា ២:១០; យ៉ូហាន ៣:១៦; កិច្ចការ ១៥:១៧)។

**តើការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាងបានបង្ហាញយើងនៅក្នុងវិធីមួយដ៏មានឥទ្ធិពលដែលថា សេចក្តីស្រឡាញ់ និងព្រះគុណរបស់ព្រះនឹងត្រូវបន្តជារៀងរហូតនោះដោយរបៀបណាដែរ?**

# សូមបង្កើតចិត្តបរិសុទ្ធនៅក្នុងទូលបង្គំ

**សូមអានខគម្ពីរទំនុកតម្កើង ៥១:១-៥។ តើហេតុអ្វីបានជាកវីនៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក ៥១ បានសូមឱ្យព្រះបង្ហាញសេចក្តីមេត្តាដល់គាត់យ៉ាងដូច្នេះ?**

______________________________________________________________________

ស្តេចដាវីឌបានសរសេរកណ្ឌគម្ពីរទំនុកតម្កើង ជំពូក៥១។ នៅក្នុងកំណាព្យនេះ ស្តេចដាវីឌបានបង្ហាញចិត្តរបស់ទ្រង់ដល់ព្រះអម្ចាស់។ ស្តេចដាវីដបានសូមឱ្យព្រះលើកលែងទោសឱ្យគាត់នូវអំពើបាបដែលគាត់បានធ្វើនៅក្នុងគ្រាងងឹងនៃជីវិតរបស់ទ្រង់នោះ (សាំយូអែលទី២ ១១ និង១២)។ ស្តេចដាវីឌបានរួមភេទជាមួយនឹងប្រពន្ធគេ រួចបន្ទាប់មក ទ្រង់បានបញ្ជូនបុរសម្នាក់ទៅឱ្យគេសម្លាប់នៅក្នុងសមរភូមិ។ ស្តេចដាវីឌបានដឹងថា ទ្រង់បានធ្វើបាបទាស់នឹងព្រះ (ទំនុកតម្កើង ១០៣:១០)។ ប៉ុន្តែ ទ្រង់បានសូមឱ្យព្រះបង្ហាញសេចក្តីមេត្តាដល់ទ្រង់វិញ (ទំនុកតម្កើង ៥១:១; និក្ខមនំ ៣៤:៦, ៧)។ ការលើកលែងទោសគឺជាអំណោយទាននៃសេចក្តីមេត្តា និងសេចក្តីស្រឡាញ់របស់ព្រះ (ទំនុកតម្កើង ៥១:១)។

**សូមអានខគម្ពីរទំនុកតម្កើង ៥១:៦-១៩។ តើខទាំងនេះបានបង្រៀនយើងអំពីការលើកលែងទោសរបស់ព្រះយ៉ាងដូចម្តេចដែរ? តើការលើកលែងទោសរបស់ព្រះបានផ្លាស់ប្តូរយើងដោយរបៀបណា? តើមានការលើកលែងទោសណាទៀត ដែលព្រះបានប្រទានឱ្យយើងដែរឬទេ?**

______________________________________________________________________

______________________________________________________________________

ការលើកលែងទោសរបស់ព្រះមានទំហំលើសពីការប្រកាសជាផ្លូវការថា ឥឡូវនេះ មនុស្សមានបាបគ្មានទោសនៅក្នុងព្រះនេត្ររបស់ព្រះទៀតឡើយ។ ដ្បិតការលើកលែងទោសរបស់ព្រះបានផ្លាស់ប្តូរយើងពីខាងក្នុង (ទំនុកតម្កើង ៥១:៦; ហេព្រើរ ៤:១២)។ ព្រះបានបង្កើតជីវិតរបស់យើងជាថ្មី (ទំនុកតម្កើង ៥១:១០; យ៉ូហាន ៣:៣-៨)។ ពាក្យ «បង្កើត» ប្រែមកពីពាក្យថា «បារ៉ា (bara)» ជាភាសាហេព្រើរ។ ពាក្យថា «បារ៉ា» បានបង្ហាញយើងថា ព្រះអាចធ្វើអ្វីៗគ្រប់យ៉ាងកើតចេញដោយឯកឯងបាន បើសិនជាទ្រង់ចង់។ ពីព្រោះទ្រង់គឺជាបុគ្គលតែម្នាក់គត់ដែលអាច «បង្កើត» ឬ «បារ៉ា» អ្វីទាំងអស់បាន។ ដ្បិតមានតែព្រះមួយគត់ដែលអាចផ្លាស់ប្តូរចិត្តរបស់មនុស្សមានបាបបាន (កូរិនថូសទី២ ៤:៦)។

ស្តេចដាវីឌបានសូមឱ្យព្រះសម្អាតចិត្តរបស់ទ្រង់ជាមួយនឹងដើមហ៊ីស៊ុប (លេវីវិន័យ ១៤:២-៨; ទំនុកតម្កើង ៥១:៧)។ ដើមហ៊ីស៊ុបគឺជាដើមឈើម្យ៉ាងដែលសម្តេចសង្ឃនៃសាសន៍អ៊ីស្រាអែលបានយកមកប្រើនៅក្នុងកម្មវិធីពិសេសនៃការថ្វាយបង្គំរបស់ពួកគេ។ ស្តេចដាវីឌបានគិតថា កំហុសរបស់គាត់បានបំបែកគាត់ចេញពីព្រះ ដូចជាមនុស្សឃ្លង់បានបែរចេញពីសហគមន៍របស់គេទៅរស់នៅតែម្នាក់ឯង នៅពេលដែលគាត់មានជំងឺសើស្បែកយ៉ាងដូច្នោះដែរ (ទំនុកតម្កើង ៥១:១១)។ ស្តេចដាវីឌបានជឿថា តង្វាយដុតមិនអាចធ្វើឱ្យក្លាយមកជាមនុស្សថ្មីបានឡើយ។ ដ្បិតទ្រង់បានដឹងថា គ្មានអំណោយណាដែលទ្រង់អាចនាំយកទៅថ្វាយព្រះ ដើម្បីឱ្យបានចេញថ្លៃលោះអំពើបាបដ៏អាក្រក់របស់ទ្រង់នោះឡើយ (ទំនុកតម្កើង ៥១:១៦; និក្ខមនំ ២១:១៤; លេវីវិន័យ ២០:១០)។

សេចក្តីមេត្តារបស់ព្រះបានអនុញ្ញាតឱ្យទ្រង់ទទួលយកតង្វាយនៃការលន់តួរបស់ស្តេចដាវីឌ។ នេះហើយគឺជាមូលហេតុដែលនាំឱ្យស្តេចដាវីឌបានមានបន្ទូលថា «ឯតង្វាយដែលគួរថ្វាយដល់ព្រះ នោះគឺជាវិញ្ញាណខ្ទេចខ្ទាំ ឱព្រះអម្ចាស់អើយ ទ្រង់មិនមើលងាយចំពោះចិត្តខ្ទេចខ្ទាំ ហើយទន់ទាបឡើយ» (ទំនុកតម្កើង ៥១:១៧)។ នៅពេលដែលស្តេចដាវីឌបានសូមឱ្យព្រះសម្អាតចិត្តរបស់ទ្រង់ជាមួយនឹងដើមហ៊ីស៊ុប នោះស្តេចដាវីឌបានបង្ហាញថា ទ្រង់ពិតជាចង់ត្រឡប់មកឯព្រះមែន។

**បើសិនជាព្រះអាចលើកលែងទោសឱ្យឃាតករ អ្នកកេងប្រវ័ញ្ច និងអ្នកកុហកបានមែននោះ តើយើងទាំងអស់គ្នាមានសេចក្តីសង្ឃឹមអ្វីដែរ?**

# តើយ៉ាងណាទៅវិញ បើសិនជាព្រះបានដាក់ទោសអំពើបាបរបស់យើងវិញនោះ?

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក១៣០។ តើកំណាព្យនេះបានប្រាប់យើងអំពីអំពើបាប និងភាពអាក្រក់របស់វាយ៉ាងដូចម្ដេចដែរ? តើមនុស្សមានបានបានទទួលសេចក្ដីសង្ឃឹមអ្វីដែរ?**

______________________________________________________________________

______________________________________________________________________

អំពើបាបរបស់កវី ហើយនិងអំពើបាបរបស់ប្រជារាស្ត្ររបស់ទ្រង់ បានធ្វើឱ្យកវីទទួលរងនូវការឈឺចាប់ (ទំនុកតម្កើង ១៣០:៣, ៨)។ អំពើបាបរបស់មនុស្សលោកអាក្រក់ល្មមនឹងអាចបំបែកពួកគេចេញពីព្រះជារៀងរហូត (ទំនុកតម្កើង ១៣០:៣)។ ដ្បិតព្រះក៏បានកត់ត្រាទុកអំពើបាបរបស់យើងនៅឯស្ថានសួគ៌ផងដែរ ដោយទ្រង់នឹងប្រើក្រាំងកត់ត្រាទាំងនេះ នៅពេលដែលទ្រង់ជំនុំជម្រះយើង (ដានីយ៉ែល ៧:១០; វិវរណៈ ២០:១២)។ ឈ្មោះរបស់មនុស្សមានបាបនឹងត្រូវបានលុបចេញពីក្រាំងជីវិត បើសិនជាពួកគេមិនបានលន់តួអំពើបាបរបស់ពួកគេ ដោយនៅបន្តធ្វើអំពើបាបទាំងនោះតទៅទៀតនោះ (និក្ខមនំ ៣២:៣២; ទំនុកតម្កើង ៦៩:២៨; វិវរណៈ ១៣:៨)។

កវីនៅក្នុងជំពូកនេះបានសូមឱ្យព្រះលើកលែងទោសឱ្យគាត់។ ពីព្រោះការលើកលែងទោសរបស់ព្រះគឺជាវិធីតែមួយគត់ ដែលអាចលុបអំពើបាបចេញពីក្រាំងនៅឯស្ថានសួគ៌បាន (ទំនុកតម្កើង ៥១:១, ៩; យេរេមា ៣១:៣៤; មីកា ៧:១៩)។ កវីនៅក្នុងជំពូកនេះបានដឹងថា «ព្រះមិនមែនជាព្រះនៃកំហឹងនោះឡើយ តែទ្រង់គឺជាព្រះនៃសេចក្ដីស្រឡាញ់វិញ។ ព្រះទ្រង់ខ្វាល់តែនៅពេលដែលមនុស្សលោកមិនបានដឹងគុណចំពោះអំណោយទាននៃសេចក្ដីស្រឡាញ់របស់ទ្រង់ប៉ុណ្ណោះ . . . . ព្រះមិនបានចាក់សេចក្ដីក្រោធរបស់ទ្រង់មកលើយើង ដើម្បីធ្វើបាបយើងនោះទេ។ ផ្ទុយទៅវិញ សេចក្ដីក្រោធរបស់ទ្រង់គឺជាមធ្យោបាយមួយ ដើម្បីព្យាបាលយើងវិញ។ ព្រះមិនចង់បំផ្លាញយើងឡើយ តែទ្រង់ចង់សង្គ្រោះរាស្ត្ររបស់ទ្រង់វិញ (សូមអានខគម្ពីរហូសេ ៦:១, ២)»។ ដកស្រង់ពី Hans K. LaRodelle, *Delieverance in the Psalms* (Berrien Springs, MI: First Impressions, 1983), pages 180, 181, adapted។ ព្រះទ្រង់សព្វព្រះទ័យនឹងលើកលែងទោសអំពើបាបរបស់យើង ដោយមិនដាក់ទោសយើង ដោយសារតែអំពើបាបទាំងនោះឡើយ។ សេចក្ដីស្រឡាញ់តាមរយៈការលើកលែងទោសរបស់ព្រះនេះក៏បានផ្ដល់សេចក្ដីស្រឡាញ់ដល់ចិត្តរបស់យើងផងដែរ។ បន្ទាប់មក យើងនឹងមានចិត្តចង់ថ្វាយបង្គំ ព្រមទាំងចង់លើកតម្កើងទ្រង់ដែរ (ទំនុកតម្កើង ១៣០:៤; រ៉ូម ២:៤)។ ម្ល៉ោះហើយ យើងត្រូវតែថ្វាយបង្គំទ្រង់ ដោយសារតែយើងបានគោរពស្រឡាញ់ដល់ទ្រង់ មិនមែនដោយសារតែទ្រង់ដាក់ទោសយើងនោះឡើយ។

កូនៗរបស់ព្រះត្រូវតែរង់ចាំព្រះអម្ចាស់ដោយក្ដីអត់ធ្មត់ (ទំនុកតម្កើង ២៧:១៤; ទំនុកតម្កើង ៣៧:៣៤)។ តើយើងបានអង្គុយរង់ចាំឱ្យព្រះអម្ចាស់ឆ្លើយតបទៅនឹងសេចក្ដីអធិស្ឋានរបស់យើង ដោយមិនធ្វើអ្វីសោះដែរឬទេ? ទេ មិនមែនដូច្នោះឡើយ។ នៅពេលដែលយើងបានរង់ចាំចម្លើយពីព្រះអម្ចាស់នោះយើងបានតោងជាប់ទៅនឹងសេចក្ដីសន្យារបស់ព្រះអម្ចាស់ដែលមានប្រភពចេញមកពីព្រះគម្ពីរ តាមរយៈសេចក្ដីជំនឿ (ទំនុកតម្កើង ១៣០:៥)។ ដូច្នេះហើយ ការរង់ចាំព្រះអម្ចាស់របស់យើងមិនមែនជារឿងខាតបង់នោះឡើយ។ ហើយការរង់ចាំព្រះអម្ចាស់ក៏មិនមែនជាពេលដែលយើងមិនត្រូវធ្វើអ្វីសោះនោះដែរ។ ដូច្នេះហើយ ជំនួយរបស់ព្រះនឹងបានប្រទានមកឱ្យយើង នៅពេលដែលយើងត្រូវការវាជាចាំបាច់។

តើលោកអ្នកបានឃើញអំពីរបៀបដែលកវីបានសូមឱ្យព្រះជួយមនុស្សគ្រប់គ្នានៅក្នុងសហគមន៍រួមជំនឿរបស់គាត់ដែរឬទេ (ទំនុកតម្កើង ១៣០:៧, ៨)? កវីនៅក្នុងជំពូកនេះបានដឹងថា មនុស្សគ្រប់គ្នានៅក្នុងសហគមន៍មានទំនាក់ទំនងជាមួយនឹងគ្នា។ ដូច្នេះហើយ គាត់បានអធិស្ឋានសម្រាប់ខ្លួនគាត់ និងសហគមន៍របស់គាត់ទាំងមូល។ នៅក្នុងនាមជាគ្រីស្ទាន យើងក៏ជាផ្នែកមួយនៅក្នុងសហគមន៍រួមជំនឿរបស់គាត់ផងដែរ។ ដូច្នេះហើយ យើងគួរតែរក្សាការចាំយាមនៅក្នុងអធិស្ឋានឱ្យគ្នាទៅវិញមក។

## ការសរសើរតម្កើងព្រះ

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក១១៣ និងទំនុកតម្កើង ជំពូក១២៣។ តើកំណាព្យទាំងនេះបានសរសើរតម្កើងព្រះទៅលើរឿងអ្វីដែរ?**

________________________________________

________________________________________

បទគម្ពីរទំនុកតម្កើងជំពូក១១៣និងទំនុកតម្កើងជំពូក១២៣បានសរសើរតម្កើងព្រះសម្រាប់ព្រះគុណ និងអំណាចដ៏ស្មោះត្រង់របស់ទ្រង់។ មានតែព្រះមួយអង្គគត់ ដែលអាចគង់នៅលើបល្ល័ង្កនៃស្ថានសួគ៌។ ម៉្លោះហើយ បល្ល័ង្ករបស់ព្រះក៏បានបង្ហាញយើងអំពីសិរីរុងរឿងរបស់ទ្រង់ ព្រមទាំងបានបង្ហាញថា ទ្រង់មានអំណាចខ្លាំងពូកែផងដែរ។ ហើយទ្រង់ក៏មានអំណាចលើសជាមេដឹកនាំនៅលើផែនដីនេះ ឬនៅលើមេឃផងដែរ។ ពីព្រោះព្រះទ្រង់ធំលើសជាងអ្វីៗទាំងអស់ (ទំនុកតម្កើង ១១៣:៤, ៥; ទំនុកតម្កើង ១២៣:១)។ នេះហើយគឺជាមូលហេតុដែលនាំឱ្យកវីមានប្រសាសន៍ថា «តើមានអ្នកឯណាឲ្យដូចជាព្រះយេហូវ៉ាជាព្រះ នៃយើងខ្ញុំ ជាព្រះដែលគង់នៅស្ថានដ៏ខ្ពស់នោះ» (ទំនុកតម្កើង ១១៣:៥)។ ខនេះបានបង្ហាញអំពីសេចក្តីជំនឿរបស់កវីនៅក្នុងជំពូកនេះ ដោយគាត់បានជឿថា នៅលើផែនដី ឬនៅលើស្ថានសួគ៌ គ្មានបុគ្គលណា ដែលមានអំណាចជាងព្រះនៃសាសន៍អ៊ីស្រាអែលនោះឡើយ។

បល្ល័ង្ករបស់ព្រះអម្ចាស់គឺនៅខ្ពស់ផុតពីផែនដី។ ដូច្នេះហើយ កវីបានមានប្រសាសន៍ថា ព្រះអម្ចាស់បាន «ឱនព្រះនេត្រ ដើម្បីទតមើលផ្ទៃមេឃ និងផែនដី» (ទំនុកតម្កើង ១១៣:៦)។ ប៉ុន្តែ ព្រះអម្ចាស់កំពុងតែឱនព្រះនេត្រ ដើម្បីទតមើលកូនៗរបស់ទ្រង់វិញ។ ដ្បិតទ្រង់បានទតឃើញអ្វីៗគ្រប់យ៉ាងដែលបានកើតឡើងនៅលើផែនដីនេះ។ ដោយសារតែទ្រង់មានពេញទៅដោយសេចក្តីមេត្តានេះហើយ បានជាទ្រង់បានត្រៀមព្រះអង្គជាស្រេច ដើម្បីរំដោះអ្នកក្រីក្រ និងអ្នកខ្វះខាតចេញពីបញ្ហារបស់ពួកគេ។ ព្រះអម្ចាស់មិនបានលាក់ព្រះអង្គទ្រង់ចេញពីអ្នកបម្រើរបស់ទ្រង់នោះឡើយ ទោះបីជាទ្រង់បានគង់នៅឆ្ងាយពីពួកគេក៏ដោយ។

យើងមិនអាចយល់ទាំងស្រុង អំពីព្រះហឫទ័យដែលព្រះមានចំពោះយើងបានឡើយ។ ពីព្រោះព្រះបានយកព្រះទ័យទុកដាក់ចំពោះអ្នកក្រីក្រ និងអ្នកខ្វះខាត ដោយទ្រង់បានផ្លាស់ប្តូរជីវិតរបស់ពួកគេ។ ហើយព្រះក៏បានធ្វើបាដិហារ្យអស្ចារ្យជាច្រើន ដើម្បីជួយដល់ពួកគេផងដែរ។ ទ្រង់បានបង្ហាញយើងថា ទ្រង់មានអំណាចខ្លាំងពូកែ នៅពេលដែលទ្រង់ជួយដល់អ្នកកំសត់ និងជួយអ្នកឈឺចាប់នោះ។ មនុស្សលោកបានគិតថា ពួកគេអាចចូលមកទៅឯព្រះបាន ដោយសារតែពួកគេបានដឹងថា ទ្រង់គឺជាព្រះអាទិកររបស់ពួកគេ និងជាអ្នកទ្រទ្រង់ជីវិតរបស់ពួកគេ។ ទន្ទឹមគ្នានេះ យើងក៏បានដឹងថា យើងគឺជាអ្នកបម្រើរបស់ព្រះ ហើយក៏អ្នកទ្រទ្រង់ជីវិតពួកគេនោះដែរ។

យើងបានថ្វាយបង្គំព្រះ ដោយសារតែទ្រង់មានអំណាចខ្លាំងពូកែ។ លើសពីនេះទៅទៀតនោះ យើងបានថ្វាយបង្គំព្រះ ក៏ដោយសារតែទ្រង់ជាព្រះនៃសេចក្តីស្រឡាញ់ និងសេចក្តីបរិសុទ្ធផងដែរ។ យើងអាចសរសើរតម្កើងព្រះនៅគ្រប់ពេលវេលា និងនៅគ្រប់ទីកន្លែង (ទំនុកតម្កើង ១១៣:២, ៣)។ យើងបានឃើញសិរីរុងរឿង និងសេចក្តីមេត្តារបស់ព្រះនៅក្នុងព្រះយេស៊ូវ។ ពីព្រោះព្រះយេស៊ូវបានយល់ព្រមលះចាកបល្ល័ង្ករបស់ទ្រង់នៅឯស្ថានសួគ៌ ដើម្បីយាងមកសង្គ្រោះយើងនៅលើផែនដីនេះ។ ព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង ដើម្បីនាំមនុស្សមានបាបត្រឡប់ទៅឯព្រះវិញ (ភីលីព ២:៦-៨)។ ឈើឆ្កាងបានបង្ហាញយើងពីហេតុផលដ៏ល្អបំផុតសម្រាប់សំណួរដែលថា ហេតុអ្វីបានជាយើងគួរតែថ្វាយបង្គំ និងសរសើរតម្កើងព្រះចំពោះរឿងគ្រប់យ៉ាងដែលទ្រង់បានធ្វើសម្រាប់យើងនោះ។

**សូមគិតអំពីឈើឆ្កាង និងអ្វីៗគ្រប់យ៉ាងដែលព្រះយេស៊ូវបានធ្វើសម្រាប់យើងនៅលើឈើឆ្កាងនោះ។ តើព្រះយេស៊ូវបានសង្គ្រោះយើងចេញពីអ្វីខ្លះ? តើហេតុអ្វីបានជាលោកអ្នកត្រូវតែគិតអំពីរឿងទាំងនេះយ៉ាងដូច្នេះ?**

## ការនឹកចាំអំពីព្រះពរទាំងអស់របស់ព្រះ

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក១០៣។ តើកំណាព្យនេះបានបង្រៀនយើងអំពីព្រះពរជាច្រើនរបស់ព្រះដែលបានប្រទានឱ្យយើងនោះយ៉ាងដូចម្តេចដែរ?**

____________________________________________________________

____________________________________________________________

បទគម្ពីរទំនុកតម្កើង ជំពូក១០៣ បានប្រាប់យើងអំពីព្រះពរជាច្រើនរបស់ព្រះ ដែលព្រះពរទាំងនេះក៏បានរាប់បញ្ចូលទាំងកិច្ចការល្អៗដែលព្រះអម្ចាស់បានធ្វើសម្រាប់យើងផងដែរ (ទំនុកតម្កើង ១០៣:២)។ ដ្បិតព្រះអម្ចាស់បាន «ប្រោសប្រទានឲ្យសំបកកាយនៃឯង បានស្កប់ស្កល់ដោយរបស់ល្អ» (ទំនុកតម្កើង ១០៣:៣-៦)។ ព្រះអម្ចាស់បានប្រទានព្រះពរទាំងនេះដល់យើង ដោយសារតែទ្រង់គឺជាព្រះនៃសេចក្តីស្រឡាញ់។ ហើយទ្រង់ក៏បានប្រទានព្រះពរទាំងនេះដល់យើង ដោយសារតែទ្រង់បាននឹកចាំអំពីសេចក្តីសន្យាដែលទ្រង់បានតាំងឡើងជាមួយនឹងរាស្ត្ររបស់ទ្រង់ ហើយទ្រង់ក៏បានរក្សាសេចក្តីសន្យាទាំងនោះផងដែរ (ទំនុកតម្កើង ១០៣:៧-១៨)។ ព្រះអម្ចាស់បាននឹកចាំថា មនុស្សលោកគឺជាមនុស្សកម្សោយ ដែលអាចរស់នៅបានត្រឹមតែមួយរយៈពេលខ្លីប៉ុណ្ណោះ។ ម្ល៉ោះហើយ រឿងនេះបានធ្វើឱ្យព្រះអម្ចាស់មានព្រះទ័យអាណិតអាសូរដល់រាស្ត្ររបស់ទ្រង់ (ទំនុកតម្កើង ១០៣:១៣-១៧)។

តើនៅក្នុងព្រះគម្ពីរ ការនឹកចាំមានន័យយ៉ាងណាដែរ?

ការនឹកចាំមិនត្រឹមតែជាការនឹកឃើញអំពីរឿងអតីតកាលនោះទេ។ ការនឹកចាំក៏មានន័យថាយើងបានបញ្ចេញសកម្មភាពធ្វើអ្វីមួយនៅក្នុងពេលឥឡូវនេះផងដែរ។ នៅពេលដែលព្រះបាននឹកចាំអំពីសេចក្តីសន្យារបស់ទ្រង់ នោះមានន័យថា ទ្រង់ក៏នឹងបញ្ចេញសកម្មភាពផងដែរ ដោយទ្រង់បានយាងមកជួយរាស្ត្ររបស់ទ្រង់ និងបានទ្រទ្រង់ពួកគេដោយព្រះគុណរបស់ទ្រង់ (ទំនុកតម្កើង ១០៣:៣-១៣)។ នៅក្នុងខគម្ពីរទំនុកតម្កើង ១០៣:១១-១៦ កវីបានប្រើរូបស័ព្ទដ៏មានឥទ្ធិពលមួយ ដើម្បីបង្ហាញយើងថា មានតែលំហមេឃដែលមានផ្កាយ និងមានភពជាច្រើនប៉ុណ្ណោះ ដែលអាចប្រៀបផ្ទឹមទៅនឹងព្រះគុណរបស់ព្រះបាន។

តើរាស្ត្ររបស់ព្រះបានអរព្រះគុណទ្រង់ចំពោះសេចក្តីមេត្តារបស់ទ្រង់ដោយរបៀបណា?

របៀបទី១ រាស្ត្ររបស់ព្រះគួរតែជូនពរដល់ព្រះអម្ចាស់ (ទំនុកតម្កើង ១០៣:១, ២)។ នៅពេលដែលយើងជូនពរអ្នកណាម្នាក់ នោះពររបស់យើងក៏ប្រៀបដូចជាអំណោយមួយយ៉ាងដូច្នោះដែរ។ អំណោយរបស់យើងក៏អាចជាអំណោយខាងឯវិញ្ញាណផងដែរ។ ម្យ៉ាងទៀត អំណោយរបស់យើងក៏អាចជារបស់ដែលអ្នកដទៃត្រូវការផងដែរ (លោកុប្បត្តិ ៤៩:២៥; ទំនុកតម្កើង ៥:១២)។ ដ្បិតព្រះគឺជាប្រភពនៃរបស់ទាំងអស់ដែលយើងមាន។ បើដូច្នេះមែន តើយើងអាចជូនពរព្រះយ៉ាងដូចម្តេចទៅ បើទ្រង់បានគ្រប់គ្រងរបស់ទាំងអស់ដែលយើងមានទៅហើយនោះ? ព្រះគម្ពីរបានបង្ហាញយើងថា យើងអាចសរសើរ ឬអរព្រះគុណដល់ព្រះបានទៅតាមរបៀបដែលសាសន៍អ៊ីស្រាអែលបានអរព្រះគុណស្តេចសាឡូម៉ូនចំពោះអ្វីៗគ្រប់យ៉ាងដែលទ្រង់បានធ្វើសម្រាប់ពួកគេ (ពង្សាវតារក្សត្រទី១ ៨:៦៦; សូមអានខគម្ពីរយ៉ូប ២៩:១៣)។ នៅពេលដែលព្រះប្រទានអំណោយទានល្អដល់កូនរបស់ទ្រង់ នោះទ្រង់ក៏បានប្រទានព្រះពរដល់ពួកគេផងដែរ។ នៅពេលនោះរាស្ត្ររបស់ព្រះនឹងជូនពរទៅព្រះវិញ ដោយការសរសើរចំពោះសេចក្តីស្រឡាញ់របស់ទ្រង់។

របៀបទី២ រាស្ត្ររបស់ព្រះគួរតែនឹកចាំសេចក្តីសន្យា និងព្រះពរដែលទ្រង់បានប្រទានឱ្យពួកគេកាលមុន (ទំនុកតម្កើង ១០៣:២, ១៨-២២)។ នៅពេលដែលយើងនឹកចាំអំពីព្រះពររបស់ព្រះ នោះយើងប្រាកដជាចង់ស្រឡាញ់ និងចង់ធ្វើតាមទ្រង់បន្ថែមទៀតជាមិនខាន។

អ្នកស្រីអេឡែន ជីវ៉ៃត៍បានសរសេរថា «យើងគួរតែចំណាយពេលមួយម៉ោងជារៀងរាល់ថ្ងៃ ដើម្បីពិចារណាអំពីជីវិតរបស់ព្រះយេស៊ូវ . . . . នៅពេលដែលយើងបានគិតអំពីការសុគតរបស់ទ្រង់ជំនួយយើង នោះយើងនឹងជឿទុកចិត្តទ្រង់កាន់តែខ្លាំងឡើង។ ហើយការស្រឡាញ់របស់យើងក៏នឹងបានលូតលាស់ផងដែរ។ បន្ទាប់មក យើងនឹងបានពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ»។ ដកស្រង់ពី *The Desire of Ages*, page 83, adapted។

**ការសិក្សាបន្ថែម៖** សូមអាន Ellen G. White, "The Sinner's Need of Christ," pages 17-22, in *Steps to Christ*។

«យើងបានធ្វើទាស់នឹងព្រះ។ ដូច្នេះហើយ យើងមិនស័ក្តិសមទទួលបានព្រះពររបស់ព្រះនោះទេ។ ប៉ុន្តែ ព្រះអង្គទ្រង់ផ្ទាល់បានបង្រៀនយើងឱ្យនិយាយថា៖ 'សូមកុំស្អប់យើងខ្ញុំឡើយ ដោយយល់ដល់ព្រះនាមទ្រង់ សូមកុំបង្អាប់បល្ល័ង្កនៃសិរីល្អរបស់ទ្រង់ សូមនឹកចាំឡើងវិញ ហើយកុំផ្តាច់សេចក្តីសញ្ញា ដែលទ្រង់បានតាំងនឹងយើងខ្ញុំឡើយ' (យេរេមា ១៤:២១)។ នៅពេលដែលយើងចូលទៅរកព្រះ នោះយើងត្រូវតែលន់តួអំពើបាបរបស់យើង ដោយដឹងថា យើងមិនស័ក្តិសមទទួលបានព្រះពររបស់ទ្រង់នោះឡើយ។ នៅពេលដែលយើងធ្វើដូច្នេះ នោះទ្រង់នឹងឮសេចក្តីអំពាវនាវរបស់យើងជាមិនខាន។ ពីព្រោះទ្រង់បានសន្យាថា ទ្រង់នឹងសន្យាឆ្លើយតបទៅនឹងសេចក្តីអធិស្ឋានរបស់យើង។ ហើយនៅពេលដែលទ្រង់បំពេញសេចក្តីសន្យារបស់ទ្រង់ដល់យើង នោះក៏មានន័យថា ទ្រង់បាននាំកិត្តិនាមដល់ព្រះនាមរបស់ទ្រង់ និងបល្ល័ង្ករបស់ទ្រង់ផងដែរ»។ ដកស្រង់ពី Ellen G. White, *Christ's Object Lessons*, page 148, adapted។

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក ១០៣ កវីបានដឹងថា ព្រះបានបង្ហាញសេចក្តីមេត្តាដល់គាត់ (ទំនុកតម្កើង១០៣:២) ដោយព្រះគុណរបស់ទ្រង់បានជំរុញឱ្យគាត់មានប្រសាសន៍ថា «ព្រះយេហូវ៉ាទ្រង់សម្រេចកិច្ចការដ៏សុចរិត ហើយនឹងសេចក្តីយុត្តិធម៌ ចំពោះអស់អ្នកណាដែលត្រូវគេសង្កត់សង្កិន» (ទំនុកតម្កើង ១០៣:៦)។ កវីបានមានប្រសាសន៍យ៉ាងដូច្នេះ ដោយសារតែគាត់ចង់ឱ្យមនុស្សគ្រប់គ្នាបានដឹងថា ព្រះ-អម្ចាស់គឺជាព្រះនៃសេចក្តីមេត្តា និងជាព្រះនៃសេចក្តីស្រឡាញ់។ នៅពេលដែលអ្នកដទៃបានយល់អំពីសេចក្តីពិតនៃព្រះគម្ពីរនៅត្រង់នេះ នោះពួកគេនឹងថ្វាយចិត្តរបស់ពួកគេដល់ទ្រង់ ដោយទទួលយកព្រះគុណរបស់ទ្រង់ ដោយការសរសើរតម្កើងទ្រង់ (ទំនុកតម្កើង ៩:១១, ១២; ទំនុកតម្កើង ២២:២២-២៧; ទំនុកតម្កើង ៦៦:១៦)។

សំណួរពិភាក្សា

១. ព្រះគុណរបស់ព្រះគឺនៅអស់កល្បជានិច្ច។ តើសេចក្តីពិតនេះបានជួយឱ្យលោកអ្នកយល់កាន់តែច្បាស់អំពីសេចក្តីស្រឡាញ់របស់ព្រះ និងព្រះគុណរបស់ទ្រង់នោះដោយរបៀបណាដែរ? តើការបង្រៀននេះមានន័យថា យើងអាចបន្តធ្វើបាបតទៅទៀត ដោយសារតែព្រះគុណរបស់ទ្រង់នៅអស់កល្បជានិច្ចដែរឬទេ? សូមពន្យល់។

២. ព្រះដែលបានលើកលែងទោសអំពើបាបរបស់យើងក៏ជាព្រះត្រូវជំនុំជម្រះអំពើបាបរបស់យើងផងដែរ។ តើយើងអាចបកស្រាយគោលគំនិតខុសគ្នាទាំង២យ៉ាងនេះដោយរបៀបណា?

៣. សូមអាននូវអ្វីដែលគម្ពីរសញ្ញាថ្មីបានចែងអំពីព្រះគុណរបស់ព្រះនៅក្នុងខគម្ពីរអេភេសូរ ២:៤, ៥; ធីម៉ូថេទី១ ១:១៦; ទីតុស ៣:៥; ហេព្រើរ ៤:១៦។ តើខដែលបានស្តីអំពីព្រះគុណរបស់ព្រះទាំងនេះបានស្របទៅនឹងអ្វីដែលយើងបានអាននៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង អំពីព្រះគុណរបស់ទ្រង់នោះដោយរបៀបណា?

# បន្ទុកដែលត្រូវបានសម្រាលចេញពីចិត្ត

លោកសេគូលកំពុងតែរង់ចាំនៅខាងក្រៅអគារស្នាក់នៅសិស្សប្រុសនៅឯវិទ្យាល័យរបស់គាត់ ដែលស្ថិតនៅក្នុងទីក្រុងសារ៉ាយេវ៉ូ ដែលជារាជធានីនៃប្រទេសប៊ូស្នៀ-ហេហ្ស៊េហ្គូវីណា នៅល្ងាចថ្ងៃសុក្រមួយ។ គាត់កំពុងតែរង់ចាំវាយក្មេងប្រុសម្នាក់ដែលបានមើលងាយគាត់។ ខណៈដែលគាត់បានរង់ចាំផ្លូវនោះមិត្តភក្តិរបស់គាត់ម្នាក់បានហុចស្រាខូញ៉ាក់ (cognac) ឱ្យគាត់។ គាត់បានភ្លក្សស្រានោះ បន្ទាប់មកគាត់បានផឹកស្រានោះទៀតរហូតដល់ស្រវឹងជោក។ លុះដល់ព្រឹកឡើង គាត់បានដឹងថា មិត្តភក្តិរបស់គាត់នឹងបង្អាប់គាត់ដោយមិនប្រណី ដោយសារតែគាត់មិនបានសងសឹកក្មេងប្រុសម្នាក់នោះ។ គាត់បានសម្រេចចិត្តថា គាត់នឹងលាក់ខ្លួនមួយថ្ងៃសិន។ ប៉ុន្តែ តើគាត់ត្រូវលាក់ខ្លួននៅទីណាទៅ? នៅពេលនោះគាត់បាននឹកចាំអំពីអ្នកគ្រូអាត់វេនទីស្ទរបស់គាត់ ដែលបានអញ្ជើញគាត់ទៅព្រះវិហារកាលពីថ្ងៃមុន។ ហើយនៅពេលនោះក៏ព្រឹកនៃថ្ងៃសប្បាតហ៍ផងដែរ។

សក់របស់លោកសេគូលបានដុះវែងក្រញេក្រញាញ់។ គាត់មិនបានកក់សក់អស់រយៈពេលមួយខែ។ ហើយគាត់ក៏បានដកដង្ហើមទាំងញ័រផងដែរ។ នៅពេលដែលគាត់បានមកដល់ នោះគាត់បានរកមើលកន្លែងអង្គុយយ៉ាងប្រុងប្រយ័ត្ន។ ដ្បិតគាត់ធ្លាប់ឮគេថា អ្នកអាត់វេនទីស្ទបានប្រារព្ធ «ថ្ងៃសប្បាតហ៍ដ៏រីករាយ» របស់ពួកគេ ដោយការញ៉ែងញ៉ង់គ្នា ដូច្នេះហើយ គាត់មិនចង់អង្គុយនៅក្បែរយាយចាស់នោះឡើយ។ នៅពេលដែលរកឃើញកន្លែងអង្គុយដែលមានស្ត្រីវ័យក្មេងស្រស់ស្អាតម្នាក់ នោះគាត់ចូលទៅអង្គុយជិតនាង។

នៅពេលដែលប៉ាស្ទ័របានចាប់ផ្តើមអធិប្បាយ នោះលោកសេគូលបានចំហមាត់ទាំងភ្ញាក់ផ្អើលដោយសារតែប៉ាស្ទ័របានបង្ហាញចម្លើយនៅក្នុងព្រះគម្ពីរដែលបានឆ្លើយតបទៅនឹងសំណួរដែលគាត់បានចោទសួរអំពីព្រះ ហើយឋាននរកនោះ។ បន្ទុកដ៏ធ្ងន់មួយត្រូវបានសម្រាលចេញពីចិត្តរបស់គាត់ ខណៈដែលគាត់បានឮប្រាកដថា ព្រះគឺជាសេចក្តីស្រឡាញ់នោះ (យ៉ូហានទី១ ៤:៨) ដោយទ្រង់មានព្រះទ័យចង់សង្គ្រោះមនុស្សមានបាបទាំងអស់ (លូកា ១៩:១០) ដើម្បីកុំឱ្យអ្នកណាបានធ្លាក់ទៅក្នុងគុកភ្លើងអស់កល្បជានិច្ចនោះឡើយ (ម៉ាឡាគី ៤:១, ៣; ទំនុកដំកើង ៣៧:១០, ១១)។

បន្ទាប់ពីការអធិប្បាយ មានមនុស្សម្នាក់បានមកអញ្ជើញលោកសេគូលឱ្យចូលរួមនៅក្នុងកម្មវិធីផ្សាយដំណឹងល្អ ហើយគាត់ក៏បានទៅចូលរួមនៅក្នុងកម្មវិធីផ្សាយដំណឹងល្អនោះផងដែរ។ លោកសេគូលបានសួរប៉ាស្ទ័រនៅថ្ងៃចុងក្រោយនៃការផ្សាយដំណឹងល្អនោះយ៉ាងដូច្នេះថា «លោកគ្រូ សូមលោកគ្រូជួយណែនាំខ្ញុំផងថា តើខ្ញុំអាចធ្វើអ្វីបានខ្លះ ហើយខ្ញុំមិនអាចធ្វើអ្វីបានខ្លះ?»។ ប៉ាស្ទ័របានឆ្លើយមកវិញថា «ប្អូនអាចធ្វើអ្វីក៏បានដែរ»។ លោកសេគូលបានតបទៅវិញថា «លោកគ្រូកុំនិយាយអ៊ីចឹងអី លោកគ្រូប្រាប់ខ្ញុំឱ្យត្រង់មកថា តើខ្ញុំអាចធ្វើរឿងអ្វីខ្លះ មិនអាចធ្វើរឿងអ្វីខ្លះ?»។ ប៉ាស្ទ័របានឆ្លើយថា «ប្អូនមិនអាចធ្វើការនៅថ្ងៃសប្បាតហ៍តទៅទៀតបានឡើយ»។ គាត់បានឆ្លើយថា «បាទ លោកគ្រូ»។ «ប្អូនក៏មិនអាចទៅរៀននៅថ្ងៃសប្បាតហ៍តទៅទៀតដែរ»។ «បាទ លោកគ្រូ»។ «ប្អូនមិនអាចវាយគ្នា» «បាទ លោកគ្រូ»។ «ហើយកូនក៏មិនអាចញ៉ាំសាច់មិនស្អាតតទៅបានដែរ»។ «បាទ លោកគ្រូខ្ញុំនឹងឈប់ញ៉ាំសាច់មិនស្អាត»។ «និយាយត្រង់ ព្រះវិហាររបស់យើងចង់សំណូមពរឱ្យប្អូនឈប់ញ៉ាំសាច់ បានទេ?»។ «បាទ បាន លោកគ្រូ ខ្ញុំនឹងឈប់ញ៉ាំសាច់ទៅតាមសំណូមពររបស់ព្រះវិហារ»។

ចាប់ពីថ្ងៃនោះមក លោកសេគូលមិនដែលធ្វើការ ឬទៅសាលារៀននៅថ្ងៃសប្បាតហ៍នោះទេ។ គាត់មិនដែលវាយតប់ ក៏មិនដែលញ៉ាំសាច់ដែរ។ ៦ខែក្រោយមក គាត់បានទទួលបុណ្យជ្រមុជទឹក នៅពេលដែលគាត់មានអាយុ១៨ឆ្នាំ។ ប៉ុន្តែ គាត់បានទទួលយកការបង្រៀននៃព្រះវិហារអាត់វេនទីស្ទភ្លាមៗ ដោយសារតែព្រះគម្ពីរបានឆ្លើយតបទៅនឹងសំណួរដែលគាត់បានចោទសួរ អំពីព្រះ ហើយនិងឋាននរកនេះឯង។

# របៀបនៃការទទួលបានសេចក្ដីបរិសុទ្ធ



**ល្ងាចថ្ងៃបរិសុទ្ធ - ថ្ងៃសៅរ៍ ទី១៧ ខែកុម្ភៈ ឆ្នាំ២០២៤**

**អំណានព្រះគម្ពីរសម្រាប់មេរៀនប្រចាំសប្ដាហ៍នេះ៖ ទំនុកតម្កើង ១១៩:១-១៦; ទំនុកតម្កើង ៩០; ទំនុកតម្កើង ៨១:៧, ៨; ទំនុកតម្កើង ១៤១; ទំនុកតម្កើង ១:១-៣។**

**ខចងចាំ៖ «ដូច្នេះ សូមបង្រៀនឲ្យយើងខ្ញុំចេះកំណត់រាប់ថ្ងៃអាយុនៃយើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំមានចិត្តខ្មីឃ្មាត ឲ្យបានសតិបញ្ញា» (ទំនុកតម្កើង ៩០:១២)។**

យើងបានឃើញកាលពីសប្ដាហ៍មុនរួចមកហើយថា ព្រះអាចលើកលែងទោសឱ្យយើងបានដោយសារព្រះគុណរបស់ទ្រង់។ ព្រះអាចបង្កើតចិត្តដល់យើង ហើយទ្រង់ក៏បានធ្វើឱ្យយើងបរិសុទ្ធដោយសារព្រះគុណរបស់ទ្រង់ផងដែរ។

ព្រះគម្ពីរបានបង្រៀនយើងអំពីបែបផែននៃការរស់នៅក្នុងជីវិតមួយដ៏បរិសុទ្ធ (ទំនុកតម្កើង ១១៩:៩)។ ការបង្រៀននេះរួមមានទាំងការគោរពបញ្ញត្តរបស់ព្រះផងដែរ។ ដ្បិតនៅពេលណាដែលយើងរក្សាបញ្ញត្តរបស់ទ្រង់ នោះយើងនឹងបានរស់នៅក្នុងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងទ្រង់។ បន្ទាប់មក ព្រះនឹងប្រទានព្រះពររបស់ទ្រង់មកឱ្យយើង (ទំនុកតម្កើង ១១៩:១, ២; ទំនុកតម្កើង ១២៨)។ ដូច្នេះហើយ សេចក្ដីសន្យានេះក៏ជាដំណឹងល្អផងដែរ។

តើសេចក្ដីសន្យាដែលថា ព្រះនឹងប្រទានពរដល់យើងនេះ មានន័យថា ជីវិតគ្រីស្ទានរបស់យើងនឹងដំណើរការរលូនចាប់ពីពេលនេះទៅដែរឬទេ? ទេ មិនមែនដូច្នេះឡើយ។ ពីព្រោះអំពើបាបក៏មានអំណាចខ្លាំងណាស់ដែរ (ទំនុកតម្កើង ១៤១:២-៤)។ ប្រសិនបើយើងមិនបានប្រុងប្រយ័ត្នទេ នោះអំពើបាបអាចនឹងបំបែកយើងចេញពីព្រះបាន។ ដ្បិតព្រះនឹងប្រទានការសាកល្បងដល់យើង ដោយទ្រង់បានបណ្ដោយឱ្យសាតាំងល្បួងយើងឱ្យប្រព្រឹត្តអំពើបាប។ តើហេតុអ្វីបានជាទ្រង់ធ្វើដូច្នេះ? នោះគឺដោយសារតែទ្រង់ចង់បង្ហាញយើងនូវអ្វីដែលមាននៅក្នុងចិត្តរបស់យើង។ បើសិនជាកូនៗរបស់ព្រះបានថ្វាយបង្គំទ្រង់ នោះទ្រង់នឹងធ្វើឱ្យសេចក្ដីជំនឿរបស់ពួកគេបានរឹងមាំឡើង។ ហើយការជឿទុកចិត្តរបស់ពួកគេទៅលើទ្រង់ក៏នឹងបានលូតលាស់ផងដែរ។ ការសាកល្បង ហើយនិងបញ្ហាបានចូលមកក្នុងជីវិតយើង ដោយសារតែព្រះបានបណ្ដោយឱ្យរឿងទាំងនេះកើតឡើង ដើម្បីឱ្យយើងបានរៀនអំពីរបៀបរស់នៅឱ្យបានបរិសុទ្ធ។ ពោលគឺយើងត្រូវតែអធិស្ឋានសូមឱ្យព្រះជួយឱ្យយើងបានដឹងថា ជីវិតរបស់យើងខ្លីប៉ុនណា។ នៅពេលនោះ ចំណេះដឹងរបស់យើងនឹងបានលូតលាស់ឡើង (ទំនុកតម្កើង ៩០:១២)។ នៅពេលដែលយើងអធិស្ឋានបែបនេះ នោះយើងបានបង្ហាញព្រះថា យើងមានបំណងចង់រស់នៅជាមួយនឹងសេចក្ដីជំនឿ ហើយនិងការជឿទុកចិត្តទៅលើទ្រង់ជារៀងរហូតតទៅ។

# ការសិក្សាយ៉ាងផ្ចិតផ្ចង់ទៅលើសេចក្ដីបង្រៀនរបស់ព្រះ

**តើយើងបានរក្សាបញ្ញត្តរបស់ព្រះដោយរបៀបណា? តើយើងនឹងបានទទួលព្រះពរអ្វីខ្លះចេញពីការកាន់តាមបញ្ញត្តរបស់ទ្រង់នេះ? សូមអានខគម្ពីរទំនុកតម្កើង១១៩:១-១៦ និងខ១៦១-១៦៨ សម្រាប់ចម្លើយ។**

___________________________________________________________________________

___________________________________________________________________________

តើជីវិតនៃសេចក្ដីជំនឿគឺជាអ្វី? ជីវិតនៃសេចក្ដីជំនឿគឺប្រៀបដូចជាការធ្វើដំណើរជាមួយនឹងព្រះអស់មួយជីវិតរបស់យើង។ នៅក្នុងការធ្វើដំណើរនេះ យើងនឹងរក្សាបញ្ញត្តរបស់ព្រះ (ទំនុកតម្កើង ១១៩:១)។ ដ្បិតសេចក្ដីស្រឡាញ់របស់ទ្រង់ក៏ប្រៀបដូចជាតួពន្លឺមួយ ដែលបានចែងចាំងមកលើយើង នៅក្នុងអំឡុងពេលដែលយើងបានធ្វើដំណើរជាមួយនឹងទ្រង់ (ទំនុកតម្កើង ៨៩:១៥)។ ហើយយើងក៏បានសន្យាថា យើងនឹងបម្រើ ហើយគោរពទ្រង់ដោយអស់ពីចិត្តរបស់យើងផងដែរ (ទំនុកតម្កើង ១១៩:១, ២, ១០)។

នៅពេលដែលយើងធ្វើតាមការបង្រៀនរបស់ព្រះ នោះយើងនឹងបានរស់នៅក្នុងជីវិតដែលបរិសុទ្ធ (ទំនុកតម្កើង ១១៩:១)។ ដ្បិតការរស់នៅរបស់យើងក៏ប្រៀបដូចជាតង្វាយដ៏ល្អឥតខ្ចោះដែលនាំមកថ្វាយព្រះផងដែរ (និក្ខមនំ ១២:៥)។ ហើយយើងរាល់គ្នាក៏ប្រៀបដូចជាតង្វាយ «រស់» យ៉ាងដូច្នោះដែរ (និក្ខមនំ ១២:៥)។ ពីព្រោះយើងនឹងស្អប់អំពើបាប ដោយសារតែអំពើបាបបានធ្វើឱ្យចិត្តរបស់យើងស្មោកគ្រោក។ ប៉ុន្តែ សេចក្ដីស្រឡាញ់របស់ព្រះបានសម្អាតយើងវិញ។ ដ្បិតនៅពេលដែលយើងថ្វាយជីវិតរបស់យើងទៅព្រះទាំងស្រុង នោះយើងនឹងធ្វើរឿងគ្រប់យ៉ាង ដើម្បីផ្គាប់ព្រះហឫទ័យព្រះ (ទំនុកតម្កើង ១០១:២, ៦; សូមអានខគម្ពីរទំនុកតម្កើង ១៨:៣២ ផងដែរ)។

ក្រឹត្យវិន័យរបស់ព្រះគឺមានអត្ថន័យលើសពីសំណុំនៃបញ្ញត្តទៅទៀត។ នៅពេលដែលយើងកាន់តាមបញ្ញត្តរបស់ព្រះ នោះយើងនឹងអាចវែកញែកខុស និងត្រូវ ល្អ និងអាក្រក់បាន (ទំនុកតម្កើង ១១១:១០; សូមអានខគម្ពីរកូរិនថូសទី១ ២២:១២ ផងដែរ)។ ការដែលយើងបានកាន់តាមបញ្ញត្តរបស់ព្រះនេះបានផ្លាស់ប្ដូរយើងលើសពីទង្វើរបស់យើងទៅទៀត។ ពីព្រោះបញ្ញត្តរបស់ទ្រង់ក៏បានផ្លាស់ប្ដូរចិត្ត និងគំនិតរបស់យើងផងដែរ។

ក្រឹត្យវិន័យរបស់ព្រះបានបង្ហាញផែនការរបស់ទ្រង់សម្រាប់មនុស្សគ្រប់គ្នានៅលើផែនដីនេះ។ ដ្បិតបញ្ញត្តរបស់ទ្រង់បានបង្ហាញប្រាប់យើងអំពីរបៀបរស់នៅប្រកបដោយប្រាជ្ញា និងរបៀបរស់នៅប្រកបដោយសេរីភាព និងសន្តិភាព (ទំនុកតម្កើង ១១៩:៧-១១, ១៣៣)។ នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក ១១៩ កវីបានស្រឡាញ់បញ្ញត្តរបស់ព្រះ ដោយសារតែបញ្ញត្តនោះបានបង្រៀនគាត់ថា ព្រះនឹងរក្សាសេចក្ដីសន្យារបស់ទ្រង់ (ទំនុកតម្កើង ១១៩:៧៧, ១៧៤)។

«ពួកអ្នកដែលស្រឡាញ់ក្រឹត្យវិន័យទ្រង់ នោះមានសេចក្តីសុខដ៏លើសលុប ហើយគ្មានហេតុនឹងចំពប់ដួលឡើយ» (ទំនុកតម្កើង ១១៩:១៦៥)។ នៅក្នុងព្រះគម្ពីរ ពាក្យថា «ចំពប់ដួល» គឺជារូបស័ព្ទមួយតំណាងឱ្យការធ្វើឱ្យព្រះខកព្រះទ័យ ឬតំណាងឱ្យការប្រព្រឹត្តអំពើបាប។ ពីព្រោះព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះក៏ប្រៀបដូចជាចង្កៀងមួយ (ទំនុកតម្កើង ១១៩:១០៥) ដែលបានបញ្ចេញពន្លឺ ដោយបានបង្ហាញយើងអំពីផ្លូវទៅកាន់នគរស្ថានសួគ៌។ ព្រះគម្ពីរបានការពារយើងកុំឱ្យចំពប់ដួលទៅក្នុងអំពើបាប (ទំនុកតម្កើង ១១៩:១០) នៅពេលដែលយើងធ្វើដំណើរនៅតាមផ្លូវទៅកាន់នគរស្ថានសួគ៌នោះ។

**តើព្រះយេស៊ូវបានបង្ហាញតាមរយៈជីវិតរបស់ទ្រង់ថា ព្រះបន្ទូលរបស់ព្រះមានអំណាចខ្លាំងពូកែដោយរបៀបណា (ម៉ាថាយ ៤:១-១១)? តើចម្លើយរបស់លោកអ្នកបានប្រាប់លោកអ្នក អំពីមូលហេតុដែលយើងគួរតែកាន់តាមបញ្ញត្តរបស់ព្រះនោះយ៉ាងដូចម្ដេចដែរ?**

# កណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងអំពីជីវិតខ្លីរបស់យើង

**បើប្រៀបធៀបទៅនឹងព្រះ តើយើងអាចរស់នៅបានយូរប៉ុនណាដែរ? សូមអានបទគម្ពីរទំនុកតម្កើង ជំពូក៩០; ទំនុកតម្កើង ១០២:១១ និងទំនុកតម្កើង ១០៣:១៤-១៦ សម្រាប់ចម្លើយ។**

---

ជីវិតរបស់មនុស្សលោកគឺខ្លីមែនទែន បើយើងប្រៀបធៀបទៅនឹងព្រះដែលមានព្រះជន្មរស់អស់កល្បជានិច្ចនោះ។ ដ្បិតនៅក្នុងព្រះនេត្ររបស់ព្រះ ១០០០ឆ្នាំស្មើនឹង៣ ឬ៤ម៉ោងនៅក្នុងមួយរាត្រីប៉ុណ្ណោះ។ (ទំនុកតម្កើង ៩០:៤)។ បើប្រៀបធៀបទៅនឹងព្រះ ជីវិតរបស់យើងមិនអាចបន្តជារៀងរហូតបានឡើយ (ទំនុកតម្កើង ៩០:១០)។ មនុស្សលោកដែលខ្លាំងបំផុតគឺប្រៀបដូចជាភពមួយដែលខ្សោយបំផុតវិញ (ទំនុកតម្កើង ៩០:៥, ៦; ទំនុកតម្កើង ១០៣:១៥, ១៦)។ ដ្បិតជីវិតខ្លីរបស់យើងមានពេញទៅដោយកិច្ចការលំបាកៗ និងភាពសោកសៅជាច្រើនយ៉ាង (ទំនុកតម្កើង ៩០:១០)។ មានមនុស្សខ្លះបានសោកស្តាយ នៅពេលដែលពួកគេបានចាំថា ជីវិតរបស់ពួកគេគឺមានរយៈពេលខ្លីមែនទែន។ ពួកគេបានសោកស្តាយ នៅពេលដែលជីវិតត្រូវបន្តទៅមុខទៀតដោយគ្មានរូបពួកគេ នៅពេលដែលពួកគេស្លាប់ទៅនោះ។

បទគម្ពីរទំនុកតម្កើង ជំពូក៩០ បានបង្ហាញយើងថា ព្រះបានយកព្រះទ័យទុកដាក់ចំពោះយើងនៅក្នុងអំឡុងពេលនៃជីវិតដ៏សែនខ្លីរបស់យើងនេះ។ ពីព្រោះទ្រង់ក៏ប្រៀបដូចជាជម្រកមួយសម្រាប់រាស្ត្ររបស់ទ្រង់ផងដែរ (ទំនុកតម្កើង ៩០:១, ២)។ នៅក្នុងនាមជាទីជ្រកកោណរបស់យើង ព្រះអម្ចាស់គឺជាជម្រកមួយដ៏មានសុវត្ថិភាពសម្រាប់រាស្ត្ររបស់ទ្រង់ នៅក្នុងអំឡុងពេលនៃគ្រាលំបាក។

បទគម្ពីរទំនុកតម្កើង ជំពូក៩០ ក៏បានបង្រៀនយើងថា ព្រះបានខ្ញាល់នឹងអំពើបាបជាខ្លាំង។ ដោយកវីបាននិយាយថា៖ «តើមានអ្នកណាដែលស្គាល់អំណាចនៃសេចក្តីខ្ញាល់ និងសេចក្តីក្រោធរបស់ទ្រង់ តាមដែលគួរកោតខ្លាចដល់ទ្រង់នោះ» (ទំនុកតម្កើង ៩០:១១)។ គ្មានអ្នកណាម្នាក់គិតឃើញទំហំនៃសេចក្តីខ្ញាល់ដែលព្រះបានទាស់ទៅនឹងអំពើបាបនោះឡើយ។ មូលហេតុគឺដោយសារតែទ្រង់បានទប់សេចក្តីក្រោធរបស់ទ្រង់ ដោយបង្ហាញព្រះគុណរបស់ទ្រង់ដល់យើងវិញ។ មូលហេតុនេះហើយដែលបានធ្វើឱ្យយើងមានសេចក្តីសង្ឃឹមនោះ ដ្បិតព្រះបានប្រទានឱកាសជាច្រើនដល់យើង ដើម្បីឱ្យយើងបានលន់តួអំពើបាបរបស់យើង។ ហើយយើងក៏អាចចូលទៅសូមប្រាជ្ញាពីទ្រង់ ដើម្បីឱ្យយើងបានបរិសុទ្ធផងដែរ។

ប្រាជ្ញានៅក្នុងព្រះគម្ពីរមានអត្ថន័យលើសពីការដែលយើងមានចំណេះដឹង ឬមានភាពឈ្លៀសវៃទៅទៀត។ ដ្បិតប្រាជ្ញាពិតប្រាកដនោះគឺជាការគោរពកោតខ្លាចដល់ព្រះ។ តើយើងត្រូវប្រាជ្ញាខាងឯផ្នែកអ្វីដែរ? ចម្លើយគឺថា យើងត្រូវការប្រាជ្ញាដើម្បីឱ្យបានដឹងថា ជីវិតរបស់យើងមានអាយុកាលខ្លីជាទីបំផុត។ ចំនួនឆ្នាំដែលយើងត្រូវរស់បន្តគឺមានកម្រិត។ ហើយនៅពេលដែលយើងបានយល់សេចក្តីពិតនេះ នោះយើងនឹងបានក្លាយទៅជាមនុស្សមានប្រាជ្ញា។ ដ្បិតចំណេះដឹងនេះបានបង្រៀនយើងអំពីសេចក្តីជំនឿ និងការគោរពតាម។ យើងអាចទទួលបានចំណេះនេះតែនៅពេលដែលយើងបានលន់តួអំពើបាបរបស់យើង ហើយឈប់ធ្វើវាទៀតតែប៉ុណ្ណោះ (ទំនុកតម្កើង ៩០:៨, ១២)។ បន្ទាប់មក យើងត្រូវតែទទួលយកអំណោយការលើកលែងទោស សេចក្តីស្រឡាញ់ និងព្រះគុណរបស់ព្រះ (ទំនុកតម្កើង ៩០:១៣, ១៤)។

បញ្ហារបស់យើងគឺថា យើងគឺជាមនុស្សមានបាប។ ហើយអំពើបាបនេះបានធ្វើឱ្យផែនដីឈឺចាប់ដោយបានបំផ្លាញមនុស្សលោកជាច្រើននាក់។ នៅពេលដែលយើងក្រឡេកមើលមនុស្សទាំងអស់នៅជុំវិញយើង នោះយើងនឹងបានឃើញសេចក្តីអាក្រក់ដែលអំពើបាបបានបង្កឡើងនៅគ្រប់ទីកន្លែងជាមិនខាន។

សូមអរព្រះគុណព្រះយេស៊ូវ ដែលព្រះបានរៀបចំវិធីមួយតាមរយៈទ្រង់ ដើម្បីសង្គ្រោះយើងចេញពីបញ្ហានៃអំពើបាប (យ៉ូហាន ១:២៩; យ៉ូហាន ៣:១៤-២១)។ បើសិនជាគ្មានព្រះយេស៊ូវទេ នោះយើងនឹងគ្មានសង្ឃឹមអ្វីឡើយ។

**ជាការពិតណាស់ ជីវិតរបស់យើងមានអាយុកាលខ្លីមែនទែន។ ប៉ុន្តែ តើយើងបានទទួលសេចក្តីសង្ឃឹមអ្វីតាមរយៈព្រះយេស៊ូវនោះ (យ៉ូហាន ៣:១៦)? បើសិនជាគ្មានទ្រង់ទេ តើយើងមានសេចក្តីអ្វីទៅ?**

# ការសាកល្បងរបស់ព្រះអម្ចាស់

**សូមអានខគម្ពីរទំនុកតម្កើង ៨១:៧, ៨; ទំនុកតម្កើង ៩៥:៧-១១ និងទំនុកតម្កើង ១០៥:១៧-២២។ តើខទាំងនេះបានបង្រៀនយើងអំពីការសាកល្បងដែលព្រះបានប្រទានឱ្យយើងនោះយ៉ាងដូចម្តេចដែរ?**

_______________________________________________________________

ទីកន្លែងមេរីបាគឺជាកន្លែងមួយដែលសាសន៍អ៊ីស្រាអែលបានសាកល្បងព្រះ។ ពួកគេមិនបានជឿថា ព្រះនឹងរក្សាសេចក្តីសន្យារបស់ទ្រង់ ដោយបំពេញតម្រូវការរបស់ពួកគេនោះឡើយ (និក្ខមនំ ១៧:១-៧; ទំនុកតម្កើង ៩៥:៨, ៩)។ បទគម្ពីរទំនុកតម្កើង ជំពូក៨១ បានសម្លឹងឃើញរឿងនៅត្រង់មេរីបានេះនៅក្នុងរបៀបថ្មីមួយបែប។ ពេលគឺកវីដែលបានសរសេរបទគម្ពីរទំនុកតម្កើង ជំពូក៨១ បានមានប្រសាសន៍ថា ព្រះបានប្រទានការសាកល្បងមួយនៅត្រង់កន្លែងមេរីបា (ទំនុកតម្កើង ៨១:៧)។ នៅពេលដែលសាសន៍អ៊ីស្រាអែលបានគោរពតាមព្រះ ហើយបានបដិសេធមិនព្រមជឿទុកចិត្តទៅលើទ្រង់ (ទំនុកតម្កើង ៨១:១១) នោះមានន័យថា ពួកគេបានធ្វើឱ្យព្រះខកព្រះទ័យហើយ។

បទគម្ពីរទំនុកតម្កើង ជំពូក៨១ បានបង្រៀននូវមេរៀន២យ៉ាងទាក់ទងទៅទៅនឹងទីកន្លែងមេរីបានេះ។ មេរៀនទី១ រាស្ត្ររបស់ព្រះមិនត្រូវធ្វើខុសដូចដែលឪពុកម្តាយរបស់ពួកគេបានធ្វើខុសពីមុននោះឡើយ។ ផ្ទុយទៅវិញ រាស្ត្ររបស់ព្រះត្រូវតែជឿទុកចិត្តទៅលើព្រះ ដោយគោរពតាមទ្រង់វិញ (ទំនុកតម្កើង ៨១:១៣)។ មេរៀនទី២ ព្រះបានសង្គ្រោះរាស្ត្ររបស់ទ្រង់ បន្ទាប់ពីពួកគេបានបរាជ័យនូវការសាកល្បងដែលព្រះបានប្រទានឱ្យពួកគេនោះ (ទំនុកតម្កើង ៨១:៧)។ ដ្បិតព្រះគុណរបស់ព្រះកាលពីមុនបានផ្តល់សេចក្តីសង្ឃឹមដែលថា ទ្រង់នឹងបង្ហាញសេចក្តីមេត្តាដល់យើងនៅពេលអនាគត។

បទគម្ពីរទំនុកតម្កើង ជំពូក១០៥ បានបង្ហាញយើងថា ព្រះបានយកគ្រាលំបាកមកធ្វើជាការសាកល្បងមួយ។ តួយ៉ាង ព្រះបានប្រទានការសាកល្បងមួយដល់លោកយ៉ូសែបអំពីសេចក្តីសន្យារបស់ទ្រង់ ដើម្បីឱ្យលោកយ៉ូសែបបានដកមន្ទិលសង្ស័យចេញពីចិត្តរបស់គាត់។ ការសាកល្បងនេះក៏បានជួយឱ្យជំនឿដែលលោកយ៉ូសែបមានចំពោះព្រះនោះបានរឹងមាំផងដែរ។ ដូច្នេះហើយ លោកយ៉ូសែបបានរៀនជឿទុកចិត្តថា ព្រះនឹងដឹកនាំគាត់ (លោកុប្បត្តិ ៣៧:៥-១០; ទំនុកតម្កើង ១០៥:១៩)។

យើងបានយល់ពីគោលបំណងដែលព្រះត្រូវប្រទាននូវការសាកល្បងមកឱ្យយើង។ ប៉ុន្តែ ហេតុអ្វីបានជាព្រះដាក់ទោសយើងយ៉ាងដូច្នេះ? ពីព្រោះនៅពេលដែលព្រះដាក់ទោសរាស្ត្ររបស់ទ្រង់ នោះមានន័យថា ទ្រង់ចង់ឱ្យពួកគេរៀនពីកំហុសរបស់ពួកគេ។ ដ្បិតទ្រង់ចង់ឱ្យពួកគេបានរឹងមាំឡើង ដោយត្រៀមខ្លួនទទួលព្រះពររបស់ទ្រង់ជាស្រេច។ នេះហើយគឺជាមូលហេតុដែលនាំឱ្យព្រះបណ្តោយឱ្យលោកយ៉ូសែបជួបនឹងបទពិសោធន៍លំបាកៗជាច្រើន (ទំនុកតម្កើង ១០៥:២០-២២)។ ប៉ុន្តែ យើងត្រូវតែរៀនចេញពីការសាកល្បងរបស់យើង។ បើសិនជាយើងបានបដិសេធមេរៀនរបស់ព្រះ នោះចិត្តរបស់យើងច្បាស់ជារឹងទទឹងជាមិនខាន។

«ព្រះបានរំពឹងចង់ឱ្យកូនៗរបស់ទ្រង់គោរពបញ្ញត្តរបស់ទ្រង់ភ្លាមៗ ដោយគ្មានសំណួរចោទអ្វីឡើយ។ ប៉ុន្តែ កូនៗរបស់ទ្រង់បានដេកលក់អស់ ដោយសារតែការកុហករបស់ទ្រង់បានរារាំងមិនឱ្យពួកគេធ្វើនូវអ្វីដែលត្រឹមត្រូវ។ សាតាំងបានផ្តល់ការដោះសាដល់ពួកគេ ដើម្បីកុំឱ្យពួកគេបានកាន់តាមបញ្ញត្តរបស់ព្រះ។ វាបានកុហក និងបានល្បួងឱ្យកូនៗរបស់ព្រះធ្វើនូវរឿងដែលពួកគេបានដឹងថា ខុសឆ្គងនោះ។ សាតាំងបានប្រើការកុហកដដែលដែលវាបានប្រើជាមួយនឹងនាងអេវ៉ានៅក្នុងសួនអេដែននោះដែរ ដោយវាបាននិយាយថា 'អ្នកមិនស្លាប់ជាពិតមែនទេ' (លោកុប្បត្តិ ៣:៤)។ នៅពេលដែលយើងមិនបានគោរពតាមព្រះ នោះយើងនឹងធ្វើឱ្យចិត្តរបស់យើងកាន់តែរឹងរូសទៅៗ។ ហើយយើងក៏នឹងធ្វើឱ្យអ្នកដទៃធ្លាក់ទៅក្នុងអំពើបាបផងដែរ។ ជាដំបូង អ្នកដទៃអាចនឹងមើលឃើញថា អំពើបាបរបស់យើងអាក្រក់ជាងពួកគេ។ ប៉ុន្តែក្រោយមក អំពើបាបរបស់យើងលែងអាក្រក់នៅក្នុងក្រសែភ្នែករបស់ពួកគេទៀតហើយ ដោយសារតែពួកគេបានសមជាមួយនឹងអំពើបាបទាំងនោះ។ ដ្បិតពួកគេអាចនឹងសួរថា តើអំពើបាបគឺជាបាបពិតប្រាកដដែរឬទេ»។ ដកស្រង់ពី Ellen G. White, *Testimonies for the Church*, volume 4, page 146, adatped។

## របៀបដែលអំពើបាបបានធ្វើការនៅក្នុងចិត្តរបស់យើង

**តើកវីនៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក១៤១ បានអធិស្ឋានអំពីអ្វីដែរ?**

---

បទគម្ពីរទំនុកតម្កើង ជំពូក១៤១ គឺជាសេចក្តីអធិស្ឋានទូលសូមនូវការការពារ។ កវីនៅក្នុងជំពូកនេះបានស្ថិតនៅក្នុងគ្រោះថ្នាក់ ដោយសារតែមនុស្សអាក្រក់ ហើយនិងផែនការដែលពួកគេបានរៀបចំទាស់នឹងគាត់នោះដែរ (ទំនុកតម្កើង ១៤១:៩, ១០)។ កវីក៏បានស្ថិតនៅក្នុងគ្រោះថ្នាក់ ដោយសារតែអំពើបាបនៅក្នុងចិត្តរបស់គាត់ផងដែរ។ ដ្បិតគាត់បានមានប្រសាសន៍ថា ចិត្តរបស់គាត់គឺជាគ្រោះថ្នាក់ដល់ទីជ្រកកោណរបស់គាត់យ៉ាងពិតប្រាកដ។ នោះគឺដោយសារតែសង្គ្រាមរវាងសេចក្តីល្អ និងសេចក្តីអាក្រក់បានកើតឡើងនៅក្នុងចិត្តរបស់គាត់។ មានពេលខ្លះ កវីនៅក្នុងជំពូកនេះមានបំណងចង់ធ្វើបាន ដោយចូលរួមជាមួយនឹងមនុស្សដែលធ្វើរឿងអាក្រក់។

តើកវីបានធ្វើតាមព្រះប្រាជ្ញាញាណរបស់ព្រះដែរឬទេ? តើកវីបានចូលរួមជាមួយនឹងមនុស្សអាក្រក់នៅក្នុងជីវិតនៃអំពើបាបដែរឬទេ (ទំនុកតម្កើង ១៤១:៤, ៥)? រឿងតែមួយគត់ដែលអាចសង្គ្រោះកវីចេញពីការប្រព្រឹត្តអំពើបាបនោះ គឺជាការអធិស្ឋាន និងជាការជឿទុកចិត្តទាំងស្រុងទៅលើព្រះ (ទំនុក-តម្កើង ១៤១;១, ២)។ ដូច្នេះហើយ កវីបានអធិស្ឋានសូមជំនួយពីព្រះ។ កវីបានសូមឱ្យព្រះជួយឱ្យគាត់បានគ្រប់គ្រងពាក្យសម្តី និងកម្លាំងរបស់គាត់ ដើម្បីឱ្យបាននិយាយថា ទេ ទៅកាន់អំពើបាប (ទំនុកតម្កើង ១៤១:៣, ៤)។

**សូមអានខគម្ពីរទំនុកតម្កើង ១:១ និងទំនុកតម្កើង ១៤១:៤។ តើខទាំងនេះបានបង្រៀនយើងអំពីអំពើបាប និងអំពីសេចក្តីអាក្រក់នោះយ៉ាងដូចម្តេចដែរ?**

---

---

ខគម្ពីរទំនុកតម្កើង ១៤១:៤ បានបង្ហាញយើងអំពីដំណើរការនៃអំពើបាប។ ដំណាក់កាលទី១ អំពើបាបបានចាប់ផ្តើមនៅក្នុងចិត្តរបស់យើង។ វាបានធ្វើឱ្យមានបំណងចង់ធ្វើរឿងអាក្រក់។ ដំណាក់កាលទី២ អំពើបាបបានល្បួងឱ្យយើងបញ្ចេញជាសកម្មភាពនៃការធ្វើរឿងអាក្រក់។ បន្ទាប់ពីយើងបានធ្វើបាបជាលើកដំបូងរួចមក នោះយើងនឹងធ្វើអំពើបាបនោះម្តងហើយម្តងទៀត។ ដំណាក់កាលទី៣ យើងបានទទួលសេចក្តីអាក្រក់មកដាក់នៅក្នុងចិត្តរបស់យើងទុកជារបស់មួយដ៏ល្អប្រណីត។

ទន្ទឹមគ្នានេះ ខគម្ពីរទំនុកតម្កើង ១:១ បានប្រាប់យើងនូវអ្វីដែលត្រូវកើតឡើង នៅពេលដែលយើងប្រព្រឹត្តិអំពើបាបនោះ។ ពោលគឺអំពើបាបបានរារាំងមិនឱ្យកូនៗរបស់ព្រះធ្វើតាមព្រះ ដោយមិនឱ្យពួកគេគោរពតាមបញ្ញត្តរបស់ទ្រង់។ អំពើបាបបានធ្វើឱ្យយើងចូលរួមជាមួយនឹងមនុស្សអាក្រក់ ដែលបានរំលងបញ្ញត្តរបស់ព្រះ ព្រមទាំងមនុស្សអាក្រក់ដែលបានមើលងាយព្រះផងដែរ។ ព្រះបានបង្គាប់មិនឱ្យយើងធ្វើដូចជាមនុស្សទាំងនេះបានធ្វើនោះឡើយ។ ពោលគឺយើងមិនត្រូវអនុញ្ញាតឱ្យពួកគេដឹកនាំយើងចេញពីព្រះអម្ចាស់បានឡើយ។

កណ្ឌគម្ពីរទំនុកតម្កើងបានបង្ហាញយើងថា ការពឹងផ្អែកទៅលើព្រះអម្ចាស់គឺជាវិធីតែមួយគត់ដែលអាចជួយឱ្យយើងគេចរួចពីអំពើបាប។ ដោយទ្រង់នឹងសង្គ្រោះយើងចេញពីអំពើបាប។ កណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងឱ្យចេះគ្រប់គ្រងពាក្យសម្តីរបស់យើង។ ពោលគឺយើងត្រូវតែជ្រើសរើសពាក្យដែលយើងត្រូវនិយាយនោះដោយក្តីប្រុងប្រយ័ត្ន។ ហើយយើងក៏ត្រូវតែប្រុងប្រយ័ត្នចំពោះអ្នកដែលយើងបានធ្វើតាមនោះដែរ។ ដ្បិតមនុស្សអាក្រក់នឹងផ្តល់ជំនូន្មានអាក្រក់ដល់យើង ដែលដំបូន្មាននោះបានដឹកនាំយើងឱ្យឃ្លាតឆ្ងាយពីព្រះ។ ដូច្នេះហើយ យើងត្រូវតែចូលទៅសូមប្រាជ្ញាពីព្រះ ពីព្រោះទ្រង់នឹងត្រូវជំនុំជម្រះទាំងមនុស្សល្អទាំងមនុស្សអាក្រក់ (ទំនុកតម្កើង ១:៤-៦; ទំនុកតម្កើង ១៤១:៨-១០)។ ទម្រាំតែពេលនេះបានមកដល់ រាស្ត្ររបស់ព្រះត្រូវតែអត់ធ្មត់ ហើយជឿទុកចិត្តទៅលើទ្រង់ជានិច្ច។

## ជីវិតដ៏បរិសុទ្ធ ហើយនិងព្រះពរជាច្រើនដែលបានមកពីជីវិតដ៏បរិសុទ្ធនោះ

**តើព្រះបានសន្យាថា ទ្រង់នឹងប្រទានព្រះពរអ្វីខ្លះ ដល់មនុស្សដែលបានលើកតម្កើងទ្រង់នោះ? សម្រាប់ចម្លើយ សូមអានខគម្ពីរទំនុកតម្កើង ១:១-៣; ទំនុកតម្កើង ១១២:១-៩ និងបទទំនុកតម្កើង ជំពូក ១២៨។**

____________________________________________________________

____________________________________________________________

ព្រះបានសន្យាថា ទ្រង់នឹងប្រទានព្រះពរជាច្រើនដល់មនុស្សដែលបានលើកតម្កើងទ្រង់។ នៅក្នុងនោះ សេចក្តីសុខសាន្តគឺជាព្រះពរមួយដ៏អស្ចារ្យបំផុត ដែលព្រះបានប្រទានឱ្យយើង។ បទគម្ពីរទំនុកដំកើង ជំពូក១ បានប្រៀបធៀបមនុស្សបរិសុទ្ធម្នាក់ទៅនឹងដើមឈើមួយដើម។ ដើមឈើនេះបានដុះនៅក្បែរមាត់ទឹក។ ដើមឈើនេះមានផ្លែច្រើនសណ្ឋិក។ ហើយស្លឹកនៃដើមឈើនេះក៏មិនដែលស្រពោនស្លាប់នោះដែរ (ទំនុកតម្កើង ១:៣; សូមអានខគម្ពីរយេរេមា ១៧:៧, ៨ និងអេសេគាល ៤៧:១២)។ រូបស័ព្ទនៃដើមឈើនេះបានបង្ហាញយើងថា ព្រះគឺជាអ្នកប្រទានពរឱ្យដើមឈើនេះ។ នៅពេលដែលយើងរស់នៅក្នុងសេចក្តីជំនឿជាមួយនឹងព្រះដែលគង់នៅក្នុងរោងឧបោសថនៅឯស្ថានសួគ៌ នោះយើងនឹងបានរីករាយមិត្តភាពនៃសេចក្តីស្រឡាញ់ជាមួយនឹងទ្រង់ជាមិនខាន។ រីឯមនុស្សអាក្រក់វិញ ពួកគេមិនដូចជាដើមឈើគួរឱ្យចាប់ចិត្ត ដែលមានផ្លែឈើ និងស្លឹកខៀវខ្ចីនោះទេ ដោយសារតែពួកគេគឺប្រៀបដូចជាចំបើងដែលខ្យល់បានបក់នាំឆ្ងាយវិញយ៉ាងដូច្នេះដែរ។ ហើយពួកគេក៏គ្មានសេចក្តីសង្ឃឹមនៅពេលអនាគតអ្វីឡើយ ប៉ុន្តែ រាស្ត្ររបស់ព្រះបានទទួលសេចក្តីសង្ឃឹមនៃជីវិតអស់កល្បវិញ។

ខគម្ពីរទំនុកតម្កើង ១២៨:២, ៣ បានពិពណ៌នាអំពីព្រះពរដែលយើងត្រូវត្រេកអរនៅក្នុងផែនដីថ្មីនោះ។ ទន្ទឹមគ្នានេះ យើងក៏នឹងបានអង្គុយនៅក្រោមដើមទំពាំងបាយជូរ និងដើមឧទុម្ពរផងដែរ។ ពីព្រោះដើមទាំងនេះគឺជារូបស័ព្ទតំណាងឱ្យសេចក្តីសុខសាន្ត (មីកា ៤:៤)។ នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក ១២២ កវីបានសូមឱ្យពួកបណ្តាជនអធិស្ឋានទូលសូមឱ្យព្រះប្រទានពរឱ្យទីក្រុងយេរូសាឡិមប្រកបទៅដោយសេចក្តីសុខសាន្ត (ទំនុកតម្កើង ១២២:៦-៨; ទំនុកតម្កើង ១២៨:៥,៦)។ សេចក្តីអធិស្ឋានបែបនេះបានបង្ហាញអំពីសេចក្តីសង្ឃឹមដែលកវីមានចំពោះព្រះអង្គសង្គ្រោះ ដែលត្រូវយាងមកបញ្ចប់អំពើបាប ហើយនាំសេចក្តីសុខសាន្តមកឱ្យផែនដីនេះវិញ។

«នៅក្នុងព្រះគម្ពីរ ព្រះបានសន្យាថា រាស្ត្ររបស់ទ្រង់គឺជាអំណោយដ៏ពិសេសមួយ។ ដ្បិតអំណោយនេះគឺជា 'ទឹកដីមួយកន្លែង' [ហេព្រើរ ១១:១៤-១៦]។ ព្រះយេស៊ូវគឺជាអ្នកគង្វាលចៀមមកពីស្ថានសួគ៌។ ទ្រង់បានដឹកនាំហ្វូងចៀមរបស់ទ្រង់ទៅពឹងទឹករស់ ដែលមានដើមជីវិតនៅទីនោះដែរ ដែលដើមនោះបានបង្កើតផ្លែថ្មីៗជារៀងរាល់ខែ។ ហើយស្លឹកដែលដុះចេញពីដើមជីវិតនេះក៏បានជួយព្យាបាលមនុស្សលោកឱ្យជាសះស្បើយផងដែរ។ នៅឯនគរស្ថានសួគ៌ ក៏មានដៃទន្លេយ៉ាងថ្លាឆ្វង់ផងដែរ។ ហើយនៅជាប់ដៃទន្លេនោះ ក៏មានម្លប់នៃដើមឈើដែលបង្កឱ្យមានភាពងាយស្រួលនៅក្នុងការធ្វើដំណើរផងដែរ។ ពីព្រោះព្រះអម្ចាស់បានបង្កើតផ្លូវទាំងនេះសម្រាប់រាស្ត្ររបស់ទ្រង់។ លុះផុតវាលទំនាបទៅ មានកូនភ្នំតូចៗ និងភ្នំធំៗដែលជាកម្មសិទ្ធរបស់ព្រះ។ តែឯវាលទំនាបនោះវិញគឺជាកន្លែងនៃសេចក្តីសុខសាន្ត ដែលរាស្ត្ររបស់ព្រះនឹងត្រូវស្វែងរកទីលំនៅរបស់ពួកគេនៅកន្លែងនោះ។ ដ្បិតពួកគេលែងជាជនវង្វេងតទៅទៀត ហើយ»។ ដកស្រង់ពី Ellen G. White, *The Great Controversy*, page 675, adapted។

**តើហេតុអ្វីបានជាឈើឆ្កាងគឺជាភ័ស្តុតាងបង្ហាញថា ព្រះនឹងបំពេញសេចក្តីសន្យារបស់ទ្រង់នៅក្នុងការបង្កបង្កើតផែនដីថ្មីដែលទ្រង់បានតាំងឡើងជាមួយនឹងយើងនោះយ៉ាងដូច្នេះ?**

**ការសិក្សាបន្ថែម៖** នៅក្នុងជីវិតទាន់សម័យនៅសព្វថ្ងៃនេះ មនុស្សភាគច្រើនចង់បានសុភមង្គលលើសជាងការដែលពួកគេចង់បានប្រាជ្ញាទៅទៀត។ តើយើងអាចទទួលបានសុភមង្គលនៅក្នុងជីវិតនេះ ដោយគ្មានព្រះប្រាជ្ញាញាណរបស់ព្រះយ៉ាងដូចម្តេចទៅបាន? កណ្ឌគម្ពីរទំនុកតម្កើងបានចែងថា យើងមិនអាចមានសុភមង្គល ដោយគ្មានព្រះបានទេ។ ប៉ុន្តែ អ្វីដែលជាចំណុចល្អនោះគឺថា ព្រះមិនបានសូមឱ្យយើងជ្រើសរើសរវាងប្រាជ្ញា និងសុភមង្គលនោះឡើយ។ ពីព្រោះព្រះប្រាជ្ញាញាណរបស់ព្រះបាននាំសុភមង្គលពិតប្រាកដមកកាន់ជីវិតរបស់យើងវិញ។

យោងទៅតាមព្រះគម្ពីរ ប្រាជ្ញា និងសុភមង្គលគឺមានអត្ថន័យលើសពីគោលគំនិតទៅទៀត។ ពីព្រោះប្រាជ្ញា និងសុភមង្គលគឺជាបទពិសោធន៍ពិតៗ ដែលមានប្រភពចេញមកពីការយល់ដឹងរបស់យើង ការសរសើរតម្កើង ហើយនិងការជឿទុកចិត្តទៅលើព្រះរបស់យើង។ ដ្បិតខគម្ពីរទំនុកតម្កើង ២៥:១៤ បានចែងថា «សេចក្តីមេត្រីមិត្ររបស់ព្រះយេហូវ៉ា នៅជាមួយនឹងអ្នកណាដែលកោតខ្លាចដល់ទ្រង់ ទ្រង់នឹងសំដែងឲ្យគេស្គាល់សេចក្តីសញ្ញារបស់ទ្រង់»។

«សូមអរព្រះគុណព្រះចំពោះព្រះពរដែលទ្រង់បានប្រទានឱ្យយើងនេះ។ ទន្ទឹមនឹងនេះ សូមឱ្យលោកអ្នកបានគិតអំពីភ័ស្តុតាងទាំងអស់ដែលថា ព្រះបានប្រទានសេចក្តីស្រឡាញ់របស់ទ្រង់ដល់យើង។ សូមឱ្យលោកអ្នកបានសញ្ជឹងគិតអំពីព្រះពរជាច្រើនដែលព្រះនឹងប្រទានឱ្យយើង។ សូមគិតអំពីរូបភាពទាំងនេះឱ្យបានញឹកញាប់តាមដែលលោកអ្នកអាចធ្វើទៅបាន ពោលគឺ៖ ព្រះយេស៊ូវដ៏ជាព្រះរាជបុត្រារបស់ព្រះបានលះចាកនគរស្ថានសួគ៌។ បន្ទាប់មក ព្រះយេស៊ូវបានក្លាយមកជាមនុស្សលោក ដើម្បីឱ្យទ្រង់អាចសង្គ្រោះយើងចេញពីការកុហករបស់សាតាំងបាន។ ដ្បិតព្រះយេស៊ូវទ្រង់យកឈ្នះសង្គ្រាមទាស់នឹងសាតាំងជំនួសយើង។ ព្រះយេស៊ូវបានរៀបចំផ្លូវមួយ ដើម្បីឱ្យយើងអាចចូលទៅឯព្រះនៅឯស្ថានសួគ៌បាន។ ព្រះយេស៊ូវបានសង្គ្រោះមនុស្សលោកមានបាបចេញពីអំពើបាប។ ព្រះយេស៊ូវបានផ្សាភ្ជាប់យើងជាមួយនឹងព្រះជាថ្មីម្តងទៀត។ ព្រះយេស៊ូវបានប្រទានកម្លាំងដល់យើង ដើម្បីឱ្យយើងបានជាប់នូវការសាកល្បងខុសៗគ្នានៅក្នុងជីវិតនេះ។ ព្រះយេស៊ូវគឺជាព្រះរបស់យើង និងជាព្រះអង្គសង្គ្រោះរបស់យើងដែរ។ ទ្រង់បានគ្របបាំងយើងដោយព្រះជន្មដ៏បរិសុទ្ធរបស់ទ្រង់ដូចសម្លៀកបំពាក់យ៉ាងដូច្នោះដែរ។ បន្ទាប់មក ទ្រង់នឹងអញ្ជើញយើងឱ្យអង្គុយចុះជាមួយនឹងទ្រង់នៅលើបល្ល័ង្ករបស់ទ្រង់នៅឯស្ថានសួគ៌។ ព្រះចង់ឱ្យយើងនឹកស្រមៃអំពីរូបភាពទាំងអស់នេះណាស់ ហើយទ្រង់ក៏បានគិតអំពីពួកគេយ៉ាងប្រុងប្រយ័ត្នផងដែរ»។ ដកស្រង់ពី Ellen G. White, Steps to Christ, page 118, adapted។

## សំណួរពិភាក្សា

១. ព្រះគម្ពីរបានបង្រៀនយើងនូវរឿងរ៉ាវជាច្រើន។ តើចំណេះដឹងនៃព្រះគម្ពីរអាចផ្តល់សេចក្តីអំណរដល់យើងដោយរបៀបណាដែរ? ព្រះយេស៊ូវគឺជាព្រះបន្ទូលដ៏រស់ ឬជាព្រះគម្ពីរនោះឯង។ តើហេតុអ្វីបានជាយើងចាំបាច់ឱ្យព្រះយេស៊ូវយាងមកគង់នៅក្នុងចិត្តរបស់យើងយ៉ាងដូច្នេះ បើសិនជាយើងចង់ចេះព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះ?

២. តើមានរឿងអ្វីកើតឡើងនៅសព្វថ្ងៃនេះ បើសិនជារាស្ត្ររបស់ព្រះបានបន្តបដិសេធនូវការបង្រៀនរបស់ទ្រង់ដូចដែលសាសន៍អ៊ីស្រាអែលបានធ្វើវិញនោះ (ទំនុកតម្កើង ៨១; ទំនុកតម្កើង ៩៥)? តើហេតុអ្វីបានជាព្រះបានមានបន្ទូលថា សាសន៍អ៊ីស្រាអែល «សម័យថ្មី» ទាំងនេះ 'ដែលចូលមកក្នុងសេចក្តីរបស់អញឡើយ'» (ទំនុកតម្កើង ៩៥:១១) យ៉ាងដូច្នេះ?

៣. មានពេលខ្លះ ជីវិតខាងឯអំពើបាបមើលទៅដូចជារំភើប និងសប្បាយរីករាយជាងជីវិតនៃការស្តាប់បង្គាប់ដ៏បរិសុទ្ធទៅទៀត (ទំនុកតម្កើង ១៤១)។ តើហេតុអ្វីបាបមានគោលគំនិតបែបនេះយ៉ាងដូច្នេះ? មនុស្សជាច្រើននាក់ដែលបានបដិសេធព្រះ ពួកគេបានសប្បាយរីករាយជាមួយនឹងភាពជោគជ័យរបស់ពួកគេ។ តើយើងអាចបកស្រាយពី «ភាពជោគជ័យ» របស់ពួកគេយ៉ាងដូចម្តេចដែរ?

# ពិធីជប់លៀងលាគ្នានៅក្នុងថ្ងៃសប្បាតហ៍

២សប្តាហ៍បន្ទាប់ពីពិធីបុណ្យជ្រមុជទឹករបស់លោកសេគូលរួចមក សង្គ្រាមនៃជនជាតិបូស្នី (Bosnian War) បានផ្ទុះឡើង។ ដូច្នេះហើយ លោកសេគូលបានរត់ចេញពីវិទ្យាល័យរបស់គាត់នៅឯទីក្រុងសារ៉ាយេវ៉ូ ដែលជារាជធានីនៃប្រទេសបូស្នី-ហឺសេហ្ស៊ីកូវីណា (Bosnia and Herzegovina) ទៅលាក់ខ្លួនអស់រយៈពេល២៥ថ្ងៃ។ នៅពេលដែលគាត់ត្រឡប់មកយករបស់របររបស់គាត់ពីកន្លែងស្នាក់សិស្សប្រុស នោះគាត់ក៏បានឃើញអគារនោះត្រូវទាហានដុតចោលអស់។ បណ្ណាគារតំកល់សៀវភៅសាសនាមួយកន្លែងតូច ដែលគាត់ធ្លាប់តែស្វែងរកឯកសារ នៅពេលដែលគាត់បានស្វែងរកសេចក្តីពិត ត្រូវបានគេបោះចោលនៅកណ្តាលបន្ទប់របស់គាត់ទាំងឆេះខ្លោចអស់។ គាត់បានបាត់បង់របស់របរ និងឯកសារគ្រប់យ៉ាង។ ដូច្នេះហើយ គាត់បានត្រឡប់ទៅកាន់ស្រុកកំណើតរបស់គាត់វិញនៅក្នុងទីក្រុងម៉ុងតេណេក្រូ (Monetegro)។

ដំណឹងដែលថា លោកសេគូលបានចូលជាសមាជិកសេវេនដេយអាត់វេនទីស្ទនោះមិនមែនជាដំណឹងល្អសម្រាប់គ្រួសាររបស់គាត់នោះឡើយ។ ឪពុករបស់គាត់មិនយល់ថា ហេតុអ្វីបានជាគាត់ឈប់ញ៉ាំសាច់នោះទេ ម្ល៉ោះហើយ គាត់បាននាំលោកសេគូលទៅជួបនឹងគ្រូពេទ្យម្នាក់។ ម្តាយរបស់លោកសេគូបានគិតថា កូនគាត់ច្បាស់ជាត្រូវអំពើហើយ ដូច្នេះហើយ គាត់បានសុំជំនួយពីមនុស្សម្នាក់ដែលបានហ្វឹកហាត់វេទមន្តងងឹត។ នៅពេលដែលការព្យាយាមរបស់ឪពុកម្តាយគាត់បានបរាជ័យ នោះពួកគេបានបញ្ជូនគាត់ទៅកាន់កងយោធា។ សង្គ្រាមនៃជនជាតិបូស្នី នៅក្នុងឆ្នាំ១៩៩២ កំពុងតែក្តៅគគុក។ ពួកគេបានចុះឈ្មោះកូនប្រុសរបស់ពួកគេនៅក្នុងជួរយោធា ដើម្បីបញ្ជូនគាត់ទៅធ្វើសង្គ្រាម។

នៅក្នុងសម័យនោះ ក្រុមគ្រួសារបានរៀបចំពិធីធំៗសម្រាប់ទាហានដែលបានចូលបម្រើការងារ។ ឪពុកម្តាយរបស់លោកសេគូលបានរៀបចំពិធីជប់លៀងឱ្យគាត់ចំថ្ងៃសប្បាតហ៍នៅក្នុងខែធ្នូ។ ពួកគាត់បានរំពឹងថា យ៉ាងហោចណាស់ ក៏មានមនុស្ស២០០នាក់បានមកចូលរួមដែរ។ ប៉ុន្តែ លោកសេគូលបានធ្វើដំណើរទៅថ្វាយបង្គំនៅឯព្រះវិហារវិញ។ គាត់បានត្រឡប់មកផ្ទះវិញ នៅពេលដែលព្រះអាទិត្យលិចនៅម៉ោងម្ភៃម៉ោង៤ល្ងាចនោះ។ គាត់មិនដឹងថា គាត់ត្រូវធ្វើយ៉ាងណានោះទេ ដោយសារតែគាត់បានគិតថា ផ្ទះរបស់គាត់នឹងពេញទៅដោយសាច់ញាតិនៅក្នុងប្រទេស និងនៅក្រៅប្រទេស។ គាត់បានគិតថា គាត់ច្បាស់ជាប្រឈមជាមួយនឹងការរិះគន់ចំពោះការមកយឺតរបស់គាត់ ណាមួយ សកម្មភាពរបស់គាត់ក៏បានបង្ហាញថា គាត់មិនបានគោរពចាស់ទុំផងដែរ។ គាត់បានឃើញតារបស់គាត់នៅខាងមុខរានហាលនោះ គាត់បានសួរតារបស់គាត់ថា «លោកតា តើបងប្អូនរបស់យើងមកជុំគ្នាអស់ហើយមែនទេ?»។ លោកតាបានតបទៅវិញថា «ទេ អត់ទាន់មានអ្នកណាមកទេ ចៅ»។ «អត់ទាន់មានអ្នកណាមកទេ?»។ «ហ្នឹងហើយ ចៅអត់មានអ្នកណាមកទេ»។ «ម៉េចចឹងលោកតា?»។ «តាអត់ដឹងដែរហ្នឹង»។

មួយស្របក់ក្រោយមក សាច់ញាតិបានចាប់ផ្តើមចូលរួមនៅក្នុងពិធីជប់លៀងនោះ។ បន្ទាប់មក លោក សេគូលបានសួរពួកគេថា «ហេតុអ្វីបានជាលោកអ៊ុំ ពូមីងមកនៅម៉ោងនេះអ៊ីចឹង?»។ ពួកគេបាននិយាយដូចៗគ្នាថា៖ «មានគេប្រាប់ឱ្យពួកយើងមកម៉ោង៥»។ លោកសេគូលបានសួរទៀតថា «អ្នកណាជាអ្នកប្រាប់អ៊ុំ ពូមីងឱ្យមកនៅម៉ោង?»។ សាច់ញាតិរបស់គាត់ចាំមិនបានថា អ្នកណាជាអ្នកប្រាប់ពួកគាត់នោះឡើយ។ នៅពេលនោះ លោកសេគូលបានដឹងភ្លាមថា ព្រះពិតជាបានការពារគាត់មែន។ ដូច្នេះហើយ គាត់ក៏បានចូលទៅធ្វើជាទាហានដោយចិត្តក្លាហាន។

# អ្នកដែលបានចូលមកតាមព្រះនាមរបស់ព្រះអម្ចាស់



ល្ងាចថ្ងៃបរិសុទ្ធ - ថ្ងៃសៅរ៍ ទី២៤ ខែកុម្ភៈ ឆ្នាំ២០២៤

**អំណានព្រះគម្ពីរសម្រាប់មេរៀនប្រចាំសប្តាហ៍នេះ៖ ទំនុកតម្កើង ២៣; ទំនុកតម្កើង ២២; ទំនុកតម្កើង ៨៩:២៧-៣២; ទំនុកតម្កើង ២; ទំនុកតម្កើង ១១០:៤-៧; ហេព្រើរ ៧:២០-២៨។**

**ខចងចាំ៖ «ឯថ្មដែលពួកជាងសង់ផ្ទះបានចោលចេញ នោះបានត្រឡប់ជាថ្មជ្រុងយ៉ាងឯកហើយ នេះគឺជាការដែលព្រះយេហូវ៉ាទ្រង់ធ្វើ ហើយក៏អស្ចារ្យនៅភ្នែកនៃយើងខ្ញុំ»** (ទំនុកតម្កើង ១១៨:២២, ២៣)។

កណ្ឌគម្ពីរទំនុកតម្កើងបានប្រាប់យើងអំពីព្រះយេស៊ូវ ហើយនិងកិច្ចការដែលទ្រង់បានធ្វើសម្រាប់ព្រះ។ នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង យើងអាចអានសឹងតែគ្រប់រឿងទាំងអស់ដែលព្រះយេស៊ូវត្រូវធ្វើ ដើម្បីសង្គ្រោះយើង។

តើកណ្ឌគម្ពីរទំនុកតម្កើងរួមមានប្រធានបទអ្វីខ្លះ? កណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងថា (១) ព្រះយេស៊ូវគឺជាព្រះ។ (២) ព្រះយេស៊ូវក៏ជាព្រះរាជបុត្រារបស់ព្រះ។ (៣) ព្រះយេស៊ូវគឺជាអ្នកគង្វាលល្អ។ (៤) សិស្សម្នាក់របស់ព្រះយេស៊ូវនឹងលក់ទ្រង់ទៅឱ្យខ្មាំងសត្រូវរបស់ទ្រង់។ (៥) ព្រះយេស៊ូវនឹងស្តាប់បង្គាប់ព្រះ។ (៦) ធាតុរបស់ព្រះយេស៊ូវនឹងមិនត្រូវបានបាក់បែកឡើយ។ (៧) ព្រះយេស៊ូវនឹងត្រូវសុគត។ (៨) ព្រះយេស៊ូវនឹងរស់ពីស្លាប់ឡើងវិញ។ (៩) ទ្រង់នឹងយាងទៅឯស្ថានសួគ៌។ (១០) ទ្រង់នឹងធ្វើជាអង្គជំនួយរបស់យើង។ (១១) ទ្រង់គឺជាស្តេច។ កវីដែលបានសរសេរប្រធានបទទាំងនេះនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងជាច្រើនរយឆ្នាំ មុនពេលដែលព្រះយេស៊ូវយាងត្រឡប់មកផែនដីនេះវិញ។

ព្រះយេស៊ូវបានសន្ទនាជាមួយនឹងសិស្សរបស់ទ្រង់អំពីកណ្ឌគម្ពីរទំនុកតម្កើងនៅតាមផ្លូវទៅកាន់ភូមិអេម៉ោស (លូកា ២៤:៤៤)។ ឥឡូវនេះ យើងអាចយល់អំពីមូលហេតុដែលព្រះយេស៊ូវបានធ្វើដូច្នេះហើយ។ ពោលគឺទ្រង់ចង់ឱ្យពួកសិស្សរបស់ទ្រង់បានមើលឃើញភ័ស្តុតាងនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង និងនៅក្នុងកណ្ឌគម្ពីរដទៃនៅក្នុងព្រះគម្ពីរដែលបានបង្ហាញពីអត្តសញ្ញាណរបស់ទ្រង់។

បទគម្ពីរទំនុកតម្កើង ជំពូក២៤, ៤៥, ៧២ និង១០១ បានបង្ហាញថា ព្រះយេស៊ូវគឺជាស្តេច និងជាចៅក្រមរបស់យើង។ បទគម្ពីរទំនុកតម្កើង ជំពូក៨៨ និងជំពូក១០២ គឺជាសេចក្តីអធិស្ឋានដែលបានបង្ហាញនូវការឈឺចាប់ដែលព្រះយេស៊ូវបានរងទុក្ខនៅក្នុងនាមជាមនុស្សម្នាក់ដូចជាយើងដែរ។ នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង យើងនឹងអានអំពីសេចក្តីអធិស្ឋានដែលព្រះយេស៊ូវបានទូលសូមឱ្យព្រះសង្គ្រោះមនុស្សជាតិ។

# ព្រះយេស៊ូវដែលជាអ្នកគង្វាលរបស់យើង

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក២៣; ទំនុកតម្កើង ២៨:៩; ទំនុកតម្កើង ៨០:១; ទំនុកតម្កើង ៧៨:៥២, ៥៣; ទំនុកតម្កើង ៧៩:១៣ និងទំនុកតម្កើង ១០០:៣។ តើទំនាក់ទំនងរវាងព្រះអម្ចាស់ ហើយនិងរាស្ត្ររបស់ទ្រង់ត្រូវបានបង្ហាញនៅក្នុងខទាំងនេះដោយរបៀបណា?**

______________________________________________

______________________________________________

កណ្ឌគម្ពីរទំនុកតម្កើងបានបង្រៀនយើងថា ព្រះអម្ចាស់គឺប្រៀបដូចជាអ្នកគង្វាលម្នាក់យ៉ាងដូច្នោះដែរ។ ហើយរាស្ត្ររបស់ទ្រង់គឺប្រៀបដូចជាចៀមរបស់ទ្រង់។ រូបស័ព្ទនេះបានជួយឱ្យយើងយល់អំពីរបៀបដែលព្រះបានយកព្រះទ័យទុកដាក់ចំពោះរាស្ត្ររបស់ទ្រង់។ ពោលគឺរាស្ត្ររបស់ព្រះត្រូវតែពឹងផ្អែកទៅលើទ្រង់ ដើម្បីឱ្យទ្រង់ប្រទានឱ្យពួកគេនូវអ្វីគ្រប់យ៉ាងដែលពួកគេត្រូវការ។ រូបស័ព្ទនេះបានបង្ហាញយើងអំពីទំនាក់ទំនងនៃសេចក្តីស្រឡាញ់រវាងព្រះ និងរាស្ត្ររបស់ទ្រង់។ អ្នកគង្វាលបានរស់នៅជាមួយនឹងហ្វូងចៀមរបស់ពួកគេ ដើម្បីថែរក្សាចៀមទាំងអស់។ ដូច្នេះហើយ ព្រះគឺជាម្ចាស់នៃហ្វូងចៀម។ ហ្វូងចៀមនេះគឺជារបស់ទ្រង់ ដោយសារតែទ្រង់បានប្រទានជីវិតដល់ពួកគេ (ទំនុកតម្កើង ៩៥:៦, ៧; ទំនុកតម្កើង ១០០:៣) ហើយទ្រង់ក៏បានសន្យានឹងពួកគេផងដែរ (ទំនុកតម្កើង ១៣:២០)។

នៅក្នុងខគម្ពីរទំនុកតម្កើង ៨០:១ យើងបានអានអំពីអ្នកគង្វាលដែលបានដឹកនាំលោកយ៉ូសែបដូចជាហ្វូងចៀមមួយក្រុមដូច្នោះដែរ។ នៅក្នុងរូបស័ព្ទនេះ លោកយ៉ូសែបគឺជារូបស័ព្ទមួយតំណាងឱ្យសាសន៍អ៊ីស្រាអែល ដែលរូបស័ព្ទនៃអ្នកគង្វាលចៀមដែលបានដឹកនាំលោកយ៉ូសែប បានជួយឱ្យយើងនឹកចាំពីសេចក្តីសន្យាដ៏អស្ចារ្យអំពីសាសន៍អ៊ីស្រាអែល ដែលលោកយ៉ាកុបបានប្រគល់ជូនលោកយ៉ូសែប។ កវីនៅក្នុងជំពូកនេះបានយករូបស័ព្ទនេះមកប្រើជាមធ្យោបាយមួយ ដើម្បីទូលសូមឱ្យព្រះបំពេញសេចក្តីសន្យាដ៏អស្ចារ្យនេះដល់រាស្ត្ររបស់ទ្រង់ផង (លោកុប្បត្តិ ៤៩:២៤)។

នៅក្នុងសម័យព្រះគម្ពីរ ស្តេចគឺជាអ្នកគង្វាលរាស្ត្ររបស់ទ្រង់ (សាំយូអែលទី២ ៥:២)។ គួរឱ្យសោកស្តាយណាស់ ស្តេចដែលជាមនុស្សលោកតែងតែមិនខ្វល់ខ្វាយពីសុខទុក្ខរាស្ត្ររបស់ពួកគេ ដូចជាព្រះយេស៊ូវបានធ្វើនោះទេ។ ត្រង់នេះឯងគឺជាមូលហេតុដែលព្រះបានទទួលនាមថា ជាអ្នកគង្វាលដ៏ល្អនោះ។

**សូមអានខគម្ពីរយ៉ូហាន ១០:១១-១៥។ តើនៅក្នុងខទាំងនេះ ព្រះយេស៊ូវដែលជាអ្នកគង្វាលល្អបានមានបន្ទូលអំពីអង្គទ្រង់យ៉ាងដូចម្តេចដែរ?**

______________________________________________

______________________________________________

ព្រះយេស៊ូវបានមានបន្ទូលថា ចៀមរបស់ទ្រង់បានស្គាល់ព្រះសូរសៀងរបស់ទ្រង់ (យ៉ូហាន ១០:៤, ២៧)។ រហូតមកដល់សព្វថ្ងៃនេះ អ្នកគង្វាលចៀមនៅក្នុងបែកមជ្ឈិមបូព៌ាអាចហៅឱ្យចៀមរបស់ពួកគេមករកពួកគេបាន។ នៅពេលដែលចៀមបានឮសំឡេងអ្នកគង្វាលរបស់ពួកវា នោះពួកវានឹងដើរចេញពីចៀមដទៃទៀតដែលមិនមែនជាផ្នែកនៃហ្វូងចៀមរបស់ពួកវា។ បន្ទាប់មក ចៀមនឹងទៅដើរទៅតាមអ្នកគង្វាលរបស់វាវិញ។ មានពេលខ្លះ ហ្វូងចៀមរបស់ព្រះបានរងនូវការលំបាកជាច្រើន។ ហើយពួកគេក៏បានដឹងថា បទពិសោធន៍ទាំងនេះគឺជាសញ្ញាបង្ហាញថា ព្រះអម្ចាស់មិនសព្វព្រះហឫទ័យជាមួយនឹងពួកគេនោះឡើយ។ ប៉ុន្តែ អ្នកគង្វាលចៀមល្អមិនដែលបោះបង់ពួកគេចោលឡើយ។ ទ្រង់តែងតែស្វែងរកចៀមបាត់បង់របស់ទ្រង់ ដើម្បីសង្គ្រោះពួកគេជានិច្ច។ រូបស័ព្ទដ៏មានអំណាចនេះបានបង្ហាញយើងអំពីសេចក្តីស្រឡាញ់ដែលព្រះមានចំពោះយើង។ ហើយព្រះក៏សព្វព្រះហឫទ័យនឹងសុគតជំនួសចៀមរបស់ទ្រង់ដែរ (យ៉ូហាន ១០:១១, ១៥)។ ព្រះយេស៊ូវគឺជាអ្នកគង្វាលចៀមដែលបានក្លាយមកជាកូនចៀម ដើម្បីសង្គ្រោះចៀមរបស់ទ្រង់ (យ៉ូហាន ១:២៩)។

# ព្រះអង្គសង្គ្រោះដែលបានរងទុក្ខ

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក២២ និងខគម្ពីរទំនុកតម្កើង ១១៨:២២។ តើមនុស្សលោកបានធ្វើអ្វីខ្លះ ទៅកាន់ព្រះដែលបានយាងមកសង្គ្រោះពួកគេនោះ?**

______________________________________________________________________

______________________________________________________________________

កណ្ឌគម្ពីរទំនុកតម្កើងបានពិពណ៌នាអំពីព្រះអង្គសង្គ្រោះដែលបានរងទុក្ខ រួមទាំងអារម្មណ៍នៃការឈឺចាប់ ហើយនិងភាពឯកោរបស់ទ្រង់ផងដែរ (ទំនុកតម្កើង ៤២; ទំនុកតម្កើង ៨៨; ទំនុកតម្កើង ១០២)។ បទគម្ពីរទំនុកតម្កើង ជំពូក២២ បានប្រាប់យើងអំពីការសុគតរបស់ព្រះយេស៊ូវ ដោយទ្រង់បានអធិស្ឋាននៅលើឈើឆ្កាង ដោយប្រើពាក្យពេចន៍នៃខគម្ពីរទំនុកតម្កើង ២២:១ (ម៉ាថាយ ២៧:៤៦)។

ព្រះយេស៊ូវ ហើយនិងព្រះវរបិតារបស់ទ្រង់បានស្រឡាញ់គ្នាជាខ្លាំង។ ពីព្រោះព្រះយេស៊ូវ និងព្រះវរបិតាទ្រង់មានចិត្ត និងគំនិតតែមួយ (យ៉ូហាន ១:១, ២; យ៉ូហាន ១០:៣០)។ ដូច្នេះហើយ ព្រះយេស៊ូវបានរងទុក្ខជាខ្លាំង នៅពេលដែលអំពើបាបរបស់យើងបានបំបែកទ្រង់ចេញពីព្រះវរបិតាទ្រង់នោះ។ ប៉ុន្តែការរងទុក្ខមិនអាចបំផ្លាញសេចក្តីស្រឡាញ់រវាងព្រះយេស៊ូវ ហើយនិងព្រះវរបិតារបស់ទ្រង់បានឡើយ។ នៅពេលដែលព្រះវរបិតាបានបែរព្រះភ័ក្ត្រចេញពីព្រះយេស៊ូវនៅលើឈើឆ្កាង នោះព្រះយេស៊ូវបានជឿទុកចិត្តទៅព្រះវរបិតាទ្រង់ទាំងស្រុង។

«ព្រះយេស៊ូវគឺជាអង្គជំនួសយើង។ ព្រះយេស៊ូវបានទទួលយកកំហុសនៃអំពើបាបរបស់យើង។ ទ្រង់បានទទួលរងអំពើបាបរបស់យើង ដើម្បីសង្គ្រោះយើងឱ្យរួចផុតពីទណ្ឌកម្មនៃការរំលងបញ្ញត្តរបស់ព្រះ។ ព្រះយេស៊ូវបានទ្រាំទ្រកំហុសនៃអំពើបាបដែលមនុស្សជាតិទាំងអស់បានបង្កឡើងនៅក្នុងព្រះទ័យរបស់ទ្រង់។ ដ្បិតសេចក្តីក្រោធរបស់ព្រះដែលទាស់នឹងអំពើបាបនោះ បានធ្វើឱ្យព្រះទ័យរបស់ព្រះយេស៊ូវមានពេញទៅដោយភាពភ័យខ្លាច ហើយនិងភាពអស្ចារ្យ»។ ដកស្រង់ពី Ellen G. White, *The Desire of Ages*, pages 753, adapted។

បទគម្ពីរទំនុកតម្កើង ជំពូក២២បានប្រើរូបសព្ទជាសត្វគោឈ្មោល សត្វសិង្ហ ហើយនិងសត្វឆ្កែ។ ដ្បិតសត្វទាំងនេះបានបង្ហាញអំពីសេចក្តីសម្អប់ដែលមនុស្សលោកមានចំពោះព្រះអង្គសង្គ្រោះ នៅក្នុងអំឡុងនៃនាទីចុងក្រោយរបស់ទ្រង់នៅលើឈើឆ្កាងនោះ។ មនុស្សលោកបានប្រៀបធៀបព្រះអង្គសង្គ្រោះទៅនឹងសត្វដង្កូវអស់សង្ឃឹមមួយក្បាល ដែលមិនអាចធ្វើបាបអ្នកណាបានឡើយ។ បទគម្ពីរទំនុកតម្កើងជំពូក២២បានប្រាប់យើងអំពីរបៀបដែលពួកបណ្តាជនបានមាក់ងាយព្រះយេស៊ូវ នៅពេលដែលទ្រង់អំពាវនាវរកព្រះវរបិតាទ្រង់នោះ (ទំនុកតម្កើង ២២:១, ៨; ម៉ាថាយ ២៧:៤៣)។ ពួកទាហានបានយកសម្លៀកបំពាក់របស់ព្រះយេស៊ូវទៅហែកចែកគ្នា (ទំនុកតម្កើង ២២:១៨; ម៉ាថាយ ២៧:៣៥)។ មនុស្សលោកបានគិតថា ព្រះយេស៊ូវគឺប្រៀបដូចជាដង្កូវមួយក្បាល។ ពួកគេចង់បំផ្លាញទ្រង់ណាស់ ដោយសារតែពួកគេមិនបានដឹងថា ទ្រង់នឹងក្លាយមកជាថ្មជ្រុងយ៉ាងឯកនៅក្នុងរោងឧបោសថនោះឡើយ (ទំនុកតម្កើង ១១៨:២២)។ ទ្រង់នឹងរៀបចំផ្លូវថ្មីមួយសម្រាប់ឱ្យមនុស្សមានបាបបានចូលទៅឯព្រះ។

ព្រះអង្គសង្គ្រោះដែលមនុស្សលោកបានបដិសេធនេះ ក៏បានក្លាយមកជាសេចក្តីសង្ឃឹមនៃរាស្ត្ររបស់ព្រះ នៅពេលដែលទ្រង់រស់ពីស្លាប់ឡើងវិញនោះដែរ (ម៉ាថាយ ២១:៤២; កិច្ចការ ៤:១០-១២)។ ព្រះយេស៊ូវបានរងទុក្ខ ដោយសារតែមនុស្សដែលទ្រង់បានយាងមកជួយនោះ បានបដិសេធទ្រង់។ ប៉ុន្តែព្រះបានលើកតម្កើងព្រះរាជបុត្រារបស់ទ្រង់វិញ។ ព្រះបានលើកព្រះយេស៊ូវឱ្យធ្វើជាមេនៃពួកជំនុំរបស់ទ្រង់ (អេភេសូរ ២:២០-២២; ពេត្រុសទី១ ២:៤-៨)។ អស់អ្នកណាដែលបានបដិសេធទ្រង់ ក៏មានន័យថាពួកគេបានបដិសេធផែនការដែលព្រះបានរៀបចំ ដើម្បីសង្គ្រោះមនុស្សមានបាបនោះដែរ។ ដូច្នេះហើយ យើងត្រូវតែធ្លាក់នៅលើថ្មនេះ ដើម្បីឱ្យបានសង្គ្រោះ។ តែបើថ្មនេះបានធ្លាក់មកលើយើងវិញ នោះយើងនឹងត្រូវបាក់បែកខ្ទិចខ្ទីទៅ (អេសាយ ៨:១៤; ម៉ាថាយ ២១:៤៤)។

**ព្រះយេស៊ូវបានរងទុក្ខជំនួសលោកអ្នក។ តើដំណឹងនេះគួរតែធ្វើឱ្យយើងមានអារម្មណ៍ដូចម្តេចអំពីអំពើបាបនោះ?**

# ព្រះយេស៊ូវបានរក្សាសេចក្តីសន្យារបស់ទ្រង់ជារៀងរហូត

**តើព្រះបានសន្យាជាមួយនឹងស្តេចដាវីឌយ៉ាងដូចម្តេចដែរ? សូមអានខគម្ពីរទំនុកតម្កើង ៨៩:២៧-៣២, ៣៨-៤៦ និងទំនុកតម្កើង ១៣២:១០-១២ សម្រាប់ចម្លើយ។**

_______________________________________________

_______________________________________________

ព្រះបានតាំងសេចក្តីសន្យាមួយជាមួយនឹងស្តេចដាវីឌ ដោយទ្រង់បានសន្យាថា ទ្រង់នឹងជួយគាំទ្រពួកបុត្រារបស់ស្តេចដាវីឌ ដើម្បីឱ្យពួកគេបានធ្វើជាព្រះពរដល់សាសន៍អ៊ីស្រាអែលជារៀងរហូត (សាំយូអែលទី១ ៧:៥-១៦; ទំនុកតម្កើង ៨៩:១-៤, ១៩-៣៧; ទំនុកតម្កើង ១៣២:១២-១៨)។ ព្រះនឹងយល់ព្រមរក្សាសេចក្តីសន្យារបស់ទ្រង់ជារៀងរហូត បើសិនជាស្តេចដាវីឌបានគោរពតាមទ្រង់នោះ។ នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៨៩ កវីបានកើតទុក្ខ ដោយសារតែពួកបណ្តាជនបានបាត់បង់ព្រះពរដែលព្រះបានសន្យានឹងស្តេចដាវីឌ។ តើព្រះបានបដិសេធសាសន៍អ៊ីស្រាអែលជារៀងរហូតដែរឬទេ? ទេ ទ្រង់មិនបានបដិសេធពួកគេជារៀងរហូតនោះឡើយ។

ជាការពិតណាស់ សេចក្តីក្រោធរបស់ព្រះបានបង្ហាញរាស្ត្ររបស់ទ្រង់ពីទស្សនៈដែលទ្រង់បានយល់ឃើញពីអំពើបាប (ទំនុកតម្កើង ៣៨:១; ទំនុកតម្កើង ៧៤:១)។ ប៉ុន្តែ សេចក្តីក្រោធរបស់ព្រះមិនបានបន្តជារៀងរហូតនោះឡើយ។ ដ្បិតសេចក្តីស្រឡាញ់ដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់បានលើកលែងទោសអំពើបាបរបស់មនុស្សលោក នៅពេលដែលពួកគេលន់តួកំហុសរបស់ពួកគេ។ ខណៈដែលព្រះកំពុងតែខ្ញាល់នោះទ្រង់ក៏បានបង្ហាញរាស្ត្ររបស់ទ្រង់ថា ទ្រង់មិនសព្វព្រះទ័យជាមួយនឹងពួកគេផងដែរ។ រាស្ត្ររបស់ព្រះបានដឹងថា អំពើបាបនាំទៅរកការឈឺចាប់។ ពួកគេបានដឹងថា អំពើបាបគឺជារឿងដ៏អាក្រក់បំផុត (ទំនុក-តម្កើង ៨៩:៣៨-៤៦)។ ពួកគេក៏បានដឹងថា សេចក្តីក្រោធរបស់ព្រះមិនមែនជាសេចក្តីក្រោធជារៀងរហូតនោះដែរ (ទំនុកតម្កើង ៨៩:៤៦)។ នៅពេលដែលរាស្ត្ររបស់ព្រះបាននឹកចាំថា ព្រះតែងតែរក្សាសេចក្តីសន្យារបស់ទ្រង់ នោះពួកគេក៏បាននឹកចាំអំពីព្រះគុណរបស់ទ្រង់ដែរ។ បន្ទាប់មក ចិត្តរបស់ពួកគេនឹងបានពេញទៅដោយសេចក្តីសង្ឃឹមដែលថា ព្រះនឹងនឹកចាំពីពួកគេ (ទំនុកតម្កើង ៨៩:៤៧, ៥០)។

និយាយឱ្យខ្លី យើងអាចនឹងធ្វើឱ្យព្រះខកព្រះទ័យបាន។ ប៉ុន្តែ ព្រះមិនដែលធ្វើឱ្យយើងខកចិត្តនោះទេ។ ដូច្នេះហើយ យើងអាចជឿទុកចិត្តទៅលើសេចក្តីសន្យារបស់ទ្រង់ដែលថា ទ្រង់បានសង្គ្រោះយើង ដោយសារតែព្រះយេស៊ូវ។

ព្រះយេស៊ូវគឺជាហ្លួងរបស់ស្តេចដាវីឌ ហើយទ្រង់ក៏ជាព្រះអង្គសង្គ្រោះផងដែរ (ម៉ាថាយ ១:១; ហេព្រើរ ១:៨)។ ព្រះយេស៊ូវគឺ «ជាបងច្បងនៃគ្រប់ទាំងអស់ ដែលព្រះបានបង្កើតមក» (កូឡុស ១:១៥)។ ខគម្ពីរកូឡុស ១:១៥ បានជួយឱ្យយើងនឹកចាំពីខគម្ពីរទំនុកតម្កើង ៨៩:២៧ ដែលបានចែងថា៖ «ឯអញៗនឹងតាំងឡើង ឲ្យធ្វើជាកូនច្បងរបស់អញ គឺជាមហាក្សត្រយ៉ាងខ្ពស់បំផុតនៅផែនដី»។

តើ «កូនច្បង» នៅក្នុងខគម្ពីរទំនុកតម្កើង ៨៩:២៧ គឺជាអ្នកណា? តើកំណាព្យនៅត្រង់ខនេះបានថ្លែងអំពីស្តេចដាវីឌដែរឬទេ? ទេ កំណាព្យនេះមិនបានថ្លែងអំពីស្តេចដាវីឌនោះទេ ពីព្រោះស្តេចដាវីឌគឺជាកូនទី៨នៅក្នុងគ្រួសាររបស់គាត់ មិនមែនជាកូនច្បងនោះឡើយ (សាំយូអែលទី១ ១៦:១០, ១១)។ ពាក្យថា «កូនច្បង» នៅត្រង់នេះគឺសំដៅទៅលើព្រះយេស៊ូវវិញ។ ពាក្យទាំងនេះបានបង្ហាញយើងថា ព្រះបានប្រទានកិត្តិយសដ៏ពិសេសមួយដល់ព្រះយេស៊ូវ (កូឡុស ១:១៦, ២០-២២)។ ដ្បិតនៅពេលដែលព្រះយេស៊ូវបានរស់ពីស្លាប់ឡើងវិញ នោះព្រះបានធ្វើឱ្យព្រះយេស៊ូវក្លាយទៅជាស្តេចគ្រប់គ្រងផែនដីដ៏មានអំណាចបំផុត (កិច្ចការ ២:៣០, ៣១)។

**សូមអានខគម្ពីរកូឡុស ១:១៦, ២០-២២។ តើខទាំងនេះបានបង្រៀនយើងអំពីព្រះយេស៊ូវយ៉ាងដូចម្តេចដែរ? តើទ្រង់គឺជាអ្នកណា? តើទ្រង់បានធ្វើកិច្ចការអ្វីខ្លះសម្រាប់យើង?**

# ស្ដេចដ៏នៅអស់កល្បជានិច្ច

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក២; ខគម្ពីរទំនុកតម្កើង ១១០:១-៣, ៥, ៦ និងខគម្ពីរទំនុកតម្កើង ៨៩:៤, ១៣-១៧។ តើខទាំងនេះបានបង្រៀនយើងអំពីព្រះយេស៊ូវដែលជាស្ដេចរបស់យើងនេះយ៉ាងដូចម្ដេចដែរ?**

___

___

កណ្ឌគម្ពីរទំនុកតម្កើងបានបង្ហាញយើងអំពីរូបភាពរបស់ព្រះនៅក្នុងនាមជាព្រះវរបិតារបស់ព្រះអង្គសង្គ្រោះ។ រូបភាពនេះបានជួយឱ្យយើងនឹកចាំអំពីពិធីដ៏ពិសេសមួយនៅក្នុងសាសន៍អ៊ីស្រាអែល នៅពេលដែលមានអ្នកណាម្នាក់ត្រូវបានតាំងឡើងជាស្ដេចនោះ។ ព្រះបានយកស្ដេចមកធ្វើជាកូនចិញ្ចឹមរបស់ទ្រង់ ហើយទ្រង់ក៏បានតាំងសេចក្ដីសន្យាមួយជាមួយនឹងស្ដេចផងដែរ (ទំនុកតម្កើង ២:៧; ទំនុកតម្កើង ៨៩:២៦-២៨)។ ខគម្ពីរទំនុកតម្កើង ២:៧ បានប្រាប់យើងថា ព្រះអង្គសង្គ្រោះនឹងបានរស់ពីស្លាប់ឡើងវិញ ហើយទ្រង់ក៏នឹងតាំងសេចក្ដីសន្យាថ្មីមួយដ៏នៅអស់កល្បជានិច្ចជាមួយនឹងរាស្ត្ររបស់ទ្រង់ផងដែរ (កិច្ចការ ១៣:៣៣-៣៩; ហេព្រើរ ១:៥)។ ខគម្ពីរទំនុកតម្កើង ២:៧ ក៏បានប្រាប់យើងថា ព្រះយេស៊ូវនឹងបានក្លាយទៅជាសម្ដេចសង្ឃនៃរាស្ត្ររបស់ទ្រង់ផងដែរ (ហេព្រើរ ៥:៥)។ ហើយទ្រង់ក៏បានគង់នៅខាងស្ដាំព្រះផងដែរ។ កន្លែងកិត្តិយសនេះបានបង្ហាញថា ព្រះយេស៊ូវទ្រង់មានអំណាចគ្រប់យ៉ាង ហើយទ្រង់ក៏បានគ្រប់គ្រងផែនដីទាំងមូលផងដែរ (ទំនុកតម្កើង ១១០:១; កិច្ចការ ៧:៥៥, ៥៦)។

នៅពេលដែលសង្គ្រាមរវាងព្រះ ហើយនិងសាតាំងត្រូវបានបញ្ចប់ទៅ នោះព្រះនឹងដាក់ខ្មាំងសត្រូវរបស់ព្រះយេស៊ូវឱ្យនៅក្រោមការគ្រប់គ្រងរបស់ទ្រង់ (ទំនុកតម្កើង ១១០:២; ទំនុកតម្កើង ២:៩)។ មុនពេលដែលរឿងនេះបានកើតឡើង ព្រះបានផ្ដល់ឱកាសឱ្យពួកស្ដេចអាក្រក់បានលន់តួអំពើបាបរបស់ពួកគេ ហើយបែរមកថ្វាយបង្គំព្រះអង្គសង្គ្រោះវិញ (ទំនុកតម្កើង ២:១០-១២)។

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៧ យើងបានឃើញរូបភាពនៅពេលអនាគត បន្ទាប់ពីព្រះយេស៊ូវបានឈ្នះសង្គ្រាមទាស់នឹងខ្មាំងសត្រូវរបស់ទ្រង់នោះ។ ទន្ទឹមគ្នានេះ នគររបស់ព្រះយេស៊ូវក៏ត្រូវបានតាំងឡើងនៅលើផែនដីនេះដែរ។ ដ្បិតលោកដានីយ៉ែលបានប្រាប់យើងថា នគររបស់ព្រះយេស៊ូវគឺ ជានគរដ៏នៅអស់កល្បជានិច្ច (ដានីយ៉ែល ៧:២៧)។ ដូច្នេះហើយ យើងអាចជឿទុកចិត្តទៅលើសេចក្ដីសន្យានេះបាន តាមរយៈឈើឆ្កាង។

ព្រះបានសន្យាថា ទ្រង់នឹងប្រទានព្រះពរដល់មនុស្សគ្រប់គ្នា ដែលបានជឿទុកចិត្តទៅលើព្រះមហាក្សត្រយេស៊ូវ (ទំនុកតម្កើង ២:១២)។ ដ្បិតរាស្ត្ររបស់ព្រះមានពេញទៅដោយសេចក្ដីអំណរ ដោយសារព្រះអង្គសង្គ្រោះរបស់ពួកគេក៏ជាស្ដេចរបស់ពួកគេផងដែរ។ ទ្រង់គឺជាស្ដេចដ៏បរិសុទ្ធ ហើយនគររបស់ទ្រង់ក៏បរិសុទ្ធដែរ (ទំនុកតម្កើង ៨៩:១៥-១៧)។

**យើងបានដឹងថា នៅចុងបញ្ចប់ សេចក្ដីល្អនឹងបានសេចក្ដីអាក្រក់ ដោយសារតែភាពយុត្តិធម៌របស់ព្រះ។ ដ្បិតទ្រង់នឹងបញ្ចប់ការឈឺចាប់ ហើយនិងការរងទុក្ខជារៀងរហូតតទៅ។ តើសេចក្ដីពិតនៅត្រង់នេះគួរតែធ្វើឱ្យយើងមានអារម្មណ៍យ៉ាងដូចម្ដេចដែរ នៅពេលដែលយើងក្រឡេកឃើញសេចក្ដីអាក្រក់កំពុងតែឈ្នះសេចក្ដីល្អនោះ?**

# ព្រះយេស៊ូវដែលជាសម្ដេចសង្ឃរបស់យើង

**ព្រះយេស៊ូវគឺជាសម្ដេចសង្ឃរបស់យើង (ទំនុកតម្កើង ១១០:៤-៧)។ តើអ្វីដែលធ្វើឱ្យកិច្ចការរបស់ទ្រង់ជាសម្ដេចសង្ឃសំខាន់ម្ល៉េះ សម្រាប់យើងនោះ? តើកិច្ចការរបស់ទ្រង់ដែលជាសម្ដេចសង្ឃនៅឯស្ថានសួគ៌បានផ្ដល់សេចក្ដីសង្ឃឹមអ្វីខ្លះដល់យើង?**

---

---

ព្រះអម្ចាស់បានតាំងសេចក្ដីសន្យាដ៏ពិសេសមួយជាមួយនឹងរាស្ត្ររបស់ទ្រង់ (ហេព្រើរ ៦:១៨) ដែលថា ទ្រង់នឹងធ្វើជាស្ដេច ហើយនិងជាសម្ដេចសង្ឃរបស់ពួកគេជារៀងរហូតតទៅ (ទំនុកតម្កើង ១១០:៤-៧)។ សេចក្ដីសន្យានេះបានបង្ហាញយើងអំពីព្រះគុណរបស់ព្រះ។ ដ្បិតអំពើបាបរបស់យើងនឹងបន្តបំបែកយើងចេញពីព្រះ។ ប៉ុន្តែ ព្រះបានប្រទានសេចក្ដីសន្យាមួយដល់យើងវិញ។ ហើយសេចក្ដីសន្យារបស់ទ្រង់នេះក៏មិនអាចផ្លាស់ប្ដូរបានដែរ។ ដ្បិតព្រះគុណរបស់ទ្រង់គឺជាភ័ស្តុតាងបង្ហាញថា ទ្រង់នឹងរក្សាសេចក្ដីសន្យាដែលទ្រង់បានតាំងឡើងជាមួយនឹងរាស្ត្ររបស់ទ្រង់ នៅពេលដែលពួកគេបានលន់តួអំពើបាបរបស់ពួកគេទៅឯទ្រង់នោះ (និក្ខមនំ ៣២:១៤; ទំនុកតម្កើង ១០៦:៤៥)។

ពាក្យសម្បថរបស់ព្រះមានលក្ខណៈពិសេសណាស់ ដោយសារតែទ្រង់បានសន្យាថា ព្រះអង្គសង្គ្រោះគឺជាស្ដេចផង ជាសម្ដេចសង្ឃផង (ទំនុកតម្កើង ១១០:៤)។ ស្ដេចរបស់សាសន៍អ៊ីស្រាអែលមិនត្រូវបានអនុញ្ញាតឱ្យបម្រើព្រះនៅក្នុងនាមជាសម្ដេចសង្ឃបានឡើយ (ជនគណនា ៨:១៩; របាក្សត្រទី២ ២៦:១៦-២១)។ នៅពេលដែលព្រះគម្ពីរបានចែងថា ស្ដេច ឬពួកបណ្ដាជនបាននាំយកតង្វាយមកថ្វាយដល់ពួកសង្ឃ មានន័យថា ពួកសង្ឃគឺជាបុគ្គលម្នាក់ដែលត្រូវសម្លាប់សត្វថ្វាយទៅព្រះ។ បទគម្ពីរទំនុកតម្កើងជំពូក១១០ បានចែងថា ស្ដេចដ៏ជាព្រះអង្គសង្គ្រោះមានលក្ខណៈខុសគ្នាពីស្ដេច និងសង្ឃទាំងអស់នៅក្នុងសាសន៍អ៊ីស្រាអែល។ ព្រះយេស៊ូវគឺជាសម្ដេចសង្ឃដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងលោកម៉ិលគីស្សាដែកដូច្នោះដែរ។ លោកម៉ិលគីស្សាដែកគឺជាស្ដេចនៃទីក្រុងយេរូសាឡិមផង (ឈ្មោះដើមរបស់ទីក្រុងយេរូសាឡិម) និងជាសង្ឃរបស់ព្រះផង (លោកុប្បត្តិ ១៤:១៨-២០)។ តើគម្ពីរសញ្ញាចាស់បានចែងថា ស្ដេចដាវីឌ ឬស្ដេចនៃសាសន៍អ៊ីស្រាអែលដទៃទៀតគឺជាស្ដេច និងជាសង្ឃដូចជាលោកម៉ិលគីស្សាដែកនេះនៅត្រង់កន្លែងណាទៀតដែរឬទេ? យើងអាចអានអំពីចំណុចនេះបានតែនៅក្នុងបទគម្ពីរទំនុកតម្កើងជំពូក១១០ ប៉ុណ្ណោះ។ បទគម្ពីរទំនុកតម្កើងនៅត្រង់ជំពូកនេះបានពិពណ៌នាអំពីបុគ្គលម្នាក់ដែលជាស្ដេចផង ជាសង្ឃផងនៅក្នុងប្រវត្តិសាស្ត្រនៃសាសន៍អ៊ីស្រាអែល ហើយបុគ្គលម្នាក់នោះមានតែព្រះយេស៊ូវមួយគត់ដែលស័ក្តិសម។

**សូមអានខគម្ពីរហេព្រើរ ៧:២០-២៨។ តើហេតុអ្វីបានជាកិច្ចការរបស់ព្រះយេស៊ូវជាសម្ដេចសង្ឃនេះបានផ្ដល់សេចក្ដីសង្ឃឹម និងទំនុកចិត្តដល់ចិត្តរបស់យើងយ៉ាងដូច្នេះ?**

---

ព្រះយេស៊ូវគឺជាស្ដេចផង និងជាសម្ដេចសង្ឃដ៏នៅអស់កល្បជានិច្ចផង។ ដូច្នេះហើយ ទ្រង់គឺជាស្ដេច និងជាសម្ដេចសង្ឃល្អជាងមនុស្សលោកដទៃទៀត ដោយសារតែទ្រង់បានបម្រើយើងនៅក្នុងរោងឧបោសថនៅឯស្ថានសួគ៌។ អំពើបាប និងសេចក្ដីស្លាប់មិនអាចបញ្ឈប់កិច្ចការរបស់ទ្រង់ ដូចដែលពួកវាបានបញ្ឈប់កិច្ចការរបស់សង្ឃដែលជាមនុស្សលោកនោះឡើយ។ ដូច្នេះហើយ ព្រះយេស៊ូវអាចចូលទៅឯព្រះបាន ដើម្បីសុំជំនួយសម្រាប់រាស្ត្ររបស់ទ្រង់ជារៀងរហូត។ កិច្ចការដែលព្រះបានធ្វើនៅក្នុងនាមជាចៅក្រមរបស់យើង បានធ្វើឱ្យយើងមានសេចក្ដីសង្ឃឹមទៅលើព្រះ (ហេព្រើរ ៦:១៩, ២០)។ យើងអាចជឿទុកចិត្តថា ព្រះយេស៊ូវដែលជាស្ដេច និងជាសម្ដេចសង្ឃរបស់យើងនេះ នឹងបញ្ឈប់សេចក្ដីអាក្រក់នៅក្នុងចិត្តរបស់យើង ហើយនិងសេចក្ដីអាក្រក់នៅលើផែនដីនេះផង។ ព្រះយេស៊ូវតែងតែរក្សាសេចក្ដីសន្យានៅក្នុងខគម្ពីរទំនុកតម្កើង ២:៦-៩ ជានិច្ច ដែលថា ទ្រង់នឹងជំនុំជម្រះមេដឹកនាំទាំងអស់ រួមទាំងមនុស្សគ្រប់ជាតិសាសន៍នៅលើផែនដីផងដែរ។

**ការសិក្សាបន្ថែម៖** សូមអាន Ellen G. White, "God With Us," pages 19-26, in *The Desire of Ages*។

អ្នកស្រីអេឡែន ជីវ៉ៃត៍បានបកស្រាយអំពីរបៀបដែលព្រះយេស៊ូវបានយកព្រះអង្គទ្រង់មករួមជាមួយនឹងមនុស្សជាតិ។ «ព្រះបានក្លាយមកជាមនុស្សលោក។ នៅក្នុងនាមជាមនុស្សលោក ព្រះយេស៊ូវបានប៉ះពាល់ចិត្តមនុស្សលោកជាច្រើននាក់។ នៅក្នុងនាមជាព្រះ ព្រះយេស៊ូវបានរៀបចំផ្លូវមួយ ដើម្បីឱ្យយើងបានចូលទៅឯបល្ល័ង្ករបស់ព្រះ។ ព្រះយេស៊ូវគឺជាកូនមនុស្ស ដែលបានបង្ហាញគំរូដល់យើង អំពីរបៀបដែលយើងគួរតែគោរពតាមព្រះ។ រីឯនៅក្នុងនាមជាព្រះរាជបុត្រារបស់ព្រះវិញ ព្រះយេស៊ូវបានប្រទានអំណាចឱ្យយើងបានគោរពតាមព្រះ។ ព្រះយេស៊ូវអង្គទ្រង់ផ្ទាល់ក៏បានមានបន្ទូលជាមួយនឹងលោកម៉ូសេចេញពីគុម្ពបន្លាដែលឆេះភ្លើង។ ព្រះយេស៊ូវបានមានបន្ទូលទៅកាន់លោកម៉ូសេថា៖ 'អញជាព្រះដ៏ជាព្រះ' រួចទ្រង់មានព្រះបន្ទូលទៀតថា 'ឯងត្រូវឆ្លើយប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលដូច្នេះថា ព្រះដ៏ជាព្រះទ្រង់បានចាត់ឲ្យខ្ញុំមកឯអ្នករាល់គ្នា' (និក្ខមនំ ៣:១៤)។ ព្រះនាមរបស់ព្រះអម្ចាស់ក៏ប្រៀបដូចជាសេចក្តីសន្យាមួយយ៉ាងដូច្នេះដែរ។ នៅពេលដែលទ្រង់បើកបង្ហាញព្រះនាមរបស់ទ្រង់ដល់លោកម៉ូសេ នោះទ្រង់ក៏បានប្រទានសេចក្តីសន្យារបស់ទ្រង់នៅក្នុងការសង្គ្រោះសាសន៍អ៊ីស្រាអែលផងដែរ។ ដូច្នេះហើយ នៅពេលដែលព្រះយេស៊ូវបានយាងមកកាន់ផែនដីនេះនៅក្នុងរូបកាយជាមនុស្សលោក នោះទ្រង់ក៏បានប្រកាសថាទ្រង់គឺជាព្រះដ៏ជាព្រះនោះឯង។ ព្រះយេស៊ូវគឺជាក្មេងម្នាក់មកពីភូមិបេថ្លេហិម។ ទ្រង់គឺជាព្រះអង្គសង្គ្រោះដែលគ្មានអំនួតនៅក្នុងចិត្ត។ ព្រះយេស៊ូវក៏ជាព្រះដែលបានយាងចុះមកនៅក្នុងរូបកាយជាមនុស្សលោកផងដែរ [ខគម្ពីរធីម៉ូថេ ៣:១៦]។ ព្រះយេស៊ូវបានមានបន្ទូលមកកាន់យើងថា 'ខ្ញុំជាអ្នកគង្វាលល្អ ឯអ្នកគង្វាលល្អ ក៏ស៊ូតែប្តូរជីវិតជំនួសចៀម' (យ៉ូហាន ១០:១១)។ 'ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត' (យ៉ូហាន ១៤:៦)។ ដ្បិត 'គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង' (ម៉ាថាយ ២៨:១៨)។ 'ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប' (ម៉ាថាយ ២៨:១៨)។» ដកស្រង់ពី *The Desire of Ages*, pages 24, 25, adapted។

## សំណួរពិភាក្សា

១. តើព្រះបានបង្ហាញរាស្ត្ររបស់ទ្រង់ថា ទ្រង់នឹងរក្សាសេចក្តីសន្យារបស់ទ្រង់ បើទោះបីជាពួកគេគ្មានជំនឿទៅលើទ្រង់ក៏ដោយនោះដោយរបៀបណាដែរ? តើសព្វថ្ងៃនេះ គោលគំនិតនេះបានផ្តល់សេចក្តីសង្ឃឹមអ្វីដែរដល់យើង នៅពេលដែលយើងធ្វើឱ្យព្រះខកព្រះទ័យ ដោយយើងបានធ្លាក់ចូលទៅក្នុងអំពើបាបនោះ?

២. ព្រះយេស៊ូវគឺជាសម្តេចសង្ឃដ៏ពិសេសមួយអង្គ។ ទ្រង់គឺជាសម្តេចសង្ឃដែលមានលក្ខណៈស្រដៀងទៅនឹងលោកម៉ិលគីស្សាដែកនោះដែរ។ តើសេចក្តីពិតនៅត្រង់នេះបានផ្តល់សេចក្តីជំនឿឱ្យយើងបានជឿថា ព្រះយេស៊ូវអាចសង្គ្រោះរាស្ត្ររបស់ទ្រង់ចេញពីអំពើបាបនោះដោយរបៀបណាដែរ?

៣. កណ្ឌគម្ពីរម៉ាថាយ ម៉ាកុស លូកា និងយ៉ូហានបានបង្ហាញយើងអំពីរបៀបដែលព្រះយេស៊ូវបានបំពេញសេចក្តីសន្យាជាព្រះអង្គសង្គ្រោះនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងនោះ។ តើគោលគំនិតនេះបានជួយឱ្យយើងជឿទៅលើព្រះដោយរបៀបណា?

៤. ព្រះយេស៊ូវបានមានបន្ទូលថា «គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង» (ម៉ាថាយ ២៨:១៨)។ តើព្រះបន្ទូលទាំងនេះបានផ្តល់សេចក្តីសង្ឃឹមអ្វីដល់យើង?

# សេចក្តីស្មោះត្រង់ដែលតាមទៅដល់ទីឆ្ងាយ

នៅក្នុងអំឡុងពេល២ទៅ៣សប្តាហ៍ដំបូងដែលគាត់បានចូលនៅក្នុងកងយោធា លោកសេគូល ត្រូវបានគេបញ្ជូនឱ្យទៅធ្វើការនៅលើភ្នំដែលជាទឹកដីនៃប្រទេសយូហ្គោស្លាវីកាលពីមុន។ គាត់ត្រូវបាន មេបញ្ជាឱ្យប្រែធ្យូងនៅរសៀលថ្ងៃសុក្រចូលថ្ងៃសប្បាតហ៍។ មេបញ្ជាការម្នាក់បាននិយាយថា «ឯងត្រូវតែ រើធ្យូងចេញ១៥នាទីម្តង ហើយសម្រាក១០នាទីទៅ បន្ទាប់មក ចាំ១៥នាទី ចាំយកធ្យូងចេញម្តងទៀត»។ លោកសេគូលបានតបទៅវិញថា «មេ ខ្ញុំសូមធ្វើអត់ឈប់រយៈ២ម៉ោងកន្លះ រហូតទាល់តែព្រះអាទិត្យលិច បន្ទាប់មក ខ្ញុំសូមផ្អាកការងារនេះសិន»។ មេបញ្ជាការបាននិយាយថា «គ្មានអ្នកណាអាចប្រែធ្យូង២ម៉ោង ហើយនោះទេ»។ លោកសេគូលបានតបទៅវិញថា «តែខ្ញុំអាចទាន»។

ដោយសារតែគាត់ធ្លាប់តែរស់នៅក្នុងជីវិតលុតដំខ្លួន នៅពេលដែលគាត់ធំឡើងនៅក្នុងប្រទេស ម៉ុងតេណេហ្គ្រោ (Montenegro) គាត់អាចរើធ្យូងបានយ៉ាងលឿនតាមដែលគាត់អាចទៅបាន។ ទាហានដទៃ ទៀតបានប្រាប់ឱ្យគាត់ធ្វើមួយៗ។ ពួកគេបានសួរគាត់ថា «ហេតុអ្វីបានជាធ្វើការទាំងបង្ខំអ៊ីចឹង?»។ គាត់បាន តបទៅវិញថា «ខ្ញុំកំពុងតែព្យាយាមរើយកធ្យូងឱ្យបានច្រើនតាមដែលខ្ញុំអាចធ្វើទៅបាន ដើម្បីជួយកាត់បន្ថយ ការងារបងៗ កុំបារម្ភបង ខ្ញុំគ្រាន់តែចង់ធ្វើការងារនេះឱ្យបានច្រើនបំផុតតាមដែលខ្ញុំអាចធ្វើទៅបានប៉ុណ្ណោះ ប៉ុន្តែ ការងារដែលនៅសេសសល់ សូមឱ្យបងៗជួយបង្ហើយផង»។ ពាក្យសម្តីរបស់គាត់បានធ្វើឱ្យទាហាន ដទៃទៀតគោរពស្រឡាញ់គាត់។ ពួកគេបានមើលឃើញថា គាត់ពិតជាចង់ជួយពួកគេមែន។ ទាហានគ្រប់គ្នា មានការភ្ញាក់ផ្អើលជាខ្លាំង នៅពេលដែលបានឃើញលោកសេគូលបានសម្រេចការងាររើធ្យូងរបស់គាត់ ទៅតាមចំនួនដែលបានកំណត់ទុកចំពេលដែលថ្ងៃលិចល្មម។ ប៉ុន្តែ មេបញ្ជាការរបស់គាត់ហាក់ដូចជា មិនយល់អំពីគោលបំណងនៃការរក្សាថ្ងៃសប្បាតហ៍របស់គាត់នោះទាល់តែសោះ។ មានថ្ងៃសប្បាតហ៍មួយ មេបញ្ជាការរបស់គាត់បានបើកអានបញ្ជីភារកិច្ចដែលកងទាហានត្រូវធ្វើ បន្ទាប់មក គាត់បានប្រកាសថា «អ្នកទាំងអស់គ្នាត្រូវតែធ្វើការនៅថ្ងៃនេះ»។ លោកសេគូលបានក្រោកឡើងនិយាយថា «មេ ថ្ងៃនេះគឺជា ថ្ងៃសប្បាតហ៍របស់ខ្ញុំ ដូច្នេះហើយ ខ្ញុំមិនអាចធ្វើការនៅថ្ងៃនេះបានឡើយ»។ លោកសេគូលបានដឹងថា គាត់អាចនឹងប្រឈមនឹងការចាប់ដាក់ឃុំឃាំង បើសិនជាគាត់បាននិយាយថា «ថ្ងៃនេះ ខ្ញុំមិនធ្វើការងារ អ្វីឡើយ» ប៉ុន្តែ ផ្ទុយទៅវិញ គាត់បានជ្រើសរើសពាក្យសម្តីរបស់គាត់យ៉ាងប្រុងប្រយ័ត្ន ដោយនិយាយថា «ខ្ញុំមិនអាចធ្វើការនៅថ្ងៃនេះបានឡើយ»។ មេបញ្ជាការបានសួរគាត់ថា «តើពាក្យថា «មិនអាច» នេះ ឯង ចង់មានន័យយ៉ាងម៉េច?»។ លោកសេគូលបាននិយាយថា «ខ្ញុំគឺជាសមាជិកនៃព្រះវិហារសេវេនដេយ អាត់វេនទីស្ទ ដូច្នេះហើយ ខ្ញុំមិនអាចធ្វើការនៅថ្ងៃនេះបានឡើយ»។ មេបញ្ជាការបានឈរសម្លឹងមើល លោកសេគូលយ៉ាងម៉ឺងម៉ាត់។ គាត់បានសួរលោកសេគូលថា «សេគូល បើសិនជាឯងមិនអាចធ្វើការនៅ ថ្ងៃនេះ អ្នកណាជាអ្នកធ្វើការជំនួសឯងទៅ?»។ ទាហានទាំងអស់បានក្រោកឡើង រួចនិយាយព្រមៗគ្នាថា «បាទទាន ពួកយើងនឹងធ្វើការជំនួសសេគូល»។

នៅពេលនោះ លោកសេគូលបានដឹងថា ការជឿទុកចិត្តទៅលើព្រះមិនមែនត្រឹមតែជារឿង សំខាន់ប៉ុណ្ណោះទេ ប៉ុន្តែ ការជឿទុកចិត្តទៅលើមនុស្សក៏ជារឿងសំខាន់មួយដែរ។ ដ្បិតព្រះយេស៊ូវបាន មានបន្ទូលថា «‛ហើយឯងត្រូវស្រឡាញ់ ដល់ព្រះអម្ចាស់ ជាព្រះនៃឯង ឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីគំនិត ហើយអស់អំពីកម្លាំងនៃឯង’ នោះហើយជាបញ្ញត្តទី១ ឯបញ្ញត្តទី២ ក៏បែបដូចគ្នា គឺថា ‛ត្រូវ ឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង’ គ្មានបញ្ញត្តណាទៀតធំជាងបទទាំង២នេះទេ»។ លោកសេគូលបាន យល់ឃើញថា បើសិនជាគាត់ប្រព្រឹត្តចំពោះអ្នកដទៃដោយសេចក្តីយុត្តិធម៌ជាយ៉ាងណា នោះអ្នកដទៃនឹង តបស្នងមកគាត់វិញ ដោយសេចក្តីយុត្តិធម៌ជាយ៉ាងនោះដែរ។

# មេរៀនពីអតីតកាល



លួចថ្ងៃបរិសុទ្ធ - ថ្ងៃសៅរ៍ ទី២ ខែមីនា ឆ្នាំ២០២៤

**អំណានព្រះគម្ពីរសម្រាប់មេរៀនប្រចាំសប្តាហ៍នេះ៖ ទំនុកតម្កើង ៧៨; ទំនុកតម្កើង ១០៥; កាឡាទី ៣:២៩; ទំនុកតម្កើង ១០៦; ទំនុកតម្កើង ៨០; ជនគណនា ៦:២២-២៧; ទំនុកតម្កើង ១៣៥។**

**ខចងចាំ៖ «ជាសេចក្តីដែលពួកយើងធ្លាប់បានឮបានដឹងហើយ ដែលឪពុកយើងបានប្រាប់តៗមក យើងក៏មិនលាក់សេចក្តីទាំងនោះទុកចំពោះកូនចៅរបស់គាត់ដែរ» (ទំនុកតម្កើង ៧៨:៣-៤)។**

កណ្ឌគម្ពីរទំនុកតម្កើងមានពេញទៅដោយកំណាព្យសរសើរតម្កើងព្រះអម្ចាស់ និងបានសរសេរតម្កើងទង្វើដ៏អស្ចារ្យរបស់ទ្រង់។ កំណាព្យទាំងនេះបានថ្លែងអំពីប្រវត្តិសាស្ត្រនៃសាសន៍យូដា។ កំណាព្យទាំងនេះក៏បានបង្រៀនយើងអំពីកិច្ចការដែលព្រះបានធ្វើ ដើម្បីសង្គ្រោះរាស្ត្ររបស់ទ្រង់កាលពីមុនផងដែរ។ កំណាព្យទាំងនេះត្រូវបានគេហៅថា ជាកំណាព្យប្រវត្តិសាស្ត្រ។ កំណាព្យប្រវត្តិសាស្ត្រទាំងនេះបានប្រាប់ឱ្យរាស្ត្ររបស់ព្រះរៀនអំពីកំហុសដែលពួកអយ្យកោរបស់ពួកគេបានធ្វើកាលពីមុន។ កំណាព្យប្រវត្តិសាស្ត្រទាំងនេះក៏ជាចម្រៀងសរសើរតម្កើងព្រះផងដែរ ដោយចម្រៀងទាំងនេះបានថ្លែងអំពីការអស្ចារ្យដែលព្រះបានធ្វើសម្រាប់រាស្ត្ររបស់ទ្រង់ ដើម្បីឱ្យពួកគេបានមានជំនឿមុតមាំទៅលើទ្រង់។

កំណាព្យប្រវត្តិសាស្ត្របានជួយឱ្យយើងយល់ឃើញថា ជីវិតរបស់យើងគឺជាផ្នែកមួយនៅក្នុងប្រវត្តិសាស្ត្រនៃសាសន៍អ៊ីស្រាអែល។ ប្រវត្តិសាស្ត្រនៃសាសន៍អ៊ីស្រាអែលដែលមានចែងនៅក្នុងព្រះគម្ពីរក៏ជាប្រវត្តិសាស្ត្ររបស់យើងផងដែរ ដោយសារតែព្រះបានរើសយកយើងឱ្យធ្វើជាកូនចិញ្ចឹមរបស់ទ្រង់នៅក្នុងរាជវង្សរបស់ទ្រង់។ ហើយព្រះក៏បានរើសយកយើងឱ្យធ្វើជាផ្នែកមួយនៅក្នុងរាស្ត្រនៃសាសន៍អ៊ីស្រាអែល ដោយសារតែព្រះយេស៊ូវនោះដែរ (រ៉ូម ៨:១៥; រ៉ូម ៩:២៤-២៦; កាឡាទី ៤:៦, ៧)។ ដូច្នេះហើយ រឿងប្រវត្តិសាស្ត្រនៃជនជាតិអ៊ីស្រាអែលដែលមានចែងនៅក្នុងព្រះគម្ពីរ ក៏ជារឿងនៃប្រវត្តិសាស្ត្ររបស់យើងផងដែរ។ ហើយយើងក៏ត្រូវតែរៀនអំពីអតីតកាលរបស់ពួកគេផងដែរ។ ពីព្រោះនៅក្នុងនាមជារាស្ត្ររបស់ព្រះ យើងក៏មានចំណែកនៅក្នុងផែនការនៃសង្គ្រាមលោករវាងសេចក្តីល្អ និងសេចក្តីអាក្រក់ ដូចដែលសាសន៍អ៊ីស្រាអែលបានធ្វើនៅក្នុងសម័យគម្ពីរសញ្ញាចាស់ដូច្នោះដែរ។

# ព្រះតែងតែរក្សាសេចក្តីសន្យារបស់ទ្រង់ជានិច្ច

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក៧៨។ លោកអាសាបដែលជាកវីនៅក្នុងកំណាព្យនេះបាន ថ្លែងអំពីបទពិសោធន៍៣យ៉ាង ដែលបានកើតឡើងចំពោះសាសន៍អ៊ីស្រាអែលកាលពីមុន។ តើបទពិសោធន៍ ទាំង៣យ៉ាងនេះមានអ្វីខ្លះ? តើបទពិសោធន៍ទាំងនេះបានបង្រៀនមេរៀនអ្វីខ្លះដល់យើង?**

______________________________________________________________________

______________________________________________________________________

លោកអាសាបបានពិនិត្យមើលអតីតកាលរបស់សាសន៍អ៊ីស្រាអែល។ ប៉ុន្តែ ពួកគេបានបំពាន សេចក្តីសន្យាដែលពួកគេបានស្បថជាមួយនឹងព្រះ។ ពួកគេគួរតែរៀនពីកំហុសកាលពីមុនរបស់ពួកគេ។ ហើយពួកគេក៏គួរតែបង្រៀនកូនៗរបស់ពួកគេឱ្យជឿទុកចិត្តព្រះ ហើយមានជំនឿទៅលើសេចក្តីសន្យា របស់ទ្រង់ផងដែរ។ ម៉្យាងទៀត កំណាព្យរបស់លោកអាសាបក៏ប្រៀបដូចជារូបស័ព្ទមួយយ៉ាងដូច្នោះដែរ (ទំនុកតម្កើង ៧៨:២)។ ដ្បិតព្រះយេស៊ូវបានយករូបស័ព្ទនៅក្នុងជំពូកនេះមកប្រើ ដើម្បីបង្រៀនសិស្ស របស់ទ្រង់អំពីសេចក្តីពិតនៃព្រះគម្ពីរដ៏សំខាន់មួយ (ម៉ាថាយ ១៣:៣៤, ៣៥)។ ទន្ទឹមគ្នានេះ លោកអាសាប ក៏មានបំណងចង់ឱ្យកំណាព្យរបស់គាត់បង្រៀនមេរៀនសំខាន់ៗខាងឯវិញ្ញាណផងដែរ។

កំណាព្យនៅក្នុងជំពូកនេះបានថ្លែងអំពីគ្រាដែលសាសន៍អ៊ីស្រាអែលបានចាកចេញពីស្រុកអេស៊ីព្ទ នោះមក [ហៅកាត់ និក្ខមនំ] (ទំនុកតម្កើង ៧៨:៩-៥៤)។ និក្ខមនំគឺជាគ្រាមួយ នៅពេលដែលព្រះបាន សង្គ្រោះរាស្ត្ររបស់ទ្រង់ចេញពីសាសន៍អេស៊ីព្ទ។ កំណាព្យនៅក្នុងជំពូកនេះក៏បានថ្លែងអំពីគ្រាមួយ នៅពេល ដែលព្រះបានដឹកនាំរាស្ត្ររបស់ទ្រង់ទៅកាន់ទឹកដីសន្យា (ទំនុកតម្កើង ៧៨:៥៥-៦៤) ហើយនិងថ្លែងអំពី រជ្ជកាលរបស់ស្តេចដាវីឌផងដែរ (ទំនុកតម្កើង ៧៨:៦៥-៧២)។ ដ្បិតព្រះបានធ្វើការអស្ចារ្យជាច្រើនសម្រាប់ រាស្ត្ររបស់ទ្រង់នៅក្នុងសម័យកាលទាំងនេះផងដែរ។ ប៉ុន្តែ ពួកសាសន៍អ៊ីស្រាអែលបានបំពានសេចក្តីសន្យា ដែលពួកគេបានស្បថជាមួយនឹងព្រះវិញ។ ប្រវត្តិសាស្ត្រនៃសាសន៍អ៊ីស្រាអែលបានបង្ហាញយើងម្តងហើយ ម្តងទៀតថា ពួកគេបានបដិសេធមិនព្រមជឿទុកចិត្តទៅលើព្រះ ដោយបានជឿទុកចិត្តទៅលើព្រះក្លែងក្លាយ ហើយថ្វាយបង្គំព្រះទាំងនោះវិញ (ទំនុកតម្កើង ៧៨:៥៨)។

លោកអាសាបចង់ឱ្យរាស្ត្ររបស់ទ្រង់យល់អំពីមូលហេតុដែលនាំឱ្យពួកអយ្យកោរបស់ពួកគេ បានបដិសេធព្រះ។ ពួកអយ្យកោរបស់ពួកគេបានភ្លេចរឿងគ្រប់យ៉ាងដែលព្រះបានធ្វើសម្រាប់ពួកគេ។ ពួកគេមិនបានជឿទុកចិត្តទៅលើព្រះនោះឡើយ។ ផ្ទុយទៅវិញ ពួកគេបានល្បងលព្រះវិញ (ទំនុកតម្កើង ៧៨:១៨, ៤១, ៥៦)។ ពួកគេបានប្រឆាំងទាស់នឹងទ្រង់។ ពួកគេបានអាក់ខានមិនបានធ្វើតាមបញ្ញត្តសេចក្តី ស្រឡាញ់ និងក្បួនច្បាប់របស់ទ្រង់នោះឡើយ (ទំនុកតម្កើង ៧៨:១០, ៣៧, ៥៦)។ លោកអាសាបបាន បង្ហាញអំពីប្រវត្តិនៃសាសន៍អ៊ីស្រាអែលថា មូលហេតុដែលនាំឱ្យពួកគេបានបដិសេធព្រះ នោះគឺដោយសារ តែពួកគេបានខកខានមិនបានជឿទុកចិត្តទៅលើព្រះអម្ចាស់ (ទំនុកតម្កើង ៧៨:៧, ៨)។

នៅពេលដែលយើងអានបទគម្ពីរទំនុកតម្កើង ជំពូក៧៨ នោះយើងអាចនឹងខកចិត្តជាមួយនឹង អ្នកដទៃបាន ដោយយើងអាចសួរខ្លួនយើងថា ហេតុអ្វីបានជាពួកគេរឹងរូសយ៉ាងនេះ? តើពួកគេមិនបាន រៀនពីកំហុសរបស់ពួកគេទេឬអី? មុនពេលដែលវិនិច្ឆ័យសាសន៍អ៊ីស្រាអែល យើងគួរតែគិតអំពីខ្លួនយើង ជាមុនសិន។ តើយើងតែងតែភ្លេចរឿងអស្ចារ្យដែលព្រះបានធ្វើសម្រាប់យើងនោះញឹកញាប់ប៉ុនណាដែរ។ យើងត្រូវតែជឿទុកចិត្តទៅលើព្រះ និងជឿទុកចិត្តទៅលើព្រះគុណរបស់ទ្រង់។ នៅពេលដែលសាសន៍ អ៊ីស្រាអែលបានធ្វើសង្គ្រាម ដោយប្រើកម្លាំងរបស់ពួកគេ ដោយគ្មានជំនួយពីព្រះ នោះពួកគេនឹងចាញ់ជា មិនខាន (ទំនុកតម្កើង ៧៨;៩, ៦២-៦៤)។ យើងត្រូវតែជឿទុកចិត្តទៅលើព្រះជាមុនសិន បើមិនដូច្នោះទេ នៅចុងបញ្ចប់ យើងនឹងបរាជ័យនៅក្នុងរឿងគ្រប់យ៉ាងដែលពួកគេបានធ្វើនោះវិញ។

**តើលោកអ្នកបានរៀនមេរៀនអ្វីខ្លះ ចេញពីកំហុសកាលពីមុនរបស់លោកអ្នកនោះ?**

# ការនឹកចាំអំពីប្រវត្តិរបស់យើង

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក១០៥។ តើបទគម្ពីរទំនុកតម្កើង ជំពូក១០៥ បានចែងអំពីសម័យកាលណាដែរនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សលោកនោះ? តើបទពិសោធន៍ទាំងនេះបានបង្រៀនមេរៀនយើងនូវមេរៀនអ្វីខ្លះ?**

---

បទគម្ពីរទំនុកតម្កើង ជំពូក១០៥ បានចែងអំពីសេចក្តីសន្យាដែលព្រះបានតាំងឡើងជាមួយនឹងរាស្ត្ររបស់ទ្រង់។ ដោយទ្រង់បានសន្យាថា ទ្រង់នឹងប្រទានទឹកដីសន្យាមួយកន្លែងដល់លោកអ័ប្រាហាំ និងកូនចៅរបស់គាត់។ ព្រះក៏បានតាំងសេចក្តីសន្យាដដែលនេះដល់លោកអ៊ីសាក និងលោកយ៉ាកុបផងដែរ។ បន្ទាប់មក ព្រះបានរក្សាសេចក្តីសន្យារបស់ទ្រង់ដល់លោកយ៉ូសែប លោកអើរ៉ុន និងលោកយ៉ូស្វេវិញ។ ដូច្នេះហើយ ព្រះបានប្រទានទឹកដីកាណានឱ្យរាស្ត្ររបស់ទ្រង់។ បទគម្ពីរទំនុកតម្កើង ជំពូក១០៥ បានផ្តល់ក្តីសង្ឃឹមដល់រាស្ត្ររបស់ព្រះនៅគ្រប់សម័យកាលទាំងអស់។ ដ្បិតការអស្ចារ្យដែលព្រះបានធ្វើកាលពីមុនបានជួយឱ្យយើងយល់ថា សេចក្តីស្រឡាញ់ដែលទ្រង់មានចំពោះយើងនោះ មិនដែលផ្លាស់ប្តូរម្តងណាឡើយ។ ដូច្នេះហើយ យើងអាចជឿទុកចិត្តទៅលើសេចក្តីស្រឡាញ់ដែលព្រះមានចំពោះយើងជារៀងរហូតតទៅបាន (ទំនុកតម្កើង១០៥:៥, ៧, ៨)។

បទគម្ពីរទំនុកតម្កើង ជំពូក១០៥ បានបង្ហាញពីការអស្ចារ្យទាំងអស់ដែលព្រះបានធ្វើកាលពីមុនដើម្បីជួយដល់រាស្ត្ររបស់ទ្រង់នោះ។ (យើងបានឃើញរួចមកហើយថា បទគម្ពីរទំនុកតម្កើង ជំពូក ៧៨ ក៏បានបង្ហាញអំពីរឿងដដែលនេះផងដែរ)។ ដ្បិតការអស្ចារ្យរបស់ព្រះបានជួយឱ្យយើងសរសើរតម្កើងព្រះ និងជឿទុកចិត្តទៅលើទ្រង់។ បទគម្ពីរទំនុកតម្កើង ជំពូក១០៥ ក៏មានលក្ខណៈខុសគ្នាពីបទគម្ពីរទំនុកតម្កើង ជំពូក៧៨ ផងដែរ ដោយសារតែជំពូក១០៥នេះ មិនបានចែងអំពីកំហុសរបស់មនុស្សលោកកាលពីមុននោះឡើយ។ នោះគឺដោយសារតែបទគម្ពីរទំនុកតម្កើង ជំពូក៧៨ ត្រូវបានសរសេរឡើងសម្រាប់ហេតុផលមួយផ្សេងពីនេះទៀត។ នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក១០៥ យើងបានរៀនអំពីប្រវត្តិនៃសាសន៍អ៊ីស្រា-អែលនៅក្នុងជំនាន់នៃពួកអយ្យកោដំបូងរបស់ពួកគេ ដែលមានលោកអ័ប្រាហាំ លោកអ៊ីសាក លោកយ៉ាកុប ហើយនិងចាស់ទុំដទៃទៀត។ បុរសទាំងនេះបានអត់ធ្មត់ នៅក្នុងអំឡុងពេលនៃគ្រាលំបាក។ ពួកគេបានគោរពតាមព្រះ។ ហើយព្រះក៏បានប្រទានរង្វាន់ដល់ការស្តាប់បង្គាប់របស់ពួកគេនោះដែរ។ ដូច្នេះហើយ បទគម្ពីរទំនុកតម្កើង ជំពូក១០៥ បានអញ្ជើញមនុស្សទាំងអស់ឱ្យធ្វើទៅតាមគំរូរបស់ពួកអយ្យកោដំបូងនៃសាសន៍អ៊ីស្រាអែល។ ដូច្នេះហើយ យើងត្រូវតែមានជំនឿ និងមានការជឿទុកចិត្តទៅលើព្រះ។ ហើយយើងក៏ត្រូវតែរង់ចាំឱ្យទ្រង់សង្គ្រោះយើងផងដែរ។ បទគម្ពីរទំនុកតម្កើង ជំពូក១០៥ ក៏ជាចម្រៀងសរសើរតម្កើងព្រះ (ទំនុកតម្កើង១០៥:១-៧) ដែលបានបង្រៀនសេចក្តីពិតនៃព្រះគម្ពីរដ៏សំខាន់មួយផងដែរ គឺថា៖ បើសិនជាយើងចង់សរសើរតម្កើង ព្រះឱ្យបានពេញលេញ នោះយើងត្រូវតែដឹងអំពីប្រវត្តិរបស់យើងជាមុនសិន។ នៅពេលដែលយើងបាន ដឹងអំពីប្រវត្តិរបស់យើង នោះសេចក្តីជំនឿរបស់យើងនឹងបានលូតលាស់ឡើង។ ហើយចំណេះដឹងកាលពីមុនរបស់យើងក៏បានផ្តល់ហេតុផលជាច្រើន ដើម្បីឱ្យយើងបានសរសើរតម្កើងព្រះផងដែរ។ នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក១០៥ កវីបានដាក់ឈ្មោះរាស្ត្ររបស់ព្រះដែលជាកូនចៅរបស់លោកអ័ប្រាហាំ និងជាកូនចៅរបស់លោកយ៉ាកុប (ទំនុកតម្កើង ១០៥:៦)។ ឈ្មោះទាំងនេះបានបង្ហាញយើងថា សាសន៍អ៊ីស្រាអែល (យ៉ាកុប) បានក្លាយមកជាមនុស្សម្នាក់ ដោយសារតែព្រះបានរក្សាសេចក្តីសន្យាដែលទ្រង់តាំងឡើងជាមួយនឹងលោកអ័ប្រាហាំ (លោកុប្បត្តិ ១៥:៣-៦)។ កវីនៅក្នុងជំពូកនេះក៏បានរំឭកពួកបណ្តាជនថា ផែនដីទាំងមូលបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះអម្ចាស់ដែលជាព្រះរបស់ពួកគេនោះដែរ (ទំនុកតម្កើង ៩៦:១; ទំនុកតម្កើង ៩៧:១)។ ព្រះដ៏មានគ្រប់ទាំងព្រះចេស្តាបានស្រឡាញ់មនុស្សលោកទាំងអស់ ដូចជាទ្រង់បានស្រឡាញ់ដល់សាសន៍អ៊ីស្រាអែលដែលជារាស្ត្ររបស់ទ្រង់នោះដែរ។ បទគម្ពីរទំនុកតម្កើង ជំពូក១០៥ គឺជាការអញ្ជើញឱ្យមនុស្សគ្រប់គ្នានៅគ្រប់សម័យកាលទាំងអស់បានជឿទុកចិត្តទៅលើព្រះអម្ចាស់។

**តើយើងដែលជាសេវនដេយអាត់វេនទីស្ទគឺកូនចៅរបស់លោកអ័ប្រាហាំដោយរបៀបណាដែរ? (សូមអានខគម្ពីរកាឡាទី ៣:២៩ សម្រាប់ចម្លើយ)។ តើយើងបានរៀនមេរៀនអ្វីខ្លះ ចេញពីប្រវត្តិនៃសាសន៍អ៊ីស្រាអែលនោះ?**

# ការលន់តួអំពើបាបរបស់យើង

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក១០៦។ តើកំណាព្យនេះបានថ្លែងអំពីរឿងអ្វីខ្លះ ដែលចេញពីអតីតកាលរបស់សាសន៍អ៊ីស្រាអែលនោះ? តើរឿងទាំងនេះបានបង្រៀនមេរៀនអ្វីខ្លះដល់យើង?**

បទគម្ពីរទំនុកតម្កើង ជំពូក១០៦ បានចែងអំពីបទពិសោធន៍សំខាន់ៗនៅក្នុងប្រវត្តិសាស្ត្រនៃសាសន៍អ៊ីស្រាអែល។ បទពិសោធន៍កាលពីអតីតកាលទាំងនេះរួមមានការដែលសាសន៍អ៊ីស្រាអែលបានចាកចេញពីស្រុក ការធ្វើដំណើរនៅក្នុងទីរហោស្ថាន ហើយនិងការរស់នៅនៅក្នុងទឹកដីសន្យា។ បទគម្ពីរទំនុកតម្កើង ជំពូក១០៦ ក៏បានចែងអំពីអំពើបាបដ៏អាក្រក់ ដែលពួកសាសន៍អ៊ីស្រាអែលបានធ្វើកាលពីមុនមកផងដែរ។ ដ្បិតព្រះបានដាក់ទោសរាស្ត្ររបស់ទ្រង់ ដោយសារអំពើបាបទាំងនេះឯង ដោយទ្រង់បានបណ្តោយឱ្យសាសន៍ដទៃនិរទេសក៏ពួកគេទៅស្រុកបាប៊ីឡូន។ ដូច្នេះហើយ យើងបានជឿថា បទគម្ពីរទំនុកតម្កើង ជំពូក១០៦ ត្រូវបានសរសេរឡើង នៅពេលដែលពួកសាសន៍អ៊ីស្រាអែលបានជាប់ជាឈ្លើយនៅក្នុងស្រុកបាប៊ីឡូន ឬអាចសរសេរបន្ទាប់ពីពួកគេបានមកដល់ស្រុកកំណើតរបស់ពួកគេវិញ។

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក១០៦ កវីបានប្រាប់រាស្ត្ររបស់ព្រះ អំពីអតីតកាលរបស់ពួកគេហើយនិងមេរៀនដែលពួកគេគួរតែរៀនចេញពីប្រវត្តិផ្ទាល់របស់ពួកគេនោះ។ បទគម្ពីរទំនុកតម្កើង ជំពូក ១០៦ បានមានចែងថា ព្រះបានរក្សាសេចក្តីសន្យារបស់ទ្រង់។ ដ្បិតទ្រង់បានសង្គ្រោះរាស្ត្ររបស់ទ្រង់កាលពីមុន ដោយសារសេចក្តីសន្យា និងព្រះគុណរបស់ទ្រង់ (ទំនុកតម្កើង ១០៦:៤៥)។ កវីបានសង្ឃឹមថា ព្រះនឹងបង្ហាញព្រះគុណជាថ្មីម្តងទៀតដល់រាស្ត្ររបស់ទ្រង់ណា ដែលបានលុនតួអំពើបាបរបស់ពួកគេ។ នៅពេលនោះ រាស្ត្ររបស់ព្រះកំពុងតែរស់នៅក្នុងទឹកដីនៃសាសន៍ដទៃ។ ដូច្នេះហើយ កវីបានទូលសូមឱ្យព្រះនាំរាស្ត្ររបស់ទ្រង់ត្រឡប់មកកាន់ប្រទេសរបស់ពួកគេជាថ្មីម្តងទៀត (ទំនុកតម្កើង ១០៦:៤៧)។ សេចក្តីអធិស្ឋានដែលកវីបានទូលសូមដោយក្តីជំនឿនោះ មានប្រភពចេញមកពីការដែលគាត់បានជឿទុកចិត្តទៅលើព្រះ។ កវីបានជឿទុកចិត្តថា ព្រះនឹងសង្គ្រោះរាស្ត្ររបស់ទ្រង់នៅក្នុងពេលនោះ ដោយសារតែកាលពីមុនទ្រង់ក៏បានសង្គ្រោះពួកគេផងដែរ (ទំនុកតម្កើង ១០៦:១-៣)។ កវីក៏បានជឿទុកចិត្តទៅលើសេចក្តីស្រឡាញ់ដែលព្រះមានចំពោះរាស្ត្ររបស់ទ្រង់ផងដែរ។ ពីព្រោះកវីបានដឹងថា ព្រះអម្ចាស់តែងតែរក្សាសេចក្តីសន្យារបស់ទ្រង់ជានិច្ច។

នៅពេលដែលពួកបណ្តាជនបានដឹងអំពីប្រវត្តិរបស់ពួកគេ នោះពួកគេក៏បានលន់តួអំពើបាបរបស់ពួកគេ។ ដ្បិតពួកគេបានដឹងថា ពួកគេក៏មិនល្អជាងពួកអយ្យកោកាលពីមុនរបស់ពួកគេនោះដែរ។ ពួកគេបានទទួលស្គាល់ថា ពួកគេក៏មិនល្អជាងពួកអយ្យកោរបស់ពួកគេប៉ុន្មានដែរ។ តើហេតុអ្វី? នោះគឺដោយសារតែពួកគេបានដឹងនូវអ្វីដែលបានកើតឡើងដល់ពួកអយ្យកោរបស់ពួកគេ នៅពេលពួកអយ្យកោរបស់ពួកគេបានធ្វើបាបនោះ ប៉ុន្តែ ទោះបើបានដឹងហើយ ក៏ពួកគេនៅតែធ្វើខុសតាមពួកអយ្យកោរបស់ពួកគេដដែល។ ប៉ុន្តែ ព្រះទ្រង់មានព្រះហឫទ័យអត់ធ្មត់ជាមួយនឹងរាស្ត្ររបស់ទ្រង់។ ដ្បិតទ្រង់បានសេចក្តីមេត្តាដល់ពួកគេ និងបានសង្គ្រោះពួកគេ។ យើងក៏បានដឹងនូវអ្វីដែលបានកើតឡើងកាលពីមុនផងដែរ។ ពីព្រោះយើងបានដឹងអំពីសេចក្តីស្រឡាញ់របស់ព្រះ និងព្រះគុណរបស់ទ្រង់ ដោយទ្រង់បានប្រទានព្រះយេស៊ូវដល់យើង ដើម្បីបង្ហាញយើងអំពីរឿងទាំងនេះ។ ដូច្នេះហើយ យើងគ្មានលេសណា ដើម្បីដោះសានូវការបដិសេធទ្រង់នោះឡើយ។ បទគម្ពីរទំនុកតម្កើង ជំពូក១០៦ គឺជាដំណឹងល្អមួយ ដែលថា នៅចុងបញ្ចប់សេចក្តីស្រឡាញ់របស់ព្រះតែងតែឈ្នះជានិច្ច (ទំនុកតម្កើង ១០៦:៨-១០, ៣០, ៤៣-៣៦)។ ពីព្រោះអំពើបាបរបស់យើង មិនអាចប្រៀបផ្ទឹមជាមួយនឹងអំណាចទ្រង់បានឡើយ។

**បទគម្ពីរទំនុកតម្កើង ១០៦:១៣ បានចែងថា៖ «តែមិនយូរប៉ុន្មាន ក៏ភ្លេចកិច្ចការរបស់ទ្រង់ទៅ ហើយមិនបានរង់ចាំស្តាប់សេចក្តីដំបូន្មានរបស់ទ្រង់ទេ»។ តើហេតុអ្វីបានជាយើងងាយនឹងភ្លេចរឿងដដែលនេះម្ល៉េះ?**

# រឿងប្រៀបប្រដូចអំពីចម្ការទំពាំងបាយជូររបស់ព្រះអម្ចាស់

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក៨០។ តើកំណាព្យនេះបានប្រៀបធៀបរាស្ត្ររបស់ព្រះទៅនឹងអ្វី? តើពួកបណ្ដាជនបានសូមអ្វីពីព្រះ?**

____________________________________________________

____________________________________________________

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៨០ កវីបានប្រៀបធៀបរាស្ត្ររបស់ព្រះទៅនឹងចម្ការទំពាំង-បាយជូរមួយកន្លែង។ ដ្បិតព្រះបានរើចម្ការទំពាំងបាយជូរជាមួយនឹងឫសទាំងអស់នៅក្នុងចម្ការនោះ។ បន្ទាប់មក ទ្រង់បានយកចម្ការនោះទៅកាន់ទឹកដីសន្យា ដែលជាកន្លែងថ្មីដែលទ្រង់បានដាំវាវិញ។ រូបស័ព្ទនៃចម្ការទំពាំងបាយជូរនេះបានបង្ហាញយើងពីការដែលព្រះបានយកព្រះទ័យទុកដាក់ចំពោះយើង (សូមអានខគម្ពីរលោកុប្បត្តិ ៤៩:១១, ១២, ២២; ចោទិយកថា ៧:៧-១១)។

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៨០ ព្រះបានខ្វាល់ជាមួយនឹងចម្ការទំពាំងបាយជូររបស់ទ្រង់ (ទំនុកតម្កើង ៨០:១២) ដោយពួកហោរារបស់ព្រះបានប្រកាសថា ព្រះនឹងបំផ្លាញចម្ការទំពាំងបាយជូររបស់ទ្រង់ ដោយសារតែផ្លែទំពាំងបាយជូរបានខូចអស់ (អេសាយ ៥:១-៧; យេរេមា ២:២១)។

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៨០ កវីបានយល់ឃើញថា ព្រះត្រូវតែជំនុំជម្រះរាស្ត្ររបស់ទ្រង់។ ទន្ទឹមគ្នានេះ កវីនៅក្នុងជំពូកនេះក៏មានចិត្តច្របូកច្របល់ផងដែរ។ ដ្បិតគាត់បានដឹងថា ព្រះមានពេញទៅដោយសេចក្ដីមេត្តា។ ដូច្នេះហើយ កវីពិបាកនឹងយល់អំពីមូលហេតុដែលនាំឱ្យព្រះបដិសេធមិនព្រមបង្ហាញសេចក្ដីមេត្តាដល់រាស្ត្ររបស់ទ្រង់នោះ។ កវីនៅក្នុងជំពូកនេះបានខ្លាចថា សេចក្ដីក្រោធរបស់ព្រះអាចនឹងឈ្នះសេចក្ដីមេត្តារបស់ទ្រង់។ បើសិនជារឿងបានកើតឡើងមែន នោះសាសន៍អ៊ីស្រាអែលនឹងត្រូវវិនាសជាមិនខាន (ទំនុកតម្កើង ៨០:១៦)។

**សូមអានអំពីព្រះពរនៅក្នុងខគម្ពីរជនគណនា ៦:២២-២៧។ តើកវីបានថ្លែងអំពីព្រះពរបែបនេះនៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៨០ នេះដោយរបៀបណាដែរ?**

____________________________________________________

បទគម្ពីរទំនុកតម្កើង ជំពូក៨០ បានជួយឱ្យយើងនឹកចាំអំពីសេចក្ដីសន្យាដែលលោកអើរ៉ុនបានស្បថថា ព្រះនឹងប្រទានព្រះពរដល់ពួកគេជានិច្ច (ជនគណនា ៦:២២-២៧)។ សេចក្ដីសន្យានេះបានបង្ហាញយើងថា កវីបានសង្ឃឹមថា សេចក្ដីមេត្តារបស់ព្រះនឹងជួយសង្គ្រោះរាស្ត្ររបស់ទ្រង់ឱ្យរួចផុតពីសេចក្ដីវេទនារបស់ពួកគេ ដោយគាត់បានមានប្រសាសន៍ថា៖ «ឱព្រះអង្គអើយ សូមបង្វិលយើងខ្ញុំមកវិញ សូមឲ្យព្រះភក្ត្រទ្រង់ភ្លឺមក នោះយើងខ្ញុំនឹងបានរួចហើយ» (ទំនុកតម្កើង ៨០:៣; សូមអានខគម្ពីរទំនុកតម្កើង ៨០:៧, ១៩ ផងដែរ)។

ពាក្យថា «បង្វិលយើងខ្ញុំមកវិញ» មានន័យថា ព្រះកំពុងតែត្រាស់ហៅរាស្ត្ររបស់ទ្រង់ណាដែលបានវង្វេងនោះឱ្យត្រឡប់មករកទ្រង់វិញ។ ពាក្យនេះក៏ត្រូវបានភ្ជាប់ជាមួយនឹងគោលគំនិតនៃការលន់តួបាបរបស់យើងផងដែរ។ ដ្បិតនៅពេលណាដែលយើងលន់តួបាបរបស់យើង នោះយើងនឹងឈប់ប្រព្រឹត្តអំពើបាបនោះ ហើយបែរមករកទ្រង់វិញ។ ព្រះអម្ចាស់បានពន្យល់លោកយេរេមាអំពីអ្វីដែលបានកើតឡើង នៅពេលដែលរាស្ត្ររបស់ទ្រង់ត្រឡប់មករកទ្រង់វិញ៖ «អញនឹងឲ្យគេមានចិត្តដែលស្គាល់អញថា ជាព្រះយេហូវ៉ា នោះគេនឹងបានជារាស្ត្ររបស់អញ ហើយអញនឹងធ្វើជាព្រះរបស់គេ ពីព្រោះគេនឹងវិលមកឯអញដោយអស់ពីចិត្ត» (យេរេមា ២៤:៧)។

**តើលោកអ្នកធ្លាប់មានបទពិសោធន៍ដែលបានធ្វើឱ្យចិត្តរបស់លោកអ្នកនៅកៀកនឹងព្រះ បន្ទាប់ពីលោកអ្នកបានបដិសេធអំពើបាបរបស់លោកអ្នកនោះដែរឬទេ? តើការនិយាយថា ទេ ទៅកាន់អំពើបាបបានធ្វើឱ្យចិត្តរបស់លោកអ្នកនៅកៀកនឹងព្រះដោយរបៀបណាដែរ?**

# ព្រះអម្ចាស់គឺជាអ្នកគ្រប់គ្រងប្រវត្តិសាស្ត្រទាំងមូល

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក១៣៥។ តើបទគម្ពីរទំនុកតម្កើង ជំពូក១៣៥ នេះបានថ្លែងអំពីរឿងអតីតកាលអ្វីខ្លះ? តើយើងអាចរៀនមេរៀនអ្វីខ្លះ ចេញពីរឿងទាំងនេះ?**

_______________________________________________________________________________

_______________________________________________________________________________

បទគម្ពីរទំនុកតម្កើង ជំពូក១៣៥ បានសូមឱ្យរាស្ត្ររបស់ព្រះសរសើរតម្កើងព្រះអម្ចាស់។ ដ្បិតព្រះអម្ចាស់ទ្រង់ល្អ ដែលយើងអាចមើលឃើញសេចក្ដីស្រឡាញ់របស់ទ្រង់នៅក្នុងរបស់គ្រប់យ៉ាងដែលទ្រង់បានបង្កើត (ទំនុកតម្កើង ១៣៥:៦, ៧)។ ប្រវត្តិសាស្ត្រនៃសាសន៍អ៊ីស្រាអ៊ែលកាលពីអតីតកាលក៏បានបង្ហាញយើងថា ព្រះទ្រង់ល្អផងដែរ។ ដ្បិតទ្រង់បានសង្គ្រោះរាស្ត្ររបស់ទ្រង់ឱ្យរួចផុតពីពួកសាសន៍អេស៊ីព្ទ (ទំនុកតម្កើង ១៣៥:៨, ៩)។ ហើយទ្រង់ក៏បានប្រទានទឹកដីសន្យាមួយកន្លែងដល់រាស្ត្ររបស់ទ្រង់ផងដែរ (ទំនុកតម្កើង ១៣៥:១០-១២)។

ព្រះអម្ចាស់បានបង្ហាញសេចក្ដីមេត្តារបស់ទ្រង់ នៅពេលដែលទ្រង់បានជ្រើសរើសរាស្ត្ររបស់ទ្រង់។ ពួកគេបានក្លាយមកជាទ្រព្យសម្បត្តិដ៏ពិសេសរបស់ព្រះ (ទំនុកតម្កើង ១៣៥:៤)។ ពួកគេបានមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងព្រះ (ចោទិយកថា ៧:៦-១១; ពេត្រុសទី១ ៩:១០)។ ព្រះបានជ្រើសរើសសាសន៍អ៊ីស្រាអ៊ែល ដោយសារតែទ្រង់ស្រឡាញ់ពួកគេ មិនមែនដោយសារតែពួកគេពិសេសនោះឡើយ។ ដូច្នេះហើយ សាសន៍អ៊ីស្រាអ៊ែលមិនអាចអួតថា ពួកគេប្រសើរជាងសាសន៍ដទៃនោះឡើយ។ បទគម្ពីរទំនុកតម្កើង ១៣៥:៦, ៧ បានបង្ហាញយើងថា ផែនការដែលព្រះបានរៀបចំ ដើម្បីសង្គ្រោះមនុស្សជាតិមិនបានចាប់ផ្ដើមជាមួយនឹងសាសន៍អ៊ីស្រាអ៊ែលនោះឡើយ។ ដ្បិតផែនការសង្គ្រោះរបស់ព្រះបានចាប់ផ្ដើមឡើង នៅពេលដែលទ្រង់បានបង្កើតផ្ទៃមេឃ និងផែនដីនេះ។ ដូច្នេះហើយ សាសន៍អ៊ីស្រាអ៊ែលមិនគួរមានអំនួតនៅក្នុងចិត្តរបស់គេ អំពីការដែលពួកគេបានធ្វើជារាស្ត្រពិសេសរបស់ទ្រង់នោះឡើយ។ ហើយសាសន៍អ៊ីស្រាអ៊ែលក៏មិនគួរធ្វើការជាមួយនឹងព្រះ ដោយធ្វើទៅតាមអ្វីដែលទ្រង់បានសូមឱ្យពួកគេធ្វើ ដើម្បីសង្គ្រោះអ្នកដទៃនោះដែរ។

បទគម្ពីរទំនុកតម្កើង ជំពូក១៣៥ ក៏បានចែងអំពីរបៀបដែលព្រះត្រូវជំនុំជម្រះរាស្ត្ររបស់ទ្រង់។ ទន្ទឹមគ្នានេះ ព្រះក៏នឹងបង្ហាញសេចក្ដីមេត្តាដល់រាស្ត្ររបស់ទ្រង់ផងដែរ (ទំនុកតម្កើង ១៣៥:១៤)។ នៅក្នុងនាមជាចៅក្រម ព្រះនឹងសង្គ្រោះអ្នកក្រីក្រ និងអ្នកខ្វះខាត (ទំនុកតម្កើង ៩:៤; ទំនុកតម្កើង ៧:៨; ទំនុក-តម្កើង ៥៤:១)។ ព្រះនឹងជួយដល់រាស្ត្ររបស់ទ្រង់ (ចោទិយកថា ៣២:៣៦)។ បទគម្ពីរទំនុកតម្កើង ជំពូក១៣៥ បានជួយឱ្យរាស្ត្ររបស់ព្រះជឿទុកចិត្តទៅលើព្រះអម្ចាស់ ហើយជឿទុកចិត្តទៅលើសេចក្ដីសន្យារបស់ទ្រង់។

កវីនៅក្នុងជំពូកនេះបានប្រៀបធៀបព្រះអម្ចាស់ទៅនឹងព្រះក្លែងក្លាយ។ ដ្បិតព្រះក្លែងក្លាយមិនដឹងអ្វីទេ។ ពួកគេក៏មិនមានអំណាចអ្វីដែរ។ ប៉ុន្តែ ព្រះអម្ចាស់គឺជាអ្នកគ្រប់គ្រងផែនដីនេះវិញ (ទំនុកតម្កើង ១៣៥:១៥-១៨)។ បទគម្ពីរទំនុកតម្កើង ជំពូក១៣៥ បានជួយឱ្យយើងយល់ថា យើងគួរតែសរសើរតម្កើងព្រះ ដោយសារតែទ្រង់គឺជាព្រះអាទិកររបស់យើង និងជាព្រះអង្គសង្គ្រោះរបស់យើង។ យើងបានមើលឃើញសេចក្ដីពិតអំពីព្រះអម្ចាស់នៅក្នុងបញ្ញត្តទី៤ (និក្ខមនំ ២០:៨-១១; ចោទិយកថា ៥:១២-១៥)។ គ្មានអ្នកណាម្នាក់មានអំណាចស្មើព្រះនោះឡើយ។ ពីព្រោះទ្រង់គឺជាម្ចាស់គ្រប់គ្រងទាំងផែនដី និងប្រវត្តិសាស្ត្រនៃមនុស្សលោកទាំងអស់។ ដូច្នេះហើយ រាស្ត្ររបស់ព្រះគួរតែជឿទុកចិត្តទៅលើទ្រង់ ដោយថ្វាយបង្គំទ្រង់ជានិច្ចវិញ។ ដ្បិតទ្រង់គឺជាព្រះអង្គដែលយើងគួរតែថ្វាយបង្គំ ដោយសារតែព្រះយេស៊ូវគឺជាព្រះអាទិករ និងជាព្រះអង្គសង្គ្រោះរបស់យើង។ បើសិនជាយើងបានថ្វាយបង្គំអ្នកណាម្នាក់ ឬរបស់អ្វីមួយ នោះយើងនឹងមានកំហុសដោយការក្រាបថ្វាយបង្គំព្រះក្លែងក្លាយ។

**តើហេតុអ្វីបានជាវាងាយស្រួលនៅក្នុងការថ្វាយបង្គំព្រះក្លែងក្លាយម្ល៉េះ? តើយើងអាចប្រាកដថាយើងនឹងមិនមានព្រះក្លែងក្លាយនៅក្នុងជីវិតរបស់យើងនេះដោយរបៀបណាដែរ?**

**ការសិក្សាបន្ថែម៖** សូមអានបទគម្ពីរកិច្ចការ ជំពូក៧ និងហេព្រើរ ជំពូក១១។ តើជំពូកទាំងនេះបានបង្រៀនយើងអំពីការដឹកនាំរបស់ព្រះចំពោះរាស្ត្ររបស់ទ្រង់នោះយ៉ាងដូចម្តេចដែរ?

«យើងគ្មានអ្វីដែលត្រូវខ្លាចអនាគតនោះឡើយ បើសិនជាយើងបាននឹកចាំពីរបៀបដែលព្រះអម្ចាស់បានដឹកនាំយើងកាលពីមុនមកនោះ។ យើងក៏ត្រូវតែនឹកចាំពីការបង្រៀនរបស់ទ្រង់តាមរយៈប្រវត្តិកាលពីមុនរបស់យើងផងដែរ»។ ដកស្រង់ពី Ellen G. White, *Life Sketches of Ellen G. White*, page 196, adapted។

រាស្ត្ររបស់ព្រះត្រូវតែស្គាល់ប្រវត្តិរបស់ពួកគេ។ បន្ទាប់មក ពួកគេនឹងធ្វើឱ្យកិច្ចការរបស់ព្រះដំណើរការទៅមុខ ដោយការបម្រើទ្រង់ ដោយគ្មានសេចក្តីភ័យខ្លាច។ អ្នកស្រីអេឡែន ជីវ៉ៃត៍បានប្រាប់អ្នកគ្រីស្ទានឱ្យអានបទគម្ពីរទំនុកតម្កើង ជំពូក១០៥ និងទំនុកតម្កើង ជំពូក១០៦ «យ៉ាងហោចណាស់ឱ្យបានមួយអាទិត្យម្តង»។ ដកស្រង់ពី *Testimonies to Ministers and Gospel Workers*, page 98, adapted។

ប្រវត្តិសាសន៍នៃរាស្ត្ររបស់ព្រះបានបង្ហាញយើងថា ព្រះនឹងបន្តរក្សាសេចក្តីសន្យាទាំងអស់ដែលទ្រង់បានតាំងឡើងនៅក្នុងព្រះគម្ពីរ។ ទ្រង់នឹងរក្សាសេចក្តីសន្យារបស់ទ្រង់ដែលថា ទ្រង់នឹងយកព្រះទ័យទុកដាក់ចំពោះយើងម្នាក់ៗ។ ទ្រង់នឹងរក្សាសេចក្តីសន្យារបស់ទ្រង់ដែលថា ទ្រង់នឹងយាងមកវិញម្តងទៀត។ ហើយបន្ទាប់មក ទ្រង់នឹងចាប់ផ្តើមនគរនៃសេចក្តីសុខសាន្តរបស់ទ្រង់។

### សំណួរពិភាក្សា

១. តើយើងបានទទួលព្រះពរអ្វីខ្លះ ចេញពីការនឹកចាំអំពីការអស្ចារ្យទាំងអស់ ដែលព្រះបានធ្វើសម្រាប់រាស្ត្ររបស់ទ្រង់កាលពីអតីតកាលនោះ? តើនឹងមានអ្វីកើតឡើង នៅពេលដែលយើងភ្លេចនូវការអស្ចារ្យដែលព្រះបានធ្វើសម្រាប់រាស្ត្ររបស់ទ្រង់កាលពីអតីតកាលនោះ? តើនឹងមានអ្វីកើតឡើង នៅពេលដែលយើងមិនបានប្រុងប្រយ័ត្នចំពោះមេរៀនអំពីអតីកាលនោះ? ព្រះបានជ្រើសរើសក្រុមជំនុំសេវេនដេយអាត់វេនទីស្ទឱ្យធ្វើនូវកិច្ចការ ដែលទ្រង់បានសូមឱ្យសាសន៍អ៊ីស្រាអែលធ្វើនៅក្នុងសម័យព្រះគម្ពីរ។ តើការនឹកចាំអំពីប្រវត្តិកាលពីមុនរបស់យើង បានជួយឱ្យយើងធ្វើកិច្ចការ ដែលព្រះបានប្រទានឱ្យយើងធ្វើនៅក្នុងនាមជាសមាជិកនៃក្រុមជំនុំនោះដោយរបៀបណា?

២. តើកណ្ឌគម្ពីរទំនុកតម្កើងបានជួយឱ្យយើងមើលឃើញអំពីការដែលព្រះបានយកព្រះទ័យទុកដាក់ចំពោះយើងយ៉ាងពិសេសនៅក្នុងជីវិតរបស់យើងនេះដោយរបៀបណា? ព្រះគឺជាអ្នកគ្រប់គ្រងប្រវត្តិសាស្ត្រ និងជាអ្នកគ្រប់គ្រងផែនដីនេះ។ ជាការពិតណាស់ យើងមិនអាចយល់ពីមូលហេតុដែលនាំឱ្យរឿងគ្រប់យ៉ាងបានកើតឡើងទៅតាមរបៀបដែលវាបានកើតឡើងនោះឡើយ។ ប៉ុន្តែ តើការយល់ដឹងអំពីសេចក្តីស្រឡាញ់ដែលព្រះមានចំពោះយើង បានជួយឱ្យយើងមានចិត្តអត់ធ្មត់នៅក្នុងអំឡុងនៃគ្រាលំបាក ដោយជឿទៅលើព្រះនោះដោយរបៀបណាដែរ?

៣. តើយើងអាចធ្វើឱ្យការសិក្សាទៅលើប្រវត្តិសាស្ត្រនៃសាសន៍អ៊ីស្រាអែលបានក្លាយមកជាផ្នែកដ៏សំខាន់មួយនៅក្នុងការថ្វាយបង្គំផ្ទាល់ខ្លួនរបស់យើង និងនៅក្នុងការថ្វាយបង្គំជាមួយនឹងពួកជំនុំនោះដោយរបៀបណា? តើនៅក្នុងនាមជាសេវេនដេយអាត់វេនទីស្ទ ហេតុអ្វីបានជាវាសំខាន់ម្ល៉េះ ដែលយើងត្រូវតែប្រាប់កូនចៅរបស់យើង អំពីប្រវត្តិនៃព្រះវិហាររបស់យើង ហើយនិងប្រាប់ពួកគេនូវអ្វីដែលបានកើតឡើងនៅក្នុងអតីតកាលរបស់យើងនោះ។

# បើមិនធ្វើការទេ ក៏គ្មានអាហារញ៉ាំដែរ

បន្ទាប់ពីលោកសេគួលបានបដិសេធមិនព្រមធ្វើនៅថ្ងៃសប្បាតហ៍អស់រយៈពេលជាច្រើនសប្តាហ៍ក្រោយមក មេបញ្ជាការរបស់គាត់បានចាប់ផ្តើមដឹងថា គាត់មិនអាចបង្ខំទាហានវ័យក្មេងម្នាក់នេះឱ្យបំពានមនសិការរបស់គាត់បានឡើយ។ ដូច្នេះហើយ មេបញ្ជាការបាននិយាយទៅកាន់សេគួលថា «បើអ៊ីចឹងមែនមានន័យថា ឯងមិនអាចធ្វើការនៅក្នុងជួរទាហាន នៅថ្ងៃសប្បាតហ៍ទេ មែនទេ?»។ លោកសេគួលបាននិយាយ «បានមេ ខ្ញុំមិនអាចធ្វើការនៅថ្ងៃសប្បាតហ៍បានឡើយ»។ មេបញ្ជាការបានសួរទៀតថា «ចាប់ពីល្ងាចថ្ងៃសុក្ររហូតដល់ល្ងាចថ្ងៃសៅរ៍ មែនទេ?»។ លោកសេគួលបានឆ្លើយថា «បាទមេ ខ្ញុំមិនអាចធ្វើការនៅថ្ងៃសប្បាតហ៍បានឡើយ»។ មេបញ្ជាការបាននិយាយទៀតថា «បើអ៊ីចឹង នៅក្នុងអំឡុងពេល២៤ម៉ោងដែលឯងមិនបានធ្វើការ ឯងមិនអាចញ៉ាំបាយបានឡើយ»។ លោកសេគួលបានតបទៅវិញថា «មេ ហេតុអ្វីបានជាខ្ញុំញ៉ាំបាយមិនបាន?»។ មេបញ្ជាការបានឆ្លើយឡើងថា «បើសិនជាឯងមិនធ្វើការទេ ឯងក៏មិនចាំបាច់ញ៉ាំបាយដែរ ដូច្នេះហើយ បើឯងចង់ញ៉ាំបាយទាល់តែឯងធ្វើការ ម៉្យាងទៀត អាហារខ្លះក៏ត្រូវបានចម្អិននៅក្នុងថ្ងៃសប្បាតហ៍ផងដែរ អ៊ីចឹងហើយ ឯងមិនគួរញ៉ាំអាហារទាំងនោះឡើយ»។

លោកសេគួលបានទទួលទានតែនំប៉័ង នឹងផឹកទឹកតែតែប៉ុណ្ណោះ ពីព្រោះអាហារដទៃទៀតមានខ្លាញ់ច្រើន។ ប៉ុន្តែ គាត់បានយល់ព្រមមិនទទួលទាននំប៉័ង និងផឹកទឹកតែដែលបានរៀបចំនៅថ្ងៃសប្បាតហ៍នោះឡើយ។ នៅក្នុងនាមជាអ្នកសេវេនដេយអាត់វេនទីស្ទថ្មីថ្មោង លោកសេគួលមិនដឹងប្រាកដថា គាត់អាចទទួលទាន ឬមិនអាចទទួលទានអាហារដែលបានរៀបចំឡើងនៅថ្ងៃសប្បាតហ៍នោះទេ។ ប៉ុន្តែគាត់ត្រូវតែផ្តល់ចម្លើយដ៏ល្អមួយ ដើម្បីឱ្យមេបញ្ជាការរបស់គាត់អាចទទួលយកបាន។ បើសិនជាគាត់បានបដិសេធមិនព្រមធ្វើការ នោះមេបញ្ជាការរបស់គាត់អាចនឹងគិតថា គាត់គឺមិនស្មោះត្រង់ជាមួយនឹងព្រះរបស់គាត់នោះឡើយ។

ជាច្រើនខែបានកន្លងផុតទៅ ចុងភៅបានចាប់ផ្តើមធ្វើម្ហូបគ្មានខ្លាញ់មួយសប្តាហ៍មួយពេល។ អាហារនេះគឺជាអាហារតែមួយគត់ ដែលលោកសេគួលអាចញ៉ាំបាន។ ប៉ុន្តែ អាហារនេះត្រូវបានចម្អិន និងរៀបចំចែកជូននៅក្នុងថ្ងៃសប្បាតហ៍។ ដូច្នេះហើយ លោកសេគួលបានអធិស្ឋានថា «ឱព្រះអម្ចាស់អើយ តើទ្រង់អាចប្តូរថ្ងៃសប្បាតហ៍ទៅថ្ងៃអាទិត្យវិញបានដែរឬទេ? តើទ្រង់អាចធ្វើតាមសំណូមពររបស់ទូលបង្គំបានដែរឬទេ?»។

គាត់បានអធិស្ឋានអស់រយៈពេល១ខែ ក្រោយមក ការចម្អិនអាហារគ្មានខ្លាញ់ត្រូវបានប្តូរទៅថ្ងៃអាទិត្យវិញ។ ដ្បិតថ្ងៃអាទិត្យគឺជាថ្ងៃសម្រាកកាយរបស់ពួកទាហាន ដែលពួកទាហានអាចលេងបាល់ទាត់បាល់បោះ និងកីឡាផ្សេងៗទៀត។ ដ្បិតការបដិសេធមិនលេងបាល់ទាត់នេះគឺជារឿងងាយស្រួលជាងការបដិសេធមិនធ្វើការនៅថ្ងៃសប្បាតហ៍ទៅទៀត។ ដូច្នេះហើយ គាត់បានអធិស្ឋានម្តងទៀត ដោយទូលថា៖ «ឱព្រះអម្ចាស់អើយ សូមអភ័យទោស មានសំណូមពរមួយទៀតចង់សូមដល់ទ្រង់? តើទ្រង់អាចប្តូរថ្ងៃឈប់សម្រាកពីថ្ងៃអាទិត្យទៅថ្ងៃសប្បាតហ៍វិញ ដើម្បីឱ្យទូលបង្គំហាត់នៅក្នុងពន្យល់អ្នកដទៃជារៀងរាល់ថ្ងៃថា ហេតុអ្វីបានជាទូលបង្គំមិនអាចធ្វើការនៅថ្ងៃជារៀងរាល់ថ្ងៃសប្បាតហ៍នោះ?»។

មិនយូរប៉ុន្មាន នៅពេលដែលអាហារគ្មានខ្លាញ់ត្រូវបានប្តូរទៅថ្ងៃអាទិត្យវិញ មួយសប្តាហ៍ក្រោយមក ថ្ងៃសម្រាកកាយក៏ត្រូវបានប្តូរទៅថ្ងៃសប្បាតហ៍ផងដែរ។

# មានសេចក្តីរំភើបដោយបាននៅជាប់ជាមួយនឹងព្រះអម្ចាស់



ល្ងាចថ្ងៃបរិសុទ្ធ - ថ្ងៃសៅរ៍ ទី៩ ខែមីនា ឆ្នាំ២០២៤

**អំណានព្រះគម្ពីរសម្រាប់មេរៀនប្រចាំសប្តាហ៍នេះ៖** ទំនុកតម្កើង ៨៤:៥-១២; ទំនុកតម្កើង ១២២:១-៥; ទំនុកតម្កើង ៨៧:១, ២; ទំនុកតម្កើង ៤៦:១-៧; ទំនុកតម្កើង ១២៥:១, ២។

**ខចងចាំ៖ «ព្រលឹងទូលបង្គំរឭក អើ ក៏កន្លែងចិត្ត ដោយនឹកដល់ទីលាននៃព្រះយេហូវ៉ា ចិត្ត និងសាច់ឈាមទូលបង្គំស្រែកអាល័យដល់ព្រះដ៏មានព្រះជន្មរស់នៅ»** (ទំនុកតម្កើង ៨៤:២)។

កណ្ឌគម្ពីរទំនុកតម្កើងមានពេញទៅដោយចម្រៀងអំពីភ្នំស៊ីយ៉ូន។ ភ្នំស៊ីយ៉ូនគឺជាឈ្មោះនៃភ្នំដ៏បរិសុទ្ធរបស់ព្រះ។ ចម្រៀងអំពីភ្នំស៊ីយ៉ូនបានប្រាប់យើងអំពីសិរីលំអរបស់ភ្នំនេះ។ ចម្រៀងទាំងនេះក៏បានប្រាប់យើងថា ព្រះអម្ចាស់បានគង់នៅលើភ្នំដ៏បរិសុទ្ធរបស់ទ្រង់ផងដែរ។ ដ្បិតផែនដីទាំងមូលគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទ្រង់។ ហើយចម្រៀងទាំងនេះក៏តែងតែសរសើរដំណាក់ថ្វាយបង្គំរបស់ព្រះអម្ចាស់ផងដែរ។ កូនរបស់លោកកូរេបានសរសេរកំណាព្យទាក់ទងទៅនឹងភ្នំស៊ីយ៉ូនទាំងនេះជាច្រើនជំពូក។ កូនរបស់លោកកូរេគឺជាតន្ត្រីករម្នាក់នៅក្នុងរោងឧបោសថរបស់ព្រះ (របាក្សត្រទី១ ៦:៣១-៣៨)។ កូនរបស់លោកកូរេត្រូវបានគេដាក់ឱ្យមើលការខុសត្រូវនៅត្រង់ខ្លោងទ្វារនៃរោងឧបោសថ (របាក្សត្រទី១ ៩:១៩)។

តើហេតុអ្វីបានជាភ្នំស៊ីយ៉ូនបានផ្តល់សេចក្តីសង្ឃឹម និងសេចក្តីអំណរដល់យើងយ៉ាងដូច្នេះ? នោះគឺដោយសារតែភ្នំស៊ីយ៉ូនគឺជារូបស័ព្ទមួយតំណាងឱ្យការដែលព្រះបានសណ្ឋិតនៅជាប់ជាមួយនឹងរាស្ត្ររបស់ទ្រង់។ ហើយសាសន៍អ៊ីស្រាអែលគឺជារាស្ត្រជ្រើសតាំងរបស់ព្រះ (ចោទិយកថា ៧:៦)។ ដូច្នេះហើយ ភ្នំស៊ីយ៉ូនក៏ជាភ្នំដែលព្រះជ្រើសតាំងផងដែរ (ទំនុកតម្កើង ៧៨:៦៨; ទំនុកតម្កើង ៨៧:២)។ ដ្បិតព្រះអម្ចាស់ទ្រង់បានគង់នៅលើភ្នំស៊ីយ៉ូននៅក្នុងនាមជាស្តេច (ទំនុកតម្កើង ៩៩:១, ២)។ ហើយរោងឧបោសថរបស់ទ្រង់ក៏ស្ថិតនៅលើភ្នំនោះផងដែរ (ទំនុកតម្កើង ៨៧:១, ២)។ ដ្បិតភ្នំស៊ីយ៉ូនគឺជាកន្លែងមួយ ដែលព្រះបានប្រទានពរដល់រាស្ត្ររបស់ទ្រង់។ ម៉្យាងទៀត ភ្នំស៊ីយ៉ូនក៏ជាកន្លែងសម្រាប់ឱ្យរាស្ត្ររបស់ព្រះជ្រកកោនផងដែរ។ ជាញឹកញាប់ ភ្នំស៊ីយ៉ូនត្រូវបានគេហៅថា ជារោងឧបោសថរបស់ព្រះ និងជាភ្នំនៃទីក្រុងយេរូសាឡិម ដោយសារតែរោងឧបោសថរបស់ព្រះគឺជាស្នូលនៅក្នុងកិច្ចការសង្គ្រោះមនុស្សលោករបស់ទ្រង់នៅលើផែនដីនេះ។

ព្រះបានប្រទានពរពីភ្នំស៊ីយ៉ូនដល់ផែនដីទាំងមូល។ ដ្បិតផែនដីទាំងមូលគឺជាកម្មសិទ្ធរបស់ព្រះអម្ចាស់។ ដូច្នេះហើយ ភ្នំស៊ីយ៉ូនក៏ជាកន្លែងដែលមនុស្សលោកនៅគ្រប់ទីកន្លែងនៅលើផែនដីនេះបានទទួលសេចក្តីអំណរផងដែរ (ទំនុកតម្កើង ៤៨:២)។

# មួយថ្ងៃដែលលោកអ្នកបានរស់នៅក្នុងរោងឧបោសថគឺប្រសើរជាង ១០០០ថ្ងៃដែលលោកអ្នកបានរស់នៅកន្លែងផ្សេងទៅទៀត

**តើហេតុអ្វីបានជាកវីចង់រស់នៅក្នុងរោងឧបោសថរបស់ព្រះយ៉ាងដូច្នេះ? សូមអានខគម្ពីរទំនុកតម្កើង ៨៤:១-៤ សម្រាប់ចម្លើយ។**

_______________________________________________________________

កវីនៅក្នុងជំពូកនេះមានបំណងចង់រស់នៅក្នុងរោងឧបោសថរបស់ព្រះអស់មួយជីវិតរបស់គាត់។ បន្ទាប់មក គាត់តែងតែចង់នៅជាប់ជាមួយនឹងព្រះជានិច្ច (ទំនុកតម្កើង ៨៤:១, ២)។ ដ្បិតព្រះទ្រង់គង់នៅក្នុងរោងឧបោសថរបស់ទ្រង់ (ទំនុកតម្កើង ៨៤:២)។ ហេតុដូច្នេះហើយ បានជារោងឧបោសថរបស់ព្រះគឺជាកន្លែងមួយដ៏ពិសេស។ ដ្បិតនៅក្នុងដំណាក់របស់ទ្រង់ រាស្ត្ររបស់ព្រះអាច «មើលសេចក្តីលំអនៃព្រះយេហូវ៉ា» (ទំនុកតម្កើង ២៧:៤; សូមអានខគម្ពីរទំនុកតម្កើង ៦៣:២ ផងដែរ)។ បន្ទាប់មក រាស្ត្ររបស់ព្រះ «នឹងបានស្កប់ចិត្តដោយសេចក្តីលំអនៃដំណាក់ទ្រង់ គឺជាព្រះវិហារដ៏បរិសុទ្ធរបស់ទ្រង់» (ទំនុកតម្កើង ៦៥:៤)។ នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៨៤ ពួកបណ្តាជនមានសេចក្តីរីករាយ ដោយសារតែពួកគេមានទំនាក់ទំនងជាមួយនឹងព្រះ។ ពួកគេបានសរសើរតម្កើងទ្រង់ (ទំនុកតម្កើង ៨៤:៤) ដោយសារតែព្រះបានប្រទានអំណាចរបស់ទ្រង់ដល់ពួកគេ (ទំនុកតម្កើង ៨៤:៥)។ ដូច្នេះហើយ បានជាពួកបណ្តាជនបានជឿទុកចិត្តទៅលើព្រះ (ទំនុកតម្កើង ៨៤:១២)។ ពួកគេបានចូលមកក្នុងរោងឧបោសថរបស់ព្រះ ដើម្បីថ្វាយបង្គំព្រះ និងប្រកបគ្នាជាមួយនឹងមនុស្សដទៃទៀត។ ដោយសារតែព្រះបានគង់នៅក្នុងរោងឧបោសថរបស់ទ្រង់នេះហើយ បានជារាស្ត្ររបស់ទ្រង់យល់អំពីនគររបស់ទ្រង់ប្រសើរជាងសាសន៍ដទៃ។ ហើយពួកគេក៏បានទទួលនូវការយល់អំពីជីវិតដ៏អស់កល្បផងដែរ។

**តើមានអ្នកណាទៀត ដែលអាចចូលមកទទួលព្រះពរនៅក្នុងរោងឧបោសថរបស់ព្រះបាននោះ? សូមអានខគម្ពីរទំនុកតម្កើង ៨៤:៥-១២ សម្រាប់ចម្លើយ។**

_______________________________________________________________

ព្រះបានបង្ហូរព្រះវិញ្ញាណរបស់ទ្រង់មកពីរោងឧបោសថរបស់ទ្រង់។ ជាដំបូង ទ្រង់បានប្រទានព្រះពររបស់ទ្រង់ដល់អស់អ្នកណាដែលបានបម្រើទ្រង់នៅក្នុងរោងឧបោសថរបស់ទ្រង់ (ទំនុកតម្កើង ៨៤:៤)។ បន្ទាប់មក ព្រះបានបង្ហូរព្រះពររបស់ទ្រង់មកលើសាសន៍យូដា ដែលបានធ្វើដំណើរមកកាន់រោងឧបោសថ របស់ទ្រង់ (ទំនុកតម្កើង ៨៤:៥-១០)។ នៅទីបំផុត ព្រះពររបស់ព្រះបានធ្លាក់មកលើមនុស្សគ្រប់គ្នានៅគ្រប់ទីកន្លែងនៅលើផែនដីនេះ។ មនុស្សដែលបានធ្វើដំណើរមកកាន់ភ្នំស៊ីយ៉ូនបានរំពឹងថា ពួកគេនឹងបានជួបព្រះនៅក្នុងរោងឧបោសថរបស់ទ្រង់។ ហើយសេចក្តីសង្ឃឹមនេះក៏បានធ្វើឱ្យជំនឿរបស់ពួកគេរឹងមាំផងដែរ (ទំនុកតម្កើង ៨៤:៧)។

នៅពេលដែលរាស្ត្ររបស់ព្រះបានចាកចេញពីរោងឧបោសថរបស់ទ្រង់ ពួកគេក៏បាននាំបទពិសោធន៍នៃការជួបជាមួយនឹងព្រះដែលដក់ជាប់នៅក្នុងចិត្តរបស់ពួកគេត្រឡប់ទៅលំនៅឋានរបស់ពួកគេវិញដែរ។ បទពិសោធន៍នេះបានជួយឱ្យពួកគេរស់នៅក្នុងជីវិតមួយដ៏បរិសុទ្ធ (ទំនុកតម្កើង ៨៤:១១) ពួកបណ្តាជនបានព្យាយាមរស់នៅក្នុងជីវិតដ៏បរិសុទ្ធគ្រប់ពេលវេលា ដើម្បីឱ្យពួកគេមានអភ័យឯកសិទ្ធនៅក្នុងការចូលមកក្នុងរោងឧបោសថរបស់ព្រះជាថ្មីម្តងទៀត (ទំនុកតម្កើង ១៥:១, ២)។ នៅក្នុងខគម្ពីរទំនុកតម្កើង ៨៤:១១ យើងក៏បានឃើញថា កវីបានប្រៀបធៀបព្រះអម្ចាស់ទៅនឹង «ព្រះអាទិត្យ» ផងដែរ។ ដ្បិតព្រះពររបស់ព្រះអម្ចាស់បានចែងចាំងមកពីរោងឧបោសថរបស់ទ្រង់រហូតដល់ចុងផែនដីទាំងមូល ដូចជាកាំរស្មីនៃព្រះអាទិត្យដូច្នេះដែរ (ទំនុកតម្កើង ៨៤:១១)។ ដោយទ្រង់បាន «ផ្តល់» ព្រះគុណរបស់ទ្រង់មកលើមនុស្សគ្រប់គ្នាដែលបានរស់នៅជាមួយនឹងទ្រង់ដោយក្តីជំនឿ។

**សូមអានខគម្ពីរវិវរណៈ ២១:៣។ ខនេះបានប្រាប់យើងថា ព្រះនឹងតាំងលំនៅឋានរបស់ទ្រង់នៅលើផែនដីថ្មីជាមួយនឹងយើង។ តើខនេះបានផ្តល់សេចក្តីសង្ឃឹមអ្វីដល់លោកអ្នក?**

# ការអធិស្ឋានសូមឱ្យក្រុងយេរូសាឡិមទទួលបានសេចក្ដីសុខសាន្ត

**តើរាស្ត្ររបស់ព្រះបានគិតយ៉ាងណាដែរ នៅពេលដែលពួកគេបានមកដល់ទីក្រុងយេរូសាឡិមនោះ? តើពួកគេសង្ឃឹមថា ពួកគេបានឃើញអ្វីនៅក្នុងទីក្រុងយេរូសាឡិមនោះ? សូមអានខគម្ពីរទំនុកតម្កើង ១២២:១-៥ សម្រាប់ចម្លើយ។**

____________________________________________________________

____________________________________________________________

នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក១២២ រាស្ត្ររបស់ព្រះមានសេចក្ដីអំណរ និងរំភើបចិត្ត នៅពេលដែលពួកគេបានមកដល់ទីក្រុងយេរូសាឡិមនោះ។ ដំណើរឆ្ពោះមកកាន់ទីក្រុងយេរូសាឡិមគឺជាដំណើរប្រកបដោយភាពរីករាយ។ ដ្បិតរាស្ត្ររបស់ព្រះបានធ្វើដំណើរទៅអបអរសេចក្ដីស្រឡាញ់ដែលព្រះមានចំពោះពួកគេ១ឆ្នាំ៣ដង នៅក្នុងឆ្នាំនោះ និងនៅក្នុងប្រវត្តិកាលពីមុនរបស់ពួកគេ (ចោទិយកថា ១៦:១៦)។ ទីក្រុងយេរូសាឡិមគឺជាស្នូលនៃជីវិតរបស់សាសន៍អ៊ីស្រាអែល។ ម៉្យាងទៀត «ទម្លាប់នៃសាសន៍អ៊ីស្រាអែល» ក៏មាននៅក្នុងទីក្រុងនេះដែរ (ទំនុកតម្កើង ១២២:៤)។ ទីក្រុងយេរូសាឡិមគឺជាកន្លែងមួយ «សម្រាប់ការវិនិច្ឆ័យ» (ទំនុកតម្កើង ១២២:៥)។ នៅពេលដែលពួកបណ្ដាជនធ្វើដំណើរមកកាន់ទីក្រុងយេរូសាឡិម ពួកគេអាចនឹងចូលទៅសុំជំនួយពីកន្លែងកាត់ក្ដីបាន។

**តើរាស្ត្ររបស់ព្រះបានអធិស្ឋាននៅក្នុងខគម្ពីរទំនុកតម្កើង ១២២:៦-៩ យ៉ាងដូចម្ដេចដែរ?**

____________________________________________________________

____________________________________________________________

ពួកបណ្ដាជនបានអធិស្ឋានសូមឱ្យព្រះប្រទានសេចក្ដីសុខសាន្តដល់ទីក្រុងយេរូសាឡិម។ សេចក្ដីអធិស្ឋាននេះបានធ្វើឱ្យរាស្ត្រទាំងអស់របស់ព្រះបានមានចិត្ត និងគំនិតតែមួយវិញ។ នៅពេលដែលចិត្ត និងគំនិតរបស់ពួកគេបានរួបរួមគ្នាហើយ នោះពួកគេនឹងទទួលបានសេចក្ដីសុខសាន្ត (ទំនុកតម្កើង ១២២:៨)។ ដ្បិតសេចក្ដីសុខសាន្តនឹងមាននៅក្នុងទីក្រុងយេរូសាឡិម លុះត្រាតែរាស្ត្ររបស់ព្រះមានសេចក្ដីសុខសាន្តជាមួយនឹងទ្រង់ ហើយនិងមានសេចក្ដីសុខសាន្តជាមួយនឹងគ្នាទៅវិញទៅមកជាមុនសិន។ នៅពេលដែលទីក្រុងយេរូសាឡិមមានសេចក្ដីសុខសាន្តហើយ នោះពួកគេនឹងបានរីករាយជាមួយនឹងភាពជោគជ័យនៅក្នុងជីវិតរបស់ពួកគេជាមិនខាន (ទំនុកតម្កើង ១៤៧:១២-១៤)។

បទគម្ពីរទំនុកតម្កើង ជំពូក១២២ បានបង្រៀនយើងថា យើងត្រូវតែអធិស្ឋានឱ្យព្រះវិហារ និងក្រុមជំនុំរបស់យើង។ ដ្បិតនៅពេលណាដែលយើងទទួលបានសេចក្ដីសុខសាន្ត និងសេចក្ដីសញ្ញាជាមួយនឹងគ្នាហើយ នោះយើងនឹងបានរឹងមាំឡើងនៅក្នុងនាមជាក្រុមជំនុំមួយរូប។ បន្ទាប់មក យើងនឹងអាចប្រកាសដំណឹងល្អអំពីសេចក្ដីសុខសាន្តរបស់ព្រះ និងព្រះគុណរបស់ទ្រង់ទៅកាន់មនុស្សគ្រប់គ្នានៅលើផែនដីនេះផងដែរ (យ៉ូហាន ១៣:៣៤, ៣៥)។

នៅពេលដែលយើងអធិស្ឋានសូមឱ្យក្រុមជំនុំរបស់យើងទទួលបានសេចក្ដីសុខសាន្ត នោះយើងនឹងអាចថែរក្សាសេចក្ដីសង្ឃឹមរបស់យើងនៅក្នុងសេចក្ដីសុខសាន្តនៃនគរសម័យចុងក្រោយរបស់ទ្រង់បាន។ ដ្បិតនគរនេះធំជាងទីក្រុងយេរូសាឡិម។ ហើយនគរនេះក៏បានរាប់បញ្ចូលទាំងផែនដីទាំងមូលផងដែរ (អេសាយ ៥២:៧; អេសាយ ៦៦:១២, ១៣; បទគម្ពីរវិវរណៈ ជំពូក២១-២២)។

**តើឥឡូវនេះ យើងអាចធ្វើអ្វីខ្លះ ដើម្បីឱ្យយើងទទួលបានសេចក្ដីសុខសាន្តនៅក្នុងសភាពជាមនុស្សលោកនោះ?**

## ទីក្រុងស៊ីយ៉ូនដែលជាលំនៅឋានសម្រាប់មនុស្សលោកទាំងអស់

**តើអ្វីទៅដែលធ្វើឱ្យភ្នំស៊ីយ៉ូនមានលក្ខណៈពិសេសយ៉ាងដូច្នេះ? តើហេតុអ្វីបានជាភ្នំនេះជាកន្លែងដ៏អស្ចារ្យយ៉ាងដូច្នេះ? សូមអានខគម្ពីរទំនុកតម្កើង ៨១:១, ២ សម្រាប់ចម្លើយ។**

___

បទគម្ពីរទំនុកតម្កើង ជំពូក៨៧ គឺជាចម្រៀងសរសើរតម្កើង ដែលបានអបអរទីក្រុងស៊ីយ៉ូន។ ដ្បិតព្រះទ្រង់ស្រឡាញ់ទីក្រុងស៊ីយ៉ូន។ ទ្រង់បានយកទីក្រុងស៊ីយ៉ូននេះមកធ្វើជាទីក្រុងពិសិដ្ឋរបស់ទ្រង់។ ហើយរោងឧបោសថរបស់ទ្រង់ក៏ស្ថិតនៅលើភ្នំស៊ីយ៉ូននេះដែរ (ទំនុកតម្កើង ២:៦; ទំនុកតម្កើង ១៥:១)។ ដ្បិតព្រះអម្ចាស់ដែលគង់នៅក្នុងទីក្រុងស៊ីយ៉ូនគឺជាស្តេចដ៏មានអំណាចបំផុត។ ដូច្នេះហើយ មនុស្សគ្រប់គ្នានៅលើផែនដីនេះនឹងលើកតម្កើងទ្រង់នៅទីនោះ (ទំនុកតម្កើង ៩៩:២; អេសាយ ២:២; មីកា ៤:១)។ កវីនៅក្នុងជំពូកនេះបានថ្លែងថា «ព្រះយេហូវ៉ាបានតាំងទីលំនៅរបស់ទ្រង់នៅលើភ្នំបរិសុទ្ធ» (ទំនុកតម្កើង ៨៧:១)។ ព្រះអម្ចាស់បានប្រទានព្រះពរដែលជាជីវិតអស់កល្បរបស់ទ្រង់ដល់រាស្ត្ររបស់ទ្រង់មកពីកន្លែងនេះ (ទំនុកតម្កើង ១៣៣:៣)។ ព្រះទ្រង់ស្រឡាញ់ទីក្រុងស៊ីយ៉ូនលើសជាងកន្លែងដទៃទៀតនៅក្នុងទឹកដីអ៊ីស្រាអែលទាំងមូល (ទំនុកតម្កើង ៨៧:២) រួមទាំងទីក្រុងបេតអែល និងទីក្រុងស៊ីឡូផងដែរ។ កាលពីសម័យមុន ទីក្រុងបេតអែល និងទីក្រុងស៊ីឡូគឺជាកន្លែងពិសេសមួយ សម្រាប់ឱ្យរាស្ត្ររបស់ទ្រង់បានជួបជុំគ្នា។ បទគម្ពីរទំនុកតម្កើង ជំពូក៨៧ បានបង្ហាញយើងថា យើងត្រូវតែថ្វាយបង្គំព្រះនៅត្រង់កន្លែងដែលទ្រង់បានរៀបចំឱ្យយើង។ ហើយយើងក៏ត្រូវតែថ្វាយបង្គំទ្រង់ទៅតាមរបៀបដែលទ្រង់បានបង្គាប់ឱ្យយើងថ្វាយបង្គំទ្រង់។

**តើមានរឿងអស្ចារ្យអ្វីខ្លះ ដែលបានពិពណ៌នាអំពីទីក្រុងស៊ីយ៉ូននេះ? សូមអានខគម្ពីរទំនុកតម្កើង ៨៧:៣-៧ សម្រាប់ចម្លើយ។**

___

សិរីល្អនៃទីក្រុងស៊ីយ៉ូនបានធ្វើឱ្យមនុស្សដទៃទៀតចង់ដឹងអំពីព្រះបន្ថែមទៀត។ ដូច្នេះហើយ នគររបស់ព្រះបានរួមបញ្ចូលទាំងផែនដីទាំងមូលផងដែរ។ តើលោកអ្នកបានឃើញថា ព្រះបានបដិសេធមនុស្សដែលមិនមែនជាសាសន៍អ៊ីស្រាអែលដែរឬទេ? ទេ មិនមែនដូច្នោះឡើយ។ ផ្ទុយទៅវិញ ព្រះនឹងទទួលយកមនុស្សទាំងឡាយណាដែលចូលមករកទ្រង់ ដោយទទួលយកទ្រង់ទុកជាព្រះអង្គសង្គ្រោះរបស់ពួកគេ។

នៅក្នុងសម័យព្រះគម្ពីរ មនុស្សគ្រប់រូបគឺជាកម្មសិទ្ធនៃប្រទេសដែលពួកគេបានកើតមក (នេហេមា ៧:៥; លូកា ២:១-៣)។ នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៨៧ កវីបានប្រាប់យើងចំនួន៣ដងថា ក្រៅពីសាសន៍អ៊ីស្រាអែលទៅ ក៏មានមនុស្សពីសាសន៍ដទៃបាន «កើត» នៅក្នុងទីក្រុងស៊ីយ៉ូននេះដែរ។ តើគោលគំនិតនេះមានន័យណា? គោលគំនិតនេះមានន័យថា ព្រះបានយកមនុស្សទាំងនេះមកធ្វើជាពលរដ្ឋនៃទីក្រុងស៊ីយ៉ូនរបស់ទ្រង់។ ហើយទ្រង់ក៏បានប្រទានព្រះពរ ដូចជាទ្រង់បានប្រទានឱ្យកូនៗរបស់ទ្រង់ ដែលបានកើតនៅក្នុងទីក្រុងស៊ីយ៉ូននេះដែរ (ទំនុកតម្កើង ៨៧:៤-៦)។

បទគម្ពីរទំនុកតម្កើង ជំពូក៨៧ បានពិពណ៌នាអំពីគ្រាមួយ នៅពេលដែលសាសន៍យូដា និងសាសន៍ដទៃបានក្លាយមកជាសមាជិកនៃនគរមួយដ៏បរិសុទ្ធ (សូមអានខគម្ពីររ៉ូម ៣:២២; រ៉ូម ១០:១២; កាឡាទី ៣:២៨, ២៩)។ សូមប្រៀបធៀបរូបស័ព្ទនៃទីក្រុងស៊ីយ៉ូននៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៨៧ ទៅនឹងការបើកសំដែងអំពីនគររបស់ព្រះដែលទ្រង់បានបើកសំដែងឱ្យលោកដានីយ៉ែលបានឃើញ (សូមអានខគម្ពីររ៉ូម ៣:២២; រ៉ូម ១០:១២; កាឡាទី ៣:២៨, ២៩)។ នៅក្នុងសុបិនរបស់លោកដានីយ៉ែល នគររបស់ព្រះបានក្លាយទៅជាភ្នំដ៏ធំមួយនៅពាសពេញផែនដី។

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក៨៧ បានបង្ហាញយើងថា ព្រះបានត្រៀមព្រះអង្គទ្រង់ជាស្រេច ដើម្បីចិញ្ចឹមមនុស្សទាំងអស់នៅក្នុងទីក្រុងស៊ីយ៉ូន។ តើគោលគំនិតនេះបានជួយឱ្យយើងយល់កាន់តែប្រសើរឡើង អំពីមហាបញ្ញាដែលព្រះយេស៊ូវបានបង្គាប់ឱ្យយើងចែកចាយដំណឹងល្អទៅកាន់មនុស្សគ្រប់គ្នានៅលើផែនដីនេះដោយរបៀបណា?**

# សុវត្ថិភាព និងសេចក្ដីសុខសាន្តនៅក្នុងទីក្រុងស៊ីយ៉ូន

**សូមអានខគម្ពីរទំនុកតម្កើង ៤៦:១-៧។ តើខទាំងនេះបានប្រាប់យើងអំពីផែនដីនេះយ៉ាងដូចម្ដេចដែរ?**

បទគម្ពីរទំនុកតម្កើង ជំពូក៤៦ បានបង្ហាញយើងថា ផែនដីនេះកំពុងតែជួបនឹងបញ្ហា។ បាតុភូតធម្មជាតិកំពុងតែកើតឡើងនៅគ្រប់ទីកន្លែង (ទំនុកតម្កើង ៤៦:២, ៣)។ ព្រះគម្ពីរបានយកពាក្យ «ទឹកសមុទ្របញ្ចេញសូរគឹកកង» មកធ្វើជារូបស័ព្ទមួយ ដើម្បីបង្ហាញយើងអំពីចំនួននៃមនុស្សអាក្រក់ ឬបញ្ហាដែលពួកគេបានបង្កឡើងនៅលើផែនដីនេះ (ទំនុកតម្កើង ៩៣:៣, ៤; ទំនុកតម្កើង ១២៤:២-៥)។ នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៤៦ យើងបានអានអំពីគ្រាមួយ នៅពេលដែល «អស់ទាំងសាសន៍ដទៃបានជ្រួលជ្រើម ហើយនគរទាំងប៉ុន្មានពពាក់ពពូនឡើង» (ខ៦) នោះ។

មនុស្សដែលមានសេចក្ដីភ័យខ្លាច និងមនុស្សដែលបានធ្លាក់ទៅក្នុងអំពើបាបមិនបានស្គាល់ព្រះឡើយ។ ពីព្រោះព្រះមិនបានគង់នៅជាមួយនឹងពួកគេនោះឡើយ។ តើយើងបានដឹងរឿងនេះដោយរបៀបណា? យើងអាចដឹងបានដោយសារតែយើងឃើញពួកគេគ្មានសេចក្ដីសុខសាន្ត។ នៅពេលដែលព្រះគង់ជាមួយនឹងរាស្ត្ររបស់ទ្រង់ នោះពួកគេនឹងទទួលបានសេចក្ដីសុខសាន្ត (ទំនុកតម្កើង ៤៦:៤, ៥)។ មនុស្សនៅលើផែនដីនេះអាចនឹងបដិសេធព្រះមែនពិត ប៉ុន្តែ ព្រះមិនបានបោះបង់ពួកគេ ឬបដិសេធពួកគេនោះឡើយ។ ជាការពិតណាស់ អ្វីគ្រប់យ៉ាងអាចនឹងអាប់អួរនៅលើផែនដីនេះ។ ប៉ុន្តែ យើងក៏អាចមានសង្ឃឹមនៅក្នុងជីវិតនេះដែរ ពីព្រោះព្រះតែងតែគង់នៅជាមួយនឹងយើងជានិច្ច។

ព្រះអម្ចាស់គឺជាទីជ្រកកោនរបស់យើង។ ទ្រង់បានប្រទានសេចក្ដីសុខសាន្តដល់ទីក្រុងស៊ីយ៉ូន ដោយធ្វើឱ្យទីក្រុងនេះក្លាយមកជាកន្លែងមួយដ៏មានសុវត្ថិភាព។ មនុស្សនៅលើផែនដីនេះអាចនឹងទាស់ទែងគ្នាបង្កើតទៅជាសង្គ្រាម។ ប៉ុន្តែ រាស្ត្ររបស់ព្រះគឺជាទីជ្រកកោនរបស់ពួកគេវិញ។ ដ្បិតសេចក្ដីសុខសាន្តគឺជាអំណោយទានដែលមានតែព្រះមួយគត់ដែលប្រទានឱ្យយើងបាន។ ទ្រង់បានប្រទានអំណោយទាននេះដល់កូនៗរបស់ទ្រង់ដែលបានជឿទុកចិត្តទៅលើទ្រង់។ នៅពេលដែលយើងជឿទុកចិត្តទៅលើព្រះឱ្យអស់ពីចិត្តរបស់យើង នោះទ្រង់នឹងអាចប្រទានសេចក្ដីសុខសាន្តដល់យើងបាន ហើយទ្រង់ក៏អាចធ្វើឱ្យយើងមានអារម្មណ៍កក់ក្ដៅនៅក្នុងសង្គ្រាម ឬនៅក្នុងព្យុះគំហុកនោះដែរ (ម៉ាថាយ ៨:២៣-២៧)។ អ្នកខ្លះអាចនឹងសួរលោកអ្នកថា៖ តើសង្គ្រាម និងខ្យល់ព្យុះនឹងបញ្ចប់នៅពេលណា? តើព្រះនឹងបណ្ដោយឱ្យមនុស្សលោកបន្តធ្វើបាបគ្នាទៅវិញទៅមករហូតដល់មនុស្សត្រូវវិនាសដែរឬទេ? សូមឱ្យលោកអ្នកបានសូមឱ្យបុគ្គលទាំងនេះអានបទគម្ពីរទំនុកតម្កើង ជំពូក៤៦។ ក៏សូមឱ្យយើងទាំងអស់គ្នាបានអាននៅពេលឥឡូវនេះផងដែរ។

**តើព្រះបានឈ្វេងយល់អំពីសេចក្ដីអាក្រក់ ហើយនិងការឈឺចាប់នៅលើផែនដីនេះយ៉ាងដូចម្ដេចដែរ? សូមអានខគម្ពីរទំនុកតម្កើង ៤៦:៦-១១ សម្រាប់ចម្លើយ។**

ព្រះទ្រង់មិនសព្វព្រះទ័យជាមួយនឹងសេចក្ដីអាក្រក់នៅលើផែនដីនេះឡើយ។ ទ្រង់បានខ្ញាល់ចំពោះសេចក្ដីអាក្រក់យ៉ាងខ្លាំង រហូតដល់សេចក្ដីខ្ញាល់របស់ទ្រង់អាចធ្វើឱ្យផែនដីនេះរលាយបាន (ទំនុក-តម្កើង ៤៦:៦)។ សេចក្ដីខ្ញាល់របស់ព្រះមិនបានបំផ្លាញផែនដីនេះឡើយ តែសេចក្ដីខ្ញាល់របស់ទ្រង់បានធ្វើឱ្យទ្រង់បង្កើតផែនដីថ្មីវិញ។ ដ្បិតទ្រង់នឹងបញ្ឈប់សង្គ្រាម ដោយបំផ្លាញអាវុធដែលមនុស្សបានបង្កើតមកដើម្បីធ្វើបាបអ្នកដទៃ (ទំនុកតម្កើង ៤៦:៩)។ ដោយព្រះយេស៊ូវបានសន្យាថា ទ្រង់នឹងធ្វើរឿងទាំងនេះនៅពេលដែលទ្រង់យាងមកជាលើកទី២។ ហើយសេចក្ដីសន្យារបស់ទ្រង់នេះក៏បានផ្ដល់សេចក្ដីសង្ឃឹមដល់អ្នកគ្រីស្ទានផងដែរ។

**តើយើងបានរៀនឱ្យខ្លួនយើងមានសេចក្ដីសង្ឃឹមនៅក្នុងជីវិតនេះ នៅពេលរឿងអាក្រក់កំពុងតែកើតឡើងនៅជុំវិញយើងនោះដោយរបៀបណា? តើយើងអាចរៀនជឿទុកចិត្តទៅលើព្រះ នៅក្នុងអំឡុងនៃគ្រាលំបាកនោះដោយរបៀបណាដែរ?**

# ភ្នំដែលមិនអាចរើបាន

**តើនៅក្នុងខគម្ពីរទំនុកតម្កើង ១២៥:១ កវីបានប្រៀបធៀបរាស្ត្ររបស់ព្រះទៅនឹងរូបស័ព្ទអ្វីដែរ?**

---

នៅក្នុងខគម្ពីរទំនុកតម្កើង ១២៥:១ កវីបានប្រៀបធៀបរាស្ត្ររបស់ព្រះទៅនឹងភ្នំស៊ីយ៉ូន។ ភ្នំស៊ីយ៉ូនគឺជារូបស័ព្ទមួយតំណាងឱ្យកម្លាំង។ ហើយភ្នំស៊ីយ៉ូនក៏ជាភ្នំមួយដែលមិនអាចរើបានផងដែរ។ នៅពេលដែលរាស្ត្ររបស់ព្រះបានជឿទុកចិត្តទៅលើទ្រង់ នោះពួកគេមានកម្លាំងដូចជាភ្នំស៊ីយ៉ូនអ៊ីចឹង។ ម៉្យាងទៀត កវីនៅក្នុងជំពូកនេះក៏បានដឹងថា ព្រះនឹងការពាររាស្ត្ររបស់ទ្រង់ផងដែរ (ទំនុកតម្កើង ៥:១២; ទំនុកតម្កើង ៣២:៧,១០)។ ភ្នំស៊ីយ៉ូនបានផ្តល់ទំនុកចិត្តដល់រាស្ត្ររបស់ព្រះ។ ដ្បិតសេចក្តីអាក្រក់មានជុំវិញពួកគេពាសពេញផែនដី។ ប៉ុន្តែ រាស្ត្ររបស់ព្រះបានបន្តសេចក្តីសង្ឃឹមតទៅមុខទៀត។

**តើអ្វីទៅដែលធ្វើឱ្យរាស្ត្ររបស់ព្រះមានអារម្មណ៍បាក់ទឹកចិត្តនោះ? សូមអានខគម្ពីរទំនុកតម្កើង ១២៥:៣-៥ សម្រាប់ចម្លើយ។ តើយើងអាចរៀនមេរៀនអ្វីខ្លះ ចេញពីបទពិសោធន៍របស់ពួកគេនោះ?**

---

---

កូនៗរបស់ព្រះអាចនឹងមានអារម្មណ៍បាក់ទឹកចិត្ត នៅពេលដែលពួកគេបានឃើញមនុស្សអាក្រក់សប្បាយរីករាយជាមួយនឹងភាពជោគជ័យរបស់ពួកគេនៅក្នុងជីវិតនេះ។ ភាពជោគជ័យរបស់ពួកគេក៏អាចនឹងធ្វើឱ្យរាស្ត្ររបស់ព្រះមួយចំនួនបែរចេញពីទ្រង់ទៅសប្បាយជាមួយនឹងជីវិតខាងឯអំពើបាបផងដែរ (ទំនុកតម្កើង ៧៣:២-១៣; ទំនុកតម្កើង ៩៤:៣)។ ព្រះបានបង្កើតយើងមកឱ្យមានសេរីភាពជ្រើសរើសធ្វើរឿងអាក្រក់ (ទំនុកតម្កើង ១២៥:៣, ៥)។ ប៉ុន្តែ ព្រះមិនការពារអ្នកណាដែលបានបែរចេញពីទ្រង់ទៅសប្បាយរីករាយជាមួយនឹងជីវិតខាងឯអំពើបាបនោះឡើយ។ ពីព្រោះនៅចុងបញ្ចប់ ព្រះនឹងជំនុំជម្រះដល់អ្នកដែលបានធ្វើបាបទាស់នឹងទ្រង់ ដោយបានបដិសេធមិនព្រមទទួលយកសេចក្តីលើកលែងទោសរបស់ទ្រង់នោះ។

បទគម្ពីរទំនុកតម្កើង ជំពូក១២៥ គឺជាការអញ្ជើញឱ្យមនុស្សទាំងអស់របស់ព្រះបានប្រកាន់ខ្ជាប់សេចក្តីជំនឿដែលពួកគេមានចំពោះព្រះ។ ពោលគឺពួកគេត្រូវតែប្រកាន់ជំហរដូចជាភ្នំស៊ីយ៉ូននេះដែរ។ ដ្បិតយើងតែងតែមិនបានយល់អំពីមូលហេតុដែលនាំឱ្យរឿងអាក្រក់បានកើតឡើងនោះទេ។ ប៉ុន្តែ យើងនៅតែអាចជឿទុកចិត្តទៅលើព្រះបានជានិច្ច។

«នៅក្នុងព្រះគម្ពីរ មានប្រធានបទខុសៗគ្នាជាច្រើន សម្រាប់ឱ្យយើងបកស្រាយ ឬឱ្យយើងយល់បានទាំងស្រុងនោះ។ ប្រធានបទទាំងនេះក៏បានរាប់បញ្ចូលទាំងការចាប់ផ្តើមនៃអំពើបាប កំណើតរបស់ព្រះ ការកើតជាថ្មីម្តងទៀតរបស់យើង ហើយនិងការរស់ពីស្លាប់ឡើងវិញរបស់មនុស្សលោក។ ក៏មានប្រធានបទជាច្រើនទៀតដែលអមជាមួយនឹងប្រធានបទទាំងនេះដែលនៅជាអាថ៌កំបាំង។ អមជាមួយនឹងប្រធានបទទាំងនេះ ក៏មានប្រធានបទផ្សេងៗទៀតដែលនៅបង្កប់អាថ៌កំបាំងផងដែរ។ ប៉ុន្តែ យើងមិនត្រូវសង្ស័យព្រះគម្ពីរ ដោយសារតែយើងមិនអាចយល់អាថ៌កំបាំងរបស់ព្រះនោះឡើយ។ ដ្បិតនៅជុំវិញយើងនៅលើផែនដីនេះ មានអាថ៌កំបាំងជាច្រើនដែលមិនអាចយល់បាន . . . . តើយើងគួរតែភ្ញាក់ផ្អើល នៅពេលដែលយើងដឹងថា យើងមិនអាចយល់អំពីអាថ៌កំបាំងខាងឯវិញ្ញាណនេះដែរឬទេ? បញ្ហាចោទ គឺនៅត្រង់នៅត្រង់គោលគំនិតរបស់យើង។ ពីព្រោះគំនិតរបស់យើងមានភាពកម្សោយ និងមានកម្រិត។ ម៉្លោះហើយ បាន ជាព្រះប្រទានភ័ស្តុតាងតាមរយៈព្រះគម្ពីរសមល្មមនឹងបង្ហាញយើងថា ព្រះគម្ពីរមានប្រភពមកពីទ្រង់។ យើងមិនអាចយល់នូវអ្វីគ្រប់យ៉ាងដែលព្រះបានធ្វើនោះទេ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏យើងត្រូវតែជឿទុកចិត្តទៅលើទ្រង់ ដោយគ្មានមន្ទិលសង្ស័យចំពោះព្រះគម្ពីរនោះឡើយ»។ ដកស្រង់ពី Ellen G. White, *Steps to Christ*, pages 106, 107, adapted។

ការសិក្សាបន្ថែម៖ នៅពេលដែលយើងច្រៀងចម្រៀងអំពីទីក្រុងស៊ីយ៉ូន នោះយើងនឹងមានសេចក្តីសង្ឃឹមឡើង។ ដ្បិតចម្រៀងអំពីទីក្រុងស៊ីយ៉ូននេះ បានជួយទ្រទ្រង់សេចក្តីសង្ឃឹមដែលយើងមានទៅលើសេចក្តីសន្យារបស់ព្រះ។ ព្រះបានសន្យាថា ទ្រង់បង្កើតផែនដីថ្មី (វិវរណៈ ២១:១-៥)។ បន្ទាប់មក ទ្រង់នឹងគង់នៅលើផែនដីនេះនៅក្នុងនាមជាស្តេចជារៀងរហូតតទៅ។

នៅលើផែនដីថ្មី «រាស្ត្ររបស់ព្រះនឹងរស់នៅជារៀងរហូត។ ពួកគេនឹងសិក្សាអំពីការអស្ចារ្យជាច្រើនដែលព្រះបានបង្កើតមក ដោយក្តីអំណរ។ រាស្ត្ររបស់ព្រះនឹងបានសិក្សាអំពីសេចក្តីស្រឡាញ់ដែលចេញពីការសង្គ្រោះរបស់ទ្រង់។ ពីព្រោះសេចក្តីស្រឡាញ់នេះគឺជាអាថ៌កំបាំងមួយ។ ម៉្យាងទៀត នៅលើផែនដីថ្មីនេះ នឹងលែងមានសេចក្តីអាក្រក់ដែលធ្វើឱ្យយើងភ្លេចព្រះទៀតឡើយ។ ដ្បិតយើងនឹងបានរៀនជំនាញថ្មីៗ។ យើងបាននឹងរៀនចំណេះដឹងថ្មីៗ ហើយក៏មិនដែលហត់នឿយនៅក្នុងការរៀនសូត្រនេះដែរ។ ក៏គ្មានកិច្ចការអ្វីដែលលំបាកខ្លាំងឱ្យយើងធ្វើនោះដែរ។ យើងនឹងបានរៀនធ្វើការអស្ចារ្យជាច្រើន។ ហើយការងារដែលត្រូវធ្វើបន្តបន្ទាប់នោះ ក៏មានជានិច្ចដែរ។ ដ្បិតនៅទីនោះ យើងនឹងបានឃើញការអស្ចារ្យជាច្រើន ហើយយើងក៏នឹងបានរៀនសេចក្តីពិតថ្មីៗខាងឯវិញ្ញាណផងដែរ»។ ដកស្រង់ពី Ellen G. White, *The Great Controversy*, page 677, adapted។

សំណួរពិភាក្សា

១. តើនៅសប្តាហ៍នេះ យើងបានរៀនអំពីក្បួនច្បាប់សំខាន់ៗអ្វីខ្លះ អំពីរាស្ត្ររបស់ព្រះនៅក្នុងទីក្រុងស៊ីយ៉ូននោះ? យើងបានដឹងថា ទីក្រុងស៊ីយ៉ូនគឺជាកន្លែងពិតប្រាកដមួយនៅក្នុងទីក្រុងយេរូសាឡិម។ តើក្បួនច្បាប់សំខាន់ៗដែលយើងបានរៀនអំពីទីក្រុងស៊ីយ៉ូន បានជួយឱ្យយើងយល់ពីកិច្ចការដែលយើងត្រូវធ្វើសម្រាប់ព្រះនោះដោយរបៀបណាដែរ?

២. តើសព្វថ្ងៃនេះ ពួកសិស្សរបស់ព្រះអាចរស់នៅជាមួយនឹងព្រះនៅក្នុងរោងឧបោសថរបស់ទ្រង់នោះដោយរបៀបណា (យ៉ូហាន ១:១៤-១៨; ហេព្រើរ ១២:២២-២៤)?

៣. នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៨៧ យើងបានមើលឃើញទិដ្ឋភាពនៅពេលអនាគត។ យើងក៏បានដឹងថា ទីក្រុងស៊ីយ៉ូននឹងបានក្លាយមកជាទីក្រុងនៃមនុស្សជាតិទាំងអស់នៅលើផែនដីនេះ (សូមអានខគម្ពីររ៉ូម ៥:១០; អេភេសូរ ២:១១-១៦; កូឡុស ១:១៩-២៣)។ តើសេចក្តីសន្យាដ៏អស្ចារ្យនេះបានកើតឡើងដោយរបៀបណា?

៤. តើយ៉ាងទៅវិញ បើសិនជាមានអ្នកណាម្នាក់មកសូមឱ្យលោកអ្នកបកស្រាយពីមូលហេតុដែលនាំឱ្យមនុស្សអាក្រក់សប្បាយរីករាយជាមួយនឹងភាពជោគជ័យជាច្រើននៅក្នុងជីវិតនេះ ខណៈដែលមនុស្សល្អ «ជាច្រើន» កំពុងតែរងទុក្ខនោះ តើលោកអ្នកនឹងឆ្លើយទៅកាន់បុគ្គលម្នាក់នេះយ៉ាងដូចម្តេចដែរ? តើហេតុអ្វីបានជាការដែលយើងយល់ថា យើងមិនអាចទទួលបានចម្លើយពេញលេញឆ្លើយតបទៅនឹងរឿងអាក្រក់គ្រប់យ៉ាងដែលបានកើតឡើងនៅក្នុងជីវិតនេះ គឺជារឿងសំខាន់យ៉ាងដូច្នេះ?

# ស្បែកដណ្ដប់ឆ្អឹង

នៅពេលដែលលោកសេគូលត្រឡប់ទៅកាន់បន្ទាយវិញ បន្ទាប់ពីបានរើធ្យូងនៅលើភ្នំអស់រយៈពេលខ្លីរួចមក លោកសេគូលបានប្រាប់មេបញ្ជាការរបស់គាត់ថា គាត់នឹងមិនកាន់អាវុធជាដាច់ខាត ទោះបីជាខ្ញុំត្រូវចូលនៅក្នុងសង្គ្រាមបូស្នៀ (Bosinan War) ដែលកំពុងតែកើតឡើងនោះក៏ដោយ។ គាត់បាននិយាយថា «ខ្ញុំមិនចង់បាញ់សម្លាប់អ្នកណាគេឡើយ»។ មេបញ្ជាការបានទទូចថា «ឯងត្រូវតែកាន់អាវុធ បើមិនដូច្នោះទេ ឯងនឹងត្រូវបម្រើការរយៈ២ឆ្នាំ មិនមែន១ឡើយ»។ អ្នកដែលមិនព្រមកាន់ចូលធ្វើសង្គ្រាមត្រូវបានតម្រូវឱ្យបម្រើការ២ឆ្នាំនៅក្នុងជួរកងទាហាន២ឆ្នាំ មិនមែន១ឆ្នាំនោះឡើយ»។ លោកសេគូលបានតបទៅវិញថា «មេ ខ្ញុំអត់ខ្វល់រឿងហ្នឹងទេ សំខាន់គឺខ្ញុំមិនកាន់អាវុធជាដាច់ខាត»។ មេបញ្ជាការបានបញ្ជូនលោកសេគូលទៅឱ្យមន្ត្រីស៊ើបការណ៍សម្ងាត់ម្នាក់។ កន្លែងនោះគឺជាកន្លែងអប់រំទាហានដែលមានបញ្ហាធ្ងន់ធ្ងរ។ មន្ត្រីស៊ើបការណ៍ម្នាក់នេះអាចមានសិទ្ធចាប់ទាហានឃុំឃាំងបាន។ ដូច្នេះហើយ លោកសេគូលបានបកស្រាយអំពីហេតុផលរបស់គាត់ឱ្យមន្ត្រីម្នាក់នេះបានស្ដាប់។ មន្ត្រីម្នាក់នេះបាននិយាយថា «មិនអីទេចឹង ឯងយកកាំភ្លើងទៅជាមួយទៅ បើសិនជាគេបញ្ជូនឯងទៅជួរមុខ ចូលឱ្យកាំភ្លើងឯងទៅគេវិញចុះ ដើម្បីឱ្យឯងអាចបម្រើការត្រឹមតែមួយឆ្នាំប៉ុណ្ណោះ មិនបាច់ដល់២ឆ្នាំឡើយ»។ លោកសេគូលបានសួរទៅវិញថា «តើលោកនាយចង់មានន័យយ៉ាងម៉េចដែរ?»។ មន្ត្រីម្នាក់នេះក៏បានតបមកវិញថា «ឯងប្រាប់មេបញ្ជាការឯងថា ឯងយល់ព្រមកាន់កាំភ្លើងនៅពេលហាត់សម ប៉ុន្តែ ការហាត់សមដែលឯងត្រូវអនុវត្តនោះ គឺខាងឯផ្នែកម៉ាស៊ីនអង្គុលីលេខជំនួសឱ្យការបាញ់កាំភ្លើងវិញ»។ លោកសេគូលបានយល់ព្រមនឹងការឱ្យយោបល់នោះ។ គាត់ត្រូវបានគេចាត់តាំងឱ្យធ្វើការនៅក្នុងការិយាល័យ ដោយជួយរត់ការខាងឯផ្នែកទំនាក់ទំនង តាមរយៈការវាយអង្គុលីលេខ។

ការថ្វាយបង្គំនៅថ្ងៃសប្បាតហ៍បានក្លាយជាបញ្ហាប្រឈមធំជាងការដែលលោកសេគូលត្រូវកាន់កាំភ្លើងទៅទៀត។ ដោយសារសង្គ្រាម លោកសេគូលត្រូវតែហាត់សមការខាងឯផ្នែកអង្គុលីលេខយ៉ាងប្រញ៉ាប់ប្រញាល់។ ប៉ុន្តែ គាត់បានបដិសេធមិនចូលរួមហាត់សមនៅថ្ងៃសប្បាតហ៍នោះវិញ។

អាហារក៏ជាបញ្ហាចោទមួយដែរ។ របបអាហារយោធាត្រូវបានចម្អិនឡើង ដោយប្រើខ្លាញ់យ៉ាងច្រើន។ ឪពុកម្ដាយរបស់លោកសេគូលបានបដិសេធមិនព្រមផ្ញើប្រាក់មកឱ្យលោកសេគូលទិញអាហារនោះឡើយ ដោយសារតែពួកគេសង្ឃឹមថា ពួកគេនឹងផ្លាស់ប្ដូររបបអាហាររបស់គាត់។ លោកសេគូលបានអធិស្ឋានទូលទៅព្រះថា «ឱព្រះអម្ចាស់អើយ សូមឱ្យទ្រង់បានប្រទានពរដល់ទូលបង្គំ ដូចជាទ្រង់បានប្រទានពរដល់លោកដានីយ៉ែលដូច្នោះដែរ ដ្បិតលោកដានីយ៉ែលបានបដិសេធអាហារមិនស្អាត ដូច្នេះហើយ ទូលបង្គំក៏ចង់ធ្វើដូចជាលោកដានីយ៉ែលនោះដែរ»។

មេបញ្ជាការរបស់លោកសេគូលមិនដឹងថា ត្រូវធ្វើយ៉ាងណាជាមួយនឹងលោកសេគូលនោះទេ។ គាត់បានសួរលោកសេគូលថា «តើឯងបានសម្រេចថា ឯងនឹងធ្វើការនៅថ្ងៃសៅរ៍ហើយ មែនទេ?»។ លោកសេគូលបានឆ្លើយថា «បាទមេ ខ្ញុំបានសម្រេចចិត្តថា ខ្ញុំនឹងមិនធ្វើការនៅថ្ងៃសៅរ៍នោះឡើយ»។ មេបញ្ជាការបានសួរទៀតថា «ឯងសាកឱ្យយោបល់មើលថា ឯងអាចធ្វើអ្វីបានខ្លះ?»។ លោកសេគូលបានឆ្លើយថា «មេ ខ្ញុំគ្មានយោបល់អ្វីឡើយ»។ មេបញ្ជាការបានសួរបញ្ជាក់ថា «អ៊ីចឹង ឯងមិនញ៉ាំសាច់ទេ មែនទេ?»។ លោកសេគូលបានឆ្លើយថា «បាទមេ ខ្ញុំអត់ញ៉ាំសាច់ទេ»។ មេបញ្ជាការបានសួរម្ដងទៀតថា «អ៊ីចឹង ឯងសាកឱ្យយោបល់មើលថា ឯងអាចធ្វើអ្វីបានខ្លះនៅថ្ងៃនោះ?»។ លោកសេគូលបានឆ្លើយបញ្ជាក់ម្ដងទៀតថា «បាទមេ ខ្ញុំគ្មានយោបល់អ្វីឡើយ»។

នំប៉័ង និងទឹកតែគឺជាអាហារតែមួយគត់ដែលលោកសេគូលអាចញ៉ាំបាន។ នៅក្នុងរយៈពេល៤ខែ គាត់បានស្រក២៣គីឡូក្រាមចុះរហូតដល់៨៥គីឡូក្រាម ធ្វើឱ្យគាត់សល់តែស្បែកដណ្ដប់ឆ្អឹងតែប៉ុណ្ណោះ។

# ទូលបង្គំនឹងច្រៀងថ្វាយព្រះអម្ចាស់



ល្ងាចថ្ងៃបរិសុទ្ធ - ថ្ងៃសៅរ៍ ទី១៦ ខែមីនា ឆ្នាំ២០២៤

**អំណានព្រះគម្ពីរសម្រាប់មេរៀនប្រចាំសប្ដាហ៍នេះ៖ ទំនុកតម្កើង ១៣៤; ទំនុកតម្កើង ៣៣:៣; ទំនុកតម្កើង ១៥; ទំនុកតម្កើង ៩៦; ទំនុកតម្កើង ៤០:៦-៨; ទំនុកតម្កើង ៥០:៧-២៣; ទំនុកតម្កើង ៥១:១៦-១៩។**

**ខចងចាំ៖ «កាលនៅមានជីវិតនៅឡើយ នោះទូលបង្គំនឹងច្រៀងថ្វាយព្រះយេហូវ៉ាជាដរាប កាលទូលបង្គំមាននៅៗឡើយ នោះនឹងច្រៀងសរសើរដល់ព្រះនៃទូលបង្គំ» (ទំនុកតម្កើង ១០៤:៣៣)។**

ចំណេះដឹងដែលយើងបានដឹងអំពីព្រះនឹងបានលូតលាស់ឡើងក នៅពេលយើងទទួលបានបទពិសោធន៍នៃព្រះគុណរបស់ទ្រង់នោះ។ ខណៈដែលយើងកំពុងតែលូតលាស់នៅក្នុងនាមជាគ្រីស្ទាន នោះចិត្តរបស់យើងមានពេញទៅដោយការដឹងគុណចំពោះព្រះ សម្រាប់ព្រះពរជាច្រើនរបស់ទ្រង់។ ហើយយើងនឹងសួរថា «តើត្រូវឲ្យខ្ញុំយកអ្វីតបស្នងព្រះយេហូវ៉ា ចំពោះព្រះគុណដែលទ្រង់បានផ្តល់មកខ្ញុំទាំងប៉ុន្មាន(?)» (ទំនុកតម្កើង ១១៦:១២)។ ចម្លើយដែលត្រូវឆ្លើយនោះគឺថា យើងត្រូវតែថ្វាយរូបកាយរបស់យើងដល់ព្រះទាំងស្រុង ព្រមទាំងរស់នៅសម្រាប់ទ្រង់ ដោយក្តីជំនឿផងដែរ។

នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង សាសន៍អ៊ីស្រាអែលមានតម្លៃលើសជាងសាសន៍ដទៃទៀត។ ហើយសាសន៍នេះក៏មានគ្នាយ៉ាងច្រើន នៅពេលដែលពួកគេបានជួបជុំគ្នាថ្វាយបង្គំនោះដែរ (ទំនុកតម្កើង ២២:២២, ២៥; ទំនុកតម្កើង ៣៥:១៨)។ ការជួបជុំនៃសាសន៍អ៊ីស្រាអែលបានបង្ហាញយើងថា ព្រះចង់ឱ្យរាស្ត្ររបស់ទ្រង់ចូលមកថ្វាយបង្គំទ្រង់ទាំងអស់គ្នា។ ទ្រង់ក៏ចង់ឱ្យមនុស្សលោកដែលនៅសេសសល់នៅលើផែនដីនេះទាំងអស់បានរួបរួមគ្នាជាមួយនឹងសាសន៍អ៊ីស្រាអែលផងដែរ។

ការសរសើរតម្កើងគឺជាផ្នែកមួយនៃការថ្វាយបង្គំរួមគ្នារបស់យើង នៅក្នុងនាមជាក្រុមជំនុំម្នាក់។ ការថ្វាយបង្គំនៅក្នុងក្រុមជំនុំរបស់យើងមិនបានជំនួសសេចក្តីអធិស្ឋាន និងជំនួសចម្រៀងសរសើរតម្កើងផ្ទាល់ខ្លួនរបស់យើងនោះឡើយ។ ពីព្រោះចម្រៀងសរសើរតម្កើងក៏បានធ្វើឱ្យការថ្វាយបង្គំជាសាធារណៈរបស់យើងបានរឹងមាំឡើង (ទំនុកតម្កើង ២២:២២, ២៥)។ នៅពេលដែលយើងថ្វាយបង្គំរួមគ្នានៅក្នុងនាមជាសមាជិកក្រុមជំនុំ នោះការថ្វាយបង្គំព្រះជាសាធារណៈរបស់យើងក៏បានលូតលាស់ផងដែរ។ ដ្បិតមនុស្សដែលបានចូលមកថ្វាយបង្គំព្រះរួមគ្នាទាំងនេះ ត្រូវបានហៅថាជា «មនុស្សទៀងត្រង់» (ទំនុកតម្កើង ១១១:១)។ ពួកគេបានស្គាល់ព្រះ (ទំនុកតម្កើង ៣៦:១០) ហើយព្រះក៏បានស្គាល់ពួកគេដែរ (ទំនុកតម្កើង ៣៧:១៨)។ ដូច្នេះហើយ បទពិសោធន៍ដែលពួកគេមានជាមួយនឹងព្រះបានបំពេញផ្នែកទាំងអស់នៅក្នុងជីវិតរបស់ពួកគេ។

## ចូរលើកដៃប្រណមអរព្រះគុណព្រះក្នុងរោងឧបោសថរបស់ទ្រង់

**តើមនុស្សបានថ្វាយបង្គំព្រះនៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក១៣៤ ដោយរបៀបណា? តើនឹងមានអ្វីកើតឡើង នៅពេលដែលមនុស្សលោកបានថ្វាយបង្គំព្រះអម្ចាស់បែបយ៉ាងនេះនោះ?**

---

---

បទគម្ពីរទំនុកតម្កើង ជំពូក១៣៤ បានជួយឱ្យយើងនឹកចាំអំពីព្រះពរដែលលោកអើរ៉ុនបានឱ្យដល់សាសន៍អ៊ីស្រាអែល (លេវីវិន័យ ៦:២៤-២៦; សូមអានខគម្ពីរទំនុកតម្កើង ៦៧:១ ផងដែរ)។ ព្រះពរគឺជាផ្នែកដ៏សំខាន់មួយនៅក្នុងទំនាក់ទំនងរវាងព្រះ ហើយនិងរាស្ត្ររបស់ទ្រង់។ ពួកបណ្តាជនបានជូនពរដល់ព្រះនៅក្នុងរោងឧបោសថរបស់ទ្រង់។ ព្រះបានប្រទានពរដល់រាស្ត្ររបស់ទ្រង់មកពីភ្នំស៊ីយ៉ូន។ ដ្បិតទ្រង់គឺជាព្រះអាទិកររបស់ពួកគេ ម្ល៉ោះហើយ បានជាព្រះពររបស់ទ្រង់បានប៉ះពាល់ផ្នែកទាំងអស់នៅក្នុងជីវិតនៃរាស្ត្ររបស់ទ្រង់។ ពួកគេបានស្ថិតនៅក្រោមសេចក្តីសន្យានៃព្រះគុណរបស់ព្រះ។ នៅក្នុងផ្នែកនៃសេចក្តីសន្យានេះ មនុស្សលោកអាចនឹងជូនពរដល់ព្រះអម្ចាស់ ហើយពួកគេក៏អាចនឹងទទួលព្រះពរពីទ្រង់វិញដែរ។

**សូមអានខគម្ពីរទំនុកតម្កើង ១៨:១; ទំនុកតម្កើង ៣៦:១; ទំនុកតម្កើង ១១៣:១; ទំនុកតម្កើង ១៣៤:១, ២ និងទំនុកតម្កើង ១៣៥:១, ២។ តើខទាំងនេះបានប្រាប់យើងអំពីមនុស្សដែលបានថ្វាយបង្គំទ្រង់នោះយ៉ាងដូចម្តេចដែរ?**

---

នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង អ្នកបម្រើព្រះគឺជាឈ្មោះមួយទៀតសម្រាប់អ្នកដែលបានថ្វាយបង្គំព្រះ។ ពីព្រោះកវីនៅក្នុងជំពូកនេះបានថ្លែងថា៖ «នែ អស់អ្នកបម្រើរបស់ព្រះយេហូវ៉ា ដែលឈរនៅក្នុងដំណាក់ទ្រង់ នៅពេលយប់អើយ ចូរថ្វាយពរដល់ព្រះយេហូវ៉ាចុះ» (ទំនុកតម្កើង ១៣៤:១)។ អ្នកធ្វើការយប់ទាំងនេះអាចនឹងយាមល្បាតរោងឧបោសថឱ្យពួកលេវីនៅពេលរាត្រី (របាក្សត្រទី១ ៩:២៣-២៧)។ ប៉ុន្តែ ពួកលេវីបានសរសើរតម្កើងព្រះទាំងយប់ទាំងថ្ងៃវិញ (របាក្សត្រទី១ ៩:៣៣)។

រោងឧបោសថបានជួយឱ្យសាសន៍អ៊ីស្រាអែលបានដឹង និងបានយល់ពីព្រះដែលពួកគេមិនអាចមើលឃើញ។ ជំនួយនេះសំខាន់ជាទីបំផុត ដោយសារតែព្រះបានបង្គាប់មិនឱ្យរាស្ត្ររបស់ទ្រង់ធ្វើរូបសំណាករបស់ទ្រង់ ឬថ្វាយបង្គំរូបសំណាកទាំងនោះឡើយ។ រោងឧបោសថបានបង្ហាញពួកគេអំពីសិរីល្អរបស់ព្រះអម្ចាស់។ រោងឧបោសថក៏បានបង្ហាញពួកគេអំពីកន្លែងសុវត្ថិភាព ដែលអ្នកមានបាបបានចូលមកជួបជាមួយនឹងស្តេចដ៏បរិសុទ្ធរបស់ពួកគេ។ ដ្បិតព្រះអម្ចាស់ទ្រង់បានប្រទានក្បួនច្បាប់សំខាន់ៗដល់រាស្ត្ររបស់ទ្រង់ ដើម្បីឱ្យពួកគេបានធ្វើតាម នៅពេលពួកគេបានជួបជាមួយនឹងទ្រង់នៅក្នុងរោងឧបោសថរបស់ទ្រង់នោះ។

«ឯអ្នករាល់គ្នា ដែលកំពុងតែមកឯទ្រង់ដ៏ជាថ្មរស់ ដែលមនុស្សបានបោះបង់ចោលចេញ តែព្រះបានជ្រើសរើស ហើយរាប់ជាវិសេសវិញ នោះអ្នករាល់គ្នាក៏បានស្អាងឡើង ដូចជាថ្មរស់ដែរ ឲ្យបានធ្វើជាផ្ទះខាងឯវិញ្ញាណ ជាពួកសង្ឃបរិសុទ្ធ សម្រាប់នឹងថ្វាយគ្រឿងបូជាខាងព្រលឹងវិញ្ញាណ ដែលព្រះទ្រង់សព្វព្រះហឫទ័យទទួល ដោយព្រះយេស៊ូវគ្រីស្ទ» (ពេត្រុសទី១ ២:៤, ៥)។ នៅក្នុងខទាំងនេះ លោកពេត្រុសបានបង្រៀនគោលគំនិតតែមួយ ដែលយើងបានអាននៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង។ គឺថា រាស្ត្ររបស់ព្រះគឺសង្ឃដ៏បរិសុទ្ធមួយក្រុម។ ពីព្រោះពួកគេបានថ្វាយការសរសើរតម្កើងរបស់ពួកគេ ដោយអរព្រះគុណដល់ព្រះយេស៊ូវដែលជាព្រះអាទិកររបស់ពួកគេ និងជាព្រះអង្គសង្គ្រោះរបស់ពួកគេ។ ដូច្នេះហើយ បានជារាស្ត្ររបស់ទ្រង់បានអរព្រះគុណទ្រង់សម្រាប់ការអស្ចារ្យគ្រប់យ៉ាងដែលទ្រង់បានធ្វើ និងបន្តធ្វើសម្រាប់ពួកគេ។

# ចូរច្រៀងបទថ្មីថ្វាយព្រះ

**សូមអានខគម្ពីរទំនុកតម្កើង ជំពូក ៣៣:៣; ទំនុកតម្កើង ៤០:៣; ទំនុកតម្កើង ៩៦:១; ទំនុកតម្កើង ៩៨:១; ទំនុកតម្កើង ១៤៤:៩ និងទំនុកតម្កើង ១៤៩:១។ តើនៅក្នុងខដែលចេញមកពីកំណាព្យទាំងនេះ លោកអ្នកបានឃើញគោលគំនិតតែមួយអ្វីដែរ?**

___

___

កំណាព្យទាំងនេះបានសូមឱ្យពួកបណ្ដាជនច្រៀងបទថ្មី។ ហេតុផលដែលត្រូវច្រៀងបទថ្មីនោះ គឺដោយសារតែព្រះអម្ចាស់បានគ្រប់គ្រងផែនដីនេះ។ ម្យ៉ាងទៀត ពួកគេក៏បានអរព្រះគុណព្រះអម្ចាស់ចំពោះព្រះទ័យយកចិត្តទុកដាក់របស់ទ្រង់ផងដែរ។ ពួកគេបានអរព្រះគុណព្រះអម្ចាស់ដែលបានបង្កើតពួកគេ។ ពួកគេបានដឹងគុណដល់ព្រះអម្ចាស់ដែលបានធ្វើជាចៅក្រមនៃផែនដីទាំងមូល។ ពួកគេបានអរព្រះគុណព្រះសម្រាប់ហេតុផលជាច្រើនទៀត។ ពោលគឺថា ព្រះបានសង្គ្រោះពួកគេចេញពីខ្មាំងសត្រូវរបស់ពួកគេ ហើយទ្រង់ក៏បានសង្គ្រោះពួកគេចេញពីសេចក្ដីស្លាប់ផងដែរ។ ដូច្នេះហើយ ពួកសាសន៍អ៊ីស្រាអែលបានអរព្រះគុណព្រះ សម្រាប់ព្រះគុណដ៏ពិសេសរបស់ទ្រង់។ រីឯកំណាព្យ និងចម្រៀងដទៃទៀតដែលមាននៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងបានសរសើរតម្កើងព្រះចំពោះសេចក្ដីស្រឡាញ់ ហើយនិងបាដិហារ្យដ៏អស្ចារ្យរបស់ទ្រង់។ ប៉ុន្តែ បទថ្មីមានលក្ខណៈខុសគ្នាពីបទចាស់។ ពីព្រោះបទថ្មីគឺជាចម្រៀងដ៏ពិសេសមួយបទ។ ហើយវាក៏ជាចម្រៀងនៃសេចក្ដីអំណរផងដែរ។

បទថ្មីក៏ប្រៀបដូចជាសេចក្ដីសន្យាដែលពួកបណ្ដាជនបានស្បថនឹងព្រះយ៉ាងដូច្នោះដែរ។ ពួកគេបានសន្យាថា ពួកគេនឹងថ្វាយជីវិតរបស់ពួកគេដល់ព្រះម្ដងទៀត។ បទពិសោធន៍ថ្មីៗខាងឯសេចក្ដីជំនឿរបស់ពួកគេបានធ្វើឱ្យអ្នកដទៃប្រកាសថា ព្រះគឺជាស្ដេច និងជាព្រះអាទិកររបស់ពួកគេផងដែរ។ ពីព្រោះបទថ្មីបានស្ដីអំពីការជឿទុកចិត្តទៅលើព្រះ។ ហើយបទថ្មីក៏បានសរសើរតម្កើងព្រះសម្រាប់ការអស្ចារ្យរបស់ទ្រង់ផងដែរ។ ម្យ៉ាងទៀត នៅក្នុងបទថ្មី ពួកបណ្ដាជនក៏បានអរព្រះគុណព្រះ ដោយសារតែទ្រង់បានរំដោះពួកគេចេញពីខ្មាំងសត្រូវរបស់ពួកគេនោះដែរ។

**សូមអានខគម្ពីរអេសាយ ៤២:១០-១២; វិវរណៈ ៥:៩ និងវិវរណៈ ១៤:៣។ តើខទាំងនេះបានបង្រៀនយើងអំពីបទថ្មីយ៉ាងដូចម្ដេចដែរ?**

___

ព្រះគម្ពីរបានចែងថា សាសន៍អ៊ីស្រាអែលគឺជា «ពួកអ្នកបរិសុទ្ធ» របស់ព្រះ (ទំនុកតម្កើង ១៤៨:១៤)។ ពួកសាសន៍អ៊ីស្រាអែលគឺជា «សាសន៍ដែលនៅជិតដិតនឹងទ្រង់» (ទំនុកតម្កើង ១៤៨:១៤)។ ដូច្នេះហើយ ពួកសាសន៍អ៊ីស្រាអែលបានទទួលបទពិសោធន៍ជាមួយនឹងព្រះដែលគ្មានសាសន៍ណាទទួលបានបទពិសោធន៍បែបនេះឡើយ។ ពីព្រោះបទពិសោធន៍នេះបានផ្ដល់ឱ្យពួកគេនូវការលើកតម្កើងមួយដ៏ពិសេសបំផុត។ គឺថា ពួកគេមានឱកាសសរសើរតម្កើងព្រះនៅតាមរបៀបដ៏ពិសេសមួយ ដែលគ្មានសាសន៍ដទៃណានៅលើផែនដីនេះមានឱកាសបានសរសើរតម្កើងទ្រង់នោះឡើយ។ ដូច្នេះហើយ ព្រះគម្ពីរបានលើកទឹកចិត្តឱ្យរាស្ត្រទាំងអស់របស់ព្រះនៅគ្រប់ទាំងសម័យកាលបានច្រៀងបទថ្មី ដើម្បីសរសើរតម្កើងដល់ព្រះអង្គសង្គ្រោះរបស់ពួកគេ។ បទថ្មីអាចនឹងស្ដីអំពីសេចក្ដីសង្ឃឹមដែលយើងមានចំពោះព្រះ។ បទថ្មីគឺជាការថ្វាយបង្គំមួយបែប។ ដ្បិតការថ្វាយបង្គំពិតប្រាកដនោះ គឺលើសពីការថ្វាយតង្វាយទៅទៀត។ ការថ្វាយបង្គំគឺស្ដីអំពីព្រះរបស់យើងដែលប្រកបទៅដោយសេចក្ដីស្រឡាញ់ ហើយនិងការទទួលយកសេចក្ដីស្រឡាញ់ដែលទ្រង់បានប្រទានឱ្យយើង។ បទថ្មីក៏ជាវិធីមួយបែបនៅក្នុងការចែកចាយសេចក្ដីស្រឡាញ់ និងការថ្លែងអំណរគុណរបស់យើងដល់ព្រះចំពោះរឿងគ្រប់យ៉ាងដែលទ្រង់បានធ្វើសម្រាប់យើងនោះដែរ។

**តើយ៉ាងណាទៅវិញ បើសិនជាលោកអ្នកបានច្រៀងបទថ្មីវិញនោះ?**

## ឱព្រះអម្ចាស់អើយ តើអ្នកណាខ្លះនឹងបាននៅក្នុងរោងឧបោសថរបស់ទ្រង់នោះ?

**តើអ្នកដែលស័ក្តិសមថ្វាយបង្គំព្រះដ៏មានព្រះជន្មរស់នៅក្នុងរោងឧបោសថរបស់ទ្រង់នោះគឺជាអ្នកណា? សូមអានបទគម្ពីរទំនុកតម្កើង ជំពូក១៥ សម្រាប់ចម្លើយ។**

______________________________________________

______________________________________________

ចម្លើយឆ្លើយតបទៅនឹងសំណួរខាងលើនេះគឺជាពួកអ្នកដែលមានចិត្តបរិសុទ្ធ (សូមអានខគម្ពីរចោទិយកថា ៦:៥; មីកា ៦:៦-៨)។ ដ្បិតជីវិតរបស់មនុស្សទាំងនេះបានបង្ហាញថា ពួកគេបានគោរពតាមព្រះ។ សេចក្តីស្រឡាញ់របស់ព្រះបានដក់ជាប់នៅក្នុងចិត្តរបស់ពួកគេ។ ម្ល៉ោះហើយ រោងឧបោសថរបស់ព្រះនៅក្នុងទីក្រុងយេរូសាឡិមគឺជាកន្លែងមួយដ៏បរិសុទ្ធ។ ដ្បិតរបស់គ្រប់យ៉ាងនៅក្នុងរោងឧបោសថ រួមទាំងពួកសង្ឃរបស់ព្រះសុទ្ធតែជាតង្វាយថ្វាយដល់ទ្រង់ជានិច្ច។ ដូច្នេះហើយ អ្នកណាដែលបានចូលមកក្នុងរោងឧបោសថនេះ ក៏ត្រូវតែបរិសុទ្ធផងដែរ។ រាស្ត្ររបស់ព្រះត្រូវតែបរិសុទ្ធនៅក្នុងផ្នែកទាំងអស់នៃជីវិតរបស់ពួកគេ។ ពីព្រោះព្រះបានប្រទានបញ្ញត្តដល់រាស្ត្ររបស់ទ្រង់ ដើម្បីជួយឱ្យពួកគេបានក្លាយមកជាសង្ឃហ្លួងរបស់ទ្រង់។ សង្ឃហ្លួងរបស់ព្រះត្រូវតែបរិសុទ្ធ នៅពេលដែលពួកគេចូលមកថ្វាយបង្គំព្រះ។ ជីវិតរបស់ពួកគេត្រូវតែបរិសុទ្ធ ដើម្បីឱ្យពួកគេអាចចែករំលែកព្រះពរនៃសេចក្តីសន្យារបស់ព្រះជាមួយអ្នកនឹងសាសន៍ដទៃ។

**តើភាពបរិសុទ្ធនៅត្រង់នេះមានន័យយ៉ាងណាដែរ? សូមអានខគម្ពីរទំនុកតម្កើង ២៤:៣-៦ និងទំនុកតម្កើង ១០១:១-៣ សម្រាប់ចម្លើយ។**

______________________________________________

______________________________________________

តើយើងបានបរិសុទ្ធដោយសារអ្វីទៅ? នោះគឺដោយសារតែព្រះបានប្រទានចិត្តសុចរិតដល់យើង។ ពាក្យថា «សុចរិត» ប្រែមកពីពាក្យថា «តាមីន (tamin)» ជាភាសាហេព្រើរ។ «តាមីន» មានន័យថា របស់អ្វីម្យ៉ាងដែល «គ្រប់លក្ខណ៍» ឬ «ពេញលេញ»។ ផ្លែទំពាំងបាយជូរដែលល្អឥតខ្ចោះគឺជាផ្លែស្រស់ និងមានសុខភាពល្អ (អេសេគាល ១៥:៥)។ ដូច្នេះហើយ សត្វដែលបាននាំយកមកថ្វាយព្រះនេះ ត្រូវតែជាប្រភេទនៃសត្វ «តាមីន» (លេវីវិន័យ ២២:២១-២៤)។ សត្វទាំងនេះមិនត្រូវមានជំងឺ ខ្វាក់ភ្នែក ពិការ ឬបាក់ឆ្អឹងអ្វីឡើយ។ ពាក្យថា «សុចរិត» មានពេញទៅដោយសេចក្តីពិត។ ដ្បិតពាក្យទាំងនេះមិនមែនជាពាក្យកុហកនោះឡើយ (យ៉ូប ៣៦:៤)។ ដូច្នេះហើយ ពាក្យថា «សុចរិត» គឺសំដៅទៅលើចិត្តបរិសុទ្ធ ឬអាចហៅបានថាជា ចិត្តដែលត្រូវបានសម្អាតចេញពីអំពើបាប (ទំនុកតម្កើង ២៤:៤; ទំនុកតម្កើង ១៥:២)។ អ្នកណាដែលមានចិត្ត «សុចរិត» ពួកគេនឹងស្វែងរកព្រះ (ទំនុកតម្កើង ២៤:៦) បន្ទាប់មក ពួកគេនឹងត្រូវបានសម្អាតដោយការលើកលែងទោសរបស់ព្រះ (ទំនុកតម្កើង ៥១:២-១០)។ សេចក្តីមេត្តារបស់ព្រះបានជួយឱ្យអ្នកបម្រើរបស់ទ្រង់បានរស់នៅក្នុងជីវិតនៃការស្តាប់បង្គាប់។ នៅពេលដែលយើងបានរស់នៅក្នុងជីវិតដ៏បរិសុទ្ធនេះហើយ នោះយើងនឹងបានសរសើរតម្កើងព្រះដំនួសឱ្យខ្លួនយើងវិញ។

**តើយើងអាចជ្រើសរើសគេចចេញពីការធ្វើនូវរឿងដែលនាំឱ្យយើងបែកចេញពីព្រះនោះដោយរបៀបណា? តើរឿងទាំងនេះមួយចំនួនគឺជារឿងអ្វីដែរ? តើយើងអាចឈប់ធ្វើរឿងទាំងនេះដោយរបៀបណា?**

# ការប្រកាសដល់មនុស្សគ្រប់គ្នាអំពីសិរីល្អរបស់ព្រះ

**តើការថ្វាយបង្គំរួមមានអ្វីខ្លះ? សូមអានបទគម្ពីរទំនុកតម្កើង ជំពូក៩៦ សម្រាប់ចម្លើយ។**

______________________________________________________________________

______________________________________________________________________

ការថ្វាយបង្គំក៏បានរួមបញ្ចូលនូវការច្រៀងថ្វាយព្រះអម្ចាស់ផងដែរ (ទំនុកតម្កើង ៩៦:១, ២)។ ការថ្វាយបង្គំក៏បានរាប់បញ្ចូលនូវការប្រកាសថា ព្រះទ្រង់ល្អអស្ចារ្យ និងមានអំណាច (ទំនុកតម្កើង ៩៦:៣, ៤)។ នៅពេលដែលយើងបានថ្វាយបង្គំព្រះ យើងក៏បាននាំតង្វាយមកថ្វាយទ្រង់ដែរ (ទំនុកតម្កើង ៩៦:៨)។ ការប្រកាសអំពីនគររបស់ព្រះក៏មានផ្នែកនៃការថ្វាយបង្គំផងដែរ តែផ្នែកនេះមិនសូវពេញនិយមដូចជាការច្រៀង ការសរសើរ ហើយនិងការដាក់តង្វាយថ្វាយព្រះនោះឡើយ (ទំនុកតម្កើង ៩៦:២, ៣, ១០)។

ការច្រៀង ការសរសើរ ការនាំតង្វាយ ហើយនិងការប្រកាសដំណឹងល្អអំពីព្រះយេស៊ូវ មិនត្រូវបានបំបែកចេញពីគ្នាឡើយ។ ដ្បិតនៅពេលណាដែលយើងបានចែកចាយដំណឹងល្អ នោះមានន័យថា យើងបានសរសើរតម្កើង និងបានថ្វាយបង្គំទ្រង់នៅក្នុងពេលតែមួយហើយ។ ណាមួយ ហេតុផលនៃការថ្វាយបង្គំរបស់យើងក៏ជាហេតុផលតែមួយនៅក្នុងការចែកចាយដំណឹងល្អជាមួយនឹងអ្នកដទៃផងដែរ ពោលគឺ៖ (១) ព្រះអម្ចាស់ទ្រង់ល្អអស្ចារ្យ (ទំនុកតម្កើង ៩៦:៤)។ (២) ព្រះក្លែងក្លាយរបស់សាសន៍ដទៃគឺជារូបសំណាក។ ប៉ុន្តែ ព្រះអម្ចាស់គឺជាអ្នកបង្កើតផ្ទៃមេឃ និងផែនដីនេះ (ទំនុកតម្កើង ៩៦:៥)។ (៣) ព្រះអម្ចាស់គឺជាស្តេច។ ដ្បិតផែនដីទាំងមូលគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទ្រង់ (ទំនុកតម្កើង ៩៦:១០)។ (៤) ព្រះអម្ចាស់នឹងយាងមកនៅពេលឆាប់ៗនេះ។ ទ្រង់នឹងជំនុំជម្រះមនុស្សគ្រប់គ្នានៅលើផែនដីនេះ (ទំនុក-តម្កើង ៩៦:១៣)។ យើងបានចែកចាយដំណឹងល្អជាមួយនឹងអ្នកដទៃ ដោយព្រោះហេតុផលទាំងនេះ ដើម្បីឱ្យពួកគេអាចចូលថ្វាយបង្គំព្រះជាមួយនឹងយើង (ទំនុកតម្កើង ៩៦:១១-១៣)។

ការថ្វាយបង្គំបានចាប់ផ្តើមឡើងជាមួយនឹងការទទួលស្គាល់ថា ព្រះអម្ចាស់គឺជាព្រះអាទិកររបស់យើង។ ព្រះអម្ចាស់ក៏ជាស្តេច និងជាចៅក្រមរបស់យើងដែរ (ទំនុកតម្កើង ៩៦:៥, ១០, ១៣)។ នៅពេលដែលយើងថ្វាយបង្គំព្រះ នោះយើងក៏បាននឹកចាំអំពីសកម្មភាពរបស់ទ្រង់កាលពីមុននោះផងដែរ។ ហើយឥឡូវនេះ យើងបានអបអរចំពោះកិច្ចការដែលព្រះបានធ្វើសម្រាប់យើងវិញ។ ដ្បិតយើងនឹងបានពេញទៅដោយសេចក្តីសង្ឃឹម នៅពេលដែលយើងគិតអំពីកិច្ចការដែលទ្រង់ត្រូវធ្វើនៅពេលអនាគតនោះ។ ទ្រង់នឹងជំនុំជម្រះផែនដីនេះ ហើយធ្វើឱ្យផែនដីនេះថ្មីឡើងវិញ។

តើអ្វីទៅជាកិច្ចការរបស់ព្រះជាចៅក្រមនោះ? កិច្ចការរបស់ទ្រង់គឺនាំសេចក្តីសុខសាន្តមកកាន់ផែនដីនេះ ដែលឥឡូវនេះ មានពេញទៅដោយការរងទុក្ខ និងការឈឺចាប់។ ដ្បិតទ្រង់នឹងកែភាពអយុត្តិធម៌នៅក្នុងជីវិតនេះឱ្យបានត្រឹមត្រូវឡើងវិញ។ នេះហើយគឺជាមូលហេតុដែលនាំឱ្យផែនដីទាំងមូលមានពេញដោយក្តីអំណរសម្រាប់កិច្ចការដែលព្រះបានធ្វើជាចៅក្រមនោះ (ទំនុកតម្កើង ៩៦:១០-១៣; ទំនុកតម្កើង ៩៨:៤, ៩)។

បទគម្ពីរទំនុកតម្កើង ជំពូក៩៦ បានហៅមនុស្សគ្រប់គ្នាឱ្យថ្វាយបង្គំព្រះដែលជាចៅក្រម។ ការប្រកាសដដែលនេះគឺផ្នែកនៃសារទេវតាទាំង៣ដែលមានចែងនៅក្នុងខគម្ពីរវិវរណៈ ១៤:៦-១២។ បទគម្ពីរទំនុកតម្កើង ជំពូក៩៦ បានប្រកាសសារនៃគ្រាចុងក្រោយនេះយ៉ាងដូច្នេះថា៖ ចូរថ្វាយបង្គំព្រះដែលបានបង្កើតឯងមក ដ្បិតទ្រង់គឺជាព្រះអង្គសង្គ្រោះ និងជាចៅក្រម។

# តើរបស់ដែលព្រះចង់បានពិតប្រាកដនោះគឺជាអ្វី?

**សូមអានខគម្ពីរទំនុកតម្កើង ៤០:៦-៨; ទំនុកតម្កើង ៥០:៧-២៣ និងទំនុកតម្កើង ៥១:១៦-១៩។ តើកំណាព្យទាំងនេះបានថ្លែងអំពីប្រធានបទសំខាន់អ្វីដែរ? ព្រះដែលបានសណ្ឋិតនៅក្នុងបញ្ញត្តរបស់ទ្រង់ បានសូមឱ្យរាស្ត្ររបស់ទ្រង់ថ្វាយយញ្ញបូជា និងថ្វាយតង្វាយដល់ទ្រង់ (និក្ខមនំ ២០:២៤)។ តើហេតុអ្វីបានជាពេលខ្លះ ព្រះមិនសព្វព្រះទ័យចំពោះតង្វាយនេះយ៉ាងដូច្នេះ? តើរបស់ដែលព្រះចង់បានពីរាស្ត្ររបស់ទ្រង់ពិតប្រាកដនោះគឺជាអ្វី?**

_______________________________________________

_______________________________________________

កវីនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងចង់ឱ្យរាស្ត្ររបស់ព្រះយល់ពីហេតុផលដែលមានពេលខ្លះ នាំឱ្យទ្រង់មិនសព្វព្រះទ័យជាមួយនឹងការថ្វាយបង្គំរបស់ពួកគេ ដោយសារតែអំពើបាបបានបំបែកពួកគេចេញពីព្រះ។ ដូច្នេះហើយ ការថ្វាយបង្គំរបស់ពួកគេគឺជាការថ្វាយបង្គំសំដែង ដែលជាទីស្អប់ខ្ពើមដល់ព្រះជាទីបំផុត។

ព្រះមិនបានខ្វាល់ជាមួយនឹងរាស្ត្ររបស់ទ្រង់ ដោយសារតង្វាយ ឬយញ្ញបូជារបស់ពួកគេនោះឡើយ។ ប៉ុន្តែ ទ្រង់បានខកព្រះទ័យ ដោយសារទង្វើអាក្រក់ និងអំពើបាបរបស់ពួកគេ។ ដ្បិតនៅក្នុងទីជំនុំជម្រះ រាស្ត្ររបស់ព្រះមិនបានទទួលយុត្តិធម៌នៅក្នុងជីវិតរបស់ពួកគេនោះទេ (ទំនុកតម្កើង ៥០:៨, ១៧-២១)។ ប៉ុន្តែ កណ្ឌគម្ពីរទំនុកតម្កើងបានអធិប្បាយទាស់នឹងតង្វាយ ហើយនិងថ្វាយបង្គំដែលគ្មានហេតុផលនោះវិញ។ ដ្បិតការថ្វាយបង្គំរបស់ពួកបណ្ដាជនគឺជាការថ្វាយបង្គំសំដែង និងគ្មានហេតុផលច្បាស់លាស់ ពីព្រោះជីវិតរបស់ពួកគេមានពេញទៅដោយអំពើបាប។

នៅពេលដែលទង្វើរបស់យើងមិនស្របជាមួយនឹងការថ្វាយបង្គំ ឬជំនឿរបស់យើង នោះយើងនឹងថ្វាយបង្គំព្រះជាមួយនឹងហេតុផលខុសឆ្គងជាមិនខាន។ បន្ទាប់មក រឿងដែលយើងត្រូវបានធ្វើនៅក្នុងការថ្វាយបង្គំព្រះកាន់តែសំខាន់ជាងទំនាក់ទំនងដែលយើងមានជាមួយនឹងព្រះទៅទៀត។ យើងនឹងយកចិត្តទុកដាក់ចំពោះតង្វាយរបស់យើងជាងការដែលចិត្តរបស់យើងនៅជាប់នឹងទ្រង់ទៅទៀត។ ប៉ុន្តែ នៅពេលដែលចិត្តរបស់យើងបានឃ្លាតចេញពីព្រះ នោះតង្វាយ និងយញ្ញបូជារបស់យើងនឹងគ្មានន័យអ្វីឡើយ។

**សូមអានខគម្ពីរយ៉ូហាន ៤:២៣, ២៤។ តើនៅក្នុងខទាំងនេះ ព្រះយេស៊ូវកំពុងតែមានបន្ទូលយ៉ាងដូចម្ដេចដែរ? តើព្រះបន្ទូលរបស់ទ្រង់បានស្របជាមួយនឹងរឿងដែលកណ្ឌគម្ពីរទំនុកតម្កើងរបស់យើងបានព្រមានទាស់នោះដោយរបៀបណា?**

_______________________________________________

_______________________________________________

បើមានតែយញ្ញបូជា និងតង្វាយ នោះមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ តើតង្វាយនឹងមានប្រយោជន៍អ្វីទៅ បើសិនជាចិត្តនៃមនុស្សដែលថ្វាយរបស់ទាំងនោះមិនបានលន់តួអំពើបាបដោយសេចក្ដីជំនឿផងនោះ? ដ្បិតនៅពេលដែលរាស្ត្ររបស់ព្រះបានលន់តួអំពើបាបរបស់ពួកគេ តង្វាយរបស់ពួកគេក៏ជាទីគាប់ដល់ព្រះហឫទ័យនៃព្រះដែរ។ បន្ទាប់មក ទ្រង់បានទទួលយកតង្វាយនោះទុកជាអំណោយទានបរិសុទ្ធវិញ (ទំនុកតម្កើង ៥១:១៩; សូមអានខគម្ពីរទំនុកតម្កើង ៥០:១៤)។ ព្រះយេស៊ូវបានយកសម្រង់មតិពីលោកអេសាយមកយោងយ៉ាងដូច្នេះថា៖ «បណ្ដាជននេះគេគោរពប្រតិបត្តិដល់អញតែបបូរមាត់ទេ ឯចិត្តគេ នោះនៅឆ្ងាយពីអញណាស់» (ម៉ាថាយ ១៥:៨)។ ដូច្នេះហើយ បញ្ហាដែលកវីបានជួបក៏ដូចគ្នាទៅនឹងបញ្ហាដែលព្រះយេស៊ូវមានជាមួយនឹងមនុស្សមួយចំនួន រួមទាំងពួកមេដឹកនាំផងដែរ នៅអំឡុងពេលដែលទ្រង់មានព្រះជន្មរស់នៅលើផែនដីនេះ។

**តើហេតុអ្វីបានជាការស្គាល់សេចក្ដីពិតមិនទាន់គ្រប់គ្រាន់ឱ្យយើងបានទទួលសេចក្ដីសង្គ្រោះនោះ?**

**ការសិក្សាបន្ថែម៖** សូមអាន Ellen G. White, "How to Pray," pages 26-28, in *A Call to Stand Apart*។

«ព្រះមិនបានគង់នៅក្នុងរោងឧបោសថដែលមនុស្សបានសង់ដោយដៃនោះឡើយ។ ប៉ុន្តែ ទ្រង់បានលើកតម្កើងរាស្ត្ររបស់ទ្រង់ នៅពេលដែលពួកគេបានឡើងមកជួបជុំគ្នា។ ព្រះបានតាំងសេចក្តីសញ្ញាជាមួយនឹងរាស្ត្ររបស់ទ្រង់។ ទ្រង់នឹងចាត់ព្រះវិញ្ញាណរបស់ទ្រង់ឱ្យមកជួបជាមួយនឹងពួកគេ។ ប៉ុន្តែ ជាដំបូង ពួកគេត្រូវតែរួមគ្នាចូលមកស្វែងរកទ្រង់ជាមុនសិន។ ពួកគេត្រូវតែលន់តួអំពើបាបរបស់ពួកគេ។ ពួកគេត្រូវតែអធិស្ឋានឱ្យគ្នាទៅវិញទៅមក។ រីឯអ្នកដែលបានរួបរួមគ្នាមកថ្វាយបង្គំព្រះគួរតែឈប់ធ្វើអំពើអាក្រក់តទៅទៀត។ រាស្ត្ររបស់ព្រះត្រូវតែថ្វាយបង្គំទ្រង់ដោយចិត្តបរិសុទ្ធ។ ពួកគេត្រូវតែគោរពតាមបញ្ញត្ត និងសេចក្តីពិតរបស់ទ្រង់។ បើសិនជារាស្ត្ររបស់ព្រះបានបដិសេធមិនបានធ្វើរឿងទាំងនេះហើយ នោះការរួបរួមគ្នាចូលមកថ្វាយបង្គំព្រះនឹងក្លាយទៅជាឥតប្រយោជន៍ និងគ្មានគោលបំណងច្បាស់លាស់។ ដ្បិតព្រះយេស៊ូវបានមានបន្ទូលអំពីក្រុមមនុស្សបែបនេះយ៉ាងដូច្នេះថា៖ "«បណ្តាជននេះគេគោរពប្រតិបត្តិដល់អញតែបបូរមាត់ទេ ឯចិត្តគេ នោះនៅឆ្ងាយពីអញណាស់ គេថ្វាយបង្គំអញជាឥតប្រយោជន៍ទេ ព្រោះគេបង្រៀនសេចក្តីដែលជាបញ្ញត្តរបស់មនុស្សវិញ" (ម៉ាថាយ ១៥:៨, ៩)។ អ្នកដែលចូលមកថ្វាយបង្គំព្រះចាំបាច់ត្រូវតែថ្វាយបង្គំទ្រង់ "ដោយវិញ្ញាណ និងសេចក្តីពិត ពីព្រោះព្រះវរបិតា ទ្រង់រកពួកអ្នកយ៉ាងនោះឲ្យបានថ្វាយបង្គំទ្រង់" (យ៉ូហាន ៤:២៣)»។ ដកស្រង់ពី Ellen G. White, *Prophets and Kings*, page 50, adapted។

សំណួរពិភាក្សា

១. តើអ្វីទៅជាអំណោយទានពិសេសដែលយើងអាចថ្វាយដល់ព្រះបាន នៅពេលដែលយើងចូលមកថ្វាយបង្គំទ្រង់នោះ? សូមអានខគម្ពីរទំនុកតម្កើង ៤០:៦-១០ និងរ៉ូម ១២:១, ២ សម្រាប់ចម្លើយ។

២. តើការថ្វាយបង្គំឯកជន និងការថ្វាយបង្គំជាសាធារណៈមានទំនាក់ទំនងអ្វីនឹងគ្នាដែរ? តើហេតុអ្វីបានជាយើងត្រូវការថ្វាយបង្គំទាំង២យ៉ាងនេះ? តើការថ្វាយបង្គំទាំង២យ៉ាងនេះបានជួយឱ្យការថ្វាយបង្គំ បទពិសោធន៍ និងសេចក្តីជំនឿរបស់យើងបានលូតលាស់ឡើង និងបានរឹងមាំឡើងដោយរបៀបណា?

៣. មនុស្សជាច្រើនបានគិតថា ការថ្វាយបង្គំរួមមានត្រឹមតែការអធិស្ឋាន ការច្រៀងចម្រៀង ការសិក្សាព្រះគម្ពីរ និងការអានសៀវភៅសាសនាដទៃទៀតប៉ុណ្ណោះ។ រឿងទាំងនេះមានសារៈសំខាន់ដល់ការថ្វាយបង្គំជាទីបំផុត។ ទន្ទឹមគ្នានេះ តើហេតុអ្វីបានជាការថ្វាយបង្គំមិនត្រូវបានកំណត់ធ្វើត្រឹមតែរឿងទាំងនេះយ៉ាងដូច្នេះ? តើការថ្វាយបង្គំគួរតែមានអ្វីខ្លះទៀត? សូមបង្ហាញឧទាហរណ៍មួយចំនួន។

៤. អ្នកស្រីអេឡែន ជីវ៉ៃតបានសរសេរថា៖ «យើងគួរតែមានអារម្មណ៍រីករាយ នៅពេលដែលយើងថ្វាយបង្គំព្រះអម្ចាស់ ហើយនិងធ្វើកិច្ចការរបស់ទ្រង់នោះ»។ ដកស្រង់ពី Steps to Christ, page 103, adapted។ តើយើងអាចធ្វើអ្វីខ្លះ ដើម្បីឱ្យយើងបានសប្បាយរីករាយជាមួយនឹងការថ្វាយបង្គំព្រះអម្ចាស់នោះ?

# មានម្ជុល តែគ្មានសក់

លោកសេគូលបានរៀនពីអ្នករក្សាថ្ងៃសប្បាតហ៍២នាក់នៅក្នុងជួរយោធា៖ ម្នាក់គឺជាអនុសេនីយឯកដែលកំពុងតែត្រៀមជ្រមុជទឹក ហើយម្នាក់ទៀតនោះ គឺជាបុរសចំណាស់ម្នាក់មកពីគ្រួសារសេវេនដេយអាត់វេនទីស្ទ។ សង្គ្រាមបូស្នៀកំពុងតែផ្ទុះខ្លាំង ប៉ុន្តែ អនុសេនីយឯកម្នាក់នោះបានលើកទឹកចិត្តលោកសេគូលថា ពេលវេលាដែលអស់សង្ឃឹមបំផុត ក៏ជាពេលវេលាដែលត្រូវការយុទ្ធសាស្ត្រល្អបំផុតផងដែរ។ គាត់បាននិយាយថា «ពេលនេះគឺជាពេលមួយដ៏ពិសេស ដោយសារតែឯងត្រូវតែញ៉ាំនូវអ្វីដែលឯងមាន ដ្បិតឯងអាចបន្តធ្វើតាមសាសនារបស់ឯងតទៅមុខទៀត បន្ទាប់ពីឯងបានចាកចេញពីទីនេះទៅ ប៉ុន្តែ ឥឡូវនេះ ឯងត្រូវតែញ៉ាំអាហារ ដើម្បីឱ្យឯងមានកម្លាំងឡើង»។

លោកសេគូលបានគិតនៅក្នុងចិត្តថា អនុសេនីយឯកម្នាក់នេះមិនមែនជាអ្នកអាត់វេនទីស្ទនោះទេ។ គាត់កំពុងតែនិយាយពាក្យសម្ដី ដូចជាឪពុកម្ដាយរបស់លោកសេគូលនិយាយយ៉ាងដូច្នោះដែរ ដូច្នេះហើយ លោកសេគូលមិនចង់បរិភោគអាហារនោះឡើយ។ ប៉ុន្តែ លោកមានបំណងចង់ជួបទាហានដែលបានកើតនៅក្នុងគ្រួសារអាត់វេនទីស្ទនេះណាស់។ គាត់បានសួរនាំយោបល់អំពីអ្វីដែលគាត់ត្រូវញ៉ាំ និងអ្វីដែលគាត់ត្រូវធ្វើ បើសិនជាគាត់ត្រូវគេបញ្ជូនទៅកាន់សមរភូមិមុខ ឬយ៉ាងហោចណាស់ ក៏គាត់អាចអធិស្ឋានរួមគ្នាដែរ ពីព្រោះគាត់មានអារម្មណ៍ថា ឯកោខ្លាំងណាស់។

ថ្ងៃមួយ មានបុគ្គលម្នាក់បានចង្អុលប្រាប់លោកសេគូលឱ្យមើលទៅឯអ្នកអាត់វេនទីស្ទម្នាក់នៅក្នុងសាលដែលមានមនុស្សកកកុញ។ លោកសេគូលបានលួចមើលបុរសម្នាក់អង្គុយចុះ ដោយកាន់ចានដែលមានប្រហិតសាច់ជ្រូក និងមានសណ្ដែកពណ៌ត្នោតឆាដណ្ដប់ខ្លាញ់ ប៉ុន្តែ បុរសម្នាក់នោះបានកៀរប្រហិតសាច់ជ្រូកទាំងនោះចេញ ។ ភ្លាមនោះ លោកសេគូលបានយល់ឃើញគំនិតមួយ។ គាត់បានគិតនៅក្នុងចិត្តថា *បុរសម្នាក់នោះកំពុងតែបរិភោគអាហារមិនស្អាត នៃ សេគូលអើយ ឯងពិតជាល្ងង់មែន ឯងស្រកគីឡូច្រើនណាស់ ហើយឯងក៏គ្មានកម្លាំងកំហែងអ្វីដែរ ដោយសារតែឯងមិនបានញ៉ាំអ្វីទាល់តែសោះ ចូរក្រឡេកទៅមើលបុរសម្នាក់នោះ គាត់ពិតជាឈ្លាសវៃណាស់ ដូច្នេះហើយ នៅពេលដែលឯងចាកចេញពីកងយោធានេះទៅ ឯងអាចញ៉ាំអ្វីក៏បានដែរ។* លោកសេគូលបានឈានមួយជំហានទៅកាន់កន្លែងទទួលអាហារ។ បន្ទាប់មក គាត់បានឈានមួយជំហានទៅមុខទៀត។ នៅពេលនោះ គាត់មិនសូវជាឃ្លានប៉ុន្មានឡើយ ប៉ុន្តែ គាត់បានខ្សោះល្វើយ ដោយសារតែគាត់បរិភោគត្រឹមតែនំប័ុងជាមួយនឹងទឹកតែអស់រយៈពេល២០ថ្ងៃមកហើយ។ គាត់បានឈប់ទ្រឹង នៅពេលដែលគាត់ជិតទៅដល់កន្លែងទទួលអាហារ។ គាត់បានគិតម្ដងទៀតថា *ខ្ញុំមិនអាចយកអាហារទាំងនេះបានទេ បើសិនជាព្រះបានសុគតជំនួសខ្ញុំ នោះខ្ញុំក៏ត្រូវតែស្មោះត្រង់ចំពោះទ្រង់វិញដែរ។* ប៉ុន្មានខែក្រោយមក រដូវផ្ការីកក៏បានមកដល់ ដូច្នេះហើយ លោកសេគូលបានបរិភោគត្រួយនៃដើមឈើ។ គាត់ក៏បានបរិភោគស្មៅ ដែលគាត់ធ្លាប់បរិភោគកាលនៅពីក្មេងនោះដែរ។

នៅក្នុងកិច្ចបម្រើការយោធារយៈពេល៤ខែកន្លងមកនោះ លោកសេគូលបានចេញពីបន្ទាយទៅបរិភោគអាហារជាមួយនឹងស្លាបព្រាជាលើកដំបូង។ បាស្ទ័រអាត់វេនទីស្ទម្នាក់បានអញ្ជើញលោកសេគូលឱ្យបរិភោគអាហារនៅឯផ្ទះរបស់គាត់។ មិនយូរប៉ុន្មាន លោកសេគូលត្រូវបានគេបញ្ជូនទៅកាន់ទីក្រុងបែលក្រាដ (Belgrade) ដែលជារាជធានីនៃប្រទេសស៊ីប៊ៀ ដើម្បីបម្រើការជាឧត្តមសេនីយ៍យោធាកំពូល។ គាត់គឺជាអ្នកវាយអង្គុលីលេខដ៏ស្ទាត់ជំនាញម្នាក់នៅក្នុងប្រទេសបូស្នៀ (Bosnia)។ បន្ទាយថ្មីរបស់គាត់ដើរត្រឹមតែ២០នាទីប៉ុណ្ណោះ នឹងបានទៅដល់សាលសិក្ខាសាលានៃព្រះវិហារសេវេនដេយអាត់វេនទីស្ទ។ ណាមួយនៅក្នុងតួនាទីថ្មីរបស់គាត់ គាត់ក៏ត្រូវបានគេអនុញ្ញាតឱ្យចេញពីបន្ទាយសឹងតែរៀងរាល់ថ្ងៃផងដែរ។ លោកសេគូលបានជឿថា ព្រះកំពុងតែប្រទានរង្វាន់តបស្នងទៅនឹងភាពស្មោះត្រង់របស់គាត់ហើយ។

លោកសេគូលបានសប្បាយរីករាយជាមួយនឹងកងយោធាថ្មីរបស់គាត់។ គាត់មិនដែលឈឺស្កាត់ម្ដងណាឡើយ។ គាត់គ្រាន់តែជ្រុះសក់របស់គាត់ប៉ុណ្ណោះ។ កាលពីមុន គាត់បានចូលបម្រើការនៅក្នុងកងយោធាដោយមានសក់ ប៉ុន្តែ ឥឡូវនេះ គាត់បានចាកចេញពីកងយោធាដោយគ្មានសក់វិញ។ គាត់បាននិយាយពាក្យពេចន៍ ដូចជាព្រះបានមានបន្ទូលថា «ប្រសិនបើអ្នកស្មោះត្រង់ចំពោះខ្ញុំ ខ្ញុំនឹងមើលថែរក្សាអ្នក ទោះបីជាអ្នកបានជួបនឹងបញ្ហារហូតដល់ជ្រុះសក់ក៏ដោយ ក៏បញ្ហានោះមិនជាថ្វីដែរ ពីព្រោះខ្ញុំមានម្ជុលសម្រាប់ឱ្យអ្នកពាក់ហើយ។

# ការរង់ចាំព្រះអម្ចាស់



ល្ងាចថ្ងៃបរិសុទ្ធ - ថ្ងៃសៅរ៍ ទី២៣ ខែមីនា ឆ្នាំ២០២៤

អំណានព្រះគម្ពីរសម្រាប់មេរៀនប្រចាំសប្តាហ៍នេះ៖ ទំនុកតម្កើង ២៧:១៤; ទំនុកតម្កើង ១៣១; ទំនុក-តម្កើង ១២៦; ទំនុកតម្កើង ៩២; ទំនុកតម្កើង ៥:៣, ពេត្រុសទី២ ១:១៩; វិវរណៈ ២២:១៦។

**ខចងចាំ៖ «ចូររង់ចាំព្រះយេហូវ៉ាចុះ ចូរមានកម្លាំង ហើយឲ្យចិត្តក្លាហានឡើង អើ គួររង់ចាំព្រះយេហូវ៉ាទៅ»** (ទំនុកតម្កើង ២៧:១៤)។

ឥឡូវនេះ យើងបានមកដល់សប្តាហ៍ចុងក្រោយនៃការសិក្សាកណ្ឌគម្ពីរទំនុកតម្កើងនេះហើយ។ យើងបានរៀនអំពីសេចក្តីពិតនៃព្រះគម្ពីរដ៏អស្ចារ្យជាច្រើន ដែលបានស្តីអំពីស្តេច និងពួកចៅហ្វាយរបស់យើង។ ទ្រង់គឺជាអ្នកបង្កើតយើងមក។ ទ្រង់បានសង្គ្រោះយើងចេញពីអំពើបាប។ ទ្រង់បានលើកលែងទោសឱ្យយើង។ ចិត្តរបស់យើងបានពេញទៅដោយសេចក្តីសង្ឃឹម ខណៈដែលយើងបានរង់ចាំឱ្យព្រះយេស៊ូវយាងត្រឡប់មកវិញ។ សារចុងក្រោយដែលយើងត្រូវសិក្សាចេញពីកណ្ឌគម្ពីរទំនុកតម្កើងនេះ គឺជាប្រធានបទនៃការរង់ចាំព្រះអម្ចាស់។

តើការរង់ចាំព្រះអម្ចាស់មានយ៉ាងណាដែរ? តើការរង់ចាំនេះមានន័យថា យើងត្រូវអង្គុយរង់ចាំមួយថ្ងៃពេញ ដោយមិនបានធ្វើអ្វីសោះដែរឬទេ? ជាការពិតណាស់ មិនមែនដូច្នោះឡើយ។ ការរង់ចាំព្រះអម្ចាស់គឺជាសកម្មភាពដែលយើងត្រូវធ្វើ។ ការរង់ចាំបានបង្ហាញសេចក្តីជំនឿ និងការជឿទុកចិត្តទៅលើព្រះ។ នៅពេលដែលយើងរង់ចាំព្រះអម្ចាស់ ចិត្តរបស់យើងនឹងមានពេញទៅដោយសេចក្តីសុខសាន្ត និងសេចក្តីសង្ឃឹម ទោះបីជានៅក្នុងគ្រាលំបាកក៏ដោយ។ នេះហើយគឺជាមូលហេតុដែលនាំឱ្យកវីបានមានប្រសាសន៍ថា «ទឹកភ្នែកនឹងមាននៅជាប់អស់មួយយប់ក៏បាន តែព្រឹកឡើង គង់នឹងមានសេចក្តីអំណរឡើងដែរ» (ទំនុកតម្កើង ៣០:៥)។ ហើយ «សូមឲ្យទូលបង្គំបានឮសេចក្តីសប្បុរសរបស់ទ្រង់នៅពេលព្រឹក ដ្បិតទូលបង្គំទុកចិត្តនឹងទ្រង់ សូមឲ្យទូលបង្គំបានស្គាល់ផ្លូវដែលគួរដើរ ពីព្រោះទូលបង្គំបានលើកព្រលឹងទៅរកទ្រង់» (ទំនុកតម្កើង ១៤៣:៨)។ សេចក្តីសង្ឃឹម និងការជឿទុកចិត្តនេះនឹងជំរុញឱ្យយើងខំប្រឹងធ្វើការបន្ថែមទៀត ដើម្បីបម្រើព្រះសង្គ្រោះមនុស្សលោកនៅជុំវិញយើង (ទំនុកតម្កើង ១២៦:៦; ម៉ាថាយ ៩:៣៦-៣៨)។ នៅពេលដែលយើងបានរង់ចាំព្រះអម្ចាស់ នោះយើងមិនដែលមានអារម្មណ៍សោកស្តាយនោះឡើយ។ នោះគឺដោយសារតែព្រះអម្ចាស់បានរក្សាសេចក្តីសន្យាទាំងអស់របស់ទ្រង់ (ទំនុកតម្កើង ៣៧:៧-១១, ៣៤; ទំនុកតម្កើង ៧១:១; ទំនុកតម្កើង ១១៩:១៣៧, ១៣៨)។ ដូច្នេះហើយ យើងអាចប្រាកដបានថា ព្រះនឹងប្រទានរង្វាន់ដល់យើង ចំពោះការដែលយើងបានរង់ចាំទ្រង់។

# ការត្រាស់ហៅឱ្យរង់ចាំព្រះអម្ចាស់

សូមអានខគម្ពីរទំនុកតម្កើង ២៧:១៤; ទំនុកតម្កើង ៣៧:៧, ៩, ៣៤; ទំនុកតម្កើង ៣៩:៧; ទំនុកតម្កើង ៤០:១; ទំនុកតម្កើង ៦៩:៦; កាឡាទី ៥:៥ និងរ៉ូម ៨:១៨-២៥។ តើខទាំងនេះបានសូមឱ្យរាស្ត្ររបស់ព្រះធ្វើអ្វីខ្លះ?

_______________________________________________

_______________________________________________

គ្មានអ្នកណាម្នាក់ចូលចិត្តរង់ចាំនោះទេ។ ពីព្រោះការរង់ចាំអាចធ្វើឱ្យយើងមានភាពតានតឹងបាន។ មានពេលខ្លះ យើងទាំងអស់គ្នាត្រូវតែរង់ចាំរបស់ដែលយើងបានទូលសូម។ ប្រហែលជាយើងត្រូវរង់ចាំ ដូចជាយើងតម្រង់ជួរនៅក្នុងហាងយ៉ាងដូច្នោះដែរ។ ឬដូចជាយើងបានរង់ចាំស្តាប់ដំណឹងថ្មីៗចេញពីគ្រូពេទ្យរបស់យើង អំពីសុខភាពរបស់យើងផងដែរ។ យើងតែងតែមិនចូលចិត្តធ្វើបែបនេះទេមែនទេ?

ចុះចំណែកឯការរង់ចាំព្រះអម្ចាស់វិញនោះ? កណ្ឌគម្ពីរទំនុកតម្កើងបានពិពណ៌នាអំពីការរង់ចាំព្រះអម្ចាស់។ បទគម្ពីរដែលនៅសេសសល់ក៏បានពិពណ៌នាអំពីការរង់ចាំព្រះអម្ចាស់នេះដែរ។ តើអ្វីទៅគឺជាអាថ៌កំបាំងនៅក្នុងការរង់ចាំព្រះអម្ចាស់នោះ? យើងមិនត្រូវលះបង់សេចក្តីសង្ឃឹមរបស់យើងនោះឡើយ។ យើងមិនត្រូវខ្លាចថា ព្រះមិនបានរក្សាសេចក្តីសន្យារបស់ទ្រង់ ឬនៅទីនោះសម្រាប់ទ្រង់នោះឡើយ។ នៅពេលដែលយើងរង់ចាំព្រះអម្ចាស់ យើងក៏ត្រូវតែដឹងថា យើងអាចជឿទុកចិត្តទៅលើទ្រង់បានថា ទ្រង់នឹងដោះស្រាយបញ្ហារបស់យើង។ យើងអាចប្រាកដបានថា ទ្រង់នឹងដោះស្រាយបញ្ហាទាំងអស់ដើម្បីឱ្យយើងបានប្រសើរឡើង។

ការរង់ចាំព្រះអម្ចាស់គឺមានអត្ថន័យលើសពីការរង់ចាំឱ្យទ្រង់ធ្វើអ្វីមួយសម្រាប់យើងទៅទៀត។ ការរង់ចាំព្រះអម្ចាស់គឺជាការស្តីអំពីការចង់បានព្រះអង្គទ្រង់ដោយផ្ទាល់។ យើងចង់បានអ្នកមាន មិនមែនចង់បានអំណោយ ដែលទ្រង់បានសន្យាជាមួយនឹងយើងនោះឡើយ។ ការរង់ចាំព្រះក៏ដូចជាបុគ្គលម្នាក់ស្រេកទឹកនៅក្នុងទីរហោស្ថានយ៉ាងដូច្នោះដែរ (ទំនុកតម្កើង ៦៣:១)។ ករីបានរង់ចាំឱ្យព្រះប្រទានព្រះពរជាច្រើនដល់គាត់។ ប៉ុន្តែ លើសពីការចង់បានព្រះពរបន្ថែមទៀតនេះ ករីក៏មានចិត្តនៅជាប់ជាមួយនឹងព្រះផងដែរ។ ទំនាក់ទំនងជាមួយនឹងព្រះមានសារៈសំខាន់ជាងព្រះពរទាំងអស់ដែលគាត់ត្រូវការ ឬចង់បាននៅក្នុងជីវិតរបស់គាត់ទៅទៀត។

លោកប៉ុលបានប្រាប់យើងនៅក្នុងកណ្ឌគម្ពីររ៉ូមយ៉ាងដូច្នេះថា របស់គ្រប់យ៉ាងដែលមាននៅក្នុងធម្មជាតិបានរង់ចាំឱ្យព្រះយេស៊ូវបង្កើតផែនដីថ្មី។ ធម្មជាតិទាំងអស់បានរង់ចាំព្រះយាងមកជួបជាមួយនឹងរាស្ត្ររបស់ទ្រង់នៅក្នុងគ្រាចុងក្រោយ។ លោកប៉ុលបានសរសេរថា៖ «ដ្បិតសេចក្តីទន្ទឹងរបស់ជីវិតទាំងឡាយ នោះរង់ចាំតែពួកកូនរបស់ព្រះលេចមកឲ្យឃើញប៉ុណ្ណោះទេ» (រ៉ូម ៨:១៩)។ សេចក្តីសន្យានេះគឺជាសេចក្តីសន្យាដ៏អស្ចារ្យបំផុត។

ខណៈដែលយើងកំពុងតែរង់ចាំព្រះយេស៊ូវយាងត្រឡប់មកវិញ ទន្ទឹមគ្នានេះ ព្រះអម្ចាស់ក៏បានបន្តគង់នៅជាមួយនឹងរាស្ត្ររបស់ទ្រង់ផងដែរ។ ទ្រង់បានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ឱ្យមកសណ្ឋិតនៅក្នុងចិត្តរបស់ពួកគេ។

ព្រះយេស៊ូវបានសូមឱ្យយើងធ្វើជាស្មរបន្ទាល់របស់ទ្រង់ (កិច្ចការ ១:៤-៨)។ ទ្រង់ចង់ឱ្យយើងប្រាប់មនុស្សគ្រប់គ្នាអំពីដំណឹងល្អដែលថា ទ្រង់បានសង្គ្រោះពួកគេចេញពីអំពើបាប ដោយស្អាងជីវិតរបស់ពួកគេជាថ្មី។ ទ្រង់ក៏នឹងបង្កើតផែនដីថ្មីដែរ។ ពេលនោះគឺជាពេលដែលយើងជាក្រុមជំនុំកំពុងតែរង់ចាំឱ្យថ្ងៃនោះមកដល់។ នៅក្នុងនាមជាគ្រីស្ទានសេវេនដេយអាត់វេនទីស្ទ នាមរបស់យើងក៏បានរួមបញ្ចូលនូវគោលគំនិតនៃសេចក្តីសង្ឃឹមដែលយើងបានរង់ចាំនោះដែរ។ យើងបានរង់ចាំព្រះ ប៉ុន្តែ យើងក៏បានដឹងថា ទ្រង់នឹងប្រទានរង្វាន់ឱ្យយើងសម្រាប់ការរង់ចាំរបស់យើងដែរ។

# ទារកដែលនៅជាមួយនឹងម្ដាយរបស់គាត់

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក១៣១។ តើកំណាព្យនេះបានបង្រៀនយើងអំពីទំនាក់ទំនងដែលយើងមានជាមួយនឹងព្រះនោះយ៉ាងដូចម្ដេចដែរ?**

___

___

រាស្ត្ររបស់ព្រះបានរស់នៅលើផែនដី ដែលមានពេញទៅដោយអំពើបាប និងការរងទុក្ខ។ កវីដែលបានសរសេរបទគម្ពីរទំនុកតម្កើង ជំពូក១៣១ បានយល់អំពីសេចក្ដីពិតដ៏អាក្រក់នេះ។ នេះហើយជាមូលហេតុដែលនាំឱ្យគាត់ត្រេកអរ ដោយបាននឹកចាំថា គាត់គឺជាកូនរបស់ព្រះ។ កវីបានដឹងថា គាត់ត្រូវតែពឹងផ្អែកទៅលើព្រះសម្រាប់រឿងគ្រប់យ៉ាងនៅក្នុងជីវិតនេះ។ គោលគំនិតនេះបានដកហូតសេចក្ដីអំនួតទាំងអម្បាលម៉ានចេញពីចិត្តរបស់យើង។ កវីបានសារភាពថា សេចក្ដីអំនួតគ្មានតម្លៃអ្វីទាល់តែសោះ។ ដ្បិតសេចក្ដីអំនួតគឺជាសេចក្ដីកុហកមួយបែប។ សេចក្ដីអំនួតបានធ្វើឱ្យមនុស្សគិតតែពីខ្លួនឯង។ ចិត្តដែលមានពេញទៅដោយសេចក្ដីអំនួតគឺជាចិត្តដែលប្រកបដោយភាពគ្រោះថ្នាក់។ បុគ្គលម្នាក់ដែលមានសេចក្ដីអំនួតនៅក្នុងចិត្តរបស់គាត់មិនអាចសម្លឹងឃើញថា គាត់ត្រូវការព្រះបានឡើយ។

កូនរបស់ព្រះបានមើលឃើញថា ពួកគេត្រូវការព្រះ (ទំនុកតម្កើង ១២៣:១, ២)។ កូនរបស់ព្រះគ្មានសេចក្ដីអំនួតនៅក្នុងចិត្តរបស់ពួកគេនោះឡើយ ដោយសារតែពួកគេបានយល់ថា ព្រះទ្រង់អស្ចារ្យ និងមានអំណាចគ្រប់ព្រះចេស្ដាទាំងអស់។ កវីបានមានប្រសាសន៍ថា «ឱព្រះយេហូវ៉ាអើយ ចិត្តទូលបង្គំមិនមែនឆ្មើងឆ្មៃ ហើយភ្នែកទូលបង្គំក៏មិនប្រកាន់យស ទូលបង្គំមិនយកចិត្តទុកដាក់ក្នុងការដ៏ធំ ឬក្នុងដំណើរដែលអស្ចារ្យហួសល្បត់ទូលបង្គំឡើយ។ មានតែព្រះមួយគត់ដែលអាចធ្វើការ «អស្ចារ្យ» បាន។ ពីព្រោះកិច្ចការរបស់ទ្រង់គឺជាកិច្ចការអាថ៌កំបាំង។ យើងមិនអាចយល់កិច្ចការទាំងនោះទាំងស្រុងបានឡើយ។ នៅក្នុងខគម្ពីរទំនុកតម្កើង ១៣១:២ កវីបានប្រាប់យើងបន្ថែមទៀត អំពីទំនាក់ទំនងដែលគាត់មានជាមួយនឹងព្រះ។ ទ្រង់បានប្រៀបធៀបអារម្មណ៍របស់គាត់ទៅនឹងទារកដែលនៅជាមួយនឹងម្ដាយរបស់គាត់ បន្ទាប់ពីគាត់បានបៅដោះរួចយ៉ាងដូច្នោះដែរ។ គាត់បានមានប្រសាសន៍ថា «ទូលបង្គំបានរំងាប់ ហើយព្រលួងព្រលឹងទូលបង្គំជាស្រេច ដូចជាក្មេងដែលម្ដាយបានផ្ដាច់ដោះឲ្យ គឺដូចជាក្មេងដែលលែងដោះនៅជាមួយនឹងម្ដាយ អើ ព្រលឹងនៅក្នុងខ្លួនទូលបង្គំ ប្រៀបដូចជាកូនដែលលែងដោះហើយ» (ទំនុកតម្កើង ១៣១:២)។ រូបស័ព្ទនៅត្រង់នេះគឺជារូបស័ព្ទមួយដ៏មានអំណាច។ ដ្បិតសេចក្ដីស្រឡាញ់របស់ព្រះបានផ្ដល់ សេចក្ដីសុខសាន្តដល់កវីនៅក្នុងជំពូកនេះ ដូចជាទារកដែលម្ដាយបានបីត្រកងយ៉ាងដូច្នោះដែរ។

កវីបានជឿទុកចិត្តទៅលើព្រះដូចជាទារកមានអារម្មណ៍កក់ក្ដៅជាមួយនឹងម្ដាយរបស់គាត់យ៉ាងដូច្នេះដែរ។ សេចក្ដីជំនឿនេះមានប្រភពចេញមកពីសេចក្ដីជំនឿ។ នៅពេលដែលសេចក្ដីជំនឿរបស់យើងត្រូវដាក់ទៅក្នុងការសាកល្បង នោះយើងនឹងបានលូតលាស់ឡើងនៅក្នុងអំណាចខាងឯវិញ្ញាណជាមិនខាន។ យើងបានរៀននៅក្នុងអំឡុងពេលនៃការឈឺចាប់ និងនៅក្នុងអំឡុងពេលនៃគ្រាលំបាកដែលយើងអាចជឿទុកចិត្តទៅលើព្រះបាន។ ដ្បិតទ្រង់តែងតែរក្សាសេចក្ដីសន្យារបស់ទ្រង់ជានិច្ច។

កវីមិនបានបញ្ចប់កំណាព្យរបស់គាត់ជាមួយនឹងគោលគំនិតអំពីខ្លួនគាត់នោះទេ។ ទ្រង់បានបញ្ចប់កំណាព្យរបស់គាត់ជាមួយនឹងគោលគំនិតអំពីរាស្ត្ររបស់ព្រះវិញ។ ទន្ទឹមគ្នានេះ ព្រះក៏ចង់ឱ្យគិតអំពីក្រុមជំនុំរបស់ទ្រង់ផងដែរ។ ពោលគឺទ្រង់ចង់ឱ្យយើងប្រើនូវបទពិសោធន៍ដែលយើងមានជាមួយនឹងទ្រង់ ដើម្បីជួយឱ្យក្រុមជំនុំរបស់ទ្រង់បានរឹងមាំឡើង។ តើ «បទពិសោធន៍របស់យើង» មានយ៉ាងណាដែរ? គឺមានន័យថា ព្រះចង់ឱ្យយើងចែករំលែកជាមួយនឹងអ្នកដទៃនូវរឿងដែលយើងបានចែករំលែកជាមួយនឹងសមាជិកក្រុមជំនុំ។ រឿងរបស់យើងដែលស្ដីអំពីកិច្ចការដែលព្រះយេស៊ូវបានធ្វើសម្រាប់យើងនោះបានជួយលើកទឹកចិត្តក្រុមជំនុំ ដែលមានភាពកម្សោយខាងឯសេចក្ដីជំនឿ។

# ការនាំយកដំណាំមកថ្វាយ

**តើអ្វីទៅដែលបានផ្ដល់កម្លាំង និងសេចក្ដីសង្ឃឹមដល់រាស្ត្ររបស់ព្រះនោះ? សូមអានបទគម្ពីរទំនុកតម្កើង ជំពូក១២៦ សម្រាប់ចម្លើយ។ តើយើងបានរៀនក្បួនច្បាប់សំខាន់អ្វីខ្លះនៅក្នុងកំណាព្យនេះ? តើយើងអាចដើរតាមក្បួនច្បាប់សំខាន់នេះនៅក្នុងជីវិតរបស់យើងដោយរបៀបណា?**

___

___

នៅពេលដែលយើងបានគិតអំពីការអស្ចារ្យដែលព្រះបានធ្វើកាលពីមុន នោះយើងនឹងមានក្ដីសង្ឃឹមសម្រាប់ពេលអនាគត។ នៅពេលដែលព្រះបានសង្គ្រោះរាស្ត្ររបស់ទ្រង់កាលពីសម័យមុន រាស្ត្ររបស់ទ្រង់ក៏បានគិតថា ពួកគេបានយល់សប្តិទាំងថ្ងៃដែរ។ បទពិសោធន៍នេះគឺជារឿងដ៏អស្ចារ្យបំផុត។ ជាការពិតណាស់ បទពិសោធន៍នេះក៏ដូចជាសុបិនអាក្រក់មួយសម្រាប់ខ្មាំងសត្រូវរបស់សាសន៍អ៊ីស្រាអែលផងដែរ (អេសាយ ២៩:៧, ៨)។ នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក១២៦ តើលោកអ្នកបានឃើញថា មនុស្សដែលបានសរសើរតម្កើងព្រះ ដោយសារតែទ្រង់បានសង្គ្រោះសាសន៍អ៊ីស្រាអែលកាលពីមុន (ទំនុកតម្កើង ១២៦:១) គឺជាពួកអ្នកដែលបានជាប់ជាឈ្លើយនៅក្នុងទឹកដីនៃសាសន៍ដទៃដែរឬទេ?

ការនឹកចាំអំពីអតីតកាលបានផ្ដល់សេចក្ដីសង្ឃឹមដល់រាស្ត្ររបស់ព្រះនៅក្នុងគ្រាចុងក្រោយ។ នៅក្នុងខគម្ពីរទំនុកតម្កើង ១២៦:៤ ពួកបណ្ដាជនបានអធិស្ឋានយ៉ាងដូច្នេះថា «ឱព្រះយេហូវ៉ាអើយ សូមនាំពួកយើងខ្ញុំដែលជាឈ្លើយ ឲ្យត្រឡប់មកវិញ ដូចជាទឹកជ្រោះនៅស្រុកខាងត្បូង» (ទំនុកតម្កើង ១២៦:៤)។ បន្ទាប់មក កវីបានប្រើរូបស័ព្ទមួយស្ដីអំពីការបណ្ដុះគ្រាប់ពូជនៅក្នុងគ្រាជូរចត់ តែបានប្រមូលផលដំណាំនៅក្នុងគ្រាសប្បាយរីករាយវិញ (ទំនុកតម្កើង ១២៦:៥, ៦)។ រូបស័ព្ទនេះបានបង្ហាញយើងអំពីសេចក្ដីសន្យាដ៏មានអំណាចមួយដែលថា ព្រះនឹងដឹកនាំរាស្ត្ររបស់ទ្រង់ចេញពីគ្រាលំបាកឆ្ពោះទៅរកអនាគតដ៏មានសុភមង្គលវិញ។

អ្នកសរសេរព្រះគម្ពីរតែងតែយកការប្រមូលផលនេះមកធ្វើជារូបស័ព្ទតំណាងឱ្យការបង្រៀនសាសន៍អ៊ីស្រាអែលនូវសេចក្ដីពិតដ៏សំខាន់មួយនៅក្នុងព្រះគម្ពីរ។ ពោលគឺពួកបណ្ដាជនបានខិតខំដាំគ្រាប់ពូជ និងភ្ជួររាស់ដីស្រែ ដីចំការទំពាំងបាយជូរ និងដីធ្វើសួនជាដើម។ ពួកគេបានថែរក្សាដំណាំ ផ្លែឈើ និងចំការទំពាំងបាយជូររបស់ពួកគេ។ នៅចុងរដូវនៃការដាំដុះរបស់ពួកគេ ពួកបណ្ដាជនបានរីករាយជាមួយនឹងការប្រមូលផលយ៉ាងបរិបូណ៌។ ទន្ទឹមគ្នានេះ នៅសព្វថ្ងៃនេះ រាស្ត្ររបស់ព្រះក៏បានខិតខំធ្វើការ ដើម្បីនគររបស់ទ្រង់ដែរ។ ការរងទុក្ខ និងការខិតខំរបស់ពួកគេមិនយូរមិនឆាប់នឹងបានទទួលរង្វាន់។ បន្ទាប់មកចិត្តរបស់ពួកគេនឹងមានពេញទៅដោយសេចក្ដីអំណរ។

ការយាងមកជាលើកទី២ក៏មានដូចជាការប្រមូលផលយ៉ាងធំផងដែរ។ បន្ទាប់ពីពេលនោះមក ព្រះយេស៊ូវនឹងចាប់ផ្ដើមនគររបស់ទ្រង់នៅលើផែនដីនេះ (អេម៉ុស ៩:១៣-១៥; ម៉ាថាយ ៩:៣៧)។ ប៉ុន្តែយើងត្រូវតែរង់ចាំរហូតទាល់តែពេលនោះមកដល់សិន។ យើងក៏ត្រូវតែរង់ចាំមើលរឿងអស្ចារ្យទាំងអស់ដែលត្រូវកើតឡើង ដោយសារតែកិច្ចការដែលយើងបានធ្វើសម្រាប់ទ្រង់នៅពេលឥឡូវនេះ។

**សូមគិតអំពីគ្រាមួយ នៅពេលដែលលោកអ្នកបានឃើញព្រះអម្ចាស់ធ្វើការនៅក្នុងជីវិតរបស់លោកអ្នក ឬនៅក្នុងជីវិតរបស់អ្នកដទៃ។ តើបទពិសោធន៍នេះបានផ្ដល់សេចក្ដីសង្ឃឹមដល់លោកអ្នកនៅក្នុងគ្រាលំបាក នៅពេលដែលលោកអ្នកកំពុងតែឈឺចាប់នោះដោយរបៀបណា?**

# ការសម្រាកនៅក្នុងថ្ងៃសប្បាតហ៍របស់ព្រះ

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក៩២។ បទគម្ពីរទំនុកតម្កើង ជំពូក៩២ គឺជាចម្រៀងមួយបទសម្រាប់ថ្ងៃសប្បាតហ៍។ នៅក្នុងសម័យព្រះគម្ពីរ រាស្ត្ររបស់ព្រះបានច្រៀងចម្រៀងនេះនៅថ្ងៃសប្បាតហ៍។ តើចម្រៀងនេះបានរៀបរាប់អំពីរឿងសំខាន់២យ៉ាងអ្វីខ្លះ?**

_______________________________________________________________________

_______________________________________________________________________

បទគម្ពីរទំនុកតម្កើង ជំពូក៩២ បានសរសើរតម្កើងព្រះចំពោះរបស់គ្រប់យ៉ាងដែលទ្រង់បានបង្កើត (ទំនុកតម្កើង ៩២:៤, ៥)។ កំណាព្យនេះក៏បានសរសើរតម្កើងព្រះ ដោយសារតែទ្រង់បានឈ្នះទាស់នឹងខ្មាំងសត្រូវរបស់ទ្រង់ ហើយការទាស់នោះក៏ជាការជំនុំជម្រះយ៉ាងយុត្តិធម៌ផងដែរ (ទំនុកតម្កើង ៩២:៧-១៥)។ ដូច្នេះហើយ យើងបានឃើញថា បទគម្ពីរទំនុកតម្កើង ជំពូក៩២ បានសរសើរតម្កើង ព្រះសម្រាប់កិច្ចការដែលទ្រង់បានធ្វើកាលពីមុន ហើយបទគម្ពីរនេះក៏បានសរសើរតម្កើងទ្រង់សម្រាប់សេចក្តីសុខសាន្តដែលទ្រង់នឹងនាំមកនៅពេលអនាគតផងដែរ។

មនុស្សលោកអាចសប្បាយរីករាយជាមួយនឹងការសម្រាកនៅក្នុងថ្ងៃសប្បាតហ៍បាន ពីព្រោះព្រះអម្ចាស់គឺជាព្រះដ៏ខ្ពស់បំផុត (ទំនុកតម្កើង ៩២:១)។ ទន្ទឹមគ្នានេះ ព្រះអម្ចាស់ក៏បានយាងចុះមកសង្គ្រោះអ្នកដែលបានសូមឱ្យទ្រង់ជួយដល់ពួកគេផងដែរ។ អ្វីៗគ្រប់យ៉ាងដែលព្រះអម្ចាស់បានបង្កើតមក គួរតែបានបំពេញចិត្តរបស់យើងឱ្យស្រឡាញ់ទ្រង់។ យើងគួរតែថ្វាយបង្គំទ្រង់ ពីព្រោះទ្រង់គឺជាព្រះអាទិកររបស់យើង និងជាអ្នកសង្គ្រោះយើង។

នៅក្នុងខគម្ពីរទំនុកតម្កើង ៩២:១០ កវីបានមានប្រសាសន៍ថា «ទូលបង្គំមានប្រេងថ្មីចាក់លាបលើខ្លួនហើយ»។ ប្រេងថ្មីគឺជារូបស័ព្ទដែលបានបង្ហាញសេចក្តីស្រឡាញ់ដែលកវីមានចំពោះព្រះ។ កវីបានសន្យាថា គាត់នឹងមប្រើព្រះឱ្យអស់ពីចិត្តរបស់គាត់។ នៅក្នុងសម័យគម្ពីរសញ្ញាចាស់ ពួកហោរារបស់ព្រះបានចាក់ប្រេងពិសេសនៅលើព្រះកេសររបស់ស្តេច និងសម្តេចសង្ឃ។ ប្រេងបានបង្ហាញថា ពួកបណ្តាជនទាំងនេះបានជ្រើសរើសបម្រើព្រះអម្ចាស់ (និក្ខមនំ ៤០:៥; សាំយូអែលទី១ ១០:១)។ កវីបានប្រើរូបស័ព្ទនេះដើម្បីបង្ហាញយើងថា គាត់មានបំណងចង់យករូបកាយរបស់គាត់មកធ្វើជាយញ្ញបូជាថ្វាយព្រះ។ ប្រេងបានបង្ហាញយើងថា កវីចង់ឱ្យថ្វាយជីវិតរបស់គាត់ដល់ព្រះទាំងស្រុង (រ៉ូម ១២:១)។

យើងមិនគួរភ្ញាក់ផ្អើល ដោយបានរកឃើញគោលគំនិត ស្តីអំពីការថ្វាយជីវិតរបស់យើងដល់ព្រះទាំងស្រុង នៅក្នុងកំណាព្យមួយស្តីអំពីថ្ងៃសប្បាតហ៍។ ថ្ងៃសប្បាតហ៍គឺជាសញ្ញាដែលព្រះធ្វើឱ្យរាស្ត្ររបស់ទ្រង់បានបរិសុទ្ធ (និក្ខមនំ ៣១:១៣)។ ថ្ងៃសប្បាតហ៍គឺជាទីសំគាល់នៃសេចក្តីសន្យាដ៏នៅអស់កល្ប ដែលព្រះបានតាំងឡើងជាមួយនឹងរាស្ត្ររបស់ទ្រង់ (អេសេគាល ២០:២០)។ ការសម្រាកនៅក្នុងថ្ងៃសប្បាតហ៍មានសារៈសំខាន់ដល់រាស្ត្ររបស់ព្រះណាស់ ពីព្រោះថ្ងៃនេះបានជួយឱ្យពួកគេជឿទុកចិត្តទៅលើព្រះអម្ចាស់ ព្រមទាំងជួយឱ្យពួកគេរង់ចាំឱ្យទ្រង់បំពេញសេចក្តីសន្យារបស់ទ្រង់ផងដែរ (ហេព្រើ ៤:១-១០)។

**សូមអានបទគម្ពីរទំនុកតម្កើង ជំពូក៩២ ម្តងទៀត។ តើកំណាព្យនេះបានផ្តល់សេចក្តីសង្ឃឹមអស្ចារ្យអ្វីដែរដល់យើង?**

# សេចក្តីអំណរដែលបានទទួលនៅពេលព្រឹក

**សូមអានខគម្ពីរទំនុកតម្កើង ៥:៣; ទំនុកតម្កើង ៣០:៥; ទំនុកតម្កើង ៤៩:១៤; ទំនុកតម្កើង ៥៩:១៦; ទំនុកតម្កើង ៩២:២; ទំនុកតម្កើង ១១៩:១៤៧; ពេត្រុសទី២ ១:១៩ និងវិវរណៈ ២២:១៦។ យោងទៅតាមកំណាព្យទាំងនេះ តើនៅពេលណានៅក្នុងមួយរយៈថ្ងៃ ដែលបានប្រើរូបស័ព្ទមកតំណាងឱ្យផែនការ ដែលព្រះបានរៀបចំ ដើម្បីសង្គ្រោះយើងនោះ?**

_______________________________________________

_______________________________________________

នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង ពេលព្រឹកគឺជាគ្រាមួយ នៅពេលមនុស្សលោកបានរង់ចាំឱ្យព្រះយាងមកសង្គ្រោះពួកគេ។ ពេលព្រឹកក៏ជារូបស័ព្ទមួយតំណាងឱ្យព្រះគុណ និងព្រះពររបស់ទ្រង់ផងដែរ។ ពេលព្រឹកបានបញ្ចប់ពេលយប់ដ៏យូរ។ ពេលយប់គឺជារូបស័ព្ទតំណាងឱ្យបញ្ហា និងភាពសោកសៅ (ទំនុកតម្កើង ១៣០:៥, ៦)។ នៅក្នុងបទគម្ពីរទំនុកតម្កើង ជំពូក១៤៣ នៅពេលដែលព្រះសង្គ្រោះរាស្ត្ររបស់ទ្រង់ នោះទ្រង់នឹងបង្វែរស្ថានការឡើងវិញ។ ពោលគឺទ្រង់នឹងបញ្ចប់អំពើបាប និងសេចក្តីស្លាប់ (ទំនុកតម្កើង ១៤៣:៣)។ ទ្រង់នឹងប្រែសេចក្តីងងឹតឱ្យទៅជាពន្លឺនៅពេលព្រឹកវិញ (ទំនុកតម្កើង ១៤៣:៧-១០)។

**សូមអានខគម្ពីរម៉ាកុស ១៦:១-៨។ តើខដែលស្រង់ពីកណ្ឌគម្ពីរម៉ាកុសទាំងនេះបានចែងថា មានហេតុការណ៍អ្វីខ្លះបានកើតឡើងនៅពេលព្រឹកនោះ?**

ព្រះយេស៊ូវបានរស់ពីស្លាប់ឡើងវិញនៅពេលព្រឹកនៃថ្ងៃ បន្ទាប់ពីទ្រង់ត្រូវបានឆ្កាងនៅលើឈើឆ្កាង។ នៅពេលដែលព្រះយេស៊ូវបានរស់ពីស្លាប់ឡើងវិញ ទ្រង់បានរៀបចំមនុស្សជាតិឱ្យបានសង្គ្រោះតាមរយៈព្រះនាមរបស់ទ្រង់។ នៅពេលដែលព្រះយេស៊ូវរស់ពីស្លាប់ឡើងវិញ សិស្សរបស់ទ្រង់បានយល់ច្បាស់អំពីសេចក្តីសន្យានៅក្នុងបទគម្ពីរទំនុកតម្កើង ៣០:៥ ដែលបានចែងយ៉ាងដូច្នេះថា៖ «ដ្បិតសេចក្តីខ្ញាល់របស់ទ្រង់នៅតែ១ភ្លែតទេ តែព្រះគុណនៃទ្រង់ នោះនៅអស់១ជីវិតវិញ ទឹកភ្នែកនឹងមាននៅជាប់អស់មួយយប់ក៏បាន តែព្រឹកឡើង គង់នឹងមានសេចក្តីអំណរឡើងដែរ» (ទំនុកតម្កើង ៣០:៥)។ ព្រះគុណ និងសេចក្តីស្រឡាញ់របស់ព្រះគឺជារឿងតែមួយគត់ ដែលអាចផ្លាស់ប្តូរទឹកភ្នែករបស់យើងទៅជាក្តីអំណរបាន (ទំនុកតម្កើង ៣០:៥, ៧)។

ព្រះយេស៊ូវក៏មាននាមថា ជាផ្កាយព្រឹកដ៏ភ្លឺចិញ្ចែងផងដែរ (វិវរណៈ ២២:១៦)។ ផ្កាយព្រឹកបានប្រកាសពីការចាប់ផ្តើមនៃថ្ងៃថ្មី។ យើងបានរង់ចាំឱ្យព្រះយេស៊ូវដែលជាផ្កាយព្រឹកបានផ្តើមនគររបស់ទ្រង់។ ទន្ទឹមគ្នានេះ សេចក្តីងងឹត សេចក្តីអាក្រក់ ឬសេចក្តីស្លាប់ក៏លែងមានទៀតដែរ (វិវរណៈ ២១:១-៨, ២៥)។ ដ្បិតយើងបានរង់ចាំឱ្យពេលវេលានេះមកដល់យ៉ាងអស់ពីចិត្តរបស់យើងលើសពីអ្វីទាំងអស់។ ជាការពិតណាស់ ការរង់ចាំនេះពិតជាមានតម្លៃណាស់។

«ព្រះយេស៊ូវបានយាងចេញពីផ្នូររបស់លោកយ៉ូសែប។ ទ្រង់បានប្រកាសថា ‵ខ្ញុំជាសេចក្តីរស់ឡើងវិញ និងជាជីវិត′ (បកប្រែថ្មី)។ មានតែព្រះមួយគត់ដែលអាចមានបន្ទូលនូវពាក្យពេចន៍ទាំងនេះបាន។ មនុស្សគ្រប់គ្នាដែលបានរស់ដោយសារព្រះក៏បានធ្វើដូច្នេះដែរ។ ដ្បិតយើងបានពឹងផ្អែកទៅលើព្រះ ដើម្បីជីវិតមួយនេះ។ ចាប់ពីទេវតាដ៏ខ្លាំងបំផុតរហូតទៅដល់ទារក នោះយើងទាំងអស់គ្នាត្រូវតែទទួលបានជីវិតរបស់យើងមកពីព្រះ។ ពីព្រោះទ្រង់គឺជាព្រះមួយអង្គជាមួយនឹងព្រះ។ ហើយមានទ្រង់មួយគត់ដែលអាចមានបន្ទូលថា ‵ខ្ញុំអាចលះបង់ជីវិតរបស់ខ្ញុំបាន ខ្ញុំក៏អាចទទួលបានអំណាចរស់ពីស្លាប់ឡើងម្តងបានដែរ′ (បកប្រែថ្មី)។ នៅក្នុងនាមជាព្រះ ព្រះយេស៊ូវបានទទួលអំណាចរស់ពីស្លាប់ឡើងវិញ»។ ដកស្រង់ពី Ellen G. White, *The Desire of Ages*, page 785, adapted។

**ការសិក្សាបន្ថែម៖** សូមអាន Ellen G. White, "Growing up Into Christ," pages 67-75, in *Steps to Christ*។

កណ្ឌគម្ពីរទំនុកតម្កើងបានសូមឱ្យយើងរង់ចាំព្រះអម្ចាស់ (ទំនុកតម្កើង ៣៧:៧)។ នៅពេលដែលយើងពិបាកនៅក្នុងការរង់ចាំ នោះយើងគួរតែនឹកចាំពីសិស្សរបស់ព្រះយេស៊ូវនៅថ្ងៃដែលព្រះយេស៊ូវបានយាងត្រឡប់ទៅស្ថានសួគ៌វិញ (កិច្ចការ ១:៤-១១)។ ព្រះយេស៊ូវត្រូវបានលើកឡើងទៅលើមេឃនៅមុខភ្នែករបស់ពួកគេ។ ព្រះបានទុកសិស្សរបស់ទ្រង់នៅលើផែនដីនេះ ដើម្បីរង់ចាំឱ្យទ្រង់យាងត្រឡប់មកវិញនៅថ្ងៃណាមួយនាពេលអនាគត។ ព្រះយេស៊ូវបានបង្គាប់ឱ្យសិស្សរបស់ទ្រង់រង់ចាំសេចក្តីសន្យាដែលព្រះវរបិតាបានសន្យាថា ទ្រង់នឹងប្រទានព្រះវិញ្ញាណបរិសុទ្ធដល់ពួកគេ។ ពួកសិស្សបានត្រឡប់មកកាន់ទីក្រុងយេរូសាឡិមវិញ ហើយពួកគេបានដឹងរឿងគ្រប់យ៉ាងដែលព្រះយេស៊ូវបានបង្គាប់ឱ្យពួកគេធ្វើ។ ពួកគេបានរង់ចាំអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។ បន្ទាប់មក ពួកគេបានចែកចាយដំណឹងល្អទៅកាន់មនុស្សនៅក្នុងទីក្រុងយេរូសាឡិម។

សេចក្តីបង្គាប់ដែលព្រះអម្ចាស់របស់យើងបានប្រាប់ឱ្យយើងរង់ចាំទ្រង់ នឹងអាចសម្រេចទៅបានលុះត្រាតែយើងអនុញ្ញាតឱ្យទ្រង់ធ្វើកិច្ចការរបស់ទ្រង់នៅក្នុងចិត្តរបស់យើងជាមុនសិន។ ដ្បិតព្រះអម្ចាស់នឹងបញ្ជូនព្រះវិញ្ញាណរបស់ទ្រង់ឱ្យមករស់នៅក្នុងចិត្តរបស់យើង។ ព្រះវិញ្ញាណបានជួយឱ្យយើងមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះ។ ទំនាក់ទំនងជិតស្និទ្ធផ្ទាល់ខ្លួនដែលយើងមានជាមួយនឹងព្រះ នឹងផ្តល់កម្លាំងឱ្យយើងរង់ចាំព្រះយេស៊ូវវិញ។ «'ដ្បិតគឺជាព្រះហើយ ដែលបណ្តាលចិត្តអ្នករាល់គ្នា ឲ្យមានទាំងចំណង់ចង់ធ្វើ ហើយឲ្យបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ'» (ភីលីព ២:១៣)។ បន្ទាប់មកយើងនឹងធ្វើកិច្ចការទៅតាមរបៀបដែលព្រះយេស៊ូវបានធ្វើ។ យើងនឹងបានទទួលព្រះវិញ្ញាណតែមួយពីទ្រង់។ យើងនឹងបានស្រឡាញ់ ហើយក៏បានរស់នៅ ដើម្បីទ្រង់ផង។ បន្ទាប់មក 'យើង [នឹង] បានធំឡើងខាងឯគ្រប់ការទាំងអស់ក្នុងទ្រង់ ដែលទ្រង់ជាសិរសា គឺជាព្រះគ្រីស្ទ»។ ដកស្រង់ពី Ellen G. White, Steps to Christ, page 75, adapted។

ខណៈពេលដែលយើងបានបន្តរង់ចាំព្រះអម្ចាស់ នោះយើងក៏ត្រូវតែស្វែងរកសេចក្តីសុខសាន្តនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងផងដែរ។ យើងបានជួបព្រះជារៀងរាល់ថ្ងៃតាមរយៈសេចក្តីអធិស្ឋាន និងតាមរយៈបទចម្រៀង (កំណាព្យ) ដែលបានចែងនៅក្នុងកណ្ឌគម្ពីរនេះ។

### សំណួរពិភាក្សា

១. តើហេតុអ្វីបានជាការរង់ចាំគឺជាផ្នែកមួយដ៏សំខាន់នៅក្នុងជីវិតខាងឯវិញ្ញាណរបស់យើងយ៉ាងដូច្នេះ? សូមពិភាក្សាអំពីបុរស និងស្ត្រីមួយចំនួននៅក្នុងព្រះគម្ពីរ ដែលបានរង់ចាំព្រះ។ តើការរង់ចាំបានធ្វើឱ្យសេចក្តីជំនឿរបស់ពួកគេបានរឹងមាំឡើងដោយរបៀបណា? គន្លឹះ៖ សូមអានខគម្ពីររ៉ូម ៤:១៩-២២ និងបទគម្ពីរហេព្រើរ ជំពូក១១។

២. តើយើងកំពុងតែរង់ចាំរបស់អ្វីដែរ? តើព្រះបានសន្យានឹងយើងយ៉ាងដូចម្តេចដែរ? តើយើងបានរកឃើញសេចក្តីសន្យាអ្វីដែរ នៅក្នុងខគម្ពីរទំនុកតម្កើង ៣៧:៣៤-៤០ ដែលព្រះបានសន្យាថា ទ្រង់នឹងប្រទានរបស់ទាំងនេះដល់យើងនោះ?

៣. សូមអានខគម្ពីរសាស្តា ៩:៥។ តើខនេះបានប្រាប់យើងអំពីសេចក្តីស្លាប់យ៉ាងដូចម្តេចដែរ? តើហេតុអ្វីបានជាការរង់ចាំព្រះយេស៊ូវរបស់ពួកគេជិតមកដល់ហើយយ៉ាងដូច្នេះ? តើចម្លើយនេះបានផ្តល់សេចក្តីសង្ឃឹមអ្វីដល់យើង?

# ជនជាតិវ៉ាលដេនៅក្នុងប្រទេសប៉ូឡូញ

លោករីស្សាដ ចាញ់ខូវស្គី (Ryszard Jankowski) មិនអាចរារាំងប៉ូលិសឱ្យឈប់តាមដានគាត់បានឡើយ។ ដ្បិតរាល់ពេលដែលគាត់បើកតូបលក់សៀវភៅមហាវិវាទរបស់អ្នកស្រីអេឡែន ជីវ៉ៃត៍ និងសៀវភៅដទៃទៀតនៅក្នុងរមណីយដ្ឋាននៃទីក្រុងបាល់ទិក (Baltic) នៅក្នុងប្រទេសប៉ូឡូញ ស្រាប់តែមានប៉ូលិសម្នាក់បានបង្ហាញខ្លួនឡើង ដោយបង្គាប់ឱ្យគាត់រើតូប និងសៀវភៅទាំងនោះចេញ។ បន្ទាប់មករោងបោះពុម្ពនៃខណៈនិកាយសេវេនដេយអាត់វេនទីស្ទបានបោះពុម្ពផ្សាយប្រធានបទដ៏ពិសេសមួយនៅក្នុងទស្សនាវដ្ដីសាញអុហ្វថៃម (Signs of the Times) ហើយអ្នកដឹកនាំព្រះវិហារបានបញ្ជូនទស្សនាវដ្ដីបោះពុម្ពទាំងនោះទៅឱ្យក្រុមសមាជិករដ្ឋាភិបាលប៉ូឡូញ។ រដ្ឋមន្ត្រីរដ្ឋាភិបាលម្នាក់បានពេញចិត្តនឹងប្រធានបទនៅក្នុងទស្សនាវដ្ដីនេះណាស់ រហូតដល់គាត់បានសរសេរលិខិតមួយច្បាប់ភ្ជាប់ជាមួយនឹងច្បាប់ចម្លងនៃទស្សនាវដ្ដីជូនទៅឱ្យអភិបាលក្រុងនៃរមណីយដ្ឋាន ដែលគាត់មានបញ្ហាជាមួយនឹងប៉ូលិសនោះ។ អភិបាលក្រុងបានកោតសរសើរប្រធានបទនោះ។ អភិបាលក្រុងបានស្គាល់រដ្ឋមន្ត្រីរដ្ឋាភិបាលម្នាក់នោះ។ ហើយគាត់បាននិយាយថា «អ្នកលក់សៀវភៅម្នាក់នេះគឺជាគ្រូបង្រៀននៅក្នុងសាកលវិទ្យាល័យរបស់ខ្ញុំ អ៊ីចឹង លោកគ្រូអាចរួមចំណែកចែករំលែកទស្សនាវដ្ដីនេះនៅទីនេះបាន»។ លោករីស្សាដបានសួរទៅអភិបាលក្រុងដែលគាត់បានស្គាល់នោះថា «តើលោកគ្រូអាចសុំច្បាប់សរសេរសៀវភៅបានដែរឬទេ?»។ អភិបាលក្រុងបានសរសេរលិខិតមួយច្បាប់ទៀត ដោយបានអនុញ្ញាតឱ្យគាត់ដំឡើងតូបលក់សៀវភៅរបស់គាត់នៅតាមដងផ្លូវ។ គាត់បានដាក់ទស្សនាវដ្ដីសាញអុហ្វថៃមនៅលើធ្នើរជាមួយនឹងសៀវភៅមហាវិវាទ និងសៀវភៅដទៃទៀត។ មិនយូរប៉ុន្មាន ប៉ូលិសបានបង្ហាញខ្លួនម្ដងទៀត។ គាត់បាននិយាយថា «លោកមិនអាចលក់សៀវភៅរបស់លោកនៅក្នុងទីក្រុងរបស់យើងបានឡើយ»។ លោករីស្សាដបាននិយាយថា «លោកប៉ូលិសខ្ញុំមានលិខិតអនុញ្ញាតពីអភិបាលក្រុង»។ ប៉ូលិសបានអានលិខិតនេះយ៉ាងប្រុងប្រយ័ត្ន។ បន្ទាប់មក ពួកគេបានសុំទោសគាត់។ ប៉ូលិសម្នាក់បាននិយាយថា «អូខេ លោកអាចលក់នៅទីនេះបាន»។

ប៉ុន្តែ នេះមិនមែនជាចុងបញ្ចប់នៃរឿងនេះទេ។ បន្តិចក្រោយមក មានលោកយាយម្នាក់បានដើរមកឈប់នៅមុខតូបនោះ។ ពីព្រោះមានបុគ្គលម្នាក់បានឱ្យសៀវភៅមហាវិវាទដល់គាត់មុននេះបន្តិច ហើយគាត់បានអានសៀវភៅនោះឱ្យចៅរបស់គាត់បានស្ដាប់។ លោកយាយម្នាក់នេះចូលចិត្តសៀវភៅនេះណាស់ជាពិសេស ការបើកបង្ហាញអំពីក្រុមយុវជនជនជាតិវ៉ាលដេដែលហ៊ានប្រថុយជីវិតរបស់ពួកគេចែកចាយព្រះបន្ទូលរបស់ព្រះនៅក្នុងយុគសម័យកណ្ដាល។ លោកយាយបានប្រាប់លោករីស្សាដថា ចៅរបស់គាត់ចង់ធ្វើដូចជាក្រុមយុវជនវ៉ាលដេនេះដែរ។ ចៅរបស់គាត់បានយល់ឃើញថា គាត់ត្រូវតែធ្វើដូចជាពួកគេពោលគឺគាត់ត្រូវតែស្មោះត្រង់ចំពោះព្រះបន្ទូលរបស់ព្រះជានិច្ច។

លោកយាយបាននិយាយថា «ចៅខ្ញុំបានឃើញតូប និងសៀវភៅមហាវិវាទរបស់លោកគ្រូ ហើយគាត់បាននិយាយនឹងខ្ញុំថា 'យាយ មានជនជាតិវ៉ាលដេនៅក្នុងទីក្រុងរបស់យើង'»។

ដូច្នេះហើយ លោកយាយបានដើររកលោករីស្សាដ ដើម្បីប្រាប់លោករីស្សាដឱ្យបានដឹងរឿងអំពីចៅរបស់គាត់។ លោកយាយបានចូលជាសមាជិកនៃក្រុមជំនុំសេវេនដេយអាត់វេនទីស្ទនៅពេលក្រោយមកទៀត។

# អំណានសម្រាប់លើកប្រាក់តង្វាយ

## តើជាសកម្មភាព ឬក៏គ្រាន់តែជាបំណងចិត្ត?

**ខគម្ពីររ៉ូម ១២:១ បានចែងថា «ដូច្នេះ បងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នា ដោយសេចក្តីមេត្តាករុណានៃព្រះ ឲ្យបានថ្វាយរូបកាយទុកជាយញ្ញបូជារស់ ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ ជាការគោរពនៃអ្នករាល់គ្នាដែលមានទំនង» (រ៉ូម ១២:១)។**

លោកម៉ាទីន លូធើរ (Martin Luther) ដែលជាអ្នកកែទម្រង់ ធ្លាប់បានរស់នៅក្នុងវត្តមួយនៅក្នុងប្រទេសអាឡឺម៉ង់ ដែលជាកន្លែងដែលគាត់ និងមិត្តភក្តិរបស់គាត់បានស្នាក់នៅរួមគ្នា។ គាត់ទាំង២នាក់មានគោលជំនឿដូចគ្នានៅក្នុងជំនឿគ្រីស្ទាន ហើយពួកគាត់ក៏បានបង្ហាញសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅបញ្ហាខាងឯសេចក្តីពិតផងដែរ។ ទោះជាយ៉ាងនេះក្តី នៅពេលដែលលោកលូធើរបានសម្រេចចិត្តធ្វើ «សង្គ្រាម» ដើម្បីឱ្យការកែទម្រង់បានកើតឡើង នោះមិត្តភក្តិរបស់គាត់បានយល់ព្រមស្នាក់នៅក្នុងវិហារតទៅទៀត ដើម្បីអធិស្ឋានសុំឱ្យព្រះជួយដល់គាត់។ យប់មួយ មិត្តភក្តិរបស់លោកលូធើរបានឃើញសុបិនមួយ។ នៅក្នុងសុបិននោះ គាត់បានឃើញវាលស្រែដាច់កន្ទុយភ្នែកមួយកន្លែង ដែលមើលទៅហាក់ដូចជាជាប់នឹងជើងមេឃអ៊ីចឹង។ វាលស្រែនោះបានទុំជាស្រេច។ នៅពេលនោះ គាត់បានឃើញបុរសម្នាក់កំពុងតែព្យាយាមច្រូតស្រូវទាំងអស់តែម្នាក់ឯង ប៉ុន្តែ ការងារនេះមិនបានសម្រេចតែម្នាក់ឯងបានទេ។ មិនយូរប៉ុន្មាន គាត់អាចសម្លឹងឃើញទឹកមុខរបស់កសិករម្នាក់នោះ ហើយគឺជាលោកម៉ាទីនលូធើរនោះឯង។ សុបិននេះបានបង្រៀនសេចក្តីពិតដ៏សំខាន់មួយដល់គាត់ គឺថា គាត់ត្រូវតែឈប់អធិស្ឋានឱ្យមិត្តភក្តិរបស់គាត់ ហើយបែរមកធ្វើការជាមួយនឹងគាត់វិញ។ ការចាប់ផ្តើមគឺជាអ្វីដែលបានបែងចែកសកម្មភាពចេញពីបំណងប្រាថ្នានៅក្នុងចិត្ត។

មនុស្សជាច្រើននាក់បានធ្វើការប្តេជ្ញាចិត្តនៅចុងឆ្នាំនីមួយៗ។ អ្នកខ្លះ បានប្តេជ្ញាចិត្តថា ពួកគេនឹងបង្កើតកម្មវិធីហាត់ប្រាណជារៀងរាល់ថ្ងៃ អ្នកខ្លះទៀតបានប្តេជ្ញាចិត្តថា ពួកគេនឹងសន្សំប្រាក់ ហើយខ្លះទៀតបានប្តេជ្ញាចិត្តថា ពួកគេនឹងសម្រកទម្ងន់។ ដោយសារតែខ្វះសកម្មភាពនេះហើយ បានជានៅចុងឆ្នាំថ្មី ការប្តេជ្ញាចិត្តទាំងនេះបានត្រឹមតែជាបំណងចិត្តប៉ុណ្ណោះ។

ប៉ុន្តែ គ្មានដំណោះស្រាយណាមួយសំខាន់ស្មើនឹងដំណោះស្រាយដែលទាក់ទងទៅនឹងជីវិតខាងឯវិញ្ញាណរបស់យើងនេះឡើយ។ យើងត្រូវតែចាប់ផ្តើមឆ្នាំថ្មីរបស់យើងជាមួយនឹងការបន្ត ឬបង្កើតគោលការនៃភាពស្មោះត្រង់ ហើយនិងការប្តេជ្ញាចិត្តចំពោះព្រះ។ ដំណោះស្រាយខាងក្រោមនេះគួរតែជាអាទិភាពដំបូងគេនៅក្នុងបញ្ជីរបស់យើងដែលមានដូចជា៖

១. សូមបែងចែកពេលវេលា សម្រាប់ថ្វាយបង្គំផ្ទាល់ខ្លួនជារៀងរាល់ថ្ងៃ តាមរយៈការអានព្រះគម្ពីរ មេរៀនសប្បាតហ៍ស្កូល ហើយនិងការអធិស្ឋាន។

២. សូមជួបជុំគ្នា សម្រាប់ការថ្វាយបង្គំខ្លីមួយនៅក្នុងក្រុមគ្រួសារ នៅពេលព្រលឹម និងនៅពេលព្រលប់ឱ្យបានរៀងរាល់ថ្ងៃ។

៣. សូមបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរក្សាថ្ងៃសប្បាតហ៍ពីថ្ងៃលិចនៅថ្ងៃសុក្ររហូតដល់ថ្ងៃលិចនៅថ្ងៃសៅរ៍ជារៀងរាល់ថ្ងៃ។

៤. សូមចូលរួមនៅក្នុងកម្មវិធីព្រះវិហារជាប្រចាំ ដោយមិនឱ្យទំនាក់ទំនងខាងឯសាច់ឈាមជំនួសការថ្វាយបង្គំផ្ទាល់ខ្លួនរបស់លោកអ្នកបានឡើយ។

៥. សូមបន្តការប្តេជ្ញាចិត្តរបស់លោកអ្នកចំពោះភាពស្មោះត្រង់ ដោយការបង្វិលតង្វាយ១០ហូត១ និងតង្វាយសទ្ធាឱ្យបានទៀងទាត់។ តង្វាយ១០ហូត១ត្រូវតែជា១០ភាគរយនៃប្រាក់ចំណូលទាំងអស់របស់លោកអ្នក។ រីឯតង្វាយសទ្ធាវិញ លោកអ្នកត្រូវតែកំណត់ភាគរយ (____%) ដែលត្រូវតែថ្វាយឱ្យស្របទៅតាមសមាមាត្រនៃទឹកប្រាក់ចំណូលទាំងអស់ដែលទទួលបាន។

**សេចក្តីអំពាវនាវ៖ សូមឱ្យលោកអ្នកបានទូលសុំឱ្យព្រះជួយឱ្យការប្តេជ្ញាចិត្តទាំងនេះក្លាយមកជាការពិតនៅក្នុងជីវិតប្រចាំថ្ងៃរបស់លោកអ្នកពេញមួយឆ្នាំនេះចុះ។**

# ក្រុមជំនុំដែលផុសចេញពីចិត្តនៃសមាជិកម្នាក់ៗ

**ខគម្ពីរអេភេសូរ ៥:២៧ បានចែងថា «ប្រយោជន៍នឹងថ្វាយពួកជំនុំនេះដល់ព្រះអង្គទ្រង់ ទុកជាពួកជំនុំដ៏ឧត្តម ឥតប្រឡាក់ ឥតជ្រួញ ឬមានអ្វីឲ្យដូចឡើយ គឺឲ្យបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបានវិញ» (អេភេសូរ ៥:២៧)។**

តើលោកអ្នកធ្លាប់បានគិតថា ប្រសិនបើសមាជិកក្រុមជំនុំទាំងអស់មានអត្តចរិតដូចជាលោកអ្នកនោះ តើពួកគេនឹងទៅជាយ៉ាងណាដែរឬទេ? សូមគិតអំពីទិដ្ឋភាពនៃការប្រកបគ្នានៅក្នុងក្រុមជំនុំនឹងទៅជាយ៉ាងណាទៅ បើសិនជាសមាជិកម្នាក់ៗបានអធិស្ឋាន និងបានអានព្រះគម្ពីរដូចជាលោកអ្នកវិញនោះ។ សូមស្រមៃថា បើសិនជាក្រុមជំនុំទាំងអស់បានចំណាយពេល ដូចជាលោកអ្នកបានចែកចាយសេចក្តីពិតជាមួយនឹងអ្នកដទៃដែរនោះ តើទិដ្ឋភាពនៃបេសកកម្មនឹងទៅជាយ៉ាងណាដែរ។ សូមលោកអ្នកបានគិតបន្ថែមទៀតថា បើសិនជាក្រុមជំនុំទាំងអស់បានបង្វិលតង្វាយ១០ហូត១ និងតង្វាយសទ្ធាដែលលោកអ្នកបានអនុវត្តជាប្រចាំ តើការថែរក្សាក្រុមជំនុំ និងការបង្កើតបេសកកម្មថ្មីៗនឹងទៅជាយ៉ាងណាផងដែរ។

តើក្រុមជំនុំបែបនេះអាចកើតចេញពីក្រុមជំនុំដែលមានអត្តចរិតដូចជាលោកអ្នកដូចម្តេចទៅបាន? តើក្រុមជំនុំបែបណាដែលលោកអ្នកបានស្រមៃឃើញនៅក្នុងចិត្តរបស់លោកអ្នកនោះ? ព្រះវិហារដែលមានមនុស្សតែម្នាក់ឯងនោះ គឺជាលោកអ្នកនេះហើយ។ មានពេលខ្លះ យើងបានគិតថា អាកប្ប-កិរិយារបស់យើងម្នាក់ៗមិនអាចប៉ះពាល់ដល់ក្រុមជំនុំទាំងអស់បានឡើយ។ យើងអាចនឹងគិតថា បើសិនជាយើងមិនបានបង្រៀនព្រះគម្ពីរទេ នោះអ្នកដទៃនឹងបង្រៀនជំនួសយើងវិញ ហើយសាររបស់ព្រះនឹងត្រូវបានចែកចាយដល់ពិភពលោកទាំងមូលវិញ។ យ៉ាងណាមិញ បើសិនជាយើងមិនស្មោះត្រង់នៅក្នុងការបង្វិលតង្វាយ១០ហូត១ និងតង្វាយសទ្ធាទេ នោះអ្នកដទៃនឹងធ្វើជំនួសយើងវិញ ហើយព្រះវិហារនឹងមានធនធានថែទាំក្រុមជំនុំនៅក្នុងតំបន់របស់ពួកគេ ហើយក្រុមជំនុំក៏បានចែកចាយដំណឹងល្អទៅកាន់ពិភពលោកទាំងមូលផងដែរ។ នេះគឺជាការពិត បើសិនយើងគិតឱ្យបានស៊ីជម្រៅនោះ។ បេសកកម្មរបស់ព្រះនឹងទទួលបានជោគជ័យ ទោះបីជាមាន ឬគ្មានធនធានពីលោកអ្នកក៏ដោយ។ ស្រដៀងគ្នានេះដែរ ដំណឹងល្អនឹងត្រូវផ្សព្វផ្សាយនៅពាសពេញពិភពលោក ទោះបីជាមាន ឬគ្មានការចូលរួមពីលោកអ្នកក៏ដោយ។

សំណួរដ៏ធំដែលត្រូវចោទសួរនៅត្រង់នេះ តើក្រុមជំនុំដែលខ្ញុំបានបង្កើតតែម្នាក់ឯងនេះតែងតែមានឥទ្ធិពលលើមនុស្សដែលនៅក្បែរខ្ញុំជានិច្ច ដែលមានដូចជាកូន ប្រពន្ធ ឪពុក និងបងប្អូនរបស់ខ្ញុំដែរឬទេ? ការប្តេជ្ញាចិត្ត ឬការមិនអើពើដល់ភាពស្មោះត្រង់ និងផែនការរបស់ព្រះនេះ អាចជួយ ឬបំផ្លាញដល់មនុស្សដែលនៅជុំវិញយើងបាន។ ថ្ងៃមួយ ឪពុកនឹងនិយាយថា «កេរដំណែលដ៏អស្ចារ្យបំផុតដែលខ្ញុំបានបន្សល់ទុកឱ្យកូនៗរបស់ខ្ញុំ នោះគឺជាគំរូដែលបានកំណត់ដោយជីវិតដែលបានឧទ្ទិសដល់បេសកកម្មរបស់ព្រះ ហើយខ្ញុំក៏សង្ឃឹមថា ពួកគេនឹងឧទ្ទិសជីវិតរបស់ពួកគេដល់បេសកកម្មបម្រើព្រះនេះឱ្យកាន់តែស្វាហាប់ជាងខ្ញុំផងដែរ»។

**សេចក្តីអំពាវនាវ៖ ប្រសិនបើមានអ្នកណាម្នាក់បានសួរអំពីទំហំនៃសេចក្តីស្រឡាញ់ដែលលោកអ្នកមានចំពោះព្រះ តើលោកអ្នកនឹងឆ្លើយយ៉ាងដូចម្តេចដែរ? វិធីដ៏ល្អបំផុត ដើម្បីឆ្លើយតបទៅនឹងសំណួរនេះ មិនមែនតាមការឆ្លើយជាពាក្យសម្តីនោះទេ ប៉ុន្តែ តាមរយៈជីវិតដែលបានឧទ្ទិស និងបានប្តេជ្ញាយ៉ាងអស់ពីចិត្តចំពោះកិច្ចការបម្រើព្រះវិញ។ យើងត្រូវតែយល់ថា នេះគឺជាការសាកល្បងដល់ភាពជាសាវ័ករបស់យើងនៅក្នុងនាមជាគ្រីស្ទាន។**

# ការថ្វាយរបស់ទាំងអស់

**ខគម្ពីរម៉ាថាយ ១៩:២១ បានចែងថា «នោះទ្រង់មានព្រះបន្ទូលថា បើអ្នកចង់បានជាគ្រប់លក្ខណ៍ ចូរអ្នកទៅលក់របស់ទ្រព្យខ្លួន ហើយចែកដល់ពួកអ្នកក្រីក្រទៅ នោះអ្នកនឹងបានទ្រព្យសម្បត្តិនៅឯស្ថានសួគ៌វិញ រួចឲ្យមកតាមខ្ញុំចុះ» (ម៉ាថាយ ១៩:២១)។**

នេះគឺជាចម្លើយដែលព្រះគ្រីស្ទបានឆ្លើយទៅកាន់បុរសអ្នកមានវ័យក្មេង ដែលចង់ដឹងថា គាត់គួរតែធ្វើអ្វីខ្លះ ដើម្បីឱ្យបានជីវិតអស់កល្បនោះ។ ឥឡូវនេះ តើព្រះយេស៊ូវបានអ្វីពីបុរសវ័យក្មេងម្នាក់នេះ? ចម្លើយគឺទ្រង់ចង់បានអ្វីៗទាំងអស់ពីគាត់។ វាគួរឱ្យចាប់អារម្មណ៍ដែរ ដោយបានឃើញថា នៅពេលដែលបុរសវ័យក្មេងម្នាក់នេះ «ចេញទៅទាំងព្រួយចិត្ត ព្រោះមានទ្រព្យសម្បត្តិជាច្រើន» (ម៉ាថាយ ១៩:២២) នោះព្រះយេស៊ូវមិនបានរត់ទៅតាមគាត់ ដើម្បីនឹងមានបន្ទូលថា «ហេ ប្អូនប្រុសកុំទាន់ទៅណាមួយៗ ហើយចាំខ្ញុំសិន ខ្ញុំកំពុងតែនិយាយជាពាក្យប្រៀបប្រដូចប៉ុណ្ណោះទេ ដូច្នេះ ប្អូនគ្រាន់តែដាក់តង្វាយ១០ហូត១ និងតង្វាយសទ្ធារបស់ប្អូនទៅបានហើយ»។ ទេ ទ្រង់មិនបានមានបន្ទូលដូច្នេះទេ ទ្រព្យសម្បត្តិបានក្លាយមកជាព្រះនៅក្នុងជីវិតរបស់បុរសវ័យក្មេងម្នាក់ទៅហើយ ម្ល៉ោះហើយ មានតែការថ្វាយចិត្តជីវិតទៅឯព្រះទាំងស្រុងប៉ុណ្ណោះដែលអាចទទួលយកបាន។

ប្រសិនបើយើងបានអានព្រះគម្ពីរយ៉ាងអស់ពីចិត្ត នោះនឹងនិយាយសរុបសេចក្តីមកថា ព្រះទ្រង់ចង់បានអ្វីៗទាំងអស់ពីយើង។ ថ្ងៃមួយ ខណៈពេលដែលម្តាយដែលមានកូន៥នាក់បានស្តាប់សេចក្តីអធិប្បាយ នោះនាងបានសម្រេចចិត្តថ្វាយអ្វីៗគ្រប់យ៉ាងដែលគាត់មាន ទុកជាតង្វាយសម្រាប់បេសកកម្មរបស់ព្រះវិញ។ នៅពេលដែលគាត់ត្រឡប់មកផ្ទះវិញ គាត់បានរើអីវ៉ាន់របស់គាត់ទុកជាតង្វាយថ្វាយដល់ព្រះ ដោយនាងបានដឹងថា ទោះជានៅក្នុងស្ថានភាពក្រីក្រយ៉ាងណាក៏ដោយ ក៏នាងមិនអាចបោះបង់ចោលរបស់ដែលមានប្រយោជន៍ ឬមានតម្លៃនោះឡើយ។ រំពេចនោះ ចំណាប់អារម្មណ៍របស់នាងបានទាញនាងទៅរកកូនៗទាំង៥នាក់របស់នាងវិញ ដែលមានកូនស្រី៣នាក់ និងកូនប្រុស២នាក់។ គាត់បានចូលទៅក្នុងបន្ទប់របស់គាត់ រួចអធិស្ឋានថា «ឱព្រះអម្ចាស់អើយ ទូលបង្គំមិនមានទ្រព្យសម្បត្តិដែលអាចយកមកប្រើនៅក្នុងបេសកកម្មរបស់ទ្រង់បានទេ ប៉ុន្តែ ទូលបង្គំសុំថ្វាយកូនទាំង៥នាក់របស់ទូលបង្គំវិញ ប៉ុន្តែ នៅពេលនេះ ទូលបង្គំសូមថ្វាយកូនៗរបស់ទូលបង្គំឱ្យបំពេញបេសកកម្មរបស់ទ្រង់ ដូច្នេះហើយ សូមឱ្យទ្រង់បានប្រើពួកគេនៅក្នុងនាមជាបេសកជនរបស់ទ្រង់ផងចុះ»។ ប៉ុន្មានឆ្នាំក្រោយមក កូនទាំង៥របស់គាត់បានចូលបម្រើបេសកកម្មរបស់ព្រះនៅក្នុងនាមជាបេសកជន។ អ្នកស្រីអែលឡិន ជីវ៉ៃត៍បានជួយឱ្យយើងយល់ពីគោលគំនិតនេះ ដោយសរសេរពាក្យទាំងនេះថា៖ «ព្រះយេស៊ូវបានសុំឱ្យសាវកនៅឯសមុទ្រលះបង់អ្វីៗទាំងអស់សម្រាប់កិច្ចការផ្សាយដំណឹងល្អ។ ដូច្នេះហើយ មនុស្សទាំងអស់ត្រូវតែទទួលរងនូវការសាកល្បងដែលថា តើរវាងសេចក្តីប្រាថ្នាសម្រាប់ភាពឡូយឆាយខាងឯសាច់ឈាម និងសេចក្តីប្រាថ្នាសម្រាប់ការប្រកបគ្នាជាមួយនឹងព្រះគ្រីស្ទនោះ មួយណាមានទំហំធំជាង។ (ដកស្រង់ពី *The Desire of Ages*, p.273)។

**សេចក្តីអំពាវនាវ៖ នេះគឺជាប្រភពនៃការថ្វាយដែលលោកអ្នកត្រូវធ្វើ។ អ្វីៗគ្រប់យ៉ាងដែលលោកអ្នកមាន ត្រូវតែដាក់ថ្វាយទៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់។ លោកអ្នកត្រូវតែយល់ថា ព្រះចង់បានអ្វីៗទាំងអស់ពីយើង ហើយលោកអ្នកក៏ត្រូវតែយល់ផងដែរ បើសិនជាលោកអ្នកមិនបានថ្វាយរបស់ទាំងអស់ដល់ព្រះទេ នោះមានន័យថា លោកអ្នកមិនបានថ្វាយអ្វីដល់ព្រះទាល់តែសោះ។**

# ត្រូវបានចិញ្ចឹមដោយក្មេងៗកុមារកំព្រា

**ខគម្ពីរយ៉ូហាន ១៤:១៨ បានចែងថា «ខ្ញុំមិនចោលអ្នករាល់គ្នាឲ្យនៅកំព្រាទេ ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ»។**

ជើងយន្តហោះលូហ្វថានសា (Lufthansa) ៧៥៨ បានចូលចុះចតនៅក្នុងទីក្រុងឆេនណៃ (Chennai) នៃប្រទេសឥណ្ឌា នៅយប់ពាក់កណ្ដាលអាធ្រាត្រ។ ខ្ញុំបានចុះពីយន្តហោះជាមួយនឹងអារម្មណ៍ចម្លែក ដោយសារតែគាត់នៅតែម្នាក់ឯង។ នេះជាលើកទី១នៅក្នុងជីវិតខ្ញុំ ដែលខ្ញុំមានអារម្មណ៍ដូចជាគាត់ជាក្មេងកំព្រាយ៉ាងដូច្នោះដែរ។ អ្វីៗគ្រប់យ៉ាងដែលខ្ញុំធ្លាប់តែបានស្គាល់ គឺស្ថិតនៅលើពិភពលោកមួយទៀតដែលនៅសែនឆ្ងាយ។

ខណៈពេលដែលខ្ញុំកំពុងតែឈរនៅក្នុងជួរដ៏វែងនៅឯកន្លែងឆ្លងដែន ដែលជាកន្លែងដែលមនុស្សដែលមានភិនភាគដូចជាខ្ញុំបានដើរតម្រង់ទៅកាន់សណ្ឋាគារផ្កាយ៥ ឬទៅប្រជុំ នោះខ្ញុំបានសួរខ្លួនឯងថា តើខ្ញុំសម្រេចចិត្តខុស ឬក៏ត្រូវ។ គំនិតដែលថា ខ្ញុំមិនមែនជាអ្នកនៅទីនោះ បានចូលមកក្នុងចិត្តរបស់ខ្ញុំ។ ខ្ញុំបានចុះដណ្ដើរយន្ត ដើម្បីរង់ចាំអីវ៉ាន់របស់ខ្ញុំជាមួយលិខិតឆ្លងដែនដែលមានបោះត្រា។ នៅពេលដែលខ្ញុំបានចេញពីអាកាសយានដ្ឋានដ៏ត្រជាក់នោះមក ខ្ញុំបានប៉ះនឹងកំដៅថ្ងៃខណ្ឌា។ គ្រប់យ៉ាងគឺមានសភាពធម្មតា។ ក្រោយមក នៅថ្ងៃដដែលនោះ ពួកយើងបានជិះរថភ្លើងដេកយប់មកកាន់ផ្ទះ ដែលខ្ញុំត្រូវស្នាក់នៅ៨ខែជាបណ្ដោះអាសន្ននោះ ដែលកន្លែងបណ្ដោះ អាសន្ននោះគឺជាកន្លែងដែលសមរម្យបំផុត ដែលខ្ញុំត្រូវរស់នៅដោយគ្មានគ្រួសាររបស់ខ្ញុំ។

មនុស្សជាច្រើនបាននិយាយថា ឆ្នាំនេះ ខ្ញុំបានផ្លាស់ប្ដូរអ្វីៗជាច្រើនយ៉ាង។ ប៉ុន្តែ ខ្ញុំមិនសូវពេញចិត្តនឹងចម្លើយបែបនេះប៉ុន្មានទេ ដោយសារតែចម្លើយបែបនេះមិនមែនជាបទពិសោធន៍ផ្លាស់ប្ដូរជីវិតដែលខ្ញុំចង់បាននោះឡើយ។ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងបានយកទីបន្ទាល់ «ពិតៗ» ទៅប្រាប់អ្នកស្រុករបស់ខ្ញុំ នៅពេលដែលខ្ញុំត្រឡប់ទៅផ្ទះវិញ។ ខ្ញុំបានសួរព្រះថា ហេតុអ្វីបានជាខ្ញុំមិនមានអារម្មណ៍អស្ចារ្យនៅក្នុងចិត្តយ៉ាងដូច្នេះ ប៉ុន្តែ ព្រះបានតបមកខ្ញុំវិញថា តើអ្នកមកកន្លែងនេះ ដើម្បីផ្លាស់ប្ដូរជីវិតរបស់អ្នក ឬក៏ផ្លាស់ប្ដូរជីវិតរបស់អ្នកដទៃ? នៅពេលនោះ ខ្ញុំបានដឹងភ្លាមថា ខ្ញុំបានមើលបទពិសោធន៍ទាំងអស់នេះដោយប្រើទស្សនៈអាត្មានិយមរបស់ខ្ញុំ។ ខ្ញុំបានបោះចោលបញ្ជីគោលដៅផ្ទាល់ខ្លួនរបស់ខ្ញុំទៅក្នុងធុងសំរាម ហើយបានចាប់ផ្ដើមផ្ដោតទៅលើក្មេងៗវិញ ដោយសារតែខ្ញុំបានសម្រេចចិត្តថា ខ្ញុំនឹងកាត់ផ្ដាច់ភាពអាត្មានិយមរបស់ខ្ញុំចេញ។ ដំណើរនៃបេសកកម្មនៅពេលនោះបានបង្រៀនខ្ញុំថា យើងទាំងអស់មិនមែនជាក្មេងកំព្រានោះឡើយ ពីព្រោះព្រះបានចិញ្ចឹមយើងទាំងអស់គ្នាវិញ។

**សេចក្ដីអំពាវនាវ៖ អត្តសញ្ញាណនៃអ្នកធ្វើការស្ម័គ្រចិត្តម្នាក់នេះមិនត្រូវបានព្រះបើកបង្ហាញ ដើម្បីការពារព័ន្ធកិច្ចរបស់គាត់នោះទេ។ គាត់បានចូលរួមនៅក្នុងកម្មវិធីអ្នកស្ម័គ្រចិត្តអាត់វេនទីស្ទ ដែលបានជួយសម្រួលដល់កម្មវិធីបេសកជន ដោយសមាជិកក្រុមជំនុំទាំងអស់នៅជុំវិញពិភពលោក។ អ្នកស្ម័គ្រចិត្តមានអាយុចាប់ពី១៨ដល់៨០ អាចបម្រើការជាប៉ាស្ទ័រ ជាគ្រូបង្រៀន ជាអ្នកជំនាញខាងផ្នែកវេជ្ជសាស្ត្រ ជាអ្នកបច្ចេកទេសខាងផ្នែកកុំព្យូទ័រ ជាបុគ្គលិកមណ្ឌលកុមារកំព្រា និងជាអ្នកធ្វើការងារផ្សេងៗទៀត។ តង្វាយទៀងទាត់របស់លោកអ្នកបានជួយគាំទ្រដល់បេសកកម្មនៃគ្រួសារបេសកជនទាំង៤០០នាក់នៅជុំវិញពិភពលោកនេះ។**

# មានអ្នកកំពុងតែឃ្លាំមើល

**ខគម្ពីរទំនុកតម្កើង ១៣៩:៧ បានចែងថា «តើទូលបង្គំនឹងទៅឯណា ឲ្យរួចពីព្រះវិញ្ញាណទ្រង់ តើនឹងរត់ទៅឯណាឲ្យរួចពីព្រះភក្ត្រទ្រង់»។**

បុរសម្នាក់បានសម្រេចចិត្តចូលទៅក្នុងចម្ការពោតអ្នកជិតខាងរបស់គាត់ ដើម្បីលួចបេះពោតខ្លះ។ គាត់បានគិតថា *គ្មានអ្នកណាដឹងទេ បើសិនជាខ្ញុំបេះពោតពីរបីពីចម្ការនីមួយៗនោះ* ធ្វើវិធីនេះ ខ្ញុំនឹងអាចប្រមូលពោតជាច្រើនបានយ៉ាងងាយ។ ដូច្នេះ បុរសម្នាក់នោះបានរង់ចាំដល់យប់សិន ដើម្បីអនុវត្តនូវផែនការលួចរបស់គាត់នោះ។ លុះដល់ពេលយប់ គាត់បានចាកចេញពីផ្ទះរបស់គាត់ ដោយនាំយកកូនស្រីពៅរបស់គាត់ម្នាក់ទៅជាមួយនឹងគាត់។ គាត់បានខ្សឹបកូនស្រីគាត់ថា «កូនស្រី នៅចាំមើលផ្លូវនៅត្រង់ហ្នឹងហើយ បើមានអ្នកណាមក ប្រាប់ប៉ាឱ្យដឹងផង»។ បុរសម្នាក់នោះបានលួចចូលទៅក្នុងចម្ការពោតទី១ រួចបានចាប់ផ្ដើមបេះពោតតាមដែលគាត់អាចធ្វើទៅបាន។ គាត់បានចាប់ផ្ដើមលូកដៃបេះពោតទាំងស្ទាក់ស្ទើរ នៅពេលដែលគាត់បានឮកូនស្រីរបស់គាត់ខ្សឹបគាត់ថា «ប៉ា មានអ្នកកំពុងតែឃ្លាំមើលប៉ា»។ បុរសម្នាក់នោះបានក្រឡេកមើលជុំវិញគាត់ តែមិនឃើញមានអ្នកណាឡើយ។ គាត់បានញាត់ពោតចូលទៅក្នុងការ៉ុងរបស់គាត់ រួចដើរទៅកាន់ចម្ការទី២យ៉ាងប្រញាប់ប្រញាល់។ កូនស្រីបានដាស់តឿនឪពុករបស់នាងជាលើកទី២ថា «ប៉ា មានអ្នកកំពុងតែឃ្លាំមើលប៉ា»។ បុរសម្នាក់នោះបានមើលជុំវិញម្ដងទៀត តែគាត់មិនឃើញមានអ្នកណាគេសោះ។ គាត់បាននិយាយទៅកាន់កូនស្រីរបស់គាត់ទាំងខឹងថា «ហេតុអ្វីបានជាកូនប្រាប់ប៉ាថា មានអ្នកកំពុងតែឃ្លាំមើលយើងយ៉ាងដូច្នេះ? ប៉ាមើលជុំវិញអស់ហើយ អត់មានអ្នកណាគេឃើញទេកូន»។ ក្មេងស្រីតូចបានចង្អុលទៅលើមេឃដ៏ខ្មៅងងឹត រួចខ្សឹបប្រាប់គាត់ថា «មានអ្នកនៅខាងលើកំពុងតែឃ្លាំមើលប៉ា»។

រឿងដ៏សាមញ្ញនេះបានជួយឱ្យយើងយល់ឃើញថា នៅពេលដែលយើងប្រព្រឹត្តអំពើបាបតែម្នាក់ឯងនៅពេលយប់ និងនៅក្នុងផ្ទះរបស់ពួកគេ នោះមានន័យថា យើងកំពុងតែធ្វើបាបនៅមុខព្រះវត្តមានរបស់ព្រះហើយ។ វិធីមួយដែលធ្វើឱ្យយើងអាចរស់នៅក្នុងព្រះវត្តមានរបស់ព្រះយ៉ាងស្មោះត្រង់ នោះគឺជាការរក្សាចិត្តគំនិតដែលថា ព្រះតែងតែនៅខាងយើងជានិច្ច។ ការយល់បែបនេះមិនគួរនាំឱ្យយើងភ័យខ្លាច ឬអសន្តិសុខនោះទេ ផ្ទុយទៅវិញ យើងគួរតែមានអំណរដែលបានដឹងថា ព្រះគឺជាព្រះអង្គសង្គ្រោះនិងជាព្រះអង្គប្រោសលោះដែលបានដើរនៅក្បែរយើង ហើយថា វត្តមាន និងជំនួយរបស់ទ្រង់ពិតជាស័ក្តិសមនឹងការបង្ហាញភាពស្មោះត្រង់របស់យើងណាស់។

តាមរយៈការរស់នៅបែបនេះ យើងនឹងនៅតែស្មោះត្រង់តទៅទៀត ទោះបីជាយើងនៅឆ្ងាយពីស្វាមី ឬភរិយារបស់យើងក៏ដោយ។ យើងនឹងអាចលើកតម្កើងព្រះ ទោះបីជាយើងជាគ្រីស្ទានតែម្នាក់ឯងនៅក្នុងថ្នាក់ ឬនៅកន្លែងណាក៏ដោយ។ យើងត្រូវតែរស់នៅឱ្យស្របទៅតាមព្រះហឫទ័យព្រះ ទោះបីជាអ្នកនៅជុំវិញយើងមិនបានលើកតម្កើងព្រះក៏ដោយ។

**សេចក្តីអំពាវនាវ៖ ខណៈដែលលោកអ្នកបង្ហាញភាពស្មោះត្រង់របស់លោកអ្នក តាមរយៈការបង្វិលតង្វាយ១០ហូត១ និងតង្វាយសទ្ធានៅពេលនេះ សូមឱ្យលោកអ្នកបានអរព្រះគុណព្រះ ដែលទ្រង់បានប្រទានឱកាសឱ្យលោកអ្នកបានមានជីវិតរស់ និងបានដើរជាមួយនឹងព្រះនៃសេចក្ដីស្រឡាញ់ និងព្រះគុណនេះផងចុះ។**

# ព្រះក្លែងក្លាយ

**ខគម្ពីររ៉ូម ១:២៥ បានចែងថា «គេបានផ្លាស់សេចក្ដីពិតនៃព្រះ ឲ្យទៅជាសេចក្ដីភូតភរវិញ ក៏កោតខ្លាច ហើយគោរពបូជាដល់របស់ដែលកើតមក ជាជាងដល់ព្រះ ដែលបង្កើតរបស់ទាំងនោះមក ជាព្រះដែលមានព្រះពរអស់កល្បជានិច្ច អាម៉ែន» (រ៉ូម ១:២៥)។**

អ្វីមួយដែលពាក់ព័ន្ធនឹងជីវិតរបស់យើង ដែលមិនទាន់បានថ្វាយទាំងស្រុងទៅក្នុងព្រះហស្ត របស់ព្រះ អាចក្លាយជាព្រះក្លែងក្លាយរបស់យើងបាន។ ពួកសាសន៍ក្រេក ពួកសាសន៍រ៉ូម ហើយនិងពួក សម័យបុរាណដទៃទៀតបានដឹងពីរឿងនេះ ពីព្រោះ ដោយសារតែពួកគេនេះហើយ បានជាអ្វីៗគ្រប់យ៉ាង អាចយកមកធ្វើជាព្រះក្លែងក្លាយបាន។ ដូច្នេះហើយ ពួកគេបានបង្កើតព្រះហេផេសតូស (Hephaestus) ដែលជាព្រះនៃកម្មករ ព្រះម៉ាមម៉ុន (Mammon) ដែលជាព្រះមាស ព្រះប្រាក់ ព្រះហ៊ីមេរ៉ុស (Himeros) ដែលព្រះតណ្ហា និងព្រះផ្សេងៗទៀត។

នៅក្នុងសភាពជាមនុស្សលោក យើងត្រូវតែទទួលស្គាល់ថា យើងបានជាប់ចិត្តនឹងព្រះក្លែង-ក្លាយទាំងនេះមែន។ ជាការពិតណាស់ ការងារគឺជាព្រះពរ ប៉ុន្តែ នៅពេលដែលការងារនោះបានក្លាយ មកជាអាទិភាពដំបូងគេ នោះវានឹងក្លាយមកជាព្រះហ៊ីមេរ៉ុសនៅក្នុងជីវិតរបស់យើងវិញ។ ការរួមភេទ ត្រូវបានព្រះកំណត់ខ្ញុំពីអំពើបាប ប៉ុន្តែ នៅពេលដែលយើងអាក់ខានមិនបានធ្វើតាមគំរូដែលព្រះបាន កំណត់សម្រាប់ការរួមភេទរបស់យើងទេ នោះវានឹងក្លាយមកជាព្រះក្លែងក្លាយដូចជាព្រះហ៊ីមេរ៉ុសដូច្នោះ ដែរ។ ព្រះមួយអង្គនៅក្នុងចំណោមព្រះក្លែងក្លាយទាំងនេះអាចបំផ្លាញជីវិតខាងវិញ្ញាណរបស់យើង បាន។

នៅក្នុងខគម្ពីររ៉ូម ១:២៥ លោកប៉ុលបានមានប្រសាសន៍អំពីមនុស្សលោកដែលព្យាយាមយក ការថ្វាយបង្គំធម្មជាតិមកជំនួសឱ្យការថ្វាយបង្គំព្រះដ៏ពិតវិញ។ លោកប៉ុលបានអះអាងថា ការថ្វាយបង្គំ បែបនេះគឺផ្អែកទៅលើការកុហក ដែលមិនដែលត្រូវឱ្យមនុស្សលោកមានសុភមង្គលពិតប្រាកដនោះ ឡើយ។ លោកប៉ុលបានហៅអាកប្បកិរិយាបែបនេះថា ជារឿងល្ងង់ខ្លៅវិញ (សូមមើលខគម្ពីររ៉ូម ១:២២)។ លោកអ្នកត្រូវតែយល់ថា ការស្វែងរកសុភមង្គលតាមរយៈសម្ភារៈ និងតាមរយៈអ្នកដទៃគ្រាន់តែជារឿង ល្ងង់ខ្លៅប៉ុណ្ណោះ។ មានតែមនុស្សល្ងង់ប៉ុណ្ណោះដែលចង់បានសេចក្ដីសុខសាន្ត តាមរយៈការបំពេញ បំណងខ្លួនឯង ការសេពគ្រឿងញៀន ឬសុភមង្គលពិតប្រាកដនៅក្នុងធនធានខាងផ្នែកហិរញ្ញវត្ថុ។ ប៉ុន្តែ នៅក្នុងព្រះ យើងនឹងមានសុភមង្គលយ៉ាងពេញលេញវិញ។ ព្រះក្លែងក្លាយដែលបំផ្លិចបំផ្លាញ មនុស្សជាងគេនោះគឺជាព្រះនៃការលោភលន់ និងការស្វែងរកប្រាក់មិនចេះស្ងប់។ ហេតុដូច្នេះហើយ បានជាព្រះយេស៊ូវបានមានបន្ទូលថា «គ្មានបាវណាដែលបម្រើចៅហ្វាយ២បានទេ ពីព្រោះបាវនោះនឹង ស្អប់១ ស្រឡាញ់១ ឬនឹងកាន់ខាង១ ហើយមើលងាយ១ ដូច្នេះ អ្នករាល់គ្នាក៏បម្រើព្រះផង ទ្រព្យសម្បត្តិ ផងពុំបានដែរ» (លូកា ១៦:១៣)។

សេចក្ដីស្មោះត្រង់ និងសេចក្ដីសប្បុរសគឺជាវិធីដ៏ល្អបំផុត ដើម្បីកម្ចាត់ភាពលោភលន់។ នៅពេល យើងសម្រេចចិត្តបង្វិលតង្វាយដប់ភាគរយពីប្រាក់ចំណូលរបស់យើង ដោយស្មោះអស់ពីចិត្ត ហើយនិង កំណត់ចំនួនភាគរយសម្រាប់ការបង្វិលតង្វាយសទ្ធាជាប្រចាំ នោះមានន័យថា យើងកំពុងតែអនុញ្ញាត ឱ្យព្រះសម្លាប់ព្រះនៃការលោភលន់ដែលព្យាយាមគ្រប់គ្រងនោះហើយ។

**សេចក្ដីអំពាវនាវ៖ ខណៈពេលដែលលោកអ្នកបង្វិលតង្វាយ១០ហូត១ និងតង្វាយសទ្ធានៅថ្ងៃនេះ សូម ឱ្យព្រះបានជួយឱ្យលោកអ្នកសម្លាប់ព្រះក្លែងក្លាយដែលកំពុងតែគ្រប់គ្រងលើផ្នែកជាច្រើននៃជីវិតរបស់ លោកអ្នកចុះ។ សូមឱ្យលោកអ្នកបានយកព្រះទុកជាទី១ ដោយចាត់ទុកខ្លួនជាទីចុងក្រោយវិញ។**

# តើត្រូវធ្វើយ៉ាងណា នៅពេលដែលខ្ញុំមិនបានជឿទុកចិត្ត នៅលើព្រះនោះ

**ខគម្ពីរទំនុកតម្កើង ៧៤:២២ បានថែងថា «ឱព្រះអង្គអើយ សូមឈរឡើង ផ្ចាញ់គេពីដំណើរទ្រង់» (ទំនុកតម្កើង ៧៤:២២)។**

អ្នកខ្លះបានប្រកែកថា ពួកគេមិនបានបង្វិលតង្វាយ១០ហូត១ និងតង្វាយសទ្ធា ដោយសារតែពួកគេមិនយល់ស្របជាមួយនឹងរបៀបដែលព្រះវិហារបានចាត់ចែងធនធានទាំងនោះ និងដោយសារតែពួកគេមិនជឿជាក់ពីតម្លាភាពនៅក្នុងការប្រើប្រាស់ថវិកាព្រះវិហារ។ តើយើងគួរតែធ្វើយ៉ាងណា នៅពេលដែលយើងមិនបានយល់ស្របជាមួយនឹងរបៀបនៃកិច្ចការដែលព្រះវិហារបានរៀបចំនោះ? សំណួរនេះគឺជាសំណួរសំខាន់បំផុត ដូច្នេះហើយ ខ្ញុំសូមឆ្លើយសំណួរនេះជាមួយនឹងសម្រង់មតិពីអ្នកស្រីអេឡែន ជីវ៉ៃត៍។ អ្នកស្រីបានមានប្រសាសន៍ថា៖

មានអ្នកខ្លះបាននិយាយទាំងមិនពេញចិត្តថា «ខ្ញុំឈប់ដាក់តង្វាយ១០ហូត១ហើយ ដោយសារតែខ្ញុំមិនជឿទុកចិត្តទៅលើរបៀបចាត់ចែងនៅក្នុងកិច្ចការបម្រើព្រះ»។ ប៉ុន្តែ តើលោកអ្នកគួរតែកោងយករបស់ព្រះ ដោយសារតែលោកអ្នកគិតថា ព្រះវិហារគ្មានតម្លាភាពនៅក្នុងការចាត់ចែងនោះដែរឬទេ? តាមរយៈស្មារតីដ៏ត្រឹមត្រូវ សូមឱ្យលោកអ្នកបានរិះគន់ ដោយភាពទន់ភ្លន់ និងបើកចំហដល់អ្នកដឹកនាំដែលលោកអ្នកជឿទុកចិត្តចុះនោះ។ បន្ទាប់មក សូមធ្វើលិខិតសំណូមពររបស់លោកអ្នកមក ដើម្បីកែតម្រង់ និងរបៀបរៀបចំឱ្យបានស្រួលបួលឡើងវិញ ប៉ុន្តែ សូមកុំឱ្យលោកអ្នកដកចិត្តចេញពីកិច្ចការបម្រើព្រះ ហើយបង្ហាញភាពមិនស្មោះត្រង់ ដោយសារតែអ្នកដទៃគ្មានតម្លាភាពនោះឡើយ» (ដកស្រង់ពី *Gospel Workers*, p.226)។

សម្រង់មតិនេះបានបង្រៀនសេចក្តីពិតស៊ីជម្រៅ៣យ៉ាង៖

១. នៅពេលដែលលោកអ្នកជ្រើសរើសយកភាពមិនស្មោះត្រង់ ដោយសារតែមេដឹកនាំព្រះវិហារមិនបានចាត់ចែងធនធានត្រឹមត្រូវ នោះមានន័យថា លោកអ្នកកំពុងតែកោងយករបស់ព្រះហើយ។
២. សូមបង្ហាញសំណូមពររបស់លោកអ្នកទៅកាន់អ្នកមានសមត្ថកិច្ចដែលបានគ្រប់គ្រងក្រុមជំនុំរបស់ព្រះ។ ប៉ុន្តែ នៅក្នុងសម័យរបស់យើង សូមកុំឱ្យមានចិត្តចង់បះបោរ ដោយដើរតាមការបង្រៀនថា ការបះបោរគឺជាវិធីដោះស្រាយតែមួយគត់នោះឡើយ។
៣. សូមបង្ហាញពីភាពសង្ស័យរបស់លោកអ្នកនៅក្នុងសុឆន្ទៈជាគ្រីស្ទានដ៏ត្រឹមត្រូវម្នាក់វិញ។ សូមឱ្យលោកអ្នកបានទូលសុំឱ្យព្រះបញ្ចូលសេចក្តីស្រឡាញ់ចូលទៅក្នុងពាក្យសម្តីរបស់លោកអ្នកចុះ ហើយសុំឱ្យព្រះប្រទានប្រាជ្ញាដល់លោកអ្នកផងដែរ ខណៈពេលដែលលោកអ្នកផ្ញើសំណួររបស់លោកអ្នកមកកាន់ពួកយើងនោះ។ សូមកុំឱ្យលោកអ្នកធ្វើជាអ្នកចង់បំផ្លាញ តែសូមឱ្យលោកអ្នកបានធ្វើជាអ្នកមានចិត្តចង់ជួយដល់អ្នកដទៃវិញ។

សម្រង់មតិនេះបានបញ្ចប់ ដោយបញ្ជាក់ថា «ប៉ុន្តែ សូមកុំឱ្យលោកអ្នកដកចិត្តចេញពីកិច្ចការបម្រើព្រះ ហើយបង្ហាញភាពមិនស្មោះត្រង់ ដោយសារតែអ្នកដទៃគ្មានតម្លាភាពនោះឡើយ»។ សូមកុំឱ្យលោកអ្នកដកចិត្តចេញពីកិច្ចការបម្រើព្រះនោះឡើយ ពីព្រោះព្រះអង្គមានកិច្ចការ តែទ្រង់ត្រូវធ្វើនៅលើផែនដីនេះ ហើយទ្រង់ក៏បានត្រាស់ហៅលោកអ្នកឱ្យចូលរួមជាមួយនឹងទ្រង់ផងដែរ។

**សេចក្តីអំពាវនាវ៖ លោកអ្នកអាចនឹងបាត់បង់ជំនឿចិត្តទៅលើរបៀបអនុវត្តកិច្ចការបម្រើព្រះ។ បើសិនជាលោកអ្នកមានបញ្ហានៅត្រង់ចំណុចនេះ យើងខ្ញុំសូមអញ្ជើញលោកអ្នកអធិស្ឋាននៅពេលឥឡូវនេះ ដើម្បីសុំប្រាជ្ញាពីព្រះឱ្យបានធ្វើការស្របទៅតាមសេចក្តីណែនាំពីពួកហោរា ហើយជាពិសេសទៅទៀតនោះ សូមឱ្យលោកអ្នកបានទូលសុំឱ្យព្រះជួយឱ្យលោកអ្នកបាននៅជាប់ជាមួយនឹងបេសកកម្មនៃសេចក្តីពិត ដោយភាពស្មោះត្រង់ផងចុះ។**

# ការការពារកូនរបស់យើងឱ្យមានចិត្តនៅជាប់នឹងព្រះ

**ខគម្ពីរម៉ាថាយ ៦:២១ បានចែងថា «ពីព្រោះសម្បត្តិទ្រព្យរបស់អ្នកស្ថិតនៅកន្លែងណា នោះចិត្តអ្នកក៏នឹងនៅកន្លែងនោះដែរ»។**

លោកអាន់តូនី (Anthony) គឺជាឪពុកម្នាក់ ដែលបានរងគ្រោះដូចជាឪពុកម្តាយគ្រីស្ទានរាប់ពាន់នាក់ដទៃទៀត ដោយកូនពេញវ័យទាំង៣នាក់របស់គាត់បានបោះបង់ចោលព្រះវិហារ។ ពួកគេបានរស់នៅជាមួយនឹងក្រុមគ្រួសាររបស់ពួកគេ ហើយពួកគេក៏បានបង្ហាញថា ពួកគេមិនចង់ចូលរួមនៅក្នុងកម្មវិធីព្រះវិហារនោះដែរ។

លោកអាន់តូនីបានបបួលកូនៗរបស់គាត់ទៅព្រះវិហារជារឿយៗ ហើយនៅពេលដែលជួបជុំគ្រួសារម្តងៗ គាត់តែងតែនិយាយជានិច្ច អំពីគ្រោះថ្នាក់នៃការឃ្លាតឆ្ងាយពីព្រះ។ រឿងនេះបានធ្វើឱ្យកូនៗរបស់គាត់មិនសប្បាយចិត្ត ម៉្លោះហើយ ពួកគេបានសុំឪពុករបស់ពួកគេកុំឱ្យហៅពួកគេមកព្រះវិហារតទៅទៀត។

លោកអាន់តូនីបានសម្រេចចិត្តអធិស្ឋានឱ្យកូនៗរបស់គាត់បន្ថែមទៀត។ ព្រឹកមួយ ពេលដែលគាត់កំពុងតែអធិស្ឋានឱ្យពួកគេ ស្រាប់តែខគម្ពីរម៉ាថាយ ៦:២១ បានចូលមកក្នុងគំនិតរបស់គាត់ ដោយខនេះបានចែងថា៖ «ពីព្រោះសម្បត្តិទ្រព្យរបស់អ្នកស្ថិតនៅកន្លែងណា នោះចិត្តអ្នកក៏នឹងនៅកន្លែងនោះដែរ»។ កាន់តែអធិស្ឋាន កាន់តែនឹកឃើញខនេះ។ ម៉្លោះហើយ គាត់បានសម្រេចចិត្តទៅជួបជាមួយនឹងកូនៗរបស់គាត់ រួចនិយាយថា គាត់បានសម្រេចចិត្តតាមសំណើរបស់ពួកគេហើយ ដូច្នេះហើយ គាត់ក៏លែងបង្ខំពួកគេឱ្យចូលព្រះវិហារតទៀតដែរ ប៉ុន្តែ នៅក្នុងលក្ខខណ្ឌមួយ គឺថា ពួកគេត្រូវតែបង្វិលតង្វាយ១០ហូត១ និងតង្វាយសទ្ធារបស់ពួកគេចូលទៅក្នុងព្រះវិហារវិញ។ ពួកគេបានយល់ឃើញថា នេះគឺជាលក្ខខណ្ឌដែលអាចទទួលយកបាន ឱ្យតែឪពុករបស់ពួកគេលែងរំខានពួកគេពីបញ្ហានេះតទៅទៀត។ ចំណេរក្រោយមក លោកអាន់តូនីបានមានឱកាសបានឃើញកូនៗទាំង៣នាក់របស់គាត់ត្រឡប់មកកាន់ព្រះវិហារវិញ។

អ្នកស្រីអេឡែន ជីវ៉ៃត៍បានមានប្រសាសន៍ថា៖

ឪពុកម្តាយដែលមិនបានចាប់អារម្មណ៍ឱ្យកូនៗរបស់ពួកគេបំពេញបេសកកម្មរបស់ព្រះ មានចំណុចខ្វះខាតដ៏ធំមួយ។ នៅក្នុងគ្រួសារភាគច្រើន កូនៗមើលទៅហាក់ដូចជាមានសំណួរចង់សួរថា តើពួកគេជាមនុស្សដែលគ្មានទំនួលខុសត្រូវដែរឬទេ។ ឪពុកម្តាយខ្លះថែមទាំងកោងយករបស់ព្រះនៅក្នុង១០ហូត១ និងតង្វាយសទ្ធាទៅសន្សំប្រាក់ឱ្យកូនចៅរបស់ពួកគេ ដោយមិនបានគិតថា ការធ្វើដូច្នេះបាននាំឱ្យពួកគេបើកឱកាសឱ្យសេចក្តីល្បួងចូលទៅក្នុងមនុស្សដែលពួកគេស្រឡាញ់ ដែលជាទូទៅរបស់ទាំងនោះនឹងបំផ្លាញពួកគេវិញ (ដកស្រង់ពី Counsels on Sabbath School Work, p.140)។

**សេចក្តីអំពាវនាវ៖ សូមឱ្យលោកអ្នកបានទូលសូមឱ្យព្រះជួយឱ្យកូនៗរបស់លោកអ្នកបានយកទ្រង់និងបេសកកម្មរបស់ទ្រង់ទុកជាទី១ផងចុះ។**

# តើអ្នកណាជាម្ចាស់ពិតប្រាកដ

**ខគម្ពីរទំនុកតម្កើង ៥០:១២ បានចែងថា៖ «បើកាលណាអញឃ្លាន នោះអញមិនប្រាប់ដល់ឯង ពីព្រោះលោកីយ៍ និងរបស់សព្វសារពើក្នុងលោកជារបស់ផងអញ»។**

ថ្ងៃមួយ មានអ្នកជំនួញម្នាក់បានទូរស័ព្ទហៅមេធាវី និងគណនេយ្យករមកជួបនឹងគាត់ ដើម្បីសុំឱ្យពួកគេផ្លាស់ប្តូរឯកសារមួយចំនួនពីក្រុមហ៊ុន។ គាត់ចង់ធ្វើបទបង្ហាញតាមរយៈឯកសារទាំងនេះ ដោយសារតែគាត់បានយល់នូវអំពីភាពស្មោះត្រង់ចំពោះព្រះ។ គាត់បានទទួលយកព្រះមកធ្វើដៃគូជំនួញរបស់គាត់ ដោយគាត់បានសុំឱ្យអ្នកជំនាញទាំង២នាក់នោះកែលំអឯកសារក្រុមហ៊ុន ដើម្បីឱ្យព្រះនាមរបស់ព្រះបង្ហាញលេចចេញនៅក្នុងនាមជាដៃគូរបស់គាត់នៅក្នុងក្រុមហ៊ុន។ មិនយូរប៉ុន្មាន មេធាវី និងគណនេយ្យករបានដឹងថា ពួកគេកំពុងតែសាងបញ្ហាដ៏ធំមួយ ដោយសារតែយោងទៅតាមច្បាប់ប្រទេស ដៃគូជំនួញត្រូវតែរៀបចំឯកសារ និងកែអាសយដ្ឋាននៅក្នុងប្រទេស។ ឥឡូវនេះ តើពួកគេគួរតែធ្វើឯកសារឱ្យព្រះ ឬបញ្ជាក់អាសយដ្ឋានរបស់ទ្រង់ដោយរបៀបណា? នៅពេលនោះ ពួកគេបានបែរមករកម្ចាស់ក្រុមហ៊ុនវិញ រួចបញ្ជាក់ថា រឿងបែបនេះពួកយើងមិនអាចធ្វើបានទេ ពីព្រោះវាខុសច្បាប់រដ្ឋ។

អ្នកជំនួញម្នាក់នោះបានត្រឡប់មកផ្ទះវិញទាំងទឹកមុខក្រៀមក្រំ ដោយសារតែគាត់ខកចិត្តចំពោះផែនការរបស់គាត់ ប៉ុន្តែ នៅពេលដែលគាត់ប្រឈមជាមួយនឹងការបង្រៀននៅក្នុងបទគម្ពីរទំនុកតម្កើងជំពូក៥០ នៅទីបំផុត គាត់បានយល់ថា ផែនការដែលគាត់បានរៀបចំ ដើម្បីយកព្រះមកធ្វើជាដៃគូនៅក្នុងក្រុមហ៊ុនរបស់គាត់មិនស៊ីសង្វាក់គ្នានឹងការពិតនោះឡើយ។ គាត់បានយល់ឃើញថា គាត់ចង់ឱ្យព្រះមានសិទ្ធធ្វើជាដៃគូជំនួញនៅក្នុងក្រុមហ៊ុន ប៉ុន្តែ តាមពិតទៅ ព្រះគឺជាអ្នកប្រទានសិទ្ធឱ្យគាត់មានឈ្មោះនៅលើឯកសារក្រុមហ៊ុនដែលជារបស់ផងទ្រង់វិញទេតើ។ យើងប្រហែលជាមិនបានដឹងថា ព្រះគឺជាម្ចាស់របស់យើង ប៉ុន្តែ ការមិនដឹងនេះមិនបានផ្លាស់ប្តូរពីការដែលទ្រង់គ្រប់គ្រងរបស់ទាំងអស់នោះឡើយ។

នៅពេលដែលយើងយល់ពីមូលដ្ឋាននេះ ទំនាក់ទំនងដែលយើងមានជាមួយនឹងភាពស្មោះត្រង់បានផ្លាស់ប្តូរទាំងស្រុង។ យើងក៏តែងតែឮជារឿយៗអំពីសេចក្តីអំពាវនាវនៅក្នុងព្រះវិហារដែលថា៖ «សូមឱ្យលោកអ្នកបានលះបង់ពេលវេលា ទេពកោសល្យ និងធនធានរបស់លោកអ្នក ដើម្បីបំពេញតម្រូវការនៅក្នុងក្រុមជំនុំរបស់ព្រះផងចុះ»។ យើងត្រូវតែលះបង់គោលគំនិតដែលថា យើងគឺជាម្ចាស់នៃរបស់អ្វីមួយ ព្រមទាំងលះបង់ចោលគំនិតដែលថា យើងក៏នឹងយកទ្រព្យសម្បត្តិរបស់យើងមកជួយដល់បេសកកម្មរបស់ព្រះផងដែរ។ ពោលគឺយើងត្រូវតែដឹងជាបន្ទាន់ថា អ្វីៗគ្រប់យ៉ាងដែលស្ថិតនៅក្នុងដៃរបស់យើង គឺជាកម្មសិទ្ធរបស់ព្រះ ដោយសារទ្រង់ជាព្រះអាទិករ និងព្រះប្រោសលោះ។ ហេតុដូច្នេះហើយ បានជាយើងត្រូវការប្រើពាក្យថា «បង្វិលតង្វាយ១០ហូត១ និងតង្វាយសទ្ធា» ដោយហេតុថា យើងគ្រាន់តែបង្វិលតង្វាយមកឱ្យម្ចាស់នៃតង្វាយនោះប៉ុណ្ណោះ។

**សេចក្តីអំពាវនាវ៖ ខណៈពេលដែលលោកអ្នកបង្វិលតង្វាយ១០ហូត១ និងតង្វាយសទ្ធានៅថ្ងៃនេះ សូមឱ្យលោកអ្នកបានបញ្ជាក់ឡើងវិញ នូវការជឿជាក់របស់លោកអ្នកថា ព្រះគឺជាម្ចាស់នៃអ្វីៗគ្រប់យ៉ាងរបស់យើង ដូច្នេះហើយ សូមឱ្យយើងបានអរព្រះគុណទ្រង់ ដែលបានអនុញ្ញាតឱ្យយើងចូលរួមក្នុងបេសកកម្មរបស់ទ្រង់ជាមួយនឹងអំណោយទានដែលទ្រង់ដាក់នៅក្នុងដៃរបស់យើងនេះចុះ។**

# ហេតុផលដែលយើងត្រូវរស់តទៅទៀត

**ខគម្ពីរកូរិនថូសទី១ ១៥:៥៨ បានចែងថា «បានជាបងប្អូនស្ងួនភ្ងាអើយ ចូរកាន់យ៉ាងខ្ជាប់ខ្ជួន ដោយឥតរង្គើ ទាំងធ្វើការព្រះអម្ចាស់ ឲ្យបរិបូរជាដរាបចុះ ដោយដឹងថា ការដែលអ្នករាល់គ្នាខំប្រឹងធ្វើ ក្នុងព្រះអម្ចាស់ នោះមិនមែនឥតប្រយោជន៍ទេ»។**

លោកអង ខូ (Aung Ko) មើលទៅអ្នកដឹកនាំព្រះវិហារដូចជាមិនទំនងទាល់តែសោះ។ គាត់បានពិការភ្នែកតាំងតែពីកំណើត។ ហើយគាត់ក៏បានទទួលស្គាល់ថា គាត់ធ្លាប់បានព្យាយាមធ្វើអត្តឃាតខ្លួនឯងជាច្រើនលើកច្រើនសាផងដែរ។ ប៉ុន្តែ គាត់ក៏បានធ្វើជាស្មរបន្ទាល់នៃអំណាចរបស់ព្រះយេស៊ូវផងដែរ ដែលអំណាចនោះគឺជាអំណាចនៅក្នុងការស្វែងរកមនុស្សដែលស្ថិតនៅក្នុងគ្រាលំបាក ហើយយកពួកគេចេញពីភាពអស់សង្ឃឹម។ លោកអង ខូបានកើតនៅក្នុងក្រុមគ្រួសារដែលមានជំនឿស៊ុបទៅលើសាសនាព្រះពុទ្ធ។ គាត់បានចាប់ផ្តើមឈឺចាប់ពីជំងឺម៉្យាងដែលកើតនៅក្នុងភ្នែករបស់គាត់។ ទោះបីជាគាត់ឈឺចាប់យ៉ាងណាក៏ដោយ ក៏ឪពុកម្តាយរបស់គាត់មិនមានលទ្ធភាពនាំគាត់ទៅគ្លីនិចនោះទេ ជាហេតុនាំឱ្យជំងឺនោះរាលដាលដល់ភ្នែកម្ខាងទៀត។ ស្ថានភាពរបស់លោកអង ខូកាន់តែធ្ងន់ធ្ងរទៅៗ រហូតដល់គាត់បាត់បង់ភ្នែកទាំង២របស់គាត់ នៅពេលដែលគាត់ធំដឹងក្តី។ គាត់ក៏បានឈប់រៀន បន្ទាប់ពីចប់ថ្នាក់ទី៧ផងដែរ។ ជាមួយនឹងអារម្មណ៍រវើរវាយ និងបាក់ទឹកចិត្ត លោកអង ខូគិតមិនឃើញទាំងអស់ក្រៅពីភាពងងឹងសូន្យសុងនៅមុខគាត់។ គាត់បានគិតចង់ធ្វើអត្តឃាតខ្លួនគាត់ ដោយសារតែអស់សង្ឃឹមពេក។ យូរៗទៅ គោលគំនិតទាំងនេះបានដក់ជាប់នៅក្នុងចិត្តរបស់គាត់ រហូតដល់គាត់ចង់បញ្ចប់ការឈឺចាប់របស់គាត់ ដោយការសម្លាប់ខ្លួន។ ប៉ុន្តែ ការប៉ុនប៉ងរបស់គាត់បានបរាជ័យវិញ។ ថ្ងៃមួយ នៅពេលដែលលោកអង ខូមានអាយុជិត៣០ឆ្នាំ នោះមានគ្រីស្ទានផ្សាយដំណឹងល្អម្នាក់ចូលមកក្នុងភូមិរបស់គាត់ រួចចាប់ផ្តើមប្រាប់អ្នកភូមិអំពីព្រះយេស៊ូវ។ ជាលទ្ធផលឆ្លើយតបទៅនឹងសារនៃអ្នកអធិប្បាយម្នាក់នេះ លោកអង ខូ និងក្រុមគ្រួសាររបស់គាត់បានជ្រមុជទឹកចូលជាសមាជិកក្រុមជំនុំ។ ដោយសារតែលោកអង ខូមិនអាចអានសៀវភៅអំពីព្រះយេស៊ូវបាន នោះគាត់បានបែរមករកកម្មវិធីផ្សាយដំណឹងល្អជាសំឡេងវិញ។ ការស្វែងរកកម្មវិធីនេះបាននាំគាត់ឱ្យរកឃើញប៉ុស្តិ៍វិទ្យុអាត់វេនទីស្ទពិភពលោក (AWR)។ លោកអង ខូបាននិយាយថា «គ្រាន់តែបើកប៉ុស្តិ៍នេះភ្លាម ខ្ញុំបានចាប់អារម្មណ៍ភ្លាម ពីព្រោះមានតែប៉ុស្តិ៍នេះមួយគត់ដែលអាចជួយដល់ខ្ញុំបាន នៅពេលនោះ ខ្ញុំបានទាញក្រដាសមកកត់ទុកពីកាលវិភាគចាក់ផ្សាយ ព្រមទាំងបានស្តាប់ប៉ុស្តិ៍នេះជារៀងរាល់ថ្ងៃផងដែរ ហើយខ្ញុំក៏នៅតែបន្តស្តាប់រហូតមកដល់សព្វថ្ងៃនេះផងដែរ ពីមុន ខ្ញុំបានដឹងថា ព្រះជាអ្នកណានោះឡើយ ប៉ុន្តែ ឥឡូវនេះ ខ្ញុំបានស្គាល់ទ្រង់វិញ ដូច្នេះហើយ ខ្ញុំសូមថ្លែងអំណរគុណដល់ប៉ុស្តិ៍វិទ្យុអាត់វេនទីស្ទពិភពលោក»។ នៅពេលដែលចំណេះរបស់គាត់បានរីកចម្រើនឡើង លោកអង ខូបានសម្រេចចិត្តថា គាត់គួរតែចែករំលែកនូវអ្វីដែលគាត់កំពុងតែស្តាប់នោះ ដើម្បីឱ្យគាត់បានកោះហៅអ្នកជិតខាងមកបង្កើតជាក្រុមតូចមួយ។ គាត់ថែមទាំងបានចាប់ផ្តើមផ្តោតទៅលើកម្មវិធីវិទ្យុ តាមដែលគាត់អាចធ្វើទៅបាន ដើម្បីប្រមូលព័ត៌មានទាំងអស់។ ជាមួយនឹងមធ្យោបាយដ៏ងាយស្រួលនេះ លោកអង ខូបានក្លាយមកជាអ្នកអធិប្បាយដ៏មានប្រជាប្រិយ និងជាអ្នកដឹកនាំដែលក្រុមជំនុំគោរពឱ្យតម្លៃផងដែរ។ គាត់បានបង្កើតក្រុមចុះជួយសហគមន៍ ដែលមានឈ្មោះថា អង្គការនៃជនពិការ ហ្គោលដេន អ៊ីហ្គល់ (Golden Eagle Handicap Foundation) ដែលជួយដល់អ្នកខ្វះខាតដែលរស់នៅក្នុងសហគមន៍ និងនៅជុំវិញសហគម៍។ លោកអង ខូបាននិយាយទៀតថា «ខ្ញុំពិតជាសប្បាយចិត្តណាស់ ដែលបានស្គាល់ព្រះ និងសេចក្តីពិតនៃថ្ងៃសប្បាតហ៍នេះ បើសិនជាខ្ញុំមិនបានស្តាប់សារនៃវិទ្យុនៅពេលនោះទេ ជីវិតរបស់ខ្ញុំមិនដឹងថាទៅជាយ៉ាងណាឡើយ។

**សេចក្តីអធិស្ឋាន៖ តង្វាយនៅក្នុងថ្ងៃសប្បាតហ៍នេះគឺសម្រាប់វិទ្យុអាត់វេនទីស្ទពិភពលោក។ បច្ចុប្បន្ននេះ ប៉ុស្តិ៍ អេដាប់ប៊ិលយូអរ (AWR) កំពុងតែចាក់ផ្សាយជាង១០០ភាសាហើយ។ តង្វាយរបស់លោកអ្នកនឹងជួយពង្រីក និងគាំទ្រកិច្ចការផ្សាយដំណឹងល្អនេះ ដូច្នេះហើយ សូមឱ្យលោកអ្នកបានអធិស្ឋានសម្រាប់ព័ន្ធកិច្ចបម្រើព្រះ ដោយរួមចំណែកតាមរយៈតង្វាយទៀងទាត់របស់លោកអ្នកចុះ។**

# តង្វាយនៃការលះបង់

**ខគម្ពីរយ៉ូហាន ៣:១៦ បានចែងថា «ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ» (យ៉ូហាន ៣:១៦)។**

នៅក្នុងឆ្នាំ១៨៥៧ លោកដាវីឌ លីវស្តូន (David Livingstone) ត្រូវបានអញ្ជើញឱ្យចូលរួមចំណែកនៅក្នុងការផ្តល់អនុសាសន៍ដល់និស្សិតនៅឯសាកលវិទ្យាល័យខេមព្រីចនៅក្នុងប្រទេសអង់គ្លេស។ គាត់បានបន្សល់ទុកជីវិតដ៏រុងរឿងនៅក្នុងប្រទេសអឺរ៉ុប មកបន្ទាបខ្លួនផ្សាយដំណឹងល្អនៅក្នុងទ្វីបអាហ្វ្រិក។ នៅពេលដែលគាត់ឈរនៅពីមុខសិស្ស គាត់គ្រាន់តែជាបុរសស្គមស្គាំងម្នាក់ ដែលបានសន្លប់៣ដងដោយជំងឺគ្រុនក្តៅនៅអាហ្វ្រិកដ៏សាហាវមួយ ហើយគាត់ក៏បានរ៉ាំរ៉ៃស្លែងនឹងដៃម្ខាង បន្ទាប់ពីគាត់បានជួបប្រទះជាមួយនឹងសត្វតោផងដែរ។ អ្នកបម្រើដ៏បន្ទាបខ្លួនម្នាក់នេះត្រូវបានគេចាត់ទុកជាវីរៈបុរសម្នាក់នៅទូទាំងប្រទេសអង់គ្លេស។ ប៉ុន្តែ ឥឡូវនេះ នៅមុខសិស្សដែលខំផ្ទៀងស្តាប់គាត់ គាត់បែរជានិយាយពាក្យដូចខាងក្រោមនេះវិញថា៖

មនុស្សបាននិយាយអំពីការលះបង់ ដែលខ្ញុំបានចំណាយពេលនៅក្នុងប្រទេសអាហ្វ្រិកសឹងតែមួយជីវិតរបស់ខ្ញុំទៅហើយ។ តើសកម្មភាពដែលគ្រាន់តែសងមួយចំណែកតូចទៅក្នុងបំណុលដ៏ធំ ដែលយើងមិនអាចនឹងសងបាននោះ អាចហៅថាជាការលះបង់ដែរឬទេ? តើសកម្មភាពបែបនេះគឺជាការលះបង់ដែលនាំបានផ្តល់នូវរង្វាន់ដ៏ល្អប្រពៃ ដែលជាសកម្មភាពសុខភាព ឆន្ទះនៅក្នុងការធ្វើកិច្ចការល្អ សន្តិភាពផ្លូវចិត្ត និងសេចក្តីសង្ឃឹមដ៏ភ្លឺស្វាងនៃជោគវាសនាដ៏រុងរឿងនាពេលខាងមុខដែរឬទេ? ជាមួយនឹងពាក្យសម្តីដែលមានទស្សន និងគោលគំនិតបែបនេះ ខ្ញុំមិនដែលបានលះបង់ម្តងណាឡើយ។ តែយើងគួរតែបំភ្លេចទស្សន និងគោលគំនិតបែបនេះ នៅពេលដែលយើងគិតដល់ការលះបង់ដ៏ធំធេងដែលព្រះយេស៊ូវបានធ្វើសម្រាប់យើង ដោយទ្រង់បានចាកចេញពីបល្ល័ង្កដ៏ខ្ពង់ខ្ពស់របស់ព្រះវរបិតាទ្រង់មកសុគតជំនួសយើង។

ពាក្យពេចន៍បែបនេះបានរំឭកយើងថា តង្វាយនៃការលះបង់ដ៏ពិតប្រាកដមានប្រភពមកពីភ្នំកាល់វ៉ារី។ ជាការពិតណាស់ អ្វីគ្រប់យ៉ាងដែលយើងបានថ្វាយដល់បេសកកម្មរបស់ព្រះ គឺតិចជាងអ្វីដែលយើងទទួលបានពីអំណោយទាននៃឈើឆ្កាងរបស់ព្រះគ្រីស្ទ។ ទោះជាយ៉ាងនេះក្តី នៅក្នុងជីវិតរបស់យើង យើងត្រូវបានត្រាស់ហៅឱ្យថ្វាយតង្វាយដល់ព្រះ។ ត្រង់នេះមានន័យថា នៅពេលដែលយើងកំណត់ភាគរយទៅលើតង្វាយទៀងទាត់ (តង្វាយសទ្ធា) ដែលយើងត្រូវថ្វាយ នោះយើងត្រូវតែកំណត់ភាគរយដែលជំរុញឱ្យយើងជឿទុកចិត្តទៅលើព្រះពរ និងការថែទាំរបស់ព្រះ។ នេះគឺជាហេតុផលមួយ ដែលព្រះបានកំណត់ថា ខណៈដែលតង្វាយ១០ហូត១បានមកពី១០ភាគរយនៃប្រាក់ចំណូលរបស់យើង នោះអ្នកថ្វាយបង្គំក៏ត្រូវតែកំណត់ភាគរយនៃតង្វាយសទ្ធារបស់ពួកគេផងដែរ។

អ្នកស្រីអេឡែន ជីវ៉ៃត៍បានមានប្រសាសន៍ថា៖«ជាការពិតណាស់ នៅក្នុងព្រះគម្ពីរ ប្រព័ន្ធតង្វាយ១០ហូត១ និងប្រព័ន្ធតង្វាយសទ្ធានឹងត្រូវបានថ្វាយខុសពីគ្នា ពីព្រោះតង្វាយទាំងនេះត្រូវបានសមាមាត្រជាមួយនឹងប្រាក់ចំណូលទទួលបាន» (ដកស្រង់ពី Counsels on Stewardship, p. 73)។ អ្នកស្រីក៏បានសរសេរបន្ថែមទៀតថា «បើសិនជាអ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះបានបង្កើនសមាមាត្រនៃតង្វាយដែលត្រូវដាក់ថ្វាយទៅក្នុងជង្រុករបស់ព្រះអម្ចាស់ តើពួកគេនឹងមានភាពឆេះឆួលប៉ុន្មានណាហ៎!» (ដកស្រង់ពី Counsels on Stewardship, p. 200។

**សេចក្តីអំពាវនាវ៖ លោកអ្នកគួរតែពិនិត្យមើលប្រាក់ចំណូលរបស់លោកអ្នកឱ្យបានទៀងទាត់ ដោយសួរខ្លួនឯងថា តើភាគរយដែលលោកអ្នកកំពុងតែថ្វាយនោះបានបញ្ជាក់ពីការលះបង់ពិតប្រាកដដែរឬទេ។ នៅពេលនោះ លោកអ្នកនឹងឆ្លើយតបទៅព្រះវិញ ដោយការដឹងគុណចំពោះការលះបង់ដ៏ធំធេងដែលទ្រង់បានធ្វើសម្រាប់យើងនៅលើឈើឆ្កាង។**

# សិស្សដែលបានបង្រៀនគ្រូ

**ខគម្ពីរយ៉ូហានទី១ ២:១៤ បានចែងថា «កម្លោះរាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះមានកម្លាំង ហើយព្រះបន្ទូលក៏ស្ថិតនៅក្នុងអ្នករាល់គ្នា អ្នករាល់គ្នាបានឈ្នះមេកំណាចហើយ»។**

លោកខានបានសម្លឹងមើលលោកប្រ៊ូណូ (Bruno) និងនាងណាតាលា (Natalia) ដោយក្តីងឿងឆ្ងល់ថា ហេតុអ្វីបានជាប្តីប្រពន្ធទាំង២នេះចង់រៀនភាសាគាត់ខ្លាំងម្ល៉េះ? នៅទីបំផុត គាត់បានសួរទៅប្តីប្រពន្ធទាំង២នាក់នោះថា «តើអ្នកទាំង២ជាគ្រីស្ទានមែនទេ?»។ បេសកជនវ័យក្មេងទាំង២នាក់ឆ្លើយទាំងស្ទាក់ស្ទើរ។ ពួកគេទើបតែមកដល់ប្រទេសមជ្ឈិមបូព៌ា ដោយភ្ជាប់មកជាមួយនឹងគម្រោងនៃការតាំងទីលំនៅនៅក្នុងប្រទេសជិតខាង ដែលត្រូវបានហាមឃាត់មិនឱ្យផ្សាយដំណឹងល្អអំពីព្រះយេស៊ូវដោយបើកចំហ។ ប៉ុន្តែ ជាដំបូង ពួកគេត្រូវតែរៀនភាសាដើមជាមុនសិន ម្ល៉ោះហើយ បានជាពួកគេសាកសួរលោកខាន ក្រែងលគាត់អាចបង្រៀនពួកគេបាន។

ក្រោយមក លោកណាតាលាបាននិយាយថា «ពួកយើងមិនហ៊ានឆ្លើយសំណួរនេះឡើយ ប៉ុន្តែពួកយើងក៏មិនអាចលាក់អត្តសញ្ញាណរបស់ពួកយើងបានដែរ»។ ពួកយើងបានឆ្លើយថា «ពួកយើងគឺជាគ្រីស្ទាន» ដោយអធិស្ឋាននៅក្នុងចិត្តឱ្យព្រះជួយធ្វើអន្តរាគមន៍។ ប៉ុន្តែ ប្តីប្រពន្ធទាំង២នាក់មិននឹកស្មានថាលោកខាននឹងឆ្លើយថា «បើគ្រីវិញ ក៏គ្រូធ្វើអ៊ីចឹងដែរ»។ គាត់បានខ្សឹបថា «ពីព្រោះឥឡូវនេះ លោកគ្រូក៏កំពុងតែរៀនព្រះគម្ពីរដែរ»។ លោកប្រ៊ូណូ និងនាងណាតាលាបានសម្លឹងមើលគ្នាទាំងភ្ញាក់ផ្អើល។ នៅយប់នោះ ពួកគេបានអធិស្ឋានសុំឱ្យព្រះប្រទានពរដល់លោកខាន ដោយអនុញ្ញាតឱ្យគាត់យល់ដឹងបន្ថែមអំពីព្រះបន្ទូលរបស់ព្រះ។ នៅក្នុងការសិក្សាព្រះគម្ពីរជាលើកទី២ លោកខានបានធ្វើឱ្យពួកគេភ្ញាក់ផ្អើលម្តងទៀត ដោយបើកយកព្រះគម្ពីរចេញពីកាបូបរបស់គាត់។ នៅក្នុងពេលសិក្សាជាលើកទី២នេះ លោកខានបានសួរនាំលោកប្រ៊ូណូអំពីអ្វីដែលគាត់បានធ្វើនៅក្នុងប្រទេសរបស់គាត់។ លោកប្រ៊ូណូបាននិយាយថា គាត់បានសិក្សាជំនាញផ្នែកទេវវិទ្យា។ បន្ទាប់មក លោកខានបានសួរថា «តើអ្នកមកទីនេះធ្វើអីដែរ?»។ លោកប្រ៊ូណូបានឆ្លើយទាំងស្ទាក់ស្ទើរម្តងទៀតថា គាត់គឺជាប៉ាស្ទ័រ។ លោកខានបានសម្លឹងមើលគាត់ទាំងភ្ញាក់ផ្អើល រួចសួរគាត់ថា «បើអ៊ីចឹងមែន តើអ្នកអាចជួយបង្រៀនព្រះគម្ពីរដល់ខ្ញុំបន្ថែមទៀតបានដែរឬទេ? លោកប្រ៊ូណូបានតបទៅវិញ ទាំងអរព្រះគុណដល់ព្រះដែលបានឆ្លើយតបនឹងការអធិស្ឋានរបស់គាត់ថា «បាទ ខ្ញុំអាចបង្រៀនបងបាន»។

ក្រុមគ្រួសាររបស់លោកខានក៏បានចាប់ផ្តើមសិក្សាព្រះគម្ពីរជាមួយនឹងពួកគេផងដែរ។ គាត់បានចាប់ផ្តើមចូលថ្វាយបង្គំនៅក្នុងព្រះវិហារនៅថ្ងៃសប្បាតហ៍ជាមួយនឹងលោកប្រ៊ូណូ និងនាងណាតាលា។ នៅក្នុងអំឡុងពេលនោះ សេចក្តីអធិប្បាយទាំងអស់ត្រូវបានផ្តោតទៅលើគោលលទ្ធិទាំង២៨នៃគោលជំនឿអាត់វេនទីស្ទ។ លោកខាន និងក្រុមគ្រួសាររបស់គាត់បានចូលរួមកម្មវិធីនោះរាល់ថ្ងៃ។ បន្ទាប់ពីបានសិក្សាជាមួយនឹងលោកប្រ៊ូណូ ហើយនិងនាងណាតាលាអស់រយៈពេលជាច្រើនខែក្រោយមក លោកខានបានសុំឱ្យលោកប្រ៊ូណូជ្រមុជទឹកឱ្យគាត់។

**សេចក្តីអំពាវនាវ៖ លោកប្រ៊ូណូ និងនាងណាតាលាត្រូវបានគេអញ្ជើញឱ្យចូលរួមនៅក្នុងកម្មវិធីគំនិតផ្តួចផ្តើមរបស់សិស្សវ៉ាល់ដេ ដែលជាវិធីសាស្ត្រនៃបេសកកម្មថ្នាក់ដំបូងដែលមានសិស្សអាត់វេនទីស្ទរស់នៅ សិក្សា និងបម្រើការនៅតាមសាកលវិទ្យាល័យមិនជឿព្រះនៅក្នុងប្រទេសដែលស្ថិតនៅក្នុងប៉ែកមជ្ឈិមបូព៌ា និងប៉ែកអាហ្វ្រិកខាងជើងដែលបានកំណត់ឱ្យ។ ការធ្វើតាមគំរូនៃការផ្សាយដំណឹងល្អរបស់ព្រះគ្រីស្ទបានធ្វើឱ្យពួកគេផ្សាភ្ជាប់ជាមួយនឹងអ្នកដទៃ បំពេញតម្រូវការអ្នកដទៃ យកបានទំនុកចិត្តអ្នកដទៃ ព្រមទាំងបានអញ្ជើញពួកគេឱ្យដើរតាមព្រះយេស៊ូវ នៅពេលដែលមានឱកាសល្អផងដែរ។ តង្វាយនៃបេសកកម្មបានជួយគាំទ្រដល់ព័ន្ធកិច្ចនៃក្រុមជំនុំអាត់វេនទីស្ទនៅក្នុងប៉ែកមជ្ឈិមបូព៌ា និងប៉ែកអាហ្វ្រិកខាងជើង។ សូមអរគុណចំពោះតង្វាយរបស់លោកអ្នក។**

# ចូរទៅឱ្យបានគ្រប់ទីកន្លែង

**ខគម្ពីរយ៉ូហាន ៣:១៦ បានចែងថា «ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ»។**

មិនមែនមនុស្សទាំងអស់សុទ្ធតែបានទទួលព្រះគុណរបស់ព្រះ ឬត្រូវបានព្រះរើសទុកជាមុននោះឡើយ។ ដ្បិតព្រះស្រឡាញ់មនុស្សលោកទាំងអស់ដោយគ្មានលក្ខខណ្ឌ។ នៅពេលដែលទ្រង់ក្រឡេកមើលភពផែនដីនេះ ជម្រករបស់វាទាំងអស់គឺជាកម្មវត្ថុនៃព្រះគុណ និងការលើកលែងទោសរបស់ព្រះ។ ចក្ខុវិស័យនៃការប្រោសលោះត្រូវបានផ្ដល់ឱ្យមនុស្សគ្រប់គ្នា ហើយព្រះគុណរបស់ទ្រង់ក៏ត្រូវបានផ្សាយដល់មនុស្សលោកគ្រប់គ្នានៅលើផែនដីនេះផងដែរ។ ទោះជាមនុស្សលោកធ្វើអំពើបាបយ៉ាងក៏ដោយ ក៏សេចក្ដីស្រឡាញ់របស់ព្រះនៅតែអាចឈោងចាប់ពួកគេបាន។ នៅពេលដែលព្រះគ្រីស្ទត្រូវបានគេព្យួរនៅលើឈើឆ្កាង ទ្រង់បានគិតអំពីការសង្គ្រោះមនុស្សលោកទាំងអស់។ ទ្រង់បានយកព្រះអង្គទ្រង់ទុកជាតង្វាយនៃសេចក្ដីសង្គ្រោះ (អេភេសូរ ៥:២) ហើយការលះបង់របស់ទ្រង់នេះមានឥទ្ធិពលដល់មនុស្សនៅទូទាំងពិភពលោក។ ព្រះមានមនុស្សរបស់ទ្រង់នៅគ្រប់ទីកន្លែង ទ្រង់មានសារសម្រាប់ពិភពលោកទាំងមូល ហើយទ្រង់ក៏មានព័ន្ធកិច្ចសម្រាប់ពិភពលោកទាំងមូលផងដែរ។ ដ្បិតទ្រង់បានប្រទានព្រះរាជបុត្រារបស់ទ្រង់មកធ្វើជាតង្វាយនៃសេចក្ដីសង្គ្រោះដែលត្រូវផ្សាយទៅទូទាំងពិភពលោក។ ទន្ទឹមគ្នានេះ តង្វាយ១០ហូត១ និងតង្វាយសទ្ធាត្រូវបានថ្វាយទៅព្រះអម្ចាស់ សម្រាប់គោលបំណងទូទាំងពិភពលោក។ ដើម្បីឱ្យតង្វាយ១០ហូត១ និងតង្វាយសទ្ធាបានបំពេញបេសកកម្មនៃការចែកចាយដំណឹងល្អនៅជុំវិញពិភពលោកនេះ ពួកគេមិនត្រូវប្រើតែសម្រាប់ព្រះវិហារតំបន់របស់ពួកគេនោះទេ ប៉ុន្តែ ពួកគេគួរតែប្រើសម្រាប់ពិភពលោកទាំងមូលវិញ។ អ្នកស្រីអេឡែន ជីវ៉ៃត៍បានមានប្រសាសន៍ថា៖ «ថវិការបស់ព្រះមិនមែន ប្រើសម្រាប់តែបញ្ហានៅក្បែរលោកអ្នកនោះទេ ប៉ុន្តែ ថវិការបស់ទ្រង់ក៏ផ្ដល់ឱ្យប្រទេសឆ្ងាយៗ រួមទាំង កោះនៅលើសមុទ្រផងដែរ។ ប្រសិនបើរាស្ត្ររបស់ទ្រង់មិនបានចូលរួមនៅក្នុងកិច្ចការនេះទេ នោះព្រះនឹងដកហូតអំណាចដែលមិនសមស្របចេញពីយើងជាមិនខាន»។ (ដកស្រង់ពី Testimonies for the Church, vol. 7, p. 215)

តង្វាយ១០ហូត១ និងតង្វាយសទ្ធាគឺជាផ្នែកមួយដែលព្រះបានរៀបចំ ដើម្បីបន្តព័ន្ធកិច្ចនៃសេចក្ដីសង្គ្រោះតទៅមុខទៀត។ ពួកគេត្រូវតែហ៊ុំព័ទ្ធផែនដី ដើម្បីឱ្យព្រះវិហារបានសម្រេចគោលដៅដែលព្រះបានកំណត់ទុក។ តង្វាយនៃសេចក្ដីសន្យាដ៏ស្មោះត្រង់របស់យើង ដែលបានដាក់ថ្វាយជាប្រចាំ និងជាប្រព័ន្ធដូចជាតង្វាយ១០ហូត១ និងដែលត្រូវបានចែកចាយដូចជាអ្វីដែលគម្រោងតង្វាយរួមបានណែនាំមក បាននាំឱ្យមនុស្សដែលរស់នៅតាមភូមិនៅលើភ្នំ និងតាមទីក្រុងធំៗបានស្គាល់ព្រះយេស៊ូវ។ គម្រោងតង្វាយរួមត្រូវបានបង្កើតឡើង ដោយតង្វាយនៃសេចក្ដីសន្យារបស់លោកអ្នក៥០ទៅ៦០%គួរតែយកទៅជួយដល់កិច្ចការបេសកកម្មនៅក្នុងព្រះវិហារនៅតាមតំបន់របស់លោកអ្នក ហើយ២០ទៅ៣០%ទៀត គួរតែយកទៅជួយដល់បេសកជននៅក្នុងមិសិនរបស់លោកអ្នក ហើយ២០%ទៀត គួរតែបញ្ជូលមកក្នុងថវិកានៃបេសកម្មពិភពលោក ដែលជួយគាំទ្រដល់បេសកជននៅឯនាយសមុទ្រ ហើយជួយដល់បេសកកម្ម កម្មវិធី និងគម្រោងផ្សេងៗ ព្រមទាំងជួយដល់វិទ្យាស្ថានដែលបានផ្ដោតទៅលើការរៀបចំបេសកកម្មផ្សេងៗបន្ថែមទៀតផងដែរ។

**សេចក្ដីអំពាវនាវ៖ ចូរឱ្យយើងបានថ្វាយតង្វាយរបស់យើងឱ្យអស់ពីចិត្តចុះ ដើម្បីឱ្យយើងអាចបញ្ចប់កិច្ចការបម្រើព្រះ និងដើម្បីឱ្យយើងបានជួបគ្នាម្ដងទៀតនៅឯនគរស្ថានសួគ៌ផងដែរ។**